វិទ្យាល័យ ញ៉ឹម វណ្ណដា ពារាំង

2nd

# គណិតវិទ្យា

ថ្នាក់ទី ១០ ថ្នាក់ទី ១១ ថ្នាក់ទី ១២

## សម្រាយបញ្ជាក់

### រូបមន្ត ទ្រឹស្តីបទ លក្ខណៈ

រៀបរៀងដោយ : គរុនិស្សិត ច្រើស ដារ៉ា

www.facebook.com/7khmer
fb : Entertainment And Knowledge

www.facebook.com/7khmer
fb : Entertainment  And Knowledge

# អារម្ភកថា

សួស្តី ! លោកគ្រូ-អ្នកគ្រូ ប្អូនៗសិស្សានុសិស្ស មិត្តអ្នកសិក្សាជាទីស្រឡាញ់ រាប់អាន ។ សៀវភៅគណិតវិទ្យា «**សម្រាយបញ្ជាក់ រូបមន្ត ទ្រឹស្តីបទ លក្ខណៈ**» ដែលលោកអ្នកកំពុងតែកាន់ក្នុងដៃនេះ គឺជាសៀវភៅថ្មីមួយ ដែលបង្កើតឡើងដើម្បីធ្វើការស្រាយបញ្ជាក់ រូបមន្ត ទ្រឹស្តីបទ និងលក្ខណៈផ្សេងៗនៃមេរៀនគណិតវិទ្យា ។ ជាការពិតមានរូបមន្ត ឬទ្រឹស្តីបទ ឬលក្ខណៈមួយចំនួន មានការស្រាយបញ្ជាក់ក្នុងសៀវភៅពុម្ពរបស់ក្រសួងអប់រំ យុវជន និងកីឡា រួចហើយ ក៏ប៉ុន្តែនៅមាន រូបមន្ត ឬទ្រឹស្តីបទ ឬលក្ខណៈមួយចំនួនធំទៀត ដែលអ្នកសិក្សាជួបប្រទះ ពុំទាន់មានការស្រាយបញ្ជាក់ ចេះតែថាតាមគេ ធ្វើតាមគេតៗគ្នា មិនដឹងពីមូលហេតុ ពេលខ្លះយើងចង់ដឹងពីមូលហេតុដែរ តែមិនដឹងទៅរកឯណា ។ ម្យ៉ាងទៀត ការស្រាយបញ្ជាក់ដែលមានរួចហើយនោះ គឺមានការលំបាកក្នុងការអានឱ្យងាយយល់ ព្រោះគេសរសេរជាអត្ថបទបន្តគ្នាដោយសារក្រសួងមានការកំណត់ចំនួនទំព័រ ។ ហើយជាពិសេសទៅទៀតនោះ ពេលខ្លះយើងយល់ យើងចេះពីការស្រាយបញ្ជាក់ រូបមន្ត ឬទ្រឹស្តីបទ ឬលក្ខណៈទាំងនោះ តែក្រោយមក យើងភ្លេចខ្លះ ឬភ្លេចទាំងស្រុង ដោយសារយើងខានជួបយូរ មិនដែលបានរំលឹក ឬរវល់ការងារផ្សេងៗច្រើនពេក នេះវាជារឿងធម្មតារបស់មនុស្សគ្រប់រូបទៅហើយ «តើនរណាមួយដែលថា មិនចេះភ្លេច ? មនុស្ស មិនមែនម៉ាស៊ីន !!! » ។

ហេតុនេះ ដើម្បីជួយសម្រួលដល់អ្នកសិក្សា ដែលចង់ដឹង ចង់យល់ ចង់ចេះ ពីមូលហេតុឫសគល់ នៃរូបមន្ត ទ្រឹស្តីបទ និងលក្ខណៈផ្សេងៗនៃមេរៀនគណិតវិទ្យា ទើបខ្ញុំបានរៀបរៀងបង្កើតសៀវភៅនេះឡើង សរសេរបែបជាអត្ថបទពន្យល់ មានបញ្ជាក់មូលហេតុច្បាស់លាស់ មានច្រើនរបៀប ។ អ្នកត្រូវដឹងថា ក្នុងមេរៀនមួយចំនួនមាន រូបមន្ត ឬទ្រឹស្តីបទ ឬលក្ខណៈខ្លះ ដាក់យកសិន ព្រោះវិធីនៃការស្រាយបញ្ជាក់លំហាត់នោះរៀនមិនទាន់ដល់ ។

ដូចដែលបានបញ្ជាក់ក្នុងអារម្ភកថានៃការបោះពុម្ពលើកទី១ ថា ខ្ញុំនឹងស្រាយបញ្ជាក់ថ្នាក់ទី៧ ទី៨ ទី៩ និងទី១០ ជាបន្តបន្ទាប់តាមរយៈ ការធ្វើឱ្យទាន់សម័យ (Update) ក្នុងពេលបោះពុម្ពលើកក្រោយ ។ ដូចនេះ ក្នុងការបោះពុម្ពលើកទី ២ នេះ មានការស្រាយបញ្ជាក់ រូបមន្ត ឬទ្រឹស្តីបទ ឬលក្ខណៈ ថ្នាក់ទី១០ ទី១១ និងទី១២ ។ សូមរង់ចាំការបោះពុម្ពលើកក្រោយៗ ដែលមានការស្រាយបញ្ជាក់រូបមន្ត ឬទ្រឹស្តីបទ ឬលក្ខណៈ នៃថ្នាក់តូចជាងនេះ និងការស្រាយបញ្ជាក់លើលំហាត់គណិតវិទ្យាផ្សេងៗទៀត ដែលគ្មានក្នុងកម្មវិធីសិក្សារបស់ក្រសួង ដោយលោកអ្នកគ្រាន់តែមើលក្របកែងខាងលើមានដាក់ថា $2^{nd}$ , $3^{rd}$ , $4^{th}$ , ... ។

ខ្ញុំបាទសូមអភ័យទោសចំពោះកំហុសអចេតនាទាំងឡាយ ដែលមាននៅក្នុងសៀវភៅនេះ ខ្ញុំបាទនឹងទទួលយកការរិះគន់ ឬការផ្តល់ជាយោបល់ ឬការផ្តល់ជាគំនិតបកស្រាយថ្មីៗ ប្លែកៗ ដើម្បីអភិវឌ្ឍ សៀវភៅនេះ ឱ្យកាន់តែប្រសើរ ។

សូមជូនពរដល់អ្នកសិក្សាគ្រប់រូប មានសុខភាពល្អ និងទទួលបានជោគជ័យក្នុងដំណើរជីវិត ។

ព្រៃវែង , ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥

**អ្នករៀបរៀង**

www.facebook.com/7khmer
fb : Entertainment And Knowledge

www.facebook.com/7khmer
fb : Entertainment  And Knowledge

# បញ្ជីអត្ថបទ


| | | ចំណងជើងមេរៀន | ទំព័រ |
|---|---|---|---|
| ➢ **ថ្នាក់ទី ១០** | ១. | លំហាត់ និងការស្រាយបញ្ជាក់ តក្កវិទ្យា | 1 |
| | ២. | លំហាត់ និងការស្រាយបញ្ជាក់ សំណុំ | 15 |
| | ៣. | លំហាត់ និងការស្រាយបញ្ជាក់ ចំនួន | 18 |
| | ៤. | លំហាត់ និងការស្រាយបញ្ជាក់ ពហុធា | 25 |
| | ៥. | លំហាត់ និងការស្រាយបញ្ជាក់ សមីការ | 30 |
| | ៦. | លំហាត់ និងការស្រាយបញ្ជាក់ វិសមីការ | 40 |
| | ៧. | លំហាត់ និងការស្រាយបញ្ជាក់ ធរណីមាត្រក្នុងប្លង់ | 48 |
| | ៨. | លំហាត់ និងការស្រាយបញ្ជាក់ អនុគមន៍ | 58 |
| | ៩. | លំហាត់ និងការស្រាយបញ្ជាក់ ត្រីកោណមាត្រ | 63 |
| | ១០. | លំហាត់ និងការស្រាយបញ្ជាក់ ចម្លាស់-បន្សំ | 73 |
| | ១១. | លំហាត់ និងការស្រាយបញ្ជាក់ វ៉ិចទ័រ | 80 |
| | ១២. | លំហាត់ និងការស្រាយបញ្ជាក់ បំលែងរូបក្នុងប្លង់ | 96 |
| | ១៣. | លំហាត់ និងការស្រាយបញ្ជាក់ ធរណីមាត្រក្នុងលំហ | 101 |
| ➢ **ថ្នាក់ទី ១១** | ១. | លំហាត់ និងការស្រាយបញ្ជាក់ ស្វ៊ីត និងស៊េរី | 108 |
| | ២. | លំហាត់ និងការស្រាយបញ្ជាក់ អិចស្ប៉ូណង់ស្យែល | 108 |
| | ៣. | លំហាត់ និងការស្រាយបញ្ជាក់ លោការីត | 125 |
| | ៤. | លំហាត់ និងការស្រាយបញ្ជាក់ ត្រីកោណមាត្រ | 130 |
| | ៥. | លំហាត់ និងការស្រាយបញ្ជាក់ ម៉ាទ្រីស និងដេទែមីណង់ | 151 |
| | ៦. | លំហាត់ និងការស្រាយបញ្ជាក់ បំលែងលីនេអ៊ែ | 154 |
| | ៧. | លំហាត់ និងការស្រាយបញ្ជាក់ ធរណីមាត្រក្នុងលំហ | 157 |
| ➢ **ថ្នាក់ទី ១២** | ១. | លំហាត់ និងការស្រាយបញ្ជាក់ ចំនួនកុំផ្លិច | 171 |
| | ២. | លំហាត់ និងការស្រាយបញ្ជាក់ លីមីត | 182 |
| | ៣. | លំហាត់ និងការស្រាយបញ្ជាក់ ដេរីវេ | 194 |
| | ៤. | លំហាត់ និងការស្រាយបញ្ជាក់ សិក្សាអនុគមន៍ | 213 |
| | ៥. | លំហាត់ និងការស្រាយបញ្ជាក់ អាំងតេក្រាល | 220 |
| | ៦. | លំហាត់ និងការស្រាយបញ្ជាក់ សមីការឌីផេរ៉ង់ស្យែល | 244 |
| | ៧. | លំហាត់ និងការស្រាយបញ្ជាក់ ធរណីមាត្រក្នុងលំហ | 249 |
| | ៨. | លំហាត់ និងការស្រាយបញ្ជាក់ កោនិច | 265 |
| ➢ **សេចក្តីបន្ថែម** | | ការស្រាយបញ្ជាក់អំពីរង្វង់ | 281 |

www.facebook.com/7khmer
fb : Entertainment  And Knowledge

# ការស្រាយបញ្ជាក់លើមេរៀន តក្កវិទ្យា

1. បង្ហាញថា សំណើ $\overline{\overline{p}}$ និងសំណើ $p$ ជាសំណើតែមួយ ។
2. ស្រាយបញ្ជាក់លក្ខណៈដឺម៉ដេន $(\text{De Morgan})$ ៖ $(i)$ $\overline{p\wedge q}=\overline{p}\vee\overline{q}$ និង $(ii)$ $\overline{p\vee q}=\overline{p}\wedge\overline{q}$ ។
3. បង្ហាញថា សំណើ $p\Rightarrow q$ និងសំណើ $\overline{q}\Rightarrow\overline{p}$ មានតម្លៃភាពពិតដូចគ្នា ។
4. បង្ហាញថា $p\Leftrightarrow q=(p\Rightarrow q)\wedge(q\Rightarrow p)$ ។
5. បង្ហាញថា បើ $x$ និង $y$ ជាចំនួនសនិទាន នោះ $x+y$ ជាចំនួនសនិទាន ។
6. បង្ហាញថា បើ $|x|>|y|$ នោះ $x^2>y^2$ ។
7. បង្ហាញថា បើ $x$ និង $y$ ជាចំនួនគត់សេស នោះ $x+y$ ជាចំនួនគត់គូ ។
8. បង្ហាញថា បើ $x$ និង $y$ ជាចំនួនគត់សេស នោះ $xy$ ក៏ជាចំនួនគត់សេសដែរ ។
9. បង្ហាញថា បើ $n^2$ ជាចំនួនគត់គូ នោះ $n$ ក៏ជាចំនួនគត់គូ ។
10. បង្ហាញថា បើ $mn$ មិនមែនជាពហុគុណនៃ $3$ នោះ $m$ និង $n$ ក៏មិនមែនជាពហុគុណនៃ $3$ ដែរ ។
11. បង្ហាញថា បើមុំឆ្លាស់ក្នុងពីរនៃបន្ទាត់ពីរជាមុំស្មើគ្នា នោះបន្ទាត់ទាំងពីរនោះស្របគ្នា ។
12. បង្ហាញថា $\sqrt{2}$ ជាចំនួនអសនិទាន ។
13. បង្ហាញថា $\sqrt{5}$ ជាចំនួនអសនិទាន ។
14. បង្ហាញថា $\sqrt{3}$ ជាចំនួនអសនិទាន ។
15. បង្ហាញថា $\sqrt[4]{2}$ ជាចំនួនអសនិទាន ។
16. បង្ហាញថា $\sqrt{p}$ ជាចំនួនអសនិទាន ចំពោះគ្រប់ចំនួនបឋម $p$ ។
17. បង្ហាញថា $1+\sqrt{2}$ ជាចំនួនអសនិទាន ។
18. បង្ហាញថា $\sqrt{2}+\sqrt{3}$ ជាចំនួនអសនិទាន ។
19. បង្ហាញថា $x^2+5x+6=0$ លុះត្រាតែ $x=-2$ ឬ $x=-3$ ។
20. បង្ហាញថា $x^3-4x=0$ លុះត្រាតែ $x=0$ ឬ $x=-2$ ឬ $x=2$ ។
21. បង្ហាញថា $x^2+y^2=0$ លុះត្រាតែ $x=0$ និង $y=0$ ។
22. បង្ហាញថា អង្គការអាស៊ានមានសមាជិកមកពីគ្រប់ប្រទេសក្នុងទ្វីបអាស៊ី ជាសំណើមិនពិត ។
23. បង្ហាញថា ចំនួនបឋមជាចំនួនគត់សេស ជាសំណើមិនពិត ។
24. បង្ហាញថា បើ $p$ និង $q$ ជាចំនួនបឋម ហើយ $n=p^2+q^2$ នោះ $n$ ជាចំនួនបឋម ជាសំណើមិនពិត ។
25. បង្ហាញថា បើ $a>b$ នោះ $a^2>b^2$ ចំពោះគ្រប់ចំនួនពិត $a$ និង $b$ ជាសំណើមិនពិត ។
26. បង្ហាញថា បើ $x$ និង $y$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាន និង $xy$ ជាចំនួនគត់សេស នោះ $x$ និង $y$ ក៏ជាចំនួនគត់សេសដែរ ។
27. បង្ហាញថា បើ $x(x-2)<0$ នោះ $0<x<2$ ។
28. បង្ហាញថា ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n$ បើ $n^2>25$ នោះ $n>5$ ។
29. បង្ហាញថា $x+\dfrac{1}{x}>2$ ចំពោះគ្រប់ $x>1$ ។
30. បង្ហាញថា គ្មានចំនួនគត់រ៉ឺឡាទីប $p$ និង $q$ ដែល $\dfrac{p^2}{q^2}=2$ ។

# ការស្រាយបញ្ជាក់លើមេរៀន តក្កវិទ្យា

1. **បង្ហាញថា សំណើ $\overline{\overline{p}}$ និងសំណើ $p$ ជាសំណើតែមួយ**

គេមាន សំណើ $p$ និងសំណើ $\overline{p}$ មានតម្លៃភាពពិតខុសគ្នា

គេសង់បានតារាងតម្លៃភាពពិត នៃសំណើ $p$ , $\overline{p}$ , $\overline{\overline{p}}$ បានដូចខាងក្រោម

| $p$ | $\overline{p}$ | $\overline{\overline{p}}$ |
|---|---|---|
| 1 | 0 | 1 |
| 0 | 1 | 0 |

តាមតារាងតម្លៃភាពពិតឃើញថា សំណើ $p$ និងសំណើ $\overline{\overline{p}}$ មានតម្លៃភាពពិតដូចគ្នា

នាំឱ្យ សំណើ $\overline{\overline{p}}$ និងសំណើ $p$ ជាសំណើតែមួយ

ដូចនេះ: សំណើ $\overline{\overline{p}}$ និងសំណើ $p$ ជាសំណើតែមួយ ត្រូវបានបង្ហាញ ។

2. **ស្រាយបញ្ជាក់លក្ខណៈដឺម៉ង់ហ្គង់** (De Morgan) ៖

**➢ស្រាយបញ្ជាក់ថា** $(i)$ $\overline{p \wedge q} = \overline{p} \vee \overline{q}$

គេនឹងប្រើតារាងតម្លៃភាពពិត ដើម្បីបង្ហាញថា $\overline{p \wedge q} = \overline{p} \vee \overline{q}$

| $p$ | $q$ | $\overline{p}$ | $\overline{q}$ | $p \wedge q$ | $\overline{p \wedge q}$ | $\overline{p} \vee \overline{q}$ |
|---|---|---|---|---|---|---|
| 1 | 1 | 0 | 0 | 1 | 0 | 0 |
| 1 | 0 | 0 | 1 | 0 | 1 | 1 |
| 0 | 1 | 1 | 0 | 0 | 1 | 1 |
| 0 | 0 | 1 | 1 | 0 | 1 | 1 |

តាមតារាងតម្លៃភាពពិតឃើញថា សំណើ $\overline{p \wedge q}$ និងសំណើ $\overline{p} \vee \overline{q}$ មានតម្លៃភាពពិតដូចគ្នា

នាំឱ្យ គេបានសំណើ $\overline{p \wedge q} = \overline{p} \vee \overline{q}$

ដូចនេះ: លក្ខណៈដឺម៉ង់ហ្គង់ $\overline{p \wedge q} = \overline{p} \vee \overline{q}$ ត្រូវបានបង្ហាញ ។

**➢ស្រាយបញ្ជាក់ថា** $(ii)$ $\overline{p \vee q} = \overline{p} \wedge \overline{q}$

គេនឹងប្រើតារាងតម្លៃភាពពិត ដើម្បីបង្ហាញថា $\overline{p \wedge q} = \overline{p} \vee \overline{q}$

| $p$ | $q$ | $\overline{p}$ | $\overline{q}$ | $p \wedge q$ | $\overline{p \wedge q}$ | $\overline{p} \vee \overline{q}$ |
|---|---|---|---|---|---|---|
| 1 | 1 | 0 | 0 | 1 | 0 | 0 |
| 1 | 0 | 0 | 1 | 0 | 1 | 1 |
| 0 | 1 | 1 | 0 | 0 | 1 | 1 |
| 0 | 0 | 1 | 1 | 0 | 1 | 1 |

តាមតារាងតម្លៃភាពពិតឃើញថា សំណើ $\overline{p \wedge q}$ និងសំណើ $\overline{p} \vee \overline{q}$ មានតម្លៃភាពពិតដូចគ្នា

នាំឱ្យ គេបានសំណើ $\overline{p \wedge q} = \overline{p} \vee \overline{q}$

ដូចនេះ: លក្ខណៈដឺម៉ង់ហ្គង់ $\overline{p \wedge q} = \overline{p} \vee \overline{q}$ ត្រូវបានបង្ហាញ ។

3. **បង្ហាញថា សំណើ $p \Rightarrow q$ និងសំណើ $\bar{q} \Rightarrow \bar{p}$ មានតម្លៃភាពពិតដូចគ្នា**

គេសង់តារាងតម្លៃភាពពិនៃសំណើ $p \Rightarrow q$ និងសំណើ $\bar{q} \Rightarrow \bar{p}$ បានដូចខាងក្រោម ៖

| $p$ | $q$ | $\bar{p}$ | $\bar{q}$ | $p \Rightarrow q$ | $\bar{q} \Rightarrow \bar{p}$ |
|---|---|---|---|---|---|
| 1 | 1 | 0 | 0 | 1 | 1 |
| 1 | 0 | 0 | 1 | 0 | 0 |
| 0 | 1 | 1 | 0 | 1 | 1 |
| 0 | 0 | 1 | 1 | 1 | 1 |

តាមតារាងតម្លៃភាពពិតឃើញថា សំណើ $p \Rightarrow q$ និងសំណើ $\bar{q} \Rightarrow \bar{p}$ មានតម្លៃភាពពិតដូចគ្នា

ដូចនេះ: សំណើ $p \Rightarrow q$ និងសំណើ $\bar{q} \Rightarrow \bar{p}$ មានតម្លៃភាពពិតដូចគ្នា ត្រូវបានបង្ហាញ ។

4. **បង្ហាញថា $p \Leftrightarrow q = (p \Rightarrow q) \wedge (q \Rightarrow p)$**

គេសង់តារាងតម្លៃភាពពិនៃសំណើ $(p \Rightarrow q) \wedge (q \Rightarrow p)$ និងសំណើ $p \Leftrightarrow q$ បានដូចខាងក្រោម ៖

| $p$ | $q$ | $p \Rightarrow q$ | $q \Rightarrow p$ | $(p \Rightarrow q) \wedge (q \Rightarrow p)$ | $p \Leftrightarrow q$ |
|---|---|---|---|---|---|
| 1 | 1 | 1 | 1 | 1 | 1 |
| 1 | 0 | 0 | 1 | 0 | 0 |
| 0 | 1 | 1 | 0 | 0 | 0 |
| 0 | 0 | 1 | 1 | 1 | 1 |

តាមតារាងតម្លៃភាពពិតឃើញថា សំណើ $(p \Rightarrow q) \wedge (q \Rightarrow p)$ និងសំណើ $p \Leftrightarrow q$ មានតម្លៃភាពពិតដូចគ្នា

ដូចនេះ: $p \Leftrightarrow q = (p \Rightarrow q) \wedge (q \Rightarrow p)$ ត្រូវបានបង្ហាញ ។

5. **បង្ហាញថា បើ $x$ និង $y$ ជាចំនួនសនិទាន នោះ $x + y$ ជាចំនួនសនិទាន**

គេមាន $x$ និង $y$ ជាចំនួនសនិទាន

គេតាង $x = \frac{a}{b}$ និង $y = \frac{c}{d}$ ដែល $a , b , c , d$ ជាចំនួនគត់រ៉ឺឡាទីប និង $b \neq 0 , d \neq 0$

គេបាន $x + y = \frac{a}{b} + \frac{c}{d} = \frac{ad + bc}{bd}$

ដោយ $ad + bc$ និង $bd$ ជាចំនួនគត់រ៉ឺឡាទីប

នាំឱ្យ $x + y = \frac{ad + bc}{bd}$ ជាចំនួនសនិទា ន

ដូចនេះ: បើ $x$ និង $y$ ជាចំនួនសនិទាន នោះ $x + y$ ជាចំនួនសនិទាន ត្រូវបានបង្ហាញ ។

6. **បង្ហាញថា បើ $|x| > |y|$ នោះ $x^2 > y^2$**

គេមាន $|x| \geq 0$ , $|y| \geq 0$ និង $|x| > |y|$ នោះគេបាន $|x|^2 > |y|^2$ (មិនប្តូរទិសដៅ)

តែ $|x|^2 = x^2$ , $|y|^2 = y^2$

គេបាន $|x|^2 > |y|^2$ អាចសរសេរ $x^2 > y^2$

ដូចនេះ: បើ $|x| > |y|$ នោះ $x^2 > y^2$ ត្រូវបានបង្ហាញ ។

**7. បង្ហាញថា បើ $x$ និង $y$ ជាចំនួនគត់សេស នោះ $x+y$ ជាចំនួនគត់គូ**

គេមាន $x$ និង $y$ ជាចំនួនគត់សេស

គេតាងបាន $x=2m+1$ និង $y=2n+1$ ដែល $m$ , $n$ ជាចំនួនគត់

នាំឱ្យ
$$\begin{aligned} x+y &= 2m+1+2n+1 \\ &= 2m+2n+2 \\ &= 2(m+n+1) \\ &= 2k \ , \ k=m+n+1 \end{aligned}$$

ដោយ $x+y=2k$ មានទម្រង់ជាចំនួនគត់គូ នោះ $x+y$ ជាចំនួនគត់គូ

ដូចនេះ **បើ $x$ និង $y$ ជាចំនួនគត់សេស នោះ $x+y$ ជាចំនួនគត់គូ ត្រូវបានបង្ហាញ** ។

**8. បង្ហាញថា បើ $x$ និង $y$ ជាចំនួនគត់សេស នោះ $xy$ ក៏ជាចំនួនគត់សេសដែរ**

គេមាន $x$ និង $y$ ជាចំនួនគត់សេស

គេតាងបាន $x=2m+1$ និង $y=2n+1$ ដែល $m$ , $n$ ជាចំនួនគត់

នាំឱ្យ
$$\begin{aligned} xy &= (2m+1)(2n+1) \\ &= 4mn+2m+2n+1 \\ &= 2(mn+m+n)+1 \\ &= 2k+1 \ , \ k=mn+m+n \end{aligned}$$

ដោយ $xy=2k+1$ មានទម្រង់ជាចំនួនគត់សេស នោះ $xy$ ជាចំនួនគត់សេស

ដូចនេះ **បើ $x$ និង $y$ ជាចំនួនគត់សេស នោះ $xy$ ក៏ជាចំនួនគត់សេសដែរ ត្រូវបានបង្ហាញ** ។

**9. បង្ហាញថា បើ $n^2$ ជាចំនួនគត់គូ នោះ $n$ ក៏ជាចំនួនគត់គូ**

គេនឹងស្រាយតាមសំណើផ្ទុយពីសម្មតិកម្ម ព្រោះគេដឹងថា $p\Rightarrow q$ និង $\overline{q}\Rightarrow\overline{p}$ មានតម្លៃភាពពិតដូចគ្នា (បង្ហាញរួចខាងលើ)

គេតាង $p:\ n^2$ ជាចំនួនគត់គូ

$q:\ n$ ជាចំនួនគត់គូ

នាំឱ្យ $\overline{p}:\ n^2$ ជាចំនួនគត់សេស

$\overline{q}:\ n$ ជាចំនួនគត់សេស

ដោយ $\overline{q}:\ n$ ជាចំនួនគត់សេស នោះ $n=2k+1$ , $k$ ជាចំនួនគត់

នោះ
$$\begin{aligned} n^2 &= (2k+1)^2 \\ &= 4k^2+4k+1 \\ &= 2(2k^2+2k)+1 \\ &= 2m+1 \ , \ m=2k^2+2k \end{aligned}$$

គេបាន $n^2=2m+1$ ជាចំនួនគត់សេស ជាសំណើ $\overline{p}$

ដោយ គេស្រាយបាន $\overline{q}\Rightarrow\overline{p}$ ជាសំណើពិត នោះសំណើ $p\Rightarrow q$ ក៏ជាសំណើពិតដែរ

ដូចនេះ **បើ $n^2$ ជាចំនួនគត់គូ នោះ $n$ ក៏ជាចំនួនគត់គូ ត្រូវបានបង្ហាញ** ។

10. **បង្ហាញថា បើ $mn$ មិនមែនជាពហុគុណនៃ 3 នោះ $m$ និង $n$ ក៏មិនមែនជាពហុគុណនៃ 3 ដែរ**

គេនឹងស្រាយតាមសំណើផ្ទុយពីសម្មតិកម្ម ព្រោះគេដឹងថា $p \Rightarrow q$ និង $\overline{q} \Rightarrow \overline{p}$ មានតម្លៃភាពពិតដូចគ្នា (បង្ហាញរួចខាងលើ)

គេតាង $p:$ $mn$ មិនមែនជាពហុគុណនៃ 3

$q:$ $m$ និង $n$ មិនមែនជាពហុគុណនៃ 3

នាំឱ្យ $\overline{p}:$ $mn$ ជាពហុគុណនៃ 3

$\overline{q}:$ យ៉ាងហោចណាស់មានមួយក្នុងចំណោម $m$ និង $n$ ជាពហុគុណនៃ 3

ចេញពីសំណើ $\overline{q}$ គេនឹងស្រាយរហូតបាន $\overline{p}$ តាមករណីទាំងបីដូចខាងក្រោម ៖

- ករណី $m$ ជាពហុគុណនៃ 3 និង $n$ មិនមែនជាពហុគុណនៃ 3

 គេតាង $m = 3k$

 គេបាន $mn = 3k \cdot n = 3(kn)$ ជាពហុគុណនៃ 3 ជាសំណើ $\overline{p}$

- ករណី $m$ មិនមែនជាពហុគុណនៃ 3 និង $n$ ជាពហុគុណនៃ 3

 គេតាង $n = 3\ell$

 គេបាន $mn = m \cdot 3\ell = 3(m\ell)$ ជាពហុគុណនៃ 3 ជាសំណើ $\overline{p}$

- ករណី $m$ ជាពហុគុណនៃ 3 និង $n$ ជាពហុគុណនៃ 3

 គេតាង $m = 3u$ , $n = 3v$

 គេបាន $mn = 3u \cdot 3v = 3(3uv)$ ជាពហុគុណនៃ 3 ជាសំណើ $\overline{p}$

ឃើញថា គ្រប់ករណីគេបានសំណើ $\overline{q} \Rightarrow \overline{p}$ ជាសំណើពិត នោះសំណើ $p \Rightarrow q$ ក៏ជាសំណើពិតដែរ

ដូចនេះ | បើ $mn$ មិនមែនជាពហុគុណនៃ 3 នោះ $m$ និង $n$ ក៏មិនមែនជាពហុគុណនៃ 3 ដែរ ត្រូវបានបង្ហាញ | ។

11. **បង្ហាញថា បើមុំឆ្លាស់ក្នុងពីរនៃបន្ទាត់ពីរជាមុំស្មើគ្នា នោះបន្ទាត់ទាំងពីរនោះស្របគ្នា**

គេនឹងស្រាយតាមសំណើផ្ទុយពីសម្មតិកម្ម ព្រោះគេដឹងថា $p \Rightarrow q$ និង $\overline{q} \Rightarrow \overline{p}$ មានតម្លៃភាពពិតដូចគ្នា (បង្ហាញរួចខាងលើ)

គេតាង $p:$ មុំឆ្លាស់ក្នុងពីរនៃបន្ទាត់ពីរជាមុំស្មើគ្នា

$q:$ បន្ទាត់ទាំងពីរនោះស្របគ្នា

នាំឱ្យ $\overline{p}:$ មុំឆ្លាស់ក្នុងពីរនៃបន្ទាត់ពីរជាមុំមិនស្មើគ្នា

$\overline{q}:$ បន្ទាត់ទាំងពីរនោះមិនស្របគ្នា

ចេញពីសំណើ $\overline{q}$ គេនឹងស្រាយរហូតបាន $\overline{p}$ ដូចខាងក្រោម ៖

គេមាន $\overline{q}:$ បន្ទាត់ទាំងពីរនោះមិនស្របគ្នា មានន័យថាបន្ទាត់ប្រសព្វគ្នា




តាមផលបូកមុំក្រៅនៃត្រីកោណ គេបាន ៖

$\angle BAP + \angle APB = \angle ABx$ នោះ $\angle ABx > \angle BAP$

គេបាន $\angle ABx \neq \angle BAP$

មានន័យថា មុំឆ្លាស់ក្នុងពីរនៃបន្ទាត់ពីរជាមុំមិនស្មើគ្នា ជាសំណើ $\overline{p}$

នាំឱ្យ $\overline{q} \Rightarrow \overline{p}$ ជាសំណើពិត នោះ $p \Rightarrow q$ ក៏ពិតដែរ

ដូចនេះ | បើមុំឆ្លាស់ក្នុងពីរនៃបន្ទាត់ពីរជាមុំស្មើគ្នា នោះបន្ទាត់ទាំងពីរនោះស្របគ្នា ត្រូវបានបង្ហាញ | ។

12. បង្ហាញថា $\sqrt{2}$ ជាចំនួនអសនិទាន

**>របៀបទី១ តាមប្រភាគសម្រួលមិនបាន**

គេនឹងបង្ហាញថា $\sqrt{2}$ ជាចំនួនអសនិទាន តាមសំណើផ្ទុយពីការពិត គេដឹងថា បើ $\overline{p}$ មិនពិត នោះ $p$ ពិត

គេតាង $p:\sqrt{2}$ ជាចំនួនអសនិទាន នោះ $\overline{p}:\sqrt{2}$ ជាចំនួនសនិទាន

ឧបមាថា $\overline{p}:\sqrt{2}$ ជាចំនួនសនិទាន ជាសំណើពិត

គេបាន $\sqrt{2}=\dfrac{a}{b}$ ជាប្រភាគសម្រួលមិនបាន (ឬ $a$ និង $b$ ជាចំនួនបឋមរវាងគ្នា ឬតួចែករួមធំបំផុតនៃ $a$ និង $b$ ស្មើ 1)

នាំឱ្យ $a^2=2b^2 \quad (1)$

ដោយ $a^2=2b^2$ មានទម្រង់ជាចំនួនគូ នោះ $a^2$ ជាចំនួនគូ នាំឱ្យ $a$ ក៏ជាចំនួនគូដែរ (មើលលំហាត់ 9)

តាងបាន $a=2m$ ដែល $m$ ជាចំនួនគត់

គេបាន $(1)\ :\ (2m)^2=2b^2 \Leftrightarrow 4m^2=2b^2 \Leftrightarrow 2m^2=b^2$

ដោយ $b^2=2m^2$ មានទម្រង់ជាចំនួនគូ នោះ $b^2$ ជាចំនួនគូ នាំឱ្យ $b$ ក៏ជាចំនួនគូដែរ

តាងបាន $b=2n$ ដែល $n$ ជាចំនួនគត់

ឃើញថា $\sqrt{2}=\dfrac{a}{b}=\dfrac{2m}{2n}$ អាចសម្រួលនឹង 2 បាន ផ្ទុយពីការពិត ដែលថា $\sqrt{2}=\dfrac{a}{b}$ ជាប្រភាគសម្រួលមិនបាន

នាំឱ្យ សំណើ $\overline{p}:\sqrt{2}$ ជាចំនួនសនិទាន ជាសំណើមិនពិត មានន័យថា $p:\sqrt{2}$ ជាចំនួនអសនិទាន ជាសំណើពិត

ដូចនេះ: **$\sqrt{2}$ ជាចំនួនអសនិទាន ត្រូវបានបង្ហាញ** ។

**>របៀបទី២ តាមចំនួនកត្តាបឋម**

គេតាង $p:\sqrt{2}$ ជាចំនួនអសនិទាន នោះ $\overline{p}:\sqrt{2}$ ជាចំនួនសនិទាន

ឧបមាថា $\overline{p}:\sqrt{2}$ ជាចំនួនសនិទាន ជាសំណើពិត

គេបាន $\sqrt{2}=\dfrac{a}{b} \Leftrightarrow a^2=2b^2 \quad (1)$

ដោយ ចំនួន $a$ មានកត្តាបឋមតែមួយបែបគត់ តាងដោយ $a=a_1\times a_2\times a_3\times\ldots\times a_m$ មាន $m$ កត្តាបឋម

ដែល $a_1, a_2, a_3, \ldots, a_m$ ជាចំនួនបឋម

នោះ $a^2=(a_1\times a_2\times a_3\times\ldots\times a_m)^2$ មាន $2m$ កត្តា គឺចំនួនគូកត្តា

ហើយ ចំនួន $b$ មានកត្តាបឋមតែមួយបែបគត់ តាងដោយ $b=b_1\times b_2\times b_3\times\ldots\times b_n$ មាន $n$ កត្តាបឋម

ដែល $b_1, b_2, b_3, \ldots, b_n$ ជាចំនួនបឋម

នោះ $b^2=(b_1\times b_2\times b_3\times\ldots\times b_n)^2$ មាន $2n$ កត្តា គឺចំនួនគូកត្តា

នាំឱ្យ $2b^2=2(b_1\times b_2\times b_3\times\ldots\times b_n)^2$ មាន $2n+1$ កត្តា គឺចំនួនសេសកត្តា

តាម $(1)$ ឃើញថា អង្គទីមួយ $a^2$ មានគូកត្តាបឋម ឯអង្គទីពីរ $2b^2$ មានសេសកត្តាបឋម នោះ $a^2$ និង $2b^2$ មានកត្តាបឋមខុសគ្នា

នាំឱ្យ $a^2$ និង $2b^2$ មិនស្មើគ្នា នោះការឧបមាថា $\overline{p}:\sqrt{2}$ ជាចំនួនសនិទាន ជាសំណើមិនពិត

គេបាន $p:\sqrt{2}$ ជាចំនួនអសនិទាន ជាសំណើពិត

ដូចនេះ: **$\sqrt{2}$ ជាចំនួនអសនិទាន ត្រូវបានបង្ហាញ** ។

13. **បង្ហាញថា $\sqrt{5}$ ជាចំនួនអសនិទាន**

គេនឹងបង្ហាញថា $\sqrt{5}$ ជាចំនួនអសនិទាន តាមសំណើផ្ទុយពីការពិត គេដឹងថា បើ $\overline{p}$ មិនពិត នោះ $p$ ពិត

គេតាង $p: \sqrt{5}$ ជាចំនួនអសនិទាន នោះ $\overline{p}: \sqrt{5}$ ជាចំនួនសនិទាន

ឧបមាថា $\overline{p}: \sqrt{5}$ ជាចំនួនសនិទាន ជាសំណើពិត

គេបាន $\sqrt{5} = \dfrac{a}{b} \Leftrightarrow a^2 = 5b^2 \quad (1)$

ដោយ ចំនួន $a$ មានកត្តាបឋមតែមួយបែបគត់ តាងដោយ $a = a_1 \times a_2 \times a_3 \times \ldots \times a_m$ មាន $m$ កត្តាបឋម ដែល $a_1, a_2, a_3, \ldots, a_m$ ជាចំនួនបឋម នោះ $a^2 = (a_1 \times a_2 \times a_3 \times \ldots \times a_m)^2$ មាន $2m$ កត្តា គឺចំនួនគូកត្តា

ហើយ ចំនួន $b$ មានកត្តាបឋមតែមួយបែបគត់ តាងដោយ $b = b_1 \times b_2 \times b_3 \times \ldots \times b_n$ មាន $n$ កត្តាបឋម ដែល $b_1, b_2, b_3, \ldots, b_n$ ជាចំនួនបឋម នោះ $b^2 = (b_1 \times b_2 \times b_3 \times \ldots \times b_n)^2$ មាន $2n$ កត្តា គឺចំនួនគូកត្តា

នាំឱ្យ $5b^2 = 5(b_1 \times b_2 \times b_3 \times \ldots \times b_n)^2$ មាន $2n+1$ កត្តា គឺចំនួនសេសកត្តា

តាម $(1)$ ឃើញថា អង្គទីមួយ $a^2$ មានគូកត្តាបឋម ឯអង្គទីពីរ $5b^2$ មានសេសកត្តាបឋម នោះ $a^2$ និង $5b^2$ មានកត្តាបឋមខុសគ្នា

នាំឱ្យ $a^2$ និង $5b^2$ មិនស្មើគ្នា នោះការឧបមាថា $\overline{p}: \sqrt{5}$ ជាចំនួនសនិទាន ផ្ទុយពីការពិត

គេបាន $p: \sqrt{5}$ ជាចំនួនអសនិទាន ជាសំណើពិត

ដូចនេះ $\boxed{\sqrt{5} \text{ ជាចំនួនអសនិទាន ត្រូវបានបង្ហាញ}}$ ។

14. **បង្ហាញថា $\sqrt{3}$ ជាចំនួនអសនិទាន**

ឧបមាថា $\sqrt{3}$ ជាចំនួនសនិទាន

គេបាន $\sqrt{3} = \dfrac{a}{b} \Leftrightarrow a^2 = 3b^2 \quad (1)$

គេតាង $a = a_1 \times a_2 \times a_3 \times \ldots \times a_m$ មាន $m$ កត្តាបឋម ដែល $a_1, a_2, a_3, \ldots, a_m$ ជាចំនួនបឋម

នោះ $a^2 = (a_1 \times a_2 \times a_3 \times \ldots \times a_m)^2$ មាន $2m$ កត្តាបឋម គឺចំនួនគូកត្តាបឋម

គេតាង $b = b_1 \times b_2 \times b_3 \times \ldots \times b_n$ មាន $n$ កត្តាបឋម ដែល $b_1, b_2, b_3, \ldots, b_n$ ជាចំនួនបឋម

នោះ $b^2 = (b_1 \times b_2 \times b_3 \times \ldots \times b_n)^2$ មាន $2n$ កត្តាបឋម គឺចំនួនគូកត្តាបឋម

នាំឱ្យ $3b^2 = 3(b_1 \times b_2 \times b_3 \times \ldots \times b_n)^2$ មាន $2n+1$ កត្តា គឺចំនួនសេសកត្តាបឋម

តាម $(1)$ ឃើញថា អង្គទីមួយ $a^2$ មានគូកត្តាបឋម ឯអង្គទីពីរ $3b^2$ មានសេសកត្តាបឋម នោះ $a^2$ និង $3b^2$ មានកត្តាបឋមខុសគ្នា

នាំឱ្យ $a^2$ និង $3b^2$ មិនស្មើគ្នា នោះការឧបមាថា $\sqrt{3}$ ជាចំនួនសនិទាន ផ្ទុយពីការពិត

គេបាន $\sqrt{3}$ ជាចំនួនអសនិទាន ជាសំណើពិត

ដូចនេះ $\boxed{\sqrt{3} \text{ ជាចំនួនអសនិទាន ត្រូវបានបង្ហាញ}}$ ។

**សម្គាល់** - គ្រប់ចំនួនគត់ធម្មជាតិ គេអាចបំបែកជាផលគុណកត្តាបឋមបានតែមួយបែបគត់ ។

- ចំនួនពីរស្មើគ្នា កាលណាចំនួនទាំងពីរមានផលគុណកត្តាបឋមដូចគ្នា ។

15. **បង្ហាញថា $\sqrt[4]{2}$ ជាចំនួនអសនិទាន**

ឧបមាថា $\sqrt[4]{2}$ ជាចំនួនសនិទាន

គេបាន $\sqrt[4]{2}=\frac{a}{b} \Leftrightarrow a^4=2b^4 \quad (1)$

គេតាង $a=a_1\times a_2\times a_3\times\ldots\times a_m$ មាន $m$ កត្តាបឋម ដែល $a_1, a_2, a_3, \ldots, a_m$ ជាចំនួនបឋម

នោះ $a^4=\left(a_1\times a_2\times a_3\times\ldots\times a_m\right)^4$ មាន $4m=2(2m)$ កត្តាបឋម គឺចំនួនគូកត្តាបឋម

គេតាង $b=b_1\times b_2\times b_3\times\ldots\times b_n$ មាន $n$ កត្តាបឋម ដែល $b_1, b_2, b_3, \ldots, b_n$ ជាចំនួនបឋម

នោះ $b^4=\left(b_1\times b_2\times b_3\times\ldots\times b_n\right)^4$ មាន $4n=2(2n)$ កត្តាបឋម គឺចំនួនគូកត្តាបឋម

នាំឱ្យ $2b^4=2\left(b_1\times b_2\times b_3\times\ldots\times b_n\right)^4$ មាន $2(2n)+1$ កត្តា គឺចំនួនសេសកត្តាបឋម

តាម $(1)$ ឃើញថា អង្គទីមួយ $a^4$ មានគូកត្តាបឋម ឯអង្គទីពីរ $2b^4$ មានសេសកត្តាបឋម នោះ $a^4$ និង $2b^4$ មានកត្តាបឋមខុសគ្នា

នាំឱ្យ $a^4$ និង $2b^4$ ជាចំនួនមិនស្មើគ្នា នោះការឧបមាថា $\sqrt{3}$ ជាចំនួនសនិទាន មិនពិត

គេបាន $\sqrt[4]{2}$ ជាចំនួនអសនិទាន ពិត

ដូចនេះ $\boxed{\sqrt[4]{2} \text{ ជាចំនួនអសនិទាន ត្រូវបានបង្ហាញ}}$ ។

16. **បង្ហាញថា $\sqrt{p}$ ជាចំនួនអសនិទាន ចំពោះគ្រប់ចំនួនបឋម $p$**

ឧបមាថា $\sqrt{p}$ ជាចំនួនសនិទាន

គេបាន $\sqrt{p}=\frac{a}{b} \Leftrightarrow a^2=pb^2 \quad (1)$

គេតាង $a=a_1\times a_2\times a_3\times\ldots\times a_m$ មាន $m$ កត្តាបឋម ដែល $a_1, a_2, a_3, \ldots, a_m$ ជាចំនួនបឋម

នោះ $a^2=\left(a_1\times a_2\times a_3\times\ldots\times a_m\right)^2$ មាន $2m$ កត្តាបឋម គឺចំនួនគូកត្តាបឋម

គេតាង $b=b_1\times b_2\times b_3\times\ldots\times b_n$ មាន $n$ កត្តាបឋម ដែល $b_1, b_2, b_3, \ldots, b_n$ ជាចំនួនបឋម

នោះ $b^2=\left(b_1\times b_2\times b_3\times\ldots\times b_n\right)^2$ មាន $2n$ កត្តាបឋម គឺចំនួនគូកត្តាបឋម

នាំឱ្យ $pb^2=p\left(b_1\times b_2\times b_3\times\ldots\times b_n\right)^2$ មាន $2n+1$ កត្តា គឺចំនួនសេសកត្តាបឋម ព្រោះ $p$ ជាចំនួនបឋម

តាម $(1)$ ឃើញថា អង្គទីមួយ $a^2$ មានគូកត្តាបឋម ឯអង្គទីពីរ $pb^2$ មានសេសកត្តាបឋម នោះ $a^2$ និង $pb^2$ មានកត្តាបឋមខុសគ្នា

នាំឱ្យ $a^2$ និង $pb^2$ ជាចំនួនមិនស្មើគ្នា នោះការឧបមាថា $\sqrt{p}$ ជាចំនួនសនិទាន មិនពិត

គេបាន $\sqrt{p}$ ជាចំនួនអសនិទាន ពិត

ដូចនេះ $\boxed{\sqrt{p} \text{ ជាចំនួនអសនិទាន ចំពោះគ្រប់ចំនួនបឋម } p \text{ ត្រូវបានបង្ហាញ}}$ ។

17. **បង្ហាញថា $1+\sqrt{2}$ ជាចំនួនអសនិទាន**

ឧបមាថា $1+\sqrt{2}$ ជាចំនួនសនិទាន

គេបាន $1+\sqrt{2}=\dfrac{a}{b} \Leftrightarrow \sqrt{2}b=a-b \Leftrightarrow 2b^2=(a-b)^2 \quad (1)$

តាម $(1)$ $(a-b)^2$ ជាពហុគុណនៃ $2$ នោះ $a-b$ ក៏ជាពហុគុណនៃ $2$ ដែរ

គេតាង $a-b=2m$ ដែល $m$ ជាចំនួនគត់វិជ្ជមាន

គេបាន $(1):\ 2b^2=(2m)^2 \Leftrightarrow b^2=2m^2 \quad (2)$

តាម $(2)$ $b^2$ ជាពហុគុណនៃ $2$ នោះ $b$ ក៏ជាពហុគុណនៃ $2$ ដែរ

គេតាង $b=2k$ ដែល $k$ ជាចំនួនគត់វិជ្ជមាន

គេបាន $a-b=2m \Leftrightarrow a-2k=2m \Leftrightarrow a=2(m+k)$

នាំឱ្យ $a$ ជាពហុគុណនៃ $2$ ដែលគេតាង $a=2\ell$ , $\ell=m+k$

ឃើញថា $a=2\ell$ និង $b=2k$ សុទ្ធតែជាចំនួនគូ នោះវាមានតួចែករួមធំបំផុតខុសពី 1 (មិនមែនជាចំនួនបឋមរវាងគ្នា)

នាំឱ្យ ការឧបមាថា $1+\sqrt{2}$ ជាចំនួនសនិទាន ជារឿងមិនពិត នោះ $1+\sqrt{2}$ ជាចំនួនអសនិទាន

ដូចនេះ $1+\sqrt{2}$ ជាចំនួនអសនិទាន ត្រូវបានបង្ហាញ ។

18. **បង្ហាញថា $\sqrt{2}+\sqrt{3}$ ជាចំនួនអសនិទាន**

ឧបមាថា $\sqrt{2}+\sqrt{3}$ ជាចំនួនសនិទាន

គេបាន $\sqrt{2}+\sqrt{3}=\dfrac{a}{b} \Leftrightarrow 5+2\sqrt{6}=\dfrac{a^2}{b^2} \Leftrightarrow 2\sqrt{6}b^2=a^2-5b^2 \Leftrightarrow 6(4b^4)=(a^2-5b^2)^2 \quad (1)$

តាម $(1)$ $(a^2-5b^2)^2$ ជាពហុគុណនៃ $6$ នោះ $a^2-5b^2$ ក៏ជាពហុគុណនៃ $6$ ដែរ ហេតុនេះគេតាង $a^2-5b^2=6m$

នាំឱ្យ $6(4b^4)=(6m)^2 \Leftrightarrow 24b^4=36m^2 \Leftrightarrow 2b^4=3m^2$

ដោយ $b^4$ ជាពហុគុណនៃ $3$ នោះ $b$ ក៏ជាពហុគុណនៃ $3$ ដែរ ហេតុនេះគេតាង $b=3n$

គេបាន $a^2-5b^2=6m \Leftrightarrow a^2-5(3n)^2=6m \Leftrightarrow a^2=6m+45n^2 \Leftrightarrow a^2=3(2m+15n^2)$

ដោយ $a^2$ ជាពហុគុណនៃ $3$ នោះ $a$ ក៏ជាពហុគុណនៃ $3$ ដែរ ហេតុនេះគេតាង $a=3k$

ប៉ុន្តែ ប្រសិនបើ $a$ និង $b$ សុទ្ធតែជាពហុគុណនៃ $3$ នោះ $a$ និង $b$ មិនមែនជាចំនួនបឋមរវាងគ្នាទេ

នាំឱ្យ ការឧបមាថា $\sqrt{2}+\sqrt{3}$ ជាចំនួនសនិទាន គឺជារឿងមិនពិត

គេបាន $\sqrt{2}+\sqrt{3}$ ជាចំនួនអសនិទាន គឺជារឿងពិត

ដូចនេះ $\sqrt{2}+\sqrt{3}$ ជាចំនួនអសនិទាន ត្រូវបានបង្ហាញ ។

19. **បង្ហាញថា** $x^2+5x+6=0$ **លុះត្រាតែ** $x=-2$ ឬ $x=-3$

គេនឹងបង្ហាញតាម សម្រាយបញ្ជាក់ទ្វេលក្ខខណ្ឌ គេដឹងថា $p \Leftrightarrow q=(p \Rightarrow q)\wedge(q \Rightarrow p)$

គេតាង $p:\ x^2+5x+6=0$

$q:\ x=-2$ ឬ $x=-3$

គេមាន $p:\ x^2+5x+6=0$

$(x+2)(x+3)=0$

នាំឱ្យ $x+2=0$ ឬ $x+3=0$

គេបាន $x=-2$ ឬ $x=-3$

គេស្រាយបានថា $p:\ x^2+5x+6=0$ នោះ $q:$ ($x=-2$ ឬ $x=-3$) មានន័យថា $p \Rightarrow q$ $(1)$

ម្យ៉ាងទៀត បើ $x=-2$ នោះ $x^2+5x+6=(-2)^2+5(-2)+6=4-10+6=0$

បើ $x=-3$ នោះ $x^2+5x+6=(-3)^2+5(-3)+6=9-15+6=0$

គេស្រាយបានថា $q:$ ($x=-2$ ឬ $x=-3$) នោះ $p:\ x^2+5x+6=0$ មានន័យថា $q \Rightarrow p$ $(2)$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ គេបាន $p \Leftrightarrow q$ គឺ $x^2+5x+6=0$ លុះត្រាតែ $x=-2$ ឬ $x=-3$

ដូចនេះ $x^2+5x+6=0$ លុះត្រាតែ $x=-2$ ឬ $x=-3$ ត្រូវបានបង្ហាញ ។

20. **បង្ហាញថា** $x^3-4x=0$ **លុះត្រាតែ** $x=0$ ឬ $x=-2$ ឬ $x=2$

គេនឹងបង្ហាញតាម សម្រាយបញ្ជាក់ទ្វេលក្ខខណ្ឌ គេដឹងថា $p \Leftrightarrow q=(p \Rightarrow q)\wedge(q \Rightarrow p)$

គេតាង $p:\ x^3-4x=0$

$q:\ x=0$ ឬ $x=-2$ ឬ $x=2$

គេមាន $p:\ x^3-4x=0$

$x(x^2-4)=0$

$x(x+2)(x-2)=0$

នាំឱ្យ $x=0$ ឬ $x+2=0$ ឬ $x-2=0$

គេបាន $x=0$ ឬ $x=-2$ ឬ $x=2$

គេស្រាយបានថា $p:\ x^3-4x=0$ នោះ $q:$ ($x=0$ ឬ $x=-2$ ឬ $x=2$) មានន័យថា $p \Rightarrow q$ $(1)$

ម្យ៉ាងទៀត បើ $x=0$ នោះ $x^3-4x=0^3-4\cdot 0=0$

បើ $x=-2$ នោះ $x^3-4x=(-2)^3-4(-2)=-8+8=0$

បើ $x=2$ នោះ $x^3-4x=(2)^3-4(2)=8-8=0$

គេស្រាយបានថា $q:$ ($x=0$ ឬ $x=-2$ ឬ $x=2$) នោះ $p:\ x^3-4x=0$ មានន័យថា $q \Rightarrow p$ $(2)$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ គេបាន $p \Leftrightarrow q$ គឺ $x^3-4x=0$ លុះត្រាតែ $x=0$ ឬ $x=-2$ ឬ $x=2$

ដូចនេះ $x^3-4x=0$ លុះត្រាតែ $x=0$ ឬ $x=-2$ ឬ $x=2$ ត្រូវបានបង្ហាញ ។

21. **បង្ហាញថា $x^2+y^2=0$ លុះត្រាតែ $x=0$ និង $y=0$**

គេនឹងបង្ហាញតាម សម្រាយបញ្ជាក់ទ្វេលក្ខខណ្ឌ គេដឹងថា $p\Leftrightarrow q=(p\Rightarrow q)\wedge(q\Rightarrow p)$

គេតាង $p:\ x^2+y^2=0$

$q:\ x=0$ និង $y=0$

គេមាន $p:\ x^2+y^2=0$

ដោយ $x^2\geq 0$ និង $y^2\geq 0$

នោះមានតែមួយករណីគត់ដែលនាំឱ្យ $x^2+y^2=0$ គឺ $x=0$ និង $y=0$

គេស្រាយបានថា $p:\ x^2+y^2=0$ នោះ $q:$ ($x=0$ និង $y=0$) មានន័យថា $p\Rightarrow q$ $(1)$

ម្យ៉ាងទៀត បើ $x=0$ និង $y=0$ នោះ $x^2+y^2=0^2+0^2=0$

គេស្រាយបានថា $q:$ ($x=0$ និង $y=0$) នោះ $p:\ x^2+y^2=0$ មានន័យថា $q\Rightarrow p$ $(2)$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ គេបាន $p\Leftrightarrow q$ គឺ $x^2+y^2=0$ លុះត្រាតែ $x=0$ និង $y=0$

ដូចនេះ $x^2+y^2=0$ លុះត្រាតែ $x=0$ និង $y=0$ ត្រូវបានបង្ហាញ ។

22. **បង្ហាញថា អង្គការអាស៊ានមានសមាជិកមកពីគ្រប់ប្រទេសក្នុងទ្វីបអាស៊ី ជាសំណើមិនពិត**

គេនឹងបង្ហាញសំណើខាងលើជាសំណើមិនពិត ដោយប្រើឧទាហរណ៍ផ្ទុយ (ត្រឹមតែរកឱ្យបានឧទាហរណ៍មួយមកផ្ទុយ)

ដោយ ប្រទេសជប៉ុន ជាប្រទេសនៅក្នុងទ្វីបអាស៊ីដែរ តែប្រទេសជប៉ុនមិនមែនជាសមាជិកអង្គការអាស៊ាន

នាំឱ្យ សំណើថា អង្គការអាស៊ានមានសមាជិកមកពីគ្រប់ប្រទេសក្នុងទ្វីបអាស៊ី ជាសំណើមិនពិត

ដូចនេះ អង្គការអាស៊ានមានសមាជិកមកពីគ្រប់ប្រទេសក្នុងទ្វីបអាស៊ី ជាសំណើមិនពិត ត្រូវបានបង្ហាញ ។

23. **បង្ហាញថា ចំនួនបឋមជាចំនួនគត់សេស ជាសំណើមិនពិត**

គេនឹងបង្ហាញសំណើខាងលើជាសំណើមិនពិត ដោយប្រើឧទាហរណ៍ផ្ទុយ (ត្រឹមតែរកឱ្យបានឧទាហរណ៍មួយមកផ្ទុយ)

ដោយ លេខ 2 ជាចំនួនបឋមដែរ តែលេខ 2 មិនមែនជាចំនួនគត់សេសទេ

នាំឱ្យ សំណើថា ចំនួនបឋមជាចំនួនគត់សេស ជាសំណើមិនពិត

ដូចនេះ ចំនួនបឋមជាចំនួនគត់សេស ជាសំណើមិនពិត ត្រូវបានបង្ហាញ ។

24. **បង្ហាញថា បើ $p$ និង $q$ ជាចំនួនបឋម ហើយ $n=p^2+q^2$ នោះ $n$ ជាចំនួនបឋម ជាសំណើមិនពិត**

ដោយ $p=3$ និង $q=5$ ជាចំនួនបឋមដែរ ប៉ុន្តែ $n=p^2+q^2=3^2+5^2=9+25=34$ មិនមែនជាចំនួនបឋមទេ

នាំឱ្យ សំណើថា បើ $p$ និង $q$ ជាចំនួនបឋម ហើយ $n=p^2+q^2$ នោះ $n$ ជាចំនួនបឋម ជាសំណើមិនពិត

ដូចនេះ បើ $p$ និង $q$ ជាចំនួនបឋម ហើយ $n=p^2+q^2$ នោះ $n$ ជាចំនួនបឋម ជាសំណើមិនពិត ត្រូវបានបង្ហាញ ។

25. **បង្ហាញថា បើ $a>b$ នោះ $a^2>b^2$ ចំពោះគ្រប់ចំនួនពិត $a$ និង $b$ ជាសំណើមិនពិត**

ដោយ ចំពោះគ្រប់ចំនួនពិត $a$ និង $b$ គេយក $a=1>b=-2$ ប៉ុន្តែ $a^2=1^2<b^2=(-2)^2$

នាំឱ្យ សំណើថា បើ $a>b$ នោះ $a^2>b^2$ ចំពោះគ្រប់ចំនួនពិត $a$ និង $b$ ជាសំណើមិនពិត

ដូចនេះ បើ $a>b$ នោះ $a^2>b^2$ ចំពោះគ្រប់ចំនួនពិត $a$ និង $b$ ជាសំណើមិនពិត ត្រូវបានបង្ហាញ ។

**26. បង្ហាញថា បើ $x$ និង $y$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាន និង $xy$ ជាចំនួនគត់សេស នោះ $x$ និង $y$ ក៏ជាចំនួនគត់សេសដែរ**

គេនឹងស្រាយតាមសំណើផ្ទុយពីសម្មតិកម្ម ព្រោះគេដឹងថា $p \Rightarrow q$ និង $\overline{q} \Rightarrow \overline{p}$ មានតម្លៃភាពពិតដូចគ្នា (បង្ហាញរួចខាងលើ!)

គេតាង $p:$ $xy$ ជាចំនួនគត់សេស

$q:$ $x$ និង $y$ ជាចំនួនគត់សេស

នាំឱ្យ $\overline{p}:$ $xy$ ជាចំនួនគត់គូ

$\overline{q}:$ យ៉ាងហោចណាស់មានមួយក្នុងចំណោម $x$ និង $y$ ជាចំនួនគត់គូ

ចេញពីសំណើ $\overline{q}$ គេនឹងស្រាយរហូតបាន $\overline{p}$ តាមករណីទាំងបីដូចខាងក្រោម ៖

- ករណី $x$ ជាចំនួនគត់គូ និង $y$ ជាចំនួនគត់សេស

  គេតាង $x=2a$ និង $y=2b-1$ ដែល $a$ និង $b$ ជាចំនួនគត់ធម្មជាតិ

  គេបាន $xy=2a\times(2b-1)=2(2ab-a)$ ជាចំនួនគូ ជាសំណើ $\overline{p}$

- ករណី $x$ ជាចំនួនគត់សេស និង $y$ ជាចំនួនគត់គូ

  គេតាង $x=2c-1$ និង $y=2d$ ដែល $c$ និង $d$ ជាចំនួនគត់ធម្មជាតិ

  គេបាន $xy=(2c-1)\times 2d=2(2cd-d)$ ជាចំនួនគូ ជាសំណើ $\overline{p}$

- ករណី $x$ ជាចំនួនគត់គូ និង $y$ ជាចំនួនគូ

  គេតាង $x=2e$ និង $y=2f$ ដែល $e$ និង $f$ ជាចំនួនគត់ធម្មជាតិ

  គេបាន $xy=2e\times 2f=2(2ef)$ ជាចំនួនគូ ជាសំណើ $\overline{p}$

ឃើញថា គ្រប់ករណីគេបានសំណើ $\overline{q} \Rightarrow \overline{p}$ ជាសំណើពិត នោះសំណើ $p \Rightarrow q$ ក៏ជាសំណើពិតដែរ

ដូចនេះ បើ $x$ និង $y$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាន និង $xy$ ជាចំនួនគត់សេស នោះ $x$ និង $y$ ក៏ជាចំនួនគត់សេសដែរ ។

**27. បង្ហាញថា បើ $x(x-2)<0$ នោះ $0<x<2$**

គេនឹងស្រាយតាមសំណើផ្ទុយពីសម្មតិកម្ម ព្រោះគេដឹងថា $p \Rightarrow q$ និង $\overline{q} \Rightarrow \overline{p}$ មានតម្លៃភាពពិតដូចគ្នា (បង្ហាញរួចខាងលើ!)

គេតាង $p:$ $x(x-2)<0$

$q:$ $0<x<2$

នាំឱ្យ $\overline{p}:$ $x(x-2)\geq 0$

$\overline{q}:$ $x\leq 0$ ឬ $x\geq 2$

ចេញពីសំណើ $\overline{q}$ គេនឹងស្រាយរហូតបាន $\overline{p}$ ដូចខាងក្រោម ៖

-ចំពោះ $x\leq 0$ នោះ $x-2\leq -2$ នាំឱ្យ $x(x-2)\geq -2x$ (ត្រូវប្តូរទិសដៅ ព្រោះគុណនឹង $x\leq 0$ អវិជ្ជមាន)

  ដោយ $x\leq 0$ នោះ $-2x\geq 0$ គេបាន $x(x-2)\geq -2x\geq 0$ នាំឱ្យ $x(x-2)\geq 0$ ជាសំណើ $\overline{p}$

-ចំពោះ $x\geq 2$ នោះ $x-2\geq 0$ នាំឱ្យ $x(x-2)\geq 0$ (មិនប្តូរទិសដៅ ព្រោះគុណនឹង $x\geq 2$ វិជ្ជមាន) ជាសំណើ $\overline{p}$

ឃើញថា គេស្រាយបានថា សំណើ $\overline{q} \Rightarrow \overline{p}$ ជាសំណើពិត នាំឱ្យសំណើ $p \Rightarrow q$ ក៏ជាសំណើពិតដែរ

គេបាន $p \Rightarrow q$ គឺ បើ $x(x-2)<0$ នោះ $0<x<2$ ជាសំណើពិត

ដូចនេះ បើ $x(x-2)<0$ នោះ $0<x<2$ ត្រូវបានបង្ហាញ ។

28. **បង្ហាញថា ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n$ បើ $n^2>25$ នោះ $n>5$**

គេនឹងស្រាយតាមសំណើផ្ទុយពីសម្មតិកម្ម ព្រោះគេដឹងថា $p\Rightarrow q$ និង $\overline{q}\Rightarrow\overline{p}$ មានតម្លៃភាពពិតដូចគ្នា (បង្ហាញរួចខាងលើ!)

គេតាង $p:\ n^2>25$

$q:\ n>5$

នាំឱ្យ $\overline{p}:\ n^2\le 25$

$\overline{q}:\ n\le 5$

ចេញពីសំណើ $\overline{q}$ គេនឹងស្រាយរហូតបាន $\overline{p}$ ដូចខាងក្រោម ៖

ដោយ $n$ ជាចំនួនគត់ធម្មជាតិ ហើយ $n\le 5$ នោះ $n=1,2,3,4,5$

ចំពោះ $n=1$ នោះ $n^2=1\le 25$ ពិត

ចំពោះ $n=2$ នោះ $n^2=4\le 25$ ពិត

ចំពោះ $n=3$ នោះ $n^2=9\le 25$ ពិត

ចំពោះ $n=4$ នោះ $n^2=16\le 25$ ពិត

ចំពោះ $n=5$ នោះ $n^2=25\le 25$ ពិត

ឃើញថា គេស្រាយបានថា សំណើ $\overline{q}\Rightarrow\overline{p}$ ជាសំណើពិត នាំឱ្យសំណើ $p\Rightarrow q$ ក៏ជាសំណើពិតដែរ

គេបាន $p\Rightarrow q$ គឺ បើ $n^2>25$ នោះ $n>5$ ជាសំណើពិត

ដូចនេះ បើ $n^2>25$ នោះ $n>5$ ត្រូវបានបង្ហាញ ។

29. **បង្ហាញថា $x+\frac{1}{x}>2$ ចំពោះគ្រប់ $x>1$**

គេនឹងស្រាយតាមសំណើផ្ទុយពីការពិត ព្រោះគេដឹងថា បើសំណើ $\overline{p}$ មិនពិត នោះសំណើ $p$ ពិត

គេតាង $p:\ x+\frac{1}{x}>2$ នោះគេបាន $\overline{p}:\ x+\frac{1}{x}\le 2$

គេមាន $\overline{p}:\ x+\frac{1}{x}\le 2$ (គុណអង្គទាំងពីរ និង $x>1$ វិជ្ជមាន មិនប្តូរទិសដៅ)

$x^2+1\le 2x$

$x^2-2x+1\le 0$

$(x-1)^2\le 0$ មិនពិត ព្រោះ $(x-1)^2>0$ ចំពោះគ្រប់ $x>1$

គេបាន សំណើ $p:\ x+\frac{1}{x}>2$ ចំពោះគ្រប់ $x>1$ ជាសំណើពិត

ដូចនេះ $x+\frac{1}{x}>2$ ចំពោះគ្រប់ $x>1$ ត្រូវបានបង្ហាញ ។

30. **បង្ហាញថា គ្មានចំនួនគត់រ៉ឺឡាទីប $p$ និង $q$ ដែល $\frac{p^2}{q^2}=2$**

ឧបមាថា មានចំនួនគត់រ៉ឺឡាទីប $p$ និង $q$ ដែលផ្ទៀងផ្ទាត់ $\frac{p^2}{q^2}=2$

គេមាន $\frac{p^2}{q^2}=2$ អាចសរសេរ $p^2=2q^2 \quad (1)$

ដោយ គ្រប់ចំនួនគត់រ៉ឺឡាទីប $p$ និង $q$ គេអាចបំបែក $p$ និង $q$ ជាកត្តាបឋមបានតែមួយបែបគត់

គេតាង $p=p_1\times p_2\times p_3\times\ldots\times p_m$ មាន $m$ កត្តាបឋម ដែល $p_1, p_2, p_3, \ldots, p_m$ ជាចំនួនបឋម

នោះ $p^2=(p_1\times p_2\times p_3\times\ldots\times p_m)^2$ មាន $2m$ កត្តាបឋម គឺចំនួនគូកត្តាបឋម

គេតាង $q=q_1\times q_2\times q_3\times\ldots\times q_n$ មាន $n$ កត្តាបឋម ដែល $q_1, q_2, q_3, \ldots, q_n$ ជាចំនួនបឋម

នោះ $q^2=(q_1\times q_2\times q_3\times\ldots\times q_n)^2$ មាន $2n$ កត្តាបឋម គឺចំនួនគូកត្តាបឋម

នាំឱ្យ $2q^2=2(q_1\times q_2\times q_3\times\ldots\times q_n)^2$ មាន $2n+1$ កត្តា គឺចំនួនសេសកត្តាបឋម

តាម $(1)$ ឃើញថា អង្គទីមួយ $p^2$ មានគូកត្តាបឋម ឯអង្គទីពីរ $2q^2$ មានសេសកត្តាបឋម នោះ $p^2$ និង $2q^2$ មានកត្តាបឋមខុសគ្នា នាំឱ្យ $p^2$ និង $2q^2$ ជាចំនួនមិនស្មើគ្នា

នោះ មិនអាចមាន ចំនួនគត់រ៉ឺឡាទីប $p$ និង $q$ ដែលផ្ទៀងផ្ទាត់ $\frac{p^2}{q^2}=2$ នោះទេ

ដូចនេះ: | គ្មានចំនួនគត់រ៉ឺឡាទីប $p$ និង $q$ ដែល $\frac{p^2}{q^2}=2$ ត្រូវបានបង្ហាញ | ។

# ការស្រាយបញ្ជាក់លើមេរៀន សំណុំ

1. ស្រាយបញ្ជាក់លក្ខណៈដឺម៉ រ៉េង $(\text{De Morgan})$ ៖

   $(i)$ $\overline{A\cup B}=\overline{A}\cap\overline{B}$

   $(ii)$ $\overline{A\cap B}=\overline{A}\cup\overline{B}$ ។

2. ស្រាយបញ្ជាក់ថា បើគេមានបីសំណុំ $A$ , $B$ និង $C$ នោះគេបានលក្ខណៈផ្តុំដូចខាងក្រោម ៖

   ក. $A\cap(B\cap C)=(A\cap B)\cap C$ ។

   ខ. $A\cup(B\cup C)=(A\cup B)\cup C$ ។

3. ស្រាយបញ្ជាក់ថា បើគេមានបីសំណុំ $A$ , $B$ និង $C$ នោះគេបានលក្ខណៈបំបែកដូចខាងក្រោម ៖

   ក. $A\cap(B\cup C)=(A\cap B)\cup(A\cap C)$ ។

   ខ. $A\cup(B\cap C)=(A\cup B)\cap(A\cup C)$ ។

4. ស្រាយបញ្ជាក់ថា បើគេមានសំណុំ $A$ និង $U$ ជាចំណុំសកល ហើយ $\overline{A}$ ជាសំណុំរងបំពេញនៃ $A$ នោះគេបាន ៖

   ក. $A\cap\overline{A}=\varnothing$ ។

   ខ. $A\cup\overline{A}=U$ ។

   គ. $n(A)+n(\overline{A})=n(U)$ ។

5. គេមានពីរសំណុំ $A$ និង $B$ ជាសំណុំរាប់អស់ ៖

   ក. បង្ហាញថា $n(A\cup B)=n(A)+n(B)-n(A\cap B)$ ។

   ខ. ទាញថា $n(A\cap B)=n(A)+n(B)-n(A\cup B)$ ។

6. បង្ហាញថា បើ $A\cap B=\varnothing$ នោះ $A$ និង $B$ ជាពីរសំណុំដាច់គ្នា ។

7. បង្ហាញថា $A=\{x|x^2-4=0\}$ ជាសំណុំរាប់អស់ ។

8. បង្ហាញថា $B=\{y|1<y<2\}$ ជាសំណុំរាប់មិនអស់ ឬសំណុំអនន្ត ។

9. បង្ហាញថា បើ $A$ ជាសំណុំរងនៃសំណុំ $B$ នោះគេបាន $n(A)\le n(B)$ ។

10. ស្រាយបញ្ជាក់ថា ចំនួនសំណុំរងនៃសំណុំមួយដែលមាន $n$ ធាតុ ស្មើនឹង $2^n$ ។

# ការស្រាយបញ្ជាក់លើមេរៀន សំណុំ

1. ស្រាយបញ្ជាក់លក្ខណៈដឺម៉ជេន (De Morgan) ៖

➢របៀបទី១ : ស្រាយបញ្ជាក់ថា $(i)\quad \overline{A\cup B}=\overline{A}\cap\overline{B}$

គេមាន $\quad A\cup B=\{x \mid x\in A$ ឬ $x\in B\}$

នាំឱ្យ $\quad \overline{A\cup B}=\{x \mid x\notin A$ និង $x\notin B\}$

$=\{x \mid x\in \overline{A}$ និង $x\in \overline{B}\}$

$=\{x \mid x\in \overline{A}\}\cap\{x \mid x\in \overline{B}\}$

$=\overline{A}\cap\overline{B}$

ដូចនេះ: | លក្ខណៈដឺម៉ជេន $\overline{A\cup B}=\overline{A}\cap\overline{B}$ ត្រូវបានស្រាយបញ្ជាក់ | ។

➢របៀបទី២ : ស្រាយបញ្ជាក់ថា $(i)\quad \overline{A\cup B}=\overline{A}\cap\overline{B}$ ដោយប្រើដ្យាក្រាមវិន




ផ្ទៃកឆូតខ្វែងជាសំណុំ $\overline{A\cup B}$




ផ្ទៃកឆូតខ្វែងជាសំណុំ $\overline{A}\cap\overline{B}$

ផ្ទៃកឆូតស្របទ្រេតទៅខាងស្តាំជាសំណុំ $\overline{A}$

ផ្ទៃកឆូតស្របទ្រេតទៅខាងឆ្វេងជាសំណុំ $\overline{B}$

តាមដ្យាក្រាមវិនទាំងពីរ គេសង្កេតឃើញថា សំណុំ $\overline{A\cup B}$ និងសំណុំ $\overline{A}\cap\overline{B}$ ជាសំណុំតែមួយ នាំឱ្យ $\overline{A\cup B}=\overline{A}\cap\overline{B}$

ដូចនេះ: | លក្ខណៈដឺម៉ជេន $\overline{A\cup B}=\overline{A}\cap\overline{B}$ ត្រូវបានស្រាយបញ្ជាក់ | ។

➢របៀបទី១ : ស្រាយបញ្ជាក់ថា $(ii)\quad \overline{A\cap B}=\overline{A}\cup\overline{B}$

គេមាន $\quad A\cap B=\{x \mid x\in A$ និង $x\in B\}$

នាំឱ្យ $\quad \overline{A\cap B}=\{x \mid x\notin A$ ឬ $x\notin B\}$

$=\{x \mid x\in \overline{A}$ ឬ $x\in \overline{B}\}$

$=\{x \mid x\in \overline{A}\}\cup\{x \mid x\in \overline{B}\}$

$=\overline{A}\cup\overline{B}$

ដូចនេះ: | លក្ខណៈដឺម៉ជេន $\overline{A\cap B}=\overline{A}\cup\overline{B}$ ត្រូវបានស្រាយបញ្ជាក់ | ។

➢របៀបទី២ : ស្រាយបញ្ជាក់ថា $(ii)$ $\overline{A\cap B}=\bar{A}\cup\bar{B}$ ដោយប្រើដ្យាក្រាមវិន




ផ្នែកឆូតខ្វែងជាសំណុំ $\overline{A\cap B}$




ផ្នែកឆូតស្របទ្រេតទៅខាងស្តាំជាសំណុំ $\bar{A}$

ផ្នែកឆូតស្របទ្រេតទៅខាងឆ្វេងជាសំណុំ $\bar{B}$

ផ្នែកឆូតមួយជាន់និងពីរជាន់ ជាសំណុំ $\bar{A}\cup\bar{B}$

តាមដ្យាក្រាមវិនទាំងពីរ គេសង្កេតឃើញថា សំណុំ $\overline{A\cap B}$ និងសំណុំ $\bar{A}\cup\bar{B}$ ជាសំណុំតែមួយ នាំឱ្យ $\overline{A\cap B}=\bar{A}\cup\bar{B}$

ដូចនេះ

| លក្ខណៈដឺម៉ដេន $\overline{A\cap B}=\bar{A}\cup\bar{B}$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

2. **ស្រាយបញ្ជាក់ថា បើគេមានបីសំណុំ $A$ , $B$ និង $C$ នោះគេបានលក្ខណៈផ្តុំដូចខាងក្រោម ៖**

**ក. របៀបទី១ : ស្រាយបញ្ជាក់ថា** $A\cap(B\cap C)=(A\cap B)\cap C$

គេមាន $A\cap B=\{x|x\in A \text{ និង } x\in B\}$

$B\cap C=\{x|x\in B \text{ និង } x\in C\}$

គេបាន $A\cap(B\cap C)=\{x|x\in A\}\cap\{x|x\in B \text{ និង } x\in C\}$

$=\{x|x\in A \text{ និង } x\in B \text{ និង } x\in C\}$

$=\{x|x\in A \text{ និង } x\in B\}\cap\{x|x\in C\}$

$=(A\cap B)\cap C$

ដូចនេះ

| លក្ខណៈផ្តុំ $A\cap(B\cap C)=(A\cap B)\cap C$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

**➢របៀបទី២ : ស្រាយបញ្ជាក់ថា** $A\cap(B\cap C)=(A\cap B)\cap C$




ផ្នែកឆូតខ្វែងជាសំណុំ $A\cap(B\cap C)$




ផ្នែកឆូតខ្វែងជាសំណុំ $(A\cap B)\cap C$

តាមដ្យាក្រាមវិនទាំងពីរ គេសង្កេតឃើញថា សំណុំ $A\cap(B\cap C)$ និងសំណុំ $(A\cap B)\cap C$ ជាសំណុំតែមួយ

នាំឱ្យ $A\cap(B\cap C)=(A\cap B)\cap C$

ដូចនេះ

| លក្ខណៈផ្តុំ $A\cap(B\cap C)=(A\cap B)\cap C$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

**ខ. របៀបទី១ : ស្រាយបញ្ជាក់ថា** $A\cup(B\cup C)=(A\cup B)\cup C$

គេមាន $A\cup B=\{x|x\in A \text{ ឬ } x\in B\}$

$B\cup C=\{x|x\in B \text{ ឬ } x\in C\}$

គេបាន $A\cup(B\cup C)=\{x|x\in A\}\cup\{x|x\in B \text{ ឬ } x\in C\}$

$=\{x|x\in A \text{ ឬ } x\in B \text{ ឬ } x\in C\}$

$=\{x|x\in A \text{ ឬ } x\in B\}\cap\{x|x\in C\}$

$=(A\cup B)\cup C$

ដូចនេះ លក្ខណៈផ្តុំ $A\cup(B\cup C)=(A\cup B)\cup C$ ត្រូវបានស្រាយបញ្ជាក់ ។

➢ **របៀបទី២ : ស្រាយបញ្ជាក់ថា** $A\cup(B\cup C)=(A\cup B)\cup C$




ផ្នែកឆូតជាសំណុំ $A\cup(B\cup C)$




ផ្នែកឆូតជាសំណុំ $(A\cup B)\cup C$

តាមដ្យាក្រាមវិនទាំងពីរ គេសង្កេតឃើញថា សំណុំ $A\cup(B\cup C)$ និងសំណុំ $(A\cup B)\cup C$ ជាសំណុំតែមួយ

នាំឱ្យ $A\cup(B\cup C)=(A\cup B)\cup C$

ដូចនេះ លក្ខណៈផ្តុំ $A\cup(B\cup C)=(A\cup B)\cup C$ ត្រូវបានស្រាយបញ្ជាក់ ។

3. **បើគេមានបីសំណុំ** $A$ , $B$ **និង** $C$ **នោះគេបានលក្ខណៈបំបែកដូចខាងក្រោម ៖**

**ក. ស្រាយបញ្ជាក់ថា** $A\cap(B\cup C)=(A\cap B)\cup(A\cap C)$




ផ្នែកឆូតពីរជាន់ជាសំណុំ $A\cap(B\cup C)$




ទាំងផ្នែកឆូតមួយជាន់និងពីរជាន់ ជាសំណុំ $(A\cap B)\cup(A\cap C)$

តាមដ្យាក្រាមវិនទាំងពីរ គេសង្កេតឃើញថា សំណុំ $A\cap(B\cup C)$ និងសំណុំ $(A\cap B)\cup(A\cap C)$ ជាសំណុំតែមួយ

នាំឱ្យ $A\cap(B\cup C)=(A\cap B)\cup(A\cap C)$

ដូចនេះ លក្ខណៈបំបែក $A\cap(B\cup C)=(A\cap B)\cup(A\cap C)$ ត្រូវបានស្រាយបញ្ជាក់ ។

ខ. ស្រាយបញ្ជាក់ថា $A\cup(B\cap C)=(A\cup B)\cap(A\cup C)$







ទាំងផ្នែកឆូតមួយជាន់និងពីរជាន់ ជាសំណុំ $A\cup(B\cap C)$ ផ្នែកឆូតពីរជាន់ជាសំណុំ $(A\cup B)\cap(A\cup C)$

តាមដ្យាក្រាមវិនទាំងពីរ គេសង្កេតឃើញថា សំណុំ $A\cup(B\cap C)$ និងសំណុំ $(A\cup B)\cap(A\cup C)$ ជាសំណុំតែមួយ

នាំឱ្យ $A\cup(B\cap C)=(A\cup B)\cap(A\cup C)$

ដូចនេះ **លក្ខណៈបំបែក $A\cup(B\cap C)=(A\cup B)\cap(A\cup C)$ ត្រូវបានស្រាយបញ្ជាក់** ។

4. **គេមានសំណុំ $A$ និង $U$ ជាចំណុំសកល ហើយ $\bar{A}$ ជាសំណុំរងបំពេញនៃ $A$ ៖**

ក. ស្រាយបញ្ជាក់ថា $A\cap\bar{A}=\varnothing$

➤ **របៀបទី១**

គេមាន $\bar{A}=\{x|x\notin A\,,\,x\in U\}$

នាំឱ្យ $A\cap\bar{A}=\{x|x\in A$ និង $x\notin A\}$

$=\{$ គ្មាន $x$ ណាដែលផ្ទៀងផ្ទាត់ $x\in A$ និង $x\notin A\}$

$=\{\ \}=\varnothing$

ដូចនេះ **$A\cap\bar{A}=\varnothing$ ត្រូវបានស្រាយបញ្ជាក់** ។

➤ **របៀបទី២** តាមដ្យាក្រាមវិន




តាមក្រាបឃើញថា គ្មានចំណុចប្រសព្វរវាង $A$ និង $\bar{A}$ សោះឡើយ នាំឱ្យ $A\cap\bar{A}=\varnothing$

ដូចនេះ **$A\cap\bar{A}=\varnothing$ ត្រូវបានស្រាយបញ្ជាក់** ។

ខ. ➤ **របៀបទី១ : ស្រាយបញ្ជាក់ថា** $A\cup\bar{A}=U$

ដោយ $\bar{A}$ ជាសំណុំរងបំពេញនៃសំណុំ $A$

គេមាន $A\cup\bar{A}=\{x|x\in A$ ឬ $x\in\bar{A}\}$

$=U$

ដូចនេះ **$A\cup\bar{A}=U$ ត្រូវបានស្រាយបញ្ជាក់** ។

➤ របៀបទី២ : តាមដ្យាក្រាមវិន




ផ្នែកឆូតជាសំណុំ $A\cup\bar{A}$ ដែលផ្នែកឆូតទាំងអស់ជាសំណុំ $U$

ដូចនេះ: $A\cup\bar{A}=U$ ត្រូវបានស្រាយបញ្ជាក់ ។

**គ. ស្រាយបញ្ជាក់ថា** $n(A)+n(\bar{A})=n(U)$

ដោយ $A\cup\bar{A}=U$ នាំឱ្យ $n(A)+n(\bar{A})=n(U)$

ដូចនេះ: $n(A)+n(\bar{A})=n(U)$ ត្រូវបានស្រាយបញ្ជាក់ ។

5. **គេមានពីរសំណុំ $A$ និង $B$ ជាសំណុំរាប់អស់ ៖**

**ក. បង្ហាញថា** $n(A\cup B)=n(A)+n(B)-n(A\cap B)$

គេប្រើដ្យាក្រាមវិន




តាមដ្យាក្រាមវិន ដើម្បីរក $n(A\cup B)$ គេត្រូវយក $n(A)+n(B)-n(A\cap B)$

ដូចនេះ: $n(A\cup B)=n(A)+n(B)-n(A\cap B)$ ត្រូវបានស្រាយបញ្ជាក់ ។

**ខ. ទាញថា** $n(A\cap B)=n(A)+n(B)-n(A\cup B)$

គេមាន រូបមន្ត $n(A\cup B)=n(A)+n(B)-n(A\cap B)$

ទាញបាន $n(A\cap B)=n(A)+n(B)-n(A\cup B)$

ដូចនេះ: $n(A\cap B)=n(A)+n(B)-n(A\cup B)$ ត្រូវបានស្រាយបញ្ជាក់ ។

6. **បង្ហាញថា បើ $A\cap B=\varnothing$ នោះ $A$ និង $B$ ជាពីរសំណុំដាច់គ្នា**

គេប្រើដ្យាក្រាមវិន




ដោយ $A\cap B=\varnothing$ មានន័យថា សំណុំ $A$ និង $B$ គ្មានធាតុរួមគ្នាទេ ធ្វើឱ្យដ្យាក្រាមរបស់វាដាច់គ្នា

ដូចនេះ: បើ $A\cap B=\varnothing$ នោះ $A$ និង $B$ ជាពីរសំណុំដាច់គ្នា ត្រូវបានបង្ហាញ ។

7. **បង្ហាញថា** $A=\{x|x^2-4=0\}$ **ជាសំណុំរាប់អស់**

គេមាន $A=\{x|x^2-4=0\}$

$=\{x|(x-2)(x+2)=0\}$

$=\{2,-2\}$

ដោយ $n(A)=2$ ជាចំនួនកំណត់ (ជាចំនួនរាប់អស់)

នាំឱ្យ $A$ ជាសំណុំរាប់អស់

ដូចនេះ | សំណុំ $A=\{x|x^2-4=0\}$ ជាសំណុំរាប់អស់ ត្រូវបានបង្ហាញ | ។

8. **បង្ហាញថា** $B=\{y|1<y<2\}$ **ជាសំណុំរាប់មិនអស់ ឬសំណុំអនន្ត**

គេមាន $B=\{y|1<y<2\}$

$=\{1.1, 1.2, 1.24, ..., 1.99, 1.9942, ...\}$

ឃើញថា សំណុំ $B$ មានធាតុច្រើនរាប់មិនអស់

នាំឱ្យ $B$ ជាសំណុំរាប់មិនអស់ ឬសំណុំអនន្ត

ដូចនេះ | សំណុំ $B=\{y|1<y<2\}$ ជាសំណុំរាប់មិនអស់ ឬសំណុំអនន្ត ត្រូវបានបង្ហាញ | ។

9. **បង្ហាញថា បើ** $A$ **ជាសំណុំរងនៃសំណុំ** $B$ **នោះគេបាន** $n(A)\le n(B)$

ដោយ $A$ ជាសំណុំរងនៃសំណុំ $B$

គេបាន $A=\{x|x\in A\Rightarrow x\in B\}$ មានន័យថា $n(A)<n(B)$

ម្យ៉ាងទៀត បើ $A=B$ នោះ សំណុំ $A$ ក៏ជាសំណុំរងនៃសំណុំ $B$ ដែរ

នាំឱ្យ $n(A)\le n(B)$

ដូចនេះ | បើ $A$ ជាសំណុំរងនៃសំណុំ $B$ នោះគេបាន $n(A)\le n(B)$ ត្រូវបានបង្ហាញ | ។

10. **ស្រាយបញ្ជាក់ថា ចំនួនសំណុំរងនៃសំណុំមួយដែលមាន** $n$ **ធាតុ ស្មើនឹង** $2^n$

សំណុំដែលមាន $n$ ធាតុមានសំណុំរងដែលមាន $0$ ធាតុ , $1$ ធាតុ , $2$ ធាតុ , ... , $n$ ធាតុ

សំណុំរងទាំងអស់នៃសំណុំដែលមាន $n$ ធាតុ ជាសំណុំបានពីបន្សំនៃ $0$ ធាតុ , $1$ ធាតុ , $2$ ធាតុ , ... , $n$ ធាតុ យកពី $n$ ធាតុខុសគ្នា

គេបាន ចំនួនសំណុំរងនៃសំណុំដែលមាន $n$ ធាតុ ស្មើនឹង $C(n,0)+C(n,1)+C(n,2)+C(n,3)+...+C(n,n)$

តាមរូបមន្ត $(a+b)^n=C(n,0)a^n+C(n,1)a^{n-1}b+C(n,2)a^{n-2}b^2+...+C(n,n)b^n$

ចំពោះ $a=1$ និង $b=1$

គេបាន $(1+1)^n=C(n,0)+C(n,1)+C(n,2)+...+C(n,n)$

$2^n=C(n,0)+C(n,1)+C(n,2)+...+C(n,n)$

ដូចនេះ | ចំនួនសំណុំរងនៃសំណុំមួយដែលមាន $n$ ធាតុ ស្មើនឹង $C(n,0)+C(n,1)+C(n,2)+...+C(n,n)=2^n$ | ។

# ការស្រាយបញ្ជាក់លើមេរៀន ចំនួន

1. បង្ហាញថា សមភាព $|-a|=|a|$ ពិត ចំពោះគ្រប់ចំនួនពិត $a$ ។
2. បង្ហាញថា $a^2=|a|^2$ ពិត ចំពោះគ្រប់ចំនួនពិត $a$ ។
3. បង្ហាញថា $\sqrt{a^2}=|a|$ ពិត ចំពោះគ្រប់ចំនួនពិត $a$ ។
4. បង្ហាញថា បើ $a>0$ , $b>0$ និង $a<b$ នោះគេបាន $\sqrt{a}<\sqrt{b}$ ។
5. បង្ហាញថា បើ $a>b>0$ នោះគេបាន $\sqrt{a\pm 2\sqrt{ab}+b}=\sqrt{a}\pm\sqrt{b}$
6. បង្ហាញថា ចំនួន 10101 ក្នុងប្រព័ន្ធរបាប់គោល 2 ស្មើនឹងចំនួន 21 ក្នុងប្រព័ន្ធរបាប់គោល 10 ។
7. បង្ហាញថា ចំនួន 120 ក្នុងប្រព័ន្ធរបាប់គោល 10 ស្មើនឹងចំនួន 1111000 ក្នុងប្រព័ន្ធរបាប់គោល 2 ។

# ការស្រាយបញ្ជាក់លើមេរៀន ចំនួន

1. **បង្ហាញថា សមភាព $|-a|=|a|$ ពិត ចំពោះគ្រប់ចំនួនពិត $a$**

តាមលក្ខណៈ: $|x|=\begin{cases} x & \text{បើ } x\geq 0 \\ -x & \text{បើ } x<0 \end{cases}$ គេនឹងបង្ហាញថា $|-a|=|a|$ ពិត ចំពោះគ្រប់ចំនួនពិត $a$

-ចំពោះ $a\geq 0$ គេបាន : $|a|=a$ និង $-a\leq 0$ នោះ $|-a|=-(-a)=a=|a|$ $(1)$

-ចំពោះ $a<0$ គេបាន : $|a|=-a$ និង $-a>0$ នោះ $|-a|=-a=|a|$ $(2)$

តាមករណី $(1)$ និង $(2)$ ខាងលើគ្រប់គ្រាន់បញ្ជាក់ថា $|-a|=|a|$ ពិត ចំពោះគ្រប់ចំនួនពិត $a$

ដូចនេះ | សមភាព $|-a|=|a|$ ពិត ចំពោះគ្រប់ចំនួនពិត $a$ ត្រូវបានបង្ហាញ | ។

2. **បង្ហាញថា $a^2=|a|^2$ ពិត ចំពោះគ្រប់ចំនួនពិត $a$**

តាមលក្ខណៈ: $|x|=\begin{cases} x & \text{បើ } x\geq 0 \\ -x & \text{បើ } x<0 \end{cases}$ គេនឹងបង្ហាញថា $a^2=|a|^2$ ពិត ចំពោះគ្រប់ចំនួនពិត $a$

-ចំពោះ $a\geq 0$ គេបាន : $|a|^2=a^2$ $(1)$

-ចំពោះ $a<0$ គេបាន : $|a|^2=(-a)^2=a^2$ $(2)$

តាមករណី $(1)$ និង $(2)$ ខាងលើគ្រប់គ្រាន់បញ្ជាក់ថា $a^2=|a|^2$ ពិត ចំពោះគ្រប់ចំនួនពិត $a$

ដូចនេះ | សមភាព $|-a|=|a|$ ពិត ចំពោះគ្រប់ចំនួនពិត $a$ ត្រូវបានបង្ហាញ | ។

3. **បង្ហាញថា $\sqrt{a^2}=|a|$ ពិត ចំពោះគ្រប់ចំនួនពិត $a$**

តាមលក្ខណៈ: $\sqrt{x^2}=\begin{cases} x & \text{បើ } x\geq 0 \\ -x & \text{បើ } x<0 \end{cases}$ និង $|x|=\begin{cases} x & \text{បើ } x\geq 0 \\ -x & \text{បើ } x<0 \end{cases}$ គេនឹងបង្ហាញថា $\sqrt{a^2}=|a|$ ពិត ចំពោះគ្រប់ចំនួនពិត $a$

-ចំពោះ $a\geq 0$ គេបាន : $\sqrt{a^2}=a$ និង $|a|=a$ នាំឱ្យ $\sqrt{a^2}=|a|$ $(1)$

-ចំពោះ $a<0$ គេបាន : $\sqrt{a^2}=-a$ និង $|a|=-a$ នាំឱ្យ $\sqrt{a^2}=|a|$ $(2)$

តាមករណី $(1)$ និង $(2)$ ខាងលើគ្រប់គ្រាន់បញ្ជាក់ថា $\sqrt{a^2}=|a|$ ពិត ចំពោះគ្រប់ចំនួនពិត $a$

ដូចនេះ | សមភាព $|-a|=|a|$ ពិត ចំពោះគ្រប់ចំនួនពិត $a$ ត្រូវបានបង្ហាញ | ។

4. **បង្ហាញថា បើ $a>0$ , $b>0$ និង $a<b$ នោះគេបាន $\sqrt{a}<\sqrt{b}$**

គេមាន $a<b \Leftrightarrow a-b<0$ អាចសរសេរ $\left(\sqrt{a}\right)^2-\left(\sqrt{b}\right)^2<0$

ចំពោះ $a>0$ , $b>0$ គេបាន $\left(\sqrt{a}-\sqrt{b}\right)\left(\sqrt{a}+\sqrt{b}\right)<0$ (ចែកអង្គទាំងពីរនឹង $\sqrt{a}+\sqrt{b}>0$ មិនប្តូរទិសដៅ)

គេបាន $\sqrt{a}-\sqrt{b}<0$ ឬ $\sqrt{a}<\sqrt{b}$

ដូចនេះ | បើ $a>0$ , $b>0$ និង $a<b$ នោះគេបាន $\sqrt{a}<\sqrt{b}$ ត្រូវបានបង្ហាញ | ។

5. **បង្ហាញថា បើ $a>b>0$ នោះគេបាន $\sqrt{a\pm 2\sqrt{ab}+b}=\sqrt{a}\pm\sqrt{b}$**

គេមាន $\sqrt{a\pm 2\sqrt{ab}+b}=\sqrt{\sqrt{a^2}\pm 2\sqrt{ab}+\sqrt{b^2}}$

$=\sqrt{\left(\sqrt{a}\pm\sqrt{b}\right)^2}$

$=\sqrt{a}\pm\sqrt{b}$

ព្រោះ $a>b>0$ នោះ $\sqrt{a}>\sqrt{b}>0$ នាំឱ្យ $\sqrt{a}\pm\sqrt{b}>0$

ដូចនេះ: | បើ $a>b>0$ នោះគេបាន $\sqrt{a\pm 2\sqrt{ab}+b}=\sqrt{a}\pm\sqrt{b}$ ត្រូវបានបង្ហាញ | ។

6. **បង្ហាញថា ចំនួន 10101 ក្នុងប្រព័ន្ធរបាប់គោល 2 ស្មើនឹងចំនួន 21 ក្នុងប្រព័ន្ធរបាប់គោល 10**

គេមាន 10101 ក្នុងប្រព័ន្ធរបាប់គោល 2

គេបាន $10101_2=1\cdot 2^4+0\cdot 2^3+1\cdot 2^2+0\cdot 2^1+1\cdot 2^0$

$=2^4+2^2+1$

$=16+4+1$

$=21$

ដូចនេះ: | $10101_2=21$ ត្រូវបានបង្ហាញ | ។

7. **បង្ហាញថា ចំនួន 120 ក្នុងប្រព័ន្ធរបាប់គោល 10 ស្មើនឹងចំនួន 1111000 ក្នុងប្រព័ន្ធរបាប់គោល 2**

ដើម្បីបំបែក 120 ក្នុងប្រព័ន្ធរបាប់គោល 10 ទៅចំនួនក្នុងប្រព័ន្ធគោល 2 គេត្រូវចែករកសំណល់ដូចខាងក្រោម




ដូចនេះ: | $120=1111000_2$ ត្រូវបានបង្ហាញ | ។

# ការស្រាយបញ្ជាក់លើមេរៀន ពហុធា

1. បង្ហាញថា $x^{-1}$ , $2\sqrt{x}$ , $12x^{0.4}$ មិនមែនជា ឯកធា ។
2. បង្ហាញថា 999 ជាឯកធា ។
3. បង្ហាញថា $2xy^2$ និង $-3y^2x$ ជាឯកធាដូចគ្នា ។
4. បង្ហាញថា $2x$ និង $2x^2$ ជាឯធាមិនដូចគ្នា ។
5. បង្ហាញថា ឯកធា $-52xy^2zt^3$ ជាឯកធាដែលមានដឺក្រេស្មើ 7 ។
6. បង្ហាញថា $x^2-10x^2+11x^2=2x^2$ ។
7. ស្រាយបញ្ជាក់ថា $a^m\cdot a^n=a^{m+n}$ , $\left(a^m\right)^n=a^{m\times n}$ , $\left(ab\right)^n=a^n\cdot b^n$ និង $\dfrac{a^m}{a^n}=a^{m-n}$ ដែល $a\neq 0$ ។
8. បង្ហាញថា $3x^3+7xyz^2-12ab^2cx$ ជាពហុធាដែលមានដឺក្រេស្មើ 5 ។
9. បង្ហាញថា $x^2+4x-5$ ជាពហុធាដែលមានដឺក្រេស្មើ 2 លំដាប់ចុះ ។
10. បង្ហាញថា $(2x-1)(3x+2)=6x^2+x-2$ ។
11. បង្ហាញថា ៖
    - $(a+b)^2=a^2+2ab+b^2$
    - $(a-b)^2=a^2-2ab+b^2$
    - $a^2-b^2=(a-b)(a+b)$
    - $(a+b+c)^2=a^2+b^2+c^2+2ab+2ac+2bc$
    - $(a+b)^3=a^3+3a^2b+3ab^2+b^3$
    - $(a-b)^3=a^3-3a^2b+3ab^2-b^3$
    - $(a-b)\left(a^2+ab+b^2\right)=a^3-b^3$
    - $(a+b)\left(a^2-ab+b^2\right)=a^3+b^3$
    - $a^4-b^4=(a-b)(a+b)\left(a^2+b^2\right)$
12. បង្ហាញថា $x^2+(a+b)x+ab=(x+a)(x+b)$ ។
13. បង្ហាញថា $acx^2+(ad+bc)x+bd=(ax+b)(cx+d)$ ។
14. បង្ហាញថា $\sqrt{3+\sqrt{6}}+\sqrt{3-\sqrt{6}}=\sqrt{6+2\sqrt{3}}$ ពិត ។

# ការស្រាយបញ្ជាក់លើមេរៀន ពហុធា

1. **បង្ហាញថា** $x^{-1}$ , $2\sqrt{x}$ , $12x^{0.4}$ **មិនមែនជា ឯកធា**

តាមនិយមន័យ ឯកធា គឺជាកន្សោមដែលប្រមាណវិធីលើអថេរមានតែវិធីគុណ និងស្វ័យគុណ ដែលមាននិទស្សន្តជាចំនួនគត់វិជ្ជមាន ឬសូន្យ ។

ដោយ $x^{-1}$ មាននិទស្សន្តនៃអថេរជាចំនួនគត់អវិជ្ជមាន នោះ $x^{-1}$ មិនមែនជា ឯកធា

$2\sqrt{x} = 2x^{\frac{1}{2}}$ មាននិទស្សន្តនៃអថេរមិនមែនជាចំនួនគត់ នោះ $2\sqrt{x}$ មិនមែនជា ឯកធា

$12x^{0.4}$ មាននិទស្សន្តនៃអថេរមិនមែនជាចំនួនគត់ នោះ $2\sqrt{x}$ មិនមែនជា ឯកធា

ដូចនេះ $x^{-1}$ , $2\sqrt{x}$ , $12x^{0.4}$ មិនមែនជាឯកធា ត្រូវបានបង្ហាញ ។

2. **បង្ហាញថា** 999 **ជាឯកធា**

ដោយ $999 = 999x^0$ មាននិទស្សន្តនៃអថេរស្មើសូន្យ

តាមនិយមន័យនៃឯកធា បញ្ជាក់ថា 999 ជាឯកធា

ដូចនេះ 999 ជាឯកធា ត្រូវបានបង្ហាញ ។

3. **បង្ហាញថា** $2xy^2$ **និង** $-3y^2x$ **ជាឯកធាដូចគ្នា**

តាមនិយមន័យ ឯកធាដូចគ្នា គឺជាឯកធាដែលមានផ្នែកអថេរដូចគ្នា

ដោយ $2xy^2$ និង $-3y^2x$ មានផ្នែកអថេរ $xy^2$ ដូចគ្នា

នាំឱ្យ $2xy^2$ និង $-3y^2x$ ជាឯកធាដូចគ្នា

ដូចនេះ $2xy^2$ និង $-3y^2x$ ជាឯកធាដូចគ្នា ត្រូវបានបង្ហាញ ។

4. **បង្ហាញថា** $2x$ **និង** $2x^2$ **ជាឯធាមិនដូចគ្នា**

តាមនិយមន័យ ឯកធាដូចគ្នា គឺជាឯកធាដែលមានផ្នែកអថេរដូចគ្នា

ដោយ $2x$ មានផ្នែកអថេរស្មើ $x$ និង $2x^2$ មានផ្នែកអថេរស្មើ $x^2$

នាំឱ្យ $2x$ និង $2x^2$ មានផ្នែកអថេរមិនដូចគ្នា នោះឯកធាទាំងពីរមិនដូចគ្នាទេ

ដូចនេះ $2x$ និង $2x^2$ ជាឯកធាមិនដូចគ្នា ត្រូវបានបង្ហាញ ។

5. **បង្ហាញថា ឯកធា** $-52xy^2zt^3$ **ជាឯកធាដែលមានដឺក្រេស្មើ** 7

តាមនិយមន័យ ដឺក្រេនៃឯកធា គឺជាផលបូកនិទស្សន្តរបស់អថេរនីមួយៗនៃឯធា ។

ដោយ ឯកធា $-52xy^2zt^3$ មានអថេរ $x$ , $y$ , $z$ , $t$

នាំឱ្យ ផលបូកនិទស្សន្តនៃអថេរនីមួយៗគឺ $1+2+1+3=7$

គេបាន $-52xy^2zt^3$ ជាឯកធា ដែលមាននិទស្សន្តស្មើ 7

ដូចនេះ ឯកធា $-52xy^2zt^3$ ជាឯកធាដែលមានដឺក្រេស្មើ 7 ត្រូវបានបង្ហាញ ។

6. បង្ហាញថា $x^2-10x^2+11x^2=2x^2$

ដោយ $x^2$ , $-10x^2$ , $11x^2$ ជាឯកធា ដែលមានផ្នែកអថេរស្មើ $x^2$ ដូចគ្នា

នាំឱ្យ គេបូកឬដកតែលេខមេគុណ និងរក្សាផ្នែកអថេរទុកនៅដដែល

គេបាន $x^2-10x^2+11x^2=(1-10+11)x^2=2x^2$

ដូចនេះ $\boxed{x^2-10x^2+11x^2=2x^2}$ ត្រូវបានបង្ហាញ ។

7. ➢ ស្រាយបញ្ជាក់ថា $a^m\cdot a^n=a^{m+n}$

តាមនិយមន័យ $\underbrace{a\times a\times a\times\ldots\times a}_{n\text{ កត្តា}}=a^n$

គេបាន $a^m\times a^n=\underbrace{a\times a\times a\times\ldots\times a}_{m\text{ កត្តា}}\times\underbrace{a\times a\times a\times\ldots\times a}_{n\text{ កត្តា}}=\underbrace{a\times a\times a\times\ldots\times a\times a\times a}_{(m+n)\text{ កត្តា}}=a^{m+n}$

ដូចនេះ $\boxed{a^m\times a^n=a^{m+n}}$ ត្រូវបានស្រាយបញ្ជាក់ ។

➢ ស្រាយបញ្ជាក់ថា $(a^m)^n=a^{m\times n}$

ពិនិត្យ $(a^m)^n=\underbrace{a^m\times a^m\times a^m\times\ldots\times a^m}_{n\text{ កត្តា}}=a^{\overbrace{m+m+m+\ldots+m}_{n\text{ កត្តា}}}=a^{m\times n}$ (ពង្រីកឱ្យធំស្រួលមើលស្វ័យគុណ)

ដូចនេះ $\boxed{(a^m)^n=a^{m\times n}}$ ត្រូវបានស្រាយបញ្ជាក់ ។

➢ ស្រាយបញ្ជាក់ថា $(ab)^n=a^n\cdot b^n$

ពិនិត្យ $a^n\times b^n=\underbrace{a\times a\times a\times\ldots\times a}_{n\text{ កត្តា}}\times\underbrace{b\times b\times b\times\ldots\times b}_{n\text{ កត្តា}}=\underbrace{(ab)\times(ab)\times(ab)\times\ldots\times(ab)}_{n\text{ កត្តា}}=(ab)^n$

ដូចនេះ $\boxed{(ab)^n=a^n\times b^n}$ ត្រូវបានស្រាយបញ្ជាក់ ។

➢ ស្រាយបញ្ជាក់ថា $\frac{a^m}{a^n}=a^{m-n}$ ដែល $a\neq 0$

$$\frac{a^m}{a^n}=\frac{\overbrace{a\times a\times a\times\ldots\times a}^{m\text{ កត្តា}}}{\underbrace{a\times a\times a\times\ldots\times a}_{n\text{ កត្តា}}}=\underbrace{\frac{a}{a}\times\frac{a}{a}\times\frac{a}{a}\times\ldots\times\frac{a}{a}}_{n\text{ កត្តា}}\times\underbrace{a\times a\times a\times\ldots\times a}_{(m-n)\text{ កត្តា}}=\underbrace{a\times a\times a\times\ldots\times a}_{(m-n)\text{ កត្តា}}=a^{m-n}$$

ដូចនេះ $\boxed{\frac{a^m}{a^n}=a^{m-n}\ ,\ a\neq 0}$ ត្រូវបានស្រាយបញ្ជាក់ ។

8. **បង្ហាញថា** $3x^3+7xyz^2-12ab^2cx$ **ជាពហុធាដែលមានដឺក្រេស្មើ** 5

ដោយ ដឺក្រេនៃពហុធា គឺជាដឺក្រេរបស់តួ ដែលមានដឺក្រេខ្ពស់ជាងគេ

ហើយ តួ $3x^3$ មានដឺក្រេស្មើ 3 , $7xyz^2$ មានដឺក្រេស្មើ 4 និង $-12ab^2cx$ មានដឺក្រេស្មើ 5

នាំឱ្យ $3x^3+7xyz^2-12ab^2cx$ ជាពហុធាដែលមានដឺក្រេស្មើ 5

ដូចនេះ: $3x^3+7xyz^2-12ab^2cx$ ជាពហុធាដែលមានដឺក្រេស្មើ 5 ត្រូវបានបង្ហាញ ។

9. **បង្ហាញថា** $x^2+4x-5$ **ជាពហុធាដែលមានដឺក្រេស្មើ** 2 **លំដាប់ចុះ**

ដោយ ពហុធា $x^2+4x-5$ មានតួដែលមានដឺក្រេខ្ពស់ជាងគេស្មើ 2 និងរៀបតាមលំដាប់ចុះនៃដឺក្រេគឺ 2 , 1 , 0

នាំឱ្យ $x^2+4x-5$ ជាពហុធាដែលមានដឺក្រេស្មើ 2 លំដាប់ចុះ

ដូចនេះ: $x^2+4x-5$ ជាពហុធាដែលមានដឺក្រេស្មើ 2 លំដាប់ចុះ ត្រូវបានបង្ហាញ ។

10. **បង្ហាញថា** $(2x-1)(3x+2)=6x^2+x-2$

យោងតាម ដើម្បីគុណពហុធានឹងពហុធា គេយកតួនីមួយៗនៃពហុធាទីមួយ គុណឱ្យគ្រប់តួនៃពហុធាទីពីរ រួចបង្រួមលទ្ធផល ។

គេបាន
$$(2x-1)(3x+2)=6x^2+4x-3x-2$$
$$=6x^2+x-2$$

ដូចនេះ: $(2x-1)(3x+2)=6x^2+x-2$ ត្រូវបានបង្ហាញ ។

11. **បង្ហាញថា ៖**

- $(a+b)^2$
$$=(a+b)(a+b)$$
$$=a^2+ab+ba+b^2$$
$$=a^2+2ab+b^2$$

- $(a-b)^2$
$$=(a-b)(a-b)$$
$$=a^2-ab-ba+b^2$$
$$=a^2-2ab+b^2$$

- $(a-b)(a+b)$
$$=a^2+ab-ba-b^2$$
$$=a^2-b^2$$

- $(a+b+c)^2$
$$=(a+b+c)(a+b+c)$$
$$=a^2+ab+ac+ba+b^2+bc+ca+cb+c^2$$
$$=a^2+b^2+c^2+2ab+2ac+2bc$$

- $(a+b)^3$
$$=(a+b)^2(a+b)$$
$$=(a^2+2ab+b^2)(a+b)$$
$$=a^3+a^2b+2a^2b+2ab^2+b^2a+b^3$$
$$=a^3+3a^2b+3ab^2+b^3$$

- $(a-b)^3$
$$=(a-b)^2(a-b)$$
$$=(a^2-2ab+b^2)(a-b)$$
$$=a^3-a^2b-2a^2b+2ab^2+b^2a-b^3$$
$$=a^3-3a^2b+3ab^2-b^3$$

- $(a-b)(a^2+ab+b^2)$
$$=a^3+a^2b+ab^2-ba^2-ab^2-b^3$$
$$=a^3-b^3$$

- $(a+b)(a^2-ab+b^2)$
$$=a^3-a^2b+ab^2+ba^2-ab^2+b^3$$
$$=a^3+b^3$$

- $(a-b)(a+b)(a^2+b^2)$

$=(a^2-b^2)(a^2+b^2)$

$=(a^2)^2-(b^2)^2$

$=a^4-b^4$

12. បង្ហាញថា $x^2+(a+b)x+ab=(x+a)(x+b)$

គេមាន $x^2+(a+b)x+ab=x^2+ax+bx+ab$

$=(x+a)x+b(x+a)$

$=(x+a)(x+b)$

ដូចនេះ $x^2+(a+b)x+ab=(x+a)(x+b)$ ត្រូវបានបង្ហាញ ។

13. បង្ហាញថា $acx^2+(ad+bc)x+bd=(ax+b)(cx+d)$

គេមាន $acx^2+(ad+bc)x+bd=acx^2+adx+bcx+bd$

$=ax(cx+d)+b(cx+d)$

$=(cx+d)(ax+b)$

ដូចនេះ $acx^2+(ad+bc)x+bd=(ax+b)(cx+d)$ ត្រូវបានបង្ហាញ ។

14. បង្ហាញថា $\sqrt{3+\sqrt{6}}+\sqrt{3-\sqrt{6}}=\sqrt{6+2\sqrt{3}}$ ពិត

ពិនិត្យ $\sqrt{3+\sqrt{6}}+\sqrt{3-\sqrt{6}}=\sqrt{6+2\sqrt{3}}$

$\left[\sqrt{3+\sqrt{6}}+\sqrt{3-\sqrt{6}}\right]^2=\left[\sqrt{6+2\sqrt{3}}\right]^2$

$3+\sqrt{6}+2\sqrt{(3+\sqrt{6})(3+\sqrt{6})}+3-\sqrt{6}=6+2\sqrt{3}$

$6+2\sqrt{9-6}=6+2\sqrt{3}$

$6+2\sqrt{3}=6+2\sqrt{3}$ ពិត

ដូចនេះ $\sqrt{3+\sqrt{6}}+\sqrt{3-\sqrt{6}}=\sqrt{6+2\sqrt{3}}$ ពិត ត្រូវបានបង្ហាញ ។

# ការស្រាយបញ្ជាក់លើមេរៀន សមីការ

1. បង្ហាញថា បើ $a$ ជាចំនួនវិជ្ជមាន នោះ $\sqrt{-a}=i\sqrt{a}$ ។
2. បង្ហាញថា $-\sqrt{-2}$ ជាចំនួននិមិត្ត ។
3. បង្ហាញថា $\sqrt{-8}\times\sqrt{-18}=\sqrt{(-8)(-18)}=\sqrt{144}=12$ ខុស ។ ចូរឱ្យចម្លើយដែលត្រឹមត្រូវ ។
4. ស្រាយបញ្ជាក់ប្រមាណវិធីលើចំនួនកុំផ្លិច ៖

   ក. $(a+bi)+(c+di)=(a+c)+(b+d)i$

   ខ. $(a+bi)-(c+di)=(a-c)+(b-d)i$

   គ. $(a+bi)(c+di)=(ac-bd)+(ad+bc)i$

   ឃ. $\dfrac{a+bi}{c+di}=\dfrac{ac+bd}{c^2+d^2}+\dfrac{bc-ad}{c^2+d^2}i$
5. ស្រាយថា បើ $A\times B=0$ លុះត្រាតែ $A=0$ ឬ $B=0$ ។
6. បង្ហាញថា $x=-2$ ឬ $x=4$ ជាឫសនៃសមីការ $x^2-2x-8=0$ ។
7. បង្ហាញថា $x=\sqrt{b}$ ឬ $x=-\sqrt{b}$ ជាឫសនៃសមីការ $x^2=b$ ។
8. ស្រាយបញ្ជាក់ថា សមីការ $ax^2+bx+c=0$ , $a\neq 0$ មានឫស $x=\dfrac{-b\pm\sqrt{b^2-4ac}}{2a}$ ។
9. ក. ស្រាយបញ្ជាក់ថា សមីការ $ax^2+bx+c=0$ , $a\neq 0$ មានឫស $x=\dfrac{-b\pm\sqrt{\Delta}}{2a}$ ដែល ឌីសគ្រីមីណង់ $\Delta=b^2-4ac$ ។

   ខ. បង្ហាញថា បើ $\Delta>0$ សមីការមានឫសជាចំនួនពិតពីរផ្សេងគ្នា $x_1=\dfrac{-b-\sqrt{\Delta}}{2a}$ , $x_2=\dfrac{-b+\sqrt{\Delta}}{2a}$ ។

   គ. បង្ហាញថា បើ $\Delta=0$ សមីការមានឫសឌុប $x_1=x_2=\dfrac{-b}{2a}$ ។

   ឃ. បង្ហាញថា បើ $\Delta<0$ សមីការមានឫសពីរជាចំនួនកុំផ្លិចឆ្លាស់គ្នា $x_1=\dfrac{-b-i\sqrt{-\Delta}}{2a}$ , $x_2=\dfrac{-b+i\sqrt{-\Delta}}{2a}$ ។
10. ក. ចំពោះសមីការ $ax^2+bx+c=0$ , $a\neq 0$ មាន $b$ ជាចំនួនគូ ដែល $b=2b'$ នោះ $\Delta'=b'^2-ac$ ។

    ខ. បង្ហាញថា បើ $\Delta'>0$ សមីការមានឫសជាចំនួនពិតពីរផ្សេងគ្នា $x_1=\dfrac{-b'-\sqrt{\Delta'}}{a}$ , $x_2=\dfrac{-b'+\sqrt{\Delta'}}{a}$ ។

    គ. បង្ហាញថា បើ $\Delta'=0$ សមីការមានឫសឌុប $x_1=x_2=\dfrac{-b'}{a}$ ។

    ឃ. បង្ហាញថា បើ $\Delta'<0$ សមីការមានឫសពីរជាចំនួនកុំផ្លិចឆ្លាស់គ្នា $x_1=\dfrac{-b'-i\sqrt{-\Delta'}}{a}$ , $x_2=\dfrac{-b'+i\sqrt{-\Delta'}}{a}$ ។
11. ចំពោះសមីការ $ax^2+bx+c=0$ , $a\neq 0$ មាន $x_1$ និង $x_2$ ជាឫស ។

    ក. បង្ហាញថា ផលបូកឫស $S=x_1+x_2=\dfrac{-b}{a}$ ។

    ខ. បង្ហាញថា ផលគុណឫស $P=x_1x_2=\dfrac{c}{a}$ ។
12. ចំពោះសមីការ $ax^2+bx+c=0$ , $a\neq 0$ មាន $x_1$ និង $x_2$ ជាឫស ។

    ក. បង្ហាញថា បើ $a+b+c=0$ នោះ $x_1=1$ , $x_2=\dfrac{c}{a}$ ។

    ខ. បង្ហាញថា បើ $a-b+c=0$ នោះ $x_1=-1$ , $x_2=-\dfrac{c}{a}$ ។

13. ចំពោះសមីការ $ax^2+bx+c=0$ , $a\neq 0$ មានឫសពីរផ្សេងគ្នាគឺ $x_1$ និង $x_2$ ។
បង្ហាញថា គេអាចសរសេរកន្សោមដឺក្រេទី២ ជាផលគុណកត្តា $ax^2+bx+c=a(x-x_1)(x-x_2)$ ។
14. បង្ហាញថា បើគេស្គាល់ឫសសមីការគឺ $x_1$ និង $x_2$ នោះគេអាចបង្កើតសមីការបាន $x^2-Sx+P=0$ ដែល $S$ ជាផលបូកឫស និង $P$ ជាផលគុណឫស ។
15. ស្រាយបញ្ជាក់ទ្រឹស្តីបទសំណល់ ៖ បើ $R$ ជាសំណល់ក្នុងការចែកកន្សោមពហុធា $f(x)$ នឹង $x-\alpha$ នោះគេបាន $R=f(\alpha)$ ។
16. ស្រាយបញ្ជាក់ទ្រឹស្តីបទកត្តា ៖ $f(x)$ ជាពហុធា ។ បើ $\alpha$ ជាចម្លើយនៃសមីការ $f(x)=0$ នោះ $x-\alpha$ ជាកត្តានៃ $f(x)$ ។
17. បង្ហាញថា $f(x)$ ចែកដាច់នឹង $ax+b$ ប្រសិនបើ $f\left(-\frac{b}{a}\right)=0$ ។

# ការស្រាយបញ្ជាក់លើមេរៀន សមីការ

1. **បង្ហាញថា** $\sqrt{-a}=i\sqrt{a}$

គេមាន $a$ ជាចំនួនវិជ្ជមាន

ដោយ $i^2=-1$

គេបាន $\sqrt{-a}=\sqrt{(-1)\cdot a}=\sqrt{i^2\cdot a}=i\sqrt{a}$

ដូចនេះ $\boxed{\sqrt{-a}=i\sqrt{a}}$ ត្រូវបានបង្ហាញ ។

2. **បង្ហាញថា** $-\sqrt{-2}$ **ជាចំនួននិមិត្ត**

តាមនិយមន័យ ចំនួននិមិត្ត ជាផលគុណចំនួនពិតនឹងឯកតានិមិត្ត $i$

ដោយ $-\sqrt{-2}=-\sqrt{(-1)\cdot 2}=-\sqrt{i^2\cdot 2}=-\sqrt{2}\cdot i$ (ជាផលគុណចំនួនពិតនឹងឯកតានិតមិត្ត)

ដូចនេះ $-\sqrt{-2}$ ជាចំនួននិមិត្ត ត្រូវបានបង្ហាញ ។

3. **បង្ហាញថា** $\sqrt{-8}\times\sqrt{-18}=\sqrt{(-8)(-18)}=\sqrt{144}=12$ **ខុស និងឱ្យចម្លើយដែលត្រឹមត្រូវ**

គេមាន $\sqrt{-8}\times\sqrt{-18}=\sqrt{(-8)(-18)}=\sqrt{144}=12$

ព្រោះ រូបមន្ត $\sqrt{a}\times\sqrt{b}=\sqrt{a\cdot b}$ ប្រើបានតែ $a\ge 0$ , $b\ge 0$ ប៉ុណ្ណោះ

ចម្លើយដែល ត្រឹមត្រូវគឺ $\sqrt{-8}\times\sqrt{-18}=\sqrt{i^2\cdot 8}\times\sqrt{i^2\cdot 18}=i\sqrt{8}\times i\sqrt{18}=i^2\times\sqrt{8\times 18}=(-1)\sqrt{144}=-12$

ដូចនេះ $\sqrt{-8}\times\sqrt{-18}=12$ ខុស ចម្លើយត្រឹមត្រូវគឺ $\sqrt{-8}\times\sqrt{-18}=-12$ ។

4. **ស្រាយបញ្ជាក់ប្រមាណវិធីលើចំនួនកុំផ្លិច ៖**

**ក. ស្រាយបញ្ជាក់** $(a+bi)+(c+di)=(a+c)+(b+d)i$

ដើម្បីបូកចំនួនកុំផ្លិចជាមួយចំនួនកុំផ្លិច គេបូកផ្នែកពិតជាមួយផ្នែកពិត និងបូកផ្នែកនិមិត្តជាមួយផ្នែកនិមិត្ត

គេបាន $(a+bi)+(c+di)=a+c+bi+di=(a+c)+(b+d)i$

ដូចនេះ $(a+bi)+(c+di)=(a+c)+(b+d)i$ ត្រូវបានស្រាយបញ្ជាក់ ។

**ខ. ស្រាយបញ្ជាក់** $(a+bi)-(c+di)=(a-c)+(b-d)i$

ដើម្បីដកចំនួនកុំផ្លិចជាមួយចំនួនកុំផ្លិច គេដកផ្នែកពិតជាមួយផ្នែកពិត និងដកផ្នែកនិមិត្តជាមួយផ្នែកនិមិត្ត

គេបាន $(a+bi)-(c+di)=a-c+bi-di=(a-c)+(b-d)i$

ដូចនេះ $(a+bi)-(c+di)=(a-c)+(b-d)i$ ត្រូវបានស្រាយបញ្ជាក់ ។

គ. ស្រាយបញ្ជាក់ $(a+bi)(c+di)=(ac-bd)+(ad+bc)i$

គេមាន $(a+bi)(c+di)=ac+adi+bci+bdi^2$

$=ac-bd+adi+bci$

$=(ac-bd)+(ad+bc)i$

ដូចនេះ $(a+bi)(c+di)=(ac-bd)+(ad+bc)i$ ត្រូវបានស្រាយបញ្ជាក់ ។

ឃ. ស្រាយបញ្ជាក់ $\frac{a+bi}{c+di}=\frac{ac+bd}{c^2+d^2}+\frac{bc-ad}{c^2+d^2}i$

គេមាន $\frac{a+bi}{c+di}=\frac{(a+bi)(c-di)}{(c+di)(c-di)}$

$=\frac{ac+bd-adi+bci}{c^2+d^2}$

$=\frac{ac+bd}{c^2+d^2}+\frac{bc-ad}{c^2+d^2}i$

ដូចនេះ $\frac{a+bi}{c+di}=\frac{ac+bd}{c^2+d^2}+\frac{bc-ad}{c^2+d^2}i$ ត្រូវបានស្រាយបញ្ជាក់ ។

5. **ស្រាយថា បើ $A\times B=0$ លុះត្រាតែ $A=0$ ឬ $B=0$**

គេនឹងស្រាយតាមទ្វេលក្ខខណ្ឌ គេដឹងថា $p\Leftrightarrow q=(p\Rightarrow q)\wedge(q\Rightarrow p)$

ដោយ $A\times B=0\Rightarrow A=0$ ឬ $B=0$ $(1)$

ម្យ៉ាងទៀត បើ $A=0\Rightarrow A\times B=0\times B=0$

បើ $B=0\Rightarrow A\times B=A\times 0=0$

នាំឱ្យ $(A=0$ ឬ $B=0)\Rightarrow A\times B=0$ $(2)$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ គេបាន $A\times B=0$ លុះត្រាតែ $A=0$ ឬ $B=0$

ដូចនេះ $A\times B=0$ លុះត្រាតែ $A=0$ ឬ $B=0$ ត្រូវបានស្រាយបញ្ជាក់ ។

6. **បង្ហាញថា $x=-2$ ឬ $x=4$ ជាឫសនៃសមីការ $x^2-2x-8=0$**

បើ $x=-2$ ឬ $x=4$ ជាឫសនៃសមីការ $x^2-2x-8=0$ កាលណា $x=-2$ ឬ $x=4$ ផ្ទៀងផ្ទាត់សមីការ $x^2-2x-8=0$

ដោយ ចំពោះ $x=-2$ នោះ $x^2-2x-8=(-2)^2-2\cdot(-2)-8=4+4-8=0$ ពិត

ចំពោះ $x=4$ នោះ $x^2-2x-8=4^2-2\cdot4-8=16-8-8=0$ ពិត

នាំឱ្យ $x=-2$ ឬ $x=4$ ជាឫសនៃសមីការ $x^2-2x-8=0$

ដូចនេះ $x=-2$ ឬ $x=4$ ជាឫសនៃសមីការ $x^2-2x-8=0$ ត្រូវបានបង្ហាញ ។

7. **បង្ហាញថា** $x=\sqrt{b}$ **ឬ** $x=-\sqrt{b}$ **ជាឬសនៃសមីការ** $x^2=b$

បើ $x=\sqrt{b}$ ឬ $x=-\sqrt{b}$ ជាឬសនៃសមីការ $x^2=b$ កាលណា $x=\sqrt{b}$ ឬ $x=-\sqrt{b}$ ផ្ទៀងផ្ទាត់សមីការ $x^2=b$

ដោយ ចំពោះ $x=\sqrt{b}$ នោះ $x^2=\left(\sqrt{b}\right)^2=b$ ពិត

ចំពោះ $x=-\sqrt{b}$ នោះ $x^2=\left(-\sqrt{b}\right)^2=b$ ពិត

នាំឱ្យ $x=\sqrt{b}$ ឬ $x=-\sqrt{b}$ ជាឬសនៃសមីការ $x^2=b$

ដូចនេះ $x=\sqrt{b}$ ឬ $x=-\sqrt{b}$ ជាឬសនៃសមីការ $x^2=b$ ត្រូវបានបង្ហាញ ។

8. **ស្រាយបញ្ជាក់ថា សមីការ** $ax^2+bx+c=0$ , $a\neq 0$ **មានឬស** $x=\dfrac{-b\pm\sqrt{b^2-4ac}}{2a}$

គេមាន $ax^2+bx+c=0$ , $a\neq 0$ (ចែកអង្គទាំងពីរនឹង $a$)

$$x^2+\frac{b}{a}x+\frac{c}{a}=0$$

$$x^2+2\cdot x\cdot\frac{b}{2a}=-\frac{c}{a}$$

$$x^2+2\cdot x\cdot\frac{b}{2a}+\left(\frac{b}{2a}\right)^2=\left(\frac{b}{2a}\right)^2-\frac{c}{a}$$

$$\left(x+\frac{b}{2a}\right)^2=\frac{b^2}{4a}-\frac{c}{a}$$

$$\left(x+\frac{b}{2a}\right)^2=\frac{b^2-4ac}{4a^2}$$

$$x+\frac{b}{2a}=\pm\sqrt{\frac{b^2-4ac}{4a^2}}$$

$$x=-\frac{b}{2a}\pm\frac{\sqrt{b^2-4ac}}{\sqrt{4a^2}}$$

$$x=-\frac{b}{2a}\pm\frac{\sqrt{b^2-4ac}}{2a}$$

$$x=\frac{-b\pm\sqrt{b^2-4ac}}{2a}$$

(សូមបញ្ជាក់ថា ត្រង់ $\sqrt{4a^2}=2a$ តាមពិត $\sqrt{4a^2}=2|a|$ ចំពោះ $a\neq 0$ គេបាន $\sqrt{4a^2}=\pm 2a$ តែ $\frac{\pm}{\pm}=\pm$ ដដែល)

ដូចនេះ $ax^2+bx+c=0$ , $a\neq 0$ មានឬស $x=\dfrac{-b\pm\sqrt{b^2-4ac}}{2a}$ ត្រូវបានស្រាយបញ្ជាក់ ។

9. **ក. ស្រាយបញ្ជាក់ថា សមីការ** $ax^2+bx+c=0$ , $a\neq 0$ **មានឫស** $x=\dfrac{-b\pm\sqrt{\Delta}}{2a}$

គេមាន $ax^2+bx+c=0$ , $a\neq 0$ មានឫស $x=\dfrac{-b\pm\sqrt{b^2-4ac}}{2a}$ (បានស្រាយរួចខាងលើ)

ចំពោះ ឌីសគ្រីមីណង់ $\Delta=b^2-4ac$

គេបាន $x=\dfrac{-b\pm\sqrt{\Delta}}{2a}$

ដូចនេះ: សមីការ $ax^2+bx+c=0$ , $a\neq 0$ មានឫស $x=\dfrac{-b\pm\sqrt{\Delta}}{2a}$ ត្រូវបានស្រាយបញ្ជាក់ ។

**ខ. បង្ហាញថា បើ $\Delta>0$ សមីការមានឫសជាចំនួនពិតពីរផ្សេងគ្នា** $x_1=\dfrac{-b-\sqrt{\Delta}}{2a}$ , $x_2=\dfrac{-b+\sqrt{\Delta}}{2a}$

គេមាន $x=\dfrac{-b\pm\sqrt{\Delta}}{2a}$ ជាឫសនៃសមីការ $ax^2+bx+c=0$ , $a\neq 0$

ចំពោះ $\Delta>0$ គេអាចសរសេរបាន $x_1=\dfrac{-b-\sqrt{\Delta}}{2a}$ , $x_2=\dfrac{-b+\sqrt{\Delta}}{2a}$

ដូចនេះ: បើ $\Delta>0$ សមីការ $ax^2+bx+c=0$ , $a\neq 0$ មានឫស $x_1=\dfrac{-b-\sqrt{\Delta}}{2a}$ , $x_2=\dfrac{-b+\sqrt{\Delta}}{2a}$ ។

**គ. បង្ហាញថា បើ $\Delta=0$ សមីការមានឫសឌុប** $x_1=x_2=\dfrac{-b}{2a}$

គេមាន $x=\dfrac{-b\pm\sqrt{\Delta}}{2a}$ ជាឫសនៃសមីការ $ax^2+bx+c=0$ , $a\neq 0$

ចំពោះ $\Delta=0$ គេសរសេរបាន $x_1=\dfrac{-b-\sqrt{0}}{2a}=\dfrac{-b}{2a}$ , $x_2=\dfrac{-b+\sqrt{0}}{2a}=\dfrac{-b}{2a}$

ដូចនេះ: បើ $\Delta=0$ សមីការមានឫសឌុប $x_1=x_2=\dfrac{-b}{2a}$ ត្រូវបានបង្ហាញ ។

**ឃ. បង្ហាញថា បើ $\Delta<0$ សមីការមានឫសពីរជាចំនួនកុំផ្លិចឆ្លាស់គ្នា** $x_1=\dfrac{-b-i\sqrt{-\Delta}}{2a}$ , $x_2=\dfrac{-b+i\sqrt{-\Delta}}{2a}$

គេមាន $x=\dfrac{-b\pm\sqrt{\Delta}}{2a}$ ជាឫសនៃសមីការ $ax^2+bx+c=0$ , $a\neq 0$

ចំពោះ $\Delta<0$ គេសរសេរបាន

$$x_1=\frac{-b-\sqrt{-(-\Delta)}}{2a}=\frac{-b-\sqrt{(-1)(-\Delta)}}{2a}=\frac{-b-\sqrt{i^2\cdot(-\Delta)}}{2a}=\frac{-b-i\sqrt{-\Delta}}{2a}$$

$$x_2=\frac{-b+\sqrt{-(-\Delta)}}{2a}=\frac{-b+\sqrt{(-1)(-\Delta)}}{2a}=\frac{-b+\sqrt{i^2\cdot(-\Delta)}}{2a}=\frac{-b+i\sqrt{-\Delta}}{2a}$$

ព្រោះ គេត្រូវទុករ៉ាឌីកង់ឱ្យវិជ្ជមាន ហេតុនេះ $-\Delta$ ជាចំនួនវិជ្ជមាន ដោយសារតែ $\Delta<0$

ដូចនេះ: បើ $\Delta<0$ សមីការមានឫសពីរជាចំនួនកុំផ្លិចឆ្លាស់គ្នា $x_1=\dfrac{-b-i\sqrt{-\Delta}}{2a}$ , $x_2=\dfrac{-b+i\sqrt{-\Delta}}{2a}$ ។

10. **ក. ចំពោះសមីការ** $ax^2+bx+c=0$ , $a\neq 0$ **មាន** $b$ **ជាចំនួនគូ ដែល** $b=2b'$ **នោះ** $\Delta'=b'^2-ac$

គេមាន $ax^2+bx+c=0$ , $a\neq 0$ មានឫស $x=\dfrac{-b\pm\sqrt{b^2-4ac}}{2a}$

ក្នុងករណី $b=2b'$ នោះ $x=\dfrac{-2b'\pm\sqrt{(2b')^2-4ac}}{2a}=\dfrac{-2b'\pm\sqrt{4b'^2-4ac}}{2a}=\dfrac{-2b'\pm 2\sqrt{b'^2-ac}}{2a}=\dfrac{-b'\pm\sqrt{b'^2-ac}}{a}$

ដើម្បីសម្រួលរាងឱ្យងាយ គេតាង $\Delta'=b'^2-ac$ នោះគេបាន $x=\dfrac{-b'\pm\sqrt{\Delta'}}{a}$

ដូចនេះ | គេបាន $\Delta'=b'^2-ac$ ចំពោះ $b=2b'$ | ។

**ខ. បង្ហាញថា បើ** $\Delta'>0$ **សមីការមានឫសជាចំនួនពិតពីរផ្សេងគ្នា** $x_1=\dfrac{-b'-\sqrt{\Delta'}}{a}$ , $x_2=\dfrac{-b'+\sqrt{\Delta'}}{a}$

ក្នុងករណី $\Delta'=b'^2-ac$ គេមាន $x=\dfrac{-b'\pm\sqrt{\Delta'}}{a}$

ចំពោះ $\Delta'>0$ គេអាចសរសេរ $x_1=\dfrac{-b'-\sqrt{\Delta'}}{a}$ , $x_2=\dfrac{-b'+\sqrt{\Delta'}}{a}$

ដូចនេះ | បើ $\Delta'>0$ សមីការមានឫសជាចំនួនពិតពីរផ្សេងគ្នា $x_1=\dfrac{-b'-\sqrt{\Delta'}}{a}$ , $x_2=\dfrac{-b'+\sqrt{\Delta'}}{a}$ | ។

**គ. បង្ហាញថា បើ** $\Delta'=0$ **សមីការមានឫសឌុប** $x_1=x_2=\dfrac{-b'}{a}$

គេមាន $x=\dfrac{-b'\pm\sqrt{\Delta'}}{a}$

ចំពោះ $\Delta'=0$ គេសរសេរបាន $x_1=\dfrac{-b'-\sqrt{0}}{a}=\dfrac{-b'}{a}$ , $x_1=\dfrac{-b'+\sqrt{0}}{a}=\dfrac{-b'}{a}$

ដូចនេះ | បើ $\Delta'=0$ សមីការមានឫសឌុប $x_1=x_2=\dfrac{-b'}{a}$ ត្រូវបានបង្ហាញ | ។

**ឃ. បង្ហាញថា បើ** $\Delta'<0$ **សមីការមានឫសពីរជាចំនួនកុំផ្លិចឆ្លាស់គ្នា** $x_1=\dfrac{-b'-i\sqrt{-\Delta'}}{a}$ , $x_2=\dfrac{-b'+i\sqrt{-\Delta'}}{a}$

គេមាន $x=\dfrac{-b'\pm\sqrt{\Delta'}}{a}$

ចំពោះ $\Delta'<0$ គេសរសេរបាន

$$x_1=\frac{-b'-\sqrt{\Delta'}}{a}=\frac{-b'-\sqrt{-(-\Delta')}}{a}=\frac{-b'-\sqrt{(-1)(-\Delta')}}{a}=\frac{-b'-\sqrt{i^2\cdot(-\Delta')}}{a}=\frac{-b'-i\sqrt{-\Delta'}}{a}$$

$$x_2=\frac{-b'+\sqrt{\Delta'}}{a}=\frac{-b'+\sqrt{-(-\Delta')}}{a}=\frac{-b'+\sqrt{(-1)(-\Delta')}}{a}=\frac{-b'+\sqrt{i^2\cdot(-\Delta')}}{a}=\frac{-b'+i\sqrt{-\Delta'}}{a}$$

ព្រោះ គេត្រូវទុករ៉ាឌីកង់ឱ្យវិជ្ជមាន ហេតុនេះ $-\Delta'$ ជាចំនួនវិជ្ជមាន ដោយសារតែ $\Delta'<0$

ដូចនេះ | បើ $\Delta'<0$ សមីការមានឫសពីរជាចំនួនកុំផ្លិចឆ្លាស់គ្នា $x_1=\dfrac{-b'-i\sqrt{-\Delta'}}{a}$ , $x_2=\dfrac{-b'+i\sqrt{-\Delta'}}{a}$ | ។

11. **ចំពោះសមីការ** $ax^2+bx+c=0$ , $a\neq 0$ **មាន** $x_1$ **និង** $x_2$ **ជាឫស ៖**

**ក. បង្ហាញថា ផលបូកឫស** $S=x_1+x_2=\frac{-b}{a}$

គេមាន $x_1$ និង $x_2$ ជាឫសនៃសមីការ $ax^2+bx+c=0$ , $a\neq 0$

ដែល $x_1=\frac{-b-\sqrt{b^2-4ac}}{2a}$ , $x_2=\frac{-b+\sqrt{b^2-4ac}}{2a}$

គេបាន $x_1+x_2=\frac{-b-\sqrt{b^2-4ac}}{2a}+\frac{-b+\sqrt{b^2-4ac}}{2a}=\frac{-b-\sqrt{b^2-4ac}-b+\sqrt{b^2-4ac}}{2a}=\frac{-2b}{2a}=-\frac{b}{a}$

ដូចនេះ: ផលបូកឫស $S=x_1+x_2=\frac{-b}{a}$ ត្រូវបានបង្ហាញ ។ (គួរដឹងថា $S=\text{Sum}=$ផលបូក)

**ខ. បង្ហាញថា ផលគុណឫស** $P=x_1\cdot x_2=\frac{c}{a}$

គេមាន $x_1$ និង $x_2$ ជាឫសនៃសមីការ $ax^2+bx+c=0$ , $a\neq 0$

ដែល $x_1=\frac{-b-\sqrt{b^2-4ac}}{2a}$ , $x_2=\frac{-b+\sqrt{b^2-4ac}}{2a}$

គេបាន $x_1+x_2=\left(\frac{-b-\sqrt{b^2-4ac}}{2a}\right)\left(\frac{-b+\sqrt{b^2-4ac}}{2a}\right)=\frac{(-b)^2-\left(\sqrt{b^2-4ac}\right)^2}{4a^2}=\frac{b^2-b^2+4ac}{4a^2}=\frac{4ac}{4a^2}=\frac{c}{a}$

ដូចនេះ: ផលគុណឫស $P=x_1\cdot x_2=\frac{c}{a}$ ត្រូវបានបង្ហាញ ។ (គួរដឹងថា $P=\text{Product}=$ផលគុណ)

12. **ចំពោះសមីការ** $ax^2+bx+c=0$ , $a\neq 0$ **មាន** $x_1$ **និង** $x_2$ **ជាឫស**

**ក. បង្ហាញថា បើ** $a+b+c=0$ **នោះ** $x_1=1$ , $x_2=\frac{c}{a}$

គេមាន សមីការ $ax^2+bx+c=0$ , $a\neq 0$

គេឱ្យ $x_1=1$ នោះគេបាន $a\cdot 1^2+b\cdot 1+c=0$ ឬ $a+b+c=0$

ម្យ៉ាងទៀត $x_1\cdot x_2=\frac{c}{a}$ ឬ $1\cdot x_2=\frac{c}{a}$ នោះ $x_2=\frac{c}{a}$

ដូចនេះ: ចំពោះសមីការ $ax^2+bx+c=0$ , $a\neq 0$ បើ $a+b+c=0$ នោះ $x_1=1$ , $x_2=\frac{c}{a}$ ។

**ខ. បង្ហាញថា បើ** $a-b+c=0$ **នោះ** $x_1=-1$ , $x_2=-\frac{c}{a}$

គេមាន សមីការ $ax^2+bx+c=0$ , $a\neq 0$

គេឱ្យ $x_1=-1$ នោះគេបាន $a\cdot(-1)^2+b\cdot(-1)+c=0$ ឬ $a-b+c=0$

ម្យ៉ាងទៀត $x_1\cdot x_2=\frac{c}{a}$ ឬ $(-1)\cdot x_2=\frac{c}{a}$ នោះ $x_2=-\frac{c}{a}$

ដូចនេះ: ចំពោះសមីការ $ax^2+bx+c=0$ , $a\neq 0$ បើ $a-b+c=0$ នោះ $x_1=-1$ , $x_2=-\frac{c}{a}$ ។

13. **ចំពោះសមីការ** $ax^2+bx+c=0$ , $a\neq 0$ **មានឫសពីរផ្សេងគ្នាគឺ** $x_1$ **និង** $x_2$

**បង្ហាញថា គេអាចសរសេរកន្សោមដឺក្រេទី២ ជាផលគុណកត្តា** $ax^2+bx+c=a(x-x_1)(x-x_2)$

គេមាន សមីការ $ax^2+bx+c=0$ , $a\neq 0$ ដែល $x_1$ និង $x_2$ ជាឫស

គេបាន ទំនាក់ទំនងឫស និងមេគុណគឺ $x_1+x_2=\frac{-b}{a}$ , $x_1\cdot x_2=\frac{c}{a}$

ពិនិត្យ $ax^2+bx+c=a\left(x^2+\frac{b}{a}x+\frac{c}{a}\right)$

$$=a\left(x^2-\frac{-b}{a}x+\frac{c}{a}\right)$$

$$=a\left[x^2-(x_1+x_2)x+x_1x_2\right]$$

$$=a\left[x^2-x_1x-x_2x+x_1x_2\right]$$

$$=a\left[x(x-x_1)-x_2(x-x_1)\right]$$

$$=a(x-x_1)(x-x_2)$$

ដូចនេះ: | បើកន្សោមដឺក្រេទី២មានឫស $x_1$ និង $x_2$ នោះដាក់ជាផលគុណកត្តាបាន $ax^2+bx+c=a(x-x_1)(x-x_2)$ | ។

14. **បង្ហាញថា គេអាចបង្កើតបានសមីការដឺក្រេទី២** $x^2-Sx+P=0$

ដោយ $x_1$ និង $x_2$ ជាឫសនៃសមីការ

គេបាន $(x-x_1)(x-x_2)=0$

$$x^2-x_2x-x_1x+x_1x_2=0$$

$$x^2-(x_2+x_1)x+x_1x_2=0$$

$$x^2-Sx+P=0$$

ដូចនេះ: | គេអាចបង្កើតបានសមីការដឺក្រេទី២ $x^2-Sx+P=0$ បើស្គាល់ឫស $x_1$ , $x_2$ | ។

15. **ស្រាយបញ្ជាក់ទ្រឹស្តីបទសំណល់ ៖ សំណល់** $R=f(\alpha)$

គេមាន $R$ ជាសំណល់ក្នុងការចែកកន្សោមពហុធា $f(x)$ នឹង $x-\alpha$

គេតាង $q(x)$ ជាផលចែកនៃការចែកកន្សោមពហុធា $f(x)$ នឹង $x-\alpha$

នោះគេបាន ទំនាក់ទំនង $f(x)=(x-\alpha)q(x)+R$

ឬ $f(\alpha)=(\alpha-\alpha)q(\alpha)+R$ (បានពីជំនួស $x$ ដោយ $\alpha$)

$$f(\alpha)=R$$

ដូចនេះ: | $f(x)$ ចែកនឹង $x-\alpha$ បានសំណល់ $R$ ដែល $R=f(\alpha)$ ត្រូវបានស្រាយបញ្ជាក់ | ។

16. **ស្រាយបញ្ជាក់ទ្រឹស្តីបទកត្តា ៖ បើ $\alpha$ ជាចម្លើយនៃសមីការ $f(x)=0$ នោះ $x-\alpha$ ជាកត្តាមួយនៃ $f(x)$**

គេមាន $f(x)$ ជាពហុធា និង $\alpha$ ជាចម្លើយនៃសមីការ $f(x)=0$

គេតាង $q(x)$ ជាផលចែកនៃការចែកពហុធា $f(x)$ នឹង $x-\alpha$

នោះគេបាន ទំនាក់ទំនង $f(x)=(x-\alpha)q(x)+R$

ឬ $f(\alpha)=(\alpha-\alpha)q(\alpha)+R$

$f(\alpha)=R$

ដោយ $\alpha$ ជាចម្លើយនៃសមីការ $f(x)=0$ នោះ $f(\alpha)=0$

គេបាន $R=0$ មានន័យថា ពហុធា $f(x)$ ចែកដាច់នឹង $x-\alpha$

នាំឱ្យ $x-\alpha$ ជាកត្តាមួយនៃ $f(x)$

ដូចនេះ: | បើ $\alpha$ ជាចម្លើយនៃសមីការ $f(x)=0$ នោះ $x-\alpha$ ជាកត្តាមួយនៃ $f(x)$ | ។

17. **បង្ហាញថា $f(x)$ ចែកដាច់នឹង $ax+b$ ប្រសិនបើ $f\left(-\frac{b}{a}\right)=0$**

គេតាង $R$ ជាសំណល់ក្នុងការចែកកន្សោមពហុធា $f(x)$ នឹង $ax+b$

$q(x)$ ជាផលចែកនៃការចែកកន្សោមពហុធា $f(x)$ នឹង $ax+b$

នោះគេបាន ទំនាក់ទំនង $f(x)=(ax+b)q(x)+R$

ឬ $f\left(-\frac{b}{a}\right)=\left[a\cdot\left(-\frac{b}{a}\right)+b\right]q\left(-\frac{b}{a}\right)+R$ (បានពីជំនួស $x$ ដោយ $-\frac{b}{a}$)

$=(-b+b)q\left(-\frac{b}{a}\right)+R$

$=R$

តែគេឱ្យ $f\left(-\frac{b}{a}\right)=0$ នោះ សំណល់ $R=0$ មានន័យថា $f(x)$ ចែកដាច់នឹង $ax+b$

ដូចនេះ: | $f(x)$ ចែកដាច់នឹង $ax+b$ ប្រសិនបើ $f\left(-\frac{b}{a}\right)=0$ ត្រូវបានស្រាយបញ្ជាក់ | ។

# ការស្រាយបញ្ជាក់លើមេរៀន វិសមីការ

1. ចូរស្រាយបញ្ជាក់វិសមសភាពនៃត្រីកោណថា ៖
   -ផលបូករង្វាស់ជ្រុងពីរ ត្រូវធំជាងជ្រុងមួយទៀត ។
   -ផលដករង្វាស់ជ្រុងពីរ ត្រូវតូចជាងជ្រុងមួយទៀត ។
2. ក. បង្ហាញថា ទ្វេធា $f(x)=ax+b$ មានឫស $x=-\frac{b}{a}$ ។
   ខ. បង្ហាញថា បើ $x>-\frac{b}{a}$ នោះ $f(x)$ មានសញ្ញាដូច $a$ ។
   គ. បង្ហាញថា បើ $x<-\frac{b}{a}$ នោះ $f(x)$ មានសញ្ញាផ្ទុយ $a$ ។
3. ចំពោះសមីការ និងវិសមីការដឺក្រេទី១ដែលមានជាប់តម្លៃដាច់ខាត ហើយ $C>0$ ៖
   ក. បង្ហាញថា បើ $|Ax+B|=C$ នោះ $Ax+B=C$ ឬ $Ax+B=-C$ ។
   ខ. បង្ហាញថា បើ $|Ax+B|<C$ នោះ $-C<Ax+B<C$ ។
   គ. បង្ហាញថា បើ $|Ax+B|>C$ នោះ $Ax+B<-C$ ឬ $Ax+B>C$ ។
4. ស្រាយថា ត្រីធាដឺក្រេទី២ $f(x)=ax^2+bx+c$ ដែលមានឫស $\alpha$ និង $\beta$ ហើយ $\alpha<\beta$ មាន ៖
   -សញ្ញាផ្ទុយ $a$ កាលណា $\alpha<x<\beta$ (មានន័យថានៅចន្លោះឫស) ។
   -សញ្ញាដូច $a$ កាលណា $x<\alpha$ ឬ $x>\beta$ (មានន័យថានៅក្រៅឫស) ។
5. ក. ស្រាយថា ត្រីធាដឺក្រេទី២ $f(x)=ax^2+bx+c$ , $a\neq 0$ ដែល $\Delta<0$ មានសញ្ញាដូច $a$ ជានិច្ច ។
   ខ. ស្រាយថា ត្រីធាដឺក្រេទី២ $f(x)=ax^2+bx+c$ , $a\neq 0$ ដែល $\Delta=0$ មានសញ្ញាដូច $a$ លើកលែងតែត្រង់ $x=-\frac{b}{2a}$ ។
6. ចូរបង្ហាញវិសមភាពខាងក្រោម ៖
   ក. $a^2+b^2\geq ab$ ខ. $a^2+ab+b^2\geq 0$
   គ. $5x^2-4xy+6y^2\geq 0$ ឃ. $(a^2+b^2)(x^2+y^2)\geq(ax+by)^2$ ។
7. ក. ចំពោះ $a>0$ , $b>0$ បង្ហាញថា $\sqrt{a}+\sqrt{b}>\sqrt{a+b}$ ។
   ខ. បង្ហាញវិសមភាព $\sqrt{a}-\sqrt{b}<\sqrt{a-b}$ ចំពោះ $a>b>0$ ។
   គ. បង្ហាញថា ចំពោះ $a\geq 0$ , $b\geq 0$ នោះ $\frac{a+b}{2}\geq\sqrt{ab}$ (មធ្យមនព្វន្ត និងមធ្យមធរណីមាត្រ) ។

# ការស្រាយបញ្ជាក់លើមេរៀន វិសមីការ

1. **➢ស្រាយបញ្ជាក់វិសមសភាពនៃត្រីកោណ ៖ ផលបូករង្វាស់ជ្រុងពីរ ត្រូវធំជាងជ្រុងមួយទៀត**

ណែនាំ : គេមិនមែនចេះតែសង់ត្រីកោណបានគ្រប់ករណីនោះទេ ។
ដូចជា ត្រីកោណដែលមានជ្រុង 3cm , 6cm , 10cm
គេមិនអាចសង់ត្រីកោណដែលមានជ្រុងបែបនេះបានទេ ។
ដូចនេះ ជ្រុងនៃត្រីកោណត្រូវមានលក្ខខណ្ឌកំណត់ច្បាស់លាស់ ។




ឧបមាថា គេមានត្រីកោណ $ABC$ បន្លាយជ្រុង $BC$ ឱ្យបាន $CM = CA$ ។

គេមាន $\angle BAM = \angle BAC + \angle CAM$ នោះ $\angle BAM > \angle CAM \quad (1)$

ដោយ $\Delta ACM$ មាន $CM = CA$ នោះ $\Delta ACM$ ជាត្រីកោណសមបាត
កំពូល $C$ នាំឱ្យ $\angle CAM = \angle CMA$




គេបាន $(1)$ $\angle BAM > \angle CMA$ អាចសរសេរ $\angle BAM > \angle BMA$

ក្នុង $\Delta BAM$ មាន $\angle BAM > \angle BMA$ គេបាន $BM > AB$

ដោយ $BM = BC + CM = BC + CA$ ព្រោះ $CM = CA$

គេបាន $BC + CA > AB$ ឬ $BC + AC > AB$ ។

តាមលំនាំដូចគ្នាខាងលើនេះ គេក៏អាចស្រាយបានថា $AB + AC > BC$ និង $AB + BC > AC$

ដូចនេះ | ក្នុងត្រីកោណមួយ ផលបូករង្វាស់ជ្រុងពីរ ត្រូវធំជាងជ្រុងមួយទៀត ត្រូវបានស្រាយបញ្ជាក់ | ។

**➢ស្រាយបញ្ជាក់វិសមសភាពនៃត្រីកោណ ៖ ផលដករង្វាស់ជ្រុងពីរ ត្រូវតូចជាងជ្រុងមួយទៀត**

ឧបមាថា ត្រីកោណ $ABC$ មានរង្វាស់ជ្រុង $AB > AC > BC$

តាមរយៈ សម្រាយខាងលើ ក្នុងត្រីកោណមួយ ផលបូករង្វាស់ជ្រុងពីរ ត្រូវធំជាងជ្រុងមួយទៀត

គេបាន $\begin{cases} AB + BC > AC & (1) \\ AC + BC > AB & (2) \\ AB + AC > BC & (3) \end{cases}$

តាម $(1)$ $AB > AC - BC$

តាម $(2)$ $AC > AB - BC$

តាម $(2)$ $BC > AB - AC$

(ក្នុងត្រីកោណមួយ : ជ្រុងវែងជាងគេ ដកជ្រុងខ្លី ត្រូវតូចជាងជ្រុងមួយទៀត)

ដូចនេះ | ក្នុងត្រីកោណមួយ ផលដករង្វាស់ជ្រុងពីរ ត្រូវតូចជាងជ្រុងមួយទៀត ត្រូវបានស្រាយបញ្ជាក់ | ។

លំហាត់ស្រួលយ៉ាងណាក៏ដោយ តែបើយើងមិនចេះគឺវាលំបាក ។

លំហាត់ដែលខ្ញុំដោះស្រាយបាន គឺជាលំហាត់ដែលខ្ញុំធ្លាប់ជួប ឬមានលំនាំដូចលំហាត់ធ្លាប់ជួប ឬបំបែកគំនិតពីលំហាត់ធ្លាប់ជួប ឬ ... ។

2. **ក. បង្ហាញថា ទ្វេធា $f(x)=ax+b$ មានឫស $x=-\dfrac{b}{a}$**

ដើម្បីរកឫសនៃទ្វេធា $f(x)=ax+b$ គេត្រូវឱ្យ $f(x)=0$

សមមូល $ax+b=0 \Rightarrow x=-\dfrac{b}{a}$ ជាឫស ដែល $a\neq 0$

ដូចនេះ: ទ្វេធា $f(x)=ax+b$ មានឫស $x=-\dfrac{b}{a}$ ត្រូវបានបង្ហាញ ។

**ខ. បង្ហាញថា បើ $x>-\dfrac{b}{a}$ នោះ $f(x)$ មានសញ្ញាដូច $a$ (មានន័យថា ខាងស្តាំឫស មានសញ្ញាដូច $a$)**

គេមាន $x>-\dfrac{b}{a}$ (1) ដែល $a\neq 0$ គេនឹងបង្ហាញថា $f(x)$ មានសញ្ញាដូច $a$ គ្រប់ករណីនៃ $a$

-បើ $a>0$ នោះ $(1): ax>-b$ សមមូល $ax+b>0$ ឬ $f(x)>0$

មានន័យថា បើ $a$ មានសញ្ញា $+$ នោះ ទ្វេធា $f(x)$ ក៏មានសញ្ញា $+$ ដែរ ។

-បើ $a<0$ នោះ $(1): ax<-b$ សមមូល $ax+b<0$ ឬ $f(x)<0$

មានន័យថា បើ $a$ មានសញ្ញា $-$ នោះ ទ្វេធា $f(x)$ ក៏មានសញ្ញា $-$ ដែរ ។

ឃើញថា គ្រប់ករណីនៃ $a\neq 0$ នោះ $f(x)$ មានសញ្ញាដូច $a$

ដូចនេះ: បើ $x>-\dfrac{b}{a}$ នោះ $f(x)$ មានសញ្ញាដូច $a$ ត្រូវបានបង្ហាញ ។

**គ. បង្ហាញថា បើ $x<-\dfrac{b}{a}$ នោះ $f(x)$ មានសញ្ញាផ្ទុយ $a$ (មានន័យថា ខាងឆ្វេងឫស មានសញ្ញាផ្ទុយ $a$)**

គេមាន $x<-\dfrac{b}{a}$ (1) ដែល $a\neq 0$ គេនឹងបង្ហាញថា $f(x)$ មានសញ្ញាផ្ទុយ $a$ គ្រប់ករណីនៃ $a$

-បើ $a>0$ នោះ $(1): ax<-b$ សមមូល $ax+b<0$ ឬ $f(x)<0$

មានន័យថា បើ $a$ មានសញ្ញា $+$ នោះ ទ្វេធា $f(x)$ មានសញ្ញា $-$ ជាសញ្ញាផ្ទុយ $a$ ។

-បើ $a<0$ នោះ $(1): ax>-b$ សមមូល $ax+b>0$ ឬ $f(x)>0$

មានន័យថា បើ $a$ មានសញ្ញា $-$ នោះ ទ្វេធា $f(x)$ មានសញ្ញា $+$ ជាសញ្ញាផ្ទុយ $a$ ។

ឃើញថា គ្រប់ករណីនៃ $a\neq 0$ នោះ $f(x)$ មានសញ្ញាផ្ទុយ $a$

ដូចនេះ: បើ $x<-\dfrac{b}{a}$ នោះ $f(x)$ មានសញ្ញាផ្ទុយ $a$ ត្រូវបានបង្ហាញ ។

3. ចំពោះសមីការ និងវិសមីការដឺក្រេទី១ដែលមានជាប់តម្លៃដាច់ខាត ហើយ $C>0$ ៖

**ក. បង្ហាញថា បើ $|Ax+B|=C$ នោះ $Ax+B=C$ ឬ $Ax+B=-C$**

តាមលក្ខណៈ: $|x|=\begin{cases} x & \text{បើ } x\ge 0 \\ -x & \text{បើ } x<0 \end{cases}$ គេនឹងបង្ហាញថា បើ $|Ax+B|=C$ $(1)$ នោះ $Ax+B=C$ ឬ $Ax+B=-C$

-ក្នុងករណី $Ax+B>0$ នោះគេបាន $|Ax+B|=Ax+B$

នាំឱ្យ $(1)$ ទៅជា $Ax+B=C$ $(i)$

-ក្នុងករណី $Ax+B<0$ នោះគេបាន $|Ax+B|=-(Ax+B)$

នាំឱ្យ $(1)$ ទៅជា $-(Ax+B)=C$ សមមូល $Ax+B=-C$ $(ii)$

តាមរយៈ $(i)$ និង $(ii)$ គេបាន $Ax+B=C$ ឬ $Ax+B=-C$

ដូចនេះ បើ $|Ax+B|=C$ នោះ $Ax+B=C$ ឬ $Ax+B=-C$ ត្រូវបានបង្ហាញ ។

**ខ. បង្ហាញថា បើ $|Ax+B|<C$ នោះ $-C<Ax+B<C$**

តាមលក្ខណៈ: $|x|=\begin{cases} x & \text{បើ } x\ge 0 \\ -x & \text{បើ } x<0 \end{cases}$ គេនឹងបង្ហាញថា បើ $|Ax+B|<C$ $(1)$ នោះ $-C<Ax+B<C$

-ក្នុងករណី $Ax+B>0$ នោះគេបាន $|Ax+B|=Ax+B$

នាំឱ្យ $(1)$ ទៅជា $Ax+B<C$ $(i)$

-ក្នុងករណី $Ax+B<0$ នោះគេបាន $|Ax+B|=-(Ax+B)$

នាំឱ្យ $(1)$ ទៅជា $-(Ax+B)<C$ សមមូល $Ax+B>-C$ $(ii)$

តាមរយៈ $(i)$ និង $(ii)$ គេអាចសរសេរបាន $-C<Ax+B<C$

ដូចនេះ បើ $|Ax+B|<C$ នោះ $-C<Ax+B<C$ ត្រូវបានបង្ហាញ ។

**គ. បង្ហាញថា $|Ax+B|>C$ នោះ $Ax+B<-C$ ឬ $Ax+B>C$**

តាមលក្ខណៈ: $|x|=\begin{cases} x & \text{បើ } x\ge 0 \\ -x & \text{បើ } x<0 \end{cases}$ គេនឹងបង្ហាញថា បើ $|Ax+B|>C$ $(1)$ នោះ $Ax+B<-C$ ឬ $Ax+B>C$

-ក្នុងករណី $Ax+B>0$ នោះគេបាន $|Ax+B|=Ax+B$

នាំឱ្យ $(1)$ ទៅជា $Ax+B>C$ $(i)$

-ក្នុងករណី $Ax+B<0$ នោះគេបាន $|Ax+B|=-(Ax+B)$

នាំឱ្យ $(1)$ ទៅជា $-(Ax+B)>C$ សមមូល $Ax+B<-C$ $(ii)$

តាមរយៈ $(i)$ និង $(ii)$ គេបាន $Ax+B>C$ ឬ $Ax+B<-C$

ដូចនេះ បើ $|Ax+B|>C$ នោះ $Ax+B<-C$ ឬ $Ax+B>C$ ត្រូវបានបង្ហាញ ។

✓**សម្គាល់** : ហេតុអ្វីបានជាគេមិនឱ្យករណី $Ax+B=0$ ? ព្រោះថា អង្គទីពីរ $C>0$ បើគេឱ្យ $Ax+B=0$ ជាករណីមិនអាចមាន ។

4. **ស្រាយថា ត្រីធាដឺក្រេទី២ $f(x)=ax^2+bx+c$ ដែលមានឫស $\alpha$ និង $\beta$ ហើយ $\alpha<\beta$ មាន ៖**

**-សញ្ញាផ្ទុយ $a$ កាលណា $\alpha<x<\beta$ (មានន័យថានៅចន្លោះឫស)**

**-សញ្ញាដូច $a$ កាលណា $x<\alpha$ ឬ $x>\beta$ (មានន័យថានៅក្រៅឫស)**

គេមាន បើ $f(x)=ax^2+bx+c$ ដែលមាន $\alpha$ និង $\beta$ ជាឫស

នោះគេបាន $f(x)=a(x-\alpha)(x-\beta)$ (បានស្រាយបញ្ជាក់រួចក្នុងមេរៀនសមីការ លំហាត់លេខ ១៣)

នាំឱ្យ $f(x)$ មានសញ្ញា $a(x-\alpha)(x-\beta)$

តារាងសញ្ញា នៃ $a(x-\alpha)(x-\beta)$

| $x$ | $-\infty$ | $\alpha$ | $\beta$ | $+\infty$ |
|---|---|---|---|---|
| $x-\alpha$ | $-$ | 0 | $+$ | $+$ |
| $x-\beta$ | $-$ | | $-$ 0 | $+$ |
| $a$ | $a$ | | $a$ | $a$ |
| $f(x)=a(x-\alpha)(x-\beta)$ | សញ្ញាដូច $a$ | 0 | សញ្ញាផ្ទុយ $a$ 0 | សញ្ញាដូច $a$ |

តាមតារាងសញ្ញា គេសន្និដ្ឋានបានថា ៖

-ត្រីធា $f(x)$ មានសញ្ញាផ្ទុយ $a$ កាលណា $\alpha<x<\beta$ (មានន័យថានៅចន្លោះឫស)

-ត្រីធា $f(x)$ មានសញ្ញាដូច $a$ កាលណា $x<\alpha$ ឬ $x>\beta$ (មានន័យថានៅក្រៅឫស)

ដូចនេះ:
-ត្រីធា $f(x)$ មានសញ្ញាផ្ទុយ $a$ កាលណា $\alpha<x<\beta$ (មានន័យថានៅចន្លោះឫសមានសញ្ញាផ្ទុយ $a$)
-ត្រីធា $f(x)$ មានសញ្ញាដូច $a$ កាលណា $x<\alpha$ ឬ $x>\beta$ (មានន័យថានៅក្រៅឫសមានសញ្ញាដូច $a$ ) ។

5. **ក. ស្រាយថា ត្រីធាដឺក្រេទី២ $f(x)=ax^2+bx+c$ , $a\neq 0$ ដែល $\Delta<0$ មានសញ្ញាដូច $a$ ជានិច្ច**

គេមាន
$$f(x)=ax^2+bx+c=a\left(x^2+\frac{b}{a}x+\frac{c}{a}\right)$$
$$=a\left(x^2+2\cdot x\cdot\frac{b}{2a}+\frac{c}{a}\right)$$
$$=a\left[x^2+2\cdot x\cdot\frac{b}{2a}+\left(\frac{b}{2a}\right)^2-\left(\frac{b}{2a}\right)^2+\frac{c}{a}\right]$$
$$=a\left[\left(x+\frac{b}{2a}\right)^2-\frac{b^2}{4a}+\frac{c}{a}\right]=a\left[\left(x+\frac{b}{2a}\right)^2-\frac{b^2-4ac}{4a^2}\right]$$

ដោយ $\Delta<0$ នោះ $b^2-4ac<0$ និង $4a^2>0$ នាំឱ្យ $\frac{b^2-4ac}{4a^2}<0$ សមមូល $-\frac{b^2-4ac}{4a^2}>0$

ម្យ៉ាងទៀត $\left(x+\frac{b}{2a}\right)^2\geq 0$ នោះកន្សោម $\left[\left(x+\frac{b}{2a}\right)^2-\frac{b^2-4ac}{4a^2}\right]>0$

គេបាន $f(x)=a\left[\left(x+\frac{b}{2a}\right)^2-\frac{b^2-4ac}{4a^2}\right]$ មានសញ្ញាដូច $a$ ជានិច្ច

ដូចនេះ: ត្រីធាដឺក្រេទី២ $f(x)=ax^2+bx+c$ , $a\neq 0$ ដែល $\Delta<0$ មានសញ្ញាដូច $a$ ជានិច្ច ត្រូវបានបង្ហាញ ។

ខ. ស្រាយថា ត្រីធាដឺក្រេទី២ $f(x)=ax^2+bx+c$ , $a\neq 0$ ដែល $\Delta=0$ មានសញ្ញាដូច $a$ លើកលែងតែត្រង់ $x=-\dfrac{b}{2a}$

គេមាន $f(x)=ax^2+bx+c=a\left(x^2+\dfrac{b}{a}x+\dfrac{c}{a}\right)$

$$=a\left(x^2+2\cdot x\cdot\frac{b}{2a}+\frac{c}{a}\right)$$

$$=a\left[x^2+2\cdot x\cdot\frac{b}{2a}+\left(\frac{b}{2a}\right)^2-\left(\frac{b}{2a}\right)^2+\frac{c}{a}\right]$$

$$=a\left[\left(x+\frac{b}{2a}\right)^2-\frac{b^2}{4a}+\frac{c}{a}\right]$$

$$=a\left[\left(x+\frac{b}{2a}\right)^2-\frac{b^2-4ac}{4a^2}\right]$$

ដោយ $\Delta=0$ នោះ $b^2-4ac=0$ និង $4a^2\neq 0$ នាំឱ្យ $\dfrac{b^2-4ac}{4a^2}=0$

គេបាន $f(x)=a\left(x+\dfrac{b}{2a}\right)^2$

ដោយ $\left(x+\dfrac{b}{2a}\right)^2>0$ លើកលែងតែ $x=-\dfrac{b}{2a}$

នាំឱ្យ $f(x)=a\left(x+\dfrac{b}{2a}\right)^2$ មានសញ្ញាដូច $a$ លើកលែងតែត្រង់ $x=-\dfrac{b}{2a}$

ដូចនេះ: ត្រីធាដឺក្រេទី២ $f(x)=ax^2+bx+c$ ដែល $\Delta=0$ មានសញ្ញាដូច $a$ លើកលែងតែត្រង់ $x=-\dfrac{b}{2a}$ ។

6. **បង្ហាញវិសមភាពខាងក្រោម ៖**

**ក. បង្ហាញថា** $a^2+b^2\geq ab$

គេមាន $a^2+b^2\geq ab$

$$a^2-ab+b^2\geq 0$$

$$a^2-ab+\left(\frac{b}{2}\right)^2-\left(\frac{b}{2}\right)^2+b^2\geq 0$$

$$\left(a-\frac{b}{2}\right)^2-\frac{b^2}{4}+b^2\geq 0$$

$$\left(a-\frac{b}{2}\right)^2+\frac{3}{4}b^2\geq 0$$

ដោយ $\left(a-\dfrac{b}{2}\right)^2\geq 0$ និង $\dfrac{3}{4}b^2\geq 0$ នោះគេបាន $\left(a-\dfrac{b}{2}\right)^2+\dfrac{3}{4}b^2\geq 0$

ដូចនេះ: គេបង្ហាញបានថា $a^2+b^2\geq ab$ ។

ខ. បង្ហាញថា $a^2+ab+b^2\geq 0$

គេមាន $a^2+ab+b^2\geq 0$

$$a^2+ab+\left(\frac{b}{2}\right)^2-\left(\frac{b}{2}\right)^2+b^2\geq 0$$

$$\left(a+\frac{b}{2}\right)^2-\frac{b^2}{4}+b^2\geq 0$$

$$\left(a+\frac{b}{2}\right)^2+\frac{3}{4}b^2\geq 0$$

ដោយ $\left(a+\frac{b}{2}\right)^2\geq 0$ និង $\frac{3}{4}b^2\geq 0$ នោះគេបាន $\left(a+\frac{b}{2}\right)^2+\frac{3}{4}b^2\geq 0$

ដូចនេះ **គេបង្ហាញបានថា $a^2+ab+b^2\geq 0$** ។

គ. បង្ហាញថា $5x^2-4xy+6y^2\geq 0$

គេមាន $5x^2-4xy+6y^2\geq 0$

$$5x^2-4xy+6y^2\geq 0$$

$$x^2-4xy+4y^2+4x^2+2y^2\geq 0$$

$$(x-2y)^2+4x^2+2y^2\geq 0$$

ដោយ $(x-2y)^2\geq 0$ , $4x^2\geq 0$ , $2y^2\geq 0$

នាំឱ្យ ផលបូក $(x-2y)^2+4x^2+2y^2\geq 0$ ជារឿងត្រឹមត្រូវ

ដូចនេះ **កន្សោម $5x^2-4xy+6y^2\geq 0$ ត្រូវបានបង្ហាញ** ។

ឃ. បង្ហាញថា $(a^2+b^2)(x^2+y^2)\geq(ax+by)^2$

គេមាន $(a^2+b^2)(x^2+y^2)\geq(ax+by)^2$

$$a^2x^2+a^2y^2+b^2x^2+b^2y^2\geq a^2x^2+2axby+b^2y^2$$

$$a^2y^2+b^2x^2\geq 2axby$$

$$a^2y^2-2axby+b^2x^2\geq 0$$

$$(ay)^2-2\cdot ay\cdot bx+(bx)^2\geq 0$$

$(ay+bx)^2\geq 0$ ពិតគ្រប់ករណីនៃ $a$ , $b$ , $x$ និង $y$ ជាចំនួនពិត

ដូចនេះ **កន្សោម $(a^2+b^2)(x^2+y^2)\geq(ax+by)^2$ ត្រូវបានបង្ហាញ** ។

☞ **ហេតុអ្វីបានជា $x^2\geq 0$ គ្រប់ $x$ ចំនួនពិត ?** ព្រោះ

បើ $x<0$ នោះ $x^2>0$ ពិត
បើ $x=0$ នោះ $x^2=0$ ពិត
បើ $x>0$ នោះ $x^2>0$ ពិត

នាំឱ្យ $x^2\geq 0$ ពិតគ្រប់ $x$ ចំនួនពិត

7. **ក. ចំពោះ** $a>0$ , $b>0$ **បង្ហាញថា** $\sqrt{a}+\sqrt{b}>\sqrt{a+b}$

គេមាន $\sqrt{a}+\sqrt{b}>\sqrt{a+b}$ (លើកអង្គទាំងពីរជាការេ មិនប្តូរទិសដៅ ព្រោះ $a>0$ , $b>0$ )

គេបាន $\left(\sqrt{a}+\sqrt{b}\right)^2>\left(\sqrt{a+b}\right)^2$

$a+2\sqrt{ab}+b>a+b$

$2\sqrt{ab}>0$

$\sqrt{ab}>0$

$ab>0$

ដោយ $a>0$ , $b>0$ នាំឱ្យ $ab>0$ ជារឿងពិត

ដូចនេះ: $\sqrt{a}+\sqrt{b}>\sqrt{a+b}$ ចំពោះ $a>0$ , $b>0$ ត្រូវបានបង្ហាញ ។

**ខ. បង្ហាញវិសមភាព** $\sqrt{a}-\sqrt{b}<\sqrt{a-b}$ **ចំពោះ** $a>b>0$

គេមាន $\sqrt{a}-\sqrt{b}<\sqrt{a-b}$ (លើកអង្គទាំងពីរជាការេ មិនប្តូរទិសដៅ ព្រោះ $a>b>0$ )

គេបាន $\left(\sqrt{a}-\sqrt{b}\right)^2<\left(\sqrt{a-b}\right)^2$

$a-2\sqrt{ab}+b<a-b$

$2b<2\sqrt{ab}$

$b<\sqrt{ab}$

$b<a$

ដោយ គេមាន $a>b>0$ នាំឱ្យ $b<a$ ជារឿងពិត

ដូចនេះ: $\sqrt{a}-\sqrt{b}<\sqrt{a-b}$ ចំពោះ: $a>b>0$ ត្រូវបានបង្ហាញ ។

**គ. បង្ហាញថា ចំពោះ** $a\ge 0$ , $b\ge 0$ **នោះ** $\frac{a+b}{2}\ge\sqrt{ab}$ **(មធ្យមនព្វន្ត និងមធ្យមធរណីមាត្រ)**

គេមាន $\frac{a+b}{2}\ge\sqrt{ab}$

គេបាន $a+b\ge 2\sqrt{ab}$

$a-2\sqrt{ab}+b\ge 0$

$\sqrt{a^2}-2\sqrt{a}\cdot\sqrt{b}+\sqrt{b^2}\ge 0$

$\left(\sqrt{a}-\sqrt{b}\right)^2\ge 0$

ដោយ $a\ge 0$ , $b\ge 0$ នាំឱ្យ $\left(\sqrt{a}-\sqrt{b}\right)^2\ge 0$ ពិត

ដូចនេះ: $\frac{a+b}{2}\ge\sqrt{ab}$ ចំពោះ: $a\ge 0$ , $b\ge 0$ ត្រូវបានបង្ហាញ ។

# ការស្រាយបញ្ជាក់លើមេរៀន ធរណីមាត្រក្នុងប្លង់

1. ស្រាយបញ្ជាក់ថា ចម្ងាយរវាងពីរចំណុច $A(a)$ និង $B(b)$ នៅលើបន្ទាត់មួយកំណត់ដោយ $AB=|b-a|=|a-b|$ ។
2. គេមានចំណុច $A(a)$ និង $B(b)$ នៅលើបន្ទាត់មួយ ។ ស្រាយបញ្ជាក់ថា បើចំណុច $P(x)$ ចែកអង្កត់ $AB$ ខាងក្នុងតាមផលធៀប $m:n$ នោះ $x=\dfrac{mb+na}{m+n}$ ។
3. គេមានចំណុច $A(a)$ និង $B(b)$ នៅលើបន្ទាត់មួយ ។ ស្រាយបញ្ជាក់ថា បើចំណុច $Q(x)$ ចែកអង្កត់ $AB$ ខាងក្រៅតាមផលធៀប $m:n$ នោះ $x=\dfrac{mb-na}{m-n}$ ។
4. ស្រាយបញ្ជាក់ថា ចម្ងាយរវាងពីចំណុច $A(x_1\ ,\ y_1)$ និង $B(x_2\ ,\ y_2)$ គឺ $AB=\sqrt{(x_2-x_1)^2+(y_2-y_1)^2}$ ។
5. បើគេមានពីរចំណុច $A(x_a\ ,\ y_a)$ និង $B(x_b\ ,\ y_b)$ ជាពីរចំណុចក្នុងតម្រុយកូអរដោនេ ។

   ក. ស្រាយបញ្ជាក់ថា បើចំណុច $P(x\ ,\ y)$ ចែកអង្កត់ $AB$ ខាងក្នុងតាមផលធៀប $m:n$ នោះ $P\left(\dfrac{mx_b+nx_a}{m+n}\ ,\ \dfrac{my_b+ny_a}{m+n}\right)$ ។

   ខ. ស្រាយបញ្ជាក់ថា បើចំណុច $Q(x\ ,\ y)$ ចែកអង្កត់ $AB$ ខាងក្រៅតាមផលធៀប $m:n$ នោះ $Q\left(\dfrac{mx_b-nx_a}{m-n}\ ,\ \dfrac{my_b-ny_a}{m-n}\right)$ ។
6. ស្រាយបញ្ជាក់ថា សមីការបន្ទាត់កាត់តាមចំណុច $A(x_1\ ,\ y_1)$ និងមានមេគុណប្រាប់ទិស $m$ គឺ $y-y_1=m(x-x_1)$ ។
7. ស្រាយបញ្ជាក់ថា សមីការបន្ទាត់កាត់តាមពីរចំណុច $A(x_1, y_1)$ និង $B(x_2, y_2)$ គឺ $y-y_1=\dfrac{y_2-y_1}{x_2-x_1}(x-x_1)$ ដែល $x_1\neq x_2$ ។
8. ស្រាយបញ្ជាក់ថា បន្ទាត់ពីរស្របគ្នា លុះត្រាតែវាមានមេគុណប្រាប់ទិសស្មើគ្នា ។
9. ស្រាយបញ្ជាក់ថា បន្ទាត់ពីរកែងគ្នា លុះត្រាតែផលគុណមេគុណប្រាប់ទិសនៃបន្ទាត់ទាំងពីរស្មើ $-1$ ។
10. ស្រាយបញ្ជាក់ថា ចម្ងាយ $d$ រវាងចំណុច $P(x_1\ ,\ y_1)$ និងបន្ទាត់ $L: ax+by+c=0$ គឺ $d=\dfrac{|ax_1+by_1+c|}{\sqrt{a^2+b^2}}$ ។
11. ក. បង្ហាញថា មេដ្យានដែលគូសចេញពីកំពូលនៃមុំកែងស្មើនឹងពាក់កណ្ដាលអ៊ីប៉ូតេនុស ។

    ខ. បង្ហាញថា អង្កត់ទ្រូងនៃចតុកោណស្មើកែងគ្នា ។
12. ក. ស្រាយបញ្ជាក់ថា សមីការស្ដង់ដានៃរង្វង់ដែលមានផ្ចិត $I(a\ ,\ b)$ និងកាំ $r$ គឺ $(x-a)^2+(y-b)^2=r^2$ ។

    ខ. ស្រាយបញ្ជាក់ថា សមីការទូទៅនៃរង្វង់មានរាង $x^2+y^2+Ax+By+C=0$ ដែល $A\ ,\ B\ ,\ C$ ជាចំនួនថេរ ។
13. ក. ស្រាយបញ្ជាក់ថា សមីការបន្ទាត់ប៉ះនឹងរង្វង់ $x^2+y^2=r^2$ ត្រង់ចំណុច $(x_0\ ,\ y_0)$ គឺ $x_0x+y_0y=r^2$ ។

    ខ. ស្រាយបញ្ជាក់ថា សមីការបន្ទាត់ប៉ះនឹងរង្វង់ $(x-a)^2+(y-b)^2=r^2$ ត្រង់ចំណុច $(x_0\ ,\ y_0)$ គឺ

    $(x_0-a)(x-a)+(y_0-b)(y-b)=r^2$ ។

# ការស្រាយបញ្ជាក់លើមេរៀន ធរណីមាត្រក្នុងប្លង់

1. **ស្រាយបញ្ជាក់ថា ចម្ងាយរវាងពីរចំណុច $A(a)$ និង $B(b)$ នៅលើបន្ទាត់មួយកំណត់ដោយ $AB=|b-a|=|a-b|$**

ចម្ងាយរវាងពីរចំណុច គឺជាតម្លៃមិនអវិជ្ជមាន

គេដឹងថា នៅលើបន្ទាត់ចំនួន ចំនួនដែលនៅខាងស្តាំ ត្រូវធំជាងចំនួនដែលនៅខាងឆ្វេង

ហើយទីតាំងរវាងពីចំណុច $A(a)$ និង $B(b)$ វាអាច $A$ នៅខាងស្តាំ $B$ ឬក៏ អាច $B$ នៅខាងស្តាំ $A$

-ករណី $A$ នៅខាងស្តាំ $B$ នោះចម្ងាយ $AB=a-b$ (ព្រោះ $a>b$ ដែលធ្វើឱ្យ $AB=a-b>0$)

-ករណី $B$ នៅខាងស្តាំ $A$ នោះចម្ងាយ $AB=b-a$ (ព្រោះ $b>a$ ដែលធ្វើឱ្យ $AB=b-a>0$)

ដើម្បីឱ្យប្រាកដថា $AB$ គឺជាតម្លៃមិនអវិជ្ជមាន គេបំពាក់តម្លៃដាច់ខាត

គេបាន $AB=|b-a|=|a-b|$

ដូចនេះ | ចម្ងាយរវាងពីរចំណុច $A(a)$ និង $B(b)$ នៅលើបន្ទាត់មួយកំណត់ដោយ $AB=|b-a|=|a-b|$ | ។

2. **ស្រាយបញ្ជាក់ថា បើចំណុច $P(x)$ ចែកអង្កត់ $AB$ ខាងក្នុងតាមផលធៀប $m:n$ នោះ $x=\dfrac{mb+na}{m+n}$**

គេមាន ចំណុច $A(a)$ និង $B(b)$ នៅលើបន្ទាត់មួយ និងចំណុចចែកក្នុង $P(x)$

ផលធៀប ចែកក្នុង $m:n$ មានន័យថា $AP:PB=m:n$ អាចសរសេរ $\dfrac{AP}{m}=\dfrac{PB}{n}$

➢ ករណី $a<b$ នោះ $a<x<b$ ព្រោះ $P$ នៅក្នុងអង្កត់ $AB$

នាំឱ្យ $AP=x-a$ , $PB=b-x$

គេបាន $\dfrac{x-a}{m}=\dfrac{b-x}{n} \Leftrightarrow nx-na=mb-mx$

$$mx+nx=mb+na$$
$$(m+n)x=mb+na$$
$$x=\frac{mb+na}{m+n}$$




ដូចនេះ | បើចំណុច $P(x)$ ចែកអង្កត់ $AB$ ខាងក្នុងតាមផលធៀប $m:n$ នោះ $x=\dfrac{mb+na}{m+n}$ | ។

➢ ករណី $a>b$ នោះ $a>x>b$ ព្រោះ $P$ នៅក្នុងអង្កត់ $AB$

នាំឱ្យ $AP=a-x$ , $PB=x-b$

គេបាន $\dfrac{a-x}{m}=\dfrac{x-b}{n} \Leftrightarrow na-nx=mx-mb$

$$mb+na=mx+nx$$
$$mb+na=(m+n)x$$
$$x=\frac{mb+na}{m+n}$$




ដូចនេះ | បើចំណុច $P(x)$ ចែកអង្កត់ $AB$ ខាងក្នុងតាមផលធៀប $m:n$ នោះ $x=\dfrac{mb+na}{m+n}$ | ។

3. **ស្រាយបញ្ជាក់ថា បើចំណុច $Q(x)$ ចែកអង្កត់ $AB$ ខាងក្រៅតាមផលធៀប $m:n$ នោះ $x=\dfrac{mb-na}{m-n}$**

គេមាន ចំណុច $A(a)$ និង $B(b)$ នៅលើបន្ទាត់មួយ និងចំណុចចែកក្រៅ $Q(x)$

ផលធៀប ចែកក្រៅ $m:n$ មានន័យថា $AQ:QB=m:n$ អាចសរសេរ $\dfrac{AQ}{m}=\dfrac{QB}{n}$

➢ករណី $m>n$ និង $a<b$ នោះចំណុច $Q$ ត្រូវតែនៅខាងស្តាំ $B$ (ព្រោះបើ $Q$ នៅខាងឆ្វេង $B$ វានឹងធ្វើឱ្យ $m<n$)

នាំឱ្យ $AQ=x-a$ , $QB=x-b$




នាំឱ្យ $\dfrac{x-a}{m}=\dfrac{x-b}{n} \Leftrightarrow nx-na=mx-mb$

$$mx-nx=mb-na$$
$$(m-n)x=mb-na$$
$$x=\frac{mb-na}{m-n}$$

➢ករណី $m>n$ និង $a>b$ នោះចំណុច $Q$ ត្រូវតែនៅខាងឆ្វេង $B$ (ព្រោះបើ $Q$ នៅខាងស្តាំ $B$ វានឹងធ្វើឱ្យ $m<n$)

នាំឱ្យ $AQ=a-x$ , $QB=b-x$




នាំឱ្យ $\dfrac{a-x}{m}=\dfrac{b-x}{n} \Leftrightarrow na-nx=mb-mx$

$$mx-nx=mb-na$$
$$(m-n)x=mb-na$$
$$x=\frac{mb-na}{m-n}$$

➢ករណី $m<n$ និង $a<b$ នោះចំណុច $Q$ ត្រូវតែនៅខាងឆ្វេង $B$ (ព្រោះបើ $Q$ នៅខាងស្តាំ $B$ វានឹងធ្វើឱ្យ $m>n$)

នាំឱ្យ $AQ=a-x$ , $QB=b-x$




នាំឱ្យ $\dfrac{a-x}{m}=\dfrac{b-x}{n} \Leftrightarrow na-nx=mb-mx$

$$mx-nx=mb-na$$
$$(m-n)x=mb-na$$
$$x=\frac{mb-na}{m-n}$$

➢ករណី $m<n$ និង $a>b$ នោះចំណុច $Q$ ត្រូវតែនៅខាងឆ្វេង $B$ (ព្រោះបើ $Q$ នៅខាងស្តាំ $B$ វានឹងធ្វើឱ្យ $m>n$)

នាំឱ្យ $AQ=x-a$ , $QB=x-b$




នាំឱ្យ $\dfrac{x-a}{m}=\dfrac{x-b}{n} \Leftrightarrow nx-na=mx-mb$

$$mx-nx=mb-na$$
$$(m-n)x=mb-na$$
$$x=\frac{mb-na}{m-n}$$

ដូចនេះ

| បើចំណុច $Q(x)$ ចែកអង្កត់ $AB$ ខាងក្រៅតាមផលធៀប $m:n$ នោះ $x=\dfrac{mb-na}{m-n}$ |
|---|

។

4. **ស្រាយបញ្ជាក់ថា ចម្ងាយរវាងពីរចំណុច $A$ និង $B$ គឺ $AB=\sqrt{(x_2-x_1)^2+(y_2-y_1)^2}$**

គេមាន ពីរចំណុច $A(x_1\ ,\ y_1)$ និង $B(x_2\ ,\ y_2)$

គេអាច បង្កើតបានត្រីកោណកែង $ABC$ កែងត្រង់ $C$ ដែល $C$ ជាប្រសព្វរវាងអង្កត់ដេកគូសចេញពី $A$ និងអង្កត់ឈរគូសចេញពី $B$




តាមរយៈ ទ្រឹស្តីបទពីតាគ័រ ចំពោះត្រីកោណកែង $ABC$ កែងត្រង់ $C$

គេបាន $AB^2=AC^2+BC^2$ ឬ $AB=\sqrt{AC^2+BC^2}$

ដោយ $AC=|x_2-x_1| \Rightarrow AC^2=(|x_2-x_1|)^2=(x_2-x_1)^2$

$BC=|y_2-y_1| \Rightarrow BC^2=(|y_2-y_1|)^2=(y_2-y_1)^2$

នាំឱ្យ $AB=\sqrt{(x_2-x_1)^2+(y_2-y_1)^2}$

ដូចនេះ: ចម្ងាយរវាងពីរចំណុច $A$ និង $B$ គឺ $AB=\sqrt{(x_2-x_1)^2+(y_2-y_1)^2}$ ត្រូវបានស្រាយបញ្ជាក់ ។

5. **ក. ស្រាយបញ្ជាក់ថា បើចំណុច $P(x\ ,\ y)$ ចែកអង្កត់ $AB$ ខាងក្នុងតាមផលធៀប $m:n$ នោះ $P\left(\dfrac{mx_b+nx_a}{m+n}\ ,\ \dfrac{my_b+ny_a}{m+n}\right)$**

គេមាន $A(x_a\ ,\ y_a)$ និង $B(x_b\ ,\ y_b)$ ជាពីរចំណុចក្នុងតម្រុយកូអរដោនេ

គេគូស $AA'\ ,\ PP'\ ,\ BB'$ កែងនឹងអ័ក្សអាប់ស៊ីសរៀងគ្នាត្រង់ $A'\ ,\ P'\ ,\ B'$

គេបាន $P'$ ក៏ជាចំណុចចែកក្នុងនៃ $A'B'$ តាមផលធៀប $m:n$ ដែរ (ព្រោះតាមទ្រឹស្តីបទតាលែស បើបន្ទាត់ស្របគ្នាកាត់ដោយខ្នាត់ពីរ នោះគេបានអង្កត់សមាមាត្រគ្នា)




នាំឱ្យ $\dfrac{A'P'}{m}=\dfrac{P'B'}{n}$ ដោយ $A'P'=x-x_a\ ,\ P'B'=x_b-x$

គេបាន $\dfrac{x-x_a}{m}=\dfrac{x_b-x}{n} \Leftrightarrow nx-nx_a=mx_b-mx$

$$mx+nx=mx_b+nx_a \Rightarrow x=\frac{mx_b+nx_a}{m+n}$$

ម្យ៉ាងទៀត គេគូស $AA''\ ,\ PP''\ ,\ BB''$ កែងនឹងអ័ក្សអរដោនេរៀងគ្នាត្រង់ $A''\ ,\ P''\ ,\ B''$

គេបាន $P''$ ក៏ជាចំណុចចែកក្នុងនៃ $A''B''$ តាមផលធៀប $m:n$ ដែរ (ព្រោះតាមទ្រឹស្តីបទតាលែស ដូចបានបញ្ជាក់ខាងលើ)

នាំឱ្យ $\dfrac{A''P''}{m}=\dfrac{P''B''}{n}$ ដោយ $A''P''=y-y_a\ ,\ P''B''=y_b-y$

គេបាន $\dfrac{y-y_a}{m}=\dfrac{y_b-y}{n} \Leftrightarrow ny-ny_a=my_b-my \Leftrightarrow my+ny=my_b+ny_a \Rightarrow y=\dfrac{my_b+ny_a}{m+n}$

ដូចនេះ: បើចំណុច $P(x\ ,\ y)$ ចែកអង្កត់ $AB$ ខាងក្នុងតាមផលធៀប $m:n$ នោះ $P\left(\dfrac{mx_b+nx_a}{m+n}\ ,\ \dfrac{my_b+ny_a}{m+n}\right)$ ។

ខ. ស្រាយបញ្ជាក់ថា បើចំណុច $Q(x\,,\,y)$ ចែកអង្កត់ $AB$ ខាងក្រៅតាមផលធៀប $m:n$ នោះ $Q\left(\dfrac{mx_b-nx_a}{m-n}\,,\,\dfrac{my_b-ny_a}{m-n}\right)$




គេមាន $A(x_a\,,\,y_a)$ និង $B(x_b\,,\,y_b)$ ជាពីរចំណុចក្នុងតម្រុយកូអរដោនេ

គេគូស $QQ'\,,\,AA'\,,\,BB'$ កែងនឹងអ័ក្សអាប់ស៊ីសរៀងគ្នាត្រង់ $Q'\,,\,A',\,B'$

គេបាន $Q'$ ក៏ជាចំណុចចែកក្រៅនៃ $A'B'$ តាមផលធៀប $m:n$ ដែរ (ព្រោះតាមទ្រឹស្តីបទតាលែស បើបន្ទាត់ស្របគ្នា កាត់ដោយខ្នាត់ពីរ នោះគេបានអង្កត់សមាមាត្រគ្នា)

នាំឱ្យ $\dfrac{A'Q'}{m}=\dfrac{Q'B'}{n}$ ដោយ $A'Q'=x_a-x\ ,\ Q'B'=x_b-x$

គេបាន $\dfrac{x_a-x}{m}=\dfrac{x_b-x}{n}\ \Leftrightarrow\ nx_a-nx=mx_b-mx$

$$mx-nx=mx_b-nx_a\ \Rightarrow\ x=\frac{mx_b-nx_a}{m-n}$$

ម្យ៉ាងទៀត គេគូស $QQ''\,,\,AA''\,,\,BB''$ កែងនឹងអ័ក្សអរដោនេរៀងគ្នាត្រង់ $Q''\,,\,A''\,,\,B''$

គេបាន $Q''$ ក៏ជាចំណុចចែកក្រៅនៃ $A''B''$ តាមផលធៀប $m:n$ ដែរ (ព្រោះតាមទ្រឹស្តីបទតាលែស)

នាំឱ្យ $\dfrac{A''Q''}{m}=\dfrac{Q''B''}{n}$ ដោយ $A''Q''=y_a-y\ ,\ Q''B''=y_b-y$

គេបាន $\dfrac{y_a-y}{m}=\dfrac{y_b-y}{n}\ \Leftrightarrow\ ny_a-ny=my_b-my\ \Leftrightarrow\ my-ny=my_b-ny_a\ \Rightarrow\ y=\dfrac{my_b-ny_a}{m-n}$

ដូចនេះ: 

| បើចំណុច $Q(x\,,\,y)$ ចែកអង្កត់ $AB$ ខាងក្រៅតាមផលធៀប $m:n$ នោះ $Q\left(\dfrac{mx_b-nx_a}{m-n}\,,\,\dfrac{my_b-ny_a}{m-n}\right)$ |
|---|

។

6. **ស្រាយបញ្ជាក់ថា សមីការបន្ទាត់កាត់តាមចំណុច $A(x_1\,,\,y_1)$ និងមានមេគុណប្រាប់ទិស $m$ គឺ $y-y_1=m(x-x_1)$**

គេមាន បន្ទាត់កាត់តាមចំណុច $A(x_1\,,\,y_1)$

ដោយ មេគុណប្រាប់ទិសនៃបន្ទាត់មួយ ជាផលធៀបរវាង បម្រែបម្រួល $y$ និងបម្រែបម្រួល $x$

គេបាន គ្រប់ចំណុច $M(x\,,\,y)$ នៃបន្ទាត់ $L$ ផ្សេងពីចំណុច $A(x_1\,,\,y_1)$ នោះ ៖

មេគុណប្រាប់ទិស $m$ នៃបន្ទាត់ $L$ កំណត់ដោយ $m=\dfrac{y-y_1}{x-x_1}$ (គេអាចសរសេរ $m=\dfrac{y_1-y}{x_1-x}$ ក៏បាន)

ទាញបាន $y-y_1=m(x-x_1)$ ដែលគេហៅថា សមីការនៃបន្ទាត់

ដូចនេះ:

| សមីការបន្ទាត់កាត់តាមចំណុច $A(x_1\,,\,y_1)$ និងមានមេគុណប្រាប់ទិស $m$ គឺ $y-y_1=m(x-x_1)$ |
|---|

។

7. **ស្រាយបញ្ជាក់ថា សមីការបន្ទាត់កាត់តាមពីរចំណុច $A(x_1,\,y_1)$ និង $B(x_2,\,y_2)$ គឺ $y-y_1=\dfrac{y_2-y_1}{x_2-x_1}(x-x_1)$ ដែល $x_1\neq x_2$**

គេមាន សមីការបន្ទាត់កាត់តាម $A(x_1,\,y_1)$ និងមានមេគុណប្រាប់ទិស $m$ គឺ $y-y_1=m(x-x_1)$ (1)

ដោយ បន្ទាត់កាត់តាមពីរចំណុច $A(x_1,\,y_1)$ និង $B(x_2,\,y_2)$ នោះបន្ទាត់មានមេគុណប្រាប់ទិស $m=\dfrac{y_2-y_1}{x_2-x_1}$ (2)

គេយក (2) ជំនួសក្នុង (1) គេបាន $y-y_1=\dfrac{y_2-y_1}{x_2-x_1}(x-x_1)$

ដូចនេះ:

| បន្ទាត់កាត់តាមពីរចំណុច $A(x_1,\,y_1)$ និង $B(x_2,\,y_2)$ គឺ $y-y_1=\dfrac{y_2-y_1}{x_2-x_1}(x-x_1)$ ដែល $x_1\neq x_2$ |
|---|

។

8. **ស្រាយបញ្ជាក់ថា បន្ទាត់ពីរស្របគ្នា លុះត្រាតែវាមានមេគុណប្រាប់ទិសស្មើគ្នា**

គេតាង $D : y = mx + n$ និង $D' : y = m'x + n'$ ជាបន្ទាត់ស្របគ្នា

គេនឹងបង្ហាញថា បើ $D // D' \Leftrightarrow m = m'$ (មានន័យថា មេគុណប្រាប់ទិសស្មើគ្នា)




- គេតាង $A$ ជាប្រសព្វរវាង $D$ និងអ័ក្សអាប់ស៊ីស និង $B$ ជាចំណុច នៅលើ $D$ ហើយ $C$ ជាចំណោលកែងនៃ $B$ លើអ័ក្សអាប់ស៊ីស នោះ

គេបានមេគុណប្រាប់ទិសនៃបន្ទាត់ $D$ គឺ $m = \dfrac{BC}{AC}$ ។

- គេតាង $A'$ ជាប្រសព្វរវាង $D'$ និងអ័ក្សអាប់ស៊ីស និង $B'$ ជាចំណុច នៅលើ $D'$ ហើយ $C'$ ជាចំណោលកែងនៃ $B'$ លើអ័ក្សអាប់ស៊ីស នោះ

គេបានមេគុណប្រាប់ទិសនៃបន្ទាត់ $D'$ គឺ $m' = \dfrac{B'C'}{A'C'}$ ។

- ដោយ $\Delta ABC$ និង $\Delta A'B'C'$ ជាត្រីកោណកែងដែលមាន $\angle A = \angle A'$ (ជាមុំត្រូវគ្នាព្រោះ $D // D'$)

នាំឱ្យ $\Delta ABC \sim \Delta A'B'C'$ (តាមលក្ខខណ្ឌដំណូច ម.ម)

វិបាក $\sim \left.\begin{matrix}\Delta ABC \\ \Delta A'B'C'\end{matrix}\right| \Rightarrow \dfrac{BC}{B'C'} = \dfrac{AB}{A'B'} \Leftrightarrow \dfrac{BC}{AB} = \dfrac{B'C'}{A'B'}$ នាំឱ្យ $m = m'$

ដូចនេះ: | បន្ទាត់ពីរស្របគ្នា លុះត្រាតែវាមានមេគុណប្រាប់ទិសស្មើគ្នា ត្រូវបានស្រាយបញ្ជាក់ | ។

9. **ស្រាយបញ្ជាក់ថា បន្ទាត់ពីរកែងគ្នា លុះត្រាតែផលគុណមេគុណប្រាប់ទិសនៃបន្ទាត់ទាំងពីរស្មើ $-1$**

គេតាង $D_1 : y = mx + n$ និង $D_2 : y = m'x + n'$ ជាបន្ទាត់កែងគ្នា

គេនឹងបង្ហាញថា បើ $D_1 \perp D_2 \Leftrightarrow m \times m' = -1$ (មានន័យថា ផលគុណមេគុណប្រាប់ទិសស្មើ $-1$)

សង់បន្ទាត់ $D_3 : y = mx$ និង $D_4 : y = m'x$

គេតាង $P$ និង $Q$ ជាចំណុចប្រសព្វរៀងគ្នា $x = 1$ និង $D_3$ , $D_4$

គេបាន កូអរដោនេ $P(1, m)$ និង $Q(1, m')$

ដោយ $D_1 \perp D_2$ នោះ $D_3 \perp D_4$ (ព្រោះ $D_1 \parallel D_3$ , $D_2 \parallel D_4$)

នាំឱ្យ $POQ$ ជាត្រីកោណកែង ត្រង់ $O$

តាមទ្រឹស្តីបទពីតាគ័រ $PQ^2 = OP^2 + OQ^2$




ដោយ $PQ^2 = (1-1)^2 + (m'-m)^2 = m'^2 - 2mm' + m^2$

$OP^2 = (1-0)^2 + (m-0)^2 = 1 + m^2$

$OQ^2 = (1-0)^2 + (m'-0)^2 = 1 + m'^2$

គេបាន $m'^2 - 2mm' + m^2 = 1 + m^2 + 1 + m'^2$

$-2mm' = 2$

$mm' = -1$

ដូចនេះ: | បន្ទាត់ពីរកែងគ្នា លុះត្រាតែផលគុណមេគុណប្រាប់ទិសនៃបន្ទាត់ទាំងពីរស្មើ $-1$ ត្រូវបានស្រាយបញ្ជាក់ | ។

10. **ស្រាយបញ្ជាក់ថា ចម្ងាយ $d$ រវាងចំណុច $P(x_1\ ,\ y_1)$ និងបន្ទាត់ $L:\ ax+by+c=0$ គឺ $d=\dfrac{|ax_1+by_1+c|}{\sqrt{a^2+b^2}}$**




គេមាន ចំណុច $P(x_1\ ,\ y_1)$ និងបន្ទាត់ $L:\ ax+by+c=0$

គេសន្មត់ថា $a\neq 0$ និង $b\neq 0$

គេគូស $PA$ ស្របអ័ក្សអាប់ស៊ីស កាត់ $L$ ត្រង់ $A$

$PB$ ស្របអ័ក្សអរដោនេ កាត់ $L$ ត្រង់ $B$

គេបាន កូអរដោនេ $A(x_2\ ,\ y_1)$ និង $B(x_1, y_2)$

គេតាង $H$ ជាចំណោលកែងនៃ $P$ លើបន្ទាត់ $L$

នាំឱ្យ $APB$ ជាត្រីកោណកែងត្រង់ $P$ និងមានកម្ពស់ $PH$

យើងចង់គណនាចម្ងាយពី $P$ ទៅ $L$ គឺចង់គណនា $PH=???$

ដោយ $P(x_1\ ,\ y_1)\notin L$ មានន័យថា $ax_1+by_1+c\neq 0$

គេតាងបាន $ax_1+by_1+c=k \quad (1)$ ដែល $k\neq 0$

ហើយ $A(x_2\ ,\ y_1)\in L$ នោះ $ax_2+by_1+c=0 \quad (2)$

$B(x_1,\ y_2)\in L$ នោះ $ax_1+by_2+c=0 \quad (3)$

គេយក $(1)-(2):\ ax_1-ax_2=k \ \Rightarrow\ x_1-x_2=\dfrac{k}{a}$

$(1)-(3):\ by_1-by_2=k \ \Rightarrow\ y_1-y_2=\dfrac{k}{b}$

ម្យ៉ាងទៀត $PA^2=(x_1-x_2)^2+(y_1-y_1)^2=(x_1-x_2)^2$

$PB^2=(x_1-x_1)^2+(y_1-y_2)^2=(y_1-y_2)^2$

$AB^2=(x_1-x_2)^2+(y_1-y_2)^2$

តាមរយៈ លក្ខណៈនៃត្រីកោណកែង $PH\cdot AB=PA\cdot PB$ ទាញបាន $PH=\dfrac{PA\cdot PB}{AB}$

នាំឱ្យ $$PH^2=\frac{PA^2\cdot PB^2}{AB^2}=\frac{(x_1-x_2)^2\cdot(y_1-y_2)^2}{(x_1-x_2)^2+(y_1-y_2)^2}=\frac{\left(\frac{k}{a}\right)^2\cdot\left(\frac{k}{b}\right)^2}{\left(\frac{k}{a}\right)^2+\left(\frac{k}{b}\right)^2}=\frac{\frac{k^2}{a^2}\cdot\frac{k^2}{b^2}}{\frac{k^2}{a^2}+\frac{k^2}{b^2}}=\frac{\frac{k^4}{a^2b^2}}{\frac{k^2(a^2+b^2)}{a^2b^2}}=\frac{k^2}{a^2+b^2}$$

ទាញបាន $$PH=\sqrt{\frac{k^2}{a^2+b^2}}=\frac{\sqrt{k^2}}{\sqrt{a^2+b^2}}=\frac{|k|}{\sqrt{a^2+b^2}}=\frac{|k|}{\sqrt{a^2+b^2}}=\frac{|ax_1+by_1+c|}{\sqrt{a^2+b^2}}$$

គេតាង $d=PH$ (ព្រោះ $d=\text{distance}=$ ចម្ងាយ) ត្រូវនឹងចម្ងាយពីចំណុចទៅបន្ទាត់ នោះ $d=PH=\dfrac{|ax_1+by_1+c|}{\sqrt{a^2+b^2}}$

ដូចនេះ

| |
|---|
| ចម្ងាយ $d$ រវាងចំណុច $P(x_1\ ,\ y_1)$ និងបន្ទាត់ $L:\ ax+by+c=0$ គឺ $d=\dfrac{\lvert ax_1+by_1+c\rvert}{\sqrt{a^2+b^2}}$ |

។

11. **ក. បង្ហាញថា មេដ្យានដែលគូសចេញពីកំពូលនៃមុំកែងស្មើនឹងពាក់កណ្តាលអ៊ីប៉ូតេនុស**




គេយក $ABC$ ជាត្រីកោណកែងត្រង់ $C$ ដែល $C$ ជាគល់តម្រុយ

គេតាង $A(a\,,0)$ ជាចំណុចនៅលើអ័ក្សអាប់ស៊ីស

$B(0\,,b)$ ជាចំណុចនៅលើអ័ក្សអរដោនេ

$D\left(\frac{a}{2}\,,\frac{b}{2}\right)$ ជាចំណុចកណ្តាលនៃ $AB$

គេបាន $AB=\sqrt{(0-a)^2+(b-0)^2}=\sqrt{a^2+b^2}$

$AD=\frac{1}{2}AB$

$CD=\sqrt{\left(\frac{a}{2}-0\right)^2+\left(\frac{b}{2}-0\right)^2}=\sqrt{\frac{a^2}{4}+\frac{b^2}{4}}=\sqrt{\frac{a^2+b^2}{4}}=\frac{1}{2}\sqrt{a^2+b^2}=\frac{1}{2}AB$

នាំឱ្យ $AD=CD=\frac{1}{2}AB$ មានន័យថា $CD$ ជាមេដ្យានគូសចេញពីមុំកែង ស្មើពាក់កណ្តាលអ៊ីប៉ូតេនុស $AB$

ដូចនេះ | មេដ្យានដែលគូសចេញពីកំពូលនៃមុំកែងស្មើនឹងពាក់កណ្តាលអ៊ីប៉ូតេនុស ត្រូវបានបង្ហាញ | ។

**ខ. បង្ហាញថា អង្កត់ទ្រូងនៃចតុកោណស្មើកែងគ្នា**




គេយក $OABC$ ជាចតុកោណស្មើមាន $O$ ជាគល់តម្រុយ

$A(a,0)$ ត្រួតលើអ័ក្សអាប់ស៊ីស

$D(b,0)$ ជាចំណោលកែងនៃ $C$ លើអ័ក្សអាប់ស៊ីស

គេនឹងបង្ហាញថា $(CA)\perp(OB)$ ??? (អង្កត់ទ្រូងកែងគ្នា)

គេតាង $m$ ជាមេគុណប្រាប់ទិសនៃ $(CA)$

នាំឱ្យ $m=\frac{y_C-y_A}{x_C-x_A}=\frac{c-0}{b-a}=-\frac{c}{a-b}$

គេតាង $m'$ ជាមេគុណប្រាប់ទិសនៃ $(OB)$

នាំឱ្យ $m'=\frac{y_B-y_0}{x_B-x_0}=\frac{c-0}{(a+b)-0}=\frac{c}{a+b}$

នាំឱ្យ $m\times m'=\left(-\frac{c}{a-b}\right)\times\left(\frac{c}{a+b}\right)=\frac{-c^2}{a^2-b^2}$

ដោយ ក្នុងត្រីកោណ $ODC$ កែងត្រង់ $D$ មាន $OC^2=OD^2+CD^2$

អាចសរសេរបានថា $a^2=b^2+c^2$ នោះ $c^2=a^2-b^2$

គេបាន $m\times m'=\frac{-(a^2-b^2)}{a^2-b^2}=-1$ ជាផលគុណមេគុណប្រាប់ទិសនៃ អង្កត់ទ្រូង $CA$ និង $OB$ នាំឱ្យ $(CA)\perp(OB)$

ដូចនេះ | អង្កត់ទ្រូងនៃចតុកោណស្មើកែងគ្នា ត្រូវបានស្រាយបញ្ជាក់ | ។

12\. ក. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃរង្វង់ដែលមានផ្ចិត $I(a\ ,b)$ និងកាំ $r$ គឺ $(x-a)^2+(y-b)^2=r^2$

គេតាង $P(x\ ,y)$ ជាចំណុចនៅលើរង្វង់ គេបាន $IP=r$ ឬ $IP^2=r^2$

ចម្ងាយពី $I$ ទៅ $P$ កំណត់ដោយ $IP=\sqrt{(x-a)^2+(y-b)^2}$




នាំឱ្យ $IP^2=(x-a)^2+(y-b)^2$

គេបាន $(x-a)^2+(y-b)^2=r^2$

ដូចនេះ

| សមីការស្តង់ដារង្វង់មានផ្ចិត $I(a\ ,b)$ និងកាំ $r$ គឺ $(x-a)^2+(y-b)^2=r^2$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

ខ. ស្រាយបញ្ជាក់ថា សមីការទូទៅនៃរង្វង់មានរាង $x^2+y^2+Ax+By+C=0$ ដែល $A\ ,B\ ,C$ ជាចំនួនថេរ

គេមាន សមីការស្តង់ដានៃរង្វង់គឺ $(x-a)^2+(y-b)^2=r^2$

គេបាន $x^2-2ax+a^2+y^2-2by+b^2=r^2$

$x^2+y^2-2ax-2by+a^2+b^2-r^2=0$

បើតាង $A=-2a\ ,\ B=-2b\ ,\ C=a^2+b^2-r^2$

នោះគេបាន $x^2+y^2+Ax+By+C=0$

ដូចនេះ

| សមីការទូទៅនៃរង្វង់មានរាង $x^2+y^2+Ax+By+C=0$ ដែល $A\ ,B\ ,C$ ជាចំនួនថេរ |
|---|

។

13\. ក. ស្រាយបញ្ជាក់ថា សមីការបន្ទាត់ប៉ះនឹងរង្វង់ $x^2+y^2=r^2$ ត្រង់ចំណុច $(x_0\ ,\ y_0)$ គឺ $x_0x+y_0y=r^2$

គេមាន សមីការរង្វង់ $x^2+y^2=r^2$ (ធ្វើដេរីវេធៀបនឹង $x$ លើអង្គទាំងពីរ)

$2x+2y'y=0 \Rightarrow y'=-\frac{x}{y}$ ឬ $y'(x_0)=-\frac{x_0}{y_0}$

ដោយ សមីការបន្ទាត់ប៉ះមានរាង




$y=y'(x_0)(x-x_0)+y_0$

$=-\frac{x_0}{y_0}(x-x_0)+y_0$

$=\frac{-x_0x+x_0^2}{y_0}+y_0$

$=\frac{-x_0x+x_0^2+y_0^2}{y_0}$

នាំឱ្យ $y_0y=-x_0x+x_0^2+y_0^2$ ឬ $x_0x+y_0y=x_0^2+y_0^2$

ដោយ $P(x_0\ ,\ y_0)$ ជាចំណុចនៅលើរង្វង់ នោះវាផ្ទៀងផ្ទាត់ $x_0^2+y_0^2=r^2$

ដូចនេះ

| សមីការបន្ទាត់ប៉ះនឹងរង្វង់ $x^2+y^2=r^2$ ត្រង់ចំណុច $(x_0\ ,\ y_0)$ គឺ $x_0x+y_0y=r^2$ |
|---|

។

ខ. ស្រាយបញ្ជាក់ថា សមីការបន្ទាត់ប៉ះនឹងរង្វង់ $(x-a)^2+(y-b)^2=r^2$

ត្រង់ចំណុច $(x_0\ ,\ y_0)$ គឺ $(x_0-a)(x-a)+(y_0-b)(y-b)=r^2$




គេមាន $(x-a)^2+(y-b)^2=r^2$ (ធ្វើដេរីវេលើអង្គទាំងពីរធៀបនឹង $x$)

គេបាន $2(x-a)+2y'(y-b)=0$ ឬ $y'=-\dfrac{x-a}{y-b}$ ឬ $y'(x_0)=-\dfrac{x_0-a}{y_0-b}$

សមីការបន្ទាត់ប៉ះមានរាង $y=y'(x_0)(x-x_0)+y_0$

$$y=-\frac{x_0-a}{y_0-b}(x-x_0)+y_0$$

$$(y_0-b)(y-y_0)=-(x_0-a)(x-x_0)$$

$$(x_0-a)(x-a+a-x_0)+(y_0-b)(y-b+b-y_0)=0$$

$$(x_0-a)(x-a)-(x_0-a)^2+(y_0-b)(y-b)-(y_0-b)^2=0$$

$$(x_0-a)(x-a)+(y_0-b)(y-b)=(x_0-a)^2+(y_0-b)^2$$

ដោយ $P(x_0\ ,\ y_0)$ ជាចំណុចនៅលើរង្វង់ នោះវាផ្ទៀងផ្ទាត់សមីការ $(x_0-a)^2+(y_0-b)^2=r^2$

ដូចនេះ សមីការបន្ទាត់ប៉ះរង្វង់អាចសរសេរ $(x_0-a)(x-a)+(y_0-b)(y-b)=r^2$ ។

# ការស្រាយបញ្ជាក់លើមេរៀន អនុគមន៍

1. គេឱ្យ $f$ ជាអនុគមន៍កំណត់លើចន្លោះ $[a,b]$ដែល $\Delta f = f(x_2) - f(x_1)$ ជាកំណើនអនុគមន៍ និង $\Delta x = x_2 - x_1$ ជាកំណើនអថេរ ៖

   ក. បង្ហាញថា បើ $\frac{\Delta f}{\Delta x} > 0$ នោះ $f$ ជាអនុគមន៍កើន លើចន្លោះ $[a,b]$ ។

   ខ. បង្ហាញថា បើ $\frac{\Delta f}{\Delta x} < 0$ នោះ $f$ ជាអនុគមន៍ចុះ លើចន្លោះ $[a,b]$ ។

2. បង្ហាញថា $g(x) = \frac{x-1}{3}$ ជាអនុគមន៍ច្រាសនៃអនុគមន៍ $f(x) = 3x+1$ ។

3. បង្ហាញថា ក្រាបនៃអនុគមន៍ $y = f(x)$ និងក្រាបនៃអនុគមន៍ច្រាសរបស់វា $y = f^{-1}(x)$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ $y = x$ ។

4. ក. បង្ហាញថា ប៉ារ៉ាបូល $y = ax^2 + bx + c$ អាចសរសេរជារាង $y = a(x-p)^2 + q$ ដែល $p$ និង $q$ ត្រូវកំណត់ ។

   ខ. បង្ហាញថា ប៉ារ៉ាបូលនេះមានកំពូល $S(p\,,\,q)$ និងអ័ក្សឆ្លុះមានសមីការ $p = -\frac{b}{2a}$ ។

5. គេឱ្យអនុគមន៍ដឺក្រេទី២ ៖ $y = ax^2 + bx + c$ , $a \neq 0$ ។

   ក. បង្ហាញថា បើ $a > 0$ នោះអនុគមន៍មានតម្លៃ អប្បបរមា ស្មើ $y = -\frac{b^2 - 4ac}{4a}$ ត្រង់ $x = -\frac{b}{2a}$ និងគ្មានអតិបរមាទេ ។

   ខ. បង្ហាញថា បើ $a < 0$ នោះអនុគមន៍មានតម្លៃ អតិបរមា ស្មើ $y = -\frac{b^2 - 4ac}{4a}$ ត្រង់ $x = -\frac{b}{2a}$ និងគ្មានអប្បបរមា ទេ ។

6. បង្ហាញថា ក្រាបនៃអនុគមន៍ $y = \sqrt{x}$ ឆ្លុះនឹងក្រាបនៃអនុគមន៍ $y = x^2$ ធៀបនឹងបន្ទាត់ $y = x$ ដែលត្រូវនឹង $x \geq 0$ ។

# ការស្រាយបញ្ជាក់លើមេរៀន អនុគមន៍

1. **គេឱ្យ $f$ ជាអនុគមន៍កំណត់លើចន្លោះ $[a,b]$ ៖**

**ក. បង្ហាញថា បើ $\frac{\Delta f}{\Delta x}>0$ នោះ $f$ ជាអនុគមន៍កើន លើចន្លោះ $[a,b]$**

គេដឹងថា ចំពោះគ្រប់ $x_2>x_1$ ដែល $x_1$ និង $x_2$ នៅលើចន្លោះ $[a,b]$ នោះគេបាន ៖

បើ $f(x_2)>f(x_1)$ គេថា $f$ ជាអនុគមន៍កើន

បើ $f(x_2)<f(x_1)$ គេថា $f$ ជាអនុគមន៍ចុះ

គេមាន $\Delta f=f(x_2)-f(x_1)$ និង $\Delta x=x_2-x_1$

ចំពោះ $x_2>x_1$ ដែល $x_1$ និង $x_2$ នៅលើចន្លោះ $[a,b]$ នាំឱ្យ $x_2-x_1>0$

គេបាន $\frac{\Delta f}{\Delta x}>0$ សមមូល $\frac{f(x_2)-f(x_1)}{x_2-x_1}>0$ (គុណអង្គទាំងពីរនឹង $x_2-x_1$ មិនប្តូរទិសដៅ)

$f(x_2)-f(x_1)>0$ នាំឱ្យ $f(x_2)>f(x_1)$

ឃើញថា $f(x_2)>f(x_1)$ នេះបញ្ជាក់ថា $f$ ជាអនុគមន៍កើន លើចន្លោះ $[a,b]$

ដូចនេះ | បើ $\frac{\Delta f}{\Delta x}>0$ នោះ $f$ ជាអនុគមន៍កើន លើចន្លោះ $[a,b]$ ត្រូវបានបង្ហាញ | ។

**ខ. បង្ហាញថា បើ $\frac{\Delta f}{\Delta x}<0$ នោះ $f$ ជាអនុគមន៍ចុះ លើចន្លោះ $[a,b]$**

ចំពោះ $x_2<x_1$ ដែល $x_1$ និង $x_2$ នៅលើចន្លោះ $[a,b]$ នាំឱ្យ $x_2-x_1<0$

គេបាន $\frac{\Delta f}{\Delta x}<0$ សមមូល $\frac{f(x_2)-f(x_1)}{x_2-x_1}<0$ (គុណអង្គទាំងពីរនឹង $x_2-x_1$ មិនប្តូរទិសដៅ)

$f(x_2)-f(x_1)<0$ នាំឱ្យ $f(x_2)<f(x_1)$

ឃើញថា $f(x_2)>f(x_1)$ នេះបញ្ជាក់ថា $f$ ជាអនុគមន៍ចុះ លើចន្លោះ $[a,b]$

ដូចនេះ | បើ $\frac{\Delta f}{\Delta x}<0$ នោះ $f$ ជាអនុគមន៍ចុះ លើចន្លោះ $[a,b]$ ត្រូវបានបង្ហាញ | ។

2. **បង្ហាញថា $g(x)=\frac{x-1}{3}$ ជាអនុគមន៍ច្រាសនៃអនុគមន៍ $f(x)=3x+1$**

គេមានអនុគមន៍ : $f(x)=3x+1$

ប្តូរ $f(x)$ ជា $y$ : $y=3x+1$

ប្តូរ $y$ ជា $x$ និង $x$ ជា $y$ : $x=3y+1$

ទាញរក $y$ : $y=\frac{x-1}{3}$

នាំគេបានអនុគមន៍ច្រាស : $f^{-1}(x)=\frac{x-1}{3}$

ដូចនេះ | $g(x)=f^{-1}(x)=\frac{x-1}{3}$ ជាអនុគមន៍ច្រាសនៃអនុគមន៍ $f(x)=3x+1$ | ។

3. **បង្ហាញថា ក្រាបនៃអនុគមន៍ $y=f(x)$ និងក្រាបនៃអនុគមន៍ច្រាសរបស់វា $y=f^{-1}(x)$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ $y=x$**

គេដឹងថា ចំណុច $M(x\,,y)$ ឆ្លុះគ្នានឹង $M'(x'\,,y')$ ធៀបនឹង បន្ទាត់ $y=x$ កាលណា $x=y'$ និង $y=x'$

តាមនិយមន័យអនុគមន៍ច្រាស : បើ $f^{-1}$ ជាអនុគមន៍ច្រាសនៃអនុគមន៍ $f$ នោះគេបាន $f(a)=b \Leftrightarrow f^{-1}(b)=a$

គេតាង $P(a\,,b)$ ជាចំណុចនៅលើក្រាបនៃអនុគមន៍ $f$ នោះគេបាន $f(a)=b$

ដោយ $f^{-1}$ ជាអនុគមន៍ច្រាសនៃ $f$ នោះគេបាន $f^{-1}(b)=a$ នេះបញ្ជាក់ថា ចំណុច $P'(b\,,a)$ នៅលើក្រាបនៃ $f^{-1}$

គេសង្កេត ឃើញថា $P(a\,,b)$ ជាចំណុចនៃ $f$ និង $P'(b\,,a)$ ជាចំណុចនៃ $f^{-1}$

តាមនិយមន័យអនុគមន៍ច្រាស គេបាន $P'(b\,,a)$ ជាចំណុចឆ្លុះនៃ $P(a\,,b)$ ធៀបនឹងបន្ទាត់ $y=x$

ដោយ ក្រាបនៃអនុគមន៍ $f$ និង $f^{-1}$ មានគូៗចំណុច $P(a\,,b)$ និង $P'(b\,,a)$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ $y=x$

នាំឱ្យ ក្រាបនៃអនុគមន៍ $f$ និង $f^{-1}$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ $y=x$

ដូចនេះ | ក្រាបនៃអនុគមន៍ $f$ និង $f^{-1}$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ពុះទី១ $y=x$ | ។

4. **ក. បង្ហាញថា ប៉ារ៉ាបូល $y=ax^2+bx+c$ អាចសរសេរជារាង $y=a(x-p)^2+q$ ដែល $p$ និង $q$ ត្រូវកំណត់**

គេមាន $y=ax^2+bx+c$

$$=a\left(x^2+\frac{b}{a}x\right)+c$$

$$=a\left[x^2+\frac{b}{a}x+\left(\frac{b}{2a}\right)^2-\left(\frac{b}{2a}\right)^2\right]+c$$

$$=a\left[x^2+\frac{b}{a}x+\left(\frac{b}{2a}\right)^2\right]-a\left(\frac{b}{2a}\right)^2+c$$

$$=a\left(x+\frac{b}{2a}\right)^2-\frac{b^2}{4a}+c$$

$$=a\left(x+\frac{b}{2a}\right)^2-\frac{b^2-4ac}{4a}$$

$$=a\left[x-\left(-\frac{b}{2a}\right)\right]^2+\left(-\frac{b^2-4ac}{4a}\right)$$

ផ្ទឹមនឹង $y=a(x-p)^2+q$

ទាញបាន $p=-\dfrac{b}{2a}\ ,\ q=-\dfrac{b^2-4ac}{4a}$

ដូចនេះ

សមីការ $y=ax^2+bx+c$ អាចសរសេរជារាង $y=a(x-p)^2+q$ បានគឺ

$$y=a\left[x-\left(-\frac{b}{2a}\right)\right]^2+\left(-\frac{b^2-4ac}{4a}\right)$$ ដែលកំណត់បាន $p=-\dfrac{b}{2a}\ ,\ q=-\dfrac{b^2-4ac}{4a}$ ។

**ខ. បង្ហាញថា ប៉ារ៉ាបូលនេះមានកំពូល $S(p\,,\,q)$ និងអ័ក្សឆ្លុះមានសមីការ $p=-\dfrac{b}{2a}$**

គេដឹងថា $y=ax^2$ ជាប៉ារ៉ាបូលដែលមានកំពូល $O(0\,,\,0)$

ដោយ ប៉ារ៉ាបូល $y=a(x-p)^2+q$ បានពីរំកិល ប៉ារ៉ាបូល $y=ax^2$ ចំនួន $p$ ឯកតាស្របនឹងអ័ក្សអាប់ស៊ីស និង $q$ ឯកតាស្របនឹងអ័ក្សអរដោនេ

នាំឱ្យ កំពូលនៃប៉ារ៉ាបូល $y=a(x-p)^2+q$ បានពីរំកិលកំពូល $O(0\,,\,0)$ នៃប៉ារ៉ាបូល $y=ax^2$ ចំនួន $p$ ឯកតាស្របនឹងអ័ក្សអាប់ស៊ីស និង $q$ ឯកតា ស្របនឹងអ័ក្សអរដោនេ

គេបាន កំពូលនៃប៉ារ៉ាបូល $y=a(x-p)^2+q$ គឺ $S(p\,,\,q)$

ដូចនេះ

| ប៉ារ៉ាបូល $y=a(x-p)^2+q$ មានកំពូល $S(p\,,\,q)$ ត្រូវបានបង្ហាញ |
|---|

។

✓**សម្គាល់ : ប៉ារ៉ាបូល $y=ax^2+bx+c$ មានកំពូល $S(p\,,\,q)=\left(-\dfrac{b}{2a}\,,\,-\dfrac{b^2-4ac}{4a}\right)$ !!!!**

ម្យ៉ាងទៀត ប៉ារ៉ាបូល $y=ax^2$ មានអ័ក្សឆ្លុះ $x=0$

នាំឱ្យ អ័ក្សឆ្លុះនៃ $y=a(x-p)^2+q$ គឺបានពីរំកិលអ័ក្សឆ្លុះ $x=0$ ចំនួន $p$ ឯកតាស្រប់នឹងអ័ក្សអាប់ស៊ីស

គេបាន ប៉ារ៉ាបូល $y=a(x-p)^2+q$ មានអ័ក្សឆ្លុះ $x=p$ ដែល $p=-\dfrac{b}{2a}$

ដូចនេះ

| ប៉ារ៉ាបូល $y=a(x-p)^2+q$ មានអ័ក្សឆ្លុះ $x=-\dfrac{b}{2a}$ ត្រូវបានបង្ហាញ |
|---|

។

5. **ក. បង្ហាញថា បើ $a>0$ នោះអនុគមន៍មានតម្លៃ អប្បបរមា ស្មើ $y=-\dfrac{b^2-4ac}{4a}$ ត្រង់ $x=-\dfrac{b}{2a}$ និងគ្មានអតិបរមាទេ**

គេមាន
$$y=ax^2+bx+c=a\left(x^2+\frac{b}{a}x\right)+c$$
$$=a\left[x^2+\frac{b}{a}x+\left(\frac{b}{2a}\right)^2-\left(\frac{b}{2a}\right)^2\right]+c$$
$$=a\left[x^2+\frac{b}{a}x+\left(\frac{b}{2a}\right)^2\right]-a\left(\frac{b}{2a}\right)^2+c$$
$$=a\left(x+\frac{b}{2a}\right)^2-\frac{b^2}{4a}+c=a\left(x+\frac{b}{2a}\right)^2-\frac{b^2-4ac}{4a}$$

ដោយ $a>0$ និង $\left(x+\dfrac{b}{2a}\right)^2\ge 0$ នាំឱ្យ $a\left(x+\dfrac{b}{2a}\right)^2\ge 0$ នោះ $y=a\left(x+\dfrac{b}{2a}\right)^2-\dfrac{b^2-4ac}{4a}\ge-\dfrac{b^2-4ac}{4a}$

មានន័យថា $y$ មានតម្លៃតូចបំផុត គឺ $y=-\dfrac{b^2-4ac}{4a}$ កាលណា $a\left(x+\dfrac{b}{2a}\right)^2=0\Rightarrow x=-\dfrac{b}{2a}$

ម្យ៉ាងទៀត $y\ge-\dfrac{b^2-4ac}{4a}$ គឺមិនអាចកំណត់តម្លៃធំបំផុតនៃ $y$ បានទេ នោះ $y$ គ្មានតម្លៃអតិបរមាទេ

ដូចនេះ

| អនុគមន៍ $y=ax^2+bx+c$ មានតម្លៃ អប្បបរមា $y=-\dfrac{b^2-4ac}{4a}$ ត្រង់ $x=-\dfrac{b}{2a}$ និងគ្មានអតិបរមាទេ |
|---|

។

ខ. បង្ហាញថា បើ $a<0$ នោះអនុគមន៍មានតម្លៃ អតិបរមា ស្មើ $y=-\frac{b^2-4ac}{4a}$ ត្រង់ $x=-\frac{b}{2a}$ និងគ្មានអប្បបរមា ទេ

គេមាន $y=ax^2+bx+c=a\left(x+\frac{b}{2a}\right)^2-\frac{b^2-4ac}{4a}$ (បានស្រាយរួចខាងលើ)

ដោយ $a<0$ និង $\left(x+\frac{b}{2a}\right)^2\geq 0$ នាំឱ្យ $a\left(x+\frac{b}{2a}\right)^2\leq 0$

នោះ $y=a\left(x+\frac{b}{2a}\right)^2-\frac{b^2-4ac}{4a}\leq -\frac{b^2-4ac}{4a}$

មានន័យថា $y$ មានតម្លៃធំបំផុត គឺ $y=-\frac{b^2-4ac}{4a}$ កាលណា $a\left(x+\frac{b}{2a}\right)^2=0 \Rightarrow x=-\frac{b}{2a}$

ម្យ៉ាងទៀត $y\leq -\frac{b^2-4ac}{4a}$ គឺមិនអាចកំណត់តម្លៃតូចបំផុតនៃ $y$ បានទេ នោះ $y$ គ្មានតម្លៃអប្បបរមាទេ

ដូចនេះ:

| |
|---|
| អនុគមន៍ $y=ax^2+bx+c$ មានតម្លៃ អតិបរមា $y=-\frac{b^2-4ac}{4a}$ ត្រង់ $x=-\frac{b}{2a}$ និងគ្មានអប្បបរមាទេ |

។

6. បង្ហាញថា ក្រាបនៃអនុគមន៍ $y=\sqrt{x}$ ឆ្លុះនឹងក្រាបនៃអនុគមន៍ $y=x^2$ ធៀបនឹងបន្ទាត់ $y=x$ ដែលត្រូវនឹង $x\geq 0$

គេមាន អនុគមន៍ $y=\sqrt{x}$ និង $y=x^2$

បើក្រាបនៃ អនុគមន៍ $y=\sqrt{x}$ និង $y=x^2$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ $y=x$ ដែលត្រូវនឹង $x\geq 0$ លុះត្រាតែ អនុគមន៍ $y=\sqrt{x}$ ជាអនុគមន៍ច្រាសនៃអនុគមន៍ $y=x^2$




ពិនិត្យអនុគមន៍ : $y=\sqrt{x}$

ប្តូរ $y$ ជា $x$ និង $x$ ជា $y$ : $x=\sqrt{y}$

ទាញរក $y$ : $y=x^2$

ដូចនេះ:

| |
|---|
| ក្រាបនៃអនុគមន៍ $y=\sqrt{x}$ ឆ្លុះនឹងក្រាបនៃអនុគមន៍ $y=x^2$ ធៀបនឹងបន្ទាត់ $y=x$ ដែលត្រូវនឹង $x\geq 0$ |

។

# ការស្រាយបញ្ជាក់លើមេរៀន ផលធៀបត្រីកោណមាត្រ

1. ចូរបង្ហាញទំនាក់ទំនងខាងក្រោម ៖

ក. $\tan A=\dfrac{\sin A}{\cos A}$ និង $\cot A=\dfrac{\cos A}{\sin A}$ ។

ខ. $\sin^2 A+\cos^2 A=1$ និង $\tan A\times\cot A=1$ ។

គ. $1+\tan^2 A=\dfrac{1}{\cos^2 A}$ និង $1+\cot^2 A=\dfrac{1}{\sin^2 A}$ ។

2. បង្ហាញថា ក្នុងរង្វង់ត្រីកោណមាត្រ ដែលមានមុំ $\theta$ នោះគេបាន $\sin^2\theta+\cos^2\theta=1$ ។

3. ស្រាយបញ្ជាក់ផលធៀបត្រីកោណមាត្រនៃមុំខាងក្រោម ៖

ក. $\sin 30^\circ=\dfrac{1}{2}$ $\quad\cos 30^\circ=\dfrac{\sqrt{3}}{2}$ $\quad\tan 30^\circ=\dfrac{\sqrt{3}}{3}$ $\quad\cot 30^\circ=\sqrt{3}$

ខ. $\sin 60^\circ=\dfrac{\sqrt{3}}{2}$ $\quad\cos 60^\circ=\dfrac{1}{2}$ $\quad\tan 60^\circ=\sqrt{3}$ $\quad\cot 60^\circ=\dfrac{\sqrt{3}}{3}$

គ. $\sin 45^\circ=\dfrac{\sqrt{2}}{2}$ $\quad\cos 45^\circ=\dfrac{\sqrt{2}}{2}$ $\quad\tan 45^\circ=1$ $\quad\cot 45^\circ=1$

4. ក្នុងត្រីកោណ $ABC$ មានមុំកែងត្រង់ $C$ ។ បង្ហាញថា ៖

$\sin(90^\circ-A)=\cos A$ $\quad\cos(90^\circ-A)=\sin A$ $\quad\tan(90^\circ-A)=\cot A$ $\quad\cot(90^\circ-A)=\tan A$ ។

5. ដោយប្រើរង្វង់ត្រីកោណមាត្រ បង្ហាញថា ៖

$\cos(180^\circ-\alpha)=-\cos\alpha$ $\quad\sin(180^\circ-\alpha)=\sin\alpha$ $\quad\tan(180^\circ-\alpha)=-\tan\alpha$ $\quad\cot(180^\circ-\alpha)=-\cot\alpha$ ។

6. ដោយប្រើរង្វង់ត្រីកោណមាត្រ បង្ហាញថា ៖

$\cos(90^\circ-\alpha)=\sin\alpha$ $\quad\sin(90^\circ-\alpha)=\cos\alpha$ $\quad\tan(90^\circ-\alpha)=\cot\alpha$ $\quad\cot(90^\circ-\alpha)=\tan\alpha$ ។

7. ស្រាយបញ្ជាក់ទ្រឹស្តីបទស៊ីនុស ៖ ចំពោះត្រីកោណ $ABC$ ចារឹកក្នុងរង្វង់កាំ $R$ នោះគេបាន $\dfrac{a}{\sin A}=\dfrac{b}{\sin B}=\dfrac{c}{\sin C}=2R$ ។

8. ក. ស្រាយបញ្ជាក់ទ្រឹស្តីបទកូស៊ីនុស ៖ ចំពោះត្រីកោណ $ABC$ គេបាន ៖

$a^2=b^2+c^2-2bc\cos A$ , $b^2=a^2+c^2-2ac\cos B$ , $c^2=a^2+b^2-2ab\cos C$ ។

ខ. ទាញបញ្ជាក់ថា $\cos A=\dfrac{b^2+c^2-a^2}{2bc}$ , $\cos B=\dfrac{a^2+c^2-b^2}{2ac}$ , $\cos C=\dfrac{a^2+b^2-c^2}{2ab}$ ។

9. ក. ស្រាយបញ្ជាក់ថា ផ្ទៃក្រឡា $S$ នៃត្រីកោណ $ABC$ គឺ ៖ $S=\dfrac{1}{2}ab\sin C=\dfrac{1}{2}ac\sin B=\dfrac{1}{2}bc\sin A$ ។

ខ. ទាញបង្ហាញថា $\dfrac{abc}{2S}=\dfrac{c}{\sin C}=\dfrac{b}{\sin B}=\dfrac{a}{\sin A}$ ។

10. ស្រាយបញ្ជាក់ថា បើ $a$ , $b$ , $c$ ជារង្វាស់ជ្រុងនៃត្រីកោណមួយ និង $p$ ជាកន្លះបរិមាត្រ នោះគេបានរូបមន្តហេរ៉ុង ផ្ទៃក្រឡា $S=\sqrt{p(p-a)(p-b)(p-c)}$ ។

# ការស្រាយបញ្ជាក់លើមេរៀន ផលធៀបត្រីកោណមាត្រ

1. **បង្ហាញទំនាក់ទំនងខាងក្រោម ៖**

**ក. បង្ហាញថា** $\tan A=\dfrac{\sin A}{\cos A}$ **និង** $\cot A=\dfrac{\cos A}{\sin A}$

និយមន័យ $\sin A$ ជាផលធៀបរវាង ជ្រុងឈម និងអ៊ីប៉ូតេនុស

$\cos A$ ជាផលធៀបរវាង ជ្រុងជាប់ និងអ៊ីប៉ូតេនុស

$\tan A$ ជាផលធៀបរវាង ជ្រុងឈម និងជ្រុងជាប់

$\cot A$ ជាផលធៀបរវាង ជ្រុងជាប់ និងជ្រុងឈម

ដោយ $$\frac{\sin A}{\cos A}=\frac{\dfrac{\text{ជ្រុងឈម}}{\text{អ៊ីប៉ូតេនុស}}}{\dfrac{\text{ជ្រុងជាប់}}{\text{អ៊ីប៉ូតេនុស}}}=\frac{\text{ជ្រុងឈម}}{\text{អ៊ីប៉ូតេនុស}}\times\frac{\text{អ៊ីប៉ូតេនុស}}{\text{ជ្រុងជាប់}}=\frac{\text{ជ្រុងឈម}}{\text{ជ្រុងជាប់}}=\tan A$$

ហើយ $$\frac{\cos A}{\sin A}=\frac{\dfrac{\text{ជ្រុងជាប់}}{\text{អ៊ីប៉ូតេនុស}}}{\dfrac{\text{ជ្រុងឈម}}{\text{អ៊ីប៉ូតេនុស}}}=\frac{\text{ជ្រុងជាប់}}{\text{អ៊ីប៉ូតេនុស}}\times\frac{\text{អ៊ីប៉ូតេនុស}}{\text{ជ្រុងឈម}}=\frac{\text{ជ្រុងជាប់}}{\text{ជ្រុងឈម}}=\cot A$$

ដូចនេះ: $\boxed{\tan A=\dfrac{\sin A}{\cos A}\ \text{និង}\ \cot A=\dfrac{\cos A}{\sin A}\ \text{ត្រូវបានស្រាយបញ្ជាក់}}$ ។

**ខ. បង្ហាញថា** $\sin^2 A+\cos^2 A=1$

ក្នុងត្រីកោណកែង $ABC$ កែងត្រង់ $C$




គេបាន $\sin A=\dfrac{a}{c}\ \Rightarrow\ a=c\sin A$ និង $\cos A=\dfrac{b}{c}\ \Rightarrow\ b=c\cos A$

តាមទ្រឹស្តីបទពីតាគ័រ $a^2+b^2=c^2$ ឬ $(c\sin A)^2+(c\cos A)^2=c^2$

នាំឱ្យ $c^2\cdot(\sin A)^2+c^2\cdot(\cos A)^2=c^2$ (ចែកអង្គទាំងពីរនឹង $c^2$)

$(\sin A)^2+(\cos A)^2=1$ (គេអាចសរសេរ $(\sin A)^2=\sin^2 A$ និង $(\cos A)^2=\cos^2 A$ )

$\sin^2 A+\cos^2 A=1$

ដូចនេះ: $\boxed{\sin^2 A+\cos^2 A=1\ \text{ត្រូវបានស្រាយបញ្ជាក់}}$ ។

➤**បង្ហាញថា** $\tan A\times\cot A=1$

គេមាន $\tan A=\dfrac{\sin A}{\cos A}$ និង $\cot A=\dfrac{\cos A}{\sin A}$

គេបាន $\tan A\times\cot A=\dfrac{\sin A}{\cos A}\times\dfrac{\cos A}{\sin A}=1$

ដូចនេះ: $\boxed{\tan A\times\cot A=1\ \text{ត្រូវបានស្រាយបញ្ជាក់}}$ ។

**គ. បង្ហាញថា** $1+\tan^2 A=\dfrac{1}{\cos^2 A}$

គេមាន $\sin^2 A+\cos^2 A=1$ (គេចែកអង្គទាំងពីរនឹង $\cos^2 A$)

គេបាន $\dfrac{\sin^2 A}{\cos^2 A}+\dfrac{\cos^2 A}{\cos^2 A}=\dfrac{1}{\cos^2 A}$ ឬ $\tan^2 A+1=\dfrac{1}{\cos^2 A}$

ដូចនេះ $1+\tan^2 A=\dfrac{1}{\cos^2 A}$ ត្រូវបានស្រាយបញ្ជាក់ ។

➢**បង្ហាញថា** $1+\cot^2 A=\dfrac{1}{\sin^2 A}$

គេមាន $\sin^2 A+\cos^2 A=1$ (គេចែកអង្គទាំងពីរនឹង $\sin^2 A$)

គេបាន $\dfrac{\sin^2 A}{\sin^2 A}+\dfrac{\cos^2 A}{\sin^2 A}=\dfrac{1}{\sin^2 A}$ ឬ $1+\cot^2 A=\dfrac{1}{\sin^2 A}$

ដូចនេះ $1+\cot^2 A=\dfrac{1}{\sin^2 A}$ ត្រូវបានស្រាយបញ្ជាក់ ។

2. **បង្ហាញថា** $\sin^2\theta+\cos^2\theta=1$

តាមរង្វង់ត្រីកោណមាត្រ (រង្វង់ដែលមានកាំ $r=1$)




ចំពោះ ក្នុងត្រីកោណ $OAP$ កែងត្រង់ $A$

គេមាន $OA=OP\cdot\cos\theta$ និង $AP=OP\cdot\sin\theta$

តាមទ្រឹស្តីបទពីតាគ័រ ចំពោះត្រីកោណកែង $OAP$

គេបាន $OA^2+AP^2=OP^2$

ឬ $(OP\cdot\cos\theta)^2+(OP\cdot\sin\theta)^2=OP^2$

តែ $OP=1$ ជាកាំរង្វង់ត្រីកោណមាត្រ

នាំឱ្យ $(\cos\theta)^2+(\sin\theta)^2=1^2$ គេអាចសរសេរ $\cos^2\theta+\sin^2\theta=1$

ដូចនេះ $\cos^2\theta+\sin^2\theta=1$ ត្រូវបានស្រាយបញ្ជាក់ ។

3. **ស្រាយបញ្ជាក់ផលធៀបត្រីកោណមាត្រនៃមុំខាងក្រោម ៖**

**ក. ស្រាយបញ្ជាក់ថា** $\sin 30^\circ=\dfrac{1}{2}$ **និង** $\cos 30^\circ=\dfrac{\sqrt{3}}{2}$

គេមានត្រីកោណសម័ង្ស $ABC$ ដែលមានរង្វាស់ជ្រុងស្មើ $a$




នោះ $ABH$ ជាត្រីកោណកែងកន្លះសម័ង្ស ដែលមាន $AH=\dfrac{\sqrt{3}}{2}a$

$\sin 30^\circ=\dfrac{BH}{AB}=\dfrac{\frac{1}{2}a}{a}=\dfrac{1}{2}$ និង $\cos 30^\circ=\dfrac{AH}{AB}=\dfrac{\frac{\sqrt{3}}{2}a}{a}=\dfrac{\sqrt{3}}{2}$

ដូចនេះ $\sin 30^\circ=\dfrac{1}{2}$ និង $\cos 30^\circ=\dfrac{\sqrt{3}}{2}$ ត្រូវបានស្រាយបញ្ជាក់ ។

➢**ស្រាយបញ្ជាក់ថា** $\tan 30^\circ = \frac{\sqrt{3}}{3}$ **និង** $\cot 30^\circ = \sqrt{3}$

ដោយ $\tan 30^\circ = \frac{\sin 30^\circ}{\cos 30^\circ} = \frac{\frac{1}{2}}{\frac{\sqrt{3}}{2}} = \frac{1}{2} \times \frac{2}{\sqrt{3}} = \frac{1}{\sqrt{3}} = \frac{\sqrt{3}}{3}$

$\cot 30^\circ = \frac{\cos 30^\circ}{\sin 30^\circ} = \frac{\frac{\sqrt{3}}{2}}{\frac{1}{2}} = \frac{\sqrt{3}}{2} \times \frac{2}{1} = \sqrt{3}$

ដូចនេះ: $\tan 30^\circ = \frac{\sqrt{3}}{3}$ និង $\cot 30^\circ = \sqrt{3}$ ត្រូវបានស្រាយបញ្ជាក់ ។

**ខ. ស្រាយបញ្ជាក់ថា** $\sin 60^\circ = \frac{\sqrt{3}}{2}$ **និង** $\cos 60^\circ = \frac{1}{2}$

គេមានត្រីកោណសម័ង្ស $ABC$ ដែលមានរង្វាស់ជ្រុងស្មើ $a$

នោះ $ABH$ ជាត្រីកោណកែងកន្លះសម័ង្ស ដែលមាន $AH = \frac{\sqrt{3}}{2}a$




$\sin 60^\circ = \frac{AH}{AB} = \frac{\frac{\sqrt{3}}{2}a}{a} = \frac{\sqrt{3}}{2}$ និង $\cos 60^\circ = \frac{BH}{AB} = \frac{\frac{1}{2}a}{a} = \frac{1}{2}$

ដូចនេះ: $\sin 60^\circ = \frac{\sqrt{3}}{2}$ និង $\cos 60^\circ = \frac{1}{2}$ ត្រូវបានស្រាយបញ្ជាក់ ។

➢**ស្រាយបញ្ជាក់ថា** $\tan 60^\circ = \sqrt{3}$ **និង** $\cot 60^\circ = \frac{\sqrt{3}}{3}$

ដោយ $\tan 60^\circ = \frac{\sin 60^\circ}{\cos 60^\circ} = \frac{\frac{\sqrt{3}}{2}}{\frac{1}{2}} = \frac{\sqrt{3}}{2} \times \frac{2}{1} = \sqrt{3}$

$\cot 60^\circ = \frac{\cos 60^\circ}{\sin 60^\circ} = \frac{\frac{1}{2}}{\frac{\sqrt{3}}{2}} = \frac{1}{2} \times \frac{2}{\sqrt{3}} = \frac{1}{\sqrt{3}} = \frac{\sqrt{3}}{3}$

ដូចនេះ: $\tan 60^\circ = \sqrt{3}$ និង $\cot 60^\circ = \frac{\sqrt{3}}{3}$ ត្រូវបានស្រាយបញ្ជាក់ ។

- ✓ តើអ្នកដឹងទេថា បើត្រីកោណសម័ង្សមួយមានរង្វាស់ជ្រុងស្មើ $a$ នោះគេបានកម្ពស់របស់វាមានរង្វាស់ស្មើ $\frac{\sqrt{3}}{2}a$ ។
- ✓ តើអ្នកដឹងទេថា បើការេមួយមានរង្វាស់ជ្រុងស្មើ $a$ នោះគេបានប្រវែងអង្កត់ទ្រូងរបស់វាមានរង្វាស់ស្មើ $\sqrt{2}a$ ។
- ✓ តើអ្នកដឹងទេថា បើគូបមួយមានរង្វាស់ជ្រុងស្មើ $a$ នោះគេបានប្រវែងអង្កត់ទ្រូងរបស់វាមានរង្វាស់ស្មើ $\sqrt{3}a$ ។

✍ គេអាចបកស្រាយ ហេតុផលខាងលើ ដោយប្រើ ទ្រឹស្តីបទពីតាគ័រ ។

**គ. ស្រាយបញ្ជាក់ថា** $\sin 45^\circ = \dfrac{\sqrt{2}}{2}$ **និង** $\cos 45^\circ = \dfrac{\sqrt{2}}{2}$




គេមានត្រីកោណកែងសមបាត $ABC$ ដែល $AB = AC = a$ និង $\angle B = 45^\circ$

តាមទ្រឹស្តីបទពីតាគ័រ $BC^2 = AB^2 + AC^2$ ឬ $BC = \sqrt{AB^2 + AC^2}$

នាំឱ្យ $BC = \sqrt{a^2 + a^2} = \sqrt{2a^2} = \sqrt{2}a$

គេបាន $$\sin 45^\circ = \frac{AC}{BC} = \frac{a}{\sqrt{2}a} = \frac{1}{\sqrt{2}} = \frac{\sqrt{2}}{2}$$

$$\cos 45^\circ = \frac{AB}{BC} = \frac{a}{\sqrt{2}a} = \frac{1}{\sqrt{2}} = \frac{\sqrt{2}}{2}$$

ដូចនេះ $\sin 45^\circ = \dfrac{\sqrt{2}}{2}$ និង $\cos 45^\circ = \dfrac{\sqrt{2}}{2}$ ត្រូវបានស្រាយបញ្ជាក់ ។

➢**ស្រាយបញ្ជាក់ថា** $\tan 45^\circ = 1$ **និង** $\cot 45^\circ = 1$

ដោយ $$\tan 45^\circ = \frac{\sin 45^\circ}{\cos 45^\circ} = \frac{\frac{\sqrt{2}}{2}}{\frac{\sqrt{2}}{2}} = \frac{\sqrt{2}}{2} \times \frac{2}{\sqrt{2}} = 1$$

$$\cot 45^\circ = \frac{\cos 45^\circ}{\sin 45^\circ} = \frac{\frac{\sqrt{2}}{2}}{\frac{\sqrt{2}}{2}} = \frac{\sqrt{2}}{2} \times \frac{2}{\sqrt{2}} = 1$$

ដូចនេះ $\tan 45^\circ = 1$ និង $\cot 45^\circ = 1$ ត្រូវបានស្រាយបញ្ជាក់ ។

4. **បង្ហាញថា** $\sin(90^\circ - A) = \cos A$ **និង** $\cos(90^\circ - A) = \sin A$




គេមាន ត្រីកោណ $ABC$ មានមុំកែងត្រង់ $C$ នោះ $B = 90^\circ - A$

តាមផលធៀបត្រីកោណមាត្រ គេបាន៖

- $\cos A = \dfrac{b}{c}$ , $\sin B = \dfrac{b}{c}$ នោះ $\cos A = \sin B$ ឬ $\cos A = \sin(90^\circ - A)$
- $\sin A = \dfrac{a}{c}$ , $\cos B = \dfrac{a}{c}$ នោះ $\sin A = \cos B$ ឬ $\sin A = \cos(90^\circ - A)$

ដូចនេះ $\sin(90^\circ - A) = \cos A$ និង $\cos(90^\circ - A) = \sin A$ ត្រូវបានបង្ហាញ ។

➢ **បង្ហាញថា** $\tan(90^\circ - A) = \cot A$ **និង** $\cot(90^\circ - A) = \tan A$

ដោយ $$\tan(90^\circ - A) = \frac{\sin(90^\circ - A)}{\cos(90^\circ - A)} = \frac{\cos A}{\sin A} = \cot A$$

$$\cos(90^\circ - A) = \frac{\cos(90^\circ - A)}{\sin(90^\circ - A)} = \frac{\sin A}{\cos A} = \tan A$$

ដូចនេះ $\tan(90^\circ - A) = \cot A$ និង $\cot(90^\circ - A) = \tan A$ ត្រូវបានបង្ហាញ ។

5. **ដោយប្រើរង្វង់ត្រីកោណមាត្រ ៖**




➢**បង្ហាញថា** $\cos(180°-\alpha)=-\cos\alpha$ **និង** $\sin(180°-\alpha)=\sin\alpha$

ក្នុងរង្វង់ត្រីកោណមាត្រ គេតាង $\angle AOP=\alpha$ និង $\angle AOP'=180°-\alpha$

គេបាន កូអរដោនេនៃចំណុច $P$ និង $P'$ គឺ

$P(\cos\alpha\ ,\sin\alpha)$ និង $P'(\cos(180°-\alpha)\ ,\sin(180°-\alpha))$

ដោយ ចំណុច $P$ និង $P'$ ឆ្លុះគ្នាធៀបនឹងអ័ក្សអរដោនេ

តាមលក្ខណៈឆ្លុះ នោះចំណុចទាំងពីរមាន អាប់ស៊ីសផ្ទុយគ្នា និងអរដោនេដូចគ្នា

គេបាន $\cos\alpha=-\cos(180°-\alpha)$ និង $\sin\alpha=\sin(180°-\alpha)$

ដូចនេះ: | រូបមន្ត $\cos(180°-\alpha)=-\cos\alpha$ និង $\sin(180°-\alpha)=\sin\alpha$ ត្រូវបានបង្ហាញ | ។

➢**បង្ហាញថា** $\tan(180°-\alpha)=-\tan\alpha$ **និង** $\cot(180°-\alpha)=-\cot\alpha$

គេមាន រូបមន្ត $\sin(180°-\alpha)=\sin\alpha$ និង $\cos(180°-\alpha)=-\cos\alpha$ (បានស្រាយរួចខាងលើ)

គេបាន $$\tan(180°-\alpha)=\frac{\sin(180°-\alpha)}{\cos(180°-\alpha)}=\frac{\sin\alpha}{-\cos\alpha}=-\tan\alpha$$

$$\cot(180°-\alpha)=\frac{\cos(180°-\alpha)}{\sin(180°-\alpha)}=\frac{-\cos\alpha}{\sin\alpha}=-\cot\alpha$$

ដូចនេះ: | រូបមន្ត $\tan(180°-\alpha)=-\tan\alpha$ និង $\cot(180°-\alpha)=-\cot\alpha$ ត្រូវបានបង្ហាញ | ។

6. **ដោយប្រើរង្វង់ត្រីកោណមាត្រ ៖**




➢**បង្ហាញថា** $\cos(90°-\alpha)=\sin\alpha$ **និង** $\sin(90°-\alpha)=\cos\alpha$

ក្នុងរង្វង់ត្រីកោណមាត្រ គេតាង $\angle AOP=\alpha$ និង $\angle AOP'=90°-\alpha$

គេបាន កូអរដោនេនៃចំណុច $P$ និង $P'$ គឺ

$P(\cos\alpha\ ,\sin\alpha)$ និង $P'(\cos(90°-\alpha)\ ,\sin(90°-\alpha))$

ដោយ ចំណុច $P$ និង $P'$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ពុះទី១ $y=x$

(នោះអាប់ស៊ីសនៃ $P$ ស្មើអរដោនេនៃ $P'$ និង អរដោនេនៃ $P$ ស្មើអាប់ស៊ីសនៃ $P'$)

គេបាន $\cos\alpha=\sin(90°-\alpha)$ និង $\sin\alpha=\cos(90°-\alpha)$

ដូចនេះ: | រូបមន្ត $\cos(90°-\alpha)=\sin\alpha$ និង $\sin(90°-\alpha)=\cos\alpha$ ត្រូវបានបង្ហាញ | ។

➢**បង្ហាញថា** $\tan(90°-\alpha)=\cot\alpha$ **និង** $\cot(90°-\alpha)=\tan\alpha$

គេមាន $\sin(90°-\alpha)=\cos\alpha$ និង $\cos(90°-\alpha)=\sin\alpha$ (បង្ហាញរួចខាងលើ)

គេបាន $$\tan(90°-\alpha)=\frac{\sin(90°-\alpha)}{\cos(90°-\alpha)}=\frac{\cos\alpha}{\sin\alpha}=\cot\alpha$$

$$\cot(90°-\alpha)=\frac{\cos(90°-\alpha)}{\sin(90°-\alpha)}=\frac{\sin\alpha}{\cos\alpha}=\tan\alpha$$

ដូចនេះ: | រូបមន្ត $\tan(90°-\alpha)=\cot\alpha$ និង $\cot(90°-\alpha)=\tan\alpha$ ត្រូវបានបង្ហាញ | ។

7. **ស្រាយបញ្ជាក់ទ្រឹស្តីបទស៊ីនុស៖** $\dfrac{a}{\sin A}=\dfrac{b}{\sin B}=\dfrac{c}{\sin C}=2R$

គេមាន ត្រីកោណ $ABC$ ចារឹកក្នុងរង្វង់កាំ $R$ ដែល $AB=c$ , $AC=b$ , $BC=a$

គេនឹងស្រាយគ្រប់ករណីនៃមុំ $A$ ដែលនាំឱ្យគេបាន $\dfrac{a}{\sin A}=2R$

ចំពោះត្រីកោណ $ABC$ ចារឹកក្នុងរង្វង់ នោះមុំ $A$ អាចជាមុំស្រួច ឬមុំទាល ឬមុំកែង

➢**ករណី $A$ ជាមុំស្រួច**




គេគូសអង្កត់ផ្ចិត $CD$ នោះគេបាន $\Delta BCD$ ជាត្រីកោណកែងត្រង់ $B$

គេបាន $\sin D=\dfrac{BC}{CD}$

ដោយ $BC=a$ , $CD=2R$ និង $\angle A=\angle D$ (មុំមានធ្នូស្កាត់រួម $BC$)

នាំឱ្យ $\sin A=\dfrac{a}{2R}$ $(1)$

➢**ករណី $A$ ជាមុំទាល**




គេគូសអង្កត់ផ្ចិត $CD$ នោះគេបាន $\Delta BCD$ ជាត្រីកោណកែងត្រង់ $B$

គេបាន $\sin D=\dfrac{BC}{CD}$ ឬ $\sin D=\dfrac{a}{2R}$ ព្រោះ $BC=a$ , $CD=2R$

ម្យ៉ាងទៀត $ABC$ ជាត្រីកោណចារឹកក្នុងរង្វង់ នោះផលបូកមុំឈម $\angle A+\angle D=180^\circ$

នាំឱ្យ $\sin D=\sin(180^\circ-A)=\sin A$ ព្រោះ $\sin(180^\circ-\alpha)=\sin\alpha$

គេបាន $\sin A=\dfrac{a}{2R}$ $(2)$

➢**ករណី $A$ ជាមុំកែង**




គេមាន $\sin A=\sin 90^\circ=1$

ហើយ $BC=2R$ នោះ $\dfrac{BC}{2R}=1$ ឬ $\dfrac{a}{2R}=1$

នាំឱ្យ $\sin A=\dfrac{a}{2R}$ $(3)$

តាមរយៈ $(1)$ , $(2)$ និង $(3)$ ឃើញថា គ្រប់ករណីនៃមុំ $A$ គេបាន $\sin A=\dfrac{a}{2R}$ ឬ $\dfrac{a}{\sin A}=2R$

ដូចគ្នាដែរ ស្រាយដូចខាងលើចំពោះមុំ $B$ និង $C$ នោះគេបាន $\dfrac{b}{\sin B}=2R$ , $\dfrac{c}{\sin C}=2R$

ដូចនេះ | ទ្រឹស្តីបទស៊ីនុស $\dfrac{a}{\sin A}=\dfrac{b}{\sin B}=\dfrac{c}{\sin C}=2R$ ត្រូវបានស្រាយបញ្ជាក់ | ។

✓**បញ្ជាក់** -មុំចារឹកដែលមានធ្នូស្កាត់រួម ជាមុំប៉ុនគ្នា

-ត្រីកោណចារឹកកន្លះរង្វង់ ជាត្រីកោណមានជ្រុងមួយជាអង្កត់ផ្ចិតនៃរង្វង់ ហើយត្រីកោណនេះជាត្រីកោណកែង ។

-ផលបូកមុំក្នុងទាំងបីនៃត្រីកោណមួយ ស្មើនឹង $180^\circ$ ។

-មុំចារឹកស្កាត់ដោយធ្នូមួយ មានរង្វាស់ស្មើនឹងពាក់កណ្តាលធ្នូស្កាត់នោះ ។

៨. ក. ស្រាយបញ្ជាក់ទ្រឹស្តីបទកូស៊ីនុស ៖
$$a^2=b^2+c^2-2bc\cdot\cos A$$
$$b^2=a^2+c^2-2ac\cdot\cos B$$
$$c^2=a^2+b^2-2ab\cdot\cos C$$

គេនឹងស្រាយគ្រប់ករណីនៃមុំ $A$ ដែលនាំឱ្យគេបានទ្រឹស្តីបទកូស៊ីនុស $a^2=b^2+c^2-2bc\cdot\cos A$

ចំពោះត្រីកោណ $ABC$ នោះមុំ $A$ អាចជាមុំស្រួច ឬមុំទាល ឬមុំកែង

➢**ករណី $A$ ជាមុំស្រួច**

គេសង់កម្ពស់ $CH$ នៃត្រីកោណ $ABC$

គេបាន $CH=b\cdot\sin A$ , $AH=b\cdot\cos A$ និង $HB=AB-AH$




តាមទ្រឹស្តីបទពីតាគ័រ ចំពោះត្រីកោណកែង $BCH$ ៖

គេបាន $BC^2=CH^2+HB^2$ ឬ $BC^2=CH^2+\left(AB-AH\right)^2$

នាំឱ្យ $a^2=\left(b\cdot\sin A\right)^2+\left(c-b\cdot\cos A\right)^2$

$$=b^2\cdot\sin^2 A+c^2-2bc\cdot\cos A+b^2\cdot\cos^2 A$$
$$=b^2\left(\sin^2 A+\cos^2 A\right)+c^2-2bc\cdot\cos A$$
$$=b^2+c^2-2bc\cdot\cos A$$

➢**ករណី $A$ ជាមុំទាល**

គេសង់កម្ពស់ $CH$ នៃត្រីកោណ $ABC$ លើបន្លាយ $AB$




គេបាន $HB=AB+HA$ , $\angle CAH=180°-A$

$CH=b\cdot\sin\left(180°-A\right)$ ឬ $CH=b\cdot\sin A$

$HA=b\cdot\cos\left(180°-A\right)$ ឬ $HA=-b\cdot\cos A$

តាមទ្រឹស្តីបទពីតាគ័រ ចំពោះត្រីកោណកែង $BCH$ ៖

គេបាន $BC^2=CH^2+HB^2$ ឬ $BC^2=CH^2+\left(AB+HA\right)^2$

នាំឱ្យ $a^2=\left(b\cdot\sin A\right)^2+\left(c-b\cdot\cos A\right)^2$

$$=b^2\cdot\sin^2 A+c^2-2bc\cdot\cos A+b^2\cdot\cos^2 A$$
$$=b^2\left(\sin^2 A+\cos^2 A\right)+c^2-2bc\cdot\cos A$$
$$=b^2+c^2-2bc\cdot\cos A$$

➢**ករណី $A$ ជាកែង**




តាមទ្រឹស្តីបទពីតាគ័រ គេបាន $a^2=b^2+c^2$

គេអាចសរសេរ $a^2=b^2+c^2-2bc\cdot 0$

ឬ $a^2=b^2+c^2-2bc\cdot\cos A$ ព្រោះ $\cos A=\cos 90°=0$

ឃើញថា ទាំងបីករណីនៃមុំ $A$ គេបាន $a^2=b^2+c^2-2bc\cdot\cos A$

ស្រាយដូចគ្នាដែរ ចំពោះជ្រុង $b$ និងជ្រុង $c$ នោះគេបាន $b^2=a^2+c^2-2ac\cdot\cos B$ , $c^2=a^2+b^2-2ab\cdot\cos C$

ដូចនេះ ទ្រឹស្តីបទកូស៊ីនុស
$$a^2=b^2+c^2-2bc\cdot\cos A$$
$$b^2=a^2+c^2-2ac\cdot\cos B$$
$$c^2=a^2+b^2-2ab\cdot\cos C$$
ត្រូវបានស្រាយបញ្ជាក់ ។

ខ. ទាញបញ្ជាក់ថា $\cos A=\dfrac{b^2+c^2-a^2}{2bc}$ , $\cos B=\dfrac{a^2+c^2-b^2}{2ac}$ , $\cos C=\dfrac{a^2+b^2-c^2}{2ab}$

គេមាន
$$a^2=b^2+c^2-2bc\cdot\cos A$$
$$b^2=a^2+c^2-2ac\cdot\cos B$$
$$c^2=a^2+b^2-2ab\cdot\cos C$$
ជាទ្រឹស្តីបទកូស៊ីនុស បានស្រាយបញ្ជាក់រួចខាងលើ

នាំឱ្យ
$$2bc\cdot\cos A=b^2+c^2-a^2$$
$$2ac\cdot\cos B=a^2+c^2-b^2$$
$$2ab\cdot\cos C=a^2+b^2-c^2$$
ទាញបាន
$$\cos A=\frac{b^2+c^2-a^2}{2bc}$$
$$\cos B=\frac{a^2+c^2-b^2}{2ac}$$
$$\cos C=\frac{a^2+b^2-c^2}{2ab}$$

ដូចនេះ ទាញបានថា $\cos A=\dfrac{b^2+c^2-a^2}{2bc}$ , $\cos B=\dfrac{a^2+c^2-b^2}{2ac}$ , $\cos C=\dfrac{a^2+b^2-c^2}{2ab}$ ។

9. ក. ស្រាយបញ្ជាក់ថា ផ្ទៃក្រឡា $S$ នៃត្រីកោណ $ABC$ គឺ ៖ $S=\dfrac{1}{2}ab\sin C=\dfrac{1}{2}ac\sin B=\dfrac{1}{2}bc\sin A$

ចំពោះគ្រប់ករណីនៃមុំ $C$ គេនឹងស្រាយបញ្ជាក់ថា $S=\dfrac{1}{2}ab\sin C$

➢ករណី $C$ ជាមុំស្រួច




គេមាន $S=\dfrac{1}{2}\times AC\times BH$

ដោយ $BH=a\sin C$ និង $AC=b$

គេបាន $S=\dfrac{1}{2}\times b\times a\sin C$ ឬ $S=\dfrac{1}{2}ab\sin C$

➢ករណី $C$ ជាមុំទាល




គេមាន $S=\dfrac{1}{2}\times AC\times BH$

ដោយ $BH=a\sin\left(180^\circ-C\right)=a\sin C$ និង $AC=b$

គេបាន $S=\dfrac{1}{2}\times b\times a\sin C$ ឬ $S=\dfrac{1}{2}ab\sin C$

➢ករណី $C$ ជាកែង




គេមាន $S=\dfrac{1}{2}\times AC\times BC$ ឬ $S=\dfrac{1}{2}\times AC\times BC\times 1$

ដោយ $AC=b$ , $BC=a$ និង $1=\sin 90^\circ=\sin C$

គេបាន $S=\dfrac{1}{2}\times b\times a\times\sin C$ ឬ $S=\dfrac{1}{2}ab\sin C$

ឃើញថា គ្រប់ករណីនៃមុំ $C$ គេបានក្រឡាផ្ទៃនៃត្រីកោណ $ABC$ គឺ $S=\dfrac{1}{2}ab\sin C$

ស្រាយដូចគ្នា ចំពោះករណីនៃមុំ $B$ និងមុំ $A$ នោះគេបាន $S=\dfrac{1}{2}ac\sin B$ និង $S=\dfrac{1}{2}bc\sin A$

ដូចនេះ ផ្ទៃនៃត្រីកោណ $ABC$ គឺ ៖ $S=\dfrac{1}{2}ab\sin C=\dfrac{1}{2}ac\sin B=\dfrac{1}{2}bc\sin A$ ត្រូវបានស្រាយបញ្ជាក់ ។

ខ. ទាញបង្ហាញថា $\frac{abc}{2S}=\frac{c}{\sin C}=\frac{b}{\sin B}=\frac{a}{\sin A}$

គេមាន $S=\frac{1}{2}ab\sin C=\frac{1}{2}ac\sin B=\frac{1}{2}bc\sin A$

នាំឱ្យ $2S=ab\sin C=ac\sin B=bc\sin A$ (បានដោយគុណសមាមាត្រខាងលើនឹង $2$)

អាចសរសេរ $\frac{1}{2S}=\frac{1}{ab\sin C}=\frac{1}{ac\sin B}=\frac{1}{bc\sin A}$ (ព្រោះបើ $a=b$ គេអាចសរសេរ $\frac{1}{a}=\frac{1}{b}$)

គេបាន $\frac{abc}{2S}=\frac{c}{\sin C}=\frac{b}{\sin B}=\frac{a}{\sin A}$ (បានដោយគុណសមាមាត្រខាងលើនឹង $abc$)

ដូចនេះ $\frac{abc}{2S}=\frac{c}{\sin C}=\frac{b}{\sin B}=\frac{a}{\sin A}$ ត្រូវបានបង្ហាញ ។

10. ស្រាយបញ្ជាក់ថា រូបមន្តហេរ៉ុង $S=\sqrt{p(p-a)(p-b)(p-c)}$




គេមាន $S=\frac{1}{2}bc\sin A \quad (1)$

ដោយ $\sin^2 A+\cos^2 A=1$ នោះ $\sin^2 A=1-\cos^2 A$

នាំឱ្យ $\sin^2 A=(1-\cos A)(1+\cos A)$ តែ $\cos A=\frac{b^2+c^2-a^2}{2bc}$

$$\sin^2 A=\left(1-\frac{b^2+c^2-a^2}{2bc}\right)\left(1+\frac{b^2+c^2-a^2}{2bc}\right)=\left(\frac{2bc-b^2-c^2+a^2}{2bc}\right)\left(\frac{2bc+b^2+c^2-a^2}{2bc}\right)$$

$$=\left(\frac{a^2-(b-c)^2}{2bc}\right)\left(\frac{(b+c)^2-a^2}{2bc}\right)=\left(\frac{(a-b+c)(a+b-c)}{2bc}\right)\left(\frac{(b+c-a)(b+c+a)}{2bc}\right)$$

$$=\frac{1}{4b^2c^2}(a-b+c)(a+b-c)(b+c-a)(b+c+a)$$

ដោយ $0^\circ<A<180^\circ$ នោះ $\sin A>0$

គេបាន $\sin A=\sqrt{\frac{1}{4b^2c^2}(a-b+c)(a+b-c)(b+c-a)(b+c+a)}$

$$\sin A=\frac{1}{2bc}\sqrt{(a-b+c)(a+b-c)(b+c-a)(b+c+a)}$$

នាំឱ្យ $(1):\ S=\frac{1}{2}bc\times\frac{1}{2bc}\sqrt{(a-b+c)(a+b-c)(b+c-a)(b+c+a)}$

$$S=\frac{1}{4}\sqrt{(a-b+c)(a+b-c)(b+c-a)(b+c+a)} \quad (2)$$

ដោយ $p$ ជាកន្លះបរិមាត្រ នោះ $p=\frac{a+b+c}{2}$ ឬ $a+b+c=2p$

ទាញបាន $a-b+c=2p-2b$ , $a+b-c=2p-2c$ , $b+c-a=2p-2a$

នាំឱ្យ $(2):\ S=\frac{1}{4}\sqrt{(2p-2b)\cdot(2p-2c)\cdot(2p-2a)\cdot 2p}=\sqrt{(p-b)(p-c)(p-a)p}$

ដូចនេះ រូបមន្តហេរ៉ុង $S=\sqrt{p(p-a)(p-b)(p-c)}$ ត្រូវបានស្រាយបញ្ជាក់ ។

# ការស្រាយបញ្ជាក់លើមេរៀន ចម្លាស់-បន្សំ

1. ស្រាយបញ្ជាក់ថា ចម្លាស់នៃ $n$ ធាតុខុសៗគ្នាស្មើ $n!$ ។
2. ស្រាយបញ្ជាក់ថា ចម្លាស់នៃ $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា គឺ $P(n\,,r)=\dfrac{n!}{(n-r)!}$ ។
3. បង្ហាញថា $0!=1$
4. ស្រាយបញ្ជាក់ថា ចម្លាស់ច្រំដែលនៃ $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា ស្មើនឹង $n^r$ ។
5. ស្រាយបញ្ជាក់ថា ចម្លាស់វង់នៃ $n$ ធាតុស្មើនឹង $\dfrac{n!}{n}=(n-1)!$ ។
6. ស្រាយបញ្ជាក់ថា បន្សំនៃ $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា គឺ $C(n\,,r)=\dfrac{P(n\,,r)}{r!}=\dfrac{n!}{(n-r)!\times r!}$ ។
7. បង្ហាញថា $C(n\,,n-r)=C(n\,,r)$ ។
8. បង្ហាញថា $C(n\,,0)=C(n\,,n)$ ។
9. បង្ហាញថា $C(3\,,0)+C(3\,,1)+C(3\,,2)+C(3\,,3)=2^3$ ។
10. ស្រាយបញ្ជាក់ថា ចម្លាស់បែងចែកបាននៃ $n$ ធាតុ ដែលមានប្រភេទទី១ $r_1$ , ប្រភេទទី២ $r_2$ , ... , ប្រភេទទី $k$ $r_k$ គឺស្មើ $\dfrac{n!}{r_1!\times r_2!\times\ldots\times r_k!}$ ។
11. បង្ហាញថា $(1+a)^n=C(n,0)1+C(n,1)a+C(n,2)a^2+\ldots+C(n,r)a^r+\ldots+C(n,n)a^n$ ។
12. បង្ហាញថា $(a+b)^n=C(n,0)a^n+C(n,1)a^{n-1}b+C(n,2)a^{n-2}b^2+\ldots+C(n,r)a^{n-r}b^r+\ldots+C(n,n)b^n$ ។

# ការស្រាយបញ្ជាក់លើមេរៀន ចម្លាស់-បន្សំ

1. **ស្រាយបញ្ជាក់ថា ចម្លាស់នៃ $n$ ធាតុខុសៗគ្នាស្មើ $n!$**

តាមនិយមន័យចម្លាស់ : ចម្លាស់នៃ $n$ ធាតុខុសគ្នា គឺជាតម្រៀបគិតលំដាប់នៃ $n$ ធាតុជាជួរដេក ដែលធាតុមួយដាក់នៅលំដាប់ទីមួយ ធាតុមួយដាប់នៅលំដាប់ទីពីរ ធាតុមួយដាក់នៅលំដាប់ទីបី និងបន្តបន្ទាប់ ។ (១២ កម្មវិធីចាស់ ទំព័រ ១៩១)

ដោយ ធាតុដាក់នៅលំដាប់ទី 1 មាន $n$ របៀប

ធាតុដាក់នៅលំដាប់ទី 2 មាន $n-1$ របៀប

ធាតុដាក់នៅលំដាប់ទី 3 មាន $n-2$ របៀប

..................................................................

ធាតុដាក់នៅលំដាប់ទី $n-2$ មាន 3 របៀប

ធាតុដាក់នៅលំដាប់ទី $n-1$ មាន 2 របៀប

ធាតុដាក់នៅលំដាប់ទី $n$ មាន 1 របៀប

តាមគោលការណ៍ផលគុណនៃការតម្រៀប $n$ វត្ថុជាបន្តបន្ទាប់គ្នា រហូតដល់តម្រៀបវត្ថុទី $n$ នៅចុងគេបំផុត

នាំឱ្យ ចំនួនចម្លាស់នៃ $n$ ធាតុខុសៗគ្នា $=n\times(n-1)\times(n-2)\times\ldots\times 3\times 2\times 1$

គេតាង $n\times(n-1)\times(n-2)\times\ldots\times 3\times 2\times 1=n!$ (អានថា $n$ ហ្វាក់តូរីយ៉ែល)

ដូចនេះ: **ចម្លាស់នៃ $n$ ធាតុខុសៗគ្នាស្មើ $n!$ ត្រូវបានស្រាយបញ្ជាក់** ។

2. **ស្រាយបញ្ជាក់ថា ចម្លាស់នៃ $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា គឺ $P(n,r)=\dfrac{n!}{(n-r)!}$**

គេចង់យក $r$ ធាតុពី $n$ ធាតុខុសគ្នា ដើម្បីយកមកតម្រៀប

បើគេយក $r$ ធាតុចេញពី $n$ ធាតុខុសគ្នា នោះធាតុដែលនៅសល់គឺ $n-r$

បើគេរៀប ធាតុនៅសល់ គឺបាន $(n-r)!$ របៀប

គេតាង $P(n,r)$ ជាចំនួនតម្រៀបនៃ $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា

នាំឱ្យ របៀបនៃការរៀប $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា គឺ $P(n,r)$ របៀប

ដោយ ការតម្រៀប $n$ ធាតុខុសៗគ្នាស្មើ $n!$

តាមរយៈ គោលការណ៍ផលគុណគេបាន $(n-r)!\times P(n,r)=n!\quad\Rightarrow P(n,r)=\dfrac{n!}{(n-r)!}$

ដូចនេះ: **ចម្លាស់នៃ $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា គឺ $P(n,r)=\dfrac{n!}{(n-r)!}$ ត្រូវបានស្រាយបញ្ជាក់** ។

✓**សម្គាល់** : $P(n,r)=\dfrac{n!}{(n-r)!}=n\times(n-1)\times(n-2)\times\ldots\times(n-r+1)$

3. **បង្ហាញថា** $0!=1$

**➢របៀបទី១** តាមរូបមន្ត ចម្លាស់

គេមាន រូបមន្ត $P(n,r)=\dfrac{n!}{(n-r)!}$

បើគេយក $r=n$ គេបាន $P(n,n)=\dfrac{n!}{(n-n)!}=\dfrac{n!}{0!}$ $(1)$

តែ នៅពេលដែល $r=n$ មានន័យថា ចម្លាស់នៃ $n$ ធាតុយកពី $n$ ធាតុខុសគ្នា ស្មើនឹងចម្លាស់នៃ $n$ ធាតុ

គេបាន $P(n,n)=n!$ $(2)$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ គេបាន $\dfrac{n!}{0!}=n! \Rightarrow 0!=1$

ដូចនេះ

| តម្លៃ $0!=1$ ត្រូវបានបង្ហាញ |
|---|

។

**➢របៀបទី២** តាមរូបមន្ត ហ្វាក់តូរ្យែល

គេមាន រូបមន្ត $n!=n\times(n-1)\times(n-2)\times\ldots\times3\times2\times1$ ដែល $n$ ជាចំនួនគត់

ចំពោះ $n$ ជាចំនួនគត់ និង $n>0$ នាំឱ្យ $(n-1)!=(n-1)\times(n-2)\times\ldots\times3\times2\times1$

គេបាន $n!=n\times(n-1)!$ នាំឱ្យ $(n-1)!=\dfrac{n!}{n}$

បើគេឱ្យ $n=1$ នោះគេបាន $(1-1)!=\dfrac{1!}{1} \Leftrightarrow 0!=1$

ដូចនេះ

| តម្លៃ $0!=1$ ត្រូវបានបង្ហាញ |
|---|

។

4. **ស្រាយបញ្ជាក់ថា ចម្លាស់ច្រំដែលនៃ $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា ស្មើនឹង $n^r$**

គេមាន $n$ ធាតុខុសគ្នា

គេយក $r$ ធាតុមកមកធ្វើចម្លាស់ច្រំដែល

គេបាន ធាតុដាក់នៅលំដាប់ទី $1$ មាន $n$ របៀប

ធាតុដាក់នៅលំដាប់ទី $2$ មាន $n$ របៀប

ធាតុដាក់នៅលំដាប់ទី $3$ មាន $n$ របៀប

..................................................................

ធាតុដាក់នៅលំដាប់ទី $r-2$ មាន $n$ របៀប

ធាតុដាក់នៅលំដាប់ទី $r-1$ មាន $n$ របៀប

ធាតុដាក់នៅលំដាប់ទី $r$ មាន $n$ របៀប

តាមគោលការណ៍ផលគុណនៃការតម្រៀបច្រំដែលនៃ $r$ វត្ថុជាបន្តបន្ទាប់គ្នា យកពី $n$ ខុសគ្នា

នាំឱ្យ ចម្លាស់ច្រំដែលនៃ $r$ ធាតុយកពី $n$ គឺ $\underbrace{n\times n\times n\times\ldots\times n\times n\times n}_{r\text{ កត្តា}}=n^r$

ដូចនេះ

| ចម្លាស់ច្រំដែលនៃ $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា ស្មើនឹង $n^r$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

5. **ស្រាយបញ្ជាក់ថា ចម្លាស់រង់នៃ $n$ ធាតុស្មើនឹង $\frac{n!}{n}=(n-1)!$**

គេមាន ចម្លាស់នៃ $n$ ធាតុខុសៗគ្នារៀបតាមជួរដេក ស្មើ $n!$

ដោយ ពេលដែលរៀប $n$ ធាតុខុសៗគ្នា ជារង្វង់ឃើញថា ឃើញថាវាតិចជាង រៀប $n$ ធាតុខុសៗគ្នា ជាជួរដេក ចំនួន $n$ ដង

នាំឱ្យ ចំនួនចម្លាស់រង់នៃ $n$ ធាតុខុសៗគ្នា ស្មើនឹង $\frac{n!}{n}=\frac{n\times(n-1)!}{n}=(n-1)!$

ដូចនេះ: ចំនួនចម្លាស់រង់នៃ $n$ ធាតុខុសៗគ្នា ស្មើនឹង $\frac{n!}{n}=(n-1)!$ ត្រូវបានស្រាយបញ្ជាក់ ។

6. **ស្រាយបញ្ជាក់ថា បន្សំនៃ $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា គឺ $C(n,r)=\frac{P(n,r)}{r!}=\frac{n!}{(n-r)!\times r!}$**

គេមាន ចម្លាស់នៃ $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា គឺជាតម្រៀបគិតលំដាប់ តាងដោយ $P(n,r)=\frac{n!}{(n-r)!}$

បន្សំនៃ $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា គឺជាតម្រៀបមិនគិតលំដាប់ តាងដោយ $C(n,r)$

ដោយ បន្សំនៃ $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា តិចជាង ចម្លាស់នៃ $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា ចំនួន $r!$ ដង

នាំឱ្យ $C(n,r)=\frac{P(n,r)}{r!}$ ឬ $C(n,r)=\frac{\frac{n!}{(n-r)!\times r!}}{r!}=\frac{n!}{(n-r)!\times r!}$ ព្រោះ $P(n,r)=\frac{n!}{(n-r)!}$

ដូចនេះ: បន្សំនៃ $r$ ធាតុយកពី $n$ ធាតុខុសៗគ្នា គឺ $C(n,r)=\frac{P(n,r)}{r!}=\frac{n!}{(n-r)!\times r!}$ ត្រូវបានស្រាយបញ្ជាក់ ។

7. **បង្ហាញថា $C(n,n-r)=C(n,r)$**

គេមាន

$$C(n,n-r)=\frac{n!}{[n-(n-r)]!\times(n-r)!}$$
$$=\frac{n!}{r!\times(n-r)!}$$
$$=\frac{n!}{(n-r)!\times r!}$$
$$=C(n,r)$$

ដូចនេះ: $C(n,n-r)=C(n,r)$ ត្រូវបានបង្ហាញ ។

8. **បង្ហាញថា $C(n,0)=C(n,n)$**

ដោយ $C(n,0)=\frac{n!}{(n-0)!\times 0!}=\frac{n!}{n!\times 0!}=\frac{1}{0!}=\frac{1}{1}=1$

ហើយ $C(n,n)=\frac{n!}{(n-n)!\times n!}=\frac{n!}{0!\times n!}=\frac{1}{0!}=\frac{1}{1}=1$

ដូចនេះ: $C(n,0)=C(n,n)$ ត្រូវបានបង្ហាញ ។

9. បង្ហាញថា $C(3,0)+C(3,1)+C(3,2)+C(3,3)=2^3$

ដោយ $C(3,0)+C(3,1)+C(3,2)+C(3,3)$

$$=\frac{3!}{3!\times 0!}+\frac{3!}{2!\times 1!}+\frac{3!}{1!\times 2!}+\frac{3!}{0!\times 3!}$$

$=1+3+3+1$

$=8=2^3$

ដូចនេះ: $C(3,0)+C(3,1)+C(3,2)+C(3,3)=2^3$ ត្រូវបានបង្ហាញ ។

10. ស្រាយបញ្ជាក់ថា ចម្លាស់បែងចែកបាននៃ $n$ ធាតុ ដែលមានប្រភេទទី១ $r_1$ , ប្រភេទទី២ $r_2$ , ... , ប្រភេទទី $k$ $r_k$

គឺស្មើ $\frac{n!}{r_1!\times r_2!\times\ldots\times r_k!}$

គេមាន ចម្លាស់នៃ $n$ ធាតុស្មើ $n!$

-បើក្នុងចំណោម $n$ ធាតុ មានប្រភេទទី១ ចំនួន $r_1$ ដូចគ្នា

នោះចំនួនចម្លាស់នៃ $n$ ថយចុះ $r_1!$ ដង គឺ $\frac{n!}{r_1!}$

-បើក្នុងចំណោម $n$ ធាតុ មានប្រភេទទី១ ចំនួន $r_1$ ដូចគ្នា និងប្រភេទទី២ ចំនួន $r_2$ ដូចគ្នា

នោះចំនួនចម្លាស់នៃ $n$ ថយចុះ $r_1!\times r_2!$ ដង គឺ $\frac{n!}{r_1!\times r_2!}$

..........................................................................................................................................

-បើក្នុងចំណោម $n$ ធាតុ មានប្រភេទទី១ ចំនួន $r_1$ ដូចគ្នា ប្រភេទទី២ ចំនួន $r_2$ ដូចគ្នា , ... , ប្រភេទទី $k$ ចំនួន $r_k$ ដូចគ្នា

នោះចំនួនចម្លាស់នៃ $n$ ថយចុះ $r_1!\times r_2!\times\ldots\times r_k!$ ដង គឺ $\frac{n!}{r_1!\times r_2!\times\ldots\times r_k!}$

ដូចនេះ: ចំនួនចម្លាស់អាចបែងចែកបាននៃ $n$ ធាតុ ដែលមានប្រភេទទី១ $r_1$ , ប្រភេទទី២ $r_2$ , ... , ប្រភេទទី $k$ $r_k$ គឺស្មើ $\frac{n!}{r_1!\times r_2!\times\ldots\times r_k!}$

11. បង្ហាញថា $(1+a)^n=C(n,0)1+C(n,1)a+C(n,2)a^2+\ldots+C(n,r)a^r+\ldots+C(n,n)a^n$

គេអាចបំលែងធាតុនៃត្រីកោណប៉ាស្កាល់ ទៅជាបន្សំបានដូចខាងក្រោម ៖

| | |
|---|---|
| 1 1 | $C(1,0)$ $C(1,1)$ |
| 1 2 1 | $C(2,0)$ $C(2,1)$ $C(2,2)$ |
| 1 3 3 1 | $C(3,0)$ $C(3,1)$ $C(3,2)$ $C(3,3)$ |
| 1 4 6 4 1 | $C(4,0)$ $C(4,1)$ $C(4,2)$ $C(4,3)$ $C(4,4)$ |
| 1 5 10 10 5 1 | $C(5,0)$ $C(5,1)$ $C(5,2)$ $C(5,3)$ $C(5,4)$ $C(5,5)$ |
| 1 6 15 20 15 6 1 | $C(6,0)$ $C(6,1)$ $C(6,2)$ $C(6,3)$ $C(6,4)$ $C(6,5)$ $C(6,6)$ |
| ............................................ | ............................................ |

គេបាន ៖

$(1+a)^1 = 1+a \qquad = C(1,0)+C(1,1)a$

$(1+a)^2 = 1+2a+a^2 \qquad = C(2,0)+C(2,1)a+C(2,2)a^2$

$(1+a)^3 = 1+3a+3a^2+a^3 \qquad = C(3,0)+C(3,1)a+C(3,2)a^2+C(3,3)a^3$

$(1+a)^4 = 1+4a+6a^2+4a^3+a^4 \qquad = C(4,0)+C(4,1)a+C(4,2)a^2+C(4,3)a^3+C(4,4)a^4$

$(1+a)^5 = 1+5a+10a^2+10a^3+5a^4+a^5 \qquad = C(5,0)+C(5,1)a+C(5,2)a^2+C(5,3)a^3+C(5,4)a^4+C(5,5)a^5$

.............................................................. = ..............................................................

$(1+a)^n = \qquad = C(n,0)+C(n,1)a+C(n,2)a^2+C(n,3)a^3+\ldots+C(n,n)a^n$

ដូចនេះ $(1+a)^n = C(n,0)1+C(n,1)a+C(n,2)a^2+\ldots+C(n,r)a^r+\ldots+C(n,n)a^n$ ត្រូវបានបង្ហាញ ។

12. **បង្ហាញថា** $(a+b)^n = C(n,0)a^n+C(n,1)a^{n-1}b+C(n,2)a^{n-2}b^2+\ldots+C(n,r)a^{n-r}b^r+\ldots+C(n,n)b^n$

គេមាន $(a+b)^n$ អាចសរសេរ $(a+b)^n = \left[a\left(1+\frac{b}{a}\right)\right]^n = a^n\left(1+\frac{b}{a}\right)^n$

តាមរូបមន្ត $(1+a)^n = C(n,0)1+C(n,1)a+C(n,2)a^2+\ldots+C(n,r)a^r+\ldots+C(n,n)a^n$ (បានស្រាយរួច)

គេបាន $\left(1+\frac{b}{a}\right)^n = C(n,0)1+C(n,1)\frac{b}{a}+C(n,2)\left(\frac{b}{a}\right)^2+C(n,3)\left(\frac{b}{a}\right)^3+\ldots+C(n,n)\left(\frac{b}{a}\right)^n$

$$= C(n,0)1+C(n,1)\frac{b}{a}+C(n,2)\frac{b^2}{a^2}+C(n,3)\frac{b^3}{a^3}+\ldots+C(n,n)\frac{b^n}{a^n}$$

នាំឱ្យ $a^n\left(1+\frac{b}{a}\right)^n = a^n\left[C(n,0)1+C(n,1)\frac{b}{a}+C(n,2)\frac{b^2}{a^2}+C(n,3)\frac{b^3}{a^3}+\ldots+C(n,n)\frac{b^n}{a^n}\right]$

$$= C(n,0)a^n+C(n,1)a^{n-1}b+C(n,2)a^{n-2}b^2+\ldots+C(n,n)b^n$$

ដូចនេះ $(a+b)^n = C(n,0)a^n+C(n,1)a^{n-1}b+C(n,2)a^{n-2}b^2+\ldots+C(n,r)a^{n-r}b^r+\ldots+C(n,n)b^n$ ។

13. **បង្ហាញថា** $C(n,0)+C(n,1)+C(n,2)+\ldots+C(n,n)=2^n$

គេមាន $(a+b)^n = C(n,0)a^n+C(n,1)a^{n-1}b+C(n,2)a^{n-2}b^2+\ldots+C(n,r)a^{n-r}b^r+\ldots+C(n,n)b^n$

ចំពោះ $a=1$ និង $b=1$

គេបាន $(1+1)^n = C(n,0)+C(n,1)+C(n,2)+\ldots+C(n,n)$

$2^n = C(n,0)+C(n,1)+C(n,2)+\ldots+C(n,n)$

ដូចនេះ $C(n,0)+C(n,1)+C(n,2)+\ldots+C(n,n)=2^n$ ត្រូវបានបង្ហាញ ។

14. **បង្ហាញថា** $C(n,0)-C(n,1)+C(n,2)-C(n,3)+...+(-1)^n C(n,n)=0$

គេមាន $(1+a)^n = C(n,0)1+C(n,1)a+C(n,2)a^2+C(n,3)a^3+...+C(n,n)a^n \quad (1)$

គេយក $a=-1$ ជំនួសក្នុង $(1)$

គេបាន $[1+(-1)]^n = C(n,0)+C(n,1)(-1)+C(n,2)(-1)^2+C(n,3)(-1)^3+...+C(n,n)(-1)^n$

$$0 = C(n,0)-C(n,1)+C(n,2)-C(n,3)+...+(-1)^n C(n,n)$$

ដូចនេះ $\boxed{C(n,0)-C(n,1)+C(n,2)-C(n,3)+...+(-1)^n C(n,n)=0}$ ត្រូវបានបង្ហាញ ។

# ការស្រាយបញ្ជាក់លើមេរៀន វិចទ័រ

1. គេឱ្យ $A$ , $B$ និង $C$ ជាបីចំណុចរត់មិនត្រង់គ្នា ។ បង្ហាញថា $|\overrightarrow{AB}|+|\overrightarrow{BC}|>|\overrightarrow{AC}|$ ។
2. បង្ហាញលក្ខណៈគ្រឹះនៃវិចទ័រខាងក្រោម ៖

   ក. $\vec{a}+\vec{b}=\vec{b}+\vec{a}$ (លក្ខណៈត្រឡប់)

   ខ. $(\vec{a}+\vec{b})+\vec{c}=\vec{a}+(\vec{b}+\vec{c})$ (លក្ខណៈផ្តុំ)

   គ. $\vec{a}+\vec{0}=\vec{0}+\vec{a}=\vec{a}$

   ឃ. $\vec{a}+(-\vec{a})=\vec{0}$
3. បង្ហាញថា ប្រមាណវិធីដកវិចទ័រ $\overrightarrow{PQ}=\overrightarrow{OQ}-\overrightarrow{OP}$ ។
4. បង្ហាញថា $-(\vec{a}+\vec{b})=-\vec{a}-\vec{b}$ ។
5. ស្រាយបញ្ជាក់លក្ខណៈគ្រឹះនៃវិចទ័រខាងក្រោម ៖

   ក. $(mn)\vec{a}=m(n\vec{a})$ (លក្ខណៈផ្តុំ)

   ខ. $(m+n)\vec{a}=m\vec{a}+n\vec{a}$ (លក្ខណៈបំបែក $I$ )

   គ. $m(\vec{a}+\vec{b})=m\vec{a}+m\vec{b}$ (លក្ខណៈបំបែក $II$ )
6. គេមានវិចទ័រ $\vec{a}\neq\vec{0}$ ។ បង្ហាញថា $\vec{i}=\dfrac{\vec{a}}{|\vec{a}|}=\dfrac{1}{|\vec{a}|}\vec{a}$ ជាវិចទ័រឯកតា ដែលមានទិសដៅដូចទិសដៅវិចទ័រ $\vec{a}$ ។
7. បង្ហាញថា បើ $\vec{a}=(a_1\,,\,a_2)$ ប្រវែងនៃវិចទ័រ $\vec{a}$ គឺ $|\vec{a}|=\sqrt{a_1^2+a_2^2}$ ។
8. បង្ហាញការគណនាវិចទ័រ ដោយប្រើកូអរដោនេដូចខាងក្រោម ៖

   ក. $(a_1\,,\,a_2)+(b_1\,,\,b_2)=(a_1+b_1\,,\,a_2+b_2)$

   ខ. $(a_1\,,\,a_2)-(b_1\,,\,b_2)=(a_1-b_1\,,\,a_2-b_2)$

   គ. $m(a_1\,,\,a_2)=(ma_1\,,\,ma_2)$
9. បង្ហាញថា បើ $\vec{a}$ និង $\vec{b}$ ជាពីរវិចទ័រមិនសូន្យ នោះគេបាន $\vec{a}\cdot\vec{b}=\vec{b}\cdot\vec{a}$ ។
10. ដោយប្រើនិយមន័យផលគុណស្កាលែ ៖

    ក. បង្ហាញថា $|\vec{a}\cdot\vec{b}|\leq|\vec{a}||\vec{b}|$ ។

    ខ. បង្ហាញថា $\vec{a}\cdot\vec{a}=|\vec{a}|^2$ ។
11. ក. បង្ហាញថា បើ $\vec{a}\perp\vec{b}$ លុះត្រាតែ $\vec{a}\cdot\vec{b}=0$ ។

    ខ. បង្ហាញថា បើ $\vec{a}=(a_1\,,\,a_2)$ និង $\vec{b}=(b_1\,,\,b_2)$ គេបាន $\vec{a}\cdot\vec{b}=a_1b_1+a_2b_2$ ។

    គ. បង្ហាញថា $\vec{a}\perp\vec{b}$ លុះត្រាតែ $a_1b_1+a_2b_2=0$ ។

    ឃ. បង្ហាញថា $\cos\theta=\dfrac{\vec{a}\cdot\vec{b}}{|\vec{a}||\vec{b}|}=\dfrac{a_1b_1+a_2b_2}{\sqrt{a_1^2+a_2^2}+\sqrt{b_1^2+b_2^2}}$ ។

12. ចំពោះគ្រប់វ៉ិចទ័រ $\vec{a}$ , $\vec{b}$ និង $\vec{c}$ ៖

ក. បង្ហាញថា $\vec{a}\cdot\left(\vec{b}+\vec{c}\right)=\vec{a}\cdot\vec{b}+\vec{a}\cdot\vec{c}$

ខ. បង្ហាញថា $\left(\vec{a}+\vec{b}\right)\cdot\vec{c}=\vec{a}\cdot\vec{c}+\vec{b}\cdot\vec{c}$

គ. បង្ហាញថា $(m\vec{a})\cdot\vec{b}=m\left(\vec{a}\cdot\vec{b}\right)$

ឃ. បង្ហាញថា $\vec{a}\cdot\left(m\vec{b}\right)=m\left(\vec{a}\cdot\vec{b}\right)$

13. ក. បង្ហាញសមភាព $\vec{a}\cdot\left(\vec{b}-\vec{c}\right)=\vec{a}\cdot\vec{b}-\vec{a}\cdot\vec{c}$ ។

ខ. បង្ហាញសមភាព $\left(\vec{a}-\vec{b}\right)\cdot\vec{c}=\vec{a}\cdot\vec{c}-\vec{b}\cdot\vec{c}$ ។

14. ក. ស្រាយបញ្ជាក់ថា $\left|\vec{a}+\vec{b}\right|^2=\left|\vec{a}\right|^2+2\vec{a}\cdot\vec{b}+\left|\vec{b}\right|^2$ ។

ខ. ស្រាយបញ្ជាក់ថា $\left|\vec{a}-\vec{b}\right|^2=\left|\vec{a}\right|^2-2\vec{a}\cdot\vec{b}+\left|\vec{b}\right|^2$ ។

15. បង្ហាញថា ចំពោះវ៉ិចទ័រពីរ $\vec{a}$ និង $\vec{b}$ មិនសូន្យ ហើយបើ $\left|\vec{a}+\vec{b}\right|=\left|\vec{a}-\vec{b}\right|$ នោះ $\vec{a}\perp\vec{b}$ ។

16. គេឱ្យ $A(\vec{a})$ និង $B\left(\vec{b}\right)$ បង្ហាញថា $\overrightarrow{AB}=\vec{b}-\vec{a}$ ។

17. ក. ចំណុច $C(\vec{c})$ ចែក $[AB]$ ខាងក្នុងតាមផលធៀប $m:n$ ហើយ $A(\vec{a})$ និង $B\left(\vec{b}\right)$ ជាវ៉ិចទ័រទីតាំង ។

បង្ហាញថា $\vec{c}=\dfrac{m\vec{b}+n\vec{a}}{m+n}$ ។

ខ. ចំណុច $D\left(\vec{d}\right)$ ចែក $[AB]$ ខាងក្រៅតាមផលធៀប $m:n$ ហើយ $A(\vec{a})$ និង $B\left(\vec{b}\right)$ ជាវ៉ិចទ័រទីតាំង ។

បង្ហាញថា $\vec{d}=\dfrac{m\vec{b}-n\vec{a}}{m-n}$ ។

គ. បង្ហាញថា វ៉ិចទ័រទីតាំងនៃចំណុចកណ្ដាលរបស់អង្កត់ $AB$ គឺ $\dfrac{\vec{a}+\vec{b}}{2}$ ។

18. បង្ហាញថា មេដ្យានទាំងបីនៃត្រីកោណមួយប្រសព្វគ្នាបានមួយចំណុច ដោយប្រើវ៉ិចទ័រទីតាំង ។

19. បង្ហាញថា អង្កត់ដែលភ្ជាប់ចំណុចកណ្ដាលនៃជ្រុងពីររបស់ត្រីកោណមួយ ស្របទៅនឹងជ្រុងទីបី ហើយស្មើពាក់កណ្ដាលនៃប្រវែងជ្រុងទីបីនេះ ដោយប្រើវ៉ិចទ័រទីតាំង ។

20. បង្ហាញថាកូអរដោនេនៃចំណុច $C$ ដែលចែកអង្កត់ $AB$ ខាងក្នុង ដែលភ្ជាប់ពីចំណុច $A(x_1\,,\,y_1)$ និង $B(x_2\,,\,y_2)$ តាមផលធៀប $m:n$ ឱ្យដោយរូបមន្ត $x=\dfrac{mx_2+nx_1}{m+n}$ , $y=\dfrac{my_2+ny_1}{m+n}$ ។

21. បង្ហាញថា សមីការប៉ារ៉ាម៉ែតនៃបន្ទាត់ដែលកាត់តាមចំណុច $P_0(x_0\,,\,y_0)$ និងមានវ៉ិចទ័រប្រាប់ទិស $\vec{u}=(a\,,b)$ កំណត់ដោយ ៖

ក. $\vec{p}=\vec{p}_0+t\vec{u}$ ជាសមីការប៉ារ៉ាម៉ែត្រទម្រង់វ៉ិចទ័រ ។

ខ. $\begin{cases}x=x_0+at\\ y=y_0+bt\end{cases}$ ដែល $t$ ជាចំនួនពិត ជាសមីការប៉ារ៉ាម៉ែត្រទម្រង់កូអរដោនេ ។

គ. បើ $a\neq 0$ និង $b\neq 0$ ទាញបង្ហាញថា គេបាន $\dfrac{x-x_0}{a}=\dfrac{y-y_0}{b}$ រួចទាញបន្តថា $y-y_0=\dfrac{b}{a}(x-x_0)$ ។

22. បង្ហាញថា បន្ទាត់ដែលកាត់តាមពីរចំណុច $A(\vec{a})$ និង $B\left(\vec{b}\right)$ មានសមីការប៉ារ៉ាម៉ែត្រ $\vec{p}=\vec{a}+t\left(\vec{b}-\vec{a}\right)$ ។

23. បង្ហាញថា ដើម្បីឱ្យចំណុច $C(\vec{c})\in AB$ ដែល $A(\vec{a})$ និង $B\left(\vec{b}\right)$ គឺមានចំនួនពិត $m$ និង $n$ ដែល $m+n=1$ ហើយ $\vec{c}=m\vec{a}+n\vec{b}$ ។

24. ក. បង្ហាញថា សមីការបន្ទាត់ដែលកាត់តាមចំណុច $P_0(x_0\ ,\ y_0)$ ហើយកែងទៅនឹងវ៉ិចទ័រ $\vec{n}=(a\ ,\ b)$ គឺ

$$\begin{cases}\vec{n}\cdot(\vec{p}-\vec{p}_0)=0\\ a(x-x_0)+b(y-y_0)=0\end{cases}$$ ។

ខ. បើតាង $c=-ax_0-by_0$ គេអាចសរសេរ $ax+by+c=0$ ដែលគេហៅថា សមីការទូទៅនៃបន្ទាត់ ។

25. បង្ហាញថា ចម្ងាយរវាងបន្ទាត់ $ax+by+c=0$ និងចំណុច $P(x_0\ ,\ y_0)$ គឺស្មើ $d=\dfrac{|ax_0+by_0+c|}{\sqrt{a^2+b^2}}$ ។

26. ក. បង្ហាញថា សមីការរង្វង់ដែលមានផ្ចិត $C(x_0\ ,\ y_0)$ និងមានកាំ $r$ គឺ $\begin{cases}|\vec{p}-\vec{c}|=r\\ (x-x_0)^2+(y-y_0)^2=r^2\end{cases}$ ។

ខ. បង្ហាញថា សមីការរង្វង់ដែលមានផ្ចិត $O(0\ ,\ 0)$ និងកាំ $r$ គឺ $x^2+y^2=r^2$ ។

27. បង្ហាញថា បើ $M$ ជាចំណុចកណ្តាលជ្រុង $AB$ នៃត្រីកោណ $ABC$ នោះគេបាន $AB^2+AC^2=2\left(AM^2+BM^2\right)$ ។

# ការស្រាយបញ្ជាក់លើមេរៀន វ៉ិចទ័រ

1. **បង្ហាញថា** $\left|\overrightarrow{AB}\right|+\left|\overrightarrow{BC}\right|>\left|\overrightarrow{AC}\right|$

គេមាន $A$ , $B$ និង $C$ ជាបីចំណុចរត់មិនត្រង់គ្នា

នាំឱ្យ យើងភ្ជាប់បានត្រីកោណ $ABC$ (ដូចរូប)

តាមវិសមភាពក្នុងត្រីកោណ ផលបូកជ្រុងពីរត្រូវធំជាង

ជ្រុងមួយទៀត នោះគេបាន $AB+BC>AC$

តែ $AB=\left|\overrightarrow{AB}\right|$ , $BC=\left|\overrightarrow{BC}\right|$ , $AC=\left|\overrightarrow{AC}\right|$

នាំឱ្យ $\left|\overrightarrow{AB}\right|+\left|\overrightarrow{BC}\right|>\left|\overrightarrow{AC}\right|$

ដូចនេះ $\boxed{\left|\overrightarrow{AB}\right|+\left|\overrightarrow{BC}\right|>\left|\overrightarrow{AC}\right|}$ ។




2. **បង្ហាញលក្ខណៈគ្រឹះនៃវ៉ិចទ័រខាងក្រោម ៖**

**ក. បង្ហាញថា** $\vec{a}+\vec{b}=\vec{b}+\vec{a}$

គេបកស្រាយតាមរូបដូចខាងក្រោម ៖




តាមរូបឃើញថា $\vec{a}+\vec{b}$ និង $\vec{b}+\vec{a}$

ជាវ៉ិចទ័រតែមួយ

ដូចនេះ $\boxed{\vec{a}+\vec{b}=\vec{b}+\vec{a}}$ ។

**ខ. បង្ហាញថា** $\left(\vec{a}+\vec{b}\right)+\vec{c}=\vec{a}+\left(\vec{b}+\vec{c}\right)$

គេបកស្រាយតាមរូបដូចខាងក្រោម ៖




តាមរូបឃើញថា $\left(\vec{a}+\vec{b}\right)+\vec{c}$ និង $\vec{a}+\left(\vec{b}+\vec{c}\right)$

ជាវ៉ិចទ័រតែមួយ

ដូចនេះ $\boxed{\left(\vec{a}+\vec{b}\right)+\vec{c}=\vec{a}+\left(\vec{b}+\vec{c}\right)}$ ។

**គ. បង្ហាញថា** $\vec{a}+\vec{0}=\vec{0}+\vec{a}=\vec{a}$

តាង $\vec{a}=\overrightarrow{AB}$ នោះគេបាន $\vec{0}=\overrightarrow{BB}$

នាំឱ្យ $\vec{a}+\vec{0}=\overrightarrow{AB}+\overrightarrow{BB}=\overrightarrow{AB}=\vec{a}$

ហើយតាមសម្រាយ ក. $\vec{a}+\vec{0}=\vec{0}+\vec{a}$

ដូចនេះ $\boxed{\vec{a}+\vec{0}=\vec{0}+\vec{a}=\vec{a}}$ ។

**ឃ. បង្ហាញថា** $\vec{a}+\left(-\vec{a}\right)=\vec{0}$

តាង $\vec{a}=\overrightarrow{AB}$ នោះគេបាន $-\vec{a}=-\overrightarrow{AB}=\overrightarrow{BA}$

នាំឱ្យ : $\vec{a}+\left(-\vec{a}\right)=\overrightarrow{AB}+\overrightarrow{BA}=\overrightarrow{AA}=\vec{0}$

ដូចនេះ $\boxed{\vec{a}+\left(-\vec{a}\right)=\vec{0}}$ ។

3. **បង្ហាញថា ប្រមាណវិធីដកវ៉ិចទ័រ** $\overrightarrow{PQ}=\overrightarrow{OQ}-\overrightarrow{OP}$

តាមរូបខាងស្តាំ យើងបាន $\overrightarrow{PQ}=\overrightarrow{PO}+\overrightarrow{OQ}$ (ទំនាក់ទំនងសាល)

$=\overrightarrow{OQ}+\overrightarrow{PO}$ (លក្ខណៈត្រឡប់)

$=\overrightarrow{OQ}-\overrightarrow{PO}$ (លក្ខណៈផ្ទុយនៃវ៉ិចទ័រ)

ដូចនេះ $\boxed{\overrightarrow{PQ}=\overrightarrow{OQ}-\overrightarrow{OP}}$ ។



4. **បង្ហាញថា** $-\left(\vec{a}+\vec{b}\right)=-\vec{a}-\vec{b}$

គេអាចស្រាយតាមរូបដូចខាងស្ដាំ ៖




តាមរូបឃើញថា $-\left(\vec{a}+\vec{b}\right)$ និង $-\vec{a}-\vec{b}$ ជាវិចទ័រតែមួយ

ដូចនេះ $\boxed{-\left(\vec{a}+\vec{b}\right)=-\vec{a}-\vec{b}}$ ។

5. **ស្រាយបញ្ជាក់លក្ខណៈគ្រឹះនៃវិចទ័រខាងក្រោម ៖**

**ក. បង្ហាញថា** $(mn)\vec{a}=m(n\vec{a})$ (លក្ខណៈផ្តុំ)

➢ **របៀបទី១** : ប្រើរូបដើម្បីបង្ហាញ




តាមរូបឃើញថា $6\vec{a}=3(2\vec{a})$ ឬ $(2\cdot 3)\vec{a}=3(2\vec{a})$

សន្និដ្ឋាន $\boxed{(mn)\vec{a}=m(n\vec{a})}$ ។

➢ **របៀបទី២** : ប្រើកូអរដោនេដើម្បីបង្ហាញ

តាង $\vec{a}=(a_1\ ,\ a_2)$ អាចសរសេរ $\vec{a}=a_1\vec{i}+a_2\vec{j}$

គេបាន
$$\begin{aligned}(mn)\vec{a}&=(mn)\left(a_1\vec{i}+a_2\vec{j}\right)\\&=mna_1\vec{i}+mna_2\vec{j}\\&=m\left(na_1\vec{i}+na_2\vec{j}\right)\\&=m\left[n\left(a_1\vec{i}+a_2\vec{j}\right)\right]=m(n\vec{a})\end{aligned}$$

ដូចនេះ $\boxed{(mn)\vec{a}=m(n\vec{a})}$ ។

**ខ. បង្ហាញថា** $(m+n)\vec{a}=m\vec{a}+n\vec{a}$ (លក្ខណៈបំបែក $I$ )

➢ **របៀបទី១** : ប្រើរូបដើម្បីបង្ហាញ




តាមរូបឃើញថា $5\vec{a}=3\vec{a}+2\vec{a}$ ឬ $(3+2)\vec{a}=3\vec{a}+2\vec{a}$

សន្និដ្ឋាន $\boxed{(m+n)\vec{a}=m\vec{a}+n\vec{a}}$ ។

➢ **របៀបទី២** : ប្រើកូអរដោនេដើម្បីបង្ហាញ

តាង $\vec{a}=(a_1\ ,\ a_2)$ អាចសរសេរ $\vec{a}=a_1\vec{i}+a_2\vec{j}$

គេបាន
$$\begin{aligned}(m+n)\vec{a}&=(m+n)\left(a_1\vec{i}+a_2\vec{j}\right)\\&=(m+n)a_1\vec{i}+(m+n)a_2\vec{j}\\&=ma_1\vec{i}+na_1\vec{i}+ma_2\vec{j}+na_2\vec{j}\\&=m\left(a_1\vec{i}+a_2\vec{j}\right)+n\left(a_1\vec{i}+a_2\vec{j}\right)\\&=m\vec{a}+n\vec{a}\end{aligned}$$

ដូចនេះ $\boxed{(m+n)\vec{a}=m\vec{a}+n\vec{a}}$ ។

**គ. បង្ហាញថា** $m\left(\vec{a}+\vec{b}\right)=m\vec{a}+m\vec{b}$ (លក្ខណៈបំបែក $II$ )

➢ **របៀបទី១** : ប្រើរូបដើម្បីបង្ហាញ

ក្នុងត្រីកោណ $ABC$ មាន $\overrightarrow{AB}=\vec{a}$ , $\overrightarrow{BC}=\vec{b}$ និង $\overrightarrow{AC}=\vec{a}+\vec{b}$

និងមាន $\overrightarrow{AB}+\overrightarrow{BC}=\overrightarrow{AC}$

តាមបំលែងចាំងផ្ចិត $O$ ផលធៀប $m$ គេបាន ៖




$\overrightarrow{A'B'}=m\overrightarrow{AB}=m\vec{a}$ , $\overrightarrow{B'C'}=m\overrightarrow{BC}=m\vec{b}$ , $\overrightarrow{A'C'}=m\overrightarrow{AC}=m\left(\vec{a}+\vec{b}\right)$

តាមរូបគេសង្កេតឃើញថា $\overrightarrow{A'B'}+\overrightarrow{B'C'}=\overrightarrow{A'C'}$ ជំនួសបាន $m\vec{a}+m\vec{b}=m\left(\vec{a}+\vec{b}\right)$

ដូចនេះ $\boxed{m\vec{a}+m\vec{b}=m\left(\vec{a}+\vec{b}\right)}$ ។

➤ **របៀបទី២** : ប្រើកូអរដោនេដើម្បីបង្ហាញថា $m\left(\vec{a}+\vec{b}\right)=m\vec{a}+m\vec{b}$

តាង $\vec{a}=a_1\vec{i}+a_2\vec{j}$ និង $\vec{b}=b_1\vec{i}+b_2\vec{j}$

នោះ $\vec{a}+\vec{b}=a_1\vec{i}+a_2\vec{j}+b_1\vec{i}+b_2\vec{j}=\left(a_1+b_1\right)\vec{i}+\left(a_2+b_2\right)\vec{j}$

គេបាន $m\vec{a}+m\vec{b}=m\left(a_1\vec{i}+a_2\vec{j}\right)+m\left(b_1\vec{i}+b_2\vec{j}\right)$

$$=ma_1\vec{i}+ma_2\vec{j}+mb_1\vec{i}+mb_2\vec{j}$$
$$=m\left(a_1+b_1\right)\vec{i}+m\left(a_2+b_2\right)\vec{j}$$
$$=m\left[\left(a_1+b_1\right)\vec{i}+\left(a_2+b_2\right)\vec{j}\right]=m\left(\vec{a}+\vec{b}\right)$$

ដូចនេះ $\boxed{m\left(\vec{a}+\vec{b}\right)=m\vec{a}+m\vec{b}}$ ។

6. **បង្ហាញថា** $\vec{i}=\dfrac{\vec{a}}{\left|\vec{a}\right|}=\dfrac{1}{\left|\vec{a}\right|}\vec{a}$ **ជាវិចទ័រឯកតា ដែលមានទិសដៅដូចទិសដៅវិចទ័រ** $\vec{a}$

គេមានវិចទ័រ $\vec{a}\neq\vec{0}$ និង $\left|\vec{a}\right|$ ជាចំនួនវិជ្ជមាន នោះ $\vec{i}=\dfrac{\vec{a}}{\left|\vec{a}\right|}$ មានទិសដៅដូច $\dfrac{\vec{a}}{\left|\vec{a}\right|}$ ឬ មានមានទិសដៅដូច $\vec{a}$ (ព្រោះ $\left|\vec{a}\right|>0$)

តាមនិយមន័យ បើ $\vec{i}$ ជាវិចទ័រឯកតា លុះត្រាតែ $\left|\vec{i}\right|=1$

គេបាន $\left|\vec{i}\right|=\left|\dfrac{\vec{a}}{\left|\vec{a}\right|}\right|=\left|\dfrac{1}{\left|\vec{a}\right|}\vec{a}\right|=\left|\dfrac{1}{\left|\vec{a}\right|}\right|\left|\vec{a}\right|=\dfrac{1}{\left\|\vec{a}\right\|}\left|\vec{a}\right|=\dfrac{1}{\left|\vec{a}\right|}\left|\vec{a}\right|=1$ (ព្រោះថា $\left\|\vec{a}\right\|=\left|\vec{a}\right|$ ជាណមឬប្រវែងដូចគ្នា)

ដូចនេះ បង្ហាញបានថា $\boxed{\vec{i}=\dfrac{\vec{a}}{\left|\vec{a}\right|}=\dfrac{1}{\left|\vec{a}\right|}\vec{a}}$ ជាវិចទ័រឯកតាមានទិសដៅដូចវិចទ័រ $\vec{a}$ ។

7. **បង្ហាញថា** $\left|\vec{a}\right|=\sqrt{a_1^2+a_2^2}$

គេមាន $\vec{a}=\left(a_1\ ,\ a_2\right)$

តាមរូប $OHP$ ជាត្រីកោណកែងត្រង់ $H$

តាមទ្រឹស្តីបទពីតាគ័រ $OP^2=OP^2+HP^2$

ដោយ $OP=\left|\vec{a}\right|$ , $OH=a_1$ , $HP=a_2$

គេបាន $\left|\vec{a}\right|^2=a_1^2+a_2^2$

$\left|\vec{a}\right|=\sqrt{a_1^2+a_2^2}$ (ព្រោះ $\left|\vec{a}\right|>0$)




ដូចនេះ បង្ហាញបានថា $\boxed{\left|\vec{a}\right|=\sqrt{a_1^2+a_2^2}}$ ។

8. **បង្ហាញការគណនាវិចទ័រ ដោយប្រើកូអរដោនេដូចខាងក្រោម ៖**

**ក. បង្ហាញថា** $\left(a_1\ ,\ a_2\right)+\left(b_1\ ,\ b_2\right)=\left(a_1+b_1\ ,\ a_2+b_2\right)$

តាង $\vec{a}=\left(a_1\ ,\ a_2\right)$ និង $\vec{b}=\left(b_1\ ,\ b_2\right)$ នោះគេបាន $\vec{a}=a_1\vec{i}+a_2\vec{j}$ និង $\vec{b}=b_1\vec{i}+b_2\vec{j}$

គេបាន $\vec{a}+\vec{b}=\left(a_1\ ,\ a_2\right)+\left(b_1\ ,\ b_2\right)\quad(1)$

ម្យ៉ាងទៀត $\vec{a}+\vec{b}=\left(a_1\vec{i}+a_2\vec{j}\right)+\left(b_1\vec{i}+b_2\vec{j}\right)=\left(a_1+b_1\right)\vec{i}+\left(a_2+b_2\right)\vec{j}=\left(a_1+b_1\ ,\ a_2+b_2\right)\quad(2)$

តាម (1) និង (2) ទាញបាន $\left(a_1\ ,\ a_2\right)+\left(b_1\ ,\ b_2\right)=\left(a_1+b_1\ ,\ a_2+b_2\right)$

ដូចនេះ បង្ហាញបានថា $\boxed{\left(a_1\ ,\ a_2\right)+\left(b_1\ ,\ b_2\right)=\left(a_1+b_1\ ,\ a_2+b_2\right)}$ ។

**ខ. បង្ហាញថា** $(a_1 , a_2)-(b_1 , b_2)=(a_1-b_1 , a_2-b_2)$

គេតាង $\vec{a}=(a_1 , a_2)$ និង $\vec{b}=(b_1 , b_2)$ នោះគេអាចសរសេរ $\vec{a}=a_1\vec{i}+a_2\vec{j}$ និង $\vec{b}=b_1\vec{i}+b_2\vec{j}$

គេបាន $\vec{a}-\vec{b}=(a_1 , a_2)-(b_1 , b_2)$ (1)

ម្យ៉ាងទៀត $\vec{a}-\vec{b}=(a_1\vec{i}+a_2\vec{j})-(b_1\vec{i}+b_2\vec{j})=(a_1-b_1)\vec{i}+(a_2-b_2)\vec{j}=(a_1-b_1 , a_2-b_2)$ (2)

តាមរយៈ ទំនាក់ទំនង (1) និង (2) គេទាញបាន $(a_1 , a_2)-(b_1 , b_2)=(a_1-b_1 , a_2-b_2)$

ដូចនេះ បង្ហាញបានថា $\boxed{(a_1 , a_2)-(b_1 , b_2)=(a_1-b_1 , a_2-b_2)}$ ។

**គ. បង្ហាញថា** $m(a_1 , a_2)=(ma_1 , ma_2)$

គេតាង $\vec{a}=(a_1 , a_2)$ នោះគេអាចសរសេរ $\vec{a}=a_1\vec{i}+a_2\vec{j}$

គេបាន $m\vec{a}=m(a_1 , a_2)$ (1)

ម្យ៉ាងទៀត $m\vec{a}=m(a_1\vec{i}+a_2\vec{j})=ma_1\vec{i}+ma_2\vec{j}=(ma_1 , ma_2)$ (2)

នាំឱ្យបាន $m(a_1 , a_2)=(ma_1 , ma_2)$

ដូចនេះ បង្ហាញថា $\boxed{m(a_1 , a_2)=(ma_1 , ma_2)}$ ។

9. **បង្ហាញថា** $\vec{a}\cdot\vec{b}=\vec{b}\cdot\vec{a}$




$\vec{a}\cdot\vec{b}=|\vec{a}|\cdot|\vec{b}|\cdot\cos\theta$

បើ $\vec{a}$ និង $\vec{b}$ ផ្គុំបានមុំ $\theta$ នោះ $\vec{b}$ ផ្គុំជាមួយ $\vec{a}$ វិញបានមុំ $-\theta$

តាមនិយមន័យផលគុណស្កាលែ

គេបាន $\vec{a}\cdot\vec{b}=|\vec{a}|\cdot|\vec{b}|\cdot\cos\theta$ (1)

ហើយ $\vec{b}\cdot\vec{a}=|\vec{b}|\cdot|\vec{a}|\cdot\cos(-\theta)=|\vec{b}|\cdot|\vec{a}|\cdot\cos\theta$ (2)

ព្រោះ $\cos(-\theta)=\cos\theta$ មុំផ្ទុយ

គេដឹងថា $|\vec{a}|\cdot|\vec{b}|=|\vec{b}|\cdot|\vec{a}|$ ផលគុណនៃពីរចំនួនមានលក្ខណៈត្រឡប់

តាម (1) និង (2) នោះគេបាន $\vec{a}\cdot\vec{b}=\vec{b}\cdot\vec{a}$

ដូចនេះ បង្ហាញបានថា $\boxed{\vec{a}\cdot\vec{b}=\vec{b}\cdot\vec{a}}$ ។




$\vec{b}\cdot\vec{a}=|\vec{b}|\cdot|\vec{a}|\cdot\cos(-\theta)$

10. **ដោយប្រើនិយមន័យផលគុណស្កាលែ ៖**

**ក. បង្ហាញថា** $|\vec{a}\cdot\vec{b}|\le|\vec{a}||\vec{b}|$

តាមលក្ខណៈត្រីកោណមាត្រ $-1\le\cos\theta\le1$ នោះ $0\le|\cos\theta|\le1$

ចំពោះវិសមីការ $|\cos\theta|\le1$ គុណអង្គទាំងពីរនៃវិសមីការនឹង $|\vec{a}|\cdot|\vec{b}|>0$ (ដោយសារ $|\vec{a}|>0$ , $|\vec{b}|>0$)

គេបាន $|\vec{a}|\cdot|\vec{b}|\cdot|\cos\theta|\le1\cdot|\vec{a}|\cdot|\vec{b}|$ ឬ $|\vec{a}|\cdot|\vec{b}|\cdot|\cos\theta|\le|\vec{a}|\cdot|\vec{b}|$

ម្យ៉ាងទៀត $\vec{a}\cdot\vec{b}=|\vec{a}|\cdot|\vec{b}|\cdot\cos\theta$ នោះ $|\vec{a}\cdot\vec{b}|=\big||\vec{a}|\cdot|\vec{b}|\cdot\cos\theta\big|=\big||\vec{a}|\big|\cdot\big||\vec{b}|\big|\cdot|\cos\theta|=|\vec{a}|\cdot|\vec{b}|\cdot|\cos\theta|$

តាម (1) និង (2) ទាញបាន $|\vec{a}\cdot\vec{b}|\le|\vec{a}|\cdot|\vec{b}|$

ដូចនេះ បង្ហាញបានថា $\boxed{|\vec{a}\cdot\vec{b}|\le|\vec{a}|\cdot|\vec{b}|}$ ។

**ខ. បង្ហាញថា** $\vec{a}\cdot\vec{a}=|\vec{a}|^2$

តាមនិយមន័យផលគុណស្កាលែ $\vec{a}\cdot\vec{b}=|\vec{a}|\cdot|\vec{b}|\cdot\cos\theta$

បើគេយក $\vec{a}=\vec{b}$ នោះគេបានមុំផ្តុំ $\cos\theta=\cos(\vec{a},\vec{a})=\cos 0^\circ=1$

គេបាន $\vec{a}\cdot\vec{a}=|\vec{a}|\cdot|\vec{a}|\cdot\cos 0^\circ$ នាំឱ្យ $\vec{a}\cdot\vec{a}=|\vec{a}|^2$

ដូចនេះ បង្ហាញបានថា $\boxed{\vec{a}\cdot\vec{a}=|\vec{a}|^2}$ ។

11. **ក. បង្ហាញថា បើ** $\vec{a}\perp\vec{b}$ **លុះត្រាតែ** $\vec{a}\cdot\vec{b}=0$




តាមនិយមន័យផលគុណស្កាលែ $\vec{a}\cdot\vec{b}=|\vec{a}|\cdot|\vec{b}|\cdot\cos\theta$

បើ $\vec{a}\perp\vec{b}$ នោះ $\cos\theta=\cos 90^\circ=0$

គេបាន $\vec{a}\cdot\vec{b}=|\vec{a}|\cdot|\vec{b}|\cdot 0=0$

ដូចនេះ បង្ហាញបានថា $\boxed{\vec{a}\perp\vec{b}\ \Leftrightarrow\ \vec{a}\cdot\vec{b}=0}$ ។

**ខ. បង្ហាញថា** $\vec{a}\cdot\vec{b}=a_1b_1+a_2b_2$

សន្មត់ថាកូអរដោនេនៃពីរវ៉ិចទ័រ $\vec{a}=(a_1\ ,\ a_2)$ , $\vec{b}=(b_1\ ,\ b_2)$

និង $\overrightarrow{OA}=\vec{a}$ , $\overrightarrow{OB}=\vec{b}$ , $\angle AOB=\theta$ (ដូចរូបខាងស្តាំ)




ក្នុងត្រីកោណ $AOB$ តាមទ្រឹស្តីបទកូស៊ីនុសគឺ គេបាន ៖

$$AB^2=OA^2+OB^2-2OA\cdot OB\cos\theta$$

នាំឱ្យ $2OA\cdot OB\cos\theta=OA^2+OB^2-BA^2 \quad (1)$

ដោយ $OA=|\vec{a}|$ , $OB=|\vec{b}|$ , $BA=|\vec{a}-\vec{b}|$

$$OA^2=|\vec{a}|^2=\left(\sqrt{a_1^2+a_2^2}\right)^2=a_1^2+a_2^2$$

$$OB^2=|\vec{b}|^2=\left(\sqrt{b_1^2+b_2^2}\right)^2=b_1^2+b_2^2$$

$$BA^2=|\vec{a}-\vec{b}|^2=\left[\sqrt{(a_1-b_1)^2+(a_2-b_2)^2}\right]^2=(a_1-b_1)^2+(a_2-b_2)^2$$

គេបាន $(1)$ ទៅជា $2|\vec{a}|\cdot|\vec{b}|\cdot\cos\theta=a_1^2+a_2^2+b_1^2+b_2^2-\left[(a_1-b_1)^2+(a_2-b_2)^2\right]$

$$=a_1^2+a_2^2+b_1^2+b_2^2-\left[a_1^2-2a_1b_1+b_1^2+a_2^2-2a_2b_2+b_2^2\right]$$

$$=2(a_1b_1+a_2b_2)$$

នាំឱ្យ $|\vec{a}|\cdot|\vec{b}|\cdot\cos\theta=a_1b_1+a_2b_2$ មានន័យថា $\vec{a}\cdot\vec{b}=a_1b_1+a_2b_2$

ដូចនេះ បង្ហាញបានថា $\boxed{\vec{a}\cdot\vec{b}=a_1b_1+a_2b_2}$ ។

**គ. បង្ហាញថា** $\vec{a}\perp\vec{b}$ **លុះត្រាតែ** $a_1b_1+a_2b_2=0$

យើងមាន $\vec{a}\perp\vec{b}$ គេបាន $\vec{a}\cdot\vec{b}=0$ (សម្រាយ ក.)

តែ $\vec{a}\cdot\vec{b}=a_1b_1+a_2b_2$ នាំឱ្យគេបាន $\vec{a}\cdot\vec{b}=a_1b_1+a_2b_2=0$

ដូចនេះ បើ $\vec{a}\perp\vec{b}$ លុះត្រាតែ $\boxed{a_1b_1+a_2b_2=0}$ ។

**ឃ. បង្ហាញថា** $\cos\theta = \dfrac{\vec{a}\cdot\vec{b}}{|\vec{a}||\vec{b}|} = \dfrac{a_1b_1 + a_2b_2}{\sqrt{a_1^2 + a_2^2} + \sqrt{b_1^2 + b_2^2}}$

តាមនិយមន័យផលគុណស្កាលែ $\vec{a}\cdot\vec{b} = |\vec{a}|\cdot|\vec{b}|\cdot\cos\theta$ នាំឱ្យ $\cos\theta = \dfrac{\vec{a}\cdot\vec{b}}{|\vec{a}|\cdot|\vec{b}|}$

ដោយ $\vec{a}\cdot\vec{b} = a_1b_1 + a_2b_2$ និង $|\vec{a}| = \sqrt{a_1^2 + a_2^2}$ , $|\vec{b}| = \sqrt{b_1^2 + b_2^2}$

គេបាន $\cos\theta = \dfrac{\vec{a}\cdot\vec{b}}{|\vec{a}|\cdot|\vec{b}|} = \dfrac{a_1b_1 + a_2b_2}{\sqrt{a_1^2 + a_2^2}\cdot\sqrt{b_1^2 + b_2^2}}$

ដូចនេះ បង្ហាញបានថា $\boxed{\cos\theta = \dfrac{\vec{a}\cdot\vec{b}}{|\vec{a}|\cdot|\vec{b}|} = \dfrac{a_1b_1 + a_2b_2}{\sqrt{a_1^2 + a_2^2}\cdot\sqrt{b_1^2 + b_2^2}}}$ ។

12. **ចំពោះគ្រប់វិចទ័រ $\vec{a}$ , $\vec{b}$ និង $\vec{c}$ ៖**

**ក. បង្ហាញថា** $\vec{a}\cdot(\vec{b}+\vec{c}) = \vec{a}\cdot\vec{b} + \vec{a}\cdot\vec{c}$

សន្មត់ថាកូអរដោនេវិចទ័រ $\vec{a} = (a_1\ ,\ a_2)$ , $\vec{b} = (b_1\ ,\ b_2)$ និង $\vec{c} = (c_1\ ,\ c_2)$

នោះ $\vec{b}+\vec{c} = (b_1 + c_1\ ,\ b_2 + c_2)$

គេបាន
$$\begin{aligned}\vec{a}\cdot(\vec{b}+\vec{c}) &= a_1(b_1+c_1) + a_2(b_2+c_2)\\ &= a_1b_1 + a_1c_1 + a_2b_2 + a_2c_2\\ &= (a_1b_1 + a_2b_2) + (a_1c_1 + a_2c_2)\\ &= \vec{a}\cdot\vec{b} + \vec{a}\cdot c\end{aligned}$$

ដូចនេះ បង្ហាញបានថា $\boxed{\vec{a}\cdot(\vec{b}+\vec{c}) = \vec{a}\cdot\vec{b} + \vec{a}\cdot\vec{c}}$ ។

**ខ. បង្ហាញថា** $(\vec{a}+\vec{b})\cdot\vec{c} = \vec{a}\cdot\vec{c} + \vec{b}\cdot\vec{c}$

សន្មត់ថាកូអរដោនេវិចទ័រ $\vec{a} = (a_1\ ,\ a_2)$ , $\vec{b} = (b_1\ ,\ b_2)$ និង $\vec{c} = (c_1\ ,\ c_2)$

នោះ $\vec{a}+\vec{b} = (a_1 + b_1\ ,\ a_2 + b_2)$

គេបាន
$$\begin{aligned}(\vec{a}+\vec{b})\cdot\vec{c} &= (a_1+b_1)c_1 + (a_2+b_2)c_2\\ &= a_1c_1 + b_1c_1 + a_2c_2 + b_2c_2\\ &= (a_1c_1 + a_2c_2) + (b_1c_1 + b_2c_2)\\ &= \vec{a}\cdot\vec{c} + \vec{b}\cdot\vec{c}\end{aligned}$$

ដូចនេះ បង្ហាញបានថា $\boxed{(\vec{a}+\vec{b})\cdot\vec{c} = \vec{a}\cdot\vec{c} + \vec{b}\cdot\vec{c}}$ ។

**គ. បង្ហាញថា** $(m\vec{a})\cdot\vec{b} = m(\vec{a}\cdot\vec{b})$

សន្មត់ថាកូអរដោនេវិចទ័រ $\vec{a} = (a_1\ ,\ a_2)$ , $\vec{b} = (b_1\ ,\ b_2)$ នោះ $m\vec{a} = m(a_1\ ,\ a_2) = (ma_1\ ,\ ma_2)$

គេបាន $(m\vec{a})\cdot\vec{b} = ma_1b_1 + ma_2b_2 = m(a_1b_1 + a_2b_2) = m(\vec{a}\cdot\vec{b})$

ដូចនេះ បង្ហាញបានថា $\boxed{(m\vec{a})\cdot\vec{b} = m(\vec{a}\cdot\vec{b})}$ ។

ឃ. បង្ហាញថា $\vec{a}\cdot\left(m\vec{b}\right)=m\left(\vec{a}\cdot\vec{b}\right)$

សន្មត់ថាកូអរដោនៃវិចទ័រ $\vec{a}=\left(a_1\ ,\ a_2\right)$ , $\vec{b}=\left(b_1\ ,\ b_2\right)$

នោះ $m\vec{b}=m\left(b_1\ ,\ b_2\right)=\left(mb_1\ ,\ mb_2\right)$

គេបាន $\vec{a}\cdot\left(m\vec{b}\right)=a_1mb_1+a_2mb_2=m\left(a_1b_1+a_2b_2\right)=m\left(\vec{a}\cdot\vec{b}\right)$

ដូចនេះ បង្ហាញបានថា $\boxed{\vec{a}\cdot\left(m\vec{b}\right)=m\left(\vec{a}\cdot\vec{b}\right)}$ ។

13. ក. បង្ហាញសមភាព $\vec{a}\cdot\left(\vec{b}-\vec{c}\right)=\vec{a}\cdot\vec{b}-\vec{a}\cdot\vec{c}$

សន្មត់ថាកូអរដោនៃវិចទ័រ $\vec{a}=\left(a_1\ ,\ a_2\right)$ , $\vec{b}=\left(b_1\ ,\ b_2\right)$ និង $\vec{c}=\left(c_1\ ,\ c_2\right)$

នោះ $\vec{b}-\vec{c}=\left(b_1-c_1\ ,\ b_2-c_2\right)$

គេបាន
$$\begin{aligned}\vec{a}\cdot\left(\vec{b}-\vec{c}\right)&=a_1\left(b_1-c_1\right)+a_2\left(b_2-c_2\right)\\&=a_1b_1-a_1c_1+a_2b_2-a_2c_2\\&=\left(a_1b_1+a_2b_2\right)-\left(a_1c_1+a_2c_2\right)\\&=\vec{a}\cdot\vec{b}-\vec{a}\cdot\vec{c}\end{aligned}$$

ដូចនេះ បង្ហាញបានថា $\boxed{\vec{a}\cdot\left(\vec{b}-\vec{c}\right)=\vec{a}\cdot\vec{b}-\vec{a}\cdot\vec{c}}$ ។

ខ. បង្ហាញសមភាព $\left(\vec{a}-\vec{b}\right)\cdot\vec{c}=\vec{a}\cdot\vec{c}-\vec{b}\cdot\vec{c}$

សន្មត់ថាកូអរដោនៃវិចទ័រ $\vec{a}=\left(a_1\ ,\ a_2\right)$ , $\vec{b}=\left(b_1\ ,\ b_2\right)$ និង $\vec{c}=\left(c_1\ ,\ c_2\right)$

នោះ $\vec{a}-\vec{b}=\left(a_1-b_1\ ,\ a_2-b_2\right)$

គេបាន
$$\begin{aligned}\left(\vec{a}-\vec{b}\right)\cdot\vec{c}&=\left(a_1-b_1\right)c_1+\left(a_2-b_2\right)c_2\\&=a_1c_1-b_1c_1+a_2c_2-b_2c_2\\&=\left(a_1c_1+a_2c_2\right)-\left(b_1c_1+b_2c_2\right)\\&=\vec{a}\cdot\vec{c}-\vec{b}\cdot\vec{c}\end{aligned}$$

ដូចនេះ បង្ហាញបានថា $\boxed{\left(\vec{a}-\vec{b}\right)\cdot\vec{c}=\vec{a}\cdot\vec{c}-\vec{b}\cdot\vec{c}}$ ។

14. ក. ស្រាយបញ្ជាក់ថា $\left|\vec{a}+\vec{b}\right|^2=\left|\vec{a}\right|^2+2\vec{a}\cdot\vec{b}+\left|\vec{b}\right|^2$

តាមលំនាំ $\vec{a}\cdot\vec{a}=\left|\vec{a}\right|^2$ នោះ
$$\begin{aligned}\left|\vec{a}+\vec{b}\right|^2&=\left(\vec{a}+\vec{b}\right)\cdot\left(\vec{a}+\vec{b}\right)\\&=\left(\vec{a}+\vec{b}\right)\cdot\vec{a}+\left(\vec{a}+\vec{b}\right)\cdot\vec{b}\\&=\vec{a}\cdot\vec{a}+\vec{b}\cdot\vec{a}+\vec{a}\cdot\vec{b}+\vec{b}\cdot\vec{b}\qquad,\quad\vec{a}\cdot\vec{b}=\vec{b}\cdot\vec{a}\\&=\left|\vec{a}\right|^2+2\vec{a}\cdot b+\left|\vec{b}\right|^2\end{aligned}$$

ដូចនេះ បង្ហាញបានថា $\boxed{\left|\vec{a}+\vec{b}\right|^2=\left|\vec{a}\right|^2+2\vec{a}\cdot\vec{b}+\left|\vec{b}\right|^2}$ ។

ខ. ស្រាយបញ្ជាក់ថា $\left|\vec{a}-\vec{b}\right|^2=\left|\vec{a}\right|^2-2\vec{a}\cdot\vec{b}+\left|\vec{b}\right|^2$

ដោយ $\vec{a}\cdot\vec{a}=\left|\vec{a}\right|^2$ នោះ $\left|\vec{a}-\vec{b}\right|^2=\left(\vec{a}-\vec{b}\right)\cdot\left(\vec{a}-\vec{b}\right)$

$=\left(\vec{a}-\vec{b}\right)\cdot\vec{a}-\left(\vec{a}-\vec{b}\right)\cdot\vec{b}$

$=\vec{a}\cdot\vec{a}-\vec{b}\cdot\vec{a}-\vec{a}\cdot\vec{b}+\vec{b}\cdot\vec{b}$ , $\vec{a}\cdot\vec{b}=\vec{b}\cdot\vec{a}$

$=\left|\vec{a}\right|^2-2\vec{a}\cdot b+\left|\vec{b}\right|^2$

ដូចនេះ បង្ហាញបានថា $\boxed{\left|\vec{a}-\vec{b}\right|^2=\left|\vec{a}\right|^2-2\vec{a}\cdot\vec{b}+\left|\vec{b}\right|^2}$ ។

15. **បង្ហាញថា ចំពោះវ៉ិចទ័រពីរ $\vec{a}$ និង $\vec{b}$ មិនសូន្យ ហើយបើ $\left|\vec{a}+\vec{b}\right|=\left|\vec{a}-\vec{b}\right|$ នោះ $\vec{a}\perp\vec{b}$**

គេមាន $\left|\vec{a}+\vec{b}\right|=\left|\vec{a}-\vec{b}\right|$ លើកអង្គទាំងពីរជាការេ គេបាន $\left|\vec{a}+\vec{b}\right|^2=\left|\vec{a}-\vec{b}\right|^2$

ដោយ $\left|\vec{a}+\vec{b}\right|^2=\left|\vec{a}\right|^2+2\vec{a}\cdot\vec{b}+\left|\vec{b}\right|^2$ និង $\left|\vec{a}-\vec{b}\right|^2=\left|\vec{a}\right|^2-2\vec{a}\cdot\vec{b}+\left|\vec{b}\right|^2$

គេបាន $\left|\vec{a}\right|^2+2\vec{a}\cdot\vec{b}+\left|\vec{b}\right|^2=\left|\vec{a}\right|^2-2\vec{a}\cdot\vec{b}+\left|\vec{b}\right|^2$

$4\vec{a}\cdot\vec{b}=0$

$\vec{a}\cdot\vec{b}=0$

ចំពោះ $\vec{a}\cdot\vec{b}=0$ នោះគេបាន $\vec{a}\perp\vec{b}$

ដូចនេះ បង្ហាញបានថា $\boxed{\text{បើ } \left|\vec{a}+\vec{b}\right|=\left|\vec{a}-\vec{b}\right| \text{ នោះ } \vec{a}\perp\vec{b}}$ ។

16. **គេឱ្យ $A(\vec{a})$ និង $B(\vec{b})$ បង្ហាញថា $\overrightarrow{AB}=\vec{b}-\vec{a}$**




ក្នុងត្រីកោណ $OAB$ មាន $\overrightarrow{OA}+\overrightarrow{AB}=\overrightarrow{OB}$

ទាញបាន $\overrightarrow{AB}=\overrightarrow{OB}-\overrightarrow{OA}$

ដោយ $\overrightarrow{OB}=\vec{b}$ , $\overrightarrow{OA}=\vec{a}$ ព្រោះ $A(\vec{a})$ និង $B(\vec{b})$

នាំឱ្យ $\overrightarrow{AB}=\vec{b}-\vec{a}$

ដូចនេះ បង្ហាញបានថា $\boxed{\overrightarrow{AB}=\vec{b}-\vec{a}}$ ។

17. ក. **បង្ហាញថា $\vec{c}=\dfrac{m\vec{b}+n\vec{a}}{m+n}$ (វ៉ិចទ័រទីតាំងចែកក្នុង)**




គេមាន $\overrightarrow{AC}=\vec{c}-\vec{a}$ និង $\overrightarrow{AB}=\vec{b}-\vec{a}$

ផលធៀប $m:n$ មានន័យថា $\dfrac{AC}{m}=\dfrac{AB}{m+n}$ នោះ: $\overrightarrow{AC}=\dfrac{m}{m+n}\overrightarrow{AB}$

គេបាន $\vec{c}-\vec{a}=\dfrac{m}{m+n}\left(\vec{b}-\vec{a}\right)$

នាំឱ្យ $\vec{c}=\dfrac{m}{m+n}\left(\vec{b}-\vec{a}\right)+\vec{a}=\dfrac{m\vec{b}-m\vec{a}+m\vec{a}+n\vec{a}}{m+n}=\dfrac{m\vec{b}+n\vec{a}}{m+n}$

ដូចនេះ បង្ហាញបានថា $\boxed{\vec{c}=\dfrac{m\vec{b}+n\vec{a}}{m+n}}$ ។

ខ. បង្ហាញថា $\vec{d}=\dfrac{m\vec{b}-n\vec{a}}{m-n}$ (វិចទ័រទីតាំងចែកក្រៅ)




យើងមាន $\overrightarrow{AD}=\vec{d}-\vec{a}$ និង $\overrightarrow{AB}=\vec{b}-\vec{a}$

តាមផលធៀប $m:n$ មានន័យថា $\dfrac{\overrightarrow{AD}}{m}=\dfrac{\overrightarrow{AB}}{m-n}$ នោះ $\overrightarrow{AD}=\dfrac{m}{m-n}\overrightarrow{AB}$

យើងបាន $\vec{d}-\vec{a}=\dfrac{m}{m-n}\left(\vec{b}-\vec{a}\right)$

នាំឱ្យ $\vec{d}=\dfrac{m}{m-n}\left(\vec{b}-\vec{a}\right)+\vec{a}=\dfrac{m\vec{b}-m\vec{a}+m\vec{a}-n\vec{a}}{m-n}=\dfrac{m\vec{b}-n\vec{a}}{m-n}$

ដូចនេះ បង្ហាញបានថា $\boxed{\vec{d}=\dfrac{m\vec{b}-n\vec{a}}{m-n}}$ ។

គ. បង្ហាញថា វិចទ័រទីតាំងនៃចំណុចកណ្ដាលរបស់អង្កត់ $AB$ គឺ $\dfrac{\vec{a}+\vec{b}}{2}$




តាង $M(\vec{m})$ ជាវិចទ័រទីតាំងនៃចំណុចកណ្ដាលអង្កត់ $AB$

បើ $M(\vec{m})$ ជាចំណុចចែកក្នុងនៃអង្កត់ $AB$ បានផលធៀប $m:n$

គេបាន $\vec{m}=\dfrac{m\vec{b}+n\vec{a}}{m+n}$

ដោយ $M$ ជាចំណុចកណ្ដាលអង្កត់ $AB$ នោះគេបាន $m:n=1:1$

នាំឱ្យ $\vec{m}=\dfrac{1\cdot\vec{b}+1\cdot\vec{a}}{1+1}=\dfrac{\vec{b}+\vec{a}}{2}=\dfrac{\vec{a}+\vec{b}}{2}$

ដូចនេះ វិចទ័រទីតាំងនៃចំណុចកណ្ដាលអង្កត់ $AB$ គឺ $\boxed{\dfrac{\vec{a}+\vec{b}}{2}}$ ។

១៦. បង្ហាញថា មេដ្យានទាំងបីនៃត្រីកោណមួយប្រសព្វគ្នាបានមួយចំណុច ដោយប្រើវិចទ័រទីតាំង




គេយក $\vec{a}$ , $\vec{b}$ , $\vec{c}$ ជាវិចទ័រទីតាំងរៀងគ្នានៃកំពូល $A$ , $B$ , $C$

ជ្រើសរើស $D$ ជាចំណុចកណ្ដាលនៃ $[BC]$ និងមានវិចទ័រទីតាំង $\vec{d}$

តាមលក្ខណៈវិចទ័រទីតាំងនៃចំណុចកណ្ដាល $\vec{d}=\dfrac{\vec{b}+\vec{c}}{2}$

យក $G(\vec{g})$ ជាចំណុចចែកក្នុងនៃមេដ្យាន $AD$ ខាងក្នុងតាម

ផលធៀប $m:n$ ដោយយក $m=2\ ,n=1$

នោះគេបាន $\vec{g}=\dfrac{m\vec{d}+n\vec{a}}{m+n}=\dfrac{2\left(\dfrac{\vec{b}+\vec{c}}{2}\right)+1\cdot\vec{a}}{2+1}=\dfrac{\vec{a}+\vec{b}+\vec{c}}{3}$

ដូចគ្នាដែរ បើគេយក $E(\vec{e})$ , $F(\vec{f})$ ជាចំណុចកណ្ដាលរៀងគ្នានៃ $[AB]$ , $[AC]$ និង $G'(\vec{g}')$ , $G''(\vec{g}'')$ ជាចំណុចចែកក្នុងនៃ

មេដ្យាន $CE$ និង $BF$ រៀគ្នាតាមផលធៀប $m:n=2:1$ ដូចគ្នា គេនឹងបាន $\vec{g}'=\dfrac{\vec{a}+\vec{b}+\vec{c}}{3}$ , $\vec{g}''=\dfrac{\vec{a}+\vec{b}+\vec{c}}{3}$

ឃើញថា $G$ , $G'$ , $G''$ មានវិចទ័រទីតាំងតែមួយគឺ $\dfrac{\vec{a}+\vec{b}+\vec{c}}{3}$ មានន័យថា មេដ្យានទាំងបីប្រសព្វគ្នាត្រង់មួយចំណុច ។

ដូចនេះ **មេដ្យានទាំងបីប្រសព្វគ្នាបានមួយចំណុច ដែលគេហៅថា ទីប្រជុំទម្ងន់នៃត្រីកោណ** ។

19. បង្ហាញថា អង្កត់ដែលភ្ជាប់ចំណុចកណ្ដាលនៃជ្រុងពីររបស់ត្រីកោណមួយ ស្របទៅនឹងជ្រុងទីបី ហើយស្មើពាក់កណ្ដាលនៃប្រវែងជ្រុងទីបីនេះ




គេយក $\vec a\,,\vec b\,,\vec c$ ជាវ៉ិចទ័រទីតាំងរៀងគ្នានៃកំពូល $A\,,B\,,C$

ជ្រើសរើស $M(\vec m)\,,N(\vec n)$ ជាចំណុចកណ្ដាលរៀងគ្នានៃ $[AB]\,,[AC]$

គេបាន $\vec m=\dfrac{\vec a+\vec b}{2}$ និង $\vec n=\dfrac{\vec a+\vec c}{2}$

ម្យ៉ាងទៀត $\overrightarrow{MN}=\vec n-\vec m=\dfrac{\vec a+\vec c}{2}-\dfrac{\vec a+\vec b}{2}=\dfrac{\vec c-\vec b}{2}$

នាំឱ្យ $\overrightarrow{MN}=\dfrac{\overrightarrow{BC}}{2}$ ព្រោះ $\overrightarrow{BC}=\vec c-\vec b$

គេបាន $\overrightarrow{MN}//\overrightarrow{BC}$ ឬ $MN//BC$ និង $MN=\left|\overrightarrow{MN}\right|=\left|\dfrac{\overrightarrow{BC}}{2}\right|=\dfrac{\left|\overrightarrow{BC}\right|}{2}=\dfrac{BC}{2}$

ដូចនេះ

| អង្កត់ដែលភ្ជាប់ចំណុចកណ្ដាលនៃជ្រុងពីររបស់ត្រីកោណមួយ ស្របទៅនឹងជ្រុងទីបី ហើយស្មើពាក់កណ្ដាលនៃប្រវែងជ្រុងទីបីនេះ គេហៅអង្កត់នេះថា ជាបាតមធ្យម |
|---|

។

20. **បង្ហាញថាកូអរដោនេនៃចំណុច $C$ ដែលចែកអង្កត់ $AB$ ខាងក្នុង ដែលភ្ជាប់ពីចំណុច $A(x_1\,,y_1)$ និង $B(x_2\,,y_2)$ តាមផលធៀប $m:n$ ឱ្យដោយរូបមន្ត $x=\dfrac{mx_2+nx_1}{m+n}\,,\ y=\dfrac{my_2+ny_1}{m+n}$**




គេតាង $\overrightarrow{OA}=\vec a\,,\ \overrightarrow{OB}=\vec b\,,\overrightarrow{OC}=\vec c$

ដោយ $A(x_1\,,y_1)$ និង $B(x_2\,,y_2)$

នាំឱ្យ $\vec a=x_1\vec i+y_1\vec j$ និង $\vec b=x_2\vec i+y_2\vec j$

បើ $C$ ជាចំណុចចែក $[AB]$ ខាងក្នុងតាមផលធៀប $m:n$

គេបាន
$$\vec c=\frac{m\vec b+n\vec a}{m+n}=\frac{m\left(x_2\vec i+y_2\vec j\right)+n\left(x_1\vec i+y_1\vec j\right)}{m+n}$$
$$=\frac{mx_2\vec i+my_2\vec j+nx_1\vec i+ny_1\vec j}{m+n}$$
$$=\frac{mx_2\vec i+nx_1\vec i}{m+n}+\frac{my_2\vec j+ny_1\vec j}{m+n}=\left(\frac{mx_2+nx_1}{m+n}\right)\vec i+\left(\frac{my_2+ny_1}{m+n}\right)\vec j$$

ដូចនេះ

| កូអរដោនេនៃចំណុច $C$ គឺ $x=\dfrac{mx_2+nx_1}{m+n}\,,\ y=\dfrac{my_2+ny_1}{m+n}$ ត្រូវបានបង្ហាញ |
|---|

។

21. **ក. បង្ហាញថា $\vec p=\vec p_0+t\vec u$ ជាសមីការប៉ារ៉ាម៉ែត្រទម្រង់វ៉ិចទ័រ**




គេមាន បន្ទាត់កាត់តាម $P_0(\vec p_0)$ មានវ៉ិចទ័រប្រាប់ទិស $\vec u=(a\,,b)$

គេយក $P(\vec p)$ ជាចំណុចនៅលើបន្ទាត់ នោះ $\overrightarrow{P_0P}//\vec u$

គេបាន $\overrightarrow{P_0P}=t\vec u\ ,\ t\in\mathbb{R}$

ដោយ $\overrightarrow{P_0P}=\vec p-\vec p_0$ នាំឱ្យ $\vec p-\vec p_0=t\vec u$ ឬ $\vec p=\vec p_0+t\vec u$

ដូចនេះ

| បង្ហាញបានថា $\vec p=\vec p_0+t\vec u\ ,\ t\in\mathbb{R}$ ជាសមីការប៉ារ៉ាម៉ែត្រទម្រង់វ៉ិចទ័រ |
|---|

។

ខ. បង្ហាញថា $\begin{cases} x = x_0 + at \\ y = y_0 + bt \end{cases}$ ដែល $t$ ជាចំនួនពិត ជាសមីការប៉ារ៉ាម៉ែត្រទម្រង់គូអរដោនេ

គេយក $\vec{p} = (x\ ,\ y)$ , $\vec{p}_0 = (x_0\ ,\ y_0)$ , $\vec{u} = (a\ ,\ b)$ , $t \in \mathbb{R}$

គេបាន $(x\ ,\ y) = (x_0\ ,\ y_0) + t(a\ ,\ b)$

$(x\ ,\ y) = (x_0\ ,\ y_0) + (ta\ ,\ tb)$

$(x\ ,\ y) = (x_0 + at\ ,\ y_0 + bt)$

នាំឱ្យ $\begin{cases} x = x_0 + at \\ y = y_0 + bt \end{cases}$

ដូចនេះ: បង្ហាញបានថា $\begin{cases} x = x_0 + at \\ y = y_0 + bt \end{cases}$ ជាសមីការប៉ារ៉ាម៉ែត្រ ។

គ. បើ $a \neq 0$ និង $b \neq 0$ ទាញបង្ហាញថា គេបាន $\dfrac{x - x_0}{a} = \dfrac{y - y_0}{b}$ រួចទាញបន្តថា $y - y_0 = \dfrac{b}{a}(x - x_0)$

យើងមាន $\begin{cases} x = x_0 + at \\ y = y_0 + bt \end{cases}$ នាំឱ្យ $\begin{cases} x - x_o = at \\ y - y_0 = bt \end{cases}$ ទាញបាន $\begin{cases} \dfrac{x - x_o}{a} = t \\ \dfrac{y - y_0}{b} = t \end{cases}$ ឬ $\dfrac{x - x_o}{a} = \dfrac{y - y_0}{b} = t \quad (1)$

តាម $(1)$ $\quad y - y_0 = b\left(\dfrac{x - x_0}{a}\right)$ ឬ $y - y_0 = \dfrac{b}{a}(x - x_0)$

ដូចនេះ: បង្ហាញបានថា $\dfrac{x - x_0}{a} = \dfrac{y - y_0}{b}$ ហើយ $y - y_0 = \dfrac{b}{a}(x - x_0)$ ។

22. បង្ហាញថា បន្ទាត់ដែលកាត់តាមពីរចំណុច $A(\vec{a})$ និង $B(\vec{b})$ មានសមីការប៉ារ៉ាម៉ែត្រ $\vec{p} = \vec{a} + t(\vec{b} - \vec{a})$




ជ្រើសរើស ចំណុច $P(\vec{p})$ នៅលើបន្ទាត់

គេបាន $\overrightarrow{AP} // \overrightarrow{AB}$ នាំឱ្យ $\overrightarrow{AP} = t\overrightarrow{AB}$ , $t \in \mathbb{R}$

ដោយ $\overrightarrow{AP} = \vec{p} - \vec{a}$ និង $\overrightarrow{AB} = \vec{b} - \vec{a}$

គេបាន $\vec{p} - \vec{a} = t(\vec{b} - \vec{a})$ នាំឱ្យបាន $\vec{p} = \vec{a} + t(\vec{b} - \vec{a})$

ដូចនេះ: សមីការប៉ារ៉ាម៉ែត្រ $\vec{p} = \vec{a} + t(\vec{b} - \vec{a})$ ត្រូវបានបង្ហាញ ។

23. បង្ហាញថា $\vec{c} = m\vec{a} + n\vec{b}$




ដោយ បន្ទាត់កាត់ $A(\vec{a})$ និង $B(\vec{b})$ និង $C(\vec{c}) \in AB$

គេបាន $\overrightarrow{AP} // \overrightarrow{AB}$ នាំឱ្យ $\overrightarrow{AC} = t\overrightarrow{AB}$ , $t \in \mathbb{R}$

ឬ $\vec{c} - \vec{a} = t(\vec{b} - \vec{a})$ នោះ: $\vec{c} = \vec{a} + t\vec{b} - t\vec{a} = (1 - t)\vec{a} + t\vec{b} \quad (1)$

ដោយ $m + n = 1$ ហើយបើយក $t = n$ នោះ: $m = 1 - t$

គេបាន $(1)$ ទៅជា $\vec{c} = m\vec{a} + n\vec{b}$

ដូចនេះ: បង្ហាញបានថា $\vec{c} = m\vec{a} + n\vec{b}$ ។

24. **ក. បង្ហាញថា សមីការបន្ទាត់កាត់** $P_0(x_0\ ,\ y_0)$ **ហើយកែងទៅនឹងវិចទ័រ** $\vec{n}=(a\ ,\ b)$ **គឺ** $\begin{cases}\vec{n}\cdot(\vec{p}-\vec{p}_0)=0\\ a(x-x_0)+b(y-y_0)=0\end{cases}$

ជ្រើសរើស ចំណុច $P(\vec{p})$ មានកូអរដោនេ $P(x\ ,\ y)$ នៅលើបន្ទាត់




គេបាន $\vec{n}\perp\overrightarrow{P_0P}$ នាំឱ្យ $\vec{n}\cdot\overrightarrow{P_0P}=0$

ដោយ $\overrightarrow{P_0P}=\vec{p}-\vec{p}_0$ គេបាន $\vec{n}\cdot(\vec{p}-\vec{p}_0)=0 \quad (1)$

ម្យ៉ាងទៀត $\overrightarrow{P_0P}=(x-x_0\ ,\ y-y_0)$ និង $\vec{n}=(a\ ,\ b)$

គេបាន $\vec{n}\cdot(\vec{p}-\vec{p}_0)=0 \Leftrightarrow a(x-x_0)+b(y-y_0)=0 \quad (2)$

តាម $(1)$ និង $(2)$ គេបាន $\begin{cases}\vec{n}\cdot(\vec{p}-\vec{p}_0)=0\\ a(x-x_0)+b(y-y_0)=0\end{cases}$

ដូចនេះ $\begin{cases}\vec{n}\cdot(\vec{p}-\vec{p}_0)=0\\ a(x-x_0)+b(y-y_0)=0\end{cases}$ ត្រូវបានបង្ហាញ ។

**ខ. បង្ហាញថា បើតាង** $c=-ax_0-by_0$ **គេអាចសរសេរ** $ax+by+c=0$

គេមាន $a(x-x_0)+b(y-y_0)=0$ ពន្លាតកន្សោម

$$ax-ax_0+by-by_0=0$$

$$ax+by-ax_0-by_0=0 \quad , \quad c=-ax_0-by_0$$

$$ax+by+c=0$$

ដូចនេះ បង្ហាញបានថា $ax+by+c=0$ ។

25. **បង្ហាញថា ចម្ងាយរវាងបន្ទាត់** $ax+by+c=0$ **និងចំណុច** $P(x_0\ ,\ y_0)$ **គឺស្មើ** $d=\dfrac{|ax_0+by_0+c|}{\sqrt{a^2+b^2}}$

គេតាង $H(x\ ,\ y)$ ជាចំណុចនៅលើបន្ទាត់ ដែល $\overrightarrow{PH}\perp(L)$




គេបាន $\overrightarrow{PH}=(x-x_0\ ,\ y-y_0)$

បើ $\vec{n}=(a\ ,\ b)$ ជាវិចទ័រណរម៉ាល់នៃ បន្ទាត់ $(L)$ នោះ $\overrightarrow{PH}\,//\,\vec{n}$

នាំឱ្យ $\overrightarrow{PH}\cdot\vec{n}=|\overrightarrow{PH}|\cdot|\vec{n}|\cdot\cos\theta$ ដែល $\theta$ ជាមុំបង្កើតដោយ $\overrightarrow{PH}$ និង $\vec{n}$

នោះ $\theta=180^\circ$ ឬ $\theta=0^\circ$ ធ្វើឱ្យ $\cos\theta=\pm1$

គេបាន $\overrightarrow{PH}\cdot\vec{n}=\pm|\overrightarrow{PH}|\cdot|\vec{n}|$ នោះ $|\overrightarrow{PH}\cdot\vec{n}|=|\overrightarrow{PH}|\cdot|\vec{n}|$

ដោយ $|\overrightarrow{PH}|=d$ នាំឱ្យ $|\overrightarrow{PH}\cdot\vec{n}|=d\cdot|\vec{n}|$ ទាញបាន $d=\dfrac{|\overrightarrow{PH}\cdot\vec{n}|}{|\vec{n}|} \quad (1)$

ហើយ $H(x\ ,\ y)$ នោះនៅលើបន្ទាត់ $L:\ ax+by+c=0 \Rightarrow -c=ax+by$

ម្យ៉ាងទៀត $\overrightarrow{PH}\cdot\vec{n}=a(x-x_0)+b(y-y_0)=ax+by-ax_0-by_0=-ax_0-by_0-c$

គេបាន $|\overrightarrow{PH}\cdot\vec{n}|=|-ax_0-by_0-c|=|ax_0+by_0+c|$ និង $|\vec{n}|=\sqrt{a^2+b^2}$

នាំឱ្យ $(1)$ អាចសរសេរបាន $d=\dfrac{|\overrightarrow{PH}\cdot\vec{n}|}{|\vec{n}|}=\dfrac{|ax_0+by_0+c|}{\sqrt{a^2+b^2}}$

ដូចនេះ $d=\dfrac{|ax_0+by_0+c|}{\sqrt{a^2+b^2}}$ ត្រូវបានបង្ហាញ ។

26. ក. បង្ហាញថា សមីការរង្វង់ដែលមានផ្ចិត $C(x_0\ ,\ y_0)$ និងមានកាំ $r$ គឺ $\begin{cases} |\vec{p}-\vec{c}| = r \\ (x-x_0)^2+(y-y_0)^2 = r^2 \end{cases}$

គេយក $P(\vec{p})$ ជាចំណុចនៅលើរង្វង់

គេបាន $CP = r$ ឬ $|\overrightarrow{CP}| = r$

តែ $\overrightarrow{CP} = \vec{p}-\vec{c}$ នាំឱ្យ $|\vec{p}-\vec{c}| = r \quad (1)$

លើក $(1)$ ជាការេ $|\vec{p}-\vec{c}|^2 = r^2$

ដោយ $\vec{p} = (x\ ,\ y)\ ,\ \vec{c} = (x_0\ ,\ y_0)$

គេបាន $\vec{p}-\vec{c} = (x-x_0\ ,\ y-y_0)$

$$|\vec{p}-\vec{c}| = \sqrt{(x-x_0)^2+(y-y_0)^2}$$

$$|\vec{p}-\vec{c}|^2 = (x-x_0)^2+(y-y_0)^2$$




នាំឱ្យ $(x-x_0)^2+(y-y_0)^2 = r^2$

ដូចនេះ $\begin{cases} |\vec{p}-\vec{c}| = r \\ (x-x_0)^2+(y-y_0)^2 = r^2 \end{cases}$ ត្រូវបានបង្ហាញ ។

ខ. បង្ហាញថា សមីការរង្វង់ដែលមានផ្ចិត $O(0\ ,\ 0)$ និងកាំ $r$ គឺ $x^2+y^2 = r^2$

គេមានសមីការរង្វង់ផ្ចិត $C(x_0\ ,\ y_0)$ គឺ $(x-x_0)^2+(y-y_0)^2 = r^2$

គេយក ផ្ចិត $C(x_0\ ,\ y_0) = O(0\ ,\ 0)$ នោះ $x_0 = 0\ ,\ y_0 = 0$

គេបាន $(x-0)^2+(y-0)^2 = r^2$ ឬ $x^2+y^2 = r^2$

ដូចនេះ បង្ហាញបានថា សមីការរង្វង់ផ្ចិត $O(0\ ,\ 0)$ គឺ $x^2+y^2 = r^2$ ។

27. បង្ហាញថា បើ $M$ ជាចំណុចកណ្តាលជ្រុង $AB$ នៃត្រីកោណ $ABC$ នោះគេបាន $AB^2+AC^2 = 2\left(AM^2+BM^2\right)$

គេយក $M$ ជាគល់នៃវិចទ័រ

គេតាង $\vec{a}\ ,\ \vec{b}$ ជាវិចទ័រទីតាំងនៃ $A\ ,\ B$ រៀងគ្នា នោះ $C$ មានវិចទ័រទីតាំង $-\vec{b}$




នាំឱ្យ $\overrightarrow{AB} = \vec{b}-\vec{a}\ ,\ \overrightarrow{CA} = \vec{a}+\vec{b}$

គេបាន $AB^2 = |\overrightarrow{AB}|^2 = |\vec{b}-\vec{a}|^2 = (\vec{b}-\vec{a})\cdot(\vec{b}-\vec{a}) = |\vec{b}|^2 - 2\vec{a}\cdot\vec{b}+|\vec{a}|^2$

$$AC^2 = |\overrightarrow{CA}|^2 = |\vec{a}+\vec{b}|^2 = (\vec{a}+\vec{b})\cdot(\vec{a}+\vec{b}) = |\vec{a}|^2 + 2\vec{a}\cdot\vec{b}+|\vec{b}|^2$$

នាំឱ្យ $AB^2+AC^2 = \left[|\vec{b}|^2 - 2\vec{a}\cdot\vec{b}+|\vec{a}|^2\right]+\left[|\vec{a}|^2 + 2\vec{a}\cdot\vec{b}+|\vec{b}|^2\right]$

$$= 2\left(|\vec{a}|^2+|\vec{b}|^2\right)$$

$$= 2\left(AM^2+BM^2\right)$$

ដូចនេះ ស្រាយបញ្ជាក់បានថា $AB^2+AC^2 = 2\left(AM^2+BM^2\right)$ ។

# ការស្រាយបញ្ជាក់លើមេរៀន បំលែងរូបក្នុងប្លង់

1. បើគេបំលែងកិលចំណុច $M(x\,,\,y)$ តាមវ៉ិចទ័រ $\vec{p}=(a\,,\,b)$ បានចំណុចថ្មី $M'(x'\,,\,y')$ ។
   បង្ហាញថា កូអរដោនេចំណុចថ្មីនោះគឺ $M'(x+a\,,\,y+b)$ ។
2. បង្ហាញថា ចំណុច $M'(x\,,-y)$ ជាចំណុចឆ្លុះនៃចំណុច $M(x\,,\,y)$ ធៀបនឹងអ័ក្សអាប់ស៊ីស $(x'x)$ ។
3. បង្ហាញថា ចំណុច $N'(-x\,,\,y)$ ជាចំណុចឆ្លុះនៃចំណុច $N(x\,,\,y)$ ធៀបនឹងអ័ក្សអរដោនេ $(y'y)$ ។
4. ក. បង្ហាញថា បំលែងឆ្លុះ $(a\,,\,b)\to(a\,,\,2k-b)$ បើធៀបនឹងបន្ទាត់ $y=k$ ។
   ខ. បង្ហាញថា បំលែងឆ្លុះ $(a\,,\,b)\to(2h-a\,,\,b)$ បើធៀបនឹងបន្ទាត់ $x=h$ ។
   គ. បង្ហាញថា បំលែងឆ្លុះ $(a\,,\,b)\to(b\,,\,a)$ បើធៀបនឹងបន្ទាត់ $y=x$ ។
   ឃ. បង្ហាញថា បំលែងឆ្លុះ $(a\,,\,b)\to(-b\,,-a)$ បើធៀបនឹងបន្ទាត់ $y=-x$ ។
5. ក. បង្ហាញថា បំលែងវិលផ្ចិត $O$ មុំ $\theta=90^\circ$ គឺ $P(x\,,\,y)\to P'(-y\,,\,x)$ ។
   ខ. បង្ហាញថា បំលែងវិលផ្ចិត $O$ មុំ $\theta=180^\circ$ គឺ $P(x\,,\,y)\to P'(-x\,,-y)$ ។
   គ. បង្ហាញថា បំលែងវិលផ្ចិត $O$ មុំ $\theta=270^\circ$ ឬមុំ $\theta=-90^\circ$ គឺ $P(x\,,\,y)\to P'(y\,,-x)$ ។
6. បង្ហាញថា រូបភាពនៃចំណុច $A$ តាមបំលែងចាំងផ្ចិត $P$ ផលធៀប $c$ គឺចំណុច $A'$ ដែលផ្ទៀងផ្ទាត់ $\overrightarrow{PA'}=c\overrightarrow{PA}$ ។
7. បង្ហាញថា បំលែងចាំងចំណុច $(x\,,\,y)$ ផ្ចិត $O(0\,,\,0)$ ផលធៀប $c\neq0$ គឺ $(x\,,\,y)\xrightarrow{h}(cx\,,\,cy)$ ។

# ការស្រាយបញ្ជាក់លើមេរៀន បំលែងរូបក្នុងប្លង់

1. **បង្ហាញថា បើគេបំលែងកិលចំណុច** $M(x\,,\,y)$ **តាមវ៉ិចទ័រ** $\vec{p}=(a\,,\,b)$ **បានចំណុចថ្មី** $M'(x'\,,\,y')$ **ដែល** $M'(x+a\,,\,y+b)$

គេមាន តាមរូបគេបានចំណុច $M'(x'\,,\,y')$ ជារូបភាពនៃ

ចំណុច $M(x\,,\,y)$ តាមបំលែងកិលនៃវ៉ិចទ័រ $\vec{p}$




តាមវ៉ិចទ័រ $\vec{p}$ គេកំណត់ដោយ $M(x\,,\,y)\xrightarrow{t_{\vec{p}}}M(x'\,,\,y')$

ដែល $\overrightarrow{MM'}=\vec{p}$

ដោយ ត្រីកោណកែង $\Delta OQP\cong\Delta MM'N$ (ករណី អ.ម)

នាំឱ្យបាន $M'(x'\,,\,y')=M'(x+a\,,\,y+b)$ ជារូបភាពនៃ

$M(x\,,\,y)$ តាមបំលែងកិលនៃវ៉ិចទ័រ $\vec{p}=(a\,,\,b)$

ដូចនេះ: | បំលែងកិលចំណុច $M(x\,,\,y)$ តាមវ៉ិចទ័រ $\vec{p}=(a\,,\,b)$ បានចំណុចថ្មីគឺ $M'(x+a\,,\,y+b)$ | ។

2. **បង្ហាញថា ចំណុច** $M'(x\,,-y)$ **ជាចំណុចឆ្លុះនៃចំណុច** $M(x\,,\,y)$ **ធៀបនឹងអ័ក្សអាប់ស៊ីស** $(x'x)$

គេតាង $M(x\,,\,y)$ និង $M'(x'\,,\,y')$

បើចំណុច $M(x\,,\,y)$ និង $M'(x'\,,\,y')$ ឆ្លុះគ្នាធៀបនឹងអ័ក្ស $x'x$




គេបាន $x'=x$ និង $y'=-y$

នាំឱ្យ $M(x\,,\,y)\xrightarrow{S_x}M'(x\,,-y)$

ដូចនេះ: | ចំណុច $M'(x\,,-y)$ ជាចំណុចឆ្លុះនៃចំណុច $M(x\,,\,y)$ ធៀបនឹងអ័ក្សអាប់ស៊ីស $(x'x)$ ត្រូវបានបង្ហាញ | ។

3. **បង្ហាញថា ចំណុច** $N'(-x\,,\,y)$ **ជាចំណុចឆ្លុះនៃចំណុច** $N(x\,,\,y)$ **ធៀបនឹងអ័ក្សអរដោនេ** $(y'y)$

គេតាង $N(x\,,\,y)$ និង $N'(x'\,,\,y')$

បើចំណុច $N(x\,,\,y)$ និង $N'(x'\,,\,y')$ ឆ្លុះគ្នាធៀបនឹងអ័ក្ស $y'y$




គេបាន $x'=-x$ និង $y'=y$

នាំឱ្យ $M(x\,,\,y)\xrightarrow{S_y}M'(-x\,,\,y)$

ដូចនេះ: | ចំណុច $N'(-x\,,\,y)$ ជាចំណុចឆ្លុះនៃចំណុច $N(x\,,\,y)$ ធៀបនឹងអ័ក្សអាប់ស៊ីស $(y'y)$ ត្រូវបានបង្ហាញ | ។

4. **ក. បង្ហាញថា បំលែងឆ្លុះ $(a\,,b)\to(a\,,2k-b)$ បើធៀបនឹងបន្ទាត់ $y=k$**

គេតាង $A(a\,,b)$ និង $A'(x'\,,y')$

បើចំណុច $A(a\,,b)$ និង $A'(x'\,,y')$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ $y=k$

គេបាន $x'=a$ និង $y'=2k-b$

នាំឱ្យ $A(a\,,b)\to A'(a\,,2k-b)$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ $y=k$

ដូចនេះ: បំលែងឆ្លុះពីចំណុចដែលមានកូអរដោនេ $(a\,,b)\to(a\,,2k-b)$ បើធៀបនឹងបន្ទាត់ $y=k$ ។




**ខ. បង្ហាញថា បំលែងឆ្លុះ $(a\,,b)\to(2h-a\,,b)$ បើធៀបនឹងបន្ទាត់ $x=h$**

គេតាង $B(a\,,b)$ និង $B'(x'\,,y')$

បើចំណុច $B(a\,,b)$ និង $B'(x'\,,y')$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ $x=h$

គេបាន $x'=2h-a$ និង $y'=b$

នាំឱ្យ $B(a\,,b)\to B'(2h-a\,,b)$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ $x=h$

ដូចនេះ: បំលែងឆ្លុះពីចំណុចដែលមានកូអរដោនេ $(a\,,b)\to(2h-a\,,b)$ បើធៀបនឹងបន្ទាត់ $x=h$ ។




**គ. បង្ហាញថា បំលែងឆ្លុះ $(a\,,b)\to(b\,,a)$ បើធៀបនឹងបន្ទាត់ $y=x$**

គេតាង $M(a\,,b)$ និង $M'(x\,,y)$

បើចំណុច $M(a\,,b)$ និង $M'(x\,,y)$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ $y=x$

គេបាន $x=b$ និង $y=a$

ដូចនេះ: បំលែងឆ្លុះពីចំណុចដែលមានកូអរដោនេ $(a\,,b)\to(b\,,a)$ បើធៀបនឹងបន្ទាត់ $y=x$ ។




**ឃ. បង្ហាញថា បំលែងឆ្លុះ $(a\,,b)\to(-b\,,-a)$ បើធៀបនឹងបន្ទាត់ $y=-x$**

គេតាង $M(a\,,b)$ និង $M'(x\,,y)$

បើចំណុច $M(a\,,b)$ និង $M'(x,\,y)$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ $y=-x$

គេបាន $x=-b$ និង $y'=-a$

ដូចនេះ: បំលែងឆ្លុះពីចំណុចដែលមានកូអរដោនេ $(a\,,b)\to(-b\,,-a)$ បើធៀបនឹងបន្ទាត់ $y=-x$ ។



5\. **ក. បង្ហាញថា បំលែងវិលផ្ចិត** $O$ មុំ $\theta=90^\circ$ គឺ $P(x\,,\,y)\to P'(-y\,,\,x)$

គេតាង $P'(x'\,,\,y')$ ជារូបភាពនៃ $P(x\,,\,y)$ តាមបំលែងវិល ផ្ចិត $O$ មុំ $\theta=90^\circ$

នោះគេបាន $OP'=OP$ , $(\overrightarrow{OP}\,,\overrightarrow{OP'})=90^\circ$

ដៅចំណុច $M$ និង $N$ ជាចំណោលកែងនៃចំណុច $P$ មកលើអ័ក្ស $\overrightarrow{Ox}$ និង $\overrightarrow{Oy}$ បើ $P$ ផ្លាស់ទីមក $P'$ តាមមុំ $90^\circ$ នោះ $M$ និង $N$ ក៏ផ្លាស់ទីមក $M'$ និង $N'$ តាមមុំ $90^\circ$ ដែរ




តាមរូប គេបាន $x'=-y$ និង $y'=x$

នាំឱ្យ កូអរដោនេ $P'(x',y')=P'(-y\,,\,x)$

ដូចនេះ

| បំលែងវិលផ្ចិត $O$ មុំ $\theta=90^\circ$ គឺ $P(x\,,\,y)\to P'(-y\,,\,x)$ |
|---|

។

**ខ. បង្ហាញថា បំលែងវិលផ្ចិត** $O$ មុំ $\theta=180^\circ$ គឺ $P(x\,,\,y)\to P'(-x\,,\,-y)$

គេតាង $P'(x'\,,\,y')$ ជារូបភាពនៃ $P(x\,,\,y)$ តាមបំលែងវិល ផ្ចិត $O$ មុំ $\theta=180^\circ$

នោះគេបាន $OP'=OP$ , $(\overrightarrow{OP}\,,\overrightarrow{OP'})=180^\circ$

ដៅចំណុច $M$ និង $N$ ជាចំណោលកែងនៃចំណុច $P$ មកលើអ័ក្ស $\overrightarrow{Ox}$ និង $\overrightarrow{Oy}$ បើ $P$ ផ្លាស់ទីមក $P'$ តាមមុំ $180^\circ$ នោះ $M$ និង $N$ ក៏ផ្លាស់ទីមក $M'$ និង $N'$ តាមមុំ $180^\circ$ ដែរ




តាមរូប គេបាន $x'=-x$ និង $y'=-y$

នាំឱ្យ កូអរដោនេ $P'(x',y')=P'(-x\,,\,-y)$

ដូចនេះ

| បំលែងវិលផ្ចិត $O$ មុំ $\theta=180^\circ$ គឺ $P(x\,,\,y)\to P'(-x\,,\,-y)$ |
|---|

។

**គ. បង្ហាញថា បំលែងវិលផ្ចិត** $O$ មុំ $\theta=270^\circ$ ឬមុំ $\theta=-90^\circ$ គឺ $P(x\,,\,y)\to P'(y\,,\,-x)$

គេតាង $P'(x'\,,\,y')$ ជារូបភាពនៃ $P(x\,,\,y)$ តាមបំលែងវិល ផ្ចិត $O$ មុំ $\theta=270^\circ$

នោះគេបាន $OP'=OP$ , $(\overrightarrow{OP}\,,\overrightarrow{OP'})=270^\circ$

ដៅចំណុច $M$ និង $N$ ជាចំណោលកែងនៃចំណុច $P$ មកលើអ័ក្ស $\overrightarrow{Ox}$ និង $\overrightarrow{Oy}$ បើ $P$ ផ្លាស់ទីមក $P'$ តាមមុំ $270^\circ$ នោះ $M$ និង $N$ ក៏ផ្លាស់ទីមក $M'$ និង $N'$ តាមមុំ $270^\circ$ ដែរ




តាមរូប គេបាន $x'=y$ និង $y'=-x$

នាំឱ្យ កូអរដោនេ $P'(x',y')=P'(y\,,\,-x)$

ដូចនេះ

| បំលែងវិលផ្ចិត $O$ មុំ $\theta=180^\circ$ គឺ $P(x\,,\,y)\to P'(y\,,\,-x)$ |
|---|

។

6. **បង្ហាញថា រូបភាពនៃចំណុច $A$ តាមបំលែងចាំងផ្ចិត $O(0\,,0)$ ផលធៀប $c$ គឺចំណុច $A'(cx\,,cy)$**




គេតាង $A'(x'\,,y')$ ជារូបភាពនៃ $A(x\,,y)$ តាមបំលែងចាំងផលធៀប $c$

តាមចំណុច $A$ និង $A'$ ទម្លាក់ចំណោលកែងលើអ័ក្ស $\overrightarrow{Ox}$ ត្រង់ $B$ និង $B'$ រៀងគ្នា

នាំឱ្យ $\Delta OAB \sim \Delta OA'B'$ (តាមករណី ម.ម )

គេបាន ផលធៀប $\dfrac{OA'}{OA}=\dfrac{OB'}{OB}=\dfrac{A'B'}{AB}=c$

ទាញបាន $OB'=cOB$ និង $A'B'=cAB$

ដោយ $OB'=x'$ , $OB=x$ និង $A'B'=y'$ , $AB=y$

គេបាន $x'=cx$ និង $y'=cy$

នាំឱ្យ ចំណុច $A'(x'\,,y')=A'(cx\,,cy)$

ដូចនេះ រូបភាពនៃចំណុច $A$ តាមបំលែងចាំងផ្ចិត $O(0\,,0)$ ផលធៀប $c$ គឺចំណុច $A'(cx\,,cy)$ ។

# ការស្រាយបញ្ជាក់លើមេរៀន ធរណីមាត្រក្នុងលំហ

1. បង្ហាញថា បើបន្ទាត់មួយ និងប្លង់មួយមានចំណុចរួមពីរផ្សេងគ្នា នោះបន្ទាត់គឺត្រូវតែស្ថិតនៅក្នុងប្លង់នោះ ។
2. បង្ហាញថា តាមចំណុចមួយឋិតនៅក្រៅបន្ទាត់មួយ គេអាចគូសបន្ទាត់បានតែមួយគត់ ដែលស្របទៅនឹងបន្ទាត់នោះ ។
3. ក. បង្ហាញថា គ្រប់បន្ទាត់ដែលនៅក្រៅប្លង់មួយ ហើយស្របនឹងបន្ទាត់មួយនៃប្លង់ ជាបន្ទាត់ស្របនឹងប្លង់នោះ ។

   ខ. បង្ហាញថា បើបន្ទាត់មួយស្របនឹងប្លង់មួយ នោះគ្រប់ប្លង់ដែលកាត់តាមបន្ទាត់នេះ ជួបប្លង់ទី 1 តាមបន្ទាត់មួយស្របនឹងបន្ទាត់ទី 1 ។

   គ. បង្ហាញថា បើបន្ទាត់មួយស្របនឹងប្លង់ពីរប្រសព្វគ្នា នោះវាស្របទៅនឹងបន្ទាត់ប្រសព្វ រវាងប្លង់ទាំងពីរនោះ ។
4. ក. បង្ហាញថា តាមចំណុចមួយនៅក្រៅប្លង់ $P$ មួយគេអាចគូសបានប្លង់ $Q$ តែមួយ គត់ ដែលស្របទៅនឹងប្លង់នោះ ។

   ខ. បង្ហាញថា បើប្លង់ពីរស្របគ្នា នោះគ្រប់ប្លង់ដែលស្របនឹងប្លង់មួយ ត្រូវស្របនឹងប្លង់ មួយទៀត ។

   គ. បង្ហាញថា ប្លង់ពីរស្របគ្នា ហើយកាត់ដោយប្លង់ទីបី នោះបន្ទាត់ប្រសព្វ ជាបន្ទាត់ ស្របគ្នា ។

   ឃ. បង្ហាញថា បើប្លង់ពីរស្របគ្នា នោះគ្រប់បន្ទាត់កាត់ប្លង់ទី 1 ត្រូវកាត់ប្លង់ទី 2 ។

   ង. បង្ហាញថា ប្លង់ច្រើនស្របគ្នា កំណត់នៅលើខ្នាត់ពីរ បានអង្កត់ត្រូវគ្នាសមាមាត្រគ្នា។
5. ក. បង្ហាញថា បើបន្ទាត់មួយ អរតូកូណាល់នឹងបន្ទាត់ពីរប្រសព្វគ្នានៅក្នុងប្លង់ នោះ បន្ទាត់មួយនោះ ត្រូវកែងនឹងប្លង់ ។

   ខ. បង្ហាញថា $\left.\begin{matrix} a // b \\ a \perp P \end{matrix}\right\} \Rightarrow b \perp P$ ។

   គ. បង្ហាញថា $\left.\begin{matrix} a \perp P \\ b \perp P \end{matrix}\right\} \Rightarrow a // b$ ។

   ឃ. បង្ហាញថា $\left.\begin{matrix} a \perp P \\ P // Q \end{matrix}\right\} \Rightarrow a \perp Q$ ។
6. ក. បង្ហាញថា បើបន្ទាត់ $AB$ កែងនឹងប្លង់ $P$ ត្រង់ $B$ ហើយ $BO$ កែងនឹងបន្ទាត់ $a$ នៃប្លង់ $P$ ត្រង់ $O$ នោះបន្ទាត់ $AO$ កែងនឹងបន្ទាត់ $a$ ។

   ខ. បង្ហាញថា បើបន្ទាត់ $AB$ កែងនឹងប្លង់ $P$ ត្រង់ $B$ ហើយ $AO$ កែងនឹងបន្ទាត់ $a$ នៃប្លង់ $P$ ត្រង់ $O$ នោះបន្ទាត់ $BO$ កែងនឹងបន្ទាត់ $a$ ។
7. បង្ហាញថា $\left.\begin{matrix} d \perp P \\ d // Q \end{matrix}\right\} \Rightarrow P \perp Q$ ។

# ការស្រាយបញ្ជាក់លើមេរៀន ធរណីមាត្រក្នុងលំហ

1. **បង្ហាញថា បើបន្ទាត់មួយ និងប្លង់មួយមានចំណុចរួមពីរផ្សេងគ្នា នោះបន្ទាត់គឺត្រូវតែស្ថិតនៅក្នុងប្លង់នោះ**

គេនឹងបង្ហាញថា បើបន្ទាត់ និងប្លង់មានចំណុចរួមពីរ នោះបន្ទាត់ត្រូវស្ថិតនៅក្នុងប្លង់ តាមវិធីធ្វើពិសោធន៍ជាក់ស្តែង

គេដៅចំណុចពីរ $A$ និង $B$ នៅក្នុងប្លង់ក្រដាស ឬក្តារខៀន

គេយកបន្ទាត់ត្រង់មួយដាក់ឱ្យកាត់តាមពីរចំណុច $A$ និង $B$ នោះ

គេសង្កេតឃើញថា បន្ទាត់បិតនៅជាប់នឹងផ្ទៃនៃប្លង់ក្រដាស់ ឬក្តារខៀន




គេបាន $\begin{cases} A\in(P) \\ B\in(P) \end{cases}$ នោះ $(AB)\subset P$

គេថា បន្ទាត់ស្ថិតនៅក្នុងប្លង់ក្រដាស់ ឬក្តារខៀន

ដូចនេះ | បើបន្ទាត់មួយ និងប្លង់មួយមានចំណុចរួមពីរផ្សេងគ្នា នោះបន្ទាត់គឺត្រូវតែស្ថិតនៅក្នុងប្លង់នោះ | ។

2. **បង្ហាញថា តាមចំណុចមួយបិតនៅក្រៅបន្ទាត់មួយ គេអាចគូសបន្ទាត់បានតែមួយគត់ ដែលស្របទៅនឹងបន្ទាត់នោះ**

គេបកស្រាយតាមរយៈការធ្វើពិសោធន៍ជាក់ស្តែង ៖

គេមាន បន្ទាត់ $\ell$ និងចំណុច $A$ នៅក្នុងប្លង់ $P$ មួយ

គេគូស បន្ទាត់ $d$ កាត់តាម $A$ ហើយស្របនឹងបន្ទាត់ $\ell$

ឃើញថា នៅក្នុងប្លង់ $P$ គេគូសបានបន្ទាត់ $d$ តែមួយគត់

ដែលកាត់តាមចំណុច $A$ ហើយស្របនឹងបន្ទាត់ $d$




ដូចនេះ | តាមចំណុចមួយបិតនៅក្រៅបន្ទាត់មួយ គេអាចគូសបន្ទាត់បានតែមួយគត់ ដែលស្របទៅនឹងបន្ទាត់នោះ | ។

3. **ក. បង្ហាញថា គ្រប់បន្ទាត់ដែលនៅក្រៅប្លង់មួយ ហើយស្របនឹងបន្ទាត់មួយនៃប្លង់ ជាបន្ទាត់ស្របនឹងប្លង់នោះ**

គេចង់ស្រាយបញ្ជាក់ថា $\left.\begin{matrix} d\not\subset P \\ d\parallel d' \\ d'\subset P \end{matrix}\right\}$ នោះ $d\parallel P$

គេដឹងថា បន្ទាត់ពីរស្របគ្នា $d\parallel d'$ កំណត់បានប្លង់មួយ តាងដោយ

$Q$ ដែល $P\cap Q=d'$




ឧបមាថា $d\cap P=\{A\}$ មានន័យថា $A\in P$ , $A\in Q$

នោះគេបាន $A\in d'$ ព្រោះ $P\cap Q=d'$

នាំឱ្យ $d\cap d'=\{A\}$ ករណីនេះផ្ទុយពីសម្មតិកម្មដែលថា $d\parallel d'$

គេបាន $d\cap P=\varnothing$ មានន័យថា បន្ទាត់ $d$ មិនកាត់ប្លង់ $P$ ទេ ពោលគឺ $d\parallel P$

ដូចនេះ | គ្រប់បន្ទាត់ដែលនៅក្រៅប្លង់មួយ ហើយស្របនឹងបន្ទាត់មួយនៃប្លង់ ជាបន្ទាត់ស្របនឹងប្លង់នោះ | ។

ខ. បង្ហាញថា បើបន្ទាត់មួយស្របនឹងប្លង់មួយ នោះគ្រប់ប្លង់ដែលកាត់តាមបន្ទាត់នេះ ជួបប្លង់ទី 1 តាមបន្ទាត់មួយស្របនឹងបន្ទាត់ទី 1

គេចង់ស្រាយបញ្ជាក់ថា $\left.\begin{array}{l} d \parallel P \\ d \subset Q \\ P \cap Q = d' \end{array}\right\}$ នោះ $d \parallel d'$




ឧបមាថា $d \cap d' = \{A\}$ នោះ $A \in d$ , $A \in d'$ និង $A \in P$ ដែរ

ដោយ $A \in d$ និង $A \in P$ មានន័យថា $d$ ជួបនឹង $P$ ជាករណី

ផ្ទុយពីសម្មតិកម្ម ដែលថា $d \parallel P$ នាំឱ្យ $d \parallel d'$

ដូចនេះ: បើបន្ទាត់មួយស្របនឹងប្លង់មួយ នោះគ្រប់ប្លង់ដែលកាត់តាមបន្ទាត់នេះ ជួបប្លង់ទី 1 តាមបន្ទាត់មួយស្របនឹងបន្ទាត់ទី1

គ. បង្ហាញថា បើបន្ទាត់មួយស្របនឹងប្លង់ពីរប្រសព្វគ្នា នោះវាស្របទៅនឹងបន្ទាត់ប្រសព្វ រវាងប្លង់ទាំងពីរនោះ

គេចង់ស្រាយបញ្ជាក់ថា $\left.\begin{array}{l} d \parallel P \\ d \parallel Q \\ P \cap Q = d' \end{array}\right\}$ នោះ $d \parallel d'$




គេមាន ប្លង់ $P$ និង $Q$ ស្របនឹង $d$ និង $P \cap Q = d'$

គេយក $O \in d'$ តាម $O$ គូសបន្ទាត់ $d'' \parallel d$

គេបាន $O \in P$ នាំឱ្យ $d'' \in P$

$O \in Q$ នាំឱ្យ $d'' \in Q$

នាំឱ្យ $P \cap Q = d''$ មានន័យថា $d''$ ត្រួតលើ $d'$

ដោយ $d'' \parallel d$ នាំឱ្យ $d' \parallel d$ ដែរ

ដូចនេះ: បើបន្ទាត់មួយស្របនឹងប្លង់ពីរប្រសព្វគ្នា នោះវាស្របទៅនឹងបន្ទាត់ប្រសព្វ រវាងប្លង់ទាំងពីរនោះ ។

4. ក. បង្ហាញថា តាមចំណុចមួយនៅក្រៅប្លង់ $P$ មួយគេអាចគូសបានប្លង់ $Q$ តែមួយ គត់ ដែលស្របទៅនឹងប្លង់នោះ

តាមនិយមន័យ ប្លង់ពីរស្របគ្នា កាលណាវាគ្មានចំណុចប្រសព្វ ។




គេមាន ប្លង់ $P$ និងចំណុច $A$ មួយនៅក្រៅប្លង់ $P$

គេគូស បន្ទាត់ $\ell$ មួយកាត់តាមចំណុច $A$ ហើយកែងនឹងប្លង់ $P$

គេគូស ប្លង់ $Q$ មួយទៀតដែលកាត់តាមចំណុច $A$ ហើយកែងនឹងបន្ទាត់ $\ell$

ឃើញថា គេគូសបានប្លង់ $Q$ តែមួយគត់ ដែលកាត់តាមចំណុច $A$

ហើយកែងនឹងបន្ទាត់ $\ell$

ដោយ $\left.\begin{array}{l} P \perp \ell \\ Q \perp \ell \end{array}\right\}$ នោះ $P \parallel Q$

ដូចនេះ: តាមចំណុចមួយនៅក្រៅប្លង់ $P$ មួយគេអាចគូសបានប្លង់ $Q$ តែមួយ គត់ ដែលស្របទៅនឹងប្លង់នោះ ។

**ខ. បង្ហាញថា បើប្លង់ពីរស្របគ្នា នោះគ្រប់ប្លង់ដែលស្របនឹងប្លង់មួយ ត្រូវស្របនឹងប្លង់ មួយទៀត**




គេចង់ស្រាយបញ្ជាក់ថា $\left.\begin{matrix} P \parallel Q \\ P \parallel R \end{matrix}\right\}$ នោះ $Q \parallel R$

គេមាន $P$ និង $Q$ ជាប្លង់ស្របគ្នា

គេគូស បន្ទាត់ $\ell$ កែងនឹង $P$ នោះ $\ell$ ក៏កែងនឹង $Q$ ដែរ

បើមាន ប្លង់ $R$ មួយទៀតស្របនឹងប្លង់ $P$

ដោយ $P \parallel R$ និង $P \perp \ell$ នោះ $R \perp \ell$

គេបាន $\left.\begin{matrix} Q \perp \ell \\ R \perp \ell \end{matrix}\right\}$ នោះ $Q \parallel R$

ដូចនេះ | បើប្លង់ពីរស្របគ្នា នោះគ្រប់ប្លង់ដែលស្របនឹងប្លង់មួយ ត្រូវស្របនឹងប្លង់ មួយទៀត | ។

**គ. បង្ហាញថា ប្លង់ពីរស្របគ្នា ហើយកាត់ដោយប្លង់ទីបី នោះបន្ទាត់ប្រសព្វ ជាបន្ទាត់ ស្របគ្នា**




គេមាន ប្លង់ $P$ និង $Q$ ស្របគ្នា

បើមាន ប្លង់ $R$ កាត់ $P$ បានបន្ទាត់ $d$ និងកាត់ $Q$ បាន $d'$

គេនឹងបង្ហាញថា $d \parallel d'$

ឧបមាថា $d$ ជួបនឹង $d'$ ត្រង់ $A$

គេបាន $\left.\begin{matrix} A \in d \\ d \subset P \end{matrix}\right\}$ នោះ $A \in P$

ម្យ៉ាងទៀត $\left.\begin{matrix} A \in d' \\ d' \subset Q \end{matrix}\right\}$ នោះ $A \in Q$

ឃើញថា $A$ ជាចំណុចរួមនៃ $P$ និង $A$ ជាករណីផ្ទុយពីសម្មតិកម្ម ដែលថា $P \parallel Q$

នេះបញ្ជាក់ថា $d$ និង $d'$ នៅក្នុងប្លង់ $R$ តែមួយ និងគ្មានចំណុចរួម នាំឱ្យ $d \parallel d'$

ដូចនេះ | ប្លង់ពីរស្របគ្នា ហើយកាត់ដោយប្លង់ទីបី នោះបន្ទាត់ប្រសព្វ ជាបន្ទាត់ ស្របគ្នា | ។

**ឃ. បង្ហាញថា បើប្លង់ពីរស្របគ្នា នោះគ្រប់បន្ទាត់កាត់ប្លង់ទី 1 ត្រូវកាត់ប្លង់ទី 2**




គេមាន ប្លង់ $P$ និង $Q$ ស្របគ្នា

គេតាង $\ell$ ជាបន្ទាត់ដែលកាត់ប្លង់ $P$ ត្រង់ $A$ មានន័យថា

$\ell$ មិនស្របនឹងប្លង់ $P$

គេនឹងបង្ហាញថា $\ell$ ក៏កាត់ប្លង់ $Q$ ត្រង់ចំណុច $B$ ណាមួយដែរ

ឧបមាថា $\ell$ មិនកាត់ប្លង់ $Q$ នាំឱ្យ $\ell \parallel Q$

ដោយ $\ell \parallel Q$ និង $P \parallel Q$ នាំឱ្យ $P \parallel \ell$ ជាករណីផ្ទុយពីសម្មតិកម្ម

ដែលថា $P \cap \ell = \{A\}$ មានន័យថា $\ell$ ក៏កាត់ប្លង់ $Q$ ដែរ

ដូចនេះ | បើប្លង់ពីរស្របគ្នា នោះគ្រប់បន្ទាត់កាត់ប្លង់ទី 1 ត្រូវកាត់ប្លង់ទី 2 | ។

**ង. បង្ហាញថា ប្លង់ច្រើនស្របគ្នា កំណត់នៅលើខ្នាត់ពីរ បានអង្កត់ត្រូវគ្នាសមាមាត្រគ្នា**




គេមាន ប្លង់ស្របគ្នាបីគឺ $P$ , $Q$ និង $R$ ហើយកាត់ដោយខ្នាត់ពីរ $\Delta$ និង $\Delta'$ បានចំណុច $A, B, C$ និង $A', B', C'$ រៀងគ្នា ដូចរូបខាងស្តាំ ៖

ឧបមាថា បន្ទាត់ $\Delta_1$ ស្របនឹង $\Delta$ កាត់ $P$ , $Q$ , $R$ ត្រង់ $A'$, $B_1$ , $C_1$ រៀងគ្នា

គេបាន $AB = A'B_1$ , $BC = B_1C_1$ និង $AC = A'C_1$

បន្ទាត់ $\Delta_1$ កាត់ $\Delta'$ ត្រង់ចំណុច $A'$ ហើយកំណត់បានប្លង់មួយ ប្លង់នេះកាត់ប្លង់ $Q$ និង $R$ តាមបន្ទាត់ $B_1B'$ និង $C_1C'$ រៀងគ្នា ដែល $B_1B' \parallel C_1C'$

តាមទ្រឹស្តីបទតាលែស គេបានអង្កត់សមាមាត្រគ្នាគឺ $\dfrac{A'B'}{A'B_1} = \dfrac{B'C'}{B_1C_1} = \dfrac{A'C'}{A'C_1}$

ដូចនេះ: | ប្លង់ច្រើនស្របគ្នា កំណត់នៅលើខ្នាត់ពីរ បានអង្កត់ត្រូវគ្នាសមាមាត្រគ្នា | ។

5. **ក. បង្ហាញថា បើបន្ទាត់មួយ អរតូកូណាល់នឹងបន្ទាត់ពីរប្រសព្វគ្នានៅក្នុងប្លង់ នោះ បន្ទាត់មួយនោះ ត្រូវកែងនឹងប្លង់**

គេនឹងស្រាយថា $\left.\begin{array}{l} a \subset \alpha, b \subset \alpha \\ a \cap b = \{O\} \\ a \perp d, b \perp d \end{array}\right\}$ នោះ $d \perp \alpha$

ដើម្បីបង្ហាញថា $d \perp \alpha$ គេនឹងបង្ហាញថា $d \perp c$ ដែល $c \subset \alpha$ , $c$ ជាបន្ទាត់




គេមាន $a \perp d$, $b \perp d$ និងសន្មត់ថា $a \cap b = \{O\}$

ជ្រើសរើស $P$ និង $Q$ នៅលើបន្ទាត់ $d$ ដែល $PO = OQ$

គេគូស បន្ទាត់ $m$ ក្នុងប្លង់ $\alpha$ មិនកាត់តាម $O$ ដែល $m$ កាត់បន្ទាត់ $a, b, c$ រៀងគ្នាត្រង់ $A, B, C$

គេមាន $\Delta AOP \cong \Delta AOQ$ (ករណី ជ.ម.ជ ព្រោះមាន $AO$ រួម , $OP = OQ$ , $\angle AOP = \angle AOQ = 90°$ )

វិបាក $PA = AQ$

ហើយ $\Delta BOP \cong \Delta BOQ$ (ករណី ជ.ម.ជ ព្រោះមាន $BO$ រួម , $OP = OQ$ , $\angle BOP = \angle BOQ = 90°$ )

វិបាក $BA = BQ$

ដោយ $PA = AQ$ , $BA = BQ$ និង $AB = AB$ ជាជ្រុងរួម

នោះ $\Delta ABP \cong \Delta ABQ$ (ករណី ជ.ជ.ជ) វិបាក $\angle PAC = \angle QAC$

នាំឱ្យ $\Delta PAC$ និង $\Delta QAC$ មាន $PA = AQ$ , $AC$ ជ្រុងរួម និង $\angle PAC = \angle QAC$

គេបាន $\Delta PAC \cong \Delta QAC$ (ករណី ជ.ម.ជ) វិបាក $PC = CQ$

ឃើញថា $PCQ$ ជាត្រីកោណសមបាត និងមាន $O$ កណ្តាល $PQ$ នាំឱ្យ $OC$ ជាកម្ពស់នៃ $\Delta PCQ$

មានន័យថា $CO \perp PQ$ ពោលគឺ $d \perp c$ ដូចអ្វីដែលចង់បង្ហាញ

ដូចនេះ: | បើបន្ទាត់មួយ អរតូកូណាល់នឹងបន្ទាត់ពីរប្រសព្វគ្នានៅក្នុងប្លង់ នោះ បន្ទាត់មួយនោះ ត្រូវកែងនឹងប្លង់ | ។

**ខ. បង្ហាញថា** $\left.\begin{matrix} a//b \\ a\perp P\end{matrix}\right\}\Rightarrow b\perp P$




គេតាង $c$ និង $d$ ជាពីរបន្ទាត់នៅក្នុងប្លង់ $P$ ប្រសព្វគ្នាត្រង់ $O$

គេមាន $a\perp P$ នោះ $\begin{cases} a\perp c \\ a\perp d\end{cases}$

$a//b$ នោះគេបាន $b$ អរតូកូណាល់នឹង $c$ និង $d$

ដោយ $a$ អរតូកូណាល់ទៅនឹងគ្រប់បន្ទាត់ក្នុងប្លង់ $P$ និង $a//b$

នាំឱ្យ $b$ ក៏អរតូកូណាល់ទៅនឹងគ្រប់បន្ទាត់ក្នុងប្លង់ $P$ ដែល មានន័យថា $b\perp P$

ដូចនេះ: $\left.\begin{matrix} a//b \\ a\perp P\end{matrix}\right\}\Rightarrow b\perp P$ ត្រូវបានបង្ហាញ ។

**គ. បង្ហាញថា** $\left.\begin{matrix} a\perp P \\ b\perp P\end{matrix}\right\}\Rightarrow a//b$




ឧបមាថា បន្ទាត់ $b$ មិនស្របនឹង $a$

នាំឱ្យ គេអាចគូសបាន $b'$ ដែល $b'\parallel a$ ហើយ $b'$ កាត់តាម $B$

ដោយ $\left.\begin{matrix} a\perp P \\ b'\parallel a\end{matrix}\right\}\Rightarrow b'\perp P$ (បានទ្រឹស្តីបទ ក.)

បានន័យថា តាម $B$ មានបន្ទាត់ $b$ និង $b'$ ដែលកែងនឹងប្លង់ $P$ តែមួយជាករណីមិនអាច

នាំឱ្យ បន្ទាត់ $b$ មិនស្របនឹង $a$ មិនពិត មានន័យថា $a//b$

ដូចនេះ: $\left.\begin{matrix} a\perp P \\ b\perp P\end{matrix}\right\}\Rightarrow a//b$ ត្រូវបានបង្ហាញ ។

**ឃ. បង្ហាញថា** $\left.\begin{matrix} a\perp P \\ P//Q\end{matrix}\right\}\Rightarrow a\perp Q$




គេមាន $a\perp P$ , $P//Q$

ដោយ $a\perp P$ នោះ $a$ អរតូកូណាល់គ្រប់បន្ទាត់ក្នុងប្លង់ $P$

ជ្រើសរើស បន្ទាត់ពីរ $b$ និង $c$ ប្រសព្វគ្នាត្រង់ $O$ ក្នុងប្លង់ $P$

នោះ $a\perp b$ និង $a\perp c$ ត្រង់ចំណុច $O$

ម្យ៉ាងទៀត $P\parallel Q$ នាំឱ្យមានបន្ទាត់ $b'\parallel b$ , $c'\parallel c$ ដែល $b'\subset Q$ , $c'\subset Q$ និង $b'\cap c'=\{O'\}$

គេបាន $a\perp b'$ និង $a\perp c'$ ត្រង់ចំណុច $O'$

តាមទ្រឹស្តីបទ 1 នៃបន្ទាត់កែងនឹងប្លង់ គេបាន $\left.\begin{matrix} a\perp b' , a\perp c' \\ b'\cap c'=\{O'\}\end{matrix}\right\}\Rightarrow a\perp Q$

ដូចនេះ: $\left.\begin{matrix} a\perp P \\ P//Q\end{matrix}\right\}\Rightarrow a\perp Q$ ត្រូវបានបង្ហាញ ។

6. **ក. បង្ហាញថា បន្ទាត់ $AO$ កែងនឹងបន្ទាត់ $a$**

គេមាន បន្ទាត់ $AB$ កែងនឹងប្លង់ $P$ ត្រង់ $B$

ហើយ $BO$ កែងនឹងបន្ទាត់ $a$ នៃប្លង់ $P$ ត្រង់ $O$




គេបាន $\left.\begin{matrix} AB \perp P \\ a \subset P \end{matrix}\right\}$ នោះគេបាន $AB \perp a$

$\left.\begin{matrix} AB \perp a \\ BO \perp a \end{matrix}\right\}$ នោះ $a \perp AOB$

$\left.\begin{matrix} a \perp AOB \\ AO \subset AOB \end{matrix}\right\}$ នោះគេបាន $AO \perp a$

ដូចនេះ: | បន្ទាត់ $AO$ កែងនឹងបន្ទាត់ $a$ ត្រូវបានបង្ហាញ | ។

**ខ. បង្ហាញថា បន្ទាត់ $BO$ កែងនឹងបន្ទាត់ $a$**

គេមាន បន្ទាត់ $AB$ កែងនឹងប្លង់ $P$ ត្រង់ $B$

ហើយ $AO$ កែងនឹងបន្ទាត់ $a$ នៃប្លង់ $P$ ត្រង់ $O$




គេបាន $\left.\begin{matrix} AB \perp P \\ a \subset P \end{matrix}\right\}$ នោះគេបាន $AB \perp a$

$\left.\begin{matrix} AB \perp a \\ AO \perp a \end{matrix}\right\}$ នោះ $a \perp AOB$

$\left.\begin{matrix} a \perp AOB \\ BO \subset AOB \end{matrix}\right\}$ នោះគេបាន $BO \perp a$

ដូចនេះ: | បន្ទាត់ $BO$ កែងនឹងបន្ទាត់ $a$ ត្រូវបានបង្ហាញ | ។

7. **បង្ហាញថា** $\left.\begin{matrix} d \perp P \\ d // Q \end{matrix}\right\} \Rightarrow P \perp Q$

គេមាន $d \parallel Q$ យ៉ាងហោចណាស់ក៏មានបន្ទាត់ $a$ មួយដែល

$a \subset Q$ និង $a \parallel d$




ដោយ $\left.\begin{matrix} d \perp P \\ a \parallel d \end{matrix}\right\}$ នោះ $a \perp P$

តាមនិយមន័យប្លង់ពីរកែងគ្នា ៖ គេថាប្លង់ $P$ កែងនឹងប្លង់ $Q$ កាលណាប្លង់ $P$

មានបន្ទាត់មួយកែងនឹងប្លង់ $Q$ (ឬប្លង់ $Q$ មានបន្ទាត់មួយកែងនឹងប្លង់ $P$ )

ដោយ ប្លង់ $Q$ មានបន្ទាត់ $a$ កែងនឹងប្លង់ $P$ នាំឱ្យ $Q \perp P$

ដូចនេះ: | $\left.\begin{matrix} d \perp P \\ d // Q \end{matrix}\right\} \Rightarrow P \perp Q$ ត្រូវបានបង្ហាញ | ។

# ការស្រាយបញ្ជាក់លើមេរៀន ស្វ៊ីត និងស៊េរី

1. បង្ហាញថា បើ $d$ ជាផលសងរួមនៃស្វ៊ីតនព្វន្ត $(U_n)$ នោះគេបាន $d = U_{n+1} - U_n$ ។
2. ក. បង្ហាញថា តួទី $n$ នៃស្វ៊ីតនព្វន្តមួយកំណត់ដោយ $U_n = U_1 + (n-1)\times d$ ដែល $U_1$ ជាតួទីមួយ និង $d$ ជាផលសងរួម។
   ខ. បង្ហាញថា បើ $(U_n)$ ជាស្វ៊ីតនព្វន្ត មានតួទីមួយ $U_0$ និង $d$ ជាផលសងរួម គេបាន $U_n = U_0 + nd$ ។
3. ស្រាយបញ្ជាក់ ផលបូកតួនៅស្មើចម្ងាយពីតួចុង ដែល $U_1$ , $U_2$ , $U_3$ , ... , $U_{n-2}$ , $U_{n-1}$ , $U_n$ មាន $U_1 + U_n = U_2 + U_{n-1} = U_3 + U_{n-2} = ... = U_p + U_{n-p+1}$ ។
4. បង្ហាញថា បើ $a$ , $b$ និង $c$ ជាបីតួតគ្នានៃស្វ៊ីតនព្វន្ត នោះ $b = \dfrac{a+c}{2}$ (គេហៅ $b$ ថា មធ្យមនព្វន្តនៃ $a$ និង $c$) ។
5. ស្រាយបញ្ជាក់ថា ផលបូក $n$ តួដំបូងនៃស្វ៊ីតធរណីមាត្រកំណត់ដោយ $S_n = \dfrac{n}{2}(U_1 + U_n) = \dfrac{n}{2}\left[2U_1 + (n-1)d\right]$ ។
6. បង្ហាញថា បើ $q$ ជាផលធៀបរួមនៃស្វ៊ីតធរណីមាត្រ $(U_n)$ នោះគេបាន $q = \dfrac{U_{n+1}}{U_n}$ ។
7. បង្ហាញថា រូបមន្តតួទី $n$ នៃស្វ៊ីតធរណីមាត្រកំណត់ដោយ : $U_n = U_1 \times q^{n-1}$ ។
8. បង្ហាញថា ផលគុណតួស្មើចម្ងាយពីតួចុង $U_p \times U_{n-p+1} = U_1 \times U_n$ ។
9. បង្ហាញថា បើ $a$ , $b$ , $c$ ជាបីតួតគ្នានៃស្វ៊ីតធរណីមាត្រ នោះគេបាន $ac = b^2$ (គេហៅ $b$ ថា មធ្យមធរណីមាត្រនៃ $a$ និង $c$) ។
10. ស្រាយបញ្ជាក់ថា ផលបូក $n$ តួដំបូងនៃស្វ៊ីតធរណីមាត្រកំណត់ដោយ $S_n = \dfrac{U_1(q^n - 1)}{q-1}$ ។
11. ស្រាយបញ្ជាក់ថា ផលបូកអនន្តតួនៃស្វ៊ីត $(U_n)$ ដែល $|q| < 1$ កំណត់ដោយ $S_\infty = \dfrac{U_1}{1-q}$ ។
12. បង្ហាញថា $1 + 2 + 3 + ... + n = \dfrac{n(n+1)}{2}$ ។
13. បង្ហាញថា $1^2 + 2^2 + 3^2 + ... + n^2 = \dfrac{n(n+1)(2n+1)}{6}$ ។
14. បង្ហាញថា $1^3 + 2^3 + 3^3 + ... + n^3 = \dfrac{n^2(n+1)^2}{4}$ ។
15. ស្រាយបញ្ជាក់លក្ខណៈនៃផលបូកខាងក្រោម ៖

   ក. $\sum_{k=1}^{n} c = nc$

   ខ. $\sum_{k=1}^{n} ca_k = c\sum_{k=1}^{n} a_k$

   គ. $\sum_{k=1}^{n}(a_k \pm b_k) = \sum_{k=1}^{n} a_k \pm \sum_{k=1}^{n} b_k$

   ឃ. $\sum_{k=1}^{n}(a_k + b_k)^2 = \sum_{k=1}^{n} a_k^2 + 2\sum_{k=1}^{n} a_k b_k + \sum_{k=1}^{n} b_k^2$
16. ស្រាយបញ្ជាក់ថា ចំពោះ ស្វ៊ីតនៃចំនួនពិត $(a_n)$ ដែល $n \geq 2$ គេបាន $S_n - S_{n-1} = a_n$ ។

# ការស្រាយបញ្ហាក់លើមេរៀន ស្វ៊ីត និងស៊េរី

1. **បង្ហាញថា បើ $d$ ជាផលសងរួមនៃស្វ៊ីតនព្វន្ត $d=U_{n+1}-U_n$**

តាមនិយមន័យស្វ៊ីតនព្វន្ត ៖ តួនីមួយៗ ស្មើតួមុនបន្ទាប់ បូកនឹងចំនួនថេរមួយ

គេបាន $U_{n+1}=U_n+d$ (ដែល $d$ ជាចំនួនថេរ ហៅថាផលសងរួម)

នាំឱ្យ $d=U_{n+1}-U_n$

ដូចនេះ $d=U_{n+1}-U_n$ ត្រូវបានបង្ហាញ ។

2. **ក. បង្ហាញថា តួទី $n$ នៃស្វ៊ីតនព្វន្តមួយកំណត់ដោយ $U_n=U_1+(n-1)\times d$**

គេមាន $d$ ជាផលសងរួមនៃស្វ៊ីតនព្វន្ត និង $U_1$ ជាតួទីមួយ

គេបាន $U_2=U_1+d \qquad =U_1+(2-1)d$

$U_3=U_2+d=(U_1+d)+d=U_1+2d \quad =U_1+(3-1)d$

$U_4=U_3+d=(U_1+2d)+d=U_1+3d=U_1+(4-1)d$

$U_5=U_4+d=(U_1+3d)+d=U_1+4d=U_1+(5-1)d$

.....................................................................................

.....................................................................................

.....................................................................................

តាមលំនាំ $U_n=U_1+(n-1)\times d$

ដូចនេះ បង្ហាញបានថា $U_n=U_1+(n-1)\times d$ ។

**ខ. បង្ហាញថា ស្វ៊ីតនព្វន្តមានតួទី $n$ គឺ $U_n=U_0+nd$ បើ $U_0$ ជាតួទីមួយ**

គេមាន $d$ ជាផលសងរួមនៃស្វ៊ីតនព្វន្ត និង $U_0$ ជាតួទីមួយ

គេបាន $U_1=U_0+d \qquad =U_1+1d$

$U_2=U_1+d=(U_0+d)+d \quad =U_0+2d$

$U_3=U_2+d=(U_0+2d)+d=U_0+3d$

$U_4=U_3+d=(U_0+3d)+d=U_0+4d$

.................................................................

.................................................................

.................................................................

តាមលំនាំ $U_n=U_0+nd$

ដូចនេះ បង្ហាញបានថា $U_n=U_0+nd$ ។

3. **ស្រាយបញ្ជាក់ ផលបូកស្មើចម្ងាយពីតួចុង** $U_1+U_n=U_2+U_{n-1}=U_3+U_{n-2}=...=U_p+U_{n-p+1}$

តាមរូបមន្ត តួទី $n$ នៃស៊ីតនព្វន្ត $U_n=U_1+(n-1)d$

គេបាន
$$U_1+U_n=U_1+U_1+(n-1)d \qquad =2U_1+(n-1)d$$
$$U_2+U_{n-1}=U_1+d+U_1+(n-2)d \qquad =2U_1+(n-1)d$$
$$U_3+U_{n-2}=U_1+2d+U_1+(n-3)d \qquad =2U_1+(n-1)d$$
..........................................................................................
$$U_p+U_{n-p+1}=U_1+(p-1)d+U_1+[(n-p+1)-1]d$$
$$=2U_1+pd-d+nd-pd$$
$$=2U_1+(n-1)d$$

ឃើញថា ផលបូក $U_1+U_n=U_2+U_{n-1}=U_3+U_{n-2}=...=U_p+U_{n-p+1}=2U_1+(n-1)d$ ដូចគ្នា

ដូចនេះ ផលបូកស្មើចម្ងាយពីតួចុង $U_1+U_n=U_2+U_{n-1}=U_3+U_{n-2}=...=U_p+U_{n-p+1}$ ត្រូវបានស្រាយបញ្ជាក់ ។

4. **បង្ហាញថា បើ $a$ , $b$ និង $c$ ជាបីតួតគ្នានៃស៊ីតនព្វន្ត នោះ** $b=\dfrac{a+c}{2}$

➢**របៀបទី១** តាមផលបូកស្មើចម្ងាយពីតួចុង បើមានបីតួតគ្នា $a$ , $b$ , $c$

គេបាន $a+c=b+b$ ឬ $2b=a+c$ នាំឱ្យ $b=\dfrac{a+c}{2}$

➢**របៀបទី២** តាង $a$ ជាតួទី១ នាំឱ្យ $b=a+d$ , $c=a+2d$

គេបាន $\dfrac{a+c}{2}=\dfrac{a+a+2d}{2}=\dfrac{2a+2d}{2}=a+d=b$

ដូចនេះ $b=\dfrac{a+c}{2}$ ត្រូវបានស្រាយបញ្ជាក់ ។

5. **ស្រាយបញ្ជាក់ថា ផលបូក $n$ តួដំបូងនៃស៊ីតនព្វន្តគឺ** $S_n=\dfrac{n}{2}(U_1+U_n)=\dfrac{n}{2}[2U_1+(n-1)d]$

គេមាន
$$+\begin{cases}S_n=U_1+U_2+U_3+...+U_{n-2}+U_{n-1}+U_n\\ S_n=U_n+U_{n-1}+U_{n-2}+...+U_3+U_2+U_1\end{cases}$$
$$2S_n=(U_1+U_n)+(U_2+U_{n-1})+(U_3+U_{n-2})+...+(U_3+U_{n-2})+(U_2+U_{n-1})+(U_1+U_n)$$

តាមផលបូកស្មើចម្ងាយពីតួចុង គេបាន $U_1+U_n=U_2+U_{n-1}=U_3+U_{n-2}=...$

គេបាន $2S_n=(U_1+U_n)+(U_1+U_n)+(U_1+U_n)+...+(U_1+U_n)+(U_1+U_n)+(U_1+U_n)$ មាន $n$ តួនៃ $(U_1+U_n)$

$$2S_n=n(U_1+U_n)$$
$$S_n=\frac{n}{2}(U_1+U_n) \quad (1)$$

ម្យ៉ាងទៀត $U_n=U_1+(n-1)d$

នោះ (1) ទៅជា $S_n=\dfrac{n}{2}[U_1+U_1+(n-1)d]=\dfrac{n}{2}[2U_1+(n-1)d]$ (2)

តាម (1) និង (2) គេបាន $S_n=\dfrac{n}{2}(U_1+U_n)=\dfrac{n}{2}[2U_1+(n-1)d]$

ដូចនេះ $S_n=\dfrac{n}{2}(U_1+U_n)=\dfrac{n}{2}[2U_1+(n-1)d]$ ត្រូវបានស្រាយបញ្ជាក់ ។

6. **បង្ហាញថា បើ $q$ ជាផលធៀបរួមនៃស្វ៊ីតធរណីមាត្រ នោះគេបាន $q=\frac{U_{n+1}}{U_n}$**

តាមនិយមន័យស្វ៊ីតធរណីមាត្រ ៖ តួនីមួយៗ ស្មើតួមុនបន្ទាប់ គុណនឹងចំនួនថេរមួយ

គេបាន $U_{n+1}=U_n\times q$ (ដែល $q$ ជាចំនួនថេរ ហៅថាផលធៀបរួម)

នាំឱ្យ $q=\frac{U_{n+1}}{U_n}$

ដូចនេះ: $q=\frac{U_{n+1}}{U_n}$ ត្រូវបានបង្ហាញ ។

7. **បង្ហាញថា រូបមន្តតួទី $n$ នៃស្វ៊ីតធរណីមាត្រកំណត់ដោយ : $U_n=U_1\times q^{n-1}$**

គេមាន $q$ ជាផលធៀបរួមនៃស្វ៊ីតធរណីមាត្រ និង $U_1$ ជាតួទីមួយ

គេបាន
$$U_2=U_1\times q \qquad =U_1\times q^{2-1}$$
$$U_3=U_2\times q=(U_1\times q)\times q=U_1\times q^2 \qquad =U_1\times q^{3-1}$$
$$U_4=U_3\times q=(U_1\times q^2)\times q=U_1\times q^3 \qquad =U_1\times q^{4-1}$$
$$U_5=U_4\times q=(U_1\times q^3)\times q=U_1\times q^4 \qquad =U_1\times q^{5-1}$$

...........................................................................................

តាមលំនាំ $U_n=U_1\times q^{n-1}$

ដូចនេះ: បង្ហាញបានថា $U_n=U_1\times q^{n-1}$ ។

8. **បង្ហាញថា ផលគុណតួស្មើចម្ងាយពីតួចុង $U_1\times U_n=U_2\times U_{n-1}=U_3\times U_{n-2}=\ldots=U_p\times U_{n-p+1}$**

តាមរូបមន្ត តួទី $n$ នៃស្វ៊ីតធរណីមាត្រ $U_n=U_1\times q^{n-1}$

គេបាន
$$U_1\times U_n=U_1\times U_1\times q^{n-1} \qquad =U_1^2\times q^{n-1}$$
$$U_2\times U_{n-1}=U_1\times q\times U_1\times q^{n-2} \qquad =U_1^2\times q^{n-1}$$
$$U_3\times U_{n-2}=U_1\times q^2\times U_1\times q^{n-3} \qquad =U_1^2\times q^{n-1}$$

.......................................................................

$$U_p\times U_{n-p+1}=U_1\times q^{p-1}\times U_1\times q^{(n-p+1)-1}$$
$$=U_1^2\times q^{p-1}\times q^{n-p}$$
$$=U_1^2\times q^{p-1+n-p}=U_1^2\times q^{n-1}$$

ឃើញថា ផលគុណ $U_1\times U_n=U_2\times U_{n-1}=U_3\times U_{n-2}=\ldots=U_p\times U_{n-p+1}=U_1^2\times q^{n-1}$ ដូចគ្នា

ដូចនេះ: $U_1\times U_n=U_2\times U_{n-1}=U_3\times U_{n-2}=\ldots=U_p\times U_{n-p+1}$ ត្រូវបានស្រាយបញ្ជាក់ ។

9. **បង្ហាញថា បើ $a$ , $b$ , $c$ ជាបីតួតគ្នានៃស្វ៊ីតធរណីមាត្រ នោះគេបាន $ac=b^2$**

➤**របៀបទី១** តាមផលគុណស្មើចម្ងាយពីតួចុង បើមានបីតួតគ្នា $a$ , $b$ , $c$ គេបាន $a\times c=b\times b$ ឬ $b^2=ac$

➤**របៀបទី២** បើមានបីតួតគ្នា $a$ , $b$ , $c$ គេបាន $q=\frac{b}{a}=\frac{c}{b}$ នាំឱ្យបាន $b^2=ac$

ដូចនេះ: $ac=b^2$ ត្រូវបានស្រាយបញ្ជាក់ ។

10. ស្រាយបញ្ជាក់ថា ផលបូក $n$ តួដំបូងនៃស្វ៊ីតធរណីមាត្រកំណត់ដោយ $S_n=\frac{U_1(q^n-1)}{q-1}$

គេមាន $S_n=U_1+U_2+U_3+\ldots+U_{n-2}+U_{n-1}+U_n$

$S_n=U_1+U_1q+U_1q^2+\ldots+U_1q^{n-3}+U_1q^{n-2}+U_1q^{n-1}\quad(1)$

នាំឱ្យ $qS_n=U_1q+U_1q^2+U_1q^3+\ldots+U_1q^{n-2}+U_1q^{n-1}+U_1q^n\quad(2)$ (បានដោយយក $(1)$ គុណនឹង $q$)

គេយក $(2)-(1)$

គេបាន
$$-\begin{cases}qS_n= & U_1q+U_1q^2+U_1q^3+\ldots+U_1q^{n-3}+U_1q^{n-2}+U_1q^{n-1}+U_1q^n\\ S_n=U_1 & +U_1q+U_1q^2+U_1q^3+\ldots+U_1q^{n-3}+U_1q^{n-2}+U_1q^{n-1}\end{cases}$$
$$(q-1)S_n=U_1q^n-U_1$$

នាំឱ្យ $$S_n=\frac{U_1(q^n-1)}{q-1}$$

ដូចនេះ ផលបូក $n$ តួដំបូងនៃស្វ៊ីតធរណីមាត្រគឺ $S_n=\frac{U_1(q^n-1)}{q-1}$ ត្រូវបានស្រាយបញ្ជាក់ ។

11. ស្រាយបញ្ជាក់ថា ផលបូកអនន្តតួនៃស្វ៊ីតធរណីមាត្រ $S_\infty=\frac{U_1}{1-q}$

គេមាន $S_n=\frac{U_1(q^n-1)}{q-1}$ ចំពោះ $|q|\neq1$ អាចសរសេរជា $S_n=\frac{U_1q^n}{q-1}-\frac{U_1}{q-1}$

បើ $|q|<1$ នោះ $q^n$ កាន់តែតូចទៅៗកាលណាចំនួនតួ $n$ កាន់តែធំទៅៗមានន័យថា $q^n\to0$ ពេល $n\to+\infty$

គេបាន $S_n=S_\infty=0-\frac{U_1}{q-1}=\frac{U_1}{1-q}$ (ព្រោះពេល $n\to+\infty$ នោះ $q^n\to0$ នាំឱ្យ $\frac{U_1q^n}{q-1}\to0$)

ដូចនេះ ផលបូកអនន្តតួនៃស្វ៊ីត $(U_n)$ ដែល $|q|<1$ កំណត់ដោយ $S_\infty=\frac{U_1}{q-1}$ ។

12. បង្ហាញថា $1+2+3+\ldots+n=\frac{n(n+1)}{2}$

➤របៀបទី១ តាង $S_n=1+2+3+\ldots+n\quad(1)$

ឬ $S_n=n+(n-1)+(n-2)+\ldots+3+2+1\quad(2)$

ដោយយក $(1)+(2)$ គេបាន

$$+\begin{cases}S_n= & 1 + 2 + 3 +\ldots+(n-2)+(n-1)+n\\ S_n= & n+(n-1)+(n-2)+\ldots+3+2+1\end{cases}$$
$$2S_n=\underbrace{(n+1)+(n+1)+(n+1)+\ldots+(n+1)+(n+1)+(n+1)}_{(n+1)\text{ មាន } n \text{ តួ}}$$

$$2S_n=n(n+1)$$
$$S_n=\frac{n(n+1)}{2}$$

ដូចនេះ $1+2+3+\ldots+n=\frac{n(n+1)}{2}$ ត្រូវបានស្រាយបញ្ជាក់ ។

➤**របៀបទី២** ចំពោះស្វីត $1, 2, 3, \dots, n$ ជាស្វីតនព្វន្ត ដែលមាន $U_1 = 1$ , $U_n = n$ និង $d = U_2 - U_1 = 2 - 1 = 1$

តាមរូបមន្ត $S_n = \frac{n}{2}(U_1 + U_n) = \frac{n}{2}(1+n) = \frac{n(n+1)}{2}$

ដូចនេះ $\boxed{1+2+3+\dots+n = \frac{n(n+1)}{2} \text{ ត្រូវបានស្រាយបញ្ជាក់}}$ ។

➤**របៀបទី៣** តាមវិចារកំណើន ៖ តាង $S_n = 1+2+3+\dots+n = \frac{n(n+1)}{2}$

បើ $n=1$ នោះ $1 = \frac{1(1+1)}{2} \quad \Leftrightarrow 1 = 1$ ពិត

បើ $n=2$ នោះ $1+2 = \frac{2(2+1)}{2} \quad \Leftrightarrow 3 = 3$ ពិត

ឧបមាថាវាពិតដល់ $n = k$ នោះ $S_k = \frac{k(k+1)}{2}$ ពិត

យើងនឹងស្រាយថាវាពិតដល់ $n = k+1$ នោះគេបាន $S_{k+1} = \frac{(k+1)(k+2)}{2}$

គេមាន $S_{k+1} = S_k + (k+1) = \frac{k(k+1)}{2} + (k+1) = \frac{k(k+1)+2(k+1)}{2} = \frac{(k+1)(k+2)}{2}$

ដូចនេះ $\boxed{1+2+3+\dots+n = \frac{n(n+1)}{2} \text{ ត្រូវបានស្រាយបញ្ជាក់}}$ ។

13. **បង្ហាញថា** $S_n = 1^2 + 2^2 + 3^2 + \dots + n^2 = \frac{n(n+1)(2n+1)}{6}$

➤**របៀបទី១** គេមាន $(k+1)^3 = k^3 + 3k^2 + 3k + 1$ បើគេយក $k = 1, 2, 3, \dots, n$ រួចបូកអង្គនិងអង្គដោយសម្រួលគ្នា គេបាន៖

$$+\begin{cases} 2^3 = 1^3 + 3\cdot 1^2 + 3\cdot 1 + 1 \\ 3^3 = 2^3 + 3\cdot 2^2 + 3\cdot 2 + 1 \\ 4^3 = 3^3 + 3\cdot 3^2 + 3\cdot 3 + 1 \\ \dots\dots\dots\dots\dots\dots\dots\dots \\ (n+1)^3 = n^3 + 3\cdot n^2 + 3\cdot 3 + 1 \end{cases}$$

$$(n+1)^3 = 1^3 + 3(1^2 + 2^2 + 3^2 + \dots + n^2) + 3(1+2+3+\dots+n) + n$$

ដោយ $S_n = 1^2 + 2^2 + 3^2 + \dots + n^2$ និង $1+2+3+\dots+n = \frac{n(n+1)}{2}$ (ស្រាយបញ្ជាក់រួចខាងលើ)

នាំឱ្យ $(n+1)^3 = 1 + 3S_n + 3\cdot\frac{n(n+1)}{2} + n$

នោះ $3S_n = (n+1)^3 - \frac{3n(n+1)}{2} - n - 1 = \frac{2(n+1)^3 - 3n(n+1) - 2(n+1)}{2}$

$$= \frac{(n+1)\left[2(n^2+2n+1) - 3n - 2\right]}{2} = \frac{(n+1)(2n^2+n)}{2} = \frac{n(n+1)(2n+1)}{2}$$

គេបាន $S_n = \frac{n(n+1)(2n+1)}{6}$

ដូចនេះ $\boxed{S_n = 1^2 + 2^2 + 3^2 + \dots + n^2 = \frac{n(n+1)(2n+1)}{6} \text{ ត្រូវបានស្រាយបញ្ជាក់}}$ ។

➤**របៀបទី២** ស្រាយតាមវិចារកំណើន គេមាន $S_n = 1^2 + 2^2 + 3^2 + ... + n^2 = \frac{n(n+1)(2n+1)}{6}$

បើ $n = 1$ គេបាន $1^2 = \frac{1(1+1)(2+1)}{6} \Leftrightarrow 1 = 1$ ពិត

បើ $n = 2$ គេបាន $1^2 + 2^2 = \frac{2(2+1)(4+1)}{6} \Leftrightarrow 5 = 5$ ពិត

ឧបមាថា វាពិតរហូតដល់ $n = k$ គេបាន $S_k = \frac{k(k+1)(2k+1)}{6}$

គេនឹងស្រាយថាវាពិតរហូតដល់ $n = k+1$ គេបាន $S_{k+1} = \frac{(k+1)(k+2)(2k+3)}{6}$

ដោយ
$$\begin{aligned} S_{k+1} &= S_k + (k+1)^2 \\ &= \frac{k(k+1)(2k+1)}{6} + (k+1)^2 \\ &= \frac{k(k+1)(2k+1) + 6(k+1)^2}{6} \\ &= \frac{(k+1)[k(2k+1) + 6(k+1)]}{6} \\ &= \frac{(k+1)(2k^2 + k + 6k + 6)}{6} \\ &= \frac{(k+1)(2k^2 + 4k + 3k + 6)}{6} \\ &= \frac{(k+1)[2k(k+2) + 3(k+2)]}{6} \\ &= \frac{(k+1)(k+2)(2k+3)}{6} \end{aligned}$$

ដូចនេះ $S_n = 1^2 + 2^2 + 3^2 + ... + n^2 = \frac{n(n+1)(2n+1)}{6}$ ត្រូវបានស្រាយបញ្ជាក់ ។

14. **បង្ហាញថា** $S_n = 1^3 + 2^3 + 3^3 + ... + n^3 = \frac{n^2(n+1)^2}{4}$

➤**របៀបទី១** តាមវិចារកំណើន

បើ $n = 1$ គេបាន $1^3 = \frac{1^2 \cdot (1+1)^2}{4} \Leftrightarrow 1 = 1$ ពិត

បើ $n = 2$ គេបាន $1^3 + 2^3 = \frac{2^2 \cdot (2+1)^2}{4} \Leftrightarrow 9 = 9$ ពិត

ឧបមាថា វាពិតរហូតដល់ $n = k$ គេបាន $S_k = \frac{k^2(k+1)^2}{4}$

គេនឹងស្រាយថាវាពិតរហូតដល់ $n = k+1$ គេបាន $S_{k+1} = \frac{(k+1)^2(k+2)^2}{4}$

ដោយ $S_{k+1}=S_k+(k+1)^3$

$$=\frac{k^2(k+1)^2}{4}+(k+1)^3$$

$$=\frac{k^2(k+1)^2+4(k+1)^3}{4}$$

$$=\frac{(k+1)^2\left[k^2+4(k+1)\right]}{4}$$

$$=\frac{(k+1)^2\left[k^2+4k+4\right]}{4}=\frac{(k+1)^2(k+2)^2}{4}$$

ដូចនេះ: $\boxed{S_n=1^3+2^3+3^3+...+n^3=\frac{n^2(n+1)^2}{4}}$ ត្រូវបានស្រាយបញ្ជាក់ ។

**➢របៀបទី២** គេមាន $(k+1)^4=k^4+4k^3+6k^2+4k+1$

បើគេយក $k=1\,,2\,,3\,,...\,,n$ រួចបូកអង្គនិងអង្គដោយសម្រួលគ្នា គេបាន៖

$$+\begin{cases}2^4=1^4+4\cdot1^3+6\cdot1^2+4\cdot1+1\\3^4=2^4+4\cdot2^3+6\cdot2^2+4\cdot2+1\\4^4=3^4+4\cdot3^3+6\cdot3^2+4\cdot3+1\\\dots\dots\dots\dots\dots\dots\\(n+1)^4=n^4+4\cdot n^3+6\cdot n^2+4\cdot n+1\end{cases}$$

$$(n+1)^4=1^4+4\left(1^3+2^3+3^3+...+n^3\right)+6\left(1^2+2^2+3^2+...+n^2\right)+4(1+2+3+...+n)+n$$

ដោយ $S_n=1^3+2^3+3^3+...+n^3$ , $1^2+2^2+3^2+...+n^2=\frac{n(n+1)(2n+1)}{6}$ និង $1+2+3+...+n=\frac{n(n+1)}{2}$

គេបាន $(n+1)^4=1^4+4S_n+6\cdot\frac{n(n+1)(2n+1)}{6}+4\cdot\frac{n(n+1)}{2}+n$

$$4S_n=(n+1)^4-n(n+1)(2n+1)-2n(n+1)-n-1$$

$$=(n+1)\left[(n+1)^3-\left(2n^2+n\right)-2n-1\right]$$

$$=(n+1)\left[(n+1)^3-2n^2-3n-1\right]$$

$$=(n+1)\left[(n+1)^3-\left(2n^2+3n+1\right)\right]$$

$$=(n+1)\left[(n+1)^3-(n+1)(2x+1)\right]$$

$$=(n+1)^2\left[(n+1)^2-(2x+1)\right]$$

$$=(n+1)^2\left[n^2+2n+1-(2x+1)\right]$$

$$=n^2(n+1)^2$$

នាំឱ្យ $S_n=\frac{n^2(n+1)^2}{4}$

ដូចនេះ: $\boxed{S_n=1^3+2^3+3^3+...+n^3=\frac{n^2(n+1)^2}{4}}$ ត្រូវបានស្រាយបញ្ជាក់ ។

15. ស្រាយបញ្ជាក់លក្ខណៈនៃផលបូកខាងក្រោម ៖

ក. ស្រាយបញ្ជាក់ថា $\sum_{k=1}^{n} c = nc$

គេមាន $\sum_{k=1}^{n} c = c + c + \ldots + c$ ( ដោយ $\underbrace{c + c + c + \ldots + c}_{n \text{ តួ}} = nc$ )

គេបាន $\sum_{k=1}^{n} c = c + c + \ldots + c = nc$ ពិត

ដូចនេះ $\boxed{\sum_{k=1}^{n} c = nc}$ ត្រូវបានស្រាយបញ្ជាក់ ។

ខ. ស្រាយបញ្ជាក់ថា $\sum_{k=1}^{n} ca_k = c\sum_{k=1}^{n} a_k$

គេមាន $\sum_{k=1}^{n} ca_k = ca_1 + ca_2 + \ldots + ca_n$

$= c(a_1 + a_2 + \ldots + a_n) = c\sum_{k=1}^{n} a_k$ ពិត

ដូចនេះ $\boxed{\sum_{k=1}^{n} ca_k = c\sum_{k=1}^{n} a_k}$ ត្រូវបានស្រាយបញ្ជាក់ ។

គ. ស្រាយបញ្ជាក់ថា $\sum_{k=1}^{n} (a_k \pm b_k) = \sum_{k=1}^{n} a_k \pm \sum_{k=1}^{n} b_k$

គេមាន $\sum_{k=1}^{n} (a_k \pm b_k) = (a_1 \pm b_1) + (a_2 \pm b_2) + \ldots + (a_n \pm b_n)$

$= (a_1 + a_2 + \ldots + a_3) \pm (b_1 + b_2 + \ldots + b_n) = \sum_{k=1}^{n} a_k \pm \sum_{k=1}^{n} b_k$ ពិត

ដូចនេះ $\boxed{\sum_{k=1}^{n} (a_k \pm b_k) = \sum_{k=1}^{n} a_k \pm \sum_{k=1}^{n} b_k}$ ត្រូវបានស្រាយបញ្ជាក់ ។

ឃ. ស្រាយបញ្ជាក់ថា $\sum_{k=1}^{n} (a_k + b_k)^2 = \sum_{k=1}^{n} a_k^2 + 2\sum_{k=1}^{n} a_k b_k + \sum_{k=1}^{n} b_k^2$

គេមាន $\sum_{k=1}^{n} (a_k + b_k)^2 = (a_1 + b_1)^2 + (a_2 + b_2)^2 + \ldots + (a_n + b_n)^2$

$= (a_1^2 + 2a_1 b_1 + b_1^2) + (a_2^2 + 2a_2 b_2 + b_2^2) + (a_3^2 + 2a_3 b_3 + b_3^2) + \ldots + (a_n^2 + 2a_n b_n + b_n^2)$

$= (a_1^2 + a_2^2 + a_3^2 + \ldots + a_n^2) + 2(a_1 b_1 + a_2 b_2 + a_3 b_3 + \ldots + a_n b_n) + (b_1^2 + b_2^2 + b_3^2 + \ldots + b_n^2)$

$= \sum_{k=1}^{n} a_k^2 + 2\sum_{k=1}^{n} a_k b_k + \sum_{k=1}^{n} b_k^2$ ពិត

ដូចនេះ $\boxed{\sum_{k=1}^{n} (a_k + b_k)^2 = \sum_{k=1}^{n} a_k^2 + 2\sum_{k=1}^{n} a_k b_k + \sum_{k=1}^{n} b_k^2}$ ត្រូវបានស្រាយបញ្ជាក់ ។

16. ស្រាយបញ្ជាក់ថា ចំពោះ $n\geq 2$ គេបាន $S_n - S_{n-1} = a_n$

គេមាន $S_n = a_1 + a_2 + a_3 + \dots + a_{n-1} + a_n \quad (1)$ និង $S_{n-1} = a_1 + a_2 + a_3 + \dots + a_{n-1} \quad (2)$

គេយក $(1)-(2)$ គេបាន ៖

$$-\begin{cases} S_n = a_1 + a_2 + a_3 + \dots + a_{n-1} + a_n \\ S_{n-1} = a_1 + a_2 + a_3 + \dots + a_{n-1} \end{cases}$$

$$S_n - S_{n-1} = a_n$$

ដូចនេះ: ស្រាយបញ្ជាក់បានថា $S_n - S_{n-1} = a_n$ ពិតចំពោះ $n\geq 2$ ។

# ការស្រាយបញ្ជាក់លើមេរៀន អិចស្ប៉ូណង់ស្យែល

1. បង្ហាញលក្ខណៈនៃស្វ័យគុណខាងក្រោម ៖

ក. $a^m \times a^n = a^{m+n}$ ខ. $\left(a^m\right)^n = a^{m\times n}$ គ. $(ab)^n = a^n \times b^n$ ឃ. $\left(\dfrac{a}{b}\right)^n = \dfrac{a^n}{b^n}$ , $b \neq 0$

ង. $\dfrac{a^m}{a^n} = a^{m-n}$ , $a \neq 0$ ច. $a^0 = 1$ , $a \neq 0$ ឆ. $\dfrac{1}{a^n} = a^{-n}$ , $a \neq 0$ ជ. $\sqrt[n]{a} \times \sqrt[n]{b} = \sqrt[n]{ab}$

ឈ. $\dfrac{\sqrt[n]{a}}{\sqrt[n]{b}} = \sqrt[n]{\dfrac{a}{b}}$ , $b \neq 0$ ញ. $\sqrt[n]{a^m} = a^{\frac{m}{n}}$ ដ. $\sqrt[n]{\sqrt[k]{a}} = \sqrt[n\cdot k]{a}$ ឋ. $\sqrt[n]{a^m} = \sqrt[k\cdot n]{a^{k\cdot m}}$ ។

2. បង្ហាញថាគេប្រើរូបមន្ត $P_t = P_0\left(1+\dfrac{i}{n}\right)^{nt}$ សម្រាប់គណនាប្រាក់សរុបរយៈពេល $t$ ឆ្នាំ ដែល $P_0$ ជាប្រាក់ដើម , $i$ ជាអត្រាការប្រាក់ក្នុងមួយឆ្នាំ , $t$ ជាចំនួនឆ្នាំ , $P_t$ ជាប្រាក់សរុបរយៈពេល $t$ ឆ្នាំ , ទូទាត់ចំនួន $n$ ដងក្នុងមួយឆ្នាំ ។

3. បង្ហាញថា ក្រាបនៃអនុគមន៍ $y = a^x$ កាត់តាមចំណុចដែលមានកូអរដោនេ $(0\,,1)$ ជានិច្ច ។

4. ចូរបង្ហាញថា បើ $f(x) = a^x$ នោះ $f(x)\,f(y) = f(x+y)$ ។

5. គេមានអនុគមន៍ $f(x) = \dfrac{2^{x+1}+\sqrt{2}}{2^x+\sqrt{2}}$ ។ ចំពោះគ្រប់ចំនួនគត់ $m$ និង $n$ ដែល $m+n=1$ ចូរបង្ហាញថា $f(m)+f(n)=3$ ។

6. គេមានអនុគមន៍ $f(x) = \dfrac{e^x - e^{-x}}{e^x + e^{-x}}$ ។ ចំពោះគ្រប់ចំនួនពិត $a$ និង $b$ ចូរស្រាយបញ្ជាក់ថា $f(a+b) = \dfrac{f(a)+f(b)}{1+f(a)\,f(b)}$ ។

7. បើ $(x_1\,, y_1)$ និង $(x_2\,, y_2)$ ជាពីរចំណុចនៅលើខ្សែកោង $f(x) = a^x$ នោះចំណុចទាំងពីរ $(x_1+x_2\ ,\ y_1y_2)$ និង $\left(x_1-x_2\ ,\ \dfrac{y_1}{y_2}\right)$ ក៏ជាពីរចំណុចនៅលើខ្សែកោង $f(x) = a^x$ ដែរ ។

8. បើចំណុច $(x_1, y_1)$ នៅលើខ្សែកោង $f(x) = a^x$ នោះចំណុចទាំងពីរ $\left(2x_1\ ,\ y_1^2\right)$ និង $\left(-x_1\ ,\ \dfrac{1}{y_1}\right)$ ក៏នៅលើខ្សែកោង $f(x) = a^x$ ដែរ ។

# ការស្រាយបញ្ជាក់លើមេរៀន អិចស្ប៉ូណង់ស្យែល

1. បង្ហាញលក្ខណៈនៃស្វ័យគុណខាងក្រោម ៖

ក. បង្ហាញលក្ខណៈនៃស្វ័យគុណ $a^m \times a^n = a^{m+n}$

តាមនិយមន័យ $\underbrace{a\times a\times a\times\ldots\times a}_{n\text{ កត្តា}} = a^n$

គេបាន $a^m \times a^n = \underbrace{a\times a\times a\times\ldots\times a}_{m\text{ កត្តា}}\times\underbrace{a\times a\times a\times\ldots\times a}_{n\text{ កត្តា}} = \underbrace{a\times a\times a\times\ldots\times a\times a\times a}_{(m+n)\text{ កត្តា}} = a^{m+n}$

ដូចនេះ: លក្ខណៈ: $a^m \times a^n = a^{m+n}$ ត្រូវបានបង្ហាញ ។

ខ. បង្ហាញលក្ខណៈនៃស្វ័យគុណ $\left(a^m\right)^n = a^{m\times n}$

ពិនិត្យ $\left(a^m\right)^n = \underbrace{a^m \times a^m \times a^m \times\ldots\times a^m}_{n\text{ កត្តា}} = a^{\overbrace{m+m+m+\ldots+m}^{n\text{ កត្តា}}} = a^{m\times n}$ (ពង្រីកឱ្យធំស្រួលមើលស្វ័យគុណ)

ដូចនេះ: លក្ខណៈ: $\left(a^m\right)^n = a^{m\times n}$ ត្រូវបានបង្ហាញ ។

គ. បង្ហាញលក្ខណៈនៃស្វ័យគុណ $(ab)^n = a^n \times b^n$

ពិនិត្យ $a^n \times b^n = \underbrace{a\times a\times a\times\ldots\times a}_{n\text{ កត្តា}}\times\underbrace{b\times b\times b\times\ldots\times b}_{n\text{ កត្តា}} = \underbrace{(ab)\times(ab)\times(ab)\times\ldots\times(ab)}_{n\text{ កត្តា}} = (ab)^n$

ដូចនេះ: លក្ខណៈ: $(ab)^n = a^n \times b^n$ ត្រូវបានបង្ហាញ ។

ឃ. បង្ហាញលក្ខណៈនៃស្វ័យគុណ $\left(\frac{a}{b}\right)^n = \frac{a^n}{b^n}$ , $b \neq 0$

ពិនិត្យ $\frac{a^n}{b^n} = \frac{\overbrace{a\times a\times a\times\ldots\times a}^{n\text{ កត្តា}}}{\underbrace{b\times b\times b\times\ldots\times b}_{n\text{ កត្តា}}} = \underbrace{\frac{a}{b}\times\frac{a}{b}\times\frac{a}{b}\times\ldots\times\frac{a}{b}}_{n\text{ កត្តា}} = \left(\frac{a}{b}\right)^n$

ដូចនេះ: លក្ខណៈ: $\left(\frac{a}{b}\right)^n = \frac{a^n}{b^n}$ , $b \neq 0$ ត្រូវបានបង្ហាញ ។

ង. បង្ហាញលក្ខណៈនៃស្វ័យគុណ $\frac{a^m}{a^n} = a^{m-n}$ , $a \neq 0$

$\frac{a^m}{a^n} = \frac{\overbrace{a\times a\times a\times\ldots\times a}^{m\text{ កត្តា}}}{\underbrace{a\times a\times a\times\ldots\times a}_{n\text{ កត្តា}}} = \underbrace{\frac{a}{a}\times\frac{a}{a}\times\frac{a}{a}\times\ldots\times\frac{a}{a}}_{n\text{ កត្តា}}\times\underbrace{a\times a\times a\times\ldots\times a}_{(m-n)\text{ កត្តា}} = \underbrace{a\times a\times a\times\ldots\times a}_{(m-n)\text{ កត្តា}} = a^{m-n}$

ដូចនេះ: លក្ខណៈ: $\frac{a^m}{a^n} = a^{m-n}$ , $a \neq 0$ ត្រូវបានបង្ហាញ ។

ច. បង្ហាញលក្ខណៈនៃស្វ័យគុណ $a^0=1\,,\,a\neq 0$

គេមាន $\dfrac{a^n}{a^n}=\dfrac{\overbrace{a\times a\times a\times\ldots\times a}^{n\text{ កត្តា}}}{\underbrace{a\times a\times a\times\ldots\times a}_{n\text{ កត្តា}}}=\underbrace{\dfrac{a}{a}\times\dfrac{a}{a}\times\dfrac{a}{a}\times\ldots\times\dfrac{a}{a}}_{n\text{ កត្តា}}=\underbrace{1\times1\times1\times\ldots\times1}_{n\text{ កត្តា}}=1\quad(1)$

ម្យ៉ាងទៀត $\dfrac{a^n}{a^n}=a^{n-n}=a^0\quad(2)$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ គេបាន $a^0=1\,,\,a\neq0$

ដូចនេះ | លក្ខណៈ $a^0=1\,,\,a\neq0$ ត្រូវបានបង្ហាញ | ។

ឆ. បង្ហាញលក្ខណៈនៃស្វ័យគុណ $\dfrac{1}{a^n}=a^{-n}\,,\,a\neq0$

គេមាន $\dfrac{1}{a^n}=\dfrac{a^0}{a^n}=a^{0-n}=a^{-n}\,,\,a\neq0$

ដូចនេះ | លក្ខណៈ $\dfrac{1}{a^n}=a^{-n}\,,\,a\neq0$ ត្រូវបានបង្ហាញ | ។

ជ. បង្ហាញលក្ខណៈនៃស្វ័យគុណ $\sqrt[n]{a}\times\sqrt[n]{b}=\sqrt[n]{ab}$ ដែល $a>0\,,\,b>0$ និង $n$ ជាចំនួនគត់វិជ្ជមាន $n\geq2$

គេដឹងថា $\sqrt[n]{a^n}=a$ (សូមកុំច្រឡំថា $\sqrt[n]{a^n}=|a|$ ព្រោះក្នុងខណៈនេះយើងសិក្សាតែ $a>0\,,\,b>0$ )

គេតាង $x=\sqrt[n]{a}$ នោះ $x^n=a$

$y=\sqrt[n]{b}$ នោះ $y^n=b$

គេបាន $x^ny^n=ab$ ឬ $(xy)^n=ab$ ឬ $xy=\sqrt[n]{ab}$ ឬ $\sqrt[n]{a}\times\sqrt[n]{b}=\sqrt[n]{ab}$

ដូចនេះ | លក្ខណៈ $\sqrt[n]{a}\times\sqrt[n]{b}=\sqrt[n]{ab}$ ត្រូវបានបង្ហាញ | ។

ឈ. បង្ហាញលក្ខណៈនៃស្វ័យគុណ $\dfrac{\sqrt[n]{a}}{\sqrt[n]{b}}=\sqrt[n]{\dfrac{a}{b}}$ ដែល $a>0\,,\,b>0$ និង $n$ ជាចំនួនគត់វិជ្ជមាន $n\geq2$

គេតាង $x=\sqrt[n]{a}$ នោះ $x^n=a$

$y=\sqrt[n]{b}$ នោះ $y^n=b$

គេបាន $\dfrac{x^n}{y^n}=\dfrac{a}{b}$ ឬ $\left(\dfrac{x}{y}\right)^n=\dfrac{a}{b}$ ឬ $\dfrac{x}{y}=\sqrt[n]{\dfrac{a}{b}}$ ឬ $\dfrac{\sqrt[n]{a}}{\sqrt[n]{b}}=\sqrt[n]{\dfrac{a}{b}}$

ដូចនេះ | លក្ខណៈ $\dfrac{\sqrt[n]{a}}{\sqrt[n]{b}}=\sqrt[n]{\dfrac{a}{b}}\,,\,b\neq0$ ត្រូវបានបង្ហាញ | ។

ញ. បង្ហាញលក្ខណៈនៃស្វ័យគុណ $\sqrt[n]{a^m}=a^{\frac{m}{n}}$

គេតាង $x=\sqrt[n]{a^m}\Rightarrow x^n=a^m$ ឬ $\left(x^n\right)^{\frac{1}{n}}=\left(a^m\right)^{\frac{1}{n}}\Rightarrow x^{n\times\frac{1}{n}}=a^{m\times\frac{1}{n}}$ ឬ $x=a^{\frac{m}{n}}$ នាំឱ្យ $\sqrt[n]{a^m}=a^{\frac{m}{n}}$

ដូចនេះ | លក្ខណៈ $\sqrt[n]{a^m}=a^{\frac{m}{n}}$ ត្រូវបានបង្ហាញ | ។

**ជ. បង្ហាញលក្ខណៈនៃស្វ័យគុណ** $\sqrt[n]{\sqrt[k]{a}}=\sqrt[n\cdot k]{a}$

គេតាង $x=\sqrt[n]{\sqrt[k]{a}} \Rightarrow x^n=\sqrt[k]{a}$ ឬ $\left(x^n\right)^k=a$ ឬ $x^{nk}=a$ ឬ $x=\sqrt[nk]{a}$ នាំឱ្យ $\sqrt[n]{\sqrt[k]{a}}=\sqrt[n\cdot k]{a}$

ដូចនេះ: | លក្ខណៈ: $\sqrt[n]{\sqrt[k]{a}}=\sqrt[n\cdot k]{a}$ ត្រូវបានបង្ហាញ | ។

**ឋ. បង្ហាញលក្ខណៈនៃស្វ័យគុណ** $\sqrt[n]{a^m}=\sqrt[k\cdot n]{a^{k\cdot m}}$

គេតាង $x=\sqrt[n]{a^m} \Rightarrow x^n=a^m$ ឬ $\left(x^n\right)^k=\left(a^m\right)^k \Rightarrow x^{kn}=a^{km}$ ឬ $x=\sqrt[kn]{a^{km}}$ នាំឱ្យ $\sqrt[n]{a^m}=\sqrt[k\cdot n]{a^{k\cdot m}}$

ដូចនេះ: | លក្ខណៈ: $\sqrt[n]{a^m}=\sqrt[k\cdot n]{a^{k\cdot m}}$ ត្រូវបានបង្ហាញ | ។

2. **បង្ហាញថា គេប្រើរូបមន្ត** $P_t=P_0\left(1+\dfrac{i}{n}\right)^{nt}$ **សម្រាប់គណនាប្រាក់សរុបរយៈពេល** $t$ **ឆ្នាំ**

គេមាន $P_0$ ជាប្រាក់ដើម , $i$ ជាអត្រាការប្រាក់ ក្នុងមួយឆ្នាំ ,

$t$ ជាចំនួនឆ្នាំ , $P_t$ ជាប្រាក់សរុបរយៈពេល $t$ ឆ្នាំ , ទូទាត់ចំនួន $n$ ដងក្នុងមួយឆ្នាំ

គេបាន ចំនួនការប្រាក់នៅឆ្នាំទី១គឺ $P_0 i$

នាំឱ្យ ចំនួនប្រាក់សរុបនៅឆ្នាំទី១ : $P_1=P_0+P_0 i=P_0\left(1+i\right)$

ចំនួនប្រាក់សរុបនៅឆ្នាំទី២ : $P_2=P_0\left(1+i\right)+P_0\left(1+i\right)i=P_0\left(1+i\right)\left(1+i\right)=P_0\left(1+i\right)^2$

ចំនួនប្រាក់សរុបនៅឆ្នាំទី៣ : $P_3=P_0\left(1+i\right)^2+P_0\left(1+i\right)^2 i=P_0\left(1+i\right)^2\left(1+i\right)=P_0\left(1+i\right)^3$

ចំនួនប្រាក់សរុបនៅឆ្នាំទី៤ : $P_4=P_0\left(1+i\right)^3+P_0\left(1+i\right)^3 i=P_0\left(1+i\right)^3\left(1+i\right)=P_0\left(1+i\right)^4$

................................... : ..........................................................................................................

ចំនួនប្រាក់សរុបនៅឆ្នាំទី $t$ : $P_t=P_0\left(1+i\right)^{t-1}+P_0\left(1+i\right)^{t-1} i=P_0\left(1+i\right)^{t-1}\left(1+i\right)=P_0\left(1+i\right)^t$

គេបាន
- ➤ សម្រាប់ការទូទាត់ក្នុងមួយឆ្នាំ 1 ដង $P_t=P_0\left(1+i\right)^t$
- ➤ សម្រាប់ការទូទាត់ក្នុងមួយឆ្នាំ 2 ដង ឬមួយឆមាសទូទាត់ម្តង គេប្រើរូបមន្ត $P_t=P_0\left(1+\dfrac{i}{2}\right)^{2t}$ ព្រោះ មួយឆ្នាំទូទាត់ការប្រាក់ 2 ដង នាំឱ្យ $t$ ឆ្នាំ ទូទាត់ $2t$ ហើយមួយឆ្នាំទទួលអត្រាការប្រាក់ $i$ នាំឱ្យមួយឆមាសទទួលអត្រាការប្រាក់ $i/2$ ។
- ➤ សម្រាប់ការទូទាត់ក្នុងមួយឆ្នាំ 4 ដង ឬមួយត្រីមាសទូទាត់ម្តង គេប្រើរូបមន្ត $P_t=P_0\left(1+\dfrac{i}{4}\right)^{4t}$ ព្រោះ មួយឆ្នាំទូទាត់ការប្រាក់ 4 ដង នាំឱ្យ $t$ ឆ្នាំ ទូទាត់ $4t$ ហើយមួយឆ្នាំទទួលអត្រាការប្រាក់ $i$ នាំឱ្យមួយត្រីមាសទទួលអត្រាការប្រាក់ $i/4$ ។
- ➤ សម្រាប់ការទូទាត់ក្នុងមួយឆ្នាំ $n$ ដង គេប្រើរូបមន្ត $P_t=P_0\left(1+\dfrac{i}{n}\right)^{nt}$ ព្រោះ មួយឆ្នាំទូទាត់ការប្រាក់ $n$ ដង នាំឱ្យ $t$ ឆ្នាំ ទូទាត់ $nt$ ហើយមួយឆ្នាំទទួលអត្រាការប្រាក់ $i$ នោះការទូទាត់ $n$ ដងក្នុងមួយឆ្នាំទទួលអត្រាការប្រាក់ $i/n$ ។

ដូចនេះ: | គេប្រើរូបមន្ត $P_t=P_0\left(1+\dfrac{i}{n}\right)^{nt}$ សម្រាប់គណនាប្រាក់សរុបរយៈពេល $t$ ឆ្នាំ ក្នុងករណីទូទាត់ $n$ ដងក្នុងមួយឆ្នាំ | ។

3. **បង្ហាញថា ក្រាបនៃអនុគមន៍ $y=a^x$ កាត់តាមចំណុចដែលមានកូអរដោនេ $(0,1)$ ជានិច្ច**

គេមាន $y=a^x$ ជាអនុគមន៍អិចស្ប៉ូណង់ស្យែលដែល $a>0$ និង $a\neq 1$

ចំពោះ $x=0$ នោះគេបាន $y=a^0=1$ , $a>0$ និង $a\neq 1$

ម្យ៉ាងទៀត $y=1$ នោះគេបាន $a^x=1$ ឬ $a^x=a^0$ នាំឱ្យ $x=0$

ដូចនេះ ក្រាបនៃអនុគមន៍ $y=a^x$ កាត់តាមចំណុច $(0,1)$ ។

4. **បង្ហាញថា បើ $f(x)=a^x$ នោះ $f(x)f(y)=f(x+y)$**

គេមាន $f(x)=a^x$

$f(y)=a^y$

$f(x+y)=a^{x+y}$

នាំឱ្យ $f(x)f(y)=a^x\times a^y=a^{x+y}=f(x+y)$

ដូចនេះ $f(x)=a^x$ នោះ $f(x)f(y)=f(x+y)$ ត្រូវបានបង្ហាញ ។

5. **បង្ហាញថា** $f(m)+f(n)=3$

គេមាន $f(x)=\dfrac{2^{x+1}+\sqrt{2}}{2^x+\sqrt{2}}=\dfrac{2\cdot 2^x+\sqrt{2}}{2^x+\sqrt{2}}$ និង $m+n=1$

នាំឱ្យ $f(m)=\dfrac{2\cdot 2^m+\sqrt{2}}{2^m+\sqrt{2}}$

$f(n)=\dfrac{2\cdot 2^n+\sqrt{2}}{2^n+\sqrt{2}}$

គេបាន
$$\begin{aligned}
f(m)+f(n)&=\frac{2\cdot 2^m+\sqrt{2}}{2^m+\sqrt{2}}+\frac{2\cdot 2^n+\sqrt{2}}{2^n+\sqrt{2}}\\
&=\frac{\left(2\cdot 2^m+\sqrt{2}\right)\left(2^n+\sqrt{2}\right)+\left(2\cdot 2^n+\sqrt{2}\right)\left(2^m+\sqrt{2}\right)}{\left(2^m+\sqrt{2}\right)\left(2^n+\sqrt{2}\right)}\\
&=\frac{2\cdot 2^{m+n}+2\sqrt{2}\cdot 2^m+\sqrt{2}\cdot 2^n+2+2\cdot 2^{m+n}+2\sqrt{2}\cdot 2^n+\sqrt{2}\cdot 2^m+2}{2^{m+n}+\sqrt{2}\cdot 2^m+\sqrt{2}\cdot 2^n+2}\\
&=\frac{4\cdot 2^{m+n}+3\sqrt{2}\cdot 2^m+3\sqrt{2}\cdot 2^n+4}{2^{m+n}+\sqrt{2}\cdot 2^m+\sqrt{2}\cdot 2^n+2}\quad ,\ m+n=1\\
&=\frac{12+3\sqrt{2}\cdot 2^m+3\sqrt{2}\cdot 2^n}{4+\sqrt{2}\cdot 2^m+\sqrt{2}\cdot 2^n}\\
&=\frac{3\left(4+\sqrt{2}\cdot 2^m+\sqrt{2}\cdot 2^n\right)}{4+\sqrt{2}\cdot 2^m+\sqrt{2}\cdot 2^n}\\
&=3
\end{aligned}$$

ដូចនេះ $f(m)+f(n)=3$ ត្រូវបានបង្ហាញ ។

6. ស្រាយបញ្ជាក់ថា $f(a+b)=\dfrac{f(a)+f(b)}{1+f(a)f(b)}$

គេមាន $f(x)=\dfrac{e^x-e^{-x}}{e^x+e^{-x}}=\dfrac{e^x-\dfrac{1}{e^x}}{e^x+\dfrac{1}{e^x}}=\dfrac{\dfrac{e^{2x}-1}{e^x}}{\dfrac{e^{2x}+1}{e^x}}=\dfrac{e^{2x}-1}{e^{2x}+1}$

នាំឱ្យ $f(a)=\dfrac{e^{2a}-1}{e^{2a}+1}$ , $f(b)=\dfrac{e^{2b}-1}{e^{2b}+1}$ , $f(a+b)=\dfrac{e^{2(a+b)}-1}{e^{2(a+b)}+1}$

ដោយ $f(a)+f(b)=\dfrac{e^{2a}-1}{e^{2a}+1}+\dfrac{e^{2b}-1}{e^{2b}+1}=\dfrac{\left(e^{2a}-1\right)\left(e^{2b}+1\right)+\left(e^{2b}-1\right)\left(e^{2a}+1\right)}{\left(e^{2a}+1\right)\left(e^{2b}+1\right)}$

$$=\frac{e^{2a+2b}+e^{2a}-e^{2b}-1+e^{2a+2b}+e^{2b}-e^{2a}-1}{e^{2a+2b}+e^{2a}+e^{2b}+1}$$

$$=\frac{2e^{2a+2b}-2}{e^{2a+2b}+e^{2a}+e^{2b}+1} \quad (1)$$

ហើយ $f(a)\times f(b)=\dfrac{e^{2a}-1}{e^{2a}+1}\times\dfrac{e^{2b}-1}{e^{2b}+1}=\dfrac{\left(e^{2a}-1\right)\left(e^{2b}-1\right)}{\left(e^{2a}+1\right)\left(e^{2b}+1\right)}=\dfrac{e^{2a+2b}-e^{2a}-e^{2b}+1}{e^{2a+2b}+e^{2a}+e^{2b}+1}$

នាំឱ្យ $1+f(a)f(b)=1+\dfrac{e^{2a+2b}-e^{2a}-e^{2b}+1}{e^{2a+2b}+e^{2a}+e^{2b}+1}$

$$=\frac{e^{2a+2b}+e^{2a}+e^{2b}+1+e^{2a+2b}-e^{2a}-e^{2b}+1}{e^{2a+2b}+e^{2a}+e^{2b}+1}$$

$$=\frac{2e^{2a+2b}+2}{e^{2a+2b}+e^{2a}+e^{2b}+1} \quad (2)$$

គេធ្វើផលធៀប រវាង $(1)$ និង $(2)$ គេបាន ៖

$$\frac{f(a)+f(b)}{1+f(a)f(b)}=\frac{\dfrac{2e^{2a+2b}-2}{e^{2a+2b}+e^{2a}+e^{2b}+1}}{\dfrac{2e^{2a+2b}+2}{e^{2a+2b}+e^{2a}+e^{2b}+1}}=\frac{2e^{2a+2b}-2}{2e^{2a+2b}+2}=\frac{e^{2a+2b}-1}{e^{2a+2b}+1}=\frac{e^{2(a+b)}-1}{e^{2(a+b)}+1}=f(a+b)$$

ដូចនេះ

| $f(a+b)=\dfrac{f(a)+f(b)}{1+f(a)f(b)}$ ត្រូវបានបង្ហាញ |
|---|

។

7. បង្ហាញថា ចំណុចទាំងពីរ $(x_1+x_2\ ,\ y_1y_2)$ និង $\left(x_1-x_2\ ,\ \dfrac{y_1}{y_2}\right)$ ក៏ជាពីរចំណុចនៅលើខ្សែកោង $f(x)=a^x$ ដែរ

គេមាន $(x_1\ ,\ y_1)$ និង $(x_2\ ,\ y_2)$ ជាពីរចំណុចនៅលើខ្សែកោង $f(x)=a^x$

នាំឱ្យ $f(x_1)=a^{x_1}=y_1$ និង $f(x_2)=a^{x_2}=y_2$

គេបាន $f(x_1+x_2)=a^{x_1+x_2}=a^{x_1}\cdot a^{x_2}=y_1y_2$ នេះបញ្ជាក់ថា ចំណុច $(x_1+x_2\ ,\ y_1y_2)$ នៅលើខ្សែកោងតាង $f(x)=a^x$

$f(x_1-x_2)=a^{x_1-x_2}=\dfrac{a^{x_1}}{a^{x_2}}=\dfrac{y_1}{y_2}$ នេះបញ្ជាក់ថា ចំណុច $\left(x_1-x_2\ ,\ \dfrac{y_1}{y_2}\right)$ នៅលើខ្សែកោងតាង $f(x)=a^x$

ដូចនេះ

| ពីរចំណុច $(x_1+x_2\ ,\ y_1y_2)$ និង $\left(x_1-x_2\ ,\ \dfrac{y_1}{y_2}\right)$ នៅលើខ្សែកោងតាង $f(x)=a^x$ |
|---|

។

8. បង្ហាញថា ចំណុចទាំងពីរ $\left(2x_1\ ,\ y_1^2\right)$ និង $\left(-x_1\ ,\ \dfrac{1}{y_1}\right)$ ក៏នៅលើខ្សែកោង $f(x)=a^x$ ដែរ

គេមាន $(x_1, y_1)$ ជាចំណុចនៅលើខ្សែកោង $f(x)=a^x$

នាំឱ្យ $f(x_1)=a^{x_1}=y_1$ និង $f(x_2)=a^{x_2}=y_2$

គេបាន $f(2x_1)=a^{2x_1}=\left(a^{x_1}\right)^2=y_1^2$ នេះបញ្ជាក់ថា ចំណុច $\left(2x_1\ ,\ y_1^2\right)$ នៅលើខ្សែកោងតាង $f(x)=a^x$

$f(-x_1)=a^{-x_1}=\dfrac{1}{a^{x_1}}=\dfrac{1}{y_1}$ នេះបញ្ជាក់ថា ចំណុច $\left(-x_1\ ,\ \dfrac{1}{y_1}\right)$ នៅលើខ្សែកោងតាង $f(x)=a^x$

ដូចនេះ ពីរចំណុច $\left(2x_1\ ,\ y_1^2\right)$ និង $\left(-x_1\ ,\ \dfrac{1}{y_1}\right)$ នៅលើខ្សែកោងតាង $f(x)=a^x$ ។

# ការស្រាយបញ្ជាក់លើមេរៀន លោការីត

1. បង្ហាញថា ក្រាបនៃអនុគមន៍ $y = f(x)$ ជាក្រាបឆ្លុះគ្នានឹងក្រាបអនុគមន៍ច្រាសរបស់វា $y = f^{-1}(x)$ ធៀបនឹងបន្ទាត់ $y = x$ ។
2. ស្រាយបញ្ជាក់លក្ខណៈលោការីតខាងក្រោម ៖

   ក. $\log_a(x \times y) = \log_a x + \log_a y$ ខ. $\log_a\left(\frac{x}{y}\right) = \log_a x - \log_a y$ គ. $\log_a x^n = n\log_a x$

   ឃ. $\log_a x = \frac{1}{\log_x a}$ ង. $\log_a x = \frac{\log_b x}{\log_b a}$ ច. $\log_a 1 = 0$

   ឆ. $\log_a a^x = x$ ជ. $a^{\log_a x} = x$ , $x > 0$ ឈ. $\log_a a = 1$
3. ស្រាយបញ្ជាក់ថាក្រាបនៃអនុគមន៍ $y = \log_a x$ កាត់តាមចំណុចដែលមានកូអរដោនេ $(1, 0)$ ជានិច្ច ។
4. បង្ហាញថា គេបាន $\log_{xy} M = \frac{ab}{a+b}$ បើ $\log_x M = a$ និង $\log_y M = b$ ។
5. គេឱ្យ $f(x) = \lg\frac{1+x}{1-x}$ ។ បង្ហាញថា $f(x) + f(y) = f\left(\frac{x+y}{1+xy}\right)$ ។
6. បង្ហាញថា បើ $f(x) = \log_a x$ នោះ $f(xy) = f(x) + f(y)$ ។
7. បង្ហាញថា បើ $(x_1, y_1)$ និង $(x_2, y_2)$ ជាពីរចំណុចនៅលើខ្សែកោង $y = \log_a x$ នោះចំណុច $\left(\frac{x_1}{x_2}, y_1 - y_2\right)$ ក៏ស្ថិតនៅលើខ្សែកោង $y = \log_a x$ ដែរ។
8. បង្ហាញថា បើ $(x_1, y_1)$ ជាចំណុចនៅលើខ្សែកោង $y = \log_a x$ នោះចំណុច $(x_1^2, 2y_1)$ និងចំណុច $\left(\frac{1}{x_1}, -y_1\right)$ ក៏ជាចំណុចស្ថិតនៅលើខ្សែកោង $y = \log_a x$ ដែរ ។
9. ក. ស្រាយបញ្ជាក់ថា $\log_{a^n} x = \frac{1}{n}\log_a x$ ដែល $0 < a \neq 1$ , $x > 0$ , $n > 0$

   ខ. បើ $0 < a \neq 1$ , $0 < x \neq 1$ ស្រាយបញ្ជាក់ថា $\frac{1}{\log_a x} + \frac{1}{\log_{a^2} x} + \frac{1}{\log_{a^3} x} + \ldots + \frac{1}{\log_{a^n} x} = \frac{n(n+1)}{2\log_a x}$ ។

# ការស្រាយបញ្ជាក់លើមេរៀន លោការីត

1. **បង្ហាញថា ក្រាបនៃអនុគមន៍ $y=f(x)$ ជាក្រាបឆ្លុះគ្នានឹងក្រាបអនុគមន៍ច្រាសរបស់វា $y=f^{-1}(x)$ ធៀបនឹងបន្ទាត់ $y=x$**

គេមាន លក្ខណៈឆ្លុះធៀបនឹងបន្ទាត់ពុះទី១ $y=x$ ៖

បើពីរចំណុច $P(x\,,\,y)$ និង $P'(x'\,,\,y')$ ជាចំណុចឆ្លុះគ្នាធៀបនឹងបន្ទាត់ $y=x$ លុះត្រាតែ $x=y'$ និង $y=x'$ ។

តាមនិយមន័យអនុគមន៍ច្រាស : បើ $f^{-1}$ ជាអនុគមន៍ច្រាសនៃអនុគមន៍ $f$ នោះគេបាន $f(a)=b \Leftrightarrow f^{-1}(b)=a$

គេតាង $P(a\,,\,b)$ ជាចំណុចនៅលើក្រាបនៃអនុគមន៍ $f$

បើ $f^{-1}$ ជាអនុគមន៍ច្រាសនៃ $f$ នោះគេបាន $f^{-1}(b)=a$ នេះបញ្ជាក់ថា ចំណុច $P'(b\,,\,a)$ នៅលើក្រាបនៃ $f^{-1}$

គេសង្កេត ឃើញថា $P(a\,,\,b)$ ជាចំណុចនៃ $f$ និង $P'(b\,,\,a)$ ជាចំណុចនៃ $f^{-1}$

តាមនិយមន័យអនុគមន៍ច្រាស គេបាន $P'(b\,,\,a)$ ជាចំណុចឆ្លុះនៃ $P(a\,,\,b)$ ធៀបនឹងបន្ទាត់ពុះទី១ $y=x$

ដោយ ក្រាបនៃអនុគមន៍ $f$ និង $f^{-1}$ មានគូៗចំណុច $P(a\,,\,b)$ និង $P'(b\,,\,a)$ ឆ្លុះគ្នា

នាំឱ្យ ក្រាបនៃអនុគមន៍ $f$ និង $f^{-1}$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ពុះទី១ $y=x$

ដូចនេះ: ក្រាបនៃអនុគមន៍ $f$ និង $f^{-1}$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ពុះទី១ $y=x$ ។

2. **ស្រាយបញ្ជាក់លក្ខណៈលោការីតខាងក្រោម ៖**

**ក. ស្រាយបញ្ជាក់លក្ខណៈ:** $\log_a(x\times y)=\log_a x+\log_a y$

គេតាង $m=\log_a x$ នោះ $x=a^m$

$n=\log_a y$ នោះ $y=a^n$

គេបាន $x\times y=a^m\times a^n$ ឬ $x\times y=a^{m+n}$ នាំឱ្យ $\log_a(x\times y)=m+n$ ឬ $\log_a(x\times y)=\log_a x+\log_a y$

ដូចនេះ: លក្ខណៈលោការីត $\log_a(x\times y)=\log_a x+\log_a y$ ត្រូវបានស្រាយបញ្ជាក់ ។

**ខ. ស្រាយបញ្ជាក់លក្ខណៈ:** $\log_a\left(\frac{x}{y}\right)=\log_a x-\log_a y$

គេតាង $m=\log_a x$ នោះ $x=a^m$

$n=\log_a y$ នោះ $y=a^n$

គេបាន $\frac{x}{y}=\frac{a^m}{a^n}$ ឬ $\frac{x}{y}=a^{m-n}$ នាំឱ្យ $\log_a\left(\frac{x}{y}\right)=m-n$ ឬ $\log_a\left(\frac{x}{y}\right)=\log_a x-\log_a y$

ដូចនេះ: លក្ខណៈលោការីត $\log_a\left(\frac{x}{y}\right)=\log_a x-\log_a y$ ត្រូវបានស្រាយបញ្ជាក់ ។

**គ. ស្រាយបញ្ជាក់លក្ខណៈ:** $\log_a x^n=n\log_a x$

ពិនិត្យ $\log_a x^n=\log_a\underbrace{(x\times x\times x\times\ldots\times x)}_{n\text{ កត្តា}}=\underbrace{\log_a x+\log_a x+\log_a x+\ldots+\log_a x}_{n\text{ តួ}}=n\log_a x$

ដូចនេះ: លក្ខណៈលោការីត $\log_a x^n=n\log_a x$ ត្រូវបានស្រាយបញ្ជាក់ ។

**ឃ. ស្រាយបញ្ជាក់លក្ខណៈ** $\log_a x = \dfrac{1}{\log_x a}$

គេតាង $m = \log_a x$ នោះ $x = a^m$

$n = \log_x a$ នោះ $a = x^n$

គេបាន $x = a^m$ ឬ $x = \left(x^n\right)^m$ ឬ $x = x^{mn}$ ទាញបាន $mn = 1$

ចំពោះ $mn = 1$ ឬ $(\log_a x)(\log_x a) = 1$ ទាញបាន $\log_a x = \dfrac{1}{\log_x a}$

ដូចនេះ | លក្ខណៈលោការីត $\log_a x = \dfrac{1}{\log_x a}$ ត្រូវបានស្រាយបញ្ជាក់ | ។

**ង. ស្រាយបញ្ជាក់លក្ខណៈ** $\log_a x = \dfrac{\log_b x}{\log_b a}$

គេតាង $y = \log_a x$ នាំឱ្យ $x = a^y$

គេបាន $\log_b x = \log_b a^y$ ឬ $\log_b x = y\log_b a$

ទាញបាន $\dfrac{\log_b x}{\log_b a} = y$ ឬ $\dfrac{\log_b x}{\log_b a} = \log_a x$

ដូចនេះ | លក្ខណៈលោការីត $\log_a x = \dfrac{\log_b x}{\log_b a}$ ត្រូវបានស្រាយបញ្ជាក់ | ។

**ច. ស្រាយបញ្ជាក់លក្ខណៈ** $\log_a 1 = 0$

តាមអនុគមន៍ច្រាស $a^x = k \Leftrightarrow x = \log_a k$

ដោយ $a^0 = 1 \Leftrightarrow 0 = \log_a 1$

ដូចនេះ | លក្ខណៈលោការីត $\log_a 1 = 0$ ត្រូវបានស្រាយបញ្ជាក់ | ។

**ឆ. ស្រាយបញ្ជាក់លក្ខណៈ** $\log_a a^x = x$

គេមាន $\log_a a^x = x\log_a a$ ឬ $\log_a a^x = x$

ដូចនេះ | លក្ខណៈលោការីត $\log_a a^x = x$ ត្រូវបានស្រាយបញ្ជាក់ | ។

**ជ. ស្រាយបញ្ជាក់លក្ខណៈ** $a^{\log_a x} = x\ ,\ x > 0$

តាមអនុគមន៍ច្រាស $a^x = k \Leftrightarrow x = \log_a k$

គេបាន $a^{\log_a x} = x \Leftrightarrow \log_a x = \log_a x$

ដោយ $\log_a x = \log_a x$ ពិត នាំឱ្យ $a^{\log_a x} = x$ ក៏ពិតដែរ

ដូចនេះ | លក្ខណៈលោការីត $\log_a a^x = x$ ត្រូវបានស្រាយបញ្ជាក់ | ។

**ឈ. ស្រាយបញ្ជាក់លក្ខណៈ** $\log_a a = 1$

ដោយ $a^1 = a$ សមមូល $\log_a a = 1$

ដូចនេះ | លក្ខណៈលោការីត $\log_a a = 1$ ត្រូវបានស្រាយបញ្ជាក់ | ។

3. ស្រាយបញ្ជាក់ថាក្រាបនៃអនុគមន៍ $y=\log_a x$ កាត់តាមចំណុចដែលមានកូអរដោនេ $(1,0)$ ជានិច្ច

គេមាន $y=\log_a x$

ចំពោះ $x=1$ គេបាន $y=\log_a 1=0$

ចំពោះ $y=0 \Rightarrow \log_a x=0$ នោះ $x=a^0=1$

តាមករណីទាំងពីរខាងលើបញ្ជាក់ថា ក្រាបនៃអនុគមន៍ $y=\log_a x$ កាត់តាមចំណុច $(1,0)$ ជានិច្ច

ដូចនេះ: ក្រាបនៃអនុគមន៍ $y=\log_a x$ កាត់តាមចំណុច $(1,0)$ ជានិច្ច ត្រូវបានស្រាយបញ្ជាក់ ។

4. បង្ហាញថា $\log_{xy} M=\dfrac{ab}{a+b}$

គេមាន $\log_x M=a$ និង $\log_y M=b$

ដោយ
$$\log_{xy} M=\frac{1}{\log_M xy}=\frac{1}{\log_M x+\log_M y}=\frac{1}{\dfrac{1}{\log_x M}+\dfrac{1}{\log_y M}}=\frac{1}{\dfrac{1}{a}+\dfrac{1}{b}}=\frac{1}{\dfrac{b+a}{ab}}=\frac{ab}{a+b}$$

ដូចនេះ: $\log_{xy} M=\dfrac{ab}{a+b}$ ត្រូវបានបង្ហាញ ។

5. បង្ហាញថា $f(x)+f(y)=f\left(\dfrac{x+y}{1+xy}\right)$

គេមាន $f(x)=\lg\dfrac{1+x}{1-x}$ នោះ $f(y)=\lg\dfrac{1+y}{1-y}$ ,

គេបាន
$$f\left(\frac{x+y}{1+xy}\right)=\lg\frac{1+\dfrac{x+y}{1+xy}}{1-\dfrac{x+y}{1+xy}}=\lg\frac{\dfrac{1+xy+x+y}{1+xy}}{\dfrac{1+xy-x-y}{1+xy}}=\lg\frac{1+xy+x+y}{1+xy-x-y}=\lg\frac{(1+x)+y(1+x)}{(1-x)-y(1-x)}$$
$$=\lg\frac{(1+x)(1+y)}{(1-x)(1-y)}=\lg\left(\frac{1+x}{1-x}\times\frac{1+y}{1-y}\right)=\lg\frac{1+x}{1-x}+\lg\frac{1+y}{1-y}=f(x)+f(y)$$

ដូចនេះ: $f(x)+f(y)=f\left(\dfrac{x+y}{1+xy}\right)$ ត្រូវបានបង្ហាញ ។

6. បង្ហាញថា $f(xy)=f(x)+f(y)$

គេមាន $f(x)=\log_a x$ នោះ $f(y)=\log_a y$

គេបាន
$$f(xy)=\log_a xy$$
$$=\log_a x+\log_a y$$
$$=f(x)+f(y)$$

ដូចនេះ: $f(xy)=f(x)+f(y)$ ត្រូវបានបង្ហាញ ។

7. បង្ហាញថា ចំណុច $\left(\frac{x_1}{x_2}, y_1 - y_2\right)$ ស្ថិតនៅលើខ្សែកោង $y = \log_a x$

គេមាន $(x_1, y_1)$ និង $(x_2, y_2)$ ជាពីរចំណុចនៅលើខ្សែកោង $y = \log_a x$

នាំឱ្យ $y_1 = \log_a x_1$ និង $y_2 = \log_a x_2$

គេបាន $\log_a \frac{x_1}{x_2} = \log_a x_1 - \log_a x_2 = y_1 - y_2$ នេះបញ្ជាក់ថា ចំណុច $\left(\frac{x_1}{x_2}, y_1 - y_2\right)$ ស្ថិតនៅលើខ្សែកោង $y = \log_a x$

ដូចនេះ: ចំណុច $\left(\frac{x_1}{x_2}, y_1 - y_2\right)$ ស្ថិតនៅលើខ្សែកោង $y = \log_a x$ ត្រូវបានបង្ហាញ ។

8. បង្ហាញថា ចំណុច $(x_1^2, 2y_1)$ និង $\left(\frac{1}{x_1}, -y_1\right)$ ជាចំណុចស្ថិតនៅលើខ្សែកោង $y = \log_a x$

គេមាន $(x_1, y_1)$ ជាចំណុចនៅលើខ្សែកោង $y = \log_a x$

នាំឱ្យ $y_1 = \log_a x_1$

ដោយ $\log_a x_1^2 = 2\log_a x_1 = 2y_1$ នេះបញ្ជាក់ថា ចំណុច $(x_1^2, 2y_1)$ ស្ថិតនៅលើខ្សែកោង $y = \log_a x$

ហើយ $\log_a \frac{1}{x_1} = \log_a 1 - \log_a x_1 = -y_1$ នេះបញ្ជាក់ថា ចំណុច $\left(\frac{1}{x_1}, -y_1\right)$ ស្ថិតនៅលើខ្សែកោង $y = \log_a x$

ដូចនេះ: ចំណុច $(x_1^2, 2y_1)$ និង $\left(\frac{1}{x_1}, -y_1\right)$ ស្ថិតនៅលើខ្សែកោង $y = \log_a x$ ត្រូវបានបង្ហាញ ។

9. ក. ស្រាយបញ្ជាក់ថា $\log_{a^n} x = \frac{1}{n}\log_a x$ ដែល $0 < a \neq 1 , x > 0 , n > 0$

គេមាន $\log_{a^n} x = \frac{1}{\log_x a^n} = \frac{1}{n\log_x a} = \frac{1}{n} \times \frac{1}{\log_x a} = \frac{1}{n}\log_a x$

ដូចនេះ: $\log_{a^n} x = \frac{1}{n}\log_a x$ ត្រូវបានបង្ហាញ ។

ខ. ស្រាយបញ្ជាក់ថា $\frac{1}{\log_a x} + \frac{1}{\log_{a^2} x} + \frac{1}{\log_{a^3} x} + \ldots + \frac{1}{\log_{a^n} x} = \frac{n(n+1)}{2\log_a x}$ ដែល $0 < a \neq 1 , 0 < x \neq 1$

គេមាន

$$\frac{1}{\log_a x} + \frac{1}{\log_{a^2} x} + \frac{1}{\log_{a^3} x} + \ldots + \frac{1}{\log_{a^n} x}$$

$$= \frac{1}{\log_a x} + \frac{1}{\frac{1}{2}\log_a x} + \frac{1}{\frac{1}{3}\log_a x} + \ldots + \frac{1}{\frac{1}{n}\log_{a^n} x}$$

$$= \frac{1}{\log_a x} + \frac{2}{\log_a x} + \frac{3}{\log_a x} + \ldots + \frac{n}{\log_{a^n} x}$$

$$= \frac{1}{\log_a x} \times (1 + 2 + 3 + \ldots + n) = \frac{n(n+1)}{2} \times \frac{1}{\log_a x} = \frac{n(n+1)}{2\log_a x}$$

ដូចនេះ: $\frac{1}{\log_a x} + \frac{1}{\log_{a^2} x} + \frac{1}{\log_{a^3} x} + \ldots + \frac{1}{\log_{a^n} x} = \frac{n(n+1)}{2\log_a x}$ ត្រូវបានបង្ហាញ ។

# ការស្រាយបញ្ជាក់លើមេរៀន ត្រីកោណមាត្រ

1. ស្រាយបញ្ជាក់ រូបមន្តមុំ $\theta$ និង $\theta+2k\pi$ នៃអនុគមន៍ត្រីកោណមាត្រដែលមាន $k\in\mathbb{Z}$ ដូចខាងក្រោម ៖

$\sin(\theta+2k\pi)=\sin\theta$ $\quad\cos(\theta+2k\pi)=\cos\theta$

$\tan(\theta+k\pi)=\tan\theta$ $\quad\cot(\theta+k\pi)=\cot\theta$

2. ស្រាយបញ្ជាក់ រូបមន្តមុំផ្ទុយ $\theta$ និង $-\theta$ ដូចខាងក្រោម ៖

$\sin(-\theta)=-\sin\theta$ $\quad\cos(-\theta)=\cos\theta$

$\tan(-\theta)=-\tan\theta$ $\quad\cot(-\theta)=-\cot\theta$

3. ស្រាយបញ្ជាក់ រូបមន្តមុំបំពេញ $\left(\frac{\pi}{2}-\theta\right)$ និង $\theta$ ដូចខាងក្រោម ៖

$\sin\left(\frac{\pi}{2}-\theta\right)=\cos\theta$ $\quad\cos\left(\frac{\pi}{2}-\theta\right)=\sin\theta$

$\tan\left(\frac{\pi}{2}-\theta\right)=\cot\theta$ $\quad\cot\left(\frac{\pi}{2}-\theta\right)=\tan\theta$

4. ស្រាយបញ្ជាក់ រូបមន្តមុំដែលមានផលសងស្មើ $\frac{\pi}{2}$ ដូចខាងក្រោម ៖

$\sin\left(\frac{\pi}{2}+\theta\right)=\cos(-\theta)=\cos\theta$ $\quad\cos\left(\frac{\pi}{2}+\theta\right)=\sin(-\theta)=-\sin\theta$

$\tan\left(\frac{\pi}{2}+\theta\right)=\cot(-\theta)=-\cot\theta$ $\quad\cot\left(\frac{\pi}{2}+\theta\right)=\tan(-\theta)=-\tan\theta$

5. ស្រាយបញ្ជាក់រូបមន្តមុំបន្ថែម $(\pi-\theta)$ និង $\theta$ ដូចខាងក្រោម ៖

$\sin(\pi-\theta)=\sin\theta$ $\quad\cos(\pi-\theta)=-\cos\theta$

$\tan(\pi-\theta)=-\tan\theta$ $\quad\cot(\pi-\theta)=-\cot\theta$

6. ស្រាយបញ្ជាក់រូបមន្តមុំដែលមានផលសងស្មើ $\pi$ ដូចខាងក្រោម ៖

$\sin(\pi+\theta)=-\sin\theta$ $\quad\cos(\pi+\theta)=-\cos\theta$

$\tan(\pi+\theta)=\tan\theta$ $\quad\cot(\pi+\theta)=\cot\theta$

7. ស្រាយបញ្ជាក់ខួបនៃអនុគមន៍ត្រីកោណមាត្រ ដូចខាងក្រោម ៖

ក. អនុគមន៍ $\sin x$ និងអនុគមន៍ $\cos x$ មានខួប $p=2\pi$

ខ. អនុគមន៍ $\sin ax$ និងអនុគមន៍ $\cos ax$ មានខួប $T=\frac{2\pi}{|a|}$

គ. អនុគមន៍ $\tan x$ និងអនុគមន៍ $\cot x$ មានខួប $p=\pi$

ឃ.អនុគមន៍ $\tan ax$ និងអនុគមន៍ $\cot ax$ មានខួប $T=\frac{\pi}{|a|}$

8. ស្រាយបញ្ជាក់ភាពគូ-សេស នៃអនុគមន៍ត្រីកោណមាត្រដូចខាងក្រោម ៖

ក. អនុគមន៍ $f(x)=\cos x$ ជាអនុគមន៍គូ ។

ខ. អនុគមន៍ $f(x)=\sin x$ , $f(x)=\tan x$ និង $f(x)=\cot x$ ជាអនុគមន៍សេស ។



www.facebook.com/7khmer
fb : Entertainment And Knowledge

9. ក. ស្រាយបញ្ជាក់ថា $\cos(\alpha-\beta)=\cos\alpha\cos\beta+\sin\alpha\sin\beta$ តាមពីររបៀបខុសគ្នា ។

ខ. បង្ហាញថា $\cos(\alpha+\beta)=\cos\alpha\cos\beta-\sin\alpha\sin\beta$

$$\sin(\alpha+\beta)=\sin\alpha\cos\beta+\sin\beta\cos\alpha$$

$$\sin(\alpha-\beta)=\sin\alpha\cos\beta-\sin\beta\cos\alpha$$

$$\tan(\alpha+\beta)=\frac{\tan\alpha+\tan\beta}{1-\tan\alpha\tan\beta}$$

$$\tan(\alpha-\beta)=\frac{\tan\alpha-\tan\beta}{1+\tan\alpha\tan\beta}$$

$$\cot(\alpha+\beta)=\frac{\cot\alpha\cot\beta-1}{\cot\beta+\cot\alpha}$$

$$\cot(\alpha-\beta)=\frac{\cot\alpha\cot\beta+1}{\cot\beta-\cot\alpha}$$

10. ស្រាយបញ្ជាក់រូបមន្ត ដូចខាងក្រោម ៖

$$\sin 2\alpha=2\sin\alpha\cos\alpha$$

$$\cos 2\alpha=\cos^2\alpha-\sin^2\alpha=1-2\sin^2\alpha=2\cos^2\alpha-1$$

$$\tan 2\alpha=\frac{2\tan\alpha}{1-\tan^2\alpha}$$

$$\sin\alpha=2\sin\frac{\alpha}{2}\cos\frac{\alpha}{2}$$

$$\cos^2\frac{\alpha}{2}=\frac{1+\cos\alpha}{2}$$

$$\sin^2\frac{\alpha}{2}=\frac{1-\cos\alpha}{2}$$

$$\tan^2\frac{\alpha}{2}=\frac{1-\cos\alpha}{1+\cos\alpha}$$

11. ស្រាយបញ្ជាក់រូបមន្ត ដូចខាងក្រោម បើគេតាង $\tan\frac{\alpha}{2}=t$ ៖

$$\cos\alpha=\frac{1-t^2}{1+t^2}$$

$$\sin\alpha=\frac{2t}{1+t^2}$$

$$\tan\alpha=\frac{2t}{1-t^2}$$

12. ស្រាយបញ្ជាក់ទំនាក់ទំនងខាងក្រោម ៖

$$\cos 3\alpha=\cos^3\alpha-3\cos\alpha\sin^2\alpha=4\cos^3\alpha-3\cos\alpha$$

$$\sin 3\alpha=3\cos^2\alpha\sin\alpha-\sin^3\alpha=-4\sin^3\alpha+3\sin\alpha$$

$$\cos 4\alpha=\cos^4\alpha+\sin^4\alpha-6\cos^2\alpha\sin^2\alpha$$

$$\sin 4\alpha=4\cos^3\alpha\sin\alpha-4\cos\alpha\sin^3\alpha$$



www.facebook.com/7khmer
fb : Entertainment And Knowledge

13. ស្រាយបញ្ជាក់រូបមន្ត បំលែងពីផលគុណទៅផលបូក ខាងក្រោម ៖

$$\cos\alpha\cos\beta=\frac{1}{2}\left[\cos(\alpha+\beta)+\cos(\alpha-\beta)\right]$$

$$\sin\alpha\sin\beta=\frac{1}{2}\left[\cos(\alpha-\beta)-\cos(\alpha+\beta)\right]$$

$$\sin\alpha\cos\beta=\frac{1}{2}\left[\sin(\alpha+\beta)+\sin(\alpha-\beta)\right]$$

$$\sin\beta\cos\alpha=\frac{1}{2}\left[\sin(\alpha+\beta)-\sin(\alpha-\beta)\right]$$

14. ស្រាយបញ្ជាក់រូបមន្ត បំលែងពីផលបូក ទៅផលគុណ ខាងក្រោម ៖

$$\cos p+\cos q=2\cos\frac{p+q}{2}\cos\frac{p-q}{2}$$

$$\cos p-\cos q=-2\sin\frac{p+q}{2}\sin\frac{p-q}{2}$$

$$\sin p+\sin q=2\sin\frac{p+q}{2}\cos\frac{p-q}{2}$$

$$\sin p-\sin q=2\sin\frac{p-q}{2}\cos\frac{p+q}{2}$$

$$\tan p+\tan q=\frac{\sin(p+q)}{\cos p\cos q}$$

$$\tan p-\tan q=\frac{\sin(p-q)}{\cos p\cos q}$$

$$\cot p+\cot q=\frac{\sin(p+q)}{\sin p\sin q}$$

$$\cot p-\cot q=-\frac{\sin(p-q)}{\sin p\sin q}$$



www.facebook.com/7khmer
fb : Entertainment And Knowledge

# ការស្រាយបញ្ជាក់លើមេរៀន ត្រីកោណមាត្រ

1. **ស្រាយបញ្ជាក់ រូបមន្តមុំ $\theta$ និង $\theta+2k\pi$ នៃអនុគមន៍ត្រីកោណមាត្រដែលមាន $k\in\mathbb{Z}$ ដូចខាងក្រោម ៖**




**ស្រាយបញ្ជាក់ថា** $\sin(\theta+2k\pi)=\sin\theta$ **និង** $\cos(\theta+2k\pi)=\cos\theta$

**➤របៀបទី១** តាមវ៉ិចទ័រ

ដោយ មុំ $\theta$ និងមុំ $\theta+2k\pi$ ជាមុំដែលមានវ៉ិចទ័រគល់ និងវ៉ិចទ័រចុងដូចគ្នា

នាំឱ្យ $\sin(\theta+2k\pi)=\sin\theta$ និង $\cos(\theta+2k\pi)=\cos\theta$

ដូចនេះ $\boxed{\sin(\theta+2k\pi)=\sin\theta \text{ និង } \cos(\theta+2k\pi)=\cos\theta}$

**➤របៀបទី២** តាមនិមយន័យខួបនៃអនុគមន៍

និមយន័យ $f$ ជាអនុគមន៍មានដែនកំណត់ $D$ ។ $f$ ជាអនុគមន៍មានខួប $p$ លុះត្រាតែ $p$ ជាចំនួនវិជ្ជមានតូចបំផុតដែល

$\forall x\in D,\ f(x+p)=f(x)$ ។

ពីនិយមន័យទាញបាន $f(x)=f(x+p)=f((x+p)+p)=f(((x+p)+p)+p)=\ldots$

ឬ $f(x)=f(x-p)=f((x-p)-p)=f(((x-p)-p)-p)=\ldots$

ដោយ $2\pi$ ជាចំនួនវិជ្ជមានតូចបំផុតដែល $\sin(\theta+2\pi)=\sin\theta$ និង $\cos(\theta+2\pi)=\cos\theta$

ម្យ៉ាងទៀត $\sin\theta=\sin(\theta+2\pi)=\sin((\theta+2\pi)+2\pi)=\sin(((\theta+2\pi)+2\pi)+2\pi)=\ldots$

$\cos\theta=\cos(\theta+2\pi)=\cos((\theta+2\pi)+2\pi)=\cos(((\theta+2\pi)+2\pi)+2\pi)=\ldots$

ឬ $\sin\theta=\sin(\theta-2\pi)=\sin((\theta-2\pi)-2\pi)=\sin(((\theta-2\pi)-2\pi)-2\pi)=\ldots$

$\cos\theta=\cos(\theta-2\pi)=\cos((\theta-2\pi)-2\pi)=\cos(((\theta-2\pi)-2\pi)-2\pi)=\ldots$

នាំឱ្យ $\sin(\theta+2k\pi)=\sin\theta$ និង $\cos(\theta+2k\pi)=\cos\theta$ ដែល $k\in\mathbb{Z}$

ដូចនេះ $\boxed{\sin(\theta+2k\pi)=\sin\theta \text{ និង } \cos(\theta+2k\pi)=\cos\theta}$ ។

**ស្រាយបញ្ជាក់ថា** $\tan(\theta+k\pi)=\tan\theta$ **និង** $\cot(\theta+k\pi)=\cot\theta$

តាមនិយមន័យខួបនៃអនុគមន៍ (មានបង្ហាញរួចខាងលើ)

បើ $f$ មានខួប $p>0$ គេបាន $f(x)=f(x+p)=f((x+p)+p)=f(((x+p)+p)+p)=\ldots$

ឬ $f(x)=f(x-p)=f((x-p)-p)=f(((x-p)-p)-p)=\ldots$

ដោយ $\pi$ ជាចំនួនវិជ្ជមានតូចបំផុតដែល $\tan(\theta+\pi)=\tan\theta$ និង $\cot(\theta+\pi)=\cot\theta$

គេបាន $\tan\theta=\tan(\theta\pm\pi)=\tan((\theta\pm\pi)\pm\pi)=\tan(((\theta\pm\pi)\pm\pi)\pm\pi)=\ldots$

$\cot\theta=\cot(\theta\pm\pi)=\cot((\theta\pm\pi)\pm\pi)=\cot(((\theta\pm\pi)\pm\pi)\pm\pi)=\ldots$

នាំឱ្យ $\tan(\theta+k\pi)=\tan\theta$ និង $\cot(\theta+k\pi)=\cot\theta$

ដូចនេះ $\boxed{\tan(\theta+k\pi)=\tan\theta \text{ និង } \cot(\theta+k\pi)=\cot\theta}$ ។

2. **ស្រាយបញ្ជាក់ រូបមន្តមុំផ្ទុយ $\theta$ និង $-\theta$ ដូចខាងក្រោម ៖**




**ស្រាយបញ្ជាក់ថា** $\sin(-\theta)=-\sin\theta$ **និង** $\cos(-\theta)=\cos\theta$

មុំពីរផ្ទុយគ្នា កាលណាផលបូករង្វាស់វាស្មើសូន្យតាម $2\pi$

គេតាង $\left(\overrightarrow{OA},\overrightarrow{OP}\right)=\theta$ និង $\left(\overrightarrow{OA},\overrightarrow{OP'}\right)=\theta'$

ហើយ $\theta+\theta'=0$ តាម $2\pi$ នោះ $\theta=-\theta'$ តាម $2\pi$

គេបាន កូអរដោនេនៃចំណុច $P$ និង $P'$ គឺ

$P(\cos\theta\,,\sin\theta)$ និង $P'(\cos\theta'\,,\sin\theta')=P'\left(\cos(-\theta)\,,\sin(-\theta)\right)$

ដោយ $P$ និង $P'$ ឆ្លុះគ្នាធៀបនឹងអ័ក្សអាប់ស៊ីស (នោះចំណុចទាំងពីរមាន អាប់ស៊ីសដូចគ្នា និងអរដោនេផ្ទុយគ្នា)

គេបាន $\cos(-\theta)=\cos\theta$ និង $\sin(-\theta)=-\sin\theta$

ដូចនេះ | រូបមន្ត $\sin(-\theta)=-\sin\theta$ និង $\cos(-\theta)=\cos\theta$ ត្រូវបានស្រាយបញ្ជាក់ | ។

**ស្រាយបញ្ជាក់ថា** $\tan(-\theta)=-\tan\theta$ **និង** $\cot(-\theta)=-\cot\theta$

គេមាន $\sin(-\theta)=-\sin\theta$ និង $\cos(-\theta)=\cos\theta$ (ស្រាយរួចខាងលើ)

ដោយ $$\tan(-\theta)=\frac{\sin(-\theta)}{\cos(-\theta)}=\frac{-\sin\theta}{\cos\theta}=-\tan\theta$$

$$\cot(-\theta)=\frac{\cos(-\theta)}{\sin(-\theta)}=\frac{\cos\theta}{-\sin\theta}=-\cot\theta$$

ដូចនេះ | រូបមន្ត $\tan(-\theta)=-\tan\theta$ និង $\cot(-\theta)=-\cot\theta$ ត្រូវបានស្រាយបញ្ជាក់ | ។

3. **ស្រាយបញ្ជាក់ រូបមន្តមុំបំពេញ $\left(\frac{\pi}{2}-\theta\right)$ និង $\theta$ ដូចខាងក្រោម ៖**




**ស្រាយបញ្ជាក់ថា** $\sin\left(\frac{\pi}{2}-\theta\right)=\cos\theta$ **និង** $\cos\left(\frac{\pi}{2}-\theta\right)=\sin\theta$

ក្នុងរង្វង់ត្រីកោណមាត្រ គេតាង $\left(\overrightarrow{OA},\overrightarrow{OP}\right)=\theta$ និង $\left(\overrightarrow{OA},\overrightarrow{OP'}\right)=\left(\frac{\pi}{2}-\theta\right)$

គេបាន កូអរដោនេនៃចំណុច $P$ និង $P'$ គឺ

$P(\cos\theta\,,\sin\theta)$ និង $P'\left(\cos\left(\frac{\pi}{2}-\theta\right),\sin\left(\frac{\pi}{2}-\theta\right)\right)$

ដោយ ចំណុច $P$ និង $P'$ ឆ្លុះគ្នាធៀបនឹងបន្ទាត់ពុះទី១ $y=x$

(នោះ អាប់ស៊ីសនៃ $P$ ស្មើអរដោនេនៃ $P'$ និង អរដោនេនៃ $P$ ស្មើអាប់ស៊ីសនៃ $P'$)

គេបាន $\cos\theta=\sin\left(\frac{\pi}{2}-\theta\right)$ និង $\sin\theta=\cos\left(\frac{\pi}{2}-\theta\right)$

ដូចនេះ | រូបមន្ត $\sin\left(\frac{\pi}{2}-\theta\right)=\cos\theta$ និង $\cos\left(\frac{\pi}{2}-\theta\right)=\sin\theta$ ត្រូវបានស្រាយបញ្ជាក់ | ។

✓**សម្គាល់ ប្រសិនបើអ្នកស្ទាក់ស្ទើរ លក្ខណៈឆ្លុះធៀបនឹងអ័ក្ស ឬធៀបនឹងបន្ទាត់ $y=x$ សូមមើលមេរៀនបំលែងរូបក្នុងប្លង់ ។**

ស្រាយបញ្ជាក់ថា $\tan\left(\frac{\pi}{2}-\theta\right)=\cot\theta$ និង $\cot\left(\frac{\pi}{2}-\theta\right)=\tan\theta$

គេមាន $\sin\left(\frac{\pi}{2}-\theta\right)=\cos\theta$ និង $\cos\left(\frac{\pi}{2}-\theta\right)=\sin\theta$ (ស្រាយរួចខាងលើ)

គេបាន $\tan\left(\frac{\pi}{2}-\theta\right)=\frac{\sin\left(\frac{\pi}{2}-\theta\right)}{\cos\left(\frac{\pi}{2}-\theta\right)}=\frac{\cos\theta}{\sin\theta}=\cot\theta$

$\cot\left(\frac{\pi}{2}-\theta\right)=\frac{\cos\left(\frac{\pi}{2}-\theta\right)}{\sin\left(\frac{\pi}{2}-\theta\right)}=\frac{\sin\theta}{\cos\theta}=\tan\theta$

ដូចនេះ: រូបមន្ត $\tan\left(\frac{\pi}{2}-\theta\right)=\cot\theta$ និង $\cot\left(\frac{\pi}{2}-\theta\right)=\tan\theta$ ត្រូវបានស្រាយបញ្ជាក់ ។

4. ស្រាយបញ្ជាក់ រូបមន្តមុំដែលមានផលសងស្មើ $\frac{\pi}{2}$ ដូចខាងក្រោម ៖

ស្រាយបញ្ជាក់ថា $\sin\left(\frac{\pi}{2}+\theta\right)=\cos(-\theta)=\cos\theta$ និង $\cos\left(\frac{\pi}{2}+\theta\right)=\sin(-\theta)=-\sin\theta$

គេមាន រូបមន្ត $\sin\left(\frac{\pi}{2}-\theta\right)=\cos\theta$ និង $\cos\left(\frac{\pi}{2}-\theta\right)=\sin\theta$

រូបមន្ត $\cos(-\theta)=\cos\theta$ និង $\sin(-\theta)=-\sin\theta$

គេបាន $\sin\left(\frac{\pi}{2}+\theta\right)=\sin\left(\frac{\pi}{2}-(-\theta)\right)=\cos(-\theta)=\cos\theta$

$\cos\left(\frac{\pi}{2}+\theta\right)=\cos\left(\frac{\pi}{2}-(-\theta)\right)=\sin(-\theta)=-\sin\theta$

ដូចនេះ: រូបមន្ត $\sin\left(\frac{\pi}{2}+\theta\right)=\cos(-\theta)=\cos\theta$ និង $\cos\left(\frac{\pi}{2}+\theta\right)=\sin(-\theta)=-\sin\theta$ ត្រូវបានស្រាយ ។

ស្រាយបញ្ជាក់ថា $\tan\left(\frac{\pi}{2}+\theta\right)=\cot(-\theta)=-\cot\theta$ និង $\cot\left(\frac{\pi}{2}+\theta\right)=\tan(-\theta)=-\tan\theta$

គេមាន រូបមន្ត $\tan\left(\frac{\pi}{2}-\theta\right)=\cot\theta$ និង $\cot\left(\frac{\pi}{2}-\theta\right)=\tan\theta$

រូបមន្ត $\tan(-\theta)=-\tan\theta$ និង $\cot(-\theta)=-\cot\theta$

គេបាន $\tan\left(\frac{\pi}{2}+\theta\right)=\tan\left(\frac{\pi}{2}-(-\theta)\right)=\cot(-\theta)=-\cot\theta$

$\cot\left(\frac{\pi}{2}+\theta\right)=\cot\left(\frac{\pi}{2}-(-\theta)\right)=\tan(-\theta)=-\tan\theta$

ដូចនេះ: រូបមន្ត $\tan\left(\frac{\pi}{2}+\theta\right)=\cot(-\theta)=-\cot\theta$ និង $\cot\left(\frac{\pi}{2}+\theta\right)=\tan(-\theta)=-\tan\theta$ ត្រូវបានស្រាយ ។

5. **ស្រាយបញ្ជាក់រូបមន្តមុំបន្ថែម $(\pi-\theta)$ និង $\theta$ ដូចខាងក្រោម ៖**

**ស្រាយបញ្ជាក់ថា** $\sin(\pi-\theta)=\sin\theta$ **និង** $\cos(\pi-\theta)=-\cos\theta$




ក្នុងរង្វង់ត្រីកោណមាត្រ គេតាង $\left(\overrightarrow{OA},\overrightarrow{OP}\right)=\theta$ និង $\left(\overrightarrow{OA},\overrightarrow{OP'}\right)=(\pi-\theta)$

គេបាន កូអរដោនេនៃចំណុច $P$ និង $P'$ គឺ

$P(\cos\theta\,,\sin\theta)$ និង $P'\left(\cos(\pi-\theta)\,,\sin(\pi-\theta)\right)$

ដោយ ចំណុច $P$ និង $P'$ ឆ្លុះគ្នាធៀបនឹងអ័ក្សអរដោនេ

(នោះចំណុចទាំងពីរមាន អាប់ស៊ីសផ្ទុយគ្នា និងអរដោនេដូចគ្នា)

គេបាន $\cos(\pi-\theta)=-\cos\theta$ និង $\sin(\pi-\theta)=\sin\theta$

ដូចនេះ | រូបមន្ត $\sin(\pi-\theta)=\sin\theta$ និង $\cos(\pi-\theta)=-\cos\theta$ ត្រូវបានស្រាយ | ។

**ស្រាយបញ្ជាក់ថា** $\tan(\pi-\theta)=-\tan\theta$ **និង** $\cot(\pi-\theta)=-\cot\theta$

គេមាន រូបមន្ត $\sin(\pi-\theta)=\sin\theta$ និង $\cos(\pi-\theta)=-\cos\theta$ (បានស្រាយរួចខាងលើ)

គេបាន $\tan(\pi-\theta)=\dfrac{\sin(\pi-\theta)}{\cos(\pi-\theta)}=\dfrac{\sin\theta}{-\cos\theta}=-\tan\theta$

$\cot(\pi-\theta)=\dfrac{\cos(\pi-\theta)}{\sin(\pi-\theta)}=\dfrac{-\cos\theta}{\sin\theta}=-\cot\theta$

ដូចនេះ | រូបមន្ត $\tan(\pi-\theta)=-\tan\theta$ និង $\cot(\pi-\theta)=-\cot\theta$ ត្រូវបានស្រាយ | ។

6. **ស្រាយបញ្ជាក់រូបមន្តមុំដែលមានផលសងស្មើ $\pi$ ដូចខាងក្រោម ៖**

**ស្រាយបញ្ជាក់ថា** $\sin(\pi+\theta)=-\sin\theta$ **និង** $\cos(\pi+\theta)=-\cos\theta$

**➢របៀបទី១** តាមមុំ $(\pi-\theta)$

គេមាន រូបមន្ត $\sin(\pi-\theta)=\sin\theta$ និង $\cos(\pi-\theta)=-\cos\theta$ (បានស្រាយបញ្ជាក់រួចខាងលើ)

រូបមន្ត $\cos(-\theta)=\cos\theta$ និង $\sin(-\theta)=-\sin\theta$

គេបាន $\sin(\pi+\theta)=\sin\left(\pi-(-\theta)\right)=\sin(-\theta)=-\sin\theta$

$\cos(\pi+\theta)=\cos\left(\pi-(-\theta)\right)=-\cos(-\theta)=-\cos\theta$

ដូចនេះ | រូបមន្ត $\sin(\pi+\theta)=-\sin\theta$ និង $\cos(\pi+\theta)=-\cos\theta$ ត្រូវបានស្រាយ | ។

**➢របៀបទី២** តាមលក្ខណៈឆ្លុះធៀបនឹងគល់តម្រុយ




ក្នុងរង្វង់ត្រីកោណមាត្រ គេតាង $\left(\overrightarrow{OA},\overrightarrow{OP}\right)=\theta$ និង $\left(\overrightarrow{OA},\overrightarrow{OP'}\right)=(\pi+\theta)$

គេបាន កូអរដោនេនៃចំណុច $P$ និង $P'$ គឺ

$P(\cos\theta\,,\sin\theta)$ និង $P'\left(\cos(\pi+\theta)\,,\sin(\pi+\theta)\right)$

ដោយ ចំណុច $P$ និង $P'$ ឆ្លុះគ្នាធៀបនឹងគល់ $O$

គេបាន $\sin(\pi+\theta)=-\sin\theta$ និង $\cos(\pi+\theta)=-\cos\theta$

ដូចនេះ | រូបមន្ត $\sin(\pi+\theta)=-\sin\theta$ និង $\cos(\pi+\theta)=-\cos\theta$ ត្រូវបានស្រាយ | ។

**ស្រាយបញ្ជាក់ថា** $\tan(\pi+\theta)=\tan\theta$ **និង** $\cot(\pi+\theta)=\cot\theta$

គេមាន រូបមន្ត $\sin(\pi+\theta)=-\sin\theta$ និង $\cos(\pi+\theta)=-\cos\theta$ (បានស្រាយបញ្ជាក់រួចខាងលើ)

គេបាន $\tan(\pi+\theta)=\dfrac{\sin(\pi+\theta)}{\cos(\pi+\theta)}=\dfrac{-\sin\theta}{-\cos\theta}=\tan\theta$

$$\cot(\pi+\theta)=\frac{\cos(\pi+\theta)}{\sin(\pi+\theta)}=\frac{-\cos\theta}{-\sin\theta}=\cot\theta$$

ដូចនេះ: រូបមន្ត $\sin(\pi+\theta)=-\sin\theta$ និង $\cos(\pi+\theta)=-\cos\theta$ ត្រូវបានស្រាយបញ្ជាក់ ។

7. **ស្រាយបញ្ជាក់ខួបនៃអនុគមន៍ត្រីកោណមាត្រ ដូចខាងក្រោម ៖**

**ក. ស្រាយបញ្ជាក់ថា អនុគមន៍** $\sin x$ **និងអនុគមន៍** $\cos x$ **មានខួប** $p=2\pi$

និមយន័យ $f$ ជាអនុគមន៍មានដែនកំណត់ $D$ ។ $f$ ជាអនុគមន៍មានខួប $p$ លុះត្រាតែ $p$ ជាចំនួនវិជ្ជមានតូចបំផុតដែល $\forall x\in D,\ f(x+p)=f(x)$ ។

ដោយ $2\pi$ ជាចំនួនវិជ្ជមានតូចបំផុតដែល $\sin(\theta+2\pi)=\sin\theta$ និង $\cos(\theta+2\pi)=\cos\theta$

ដូចនេះ: អនុគមន៍ $\sin x$ និងអនុគមន៍ $\cos x$ មានខួប $p=2\pi$ ។

**ខ. ស្រាយបញ្ជាក់ថា អនុគមន៍** $\sin ax$ **មានខួប** $T=\dfrac{2\pi}{|a|}$

គេតាង $f(x)=\sin ax$

ដោយ $f\left(x+\dfrac{2\pi}{|a|}\right)=\sin a\left(x+\dfrac{2\pi}{|a|}\right)=\sin a\left(x\pm\dfrac{2\pi}{a}\right)=\sin(ax\pm2\pi)=\sin ax=f(x)$

នាំឱ្យ $T=\dfrac{2\pi}{|a|}$ ជាខួបនៃអនុគមន៍ $f(x)=\sin ax$

ដូចនេះ: អនុគមន៍ $f(x)=\sin ax$ មានខួប $T=\dfrac{2\pi}{|a|}$ ។

**ស្រាយបញ្ជាក់ថា អនុគមន៍** $\cos ax$ **មានខួប** $T=\dfrac{2\pi}{|a|}$

គេតាង $f(x)=\cos ax$

ដោយ $f\left(x+\dfrac{2\pi}{|a|}\right)=\cos a\left(x+\dfrac{2\pi}{|a|}\right)=\cos a\left(x\pm\dfrac{2\pi}{a}\right)=\cos(ax\pm2\pi)=\cos ax=f(x)$

នាំឱ្យ $T=\dfrac{2\pi}{|a|}$ ជាខួបនៃអនុគមន៍ $f(x)=\cos ax$

ដូចនេះ: អនុគមន៍ $f(x)=\cos ax$ មានខួប $T=\dfrac{2\pi}{|a|}$ ។

**គ. ស្រាយបញ្ជាក់ថា អនុគមន៍ $\tan x$ និងអនុគមន៍ $\cot x$ មានខួប $p=\pi$**

និមយន័យ $f$ ជាអនុគមន៍មានដែនកំណត់ $D$ ។ $f$ ជាអនុគមន៍មានខួប $p$ លុះត្រាតែ $p$ ជាចំនួនវិជ្ជមានតូចបំផុតដែល $\forall x\in D\,,\ f(x+p)=f(x)$ ។

ដោយ $\pi$ ជាចំនួនវិជ្ជមានតូចបំផុតដែល $\tan(\theta+\pi)=\tan\theta$ និង $\cot(\theta+\pi)=\cot\theta$

ដូចនេះ: | អនុគមន៍ $\tan x$ និងអនុគមន៍ $\cot x$ មានខួប $p=\pi$ | ។

**ឃ. ស្រាយបញ្ជាក់ថា អនុគមន៍ $\tan ax$ មានខួប $T=\dfrac{\pi}{|a|}$**

គេតាង $f(x)=\tan ax$

ដោយ $f\left(x+\dfrac{\pi}{|a|}\right)=\tan a\left(x+\dfrac{\pi}{|a|}\right)=\tan a\left(x\pm\dfrac{\pi}{a}\right)=\tan(ax\pm\pi)=\tan ax=f(x)$

នាំឱ្យ $T=\dfrac{\pi}{|a|}$ ជាខួបនៃអនុគមន៍ $f(x)=\tan ax$

ដូចនេះ: | អនុគមន៍ $f(x)=\tan ax$ មានខួប $T=\dfrac{\pi}{|a|}$ | ។

**ស្រាយបញ្ជាក់ថា អនុគមន៍ $\cot ax$ មានខួប $T=\dfrac{\pi}{|a|}$**

គេតាង $f(x)=\cot ax$

ដោយ $f\left(x+\dfrac{\pi}{|a|}\right)=\cot a\left(x+\dfrac{\pi}{|a|}\right)=\cot a\left(x\pm\dfrac{\pi}{a}\right)=\cot(ax\pm\pi)=\cot ax=f(x)$

នាំឱ្យ $T=\dfrac{\pi}{|a|}$ ជាខួបនៃអនុគមន៍ $f(x)=\cot ax$

ដូចនេះ: | អនុគមន៍ $f(x)=\cot ax$ មានខួប $T=\dfrac{\pi}{|a|}$ | ។

៩. **ស្រាយបញ្ជាក់ភាពគូ-សេស នៃអនុគមន៍ត្រីកោណមាត្រដូចខាងក្រោម ៖**

**ក. ស្រាយបញ្ជាក់ថា អនុគមន៍ $f(x)=\cos x$ ជាអនុគមន៍គូ**

និយមន័យ បើ $f$ ជាអនុគមន៍មានដែនកំណត់ $D$ ។

- $f$ ជាអនុគមន៍គូ លុះត្រាតែ $\forall x\in D\,,-x\in D\ ,\ f(-x)=f(x)$ ។
- $f$ ជាអនុគមន៍សេស លុះត្រាតែ $\forall x\in D\,,-x\in D\ ,\ f(-x)=-f(x)$ ។

គេមាន $f(x)=\cos x$

នាំឱ្យ $\forall x\in D\,,-x\in D\ ,\ f(-x)=\cos(-x)=\cos x=f(x)$

ដូចនេះ: | អនុគមន៍ $f(x)=\cos x$ ជាអនុគមន៍គូ | ។

**ខ. ស្រាយបញ្ជាក់ថា អនុគមន៍** $f(x)=\sin x$ , $f(x)=\tan x$ **និង** $f(x)=\cot x$ **ជាអនុគមន៍សេស**

និយមន័យ បើ $f$ ជាអនុគមន៍មានដែនកំណត់ $D$ ។

- $f$ ជាអនុគមន៍គូ លុះត្រាតែ $\forall x\in D, -x\in D$ , $f(-x)=f(x)$ ។
- $f$ ជាអនុគមន៍សេស លុះត្រាតែ $\forall x\in D, -x\in D$ , $f(-x)=-f(x)$ ។

គេមាន $f(x)=\sin x$ , $f(x)=\tan x$ និង $f(x)=\cot x$ ដែលមានដែនកំណត់តាងដោយ $D$

$\forall x\in D, -x\in D$ គេបាន ៖

ចំពោះ $f(x)=\sin x \Rightarrow f(-x)=\sin(-x)=-\sin x=-f(x)$ នោះ $f(x)=\sin x$ ជាអនុគមន៍សេស

ចំពោះ $f(x)=\tan x \Rightarrow f(-x)=\tan(-x)=-\tan x=-f(x)$ នោះ $f(x)=\tan x$ ជាអនុគមន៍សេស

ចំពោះ $f(x)=\cot x \Rightarrow f(-x)=\cot(-x)=-\cot x=-f(x)$ នោះ $f(x)=\cot x$ ជាអនុគមន៍សេស

ដូចនេះ អនុគមន៍ $f(x)=\sin x$ , $f(x)=\tan x$ និង $f(x)=\cot x$ ជាអនុគមន៍សេស ។

9. **ក. ស្រាយបញ្ជាក់ថា** $\cos(\alpha-\beta)=\cos\alpha\cos\beta+\sin\alpha\sin\beta$ **តាមពីររបៀបខុសគ្នា**




➤**របៀបទី១** តាមនិយមន័យផលគុណស្កាលែ

ពិនិត្យរង្វង់ត្រីកោណមាត្រ ខាងស្តាំ

គេមាន $(\overrightarrow{OA},\overrightarrow{OM})=\beta$ និង $(\overrightarrow{OA},\overrightarrow{ON})=\alpha$ នាំឱ្យ $(\overrightarrow{OM},\overrightarrow{ON})=\alpha-\beta$

តាមនិយមន័យផលគុណស្កាលែ $\overrightarrow{OM}\cdot\overrightarrow{ON}=OM\cdot ON\cdot\cos(\alpha-\beta)$

ដោយ $OM=ON=r=1$ (កាំរង្វង់ត្រីកោណមាត្រ)

នាំឱ្យ $\overrightarrow{OM}\cdot\overrightarrow{ON}=\cos(\alpha-\beta)$ (1)

ម្យ៉ាងទៀត កូអរដោនេនៃវ៉ិចទ័រ $\overrightarrow{OM}=(\cos\beta , \sin\beta)$ , $\overrightarrow{ON}=(\cos\alpha , \sin\alpha)$

តាមកន្សោមវិភាគផលគុណស្កាលែ $\overrightarrow{OM}\cdot\overrightarrow{ON}=\cos\alpha\cos\beta+\sin\alpha\sin\beta$ (2)

តាមរយៈ ទំនាក់ទំនង (1) និង (2) គេបាន $\cos(\alpha-\beta)=\cos\alpha\cos\beta+\sin\alpha\sin\beta$

ដូចនេះ រូបមន្ត $\cos(\alpha-\beta)=\cos\alpha\cos\beta+\sin\alpha\sin\beta$ ត្រូវបានស្រាយបញ្ជាក់ ។

➤**របៀបទី២** តាមទ្រឹស្តីបទកូស៊ីនុស និងរូបមន្តចម្ងាយរវាងពីរចំណុច




ពិនិត្យរង្វង់ត្រីកោណមាត្រ ខាងស្តាំ

គេមាន $(\overrightarrow{OA},\overrightarrow{OM})=\beta$ និង $(\overrightarrow{OA},\overrightarrow{ON})=\alpha$ នាំឱ្យ $(\overrightarrow{OM},\overrightarrow{ON})=\alpha-\beta$

នាំឱ្យ កូអរដោនេ $\overrightarrow{OM}=(\cos\beta , \sin\beta)$ , $\overrightarrow{ON}=(\cos\alpha , \sin\alpha)$

ក្នុងត្រីកោណ $OMN$ តាមទ្រឹស្តីបទកូស៊ីនុស

គេបាន $MN^2=OM^2+ON^2-2OM\cdot ON\cdot\cos(\alpha-\beta)$

$MN^2=1^2+1^2-2\cdot1\cdot1\cdot\cos(\alpha-\beta)$

$=2-2\cos(\alpha-\beta)$ (1)

ព្រោះ $OM=ON=r=1$ កាំរង្វង់ត្រីកោណមាត្រ

ម្យ៉ាងទៀត តាមរូបមន្តចម្ងាយរវាងពីរចំណុច $M(\cos\beta\ ,\ \sin\beta)$ និង $N=(\cos\alpha\ ,\ \sin\alpha)$

$$MN=\sqrt{(\cos\alpha-\cos\beta)^2+(\sin\alpha-\sin\beta)^2}$$

$$\begin{aligned} MN^2 &= (\cos\alpha-\cos\beta)^2+(\sin\alpha-\sin\beta)^2\\ &=\cos^2\alpha-2\cos\alpha\cos\beta+\cos^2\beta+\sin^2\alpha-2\sin\alpha\sin\beta+\sin^2\beta\\ &=2-2\cos\alpha\cos\beta-2\sin\alpha\sin\beta\\ &=2-2(\cos\alpha\cos\beta+\sin\alpha\sin\beta)\qquad(2)\end{aligned}$$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ ខាងលើ គេផ្ទឹមបាន ៖

$$2-2\cos(\alpha-\beta)=2-2(\cos\alpha\cos\beta+\sin\alpha\sin\beta)$$

$$-2\cos(\alpha-\beta)=-2(\cos\alpha\cos\beta+\sin\alpha\sin\beta)$$

$$\cos(\alpha-\beta)=\cos\alpha\cos\beta+\sin\alpha\sin\beta$$

ដូចនេះ: | រូបមន្ត $\cos(\alpha-\beta)=\cos\alpha\cos\beta+\sin\alpha\sin\beta$ ត្រូវបានស្រាយបញ្ជាក់ | ។

**ខ. បង្ហាញថា** $\cos(\alpha+\beta)=\cos\alpha\cos\beta-\sin\alpha\sin\beta$

គេមាន $\cos(\alpha-\beta)=\cos\alpha\cos\beta+\sin\alpha\sin\beta$ (បានស្រាយបញ្ជាក់រួចខាងលើ)

បើគេជំនួស $\beta$ ដោយ $-\beta$

គេបាន $\cos(\alpha-(-\beta))=\cos\alpha\cos(-\beta)+\sin\alpha\sin(-\beta)$

នាំឱ្យ $\cos(\alpha+\beta)=\cos\alpha\cos\beta-\sin\alpha\sin\beta$

ព្រោះមុំផ្ទុយ $\cos(-\beta)=\cos\beta$ , $\sin(-\beta)=-\sin\beta$

ដូចនេះ: | រូបមន្ត $\cos(\alpha+\beta)=\cos\alpha\cos\beta-\sin\alpha\sin\beta$ ត្រូវបានស្រាយបញ្ជាក់ | ។

**➢បង្ហាញថា** $\sin(\alpha+\beta)=\sin\alpha\cos\beta+\sin\beta\cos\alpha$

តាមលក្ខណៈមុំបំពេញ $\cos\left(\frac{\pi}{2}-\theta\right)=\sin\theta$ គេអាចសរសេរ $\cos\left(\frac{\pi}{2}-(\alpha+\beta)\right)=\sin(\alpha+\beta)\quad(1)$

តាមរូបមន្ត $\cos(\alpha-\beta)=\cos\alpha\cos\beta+\sin\alpha\sin\beta$

នាំឱ្យ

$$\begin{aligned}\cos\left(\frac{\pi}{2}-(\alpha+\beta)\right)&=\cos\left(\left(\frac{\pi}{2}-\alpha\right)-\beta\right)\\ &=\cos\left(\frac{\pi}{2}-\alpha\right)\cos\beta+\sin\left(\frac{\pi}{2}-\alpha\right)\sin\beta\\ &=\sin\alpha\cos\beta+\cos\alpha\sin\beta\\ &=\sin\alpha\cos\beta+\sin\beta\cos\alpha\qquad(2)\end{aligned}$$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ គេបាន $\sin(\alpha+\beta)=\sin\alpha\cos\beta+\sin\beta\cos\alpha$

ដូចនេះ: | រូបមន្ត $\sin(\alpha+\beta)=\sin\alpha\cos\beta+\sin\beta\cos\alpha$ ត្រូវបានស្រាយបញ្ជាក់ | ។

➢បង្ហាញថា $\sin(\alpha-\beta)=\sin\alpha\cos\beta-\sin\beta\cos\alpha$

គេមាន $\sin(\alpha+\beta)=\sin\alpha\cos\beta+\sin\beta\cos\alpha$ បើគេជំនួស $\beta$ ដោយ $-\beta$

គេបាន $\sin(\alpha+(-\beta))=\sin\alpha\cos(-\beta)+\sin(-\beta)\cos\alpha$

នាំឱ្យ $\sin(\alpha-\beta)=\sin\alpha\cos\beta-\sin\beta\cos\alpha$

ព្រោះមុំផ្ទុយ $\cos(-\beta)=\cos\beta$ , $\sin(-\beta)=-\sin\beta$

ដូចនេះ: រូបមន្ត $\sin(\alpha-\beta)=\sin\alpha\cos\beta-\sin\beta\cos\alpha$ ត្រូវបានស្រាយបញ្ជាក់ ។

➢បង្ហាញថា $\tan(\alpha+\beta)=\dfrac{\tan\alpha+\tan\beta}{1-\tan\alpha\tan\beta}$

ពិនិត្យ $\tan(\alpha+\beta)=\dfrac{\sin(\alpha+\beta)}{\cos(\alpha+\beta)}=\dfrac{\sin\alpha\cos\beta+\sin\beta\cos\alpha}{\cos\alpha\cos\beta-\sin\alpha\sin\beta}$ (ចែកភាគយក និងភាគបែង នឹង $\cos\alpha\cos\beta$ )

គេបាន $$\tan(\alpha+\beta)=\dfrac{\dfrac{\sin\alpha\cos\beta+\sin\beta\cos\alpha}{\cos\alpha\cos\beta}}{\dfrac{\cos\alpha\cos\beta-\sin\alpha\sin\beta}{\cos\alpha\cos\beta}}=\dfrac{\dfrac{\sin\alpha\cos\beta}{\cos\alpha\cos\beta}+\dfrac{\sin\beta\cos\alpha}{\cos\alpha\cos\beta}}{\dfrac{\cos\alpha\cos\beta}{\cos\alpha\cos\beta}-\dfrac{\sin\alpha\sin\beta}{\cos\alpha\cos\beta}}=\dfrac{\tan\alpha+\tan\beta}{1-\tan\alpha\tan\beta}$$

ដូចនេះ: រូបមន្ត $\tan(\alpha+\beta)=\dfrac{\tan\alpha+\tan\beta}{1-\tan\alpha\tan\beta}$ ត្រូវបានស្រាយបញ្ជាក់ ។

➢បង្ហាញថា $\tan(\alpha-\beta)=\dfrac{\tan\alpha-\tan\beta}{1+\tan\alpha\tan\beta}$

គេមាន $\tan(\alpha+\beta)=\dfrac{\tan\alpha+\tan\beta}{1-\tan\alpha\tan\beta}$ បើគេជំនួស $\beta$ ដោយ $-\beta$

គេបាន $\tan(\alpha+(-\beta))=\dfrac{\tan\alpha+\tan(-\beta)}{1-\tan\alpha\tan(-\beta)}$ (ដោយ $\tan(-\beta)=-\tan\beta$ )

នាំឱ្យ $\tan(\alpha-\beta)=\dfrac{\tan\alpha-\tan\beta}{1+\tan\alpha\tan\beta}$

ដូចនេះ: រូបមន្ត $\tan(\alpha-\beta)=\dfrac{\tan\alpha-\tan\beta}{1+\tan\alpha\tan\beta}$ ត្រូវបានស្រាយបញ្ជាក់ ។

➢បង្ហាញថា $\cot(\alpha+\beta)=\dfrac{\cot a\cot b-1}{\cot b+\cot a}$

ពិនិត្យ $\cot(\alpha+\beta)=\dfrac{\cos(\alpha+\beta)}{\sin(\alpha+\beta)}=\dfrac{\cos\alpha\cos\beta-\sin\alpha\sin\beta}{\sin\alpha\cos\beta+\sin\beta\cos\alpha}$ (ចែកភាគយក និងភាគបែង នឹង $\sin\alpha\sin\beta$ )

គេបាន $$\cot(\alpha+\beta)=\dfrac{\dfrac{\cos\alpha\cos\beta-\sin\alpha\sin\beta}{\sin\alpha\sin\beta}}{\dfrac{\sin\alpha\cos\beta+\sin\beta\cos\alpha}{\sin\alpha\sin\beta}}=\dfrac{\dfrac{\cos\alpha\cos\beta}{\sin\alpha\sin\beta}-\dfrac{\sin\alpha\sin\beta}{\sin\alpha\sin\beta}}{\dfrac{\sin\alpha\cos\beta}{\sin\alpha\sin\beta}+\dfrac{\sin\beta\cos\alpha}{\sin\alpha\sin\beta}}=\dfrac{\cot\alpha\cot\beta-1}{\cot\beta+\cot\alpha}$$

ដូចនេះ: រូបមន្ត $\cot(\alpha+\beta)=\dfrac{\cot\alpha\cot\beta-1}{\cot\beta+\cot\alpha}$ ត្រូវបានស្រាយបញ្ជាក់ ។

➢**បង្ហាញថា** $\cot(\alpha-\beta)=\dfrac{\cot\alpha\cot\beta+1}{\cot\beta-\cot\alpha}$

គេមាន $\cot(\alpha+\beta)=\dfrac{\cot\alpha\cot\beta-1}{\cot\beta+\cot\alpha}$

បើគេជំនួស $\beta$ ដោយ $-\beta$

គេបាន $\cot(\alpha+(-\beta))=\dfrac{\cot\alpha\cot(-\beta)-1}{\cot(-\beta)+\cot\alpha}$

នាំឱ្យ $\cot(\alpha-\beta)=\dfrac{-\cot\alpha\cot\beta-1}{-\cot\beta+\cot\alpha}=\dfrac{-(\cot\alpha\cot\beta+1)}{-(\cot\beta-\cot\alpha)}=\dfrac{\cot\alpha\cot\beta+1}{\cot\beta-\cot\alpha}$

ដូចនេះ: រូបមន្ត $\cot(\alpha-\beta)=\dfrac{\cot\alpha\cot\beta+1}{\cot\beta-\cot\alpha}$ ត្រូវបានស្រាយបញ្ជាក់ ។

10. ➢**ស្រាយបញ្ជាក់រូបមន្ត** $\sin 2\alpha=2\sin\alpha\cos\alpha$

គេមាន $\sin(\alpha+\beta)=\sin\alpha\cos\beta+\sin\beta\cos\alpha$ បើគេយក $\beta=\alpha$

គេបាន $\sin(\alpha+\alpha)=\sin\alpha\cos\alpha+\sin\alpha\cos\alpha$

នាំឱ្យ $\sin 2\alpha=2\sin\alpha\cos\alpha$

ដូចនេះ: រូបមន្ត $\sin 2\alpha=2\sin\alpha\cos\alpha$ ត្រូវបានស្រាយបញ្ជាក់ ។

➢**ស្រាយបញ្ជាក់រូបមន្ត** $\cos 2\alpha=(\cos^2\alpha-\sin^2\alpha)=(1-2\sin^2\alpha)=(2\cos^2\alpha-1)$

គេមាន $\cos(\alpha+\beta)=\cos\alpha\cos\beta-\sin\alpha\sin\beta$

បើគេយក $\beta=\alpha$

គេបាន $\cos(\alpha+\alpha)=\cos\alpha\cos\alpha-\sin\alpha\sin\alpha$

នាំឱ្យ $\cos 2\alpha=\cos^2\alpha-\sin^2\alpha=\left[\begin{array}{l}(1-\sin^2\alpha)-\sin^2\alpha=1-2\sin^2\alpha\\ \cos^2\alpha-(1-\cos^2\alpha)=2\cos^2\alpha-1\end{array}\right.$ ព្រោះ: $\sin^2\alpha+\cos^2\alpha=1$

ដូចនេះ: រូបមន្ត $\cos 2\alpha=(\cos^2\alpha-\sin^2\alpha)=(1-2\sin^2\alpha)=(2\cos^2\alpha-1)$ ត្រូវបានស្រាយបញ្ជាក់ ។

➢**ស្រាយបញ្ជាក់រូបមន្ត** $\tan 2\alpha=\dfrac{2\tan\alpha}{1-\tan^2\alpha}$

គេមាន $\tan(\alpha+\beta)=\dfrac{\tan\alpha+\tan\beta}{1-\tan\alpha\tan\beta}$ បើគេយក $\beta=\alpha$

គេបាន $\tan(\alpha+\alpha)=\dfrac{\tan\alpha+\tan\alpha}{1-\tan\alpha\tan\alpha}$

នាំឱ្យ $\tan 2\alpha=\dfrac{2\tan\alpha}{1-\tan^2\alpha}$

ដូចនេះ: រូបមន្ត $\tan 2\alpha=\dfrac{2\tan\alpha}{1-\tan^2\alpha}$ ត្រូវបានស្រាយបញ្ជាក់ ។

➤ស្រាយបញ្ជាក់រូបមន្ត $\sin\alpha = 2\sin\frac{\alpha}{2}\cos\frac{\alpha}{2}$

គេមាន $\sin 2\alpha = 2\sin\alpha\cos\alpha$ បើជំនួស $\alpha$ ដោយ $\frac{\alpha}{2}$

គេបាន $\sin\left(2\cdot\frac{\alpha}{2}\right) = 2\sin\frac{\alpha}{2}\cos\frac{\alpha}{2}$

នាំឱ្យ $\sin a = 2\sin\frac{\alpha}{2}\cos\frac{\alpha}{2}$

ដូចនេះ: | រូបមន្ត $\sin\alpha = 2\sin\frac{\alpha}{2}\cos\frac{\alpha}{2}$ ត្រូវបានស្រាយបញ្ជាក់ | ។

➤ស្រាយបញ្ជាក់រូបមន្ត $\cos^2\frac{\alpha}{2} = \frac{1+\cos\alpha}{2}$

គេមាន $\cos 2\alpha = 2\cos^2\alpha - 1$ ឬ $\cos^2\alpha = \frac{\cos 2\alpha + 1}{2}$

បើគេជំនួស $\alpha$ ដោយ $\frac{\alpha}{2}$ គេបាន $\cos^2\frac{\alpha}{2} = \frac{\cos 2\cdot\frac{\alpha}{2} + 1}{2}$ ឬ $\cos^2\frac{\alpha}{2} = \frac{\cos\alpha + 1}{2}$

ដូចនេះ: | រូបមន្ត $\cos^2\frac{\alpha}{2} = \frac{1+\cos\alpha}{2}$ ត្រូវបានស្រាយបញ្ជាក់ | ។

➤ស្រាយបញ្ជាក់រូបមន្ត $\sin^2\frac{\alpha}{2} = \frac{1-\cos\alpha}{2}$

គេមាន $\cos 2\alpha = 1 - 2\sin^2\alpha$ ឬ $\sin^2\alpha = \frac{1-\cos 2\alpha}{2}$

បើគេជំនួស $\alpha$ ដោយ $\frac{\alpha}{2}$ គេបាន $\sin^2\frac{\alpha}{2} = \frac{1-\cos 2\cdot\frac{\alpha}{2}}{2} = \frac{1-\cos\alpha}{2}$

ដូចនេះ: | រូបមន្ត $\sin^2\frac{\alpha}{2} = \frac{1-\cos\alpha}{2}$ ត្រូវបានស្រាយបញ្ជាក់ | ។

➤ស្រាយបញ្ជាក់រូបមន្ត $\tan^2\frac{\alpha}{2} = \frac{1-\cos\alpha}{1+\cos\alpha}$

គេមាន $\sin^2\frac{\alpha}{2} = \frac{1-\cos\alpha}{2}$ និង $\cos^2\frac{\alpha}{2} = \frac{1+\cos\alpha}{2}$ (បានស្រាយបញ្ជាក់រួចខាងលើ)

គេបាន $\tan^2\frac{\alpha}{2} = \frac{\sin^2\frac{\alpha}{2}}{\cos^2\frac{\alpha}{2}} = \frac{\frac{1-\cos\alpha}{2}}{\frac{1+\cos\alpha}{2}} = \frac{1-\cos\alpha}{1+\cos\alpha}$

ដូចនេះ: | រូបមន្ត $\tan^2\frac{\alpha}{2} = \frac{1-\cos\alpha}{1+\cos\alpha}$ ត្រូវបានស្រាយបញ្ជាក់ | ។

11. ស្រាយបញ្ជាក់រូបមន្ត ដូចខាងក្រោម បើគេតាង $\tan\frac{\alpha}{2}=t$ ៖

➢ស្រាយបញ្ជាក់រូបមន្ត $\cos\alpha=\frac{1-t^2}{1+t^2}$

គេមាន $\cos 2\alpha=\cos^2\alpha-\sin^2\alpha$ បើជំនួស $\alpha$ ដោយ $\frac{\alpha}{2}$

គេបាន $\cos\left(2\cdot\frac{\alpha}{2}\right)=\cos^2\frac{\alpha}{2}-\sin^2\frac{\alpha}{2}$

$\cos\alpha=\cos^2\frac{\alpha}{2}-\sin^2\frac{\alpha}{2}$ (ដោយ $\cos^2\frac{\alpha}{2}+\sin^2\frac{\alpha}{2}=1$)

គេសរសេរ $\cos\alpha=\dfrac{\cos^2\frac{\alpha}{2}-\sin^2\frac{\alpha}{2}}{\cos^2\frac{\alpha}{2}+\sin^2\frac{\alpha}{2}}$ (ចែកទាំងភាគយក និងភាគបែងនឹង $\cos^2\frac{\alpha}{2}$)

គេបាន $\cos\alpha=\dfrac{1-\tan^2\frac{\alpha}{2}}{1+\tan^2\frac{\alpha}{2}}$ បើគេតាង $\tan\frac{\alpha}{2}=t$ នាំឱ្យ $\cos\alpha=\frac{1-t^2}{1+t^2}$

ដូចនេះ: | រូបមន្ត $\cos\alpha=\frac{1-t^2}{1+t^2}$ ត្រូវបានស្រាយបញ្ជាក់ | ។

➢ស្រាយបញ្ជាក់រូបមន្ត $\sin\alpha=\frac{2t}{1+t^2}$

គេមាន $\sin\alpha=2\sin\frac{\alpha}{2}\cos\frac{\alpha}{2}$ (ដោយ $\cos^2\frac{\alpha}{2}+\sin^2\frac{\alpha}{2}=1$)

គេសរសេរ $\sin\alpha=\dfrac{2\sin\frac{\alpha}{2}\cos\frac{\alpha}{2}}{\cos^2\frac{\alpha}{2}+\sin^2\frac{\alpha}{2}}$ (ចែកទាំងភាគយក និងភាគបែងនឹង $\cos^2\frac{\alpha}{2}$)

គេបាន $\sin\alpha=\dfrac{2\tan\frac{\alpha}{2}}{1+\tan^2\frac{\alpha}{2}}$ បើគេតាង $\tan\frac{\alpha}{2}=t$ នាំឱ្យ $\sin\alpha=\frac{2t}{1+t^2}$

ដូចនេះ: | រូបមន្ត $\sin\alpha=\frac{2t}{1+t^2}$ ត្រូវបានស្រាយបញ្ជាក់ | ។

➢ស្រាយបញ្ជាក់រូបមន្ត $\tan\alpha=\frac{2t}{1-t^2}$

គេមាន $\sin\alpha=\frac{2t}{1+t^2}$ និង $\cos\alpha=\frac{1-t^2}{1+t^2}$ គេបាន $\tan\alpha=\dfrac{\sin\alpha}{\cos\alpha}=\dfrac{\frac{2t}{1+t^2}}{\frac{1-t^2}{1+t^2}}=\frac{2t}{1+t^2}\times\frac{1+t^2}{1-t^2}=\frac{2t}{1-t^2}$

ដូចនេះ: | រូបមន្ត $\tan\alpha=\frac{2t}{1-t^2}$ ដែល $t=\tan\frac{\alpha}{2}$ ត្រូវបានស្រាយបញ្ជាក់ | ។

12. ស្រាយបញ្ជាក់ទំនាក់ទំនងខាងក្រោម ៖

➢ស្រាយបញ្ជាក់ថា $\cos 3\alpha = \cos^3\alpha - 3\cos\alpha\sin^2\alpha = 4\cos^3\alpha - 3\cos\alpha$

ពិនិត្យ $\cos 3\alpha = \cos(2\alpha+\alpha)$

$= \cos 2\alpha\cos\alpha - \sin 2\alpha\sin\alpha$

$= (2\cos^2\alpha - 1)\cos\alpha - 2\sin^2\alpha\cos\alpha$

$= (2\cos^2\alpha - \cos^2\alpha - \sin^2\alpha)\cos\alpha - 2\sin^2\alpha\cos\alpha$

$= (\cos^2\alpha - \sin^2\alpha)\cos\alpha - 2\sin^2\alpha\cos\alpha$

$= \cos^3\alpha - \sin^2\alpha\cos\alpha - 2\sin^2\alpha\cos\alpha$

$= \cos^3\alpha - 3\sin^2\alpha\cos\alpha$

ម្យ៉ាងទៀត $\cos 3\alpha = \cos(2\alpha+\alpha)$

$= \cos 2\alpha\cos\alpha - \sin 2\alpha\sin\alpha$

$= (2\cos^2\alpha - 1)\cos\alpha - 2\sin^2\alpha\cos\alpha$

$= 2\cos^3\alpha - \cos\alpha - 2(1-\cos^2\alpha)\cos\alpha$

$= 2\cos^3\alpha - \cos\alpha - 2\cos\alpha + 2\cos^3\alpha$

$= 4\cos^3\alpha - 3\cos\alpha$

ដូចនេះ: រូបមន្ត $\cos 3\alpha = \cos^3\alpha - 3\cos\alpha\sin^2\alpha = 4\cos^3\alpha - 3\cos\alpha$ ត្រូវបានស្រាយបញ្ជាក់ ។

➢ស្រាយបញ្ជាក់ថា $\sin 3\alpha = 3\cos^2\alpha\sin a - \sin^3\alpha = -4\sin^3\alpha + 3\sin\alpha$

ពិនិត្យ $\sin 3\alpha = \sin(2\alpha+\alpha)$

$= \sin 2\alpha\cos\alpha + \sin\alpha\cos 2\alpha$

$= 2\sin\alpha\cos\alpha\cos\alpha + \sin\alpha(2\cos^2\alpha - 1)$

$= 2\sin\alpha\cos^2\alpha + 2\sin\alpha\cos^2\alpha - \sin\alpha$

$= 3\sin\alpha\cos^2\alpha + (\sin\alpha\cos^2\alpha - \sin\alpha)$

$= 3\sin\alpha\cos^2\alpha + \sin\alpha(\cos^2\alpha - 1)$

$= 3\sin\alpha\cos^2\alpha - \sin^3\alpha$

ម្យ៉ាងទៀត $\sin 3\alpha = \sin(2\alpha+\alpha)$

$= \sin 2\alpha\cos\alpha + \sin\alpha\cos 2\alpha$

$= 2\sin\alpha\cos\alpha\cos\alpha + \sin\alpha(1-2\sin^2\alpha)$

$= 2\sin\alpha\cos^2\alpha + \sin\alpha - 2\sin^3\alpha$

$= 2\sin\alpha(1-\sin^2\alpha) + \sin\alpha - 2\sin^3\alpha$

$= 2\sin\alpha - 2\sin^3\alpha + \sin\alpha - 2\sin^3\alpha$

$= 3\sin\alpha - 4\sin^3\alpha$

ដូចនេះ: រូបមន្ត $\sin 3\alpha = 3\cos^2\alpha\sin a - \sin^3\alpha = -4\sin^3\alpha + 3\sin\alpha$ ត្រូវបានស្រាយបញ្ជាក់ ។

➢ស្រាយបញ្ជាក់ថា $\cos 4\alpha = \cos^4\alpha + \sin^4\alpha - 6\cos^2\alpha\sin^2\alpha$

ពិនិត្យ $\cos 4\alpha = \cos(3\alpha + \alpha)$

$$= \cos 3\alpha\cos\alpha - \sin 3\alpha\sin\alpha$$
$$= \left(4\cos^3\alpha - 3\cos\alpha\right)\cos\alpha - \left(3\sin\alpha - 4\sin^3\alpha\right)\sin\alpha$$
$$= 4\cos^4\alpha - 3\cos^2\alpha - 3\sin^2\alpha + 4\sin^4\alpha$$
$$= \cos^4\alpha + \sin^4\alpha + \left(3\cos^4\alpha - 3\cos^2\alpha - 3\sin^2\alpha + 3\sin^4\alpha\right)$$
$$= \cos^4\alpha + \sin^4\alpha + 3\left(\cos^4\alpha - \cos^2\alpha - \sin^2\alpha + \sin^4\alpha\right)$$
$$= \cos^4\alpha + \sin^4\alpha + 3\left[\cos^2\alpha\left(\cos^2\alpha - 1\right) - \sin^2\alpha\left(1 - \sin^2\alpha\right)\right]$$
$$= \cos^4\alpha + \sin^4\alpha + 3\left(-\cos^2\alpha\sin^2\alpha - \sin^2\alpha\cos^2 x\right)$$
$$= \cos^4\alpha + \sin^4\alpha + 3\left(-2\cos^2\alpha\sin^2\alpha\right)$$
$$= \cos^4\alpha + \sin^4\alpha - 6\cos^2\alpha\sin^2\alpha$$

ដូចនេះ

| |
|---|
| រូបមន្ត $\cos 4\alpha = \cos^4\alpha + \sin^4\alpha - 6\cos^2\alpha\sin^2\alpha$ ត្រូវបានស្រាយបញ្ជាក់ |

។

➢ស្រាយបញ្ជាក់ថា $\sin 4\alpha = 4\cos^3\alpha\sin\alpha - 4\cos\alpha\sin^3\alpha$

ពិនិត្យ $\sin 4\alpha = \sin(3\alpha + \alpha)$

$$= \sin(3\alpha + \alpha)$$
$$= \sin 3\alpha\cos\alpha + \sin\alpha\cos 3\alpha$$
$$= \left(3\sin\alpha - 4\sin^3\alpha\right)\cos\alpha + \sin\alpha\left(4\cos^3\alpha - 3\cos\alpha\right)$$
$$= 3\sin\alpha\cos\alpha - 4\sin^3\alpha\cos\alpha + 4\sin\alpha\cos^3\alpha - 3\sin\alpha\cos\alpha$$
$$= 4\sin\alpha\cos^3\alpha - 4\sin^3\alpha\cos\alpha$$

ដូចនេះ

| |
|---|
| រូបមន្ត $\sin 4\alpha = 4\cos^3\alpha\sin\alpha - 4\cos\alpha\sin^3\alpha$ ត្រូវបានស្រាយបញ្ជាក់ |

។

13. ស្រាយបញ្ជាក់រូបមន្ត បំលែងពីផលគុណទៅផលបូក ខាងក្រោម ៖

➢ស្រាយបញ្ជាក់ថា $\cos\alpha\cos\beta = \frac{1}{2}\left[\cos(\alpha+\beta) + \cos(\alpha-\beta)\right]$

គេមាន $\cos(\alpha+\beta) = \cos\alpha\cos\beta - \sin\alpha\sin\beta \quad (1)$

$\cos(\alpha-\beta) = \cos\alpha\cos\beta + \sin\alpha\sin\beta \quad (2)$

គេបូកអង្គ និងអង្គនៃ $(1)$ និង $(2)$ គេបាន៖

$$\cos(\alpha+\beta) + \cos(\alpha-\beta) = 2\cos\alpha\cos\beta$$

នាំឱ្យ $\frac{1}{2}\left[\cos(\alpha+\beta) + \cos(\alpha-\beta)\right] = \cos\alpha\cos\beta$

ដូចនេះ

| |
|---|
| រូបមន្ត $\cos\alpha\cos\beta = \frac{1}{2}\left[\cos(\alpha+\beta) + \cos(\alpha-\beta)\right]$ ត្រូវបានស្រាយបញ្ជាក់ |

។

➤ស្រាយបញ្ជាក់ថា $\sin\alpha\sin\beta=\frac{1}{2}\left[\cos(\alpha-\beta)-\cos(\alpha+\beta)\right]$

គេមាន $\cos(\alpha-\beta)=\cos\alpha\cos\beta+\sin\alpha\sin\beta \quad (1)$

$\cos(\alpha+\beta)=\cos\alpha\cos\beta-\sin\alpha\sin\beta \quad (2)$

គេដកអង្គ និងអង្គនៃ $(1)$ និង $(2)$ គេបាន៖

$$\cos(\alpha-\beta)-\cos(\alpha+\beta)=2\sin\alpha\sin\beta$$

នាំឱ្យ $\frac{1}{2}\left[\cos(\alpha-\beta)-\cos(\alpha+\beta)\right]=\sin\alpha\sin\beta$

ដូចនេះ: រូបមន្ត $\sin\alpha\sin\beta=\frac{1}{2}\left[\cos(\alpha-\beta)-\cos(\alpha+\beta)\right]$ ត្រូវបានស្រាយបញ្ជាក់ ។

➤ស្រាយបញ្ជាក់ថា $\sin\alpha\cos\beta=\frac{1}{2}\left[\sin(\alpha+\beta)+\sin(\alpha-\beta)\right]$

គេមាន $\sin(\alpha+\beta)=\sin\alpha\cos\beta+\sin\beta\cos\alpha \quad (1)$

$\sin(\alpha-\beta)=\sin\alpha\cos\beta-\sin\beta\cos\alpha \quad (2)$

គេបូកអង្គ និងអង្គនៃ $(1)$ និង $(2)$ គេបាន៖

$$\sin(\alpha+\beta)+\sin(\alpha-\beta)=2\sin\alpha\cos\beta$$

នាំឱ្យ $\frac{1}{2}\left[\sin(\alpha+\beta)+\sin(\alpha-\beta)\right]=\sin\alpha\cos\beta$

ដូចនេះ: រូបមន្ត $\sin\alpha\cos\beta=\frac{1}{2}\left[\sin(\alpha+\beta)+\sin(\alpha-\beta)\right]$ ត្រូវបានស្រាយបញ្ជាក់ ។

➤ស្រាយបញ្ជាក់ថា $\sin\beta\cos\alpha=\frac{1}{2}\left[\sin(\alpha+\beta)-\sin(\alpha-\beta)\right]$

គេមាន $\sin(\alpha+\beta)=\sin\alpha\cos\beta+\sin\beta\cos\alpha \quad (1)$

$\sin(\alpha-\beta)=\sin\alpha\cos\beta-\sin\beta\cos\alpha \quad (2)$

គេដកអង្គ និងអង្គនៃ $(1)$ និង $(2)$ គេបាន៖

$$\sin(\alpha+\beta)-\sin(\alpha-\beta)=2\sin\beta\cos\alpha$$

នាំឱ្យ $\frac{1}{2}\left[\sin(\alpha+\beta)-\sin(\alpha-\beta)\right]=\sin\beta\cos\alpha$

ដូចនេះ: រូបមន្ត $\sin\beta\cos\alpha=\frac{1}{2}\left[\sin(\alpha+\beta)-\sin(\alpha-\beta)\right]$ ត្រូវបានស្រាយបញ្ជាក់ ។

14. ស្រាយបញ្ជាក់រូបមន្ត បំលែងពីផលបូក ទៅផលគុណ ខាងក្រោម ៖

➢ស្រាយបញ្ជាក់ថា $\cos p+\cos q=2\cos\frac{p+q}{2}\cos\frac{p-q}{2}$

គេមាន $\cos(\alpha-\beta)=\cos\alpha\cos\beta+\sin\alpha\sin\beta \quad (1)$

$\cos(\alpha+\beta)=\cos\alpha\cos\beta-\sin\alpha\sin\beta \quad (2)$

គេបូកអង្គ និងអង្គនៃ $(1)$ និង $(2)$ គេបាន៖ $\cos(\alpha+\beta)+\cos(\alpha-\beta)=2\cos\alpha\cos\beta \quad (*)$

បើគេតាង $\alpha+\beta=p$ និង $\alpha-\beta=q$

គេបាន $(\alpha+\beta)+(\alpha-\beta)=p+q$ នាំឱ្យ $2\alpha=p+q$ ឬ $\alpha=\frac{p+q}{2}$

$(\alpha+\beta)-(\alpha-\beta)=p-q$ នាំឱ្យ $2\beta=p-q$ ឬ $\beta=\frac{p-q}{2}$

នាំឱ្យ $(*)$ ទៅជា $\cos p+\cos q=2\cos\frac{p+q}{2}\cos\frac{p-q}{2}$

ដូចនេះ: | រូបមន្ត $\cos p+\cos q=2\cos\frac{p+q}{2}\cos\frac{p-q}{2}$ ត្រូវបានស្រាយបញ្ជាក់ | ។

➢ស្រាយបញ្ជាក់ថា $\cos p-\cos q=-2\sin\frac{p+q}{2}\sin\frac{p-q}{2}$

គេមាន $\cos(\alpha+\beta)=\cos\alpha\cos\beta-\sin\alpha\sin\beta \quad (1)$

$\cos(\alpha-\beta)=\cos\alpha\cos\beta+\sin\alpha\sin\beta \quad (2)$

គេដកអង្គ និងអង្គនៃ $(1)$ និង $(2)$ គេបាន៖ $\cos(\alpha+\beta)-\cos(\alpha-\beta)=-2\sin\alpha\sin\beta \quad (*)$

បើគេតាង $\alpha+\beta=p$ និង $\alpha-\beta=q$ នាំឱ្យ $\alpha=\frac{p+q}{2}$ និង $\beta=\frac{p-q}{2}$

គេបាន $(*)$ ទៅជា $\cos p-\cos q=-2\sin\frac{p+q}{2}\sin\frac{p-q}{2}$

ដូចនេះ: | រូបមន្ត $\cos p-\cos q=-2\sin\frac{p+q}{2}\sin\frac{p-q}{2}$ ត្រូវបានស្រាយបញ្ជាក់ | ។

➢ស្រាយបញ្ជាក់ថា $\sin p+\sin q=2\sin\frac{p+q}{2}\cos\frac{p-q}{2}$

គេមាន $\sin(\alpha+\beta)=\sin\alpha\cos\beta+\sin\beta\cos\alpha \quad (1)$

$\sin(\alpha-\beta)=\sin\alpha\cos\beta-\sin\beta\cos\alpha \quad (2)$

គេបូកអង្គ និងអង្គនៃ $(1)$ និង $(2)$ គេបាន៖ $\sin(\alpha+\beta)+\sin(\alpha-\beta)=2\sin\alpha\cos\beta \quad (*)$

បើគេតាង $\alpha+\beta=p$ និង $\alpha-\beta=q$ នាំឱ្យ $\alpha=\frac{p+q}{2}$ និង $\beta=\frac{p-q}{2}$

គេបាន $(*)$ ទៅជា $\sin p+\sin q=2\sin\frac{p+q}{2}\cos\frac{p-q}{2}$

ដូចនេះ: | រូបមន្ត $\sin p+\sin q=2\sin\frac{p+q}{2}\cos\frac{p-q}{2}$ ត្រូវបានស្រាយបញ្ជាក់ | ។

➤ស្រាយបញ្ជាក់ថា $\sin p-\sin q=2\sin\frac{p-q}{2}\cos\frac{p+q}{2}$

គេមាន $\sin(\alpha+\beta)=\sin\alpha\cos\beta+\sin\beta\cos\alpha \quad (1)$

$\sin(\alpha-\beta)=\sin\alpha\cos\beta-\sin\beta\cos\alpha \quad (2)$

គេដកអង្គ និងអង្គនៃ $(1)$ និង $(2)$ គេបាន៖ $\sin(\alpha+\beta)-\sin(\alpha-\beta)=2\sin\beta\cos\alpha \quad (*)$

បើគេតាង $\alpha+\beta=p$ និង $\alpha-\beta=q$ នាំឱ្យ $\alpha=\frac{p+q}{2}$ និង $\beta=\frac{p-q}{2}$

គេបាន $(*)$ ទៅជា $\sin p-\sin q=2\sin\frac{p-q}{2}\cos\frac{p+q}{2}$

ដូចនេះ: | រូបមន្ត $\sin p-\sin q=2\sin\frac{p-q}{2}\cos\frac{p+q}{2}$ ត្រូវបានស្រាយបញ្ជាក់ | ។

➤ស្រាយបញ្ជាក់ថា $\tan p+\tan q=\frac{\sin(p+q)}{\cos p\cos q}$

គេមាន $\tan p+\tan q=\frac{\sin p}{\cos p}+\frac{\sin q}{\cos q}$

$=\frac{\sin p\cos q+\sin q\cos p}{\cos p\cos q}$ , $\sin(p+q)=\sin p\cos q+\sin q\cos p$

$=\frac{\sin(p+q)}{\cos p\cos q}$

ដូចនេះ: | រូបមន្ត $\tan p+\tan q=\frac{\sin(p+q)}{\cos p\cos q}$ ត្រូវបានស្រាយបញ្ជាក់ | ។

➤ស្រាយបញ្ជាក់ថា $\tan p-\tan q=\frac{\sin(p-q)}{\cos p\cos q}$

គេមាន $\tan p-\tan q=\frac{\sin p}{\cos p}-\frac{\sin q}{\cos q}$

$=\frac{\sin p\cos q-\sin q\cos p}{\cos p\cos q}$ , $\sin(p-q)=\sin p\cos q-\sin q\cos p$

$=\frac{\sin(p-q)}{\cos p\cos q}$

ដូចនេះ: | រូបមន្ត $\tan p-\tan q=\frac{\sin(p-q)}{\cos p\cos q}$ ត្រូវបានស្រាយបញ្ជាក់ | ។

➢ស្រាយបញ្ជាក់ថា $\cot p+\cot q=\dfrac{\sin(p+q)}{\sin p\sin q}$

គេមាន $\cot p+\cot q=\dfrac{\cos p}{\sin p}+\dfrac{\cos q}{\sin q}$

$=\dfrac{\cos p\sin q+\cos q\sin p}{\sin p\sin q}$

$=\dfrac{\sin p\cos q+\sin q\cos p}{\sin p\sin q}$ , $\sin(p+q)=\sin p\cos q+\sin q\cos p$

$=\dfrac{\sin(p+q)}{\sin p\sin q}$

ដូចនេះ: | រូបមន្ត $\cot p+\cot q=\dfrac{\sin(p+q)}{\sin p\sin q}$ ត្រូវបានស្រាយបញ្ជាក់ | ។

➢ស្រាយបញ្ជាក់ថា $\cot p-\cot q=-\dfrac{\sin(p-q)}{\sin p\sin q}$

**របៀបទី១**

គេមាន $\cot p-\cot q=\dfrac{\cos p}{\sin p}-\dfrac{\cos q}{\sin q}$

$=\dfrac{\cos p\sin q-\cos q\sin p}{\sin p\sin q}$

$=-\dfrac{\sin p\cos q-\sin q\cos p}{\sin p\sin q}$ , $\sin(p-q)=\sin p\cos q-\sin q\cos p$

$=-\dfrac{\sin(p-q)}{\sin p\sin q}$

ដូចនេះ: | រូបមន្ត $\cot p-\cot q=-\dfrac{\sin(p-q)}{\sin p\sin q}$ ត្រូវបានស្រាយបញ្ជាក់ | ។

**របៀបទី២**

គេមាន $\cot p+\cot q=\dfrac{\sin(p+q)}{\sin p\sin q}$ (បានស្រាយបញ្ជាក់រួចខាងលើ)

បើគេជំនួស $q$ ដោយ $-q$

គេបាន $\cot p+\cot(-q)=\dfrac{\sin(p+(-q))}{\sin p\sin(-q)}$ ដោយ $\sin(-q)=-\sin q$

$\cot p-\cot q=-\dfrac{\sin(p-q)}{\sin p\sin q}$

ដូចនេះ: | រូបមន្ត $\cot p-\cot q=-\dfrac{\sin(p-q)}{\sin p\sin q}$ ត្រូវបានស្រាយបញ្ជាក់ | ។

# ការស្រាយបញ្ជាក់លើមេរៀន ម៉ាទ្រីស និងដេទែមីណង់

1. ស្រាយបញ្ជាក់លក្ខណៈនៃម៉ាទ្រីសខាងក្រោម បើ $A$ និង $B$ ជាម៉ាទ្រីសមានលំដាប់ដូចគ្នា ហើយ $k$ , $h$ ជាចំនួនថេរ ៖

   ក. $A+B=B+A$ (លក្ខណៈត្រឡប់នៃវិធីបូក)

   ខ. $(A+B)+C=A+(B+C)$ (លក្ខណៈផ្តុំនៃវិធីបូក)

   គ. $k(mA)=(km)A$ (វិធីគុណដោយស្កាលែមានលក្ខណៈផ្តុំ)

   ឃ. $k(A+B)=kA+kB$ (វិធីគុណនឹងស្កាលែមានលក្ខណៈបំបែក ចំពោះវិធីបូក) ។

2. បង្ហាញថាម៉ាទ្រីសច្រាសនៃម៉ាទ្រីស $A=\begin{bmatrix} a & b \\ c & d \end{bmatrix}$ គឺ $A^{-1}=\dfrac{1}{ad-bc}\begin{bmatrix} d & -b \\ -c & a \end{bmatrix}$ ដែល $ad-bc\neq 0$ ។

# ការស្រាយបញ្ជាក់លើមេរៀន ម៉ាទ្រីស និងដេទែមីណង់

1. បើ $A$ និង $B$ ជាម៉ាទ្រីសមានលំដាប់ដូចគ្នា ហើយ $k$ , $h$ ជាចំនួនថេរ ៖

**ក. ស្រាយបញ្ជាក់ថា** $A+B=B+A$ **(លក្ខណៈត្រឡប់នៃវិធីបូក)**

គេតាង $A=\left[a_{ij}\right]_{m\times n}$ , $B=\left[b_{ij}\right]_{m\times n}$

គេបាន
$$\begin{aligned}A+B&=\left[a_{ij}\right]+\left[b_{ij}\right]=\left[a_{ij}+b_{ij}\right]\\&=\left[b_{ij}+a_{ij}\right]\\&=\left[b_{ij}\right]+\left[a_{ij}\right]\\&=B+A\end{aligned}$$

ដូចនេះ: **លក្ខណៈនៃម៉ាទ្រីស $A+B=B+A$ ត្រូវបានស្រាយបញ្ជាក់** ។

**ខ. ស្រាយបញ្ជាក់ថា** $(A+B)+C=A+(B+C)$ **(លក្ខណៈផ្តុំនៃវិធីបូក)**

គេតាង $A=\left[a_{ij}\right]_{m\times n}$ , $B=\left[b_{ij}\right]_{m\times n}$ និង $C=\left[c_{ij}\right]_{m\times n}$

គេបាន
$$\begin{aligned}(A+B)+C&=\left(\left[a_{ij}\right]+\left[b_{ij}\right]\right)+\left[c_{ij}\right]\\&=\left[\left(a_{ij}+b_{ij}\right)+c_{ij}\right]\\&=\left[a_{ij}+\left(b_{ij}+c_{ij}\right)\right]\\&=\left[a_{ij}\right]+\left(\left[b_{ij}\right]+\left[c_{ij}\right]\right)\\&=A+(B+C)\end{aligned}$$

ដូចនេះ: **លក្ខណៈនៃម៉ាទ្រីស $(A+B)+C=A+(B+C)$ ត្រូវបានស្រាយបញ្ជាក់** ។

**គ. ស្រាយបញ្ជាក់ថា** $k(mA)=(km)A$ **(វិធីគុណដោយស្កាលែមានលក្ខណៈផ្តុំ)**

គេតាង $A=\left[a_{ij}\right]_{m\times n}$

គេបាន
$$\begin{aligned}k(mA)&=k\left[ma_{ij}\right]=\left[k\left(ma_{ij}\right)\right]\\&=\left[(km)a_{ij}\right]=(km)\left[a_{ij}\right]\\&=(km)A\end{aligned}$$

ដូចនេះ: **លក្ខណៈនៃម៉ាទ្រីស $k(mA)=(km)A$ ត្រូវបានស្រាយបញ្ជាក់** ។

**ឃ. ស្រាយបញ្ជាក់ថា** $k(A+B)=kA+kB$ **(វិធីគុណនឹងស្កាលែមានលក្ខណៈបំបែក ចំពោះវិធីបូក)**

គេតាង $A=\left[a_{ij}\right]_{m\times n}$ , $B=\left[b_{ij}\right]_{m\times n}$

គេបាន $k(A+B)=\left[k\left(a_{ij}+b_{ij}\right)\right]=\left[ka_{ij}+kb_{ij}\right]=\left[ka_{ij}\right]+\left[kb_{ij}\right]=kA+kB$

ដូចនេះ: **លក្ខណៈនៃម៉ាទ្រីស $k(A+B)=kA+kB$ ត្រូវបានស្រាយបញ្ជាក់** ។

2. បង្ហាញថាម៉ាទ្រីសច្រាសនៃម៉ាទ្រីស $A=\begin{bmatrix} a & b \\ c & d \end{bmatrix}$ គឺ $A^{-1}=\frac{1}{ad-bc}\begin{bmatrix} d & -b \\ -c & a \end{bmatrix}$ ដែល $ad-bc\neq 0$

គេមាន $A=\begin{bmatrix} a & b \\ c & d \end{bmatrix}$ និង $A^{-1}=\frac{1}{ad-bc}\begin{bmatrix} d & -b \\ -c & a \end{bmatrix}$

គេតាង $M=\begin{bmatrix} d & -b \\ -c & a \end{bmatrix}$

គេបាន $AM=\begin{bmatrix} a & b \\ c & d \end{bmatrix}\begin{bmatrix} d & -b \\ -c & a \end{bmatrix}=\begin{bmatrix} ad-bc & -ab+ba \\ cd-dc & -bc+ad \end{bmatrix}=\begin{bmatrix} ad-bc & 0 \\ 0 & ad-bc \end{bmatrix}=(ad-bc)\begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix}=(ad-bc)I$

$AM=\begin{bmatrix} d & -b \\ -c & a \end{bmatrix}\begin{bmatrix} a & b \\ c & d \end{bmatrix}=\begin{bmatrix} ad-bc & bd-bd \\ -ac+ac & -bc+ad \end{bmatrix}=\begin{bmatrix} ad-bc & 0 \\ 0 & ad-bc \end{bmatrix}=(ad-bc)\begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix}=(ad-bc)I$

ករណី $AM=(ad-bc)I$ នោះ $I=\frac{1}{ad-bc}AM$

តាមនិយមន័យ $A^{-1}$ ជាម៉ាទ្រីសនៃ $A$ នោះ $AA^{-1}=A^{-1}A=I$

គេបាន $AA^{-1}=\frac{1}{ad-bc}AM \Rightarrow A^{-1}=\frac{1}{ad-bc}M$ ឬ $A^{-1}=\frac{1}{ad-bc}\begin{bmatrix} d & -b \\ -c & a \end{bmatrix}$

ករណី $MA=(ad-bc)I$ នោះ $I=\frac{1}{ad-bc}MA$

តាមនិយមន័យ $A^{-1}$ ជាម៉ាទ្រីសនៃ $A$ នោះ $AA^{-1}=A^{-1}A=I$

គេបាន $A^{-1}A=\frac{1}{ad-bc}MA \Rightarrow A^{-1}=\frac{1}{ad-bc}M$ ឬ $A^{-1}=\frac{1}{ad-bc}\begin{bmatrix} d & -b \\ -c & a \end{bmatrix}$

តាមពីរករណីខាងលើ បញ្ជាក់ថាម៉ាទ្រីសច្រាសនៃម៉ាទ្រីស $A$ គឺ $A^{-1}=\frac{1}{ad-bc}\begin{bmatrix} d & -b \\ -c & a \end{bmatrix}$

ដូចនេះ

| ម៉ាទ្រីសច្រាសនៃម៉ាទ្រីស $A=\begin{bmatrix} a & b \\ c & d \end{bmatrix}$ គឺ $A^{-1}=\frac{1}{ad-bc}\begin{bmatrix} d & -b \\ -c & a \end{bmatrix}$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

# ការស្រាយបញ្ជាក់លើមេរៀន បំលែងលីនេអ៊ែ

1. បង្ហាញរូបមន្តបំលែងឆ្លុះតាមករណីដូចខាងក្រោម ៖

ក. បំលែងលីនេអ៊ែរឆ្លុះធៀបនឹងអ័ក្ស $x'x$ គឺ $S_{x'x}:\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}1&0\\0&-1\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$។

ខ. បំលែងលីនេអ៊ែរឆ្លុះធៀបនឹងអ័ក្ស $y'y$ គឺ $S_{y'y}:\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}-1&0\\0&1\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$។

គ. បំលែងលីនេអ៊ែរឆ្លុះធៀបនឹងគល់ $O$ គឺ $S_O:\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}-1&0\\0&-1\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$។

2. បង្ហាញរូបមន្តបំលែងចាំង ដូចខាងក្រោម ៖

បំលែងចាំង $H$ ដែលមានផលធៀប $k$ គឺៈ $H(0,k):\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}k&0\\0&k\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$ ។

3. បង្ហាញរូបមន្តបំលែងវិលដូចខាងក្រោម ៖

បំលែងវិលនៃមុំ $\alpha$ គឺៈ $\Re(0,\alpha):\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}\cos\alpha&-\sin\alpha\\\sin\alpha&\cos\alpha\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$ ។

# ការស្រាយបញ្ជាក់លើមេរៀន បំលែងលីនេអ៊ែរ

1. **បង្ហាញរូបមន្តបំលែងឆ្លុះតាមករណីដូចខាងក្រោម ៖**

**ក. បង្ហាញរូបមន្ត បំលែងលីនេអ៊ែរឆ្លុះធៀបនឹងអ័ក្ស $x'x$ គឺ $S_{x'x}:\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}1&0\\0&-1\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$**

គេតាង $M(x\,,\,y)$ និង $M'(x'\,,\,y')$




បើចំណុច $M(x\,,\,y)$ និង $M'(x'\,,\,y')$ ឆ្លុះគ្នាធៀបនឹងអ័ក្ស $x'x$

គេបាន $x'=x$ និង $y'=-y$

គេសរសេរ $M\overset{S_{x'x}}{\to}M'$ : $\begin{cases}x'=x\\y'=-y\end{cases}$ អាចសរសេរ $\begin{cases}x'=1\cdot x+0\cdot y\\y'=0\cdot x-1\cdot y\end{cases}$

គេអាចសរសេរជាទម្រង់ម៉ាទ្រីស $S_{x'x}:\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}1&0\\0&-1\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$

ដូចនេះ: រូបមន្ត បំលែងលីនេអ៊ែរឆ្លុះធៀបនឹងអ័ក្ស $x'x$ គឺ $S_{x'x}:\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}1&0\\0&-1\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$ ត្រូវបានបង្ហាញ ។

**ខ. បង្ហាញរូបមន្ត បំលែងលីនេអ៊ែរឆ្លុះធៀបនឹងអ័ក្ស $y'y$ គឺ $S_{y'y}:\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}-1&0\\0&1\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$**

គេតាង $M(x\,,\,y)$ និង $M'(x'\,,\,y')$




បើចំណុច $M(x\,,\,y)$ និង $M'(x'\,,\,y')$ ឆ្លុះគ្នាធៀបនឹងអ័ក្ស $y'y$

គេបាន $x'=-x$ និង $y'=y$

គេសរសេរ $M\overset{S_{y'y}}{\to}M'$ : $\begin{cases}x'=-x\\y'=y\end{cases}$ អាចសរសេរ $\begin{cases}x'=-1\cdot x+0\cdot y\\y'=0\cdot x+1\cdot y\end{cases}$

គេអាចសរសេរជាទម្រង់ម៉ាទ្រីស $S_{y'y}:\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}-1&0\\0&1\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$

ដូចនេះ: រូបមន្ត បំលែងលីនេអ៊ែរឆ្លុះធៀបនឹងអ័ក្ស $y'y$ គឺ $S_{y'y}:\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}-1&0\\0&1\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$ ត្រូវបានបង្ហាញ ។

**គ. បង្ហាញរូបមន្ត បំលែងលីនេអ៊ែរឆ្លុះធៀបនឹងគល់ $O$ គឺ $S_O:\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}-1&0\\0&-1\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$**

គេតាង $M(x\,,\,y)$ និង $M'(x'\,,\,y')$




បើចំណុច $M(x\,,\,y)$ និង $M'(x'\,,\,y')$ ឆ្លុះគ្នាធៀបនឹងគល់ $O$

គេបាន $x'=-x$ និង $y'=-y$

គេសរសេរ $M\overset{S_O}{\to}M'$ : $\begin{cases}x'=-x\\y'=-y\end{cases}$ អាចសរសេរ $\begin{cases}x'=-1\cdot x+0\cdot y\\y'=0\cdot x-1\cdot y\end{cases}$

គេអាចសរសេរជាទម្រង់ម៉ាទ្រីស $S_O:\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}-1&0\\0&-1\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$

ដូចនេះ: រូបមន្ត បំលែងលីនេអ៊ែរឆ្លុះធៀបនឹងអ័ក្ស $y'y$ គឺ $S_O:\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}-1&0\\0&-1\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$ ត្រូវបានបង្ហាញ ។

2. **បង្ហាញរូបមន្ត បំលែងចាំង $H$ ដែលមានផលធៀប $k$ គឺ:** $H(0\,,k):\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}k & 0\\0 & k\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$

បើ $M'(x'\,,\,y')$ ជារូបភាពនៃ $M(x\,,\,y)$ តាមបំលែងចាំង $H$ ដែលមានផលធៀប $k$ ដែល $k\neq 0$

នោះគេបានកូអរដោនេ $x'=kx$ , $y'=ky$ អាចសរសេរជា $\begin{cases}x'=k\cdot x+0\cdot y\\y'=0\cdot x+k\cdot y\end{cases}$

ដើម្បីងាយស្រួលសិក្សា គេសរសេរជាទម្រង់ម៉ាទ្រីស $H(0\,,k):\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}k & 0\\0 & k\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$

ដូចនេះ: រូបមន្តបំលែងចាំង $H$ ដែលមានផលធៀប $k$ គឺ: $H(0\,,k):\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}k & 0\\0 & k\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$ ត្រូវបានបង្ហាញ ។

3. **បង្ហាញរូបមន្ត បំលែងវិលបំលែងវិលនៃមុំ $\alpha$ គឺ:** $\Re(0,\alpha):\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}\cos\alpha & -\sin\alpha\\\sin\alpha & \cos\alpha\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$

បើ $M'(x'\,,\,y')$ ជារូបភាពនៃ $M(x\,,\,y)$ តាមបំលែងវិល $\Re(0,\alpha)$ នោះគេបាន

$OM'=OM$ , $\left(\overrightarrow{OM}\,,\overrightarrow{OM'}\right)=\alpha$




គេដៅចំណុច $P$ និង $Q$ ជាចំណោលកែងនៃចំណុច $M$ មកលើអ័ក្ស $\overrightarrow{Ox}$ និង $\overrightarrow{Oy}$

បើ $M$ ផ្លាស់ទីមក $M$ តាមមុំ $\alpha$ នោះ $P$ និង $Q$ ក៏ផ្លាស់ទីមក $P'$ និង $Q'$ តាមមុំ $\alpha$ ដែរ

តាមរូប បើគេយកកូអរដោនេ $P'(x\cos\alpha\,,\,x\sin\alpha)$ និង $P'(-y\sin\alpha\,,\,y\cos\alpha)$

ចំពោះចតុកោណ $OP'M'Q'$ គេមាន $\overrightarrow{OM'}=\overrightarrow{OP'}+\overrightarrow{OQ'}$

ដោយ $\overrightarrow{OM'}=x'\vec{i}+y'\vec{j}$ និង

$\overrightarrow{OP'}+\overrightarrow{OQ'}=\left(x\cos\alpha\vec{i}+x\sin\alpha\vec{j}\right)+\left(-y\sin\alpha\vec{i}+y\cos\alpha\vec{j}\right)$

គេបាន $x'\vec{i}+y'\vec{j}=\left(x\cos\alpha\vec{i}+x\sin\alpha\vec{j}\right)+\left(-y\sin\alpha\vec{i}+y\cos\alpha\vec{j}\right)$

$=\left(x\cos\alpha-y\sin\alpha\right)\vec{i}+\left(x\sin\alpha+y\cos\alpha\right)\vec{j}$

ទាញបាន $\begin{cases}x'=x\cos\alpha-y\sin\alpha\\y'=x\sin\alpha+y\cos\alpha\end{cases}$ ឬ $\begin{cases}x'=\cos\alpha\cdot x-\sin\alpha\cdot y\\y'=\sin\alpha\cdot x+\cos\alpha\cdot y\end{cases}$

គេអាចសរសេរជាទម្រង់ម៉ាទ្រីស នៃបំលែងវិលមុំ $\alpha$ ដែលមាន $O$ ជាផ្ចិត គឺ $\Re(0,\alpha):\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}\cos\alpha & -\sin\alpha\\\sin\alpha & \cos\alpha\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$

ដូចនេះ: រូបមន្តបំលែងវិលបំលែងវិលនៃមុំ $\alpha$ គឺ: $\Re(0,\alpha):\begin{bmatrix}x'\\y'\end{bmatrix}=\begin{bmatrix}\cos\alpha & -\sin\alpha\\\sin\alpha & \cos\alpha\end{bmatrix}\begin{bmatrix}x\\y\end{bmatrix}$ ត្រូវបានបង្ហាញ ។

# ការស្រាយបញ្ជាក់លើមេរៀន ធរណីមាត្រក្នុងលំហ

1. ស្រាយបញ្ជាក់ថា បើគេមានវ៉ិចទ័រ $\vec{u}=(x\,,\,y\,,\,z)$ ផ្គុំជាមួយអ័ក្ស $ox$ , $oy$ និង $oz$ បានមុំរៀងគ្នា $\alpha$ , $\beta$ និង $\gamma$ នោះគេបាន $\cos^2\alpha+\cos^2\beta+\cos^2\gamma=1$ ។
2. បង្ហាញថា ចំពោះគ្រប់វ៉ិចទ័រ $\vec{u}$ គេបាន $\vec{u}^2=|\vec{u}|^2$ ។
3. ស្រាយបញ្ជាក់ថា $\overrightarrow{AB}\cdot\overrightarrow{AC}=AB\cdot AH$ ដែល $H$ ជាចំណោលកែងនៃ $C$ លើ $\overrightarrow{AB}$ ។
4. ស្រាយបញ្ជាក់ថា៖

   ក. $\vec{u}\cdot\vec{v}=\vec{v}\cdot\vec{u}$ ខ. $\vec{u}\perp\vec{v}\Leftrightarrow\vec{u}\cdot\vec{v}=0$ ដែល $\vec{u}\neq\vec{0}\,,\vec{v}\neq\vec{0}$

   គ. $(m\vec{u})\cdot\vec{v}=m(\vec{u}\cdot\vec{v})$ ឃ. $|\vec{u}\cdot\vec{v}|\le|\vec{u}|\cdot|\vec{v}|$ (វិសមភាពកូស៊ី)

   ង. $|\vec{u}+\vec{v}|\le|\vec{u}|+|\vec{v}|$ (វិសមភាពត្រីកោណ) ។
5. ស្រាយបញ្ជាក់ថា បើ $\vec{u}=(x\,,\,y\,,\,z)$ និង $\vec{v}=(x'\,,\,y'\,,\,z')$ នោះគេបាន $\vec{u}\cdot\vec{v}=xx'+yy'+zz'$ ។
6. ស្រាយបញ្ជាក់ថា ចំពោះគ្រប់ $\vec{u}=(x\,,\,y\,,\,z)$ ក្នុងគោលណរម៉ាល់ $(\vec{i}\,,\,\vec{j}\,,\,\vec{k})$ នោះគេបាន ៖

   $\vec{u}\cdot\vec{i}=x$ , $\vec{u}\cdot\vec{j}=y$ , $\vec{u}\cdot\vec{k}=z$ ។
7. ស្រាយបញ្ជាក់ថា ប្រវែងនៃវ៉ិចទ័រ $\vec{u}=(x\,,\,y\,,\,z)$ គឺ $|\vec{u}|=\sqrt{x^2+y^2+z^2}$ ។
8. ស្រាយបញ្ជាក់ថា បើ $\vec{u}=(x\,,\,y\,,\,z)$ និង $\vec{v}=(x'\,,\,y'\,,\,z')$ ផ្គុំបានមុំ $\theta$ នោះគេបាន ៖

   $$\cos\theta=\frac{\vec{u}\cdot\vec{v}}{|\vec{u}|\cdot|\vec{v}|}=\frac{xx'+yy'+zz'}{\sqrt{x^2+y^2+z^2}\cdot\sqrt{x'^2+y'^2+z'^2}}$$ ។
9. ស្រាយបញ្ជាក់ថា បើ $\overrightarrow{AB}=\vec{a}$ , $\overrightarrow{AC}=\vec{b}$ ជាជ្រុងនៃត្រីកោណ $ABC$ នោះវាមានផ្ទៃ $S=\frac{1}{2}\sqrt{|\vec{a}|^2\cdot|\vec{b}|^2-(\vec{a}\vec{b})^2}$ ។
10. ស្រាយបញ្ជាក់ថា ៖

    ក. $\vec{u}\cdot(\vec{v}+\vec{w})=\vec{u}\cdot\vec{v}+\vec{u}\cdot\vec{w}$ ខ. $(\vec{u}+\vec{v})\cdot\vec{w}=\vec{u}\cdot\vec{w}+\vec{v}\cdot\vec{w}$

    គ. $\vec{u}\cdot(m\vec{v})=m(\vec{u}\cdot\vec{v})$ ឃ. $(m\vec{u})\cdot\vec{v}=m(\vec{u}\cdot\vec{v})$ ។
11. ស្រាយបញ្ជាក់ថា ចម្ងាយរវាងពីរចំណុច $P(x_1\,,\,y_1\,,\,z_1)$ និង $Q(x_2\,,\,y_2\,,\,z_2)$ កំណត់ដោយ

    $d(P\,,\,Q)=PQ=\sqrt{(x_2-x_1)^2+(y_2-y_1)^2+(z_2-z_1)^2}$ ។
12. ស្រាយបញ្ជាក់ថា សមីការស្វ៊ែដែលមានផ្ចិត $C(a\,,\,b\,,\,c)$ និងកាំ $r$ កំណត់ដោយ $(x-a)^2+(y-b)^2+(z-c)^2=r^2$ ។
13. ស្រាយបញ្ជាក់ថា វិសមីការតំបន់ផ្នែកខាងក្នុងនៃស្វ៊ែ ដែលមានផ្ចិតនៅត្រង់ $I(a\,,\,b\,,\,c)$ និងមានកាំ $r$ គឺ :

    $\left\{(x\,,\,y\,,\,z)/(x-a)^2+(y-b)^2+(z-c)^2<r^2\right\}$ ។
14. ស្រាយបញ្ជាក់ថា វិសមីការតំបន់ផ្នែកខាងក្រៅនៃស្វ៊ែ ដែលមានផ្ចិតនៅត្រង់ $I(a\,,\,b\,,\,c)$ និងមានកាំ $r$ គឺ :

    $\left\{(x\,,\,y\,,\,z)/(x-a)^2+(y-b)^2+(z-c)^2>r^2\right\}$ ។
15. ស្រាយបញ្ជាក់ថា វ៉ិចទ័រទីតាំង $\vec{c}$ នៃចំណុច $C$ ចែកអង្កត់ $[AB]$ ខាងក្នុងតាមផលធៀប $m:n$ គឺ $\vec{c}=\dfrac{m\vec{b}+n\vec{a}}{m+n}$ ។
16. ស្រាយបញ្ជាក់ថា វ៉ិចទ័រទីតាំង $\vec{d}$ នៃចំណុច $D$ ចែកអង្កត់ $[AB]$ ខាងក្រៅតាមផលធៀប $m:n$ គឺ $\vec{d}=\dfrac{m\vec{b}-n\vec{a}}{m-n}$ ។

17. ស្រាយបញ្ជាក់ថា វ៉ិចទ័រទីតាំង $\vec{g}=\dfrac{\vec{a}+\vec{b}+\vec{c}}{3}$ នៃចំណុច $G$ ដែល $G$ ជាទីប្រជុំទម្ងន់របស់ត្រីកោណ $ABC$ មានកំពូល $A(\vec{a})$ , $B(\vec{b})$ និង $C(\vec{c})$ ។

18. គេឱ្យបួនចំណុច $O$ , $A$ , $B$ , $C$ នៅក្នុងលំហ ។ បង្ហាញថា បើ $[OB]\perp[CA]$ និង $[OC]\perp[AB]$ នោះគេបាន $[OA]\perp[BC]$ ។

19. គេឱ្យចតុមុខនិយ័ត $ABCD$ មួយក្នុងលំហ ដែល $\overrightarrow{AB}=\vec{b}$ , $\overrightarrow{AC}=\vec{c}$ , $\overrightarrow{AD}=\vec{d}$ ។ បង្ហាញថា $[AB]\perp[CD]$ ។

20. បង្ហាញថា បើបួនចំណុច $A, B, C$ និង $D$ នៅក្នុងលំហ ដែលផ្ទៀងផ្ទាត់ $AB^2+CD^2=AC^2+BD^2$ នោះ $[AD]\perp[BC]$ ។

21. ស្រាយបញ្ជាក់ថា សមីការបន្ទាត់ក្នុងលំហ កាត់តាមចំណុច $P(x_0\ , y_0\ , z_0)$ និងមានវ៉ិចទ័រប្រាប់ទិស $\vec{u}=(a\ , b\ , c)$ មានសមីការ ប៉ារ៉ាម៉ែត្រ $\begin{cases} x=x_0+at \\ y=y_0+bt \\ z=z_0+ct \end{cases}$ , $t\in\mathbb{R}$ រួចទាញបញ្ជាក់ថា $\dfrac{x-x_0}{a}=\dfrac{y-y_0}{b}=\dfrac{z-z_0}{c}$ ដែលគេហៅថា សមីការឆ្លុះ ។

22. ស្រាយបញ្ជាក់ថា សមីការនៃបន្ទាត់ដែលកាត់តាមពីរចំណុច $P(x_0\ , y_0\ , z_0)$ និង ចំណុច $P_1(x_1\ , y_1\ , z_1)$ គឺ $\dfrac{x-x_0}{x_1-x_0}=\dfrac{y-y_0}{y_1-y_0}=\dfrac{z-z_0}{z_1-z_0}$ ។

23. ស្រាយបញ្ជាក់ថា សមីការប្លង់ដែលកាត់តាមចំណុច $P(x_0\ , y_0\ , z_0)$ និងមានវ៉ិចទ័រណរម៉ាល់ $\vec{n}=(a\ , b\ , c)$ មានសមីការគឺ $a(x-x_0)+b(y-y_0)+c(z-z_0)=0$ ។

24. ក. បង្ហាញថា ប្លង់ $(xoy)$ មានសមីការ $z=0$ ។

ខ. បង្ហាញថា ប្លង់ $(xoz)$ មានសមីការ $y=0$ ។

គ. បង្ហាញថា ប្លង់ $(yoz)$ មានសមីការ $x=0$ ។

25. ស្រាយបញ្ជាក់ថា ចម្ងាយពីចំណុច $P_0(x_0\ , y_0\ , z_0)$ ទៅប្លង់ $\alpha$ : $ax+by+cz+d=0$ គឺ $d(P_0\ , \alpha)=\dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$ ។

# ការស្រាយបញ្ជាក់លើមេរៀន ធរណីមាត្រក្នុងលំហ

1. **ស្រាយបញ្ជាក់ថា** $\cos^2\alpha+\cos^2\beta+\cos^2\gamma=1$




គេមាន  គេមានវ៉ិចទ័រ $\vec{u}=(x\ ,\ y\ ,\ z)$ ផ្គុំជាមួយអ័ក្ស $ox\ ,\ oy$ និង $oz$ បានមុំរៀងគ្នា $\alpha\ ,\ \beta$ និង $\gamma$

គេយក  $P$ ជាចំណុចមួយក្នុងលំហ ដែល $\vec{u}=\overrightarrow{OP}$

គេបាន  $\left|\overrightarrow{OP}\right|^2=x^2+y^2+z^2$

ត្រីកោណកែង $OxP$ មាន $\cos\alpha=\dfrac{x}{\left|\overrightarrow{OP}\right|}\ \Rightarrow\ x=\left|\overrightarrow{OP}\right|\cdot\cos\alpha$

ត្រីកោណកែង $OyP$ មាន $\cos\beta=\dfrac{y}{\left|\overrightarrow{OP}\right|}\ \Rightarrow\ y=\left|\overrightarrow{OP}\right|\cdot\cos\beta$

ត្រីកោណកែង $OzP$ មាន $\cos\gamma=\dfrac{z}{\left|\overrightarrow{OP}\right|}\ \Rightarrow\ z=\left|\overrightarrow{OP}\right|\cdot\cos\gamma$

នាំឱ្យ  $\left|\overrightarrow{OP}\right|^2=\left(\left|\overrightarrow{OP}\right|\cdot\cos\alpha\right)^2+\left(\left|\overrightarrow{OP}\right|\cdot\cos\beta\right)^2+\left(\left|\overrightarrow{OP}\right|\cdot\cos\gamma\right)^2$

$\left|\overrightarrow{OP}\right|^2=\left|\overrightarrow{OP}\right|^2\left(\cos^2\alpha+\cos^2\beta+\cos^2\gamma\right)$ នោះ $\cos^2\alpha+\cos^2\beta+\cos^2\gamma=1$

ដូចនេះ  $\boxed{\cos^2\alpha+\cos^2\beta+\cos^2\gamma=1}$ ត្រូវបានស្រាយបញ្ជាក់ ។

2. **បង្ហាញថា ចំពោះគ្រប់វ៉ិចទ័រ $\vec{u}$ គេបាន** $\vec{u}^2=\left|\vec{u}\right|^2$

តាមនិយមន័យផលគុណស្កាលែ $\vec{u}\cdot\vec{v}=\left|\vec{u}\right|\cdot\left|\vec{v}\right|\cdot\cos\theta$ ដែល $\theta$ ជាមុំផ្គុំរវាង $\vec{u}$ និង $\vec{v}$

ដោយមុំផ្គុំរវាង $\vec{u}$ និង $\vec{u}$ គឺ $\theta=0^\circ$ (វ៉ិចទ័រត្រួតស៊ីគ្នា)

គេបាន  $\vec{u}\cdot\vec{u}=\left|\vec{u}\right|\cdot\left|\vec{u}\right|\cdot\cos0^\circ$ នោះ $\vec{u}^2=\left|\vec{u}\right|^2$

ដូចនេះ  $\boxed{\vec{u}^2=\left|\vec{u}\right|^2}$ ត្រូវបានស្រាយបញ្ជាក់ ។

3. **ស្រាយបញ្ជាក់ថា** $\overrightarrow{AB}\cdot\overrightarrow{AC}=AB\cdot AH$ **ដែល** $H$ **ជាចំណោលកែងនៃ** $C$ **លើ** $\overrightarrow{AB}$




តាមនិយមន័យផលគុណស្កាលែ $\overrightarrow{AB}\cdot\overrightarrow{AC}=\left|\overrightarrow{AB}\right|\cdot\left|\overrightarrow{AC}\right|\cdot\cos\theta$

ដោយ  $AB=\left|\overrightarrow{AB}\right|$ និង $AC=\left|\overrightarrow{AC}\right|$

នាំឱ្យ  $\overrightarrow{AB}\cdot\overrightarrow{AC}=AB\cdot AC\cdot\cos\theta \quad (1)$

ក្នុងត្រីកោណកែង $AHC$ មាន $\cos\theta=\dfrac{AH}{AC}$ នោះ $AH=AC\cdot\cos\theta$

គេបាន  $(1):\ \overrightarrow{AB}\cdot\overrightarrow{AC}=AB\cdot AH$

ដូចនេះ  $\boxed{\overrightarrow{AB}\cdot\overrightarrow{AC}=AB\cdot AH}$ ត្រូវបានស្រាយបញ្ជាក់ ។

4. ក. ស្រាយបញ្ជាក់ថា $\vec{u}\cdot\vec{v}=\vec{v}\cdot\vec{u}$

គេតាង $\theta$ ជាមុំផ្ចិតរវាង $\vec{u}$ និង $\vec{v}$

នាំឱ្យ មុំផ្ចិតរវាង $\vec{v}$ និង $\vec{u}$ គឺ $-\theta$

តាមនិយមន័យផលគុណស្កាលែ $\vec{u}\cdot\vec{v}=|\vec{u}|\cdot|\vec{v}|\cdot\cos\theta$ $(1)$

ម្យ៉ាងទៀត $\vec{v}\cdot\vec{u}=|\vec{v}|\cdot|\vec{u}|\cdot\cos(-\theta)=|\vec{u}|\cdot|\vec{v}|\cdot\cos\theta$ $(2)$ (ព្រោះ $|\vec{u}|\cdot|\vec{v}|=|\vec{v}|\cdot|\vec{u}|$ និង $\cos(-\theta)=\cos\theta$ មុំផ្ទុយ)

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ នាំឱ្យ $\vec{u}\cdot\vec{v}=\vec{v}\cdot\vec{u}$

ដូចនេះ $\boxed{\vec{u}\cdot\vec{v}=\vec{v}\cdot\vec{u}\text{ ត្រូវបានស្រាយបញ្ជាក់}}$ ។

**ខ. ស្រាយបញ្ជាក់ថា** $\vec{u}\perp\vec{v}\Leftrightarrow\vec{u}\cdot\vec{v}=0$ **ដែល** $\vec{u}\neq\vec{0}\,,\,\vec{v}\neq\vec{0}$

តាមនិយមន័យផលគុណស្កាលែ $\vec{u}\cdot\vec{v}=|\vec{u}|\cdot|\vec{v}|\cdot\cos\theta$ ដែល $\theta$ ជាមុំផ្ចិតរវាង $\vec{u}$ និង $\vec{v}$

ដោយ $\vec{u}\perp\vec{v}$ នោះ $\theta=90^\circ$

គេបាន $\vec{u}\cdot\vec{v}=|\vec{u}|\cdot|\vec{v}|\cdot\cos 90^\circ=|\vec{u}|\cdot|\vec{v}|\cdot 0=0$

ម្យ៉ាងទៀត $\vec{u}\neq\vec{0}\,,\,\vec{v}\neq\vec{0}$ , $\vec{u}\cdot\vec{v}=0=|\vec{u}|\cdot|\vec{v}|\cdot 0=|\vec{u}|\cdot|\vec{v}|\cdot\cos 90^\circ$ នោះ $\vec{u}\perp\vec{v}$

ដូចនេះ $\boxed{\vec{u}\perp\vec{v}\Leftrightarrow\vec{u}\cdot\vec{v}=0\text{ ត្រូវបានស្រាយបញ្ជាក់}}$ ។

**គ. ស្រាយបញ្ជាក់ថា** $(m\vec{u})\cdot\vec{v}=m(\vec{u}\cdot\vec{v})$ **ដែល** $m$ **ជាចំនួនពិត**

បើ $\vec{u}$ ជាវ៉ិចទ័រមួយ នោះ $m\vec{u}$ ជាវ៉ិចទ័រថ្មីមួយទៀត ដែល $\vec{u}\,//\,(m\vec{u})$ និង $|m\vec{u}|=|m||\vec{u}|$

គេតាង $\theta$ ជាមុំផ្ចិតរវាង $\vec{u}$ និង $\vec{v}$ នោះ $\vec{u}\cdot\vec{v}=|\vec{u}|\cdot|\vec{v}|\cdot\cos\theta$

គេបាន •បើ $m>0$ នោះ $(m\vec{u})$ ផ្ចិតនិង $\vec{v}$ បានមុំ $\theta$

$$(m\vec{u})\cdot\vec{v}=|m\vec{u}|\cdot|\vec{v}|\cdot\cos\theta=|m|\cdot|\vec{u}|\cdot|\vec{v}|\cdot\cos\theta=m(\vec{u}\cdot\vec{v})$$

•បើ $m<0$ នោះ $(m\vec{u})$ ផ្ចិតនិង $\vec{v}$ បានមុំ $180^\circ-\theta$

$$(m\vec{u})\cdot\vec{v}=|m\vec{u}|\cdot|\vec{v}|\cdot\cos(180^\circ-\theta)=|m|\cdot|\vec{u}|\cdot|\vec{v}|\cdot(-\cos\theta)$$
$$=-m\cdot|\vec{u}|\cdot|\vec{v}|\cdot(-\cos\theta)=m\cdot|\vec{u}|\cdot|\vec{v}|\cdot\cos\theta=m(\vec{u}\cdot\vec{v})$$

•បើ $m=0$ នោះ $(m\vec{u})\cdot\vec{v}=\vec{0}\cdot\vec{v}=0=0\cdot|\vec{u}|\cdot|\vec{v}|\cdot\cos\theta=m(\vec{u}\cdot\vec{v})$

ឃើញថា គ្រប់ចំនួនពិតនៃ $m$ គេបាន $(m\vec{u})\cdot\vec{v}=m(\vec{u}\cdot\vec{v})$

ដូចនេះ $\boxed{(m\vec{u})\cdot\vec{v}=m(\vec{u}\cdot\vec{v})\text{ ត្រូវបានស្រាយបញ្ជាក់}}$ ។

**ឃ.ស្រាយបញ្ជាក់ថា** $|\vec{u}\cdot\vec{v}|\leq|\vec{u}|\cdot|\vec{v}|$ **(វិសមភាពកូស៊ី)**

តាមនិយមន័យផលគុណស្កាលែ $\vec{u}\cdot\vec{v}=|\vec{u}|\cdot|\vec{v}|\cdot\cos\theta$

គេបាន $|\vec{u}\cdot\vec{v}|=\big||\vec{u}|\cdot|\vec{v}|\cdot\cos\theta\big|=\big||\vec{u}|\big|\cdot\big||\vec{v}|\big|\cdot|\cos\theta|=|\vec{u}|\cdot|\vec{v}|\cdot|\cos\theta|$ $(1)$

ដោយ $-1\leq\cos\theta\leq 1\Rightarrow|\cos\theta|\leq 1$ គុណអង្គទាំងពីរនឹង $|\vec{u}|\cdot|\vec{v}|$ គេបាន $|\vec{u}|\cdot|\vec{v}|\cdot|\cos\theta|\leq|\vec{u}|\cdot|\vec{v}|$ $(2)$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ គេបាន $|\vec{u}\cdot\vec{v}|\leq|\vec{u}|\cdot|\vec{v}|$

ដូចនេះ $\boxed{|\vec{u}\cdot\vec{v}|\leq|\vec{u}|\cdot|\vec{v}|\text{ ត្រូវបានស្រាយបញ្ជាក់}}$ ។

ង. ស្រាយបញ្ជាក់ថា $|\vec{u}+\vec{v}| \le |\vec{u}|+|\vec{v}|$ (វិសមភាពត្រីកោណ)

តាមវិសមភាពក្នុងត្រីកោណ $ABC$




គេបាន $AC < AB + BC$ ឬ $|\vec{u}+\vec{v}| < |\vec{u}|+|\vec{v}|$ $(1)$

ព្រោះ $AC = |\vec{u}+\vec{v}|$ , $AB = |\vec{u}|$ , $BC = |\vec{v}|$

ម្យ៉ាងទៀត ជ្រុងត្រីកោណមិនអាចសូន្យ ប៉ុន្តែវ៉ិចទ័រអាចសូន្យ

បើ $\vec{u} = \vec{v} = \vec{0}$ គេបាន $|\vec{u}+\vec{v}| = |\vec{u}|+|\vec{v}|$ $(2)$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ នាំឱ្យ $|\vec{u}+\vec{v}| \le |\vec{u}|+|\vec{v}|$

ដូចនេះ $|\vec{u}+\vec{v}| \le |\vec{u}|+|\vec{v}|$ ត្រូវបានស្រាយបញ្ជាក់ ។

5. **ស្រាយបញ្ជាក់ថា** $\vec{u}\cdot\vec{v} = xx'+yy'+zz'$

គេមាន $\vec{u} = (x , y , z)$ និង $\vec{v} = (x' , y' , z')$

គេបាន $\vec{u} = x\vec{i} + y\vec{j} + z\vec{k}$ និង $\vec{v} = x'\vec{i} + y'\vec{j} + z'\vec{k}$

នាំឱ្យ $\vec{u}\cdot\vec{v} = \left(x\vec{i} + y\vec{j} + z\vec{k}\right)\cdot\left(x'\vec{i} + y'\vec{j} + z'\vec{k}\right)$

$= xx'\vec{i}^{\,2} + xy'\vec{i}\cdot\vec{j} + xz'\vec{i}\cdot\vec{k} + x'y\vec{j}\cdot\vec{i} + yy'\vec{j}^{\,2} + yz'\vec{j}\cdot\vec{k} + x'z\vec{k}\cdot\vec{i} + y'z\vec{k}\cdot\vec{j} + zz'\vec{k}^{\,2}$

ដោយ $\vec{i}^{\,2} = \vec{j}^{\,2} = \vec{k}^{\,2} = 1$ និង $\vec{i}\cdot\vec{j} = \vec{j}\cdot\vec{i} = 0$ , $\vec{i}\cdot\vec{k} = \vec{k}\cdot\vec{i} = 0$ , $\vec{j}\cdot\vec{k} = \vec{k}\cdot\vec{i} = 0$

ព្រោះ $\vec{i}$ , $\vec{j}$ , $\vec{k}$ ជាវ៉ិចទ័រឯកតា ហើយ $\vec{i}\perp\vec{j}$ , $\vec{i}\perp\vec{k}$ , $\vec{j}\perp\vec{k}$ (ដែល $\cos 90° = \cos(-90°) = 0$)

គេបាន $\vec{u}\cdot\vec{v} = xx'(1) + xy'(0) + xz'(0) + x'y(0) + yy'(1) + yz'(0) + x'z(0) + y'z(0) + zz'(1)$

$= xx'+yy'+zz'$

ដូចនេះ រូបមន្ត $\vec{u}\cdot\vec{v} = xx'+yy'+zz'$ ត្រូវបានស្រាយបញ្ជាក់ ។

6. **ស្រាយបញ្ជាក់ថា** $\vec{u}\cdot\vec{i} = x$ , $\vec{u}\cdot\vec{j} = y$ , $\vec{u}\cdot\vec{k} = z$

គេមាន $\vec{u} = (x , y , z)$ និង $\vec{i} = (1 , 0 , 0)$ , $\vec{j} = (0 , 1 , 0)$ , $\vec{k} = (0 , 0 , 1)$

គេបាន $\vec{u}\cdot\vec{i} = (x)(1) + (y)(0) + (z)(0) = x$

$\vec{u}\cdot\vec{j} = (x)(0) + (y)(1) + (z)(0) = y$

$\vec{u}\cdot\vec{k} = (x)(0) + (y)(0) + (z)(1) = z$

ដូចនេះ $\vec{u}\cdot\vec{i} = x$ , $\vec{u}\cdot\vec{j} = y$ , $\vec{u}\cdot\vec{k} = z$ ត្រូវបានស្រាយបញ្ជាក់ ។

7. **➤របៀបទី១ : ស្រាយបញ្ជាក់ថា ប្រវែងនៃវ៉ិចទ័រ** $\vec{u} = (x , y , z)$ **គឺ** $|\vec{u}| = \sqrt{x^2+y^2+z^2}$

គេមាន $\vec{u}^{\,2} = |\vec{u}|^2$ បានស្រាយរួចលំហាត់លេខ 2

ម្យ៉ាងទៀត $\vec{u}^{\,2} = xx + yy + zz = x^2 + y^2 + z^2$

គេបាន $|\vec{u}|^2 = x^2 + y^2 + z^2$ នាំឱ្យ $|\vec{u}| = \sqrt{x^2+y^2+z^2}$ ព្រោះ $|\vec{u}| \ge 0$

ដូចនេះ រូបមន្ត $|\vec{u}| = \sqrt{x^2+y^2+z^2}$ ត្រូវបានស្រាយបញ្ជាក់ ។

➢របៀបទី២ : ស្រាយបញ្ជាក់ថា ប្រវែងនៃវ៉ិចទ័រ $\vec{u}=(x\ ,\ y\ ,\ z)$ គឺ $|\vec{u}|=\sqrt{x^2+y^2+z^2}$

គេតាង $\vec{u}=\overrightarrow{OP}$ នាំឱ្យ $|\vec{u}|=|\overrightarrow{OP}|=OP$

ក្នុងត្រីកោណកែង $OQP$ មាន $OP^2=OQ^2+PQ^2$

ដោយ $OQ^2=x^2+y^2$ និង $PQ^2=z^2$

គេបាន $OP^2=x^2+y^2+z^2$ ឬ $OP=\sqrt{x^2+y^2+z^2}$

នាំឱ្យ $|\vec{u}|=|\overrightarrow{OP}|=OP=\sqrt{x^2+y^2+z^2}$




ដូចនេះ រូបមន្ត $|\vec{u}|=\sqrt{x^2+y^2+z^2}$ ត្រូវបានស្រាយបញ្ជាក់ ។

8. ស្រាយបញ្ជាក់ថា $\cos\theta=\dfrac{\vec{u}\cdot\vec{v}}{|\vec{u}|\cdot|\vec{v}|}=\dfrac{xx'+yy'+zz'}{\sqrt{x^2+y^2+z^2}\cdot\sqrt{x'^2+y'^2+z'^2}}$

គេមាន $\vec{u}=(x\ ,\ y\ ,\ z)$ និង $\vec{v}=(x'\ ,\ y'\ ,\ z')$ ផ្គុំបានមុំ $\theta$

តាមនិយមន័យផលគុណស្កាលែ $\vec{u}\cdot\vec{v}=|\vec{u}|\cdot|\vec{v}|\cdot\cos\theta$ នាំឱ្យ $\cos\theta=\dfrac{\vec{u}\cdot\vec{v}}{|\vec{u}|\cdot|\vec{v}|}$

ដោយ $\vec{u}\cdot\vec{v}=xx'+yy'+zz'$ និង $|\vec{u}|=\sqrt{x^2+y^2+z^2}$ , $|\vec{v}|=\sqrt{x'^2+y'^2+z'^2}$

គេបាន $\cos\theta=\dfrac{\vec{u}\cdot\vec{v}}{|\vec{u}|\cdot|\vec{v}|}=\dfrac{xx'+yy'+zz'}{\sqrt{x^2+y^2+z^2}\cdot\sqrt{x'^2+y'^2+z'^2}}$

ដូចនេះ រូបមន្ត $\cos\theta=\dfrac{\vec{u}\cdot\vec{v}}{|\vec{u}|\cdot|\vec{v}|}=\dfrac{xx'+yy'+zz'}{\sqrt{x^2+y^2+z^2}\cdot\sqrt{x'^2+y'^2+z'^2}}$ ត្រូវបានស្រាយបញ្ជាក់ ។

9. ស្រាយបញ្ជាក់ថា ផ្ទៃត្រីកោណ $S=\dfrac{1}{2}\sqrt{|\vec{a}|^2\cdot|\vec{b}|^2-(\vec{a}\vec{b})^2}$

គេមាន $\overrightarrow{AB}=\vec{a}$ , $\overrightarrow{AC}=\vec{b}$ ជាជ្រុងនៃត្រីកោណ $ABC$




គេបាន $S_{ABC}=\dfrac{1}{2}\times$ បាត $\times$ កម្ពស់ ឬ $S_{ABC}=\dfrac{1}{2}\times AB\times CH$

ដោយ $AB=|\vec{a}|$ និង $CH=|\vec{b}|\cdot\sin\theta$

គេបាន $S_{ABC}=\dfrac{1}{2}\cdot|\vec{a}|\cdot|\vec{b}|\cdot\sin\theta$

ម្យ៉ាងទៀត $S=\dfrac{1}{2}\sqrt{|\vec{a}|^2\cdot|\vec{b}|^2-(\vec{a}\vec{b})^2}=\dfrac{1}{2}\sqrt{|\vec{a}|^2\cdot|\vec{b}|^2-(|\vec{a}|\cdot|\vec{b}|\cdot\cos\theta)^2}$

$=\dfrac{1}{2}\sqrt{|\vec{a}|^2\cdot|\vec{b}|^2-|\vec{a}|^2\cdot|\vec{b}|^2\cdot\cos^2\theta}=\dfrac{1}{2}\sqrt{|\vec{a}|^2\cdot|\vec{b}|^2(1-\cos^2\theta)}$

$=\dfrac{1}{2}\sqrt{|\vec{a}|^2\cdot|\vec{b}|^2\cdot\sin^2\theta}=\dfrac{1}{2}\cdot|\vec{a}|\cdot|\vec{b}|\cdot\sin\theta=S_{ABC}$

ដូចនេះ ផ្ទៃក្រឡាត្រីកោណ $ABC$ គឺ $S=\dfrac{1}{2}\sqrt{|\vec{a}|^2\cdot|\vec{b}|^2-(\vec{a}\vec{b})^2}$ ត្រូវបានស្រាយបញ្ជាក់ ។

10. ស្រាយបញ្ជាក់លក្ខណៈនៃផលគុណស្កាលែក្នុងលំហដូចខាងក្រោម ៖

ក. ស្រាយបញ្ជាក់ថា $\vec{u}\cdot(\vec{v}+\vec{w})=\vec{u}\cdot\vec{v}+\vec{u}\cdot\vec{w}$

គេតាង $\vec{u}=(u_1\ ,\ u_2\ ,\ u_3)$ , $\vec{v}=(v_1\ ,\ v_2\ ,\ v_3)$ និង $\vec{w}=(w_1\ ,\ w_2\ ,\ w_3)$

គេបាន $\vec{v}+\vec{w}=(v_1+w_1\ ,\ v_2+w_2\ ,\ v_3+w_3)$

នាំឱ្យ $\vec{u}\cdot(\vec{v}+\vec{w})=u_1(v_1+w_1)+u_2(v_2+w_2)+u_3(v_3+w_3)$

$=u_1v_1+u_1w_1+u_2v_2+u_2w_2+u_3v_3+u_3w_3$

$=(u_1v_1+u_2v_2+u_3v_3)+(u_1w_1+u_2w_2+u_3w_3)$

$=\vec{u}\cdot\vec{v}+\vec{u}\cdot\vec{w}$

ដូចនេះ | លក្ខណៈ $\vec{u}\cdot(\vec{v}+\vec{w})=\vec{u}\cdot\vec{v}+\vec{u}\cdot\vec{w}$ ត្រូវបានស្រាយបញ្ជាក់ | ។

ខ. ស្រាយបញ្ជាក់ថា $(\vec{u}+\vec{v})\cdot\vec{w}=\vec{u}\cdot\vec{w}+\vec{v}\cdot\vec{w}$

គេតាង $\vec{u}=(u_1\ ,\ u_2\ ,\ u_3)$ , $\vec{v}=(v_1\ ,\ v_2\ ,\ v_3)$ និង $\vec{w}=(w_1\ ,\ w_2\ ,\ w_3)$

គេបាន $\vec{u}+\vec{v}=(u_1+v_1\ ,\ u_2+v_2\ ,\ u_3+v_3)$

នាំឱ្យ $(\vec{u}+\vec{v})\cdot\vec{w}=(u_1+v_1)w_1+(u_2+v_2)w_2+(u_3+v_3)w_3$

$=u_1w_1+v_1w_1+u_2w_2+v_2w_2+u_3w_3+v_3w_3$

$=(u_1w_1+u_2w_2+u_3w_3)+(v_1w_1+v_2w_2+v_3w_3)$

$=\vec{u}\cdot\vec{w}+\vec{v}\cdot\vec{w}$

ដូចនេះ | លក្ខណៈ $\vec{u}\cdot(\vec{v}+\vec{w})=\vec{u}\cdot\vec{v}+\vec{u}\cdot\vec{w}$ ត្រូវបានស្រាយបញ្ជាក់ | ។

គ. ស្រាយបញ្ជាក់ថា $\vec{u}\cdot(m\vec{v})=m(\vec{u}\cdot\vec{v})$

គេតាង $\vec{u}=(u_1\ ,\ u_2\ ,\ u_3)$ , $\vec{v}=(v_1\ ,\ v_2\ ,\ v_3)$ នោះ $m\vec{v}=(mv_1\ ,\ mv_2\ ,\ mv_3)$

គេបាន $\vec{u}\cdot(m\vec{v})=u_1mv_1+u_2mv_2+u_3mv_3$

$=m(u_1v_1+u_2v_2+u_3v_3)$

$=m(\vec{u}\cdot\vec{v})$

ដូចនេះ | លក្ខណៈ $\vec{u}\cdot(m\vec{v})=m(\vec{u}\cdot\vec{v})$ ត្រូវបានស្រាយបញ្ជាក់ | ។

ឃ. ស្រាយបញ្ជាក់ថា $(m\vec{u})\cdot\vec{v}=m(\vec{u}\cdot\vec{v})$

គេតាង $\vec{u}=(u_1\ ,\ u_2\ ,\ u_3)$ , $\vec{v}=(v_1\ ,\ v_2\ ,\ v_3)$ នោះ $m\vec{u}=(mu_1\ ,\ mu_2\ ,\ mu_3)$

គេបាន $(m\vec{u})\cdot\vec{v}=mu_1v_1+mu_2v_2+mu_3v_3$

$=m(u_1v_1+u_2v_2+u_3v_3)$

$=m(\vec{u}\cdot\vec{v})$

ដូចនេះ | លក្ខណៈ $(m\vec{u})\cdot\vec{v}=m(\vec{u}\cdot\vec{v})$ ត្រូវបានស្រាយបញ្ជាក់ | ។

11. **ស្រាយបញ្ជាក់ថា ចម្ងាយរវាងពីរចំណុច** $d(P\,,\,Q)=PQ=\sqrt{(x_2-x_1)^2+(y_2-y_1)^2+(z_2-z_1)^2}$




គេមាន ពីរចំណុច $P(x_1\,,\,y_1\,,\,z_1)$ និង $Q(x_2\,,\,y_2\,,\,z_2)$

ក្នុងត្រីកោណកែង $PQR$ តាមពីតាគ័រ $PQ^2=PR^2+QR^2$

ដែល $PR^2=AB^2=(x_2-x_1)^2+(y_2-y_1)^2$

ហើយ $QR^2=(z_2-z_1)^2$

គេបាន $PQ^2=(x_2-x_1)^2+(y_2-y_1)^2+(z_2-z_1)^2$

នាំឱ្យ $PQ=\sqrt{(x_2-x_1)^2+(y_2-y_1)^2+(z_2-z_1)^2}$

គេតាង $d=PQ$ (ព្រោះ $d=$ distance $=$ ចម្ងាយ)

គេសរសេរ $d=PQ=\sqrt{(x_2-x_1)^2+(y_2-y_1)^2+(z_2-z_1)^2}$

ដូចនេះ: | ចម្ងាយ $d(P\,,\,Q)=PQ=\sqrt{(x_2-x_1)^2+(y_2-y_1)^2+(z_2-z_1)^2}$ ត្រូវបានស្រាយបញ្ជាក់ | ។

12. **ស្រាយបញ្ជាក់ថា សមីការស្វ៊ែកំណត់ដោយ** $(x-a)^2+(y-b)^2+(z-c)^2=r^2$




គេមាន ស្វ៊ែដែលមានផ្ចិត $C(a\,,\,b\,,\,c)$ និងកាំ $r$

គេតាង $P(x\,,\,y\,,\,z)$ ជាចំណុចទូទៅនៅលើស្វ៊ែ

តាមនិយមន័យស្វ៊ែ គេបាន $CP^2=r^2$

តាមរូបមន្ត ចម្ងាយ $CP^2=(x-a)^2+(y-b)^2+(z-c)^2$

គេបាន $(x-a)^2+(y-b)^2+(z-c)^2=r^2$

ដូចនេះ: | សមីការស្វ៊ែ $(x-a)^2+(y-b)^2+(z-c)^2=r^2$ ត្រូវបានស្រាយបញ្ជាក់ | ។

13. **ស្រាយបញ្ជាក់ថា វិសមីការតំបន់ផ្នែកខាងក្នុងនៃស្វ៊ែ គឺ :** $\left\{(x\,,\,y\,,\,z)/(x-a)^2+(y-b)^2+(z-c)^2<r^2\right\}$




គេមាន ស្វ៊ែផ្ចិត $I(a\,,\,b\,,\,c)$ និងមានកាំ $r$

តាមនិយមន័យ វិសមីការតំបន់ផ្នែកខាងក្នុងនៃស្វ៊ែគឺ

ចំណុចដែលមានចម្ងាយពីផ្ចិតតូចជាងកាំ

គេបាន $IP<r$ ឬ $IP^2<r^2$

តាមរូបមន្ត ចម្ងាយពីរចំណុច $IP^2=(x-a)^2+(y-b)^2+(z-c)^2$

នាំឱ្យ $(x-a)^2+(y-b)^2+(z-c)^2<r^2$

ដូចនេះ: | វិសមីការតំបន់ផ្នែកខាងក្នុងនៃស្វ៊ែគឺ : $\left\{(x\,,\,y\,,\,z)/(x-a)^2+(y-b)^2+(z-c)^2<r^2\right\}$ | ។

14. **ស្រាយបញ្ជាក់ថា វិសមីការតំបន់ផ្នែកខាងក្រៅនៃស្វ៊ែ គឺ :** $\left\{(x, y, z) / (x-a)^2+(y-b)^2+(z-c)^2>r^2\right\}$




គេមាន ស្វ៊ែផ្ចិត $I(a, b, c)$ និងមានកាំ $r$

តាមនិយមន័យ វិសមីការតំបន់ផ្នែកខាងក្រៅនៃស្វ៊ែគឺ ចំណុចដែលមានចម្ងាយពីផ្ចិតធំជាងកាំ

គេបាន $IP>r$ ឬ $IP^2>r^2$

តាមរូបមន្ត ចម្ងាយពីរចំណុច $IP^2=(x-a)^2+(y-b)^2+(z-c)^2$

នាំឱ្យ $(x-a)^2+(y-b)^2+(z-c)^2>r^2$

ដូចនេះ: **វិសមីការតំបន់ផ្នែកខាងក្រៅនៃស្វ៊ែគឺ : $\left\{(x, y, z) / (x-a)^2+(y-b)^2+(z-c)^2>r^2\right\}$** ។

15. **ស្រាយបញ្ជាក់ថា** $\vec{c}=\dfrac{m\vec{b}+n\vec{a}}{m+n}$ **(វ៉ិចទ័រទីតាំងចែកក្នុង)**




គេមាន $\overrightarrow{AC}=\vec{c}-\vec{a}$ និង $\overrightarrow{AB}=\vec{b}-\vec{a}$

ផលធៀប $m:n$ មានន័យថា $\dfrac{AC}{m}=\dfrac{AB}{m+n}$ នោះ $\overrightarrow{AC}=\dfrac{m}{m+n}\overrightarrow{AB}$

គេបាន $\vec{c}-\vec{a}=\dfrac{m}{m+n}\left(\vec{b}-\vec{a}\right)$

នាំឱ្យ $\vec{c}=\dfrac{m}{m+n}\left(\vec{b}-\vec{a}\right)+\vec{a}=\dfrac{m\vec{b}-m\vec{a}+m\vec{a}+n\vec{a}}{m+n}=\dfrac{m\vec{b}+n\vec{a}}{m+n}$

ដូចនេះ: $\vec{c}=\dfrac{m\vec{b}+n\vec{a}}{m+n}$ ត្រូវបានស្រាយបញ្ជាក់ ។

16. **ស្រាយបញ្ជាក់ថា** $\vec{d}=\dfrac{m\vec{b}-n\vec{a}}{m-n}$ **(វ៉ិចទ័រទីតាំងចែកក្រៅ)**




យើងមាន $\overrightarrow{AD}=\vec{d}-\vec{a}$ និង $\overrightarrow{AB}=\vec{b}-\vec{a}$

ផលធៀប $m:n$ មានន័យថា $\dfrac{AD}{m}=\dfrac{AB}{m-n}$ នោះ: $\overrightarrow{AD}=\dfrac{m}{m-n}\overrightarrow{AB}$

យើងបាន $\vec{d}-\vec{a}=\dfrac{m}{m-n}\left(\vec{b}-\vec{a}\right)$

នាំឱ្យ $\vec{d}=\dfrac{m}{m-n}\left(\vec{b}-\vec{a}\right)+\vec{a}=\dfrac{m\vec{b}-m\vec{a}+m\vec{a}-n\vec{a}}{m-n}=\dfrac{m\vec{b}-n\vec{a}}{m-n}$

ដូចនេះ: $\vec{d}=\dfrac{m\vec{b}-n\vec{a}}{m-n}$ ត្រូវបានស្រាយបញ្ជាក់ ។

17. ស្រាយបញ្ជាក់ថា វ៉ិចទ័រទីតាំងនៃទីប្រជុំទម្ងន់ $\vec{g}=\dfrac{\vec{a}+\vec{b}+\vec{c}}{3}$




គេមាន កំពូល $A(\vec{a})$ , $B(\vec{b})$ និង $C(\vec{c})$ និង $G(\vec{g})$ ជាទីប្រជុំទម្ងន់

គេយក $D(\vec{d})$ ជាចំណុចកណ្ដាលនៃ $[BC]$

គេបាន $D(\vec{d})$ ចែកក្នុងនៃ $[BC]$ តាមផលធៀប $m:n=1:1$

គេបាន $\vec{d}=\dfrac{m\vec{c}+n\vec{b}}{m+n}=\dfrac{1\cdot\vec{c}+1\cdot\vec{b}}{1+1}=\dfrac{\vec{c}+\vec{b}}{2}=\dfrac{\vec{b}+\vec{c}}{2}$

ម្យ៉ាងទៀត $G(\vec{g})$ ជាចំណុចចែកក្នុងនៃមេដ្យាន $AD$ ខាងក្នុងតាម ផលធៀប $m:n$ ដោយយក $m=2\ ,n=1$

គេបាន $\vec{g}=\dfrac{m\vec{d}+n\vec{a}}{m+n}=\dfrac{2\left(\dfrac{\vec{b}+\vec{c}}{2}\right)+1\cdot\vec{a}}{2+1}=\dfrac{\vec{a}+\vec{b}+\vec{c}}{3}$

ដូចនេះ: វ៉ិចទ័រទីតាំងនៃទីប្រជុំទម្ងន់គឺ $\vec{g}=\dfrac{\vec{a}+\vec{b}+\vec{c}}{3}$ ត្រូវបានស្រាយបញ្ជាក់ ។

18. បង្ហាញថា $[OA]\perp[BC]$




គេមាន បួនចំណុច $O, A, B, C$ នៅក្នុងលំហ និងយក $O$ ជាគល់ $[OB]\perp[CA]$ និង $[OC]\perp[AB]$

ដោយ $[OB]\perp[CA]$ នោះ $\overrightarrow{OB}\cdot\overrightarrow{CA}=0$

នាំឱ្យ $\vec{b}\cdot(\vec{a}-\vec{c})=0$ ឬ $\vec{b}\cdot\vec{a}=\vec{b}\cdot\vec{c}\quad(1)$

ហើយ $[OC]\perp[AB]$ នោះ $\overrightarrow{OC}\cdot\overrightarrow{AB}=0$

នាំឱ្យ $\vec{c}\cdot(\vec{b}-\vec{a})=0$ ឬ $\vec{c}\cdot\vec{b}=\vec{c}\cdot\vec{a}\quad(2)$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ គេបាន $\vec{b}\cdot\vec{a}=\vec{c}\cdot\vec{a}$

នាំឱ្យ $\vec{c}\cdot\vec{a}-\vec{b}\cdot\vec{a}=0$ នោះ $\vec{a}\cdot(\vec{c}-\vec{b})=0$

គេបាន $\overrightarrow{OA}\cdot\overrightarrow{BC}=0$ នាំឱ្យ $\overrightarrow{OA}\perp\overrightarrow{BC}$ ឬ $[OA]\perp[BC]$

ដូចនេះ: បង្ហាញបានថា $[OA]\perp[BC]$ ។

19. **បង្ហាញថា** $[AB]\perp[CD]$

គេមាន ចតុមុខនិយ័ត $ABCD$ និង $\overrightarrow{AB}=\vec{b}$ , $\overrightarrow{AC}=\vec{c}$ , $\overrightarrow{AD}=\vec{d}$

គេយក $A$ ជាគល់




តាមរូប គេបាន $\overrightarrow{AB}\cdot\overrightarrow{CD}=\vec{b}\cdot(\vec{d}-\vec{c})=\vec{b}\cdot\vec{d}-\vec{b}\cdot\vec{c}$

តែ $\vec{b}\cdot\vec{d}=|\vec{b}|\cdot|\vec{d}|\cdot\cos 60^\circ$ និង $\vec{b}\cdot\vec{c}=|\vec{b}|\cdot|\vec{c}|\cdot\cos 60^\circ$

នាំឱ្យ $\vec{b}\cdot\vec{d}-\vec{b}\cdot\vec{c}=0$

ព្រោះ $ABCD$ ជាចតុមុខនិយ័ត ដែល $|\vec{b}|=|\vec{c}|=|\vec{d}|$

គេបាន $\overrightarrow{AB}\cdot\overrightarrow{CD}=0$ នោះ $\overrightarrow{AB}\perp\overrightarrow{CD}$ ឬ $[AB]\perp[CD]$

ដូចនេះ **បង្ហាញបានថា $[AB]\perp[CD]$** ។

20. **បង្ហាញថា** $[AD]\perp[BC]$

គេមាន បួនចំណុច $A, B, C$ និង $D$ នៅក្នុងលំហ ផ្ទៀងផ្ទាត់ $AB^2+CD^2=AC^2+BD^2$

គេតាង វ៉ិចទ័រទីតាំង $\vec{a}$ , $\vec{b}$ , $\vec{c}$ , $\vec{d}$ រៀងគ្នានៃចំណុច $A$ , $B$ , $C$ , $D$

ចំពោះ $AB^2+CD^2=AC^2+BD^2$

គេបាន $(\vec{b}-\vec{a})^2+(\vec{d}-\vec{c})^2=(\vec{c}-\vec{a})^2+(\vec{d}-\vec{b})^2$

$$\vec{b}^2-2\vec{b}\cdot\vec{a}+\vec{a}^2+\vec{d}^2-2\vec{d}\cdot\vec{c}+\vec{c}^2=\vec{c}^2-2\vec{c}\cdot\vec{a}+\vec{a}^2+\vec{d}^2-2\vec{d}\cdot\vec{b}+\vec{b}^2$$

$$-2\vec{b}\cdot\vec{a}-2\vec{d}\cdot\vec{c}=-2\vec{c}\cdot\vec{a}-2\vec{d}\cdot\vec{b}$$

$$\vec{b}\cdot\vec{a}+\vec{d}\cdot\vec{c}=\vec{c}\cdot\vec{a}+\vec{d}\cdot\vec{b}$$

$$\vec{b}\cdot\vec{a}-\vec{c}\cdot\vec{a}+\vec{d}\cdot\vec{c}-\vec{d}\cdot\vec{b}=0$$

$$-\vec{a}(\vec{c}-\vec{b})+\vec{d}\cdot(\vec{c}-\vec{b})=0$$

$$(\vec{c}-\vec{b})\cdot(\vec{d}-\vec{a})=0$$

$$\overrightarrow{BC}\cdot\overrightarrow{AD}=0$$

ដោយ $\overrightarrow{BC}\cdot\overrightarrow{AD}=0$ នាំឱ្យ $[BC]\perp[AD]$ ឬ $[AD]\perp[BC]$

ដូចនេះ **បង្ហាញបានថា $[AD]\perp[BC]$** ។

21. **ស្រាយបញ្ជាក់ថា សមីការបន្ទាត់ក្នុងលំហ មានសមីការប៉ារ៉ាម៉ែត្រ** $\begin{cases} x = x_0 + at \\ y = y_0 + bt \quad , t \in \mathbb{R} \\ z = z_0 + ct \end{cases}$




គេមាន បន្ទាត់កាត់តាមចំណុច $P(x_0 \, , y_0 \, , z_0)$

បន្ទាត់មានវ៉ិចទ័រប្រាប់ទិស $\vec{u} = (a \, , b \, , c)$

គេយក $Q(x \, , y \, , z)$ ជាចំណុចនៅលើបន្ទាត់

គេបាន $\overrightarrow{PQ} \parallel \vec{u}$ នោះ $\overrightarrow{PQ} = t\vec{u}$ , $t$ ជាចំនួនពិត

នាំឱ្យ $(x - x_0 \, , y - y_0 \, , z - z_0) = t(a, b \, , c)$

$(x - x_0 \, , y - y_0 \, , z - z_0) = (ta, tb \, , tc)$

ទាញបាន $\begin{cases} x - x_0 = at \\ y - y_0 = bt \\ z - z_0 = ct \end{cases} \Rightarrow \begin{cases} x = x_0 + at \\ y = y_0 + bt \\ z = z_0 + ct \end{cases}$

ដូចនេះ

| សមីការបន្ទាត់ក្នុងលំហ មានសមីការប៉ារ៉ាម៉ែត្រ $\begin{cases} x = x_0 + at \\ y = y_0 + bt \quad , t \in \mathbb{R} \\ z = z_0 + ct \end{cases}$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

**រួចទាញបញ្ជាក់ថា** $\dfrac{x - x_0}{a} = \dfrac{y - y_0}{b} = \dfrac{z - z_0}{c}$ **ដែលគេហៅថា សមីការឆ្លុះ**

គេមាន $\begin{cases} x - x_0 = at \\ y - y_0 = bt \\ z - z_0 = ct \end{cases} \Rightarrow \begin{cases} \dfrac{x - x_0}{a} = t \\ \dfrac{y - y_0}{b} = t \\ \dfrac{z - z_0}{c} = t \end{cases}$ ទាញបាន $\dfrac{x - x_0}{a} = \dfrac{y - y_0}{b} = \dfrac{z - z_0}{c} = t$ ដែល $a, b, c$ មិនសូន្យព្រមគ្នា

ដូចនេះ

| $\dfrac{x - x_0}{a} = \dfrac{y - y_0}{b} = \dfrac{z - z_0}{c}$ ដែលគេហៅថា សមីការឆ្លុះ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

✓**សម្គាល់** បើ $a = 0$ គេសរសេរ $x = x_0$ , $\dfrac{y - y_0}{b} = \dfrac{z - z_0}{c}$ ។ បើ $a = b = 0$ គេសរសេរ $x = x_0$ , $y = y_0$ , $\dfrac{z - z_0}{c} = t$ ។

22. **ស្រាយបញ្ជាក់ថា សមីការនៃបន្ទាត់ដែលកាត់តាមពីរចំណុច** $P$ **និង** $P_1$ **គឺ** $\dfrac{x - x_0}{x_1 - x_0} = \dfrac{y - y_0}{y_1 - y_0} = \dfrac{z - z_0}{z_1 - z_0}$

គេមាន $\dfrac{x - x_0}{a} = \dfrac{y - y_0}{b} = \dfrac{z - z_0}{c}$ ជាសមីការបន្ទាត់ក្នុងលំហ




ដោយ បន្ទាត់កាត់ចំណុច $P(x_0 \, , y_0 \, , z_0)$ និង ចំណុច $P_1(x_1 \, , y_1 \, , z_1)$

នាំឱ្យ បន្ទាត់មានវ៉ិចទ័រប្រាប់ទិស $\vec{u} = \overrightarrow{PP_1} = (x_1 - x_0 \, , y_1 - y_0 \, , z_1 - z_0)$

នោះ $a = x_1 - x_0$ , $b = y_1 - y_0$ , $c = z_1 - z_0$

គេបាន $\dfrac{x - x_0}{x_1 - x_0} = \dfrac{y - y_0}{y_1 - y_0} = \dfrac{z - z_0}{z_1 - z_0}$ ជាសមីការបន្ទាត់កាត់ចំណុច $P$ និង $P_1$

ដូចនេះ

| សមីការបន្ទាត់ $\dfrac{x - x_0}{x_1 - x_0} = \dfrac{y - y_0}{y_1 - y_0} = \dfrac{z - z_0}{z_1 - z_0}$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

23. ស្រាយបញ្ជាក់ថា សមីការប្លង់គឺ $a(x-x_0)+b(y-y_0)+c(z-z_0)=0$




គេមាន ប្លង់កាត់តាមចំណុច $P(x_0 , y_0 , z_0)$

ប្លង់មានវ៉ិចទ័រណរម៉ាល់ $\vec{n}=(a , b , c)$

ចំពោះ គ្រប់ចំណុច $Q(x , y , z)$ នៃប្លង់នោះ $\overrightarrow{PQ}\perp\vec{n}$

គេបាន $\vec{n}\cdot\overrightarrow{PQ}=0$ ដែល $\overrightarrow{PQ}=(x-x_0 , y-y_0 , z-z_0)$

នាំឱ្យ $a(x-x_0)+b(y-y_0)+c(z-z_0)=0$

ដូចនេះ ប្លង់មានសមីការស្តង់ដា $a(x-x_0)+b(y-y_0)+c(z-z_0)=0$ ត្រូវបានស្រាយបញ្ជាក់ ។

24. **ក. បង្ហាញថា ប្លង់ $(xoy)$ មានសមីការ $z=0$**

សមីការប្លង់ មានរាង $a(x-x_0)+b(y-y_0)+c(z-z_0)=0$

ដោយ ប្លង់ $(xoy)$ កាត់តាមគល់ $O(0 , 0 , 0)$ នោះ $x_0=0$ , $y_0=0$ , $z_0=0$

ប្លង់ $(xoy)$ មានវ៉ិចទ័រណរម៉ាល់ $\vec{k}$ (កែងនឹងអ័ក្សកូត) នោះ $a=0 , b=0 , c=1$

គេបាន ប្លង់ $(xoy)$ អាចសរសេរ $0(x-0)+0(y-0)+1(z-0)=0$ នាំឱ្យ $z=0$

ដូចនេះ ប្លង់ $(xoy)$ មានសមីការ $z=0$ ត្រូវបានស្រាយបញ្ជាក់ ។

**ខ. បង្ហាញថា ប្លង់ $(xoz)$ មានសមីការ $y=0$**

សមីការប្លង់ មានរាង $a(x-x_0)+b(y-y_0)+c(z-z_0)=0$

ដោយ ប្លង់ $(xoz)$ កាត់តាមគល់ $O(0 , 0 , 0)$ នោះ $x_0=0$ , $y_0=0$ , $z_0=0$

ប្លង់ $(xoz)$ មានវ៉ិចទ័រណរម៉ាល់ $\vec{j}$ (កែងនឹងអ័ក្សអរដោនេ) នោះ $a=0 , b=1 , c=0$

គេបាន ប្លង់ $(xoz)$ អាចសរសេរ $0(x-0)+1(y-0)+0(z-0)=0$ នាំឱ្យ $y=0$

ដូចនេះ ប្លង់ $(xoz)$ មានសមីការ $y=0$ ត្រូវបានស្រាយបញ្ជាក់ ។

**គ. បង្ហាញថា ប្លង់ $(yoz)$ មានសមីការ $x=0$**

សមីការប្លង់ មានរាង $a(x-x_0)+b(y-y_0)+c(z-z_0)=0$

ដោយ ប្លង់ $(yoz)$ កាត់តាមគល់ $O(0 , 0 , 0)$ នោះ $x_0=0$ , $y_0=0$ , $z_0=0$

ប្លង់ $(yoz)$ មានវ៉ិចទ័រណរម៉ាល់ $\vec{i}$ (កែងនឹងអ័ក្សអាប់ស៊ីស) នោះ $a=1 , b=0 , c=0$

គេបាន ប្លង់ $(yoz)$ អាចសរសេរ $1(x-0)+0(y-0)+0(z-0)=0$ នាំឱ្យ $x=0$

ដូចនេះ ប្លង់ $(yoz)$ មានសមីការ $x=0$ ត្រូវបានស្រាយបញ្ជាក់ ។

25. ស្រាយបញ្ជាក់ថា ក្នុងលំហចម្ងាយពីចំណុចទៅប្លង់កំណត់ដោយ $d\left(P_0\ ,\ \alpha\right)=\dfrac{\left|ax_0+by_0+cz_0+d\right|}{\sqrt{a^2+b^2+c^2}}$

គេមាន ចំណុច $P_0\left(x_0\ ,\ y_0\ ,\ z_0\right)$ និងប្លង់ $\alpha:\ ax+by+cz+d=0$

ដែលប្លង់ $\alpha$ មាន $\vec{u}=\left(a\ ,\ b\ ,\ c\right)$ ជាវ៉ិចទ័រណរម៉ាល់




គេយក $H\left(x_H\ ,y_H\ ,z_H\right)$ ជាចំណុចក្នុងប្លង់ $\alpha$ ដែល $\overrightarrow{P_0H}$ កែងនឹង $\alpha$

នាំឱ្យ ប្រវែង $P_0H$ ជាចម្ងាយត្រូវរក

គេតាង $P_1\left(x_1,y_1,z_1\right)$ ជាចំណុចដែល $\overrightarrow{P_0P_1}=\vec{u}$

គេបាន $\overrightarrow{P_0P_1}\cdot\overrightarrow{P_0H}=\vec{u}\cdot\overrightarrow{P_0H}$

$$=a\left(x_H-x_0\right)+b\left(y_H-y_0\right)+c\left(z_H-z_0\right)$$
$$=ax_H-ax_0+by_H-by_0+cz_H-cz_0$$
$$=\left(ax_H+by_H+cz_H\right)-ax_0-by_0-cz_0$$

ដោយ $H\in\alpha$ នាំឱ្យ $ax_H+by_H+cz_H+d=0$

ឬ $ax_H+by_H+cz_H=-d$

$$\overrightarrow{P_0P_1}\cdot\overrightarrow{P_0H}=-d-ax_0-by_0-cz_0$$

ម្យ៉ាងទៀត $\overrightarrow{P_0P_1}\cdot\overrightarrow{P_0H}=\left|\overrightarrow{P_0P_1}\right|\cdot\left|\overrightarrow{P_0H}\right|\cdot\cos\theta$ ដែល $\theta$ ជាមុំផ្គុំរវាង $\left|\overrightarrow{P_0P_1}\right|$ និង $\left|\overrightarrow{P_0H}\right|$

ទាញបាន $\left|\overrightarrow{P_0H}\right|=\dfrac{\overrightarrow{P_0P_1}\cdot\overrightarrow{P_0H}}{\left|\overrightarrow{P_0P_1}\right|\cdot\cos\theta}$

ដោយ $\overrightarrow{P_0P_1}\cdot\overrightarrow{P_0H}=-ax_0-by_0-cz_0-d$ និង $\overrightarrow{P_0P_1}=\vec{u}$

នាំឱ្យ $\left|\overrightarrow{P_0H}\right|=\dfrac{-ax_0-by_0-cz_0-d}{\left|\vec{u}\right|\cdot\cos\theta}$

ដោយ $\left|\overrightarrow{P_0H}\right|=P_0H$ ជាចម្ងាយ នោះ $\left|\overrightarrow{P_0H}\right|>0$ នាំឱ្យ $\dfrac{-ax_0-by_0-cz_0-d}{\left|\vec{u}\right|\cdot\cos\theta}$ ជាចំនួនវិជ្ជមាន

គេបាន $P_0H=\left|\overrightarrow{P_0H}\right|=\left|\dfrac{-ax_0-by_0-cz_0-d}{\left|\vec{u}\right|\cdot\cos\theta}\right|=\dfrac{\left|-ax_0-by_0-cz_0-d\right|}{\left|\vec{u}\right|\cdot\left|\cos\theta\right|}=\dfrac{\left|ax_0+by_0+cz_0+d\right|}{\sqrt{a^2+b^2+c^2}\cdot\left|\cos\theta\right|}$

តែ $\overrightarrow{P_0P_1}\parallel\overrightarrow{P_0H}$ នោះ $\theta=0^\circ$ ឬ $\theta=180^\circ$ នាំឱ្យ $\left|\cos\theta\right|=1$

នាំឱ្យ $P_0H=\left|\overrightarrow{P_0H}\right|=\dfrac{\left|ax_0+by_0+cz_0+d\right|}{\sqrt{a^2+b^2+c^2}}$

គេតាង $d\left(P_0,\alpha\right)=P_0H$ (distance from $P_0$ to $\alpha$) គេសរសេរបាន $d\left(P_0\ ,\ \alpha\right)=\dfrac{\left|ax_0+by_0+cz_0+d\right|}{\sqrt{a^2+b^2+c^2}}$

ដូចនេះ ចម្ងាយពីចំណុចទៅប្លង់កំណត់ដោយ $d\left(P_0\ ,\ \alpha\right)=\dfrac{\left|ax_0+by_0+cz_0+d\right|}{\sqrt{a^2+b^2+c^2}}$ ត្រូវបានស្រាយបញ្ជាក់ ។

# ការស្រាយបញ្ជាក់លើមេរៀន ចំនួនកុំផ្លិច

1. ស្រាយបញ្ជាក់ពីភាពខួបនៃ $i^n$ ចំពោះគ្រប់ $n \in \mathbb{N}$ ។

2. បើ $Z$ និង $W$ ជាចំនួនកុំផ្លិចមានកុំផ្លិចឆ្លាស់រៀងគ្នាគឺ $\bar{Z}$ និង $\bar{W}$ បង្ហាញថា គេបាន ៖

   ក. $\overline{Z+W} = \bar{Z} + \bar{W}$ ខ. $\overline{Z-W} = \bar{Z} - \bar{W}$ គ. $\overline{ZW} = \bar{Z} \times \bar{W}$ ឃ. $\overline{\left(\frac{Z}{W}\right)} = \frac{\bar{Z}}{\bar{W}}, W \neq 0$ ។

3. ក. ស្រាយបញ្ជាក់ថា $z + \bar{z}$ និង $z \cdot \bar{z}$ ជាចំនួនពិត ។

   ខ. ស្រាយបញ្ជាក់ថា $z \cdot \bar{z} = 0$ នាំឱ្យ $z = 0$ ។

4. ស្រាយបញ្ជាក់ថា បើ $z = a + bi$ នោះម៉ូឌុលនៃចំនួនកុំផ្លិច $z$ គឺ $|z| = r = \sqrt{a^2 + b^2}$ ។

5. ស្រាយបញ្ជាក់ថា បើ $z$ , $z_1$ , $z_2$ ជាចំនួនកុំផ្លិចគេបាន ៖

   ក. $|z| = |\bar{z}|$ ខ. $|z|^2 = z \cdot \bar{z}$ គ. $|z_1 \cdot z_2| = |z_1| \cdot |z_2|$ ឃ. $\left|\frac{z_1}{z_2}\right| = \frac{|z_1|}{|z_2|}$ ង. $|z_1 + z_2| \leq |z_1| + |z_2|$ ។

6. បើគេមាន $z_1 = r_1(\cos\alpha_1 + i\sin\alpha_1)$ និង $z_2 = r_2(\cos\alpha_2 + i\sin\alpha_2)$

   ក. ស្រាយបញ្ជាក់ថា $z_1 z_2 = r_1 r_2 \left[\cos(\alpha_1 + \alpha_2) + i\sin(\alpha_1 + \alpha_2)\right]$ ។

   ខ. ស្រាយបញ្ជាក់ថា $\frac{z_1}{z_2} = \frac{r_1}{r_2} \times \left[\cos(\alpha_1 - \alpha_2) + i\sin(\alpha_1 - \alpha_2)\right]$ ។

7. ក. ស្រាយបញ្ជាក់ថា បើគេមាន $z = r(\cos\theta + i\sin\theta)$ នោះគេបាន $z^n = r^n(\cos n\theta + i\sin n\theta)$ ។

   ខ. ស្រាយបញ្ជាក់ រូបមន្តដឺម័រ $(\cos\theta + i\sin\theta)^n = \cos n\theta + i\sin n\theta$ ។

8. ស្រាយបញ្ជាក់ថា $\left(\frac{1+\sin\varphi + i\cos\varphi}{1+\sin\varphi - i\cos\varphi}\right)^n = \cos\left[n\left(\frac{\pi}{2} - \varphi\right)\right] + i\sin\left[n\left(\frac{\pi}{2} - \varphi\right)\right]$ ។

9. ស្រាយបញ្ជាក់ រូបមន្តខាងក្រោម ៖

   ក. $\begin{cases} \cos 2\alpha = \cos^2\alpha - \sin^2\alpha \\ \sin 2\alpha = 2\sin\alpha\cos\alpha \end{cases}$

   ខ. $\begin{cases} \cos 3a = \cos^3 a - 3\cos a \sin^2 a = 4\cos^3 a - 3\cos a \\ \sin 3a = 3\cos^2 a \sin a - \sin^3 a = -4\sin^3 a + 3\sin a \end{cases}$

   គ. $\begin{cases} \cos 4a = \cos^4 a + \sin^4 a - 6\cos^2 a \sin^2 a \\ \sin 4a = 4\cos^3 a \sin a - 4\cos a \sin^3 a \end{cases}$ ។

10. ស្រាយបញ្ជាក់ថា បើគេមាន $z_1$ និង $z_2$ ជាចំនួនកុំផ្លិចដែលមានរូបភាពរៀងគ្នា $A(z_1)$ និង $B(z_2)$ ហើយចំណុច $P(z)$ ជារូបភាពនៃចំនួនកុំផ្លិច $z$ ដែល $P$ ស្ថិតនៅលើ $AB$ ហើយចែក $AB$ តាមផលធៀប $m:n$ នោះគេបាន ៖ $z = \frac{z_1 + \lambda z_2}{1+\lambda}$ ដែល $\lambda = \frac{m}{n}$ ។

11. ស្រាយបញ្ជាក់ថា បើ $A(z)$, $B(z_1)$ និង $C(z_2)$ បង្កើតបានជាត្រីកោណ $ABC$ នោះគេបាន $\frac{AC}{AB} = \left|\frac{z_2 - z}{z_1 - z}\right|$ ហើយ

    $\angle BAC = \arg\left(\frac{z_2 - z}{z_1 - z}\right)$ ។

# ការស្រាយបញ្ជាក់លើមេរៀន ចំនួនកុំផ្លិច

1. **ស្រាយបញ្ជាក់ពីភាពទូទៅនៃ $i^n$ ចំពោះគ្រប់ $n \in \mathbb{N}$**

គេមាន $i^1 = i$ អាចសរសេរជាទម្រង់ $i^1 = i^{4\times0+1} = i$

$i^2 = -1$ អាចសរសេរជាទម្រង់ $i^2 = i^{4\times0+2} = -1$

$i^3 = i^2 \times i = -i$ អាចសរសេរជាទម្រង់ $i^3 = i^{4\times0+3} = -i$

$i^4 = (i^2)^2 = 1$ អាចសរសេរជាទម្រង់ $i^4 = i^{4\times1+0} = 1$

$i^5 = i^4 \times i = i$ អាចសរសេរជាទម្រង់ $i^5 = i^{4\times1+1} = i$

$i^6 = i^4 \times i^2 = -1$ អាចសរសេរជាទម្រង់ $i^6 = i^{4\times1+2} = -1$

$i^7 = i^4 \times i^3 = -i$ អាចសរសេរជាទម្រង់ $i^7 = i^{4\times1+3} = -i$

$i^8 = i^4 \times i^4 = 1$ អាចសរសេរជាទម្រង់ $i^8 = i^{4\times2+0} = 1$

$i^9 = i^8 \times i = i$ អាចសរសេរជាទម្រង់ $i^9 = i^{4\times2+1} = i$

..............................................................................

..............................................................................

តាមលំនាំ $i^n$ អាចសរសេរជាទម្រង់ $i^n = i^{4k+A}$

សន្និដ្ឋាន

គ្រប់ $n$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាន គេអាចសរសេរបាន $i^n = i^{4k+A}$ ដែល $k$ ជាចំនួនគត់រ៉ឺឡាទីបមិនអវិជ្ជមាន និង $A = \{0, 1, 2, 3\}$ នោះគេបានតម្លៃនៃ $i^n$ តាមតម្លៃ $A$ ដូចខាងក្រោម ៖

-បើ $A = 0$ នាំឱ្យ $i^n = i^{4k+0} = 1$

-បើ $A = 1$ នាំឱ្យ $i^n = i^{4k+1} = i$

-បើ $A = 2$ នាំឱ្យ $i^n = i^{4k+2} = -1$

-បើ $A = 3$ នាំឱ្យ $i^n = i^{4k+3} = -i$ ។

2. **បើ $Z$ និង $W$ ជាចំនួនកុំផ្លិចមានកុំផ្លិចឆ្លាស់រៀងគ្នា $\overline{Z}$ និង $\overline{W}$ ៖**

គេតាង $Z = a + bi$ , $W = c + di$ នោះ $\overline{Z} = a - bi$ , $\overline{W} = c - di$

**ក. ស្រាយបញ្ជាក់ថា $\overline{Z+W} = \overline{Z} + \overline{W}$**

$Z + W = (a+bi) + (c+di) = (a+c) + (b+d)i$ នោះ $\overline{Z+W} = (a+c) - (b+d)i$

$\overline{Z} + \overline{W} = (a-bi) + (c-di) = (a+c) - (b+d)i$

ដូចនេះ $\overline{Z+W} = \overline{Z} + \overline{W}$ ត្រូវបានស្រាយបញ្ជាក់ ។

**ខ. ស្រាយបញ្ជាក់ថា $\overline{Z-W} = \overline{Z} - \overline{W}$**

$Z - W = (a+bi) - (c+di) = (a-c) + (b-d)i$ នោះ $\overline{Z-W} = (a-c) - (b-d)i$

$\overline{Z} - \overline{W} = (a-bi) - (c-di) = (a-c) - (b-d)i$

ដូចនេះ $\overline{Z-W} = \overline{Z} - \overline{W}$ ត្រូវបានស្រាយបញ្ជាក់ ។

គ. ស្រាយបញ្ជាក់ថា $\overline{ZW}=\bar{Z}\times\bar{W}$

$Z\times W=(a+bi)(c+di)=(ac-bd)+(ad+bc)i$ នោះ $\overline{Z\times W}=(ac-bd)-(ad+bc)i$

$\bar{Z}\times\bar{W}=(a-bi)(c-di)=ac-bd-adi-bci=(ac-bd)-(ad+bc)i$

ដូចនេះ $\overline{ZW}=\bar{Z}\times\bar{W}$ ត្រូវបានស្រាយបញ្ជាក់ ។

ឃ. ស្រាយបញ្ជាក់ថា $\overline{\left(\frac{Z}{W}\right)}=\frac{\bar{Z}}{\bar{W}}$ , $W\neq 0$

$$\frac{Z}{W}=\frac{a+bi}{c+di}=\frac{(a+bi)(c-di)}{(c+di)(c-di)}=\frac{ac+bd-adi+bci}{c^2+d^2}=\frac{ac+bd}{c^2+d^2}+\frac{bc-ad}{c^2+d^2}i$$

$$\overline{\left(\frac{Z}{W}\right)}=\frac{ac+bd}{c^2+d^2}-\frac{bc-ad}{c^2+d^2}i$$

$$\frac{\bar{Z}}{\bar{W}}=\frac{a-bi}{c-di}=\frac{(a-bi)(c+di)}{(c-di)(c+di)}=\frac{ac+bd+adi-bci}{c^2+d^2}=\frac{ac+bd}{c^2+d^2}-\frac{bc-ad}{c^2+d^2}i$$

ដូចនេះ $\overline{\left(\frac{Z}{W}\right)}=\frac{\bar{Z}}{\bar{W}}$ ត្រូវបានស្រាយបញ្ជាក់ ។

3. ក. ស្រាយបញ្ជាក់ថា $z+\bar{z}$ និង $z\cdot\bar{z}$ ជាចំនួនពិត

គេតាង $z=a+bi$ នោះ $\bar{z}=a-bi$ ដែល $a$ , $b$ ជាចំនួនពិត

គេបាន $z+\bar{z}=(a+bi)+(a-bi)=2a$ ជាចំនួនពិត

ហើយ $z\cdot\bar{z}=(a+bi)(a-bi)=a^2-(bi)^2=a^2+b^2$ ជាចំនួនពិត

ដូចនេះ ស្រាយបញ្ជាក់បានថា $z+\bar{z}$ និង $z\cdot\bar{z}$ ជាចំនួនពិត ។

ខ. ស្រាយបញ្ជាក់ថា បើ $z\cdot\bar{z}=0$ នាំឱ្យ $z=0$

គេតាង $z=a+bi$ នោះ $\bar{z}=a-bi$ ដែល $a$ , $b$ ជាចំនួនពិត

ហើយ $z\cdot\bar{z}=(a+bi)(a-bi)=a^2-(bi)^2=a^2+b^2$

គេមាន $z\cdot\bar{z}=0$ នោះ $a^2+b^2=0$

ដោយ $a^2\geq 0$ និង $b^2\geq 0$ នោះ $a^2+b^2=0$ មានគូចម្លើយតែមួយគត់គឺ $a=0$ និង $b=0$

នាំឱ្យ $z=a+bi=0+0i=0$

ដូចនេះ ស្រាយបញ្ជាក់បានថា បើ $z\cdot\bar{z}=0$ នាំឱ្យ $z=0$ ។

4. ស្រាយបញ្ជាក់ថា បើ $z=a+bi$ នោះម៉ូឌុលនៃចំនួនកុំផ្លិច $z$ គឺ $|z|=r=\sqrt{a^2+b^2}$




តាង $M(a\,,b)$ ជារូបភាពនៃចំនួនកុំផ្លិច $z=a+bi$ ដែល $OM=|z|=r$

ក្នុងត្រីកោណកែង $OHM$ តាទ្រឹស្តីបទពីតាគ័រ $OM^2=OH^2+HM^2$

ដោយ $OH=a$ , $HM=b$ នោះ $OM^2=a^2+b^2$ នាំឱ្យ $OM=\sqrt{a^2+b^2}$

ដូចនេះ ម៉ូឌុលនៃចំនួនកុំផ្លិច $z$ គឺ $OM=|z|=r=\sqrt{a^2+b^2}$ ត្រូវបានស្រាយបញ្ជាក់ ។

5. បើ $z$ , $z_1$ , $z_2$ ជាចំនួនកុំផ្លិច

ក. ស្រាយបញ្ជាក់ថា $|z|=|\overline{z}|$

គេតាង $z=a+bi$ នោះ $\overline{z}=a-bi$

គេបាន $|z|=\sqrt{a^2+b^2}$ (1)

ហើយ $|\overline{z}|=\sqrt{a^2+(-b)^2}=\sqrt{a^2+b^2}$ (2)

តាម (1) និង (2) បញ្ជាក់បានថា $|z|=|\overline{z}|$

ដូចនេះ $|z|=|\overline{z}|$ ត្រូវបានស្រាយបញ្ជាក់ ។

ខ.ស្រាយបញ្ជាក់ថា $|z|^2=z\cdot\overline{z}$

គេតាង $z=a+bi$ នោះ $\overline{z}=a-bi$ ហើយ $|z|=\sqrt{a^2+b^2}$

គេបាន $|z|^2=\left(\sqrt{a^2+b^2}\right)^2=a^2+b^2$ (1)

ហើយ $z\times\overline{z}=(a+bi)(a-bi)=a^2-(bi)^2=a^2+b^2$ (2) ព្រោះ $i^2=-1$

តាម (1) និង (2) បញ្ជាក់បានថា $|z|^2=z\cdot\overline{z}$

ដូចនេះ $|z|^2=z\cdot\overline{z}$ ត្រូវបានស្រាយបញ្ជាក់ ។

គ. ស្រាយបញ្ជាក់ថា $|z_1\cdot z_2|=|z_1|\cdot|z_2|$

គេតាង $z_1=a+bi$ និង $z_2=c+di$ នោះ $|z_1|=\sqrt{a^2+b^2}$ , $|z_2|=\sqrt{c^2+d^2}$

គេបាន $z_1\cdot z_2=(a+bi)(c+di)=(ac-bd)+(ad+bc)i$

នាំឱ្យ
$$\begin{aligned}|z_1\cdot z_2|&=\sqrt{(ac-bd)^2+(ad+bc)^2}\\&=\sqrt{(ac-bd)^2+(ad+bc)^2}\\&=\sqrt{a^2c^2-2abcd+b^2d^2+a^2d^2+2abcd+b^2c^2}\\&=\sqrt{a^2c^2+a^2d^2+b^2d^2+b^2c^2}\\&=\sqrt{a^2\left(c^2+d^2\right)+b^2\left(c^2+d^2\right)}\\&=\sqrt{\left(a^2+b^2\right)\left(c^2+d^2\right)} \quad (1)\end{aligned}$$

ម្យ៉ាងទៀត
$$\begin{aligned}|z_1|\cdot|z_2|&=\left(\sqrt{a^2+b^2}\right)\left(\sqrt{c^2+d^2}\right)\\&=\sqrt{\left(a^2+b^2\right)\left(c^2+d^2\right)} \quad (2)\end{aligned}$$

តាម (1) និង (2) បញ្ជាក់បានថា $|z_1\cdot z_2|=|z_1|\cdot|z_2|$

ដូចនេះ $|z_1\cdot z_2|=|z_1|\cdot|z_2|$ ត្រូវបានស្រាយបញ្ជាក់ ។

ឃ. ស្រាយបញ្ជាក់ថា $\left|\frac{z_1}{z_2}\right| = \frac{|z_1|}{|z_2|}$ , $z_2 \neq 0$

គេតាង $z_1 = a + bi$ និង $z_2 = c + di$

នាំឱ្យ $|z_1| = \sqrt{a^2 + b^2}$ និង $|z_2| = \sqrt{c^2 + d^2}$

គេបាន

$$\begin{aligned}\frac{z_1}{z_2} &= \frac{a+bi}{c+di} \\ &= \frac{(a+bi)(c-di)}{(c+di)(c-di)} \\ &= \frac{ac - adi + bci - bdi^2}{c^2 - (di)^2} \\ &= \frac{(ac+bd)+(bc-ad)i}{c^2+d^2} \quad , \ i^2 = -1 \\ &= \left(\frac{ac+bd}{c^2+d^2}\right) + \left(\frac{bc-ad}{c^2+d^2}\right)i\end{aligned}$$

នាំឱ្យ

$$\begin{aligned}\left|\frac{z_1}{z_2}\right| &= \sqrt{\left(\frac{ac+bd}{c^2+d^2}\right)^2 + \left(\frac{bc-ad}{c^2+d^2}\right)^2} \\ &= \sqrt{\frac{(ac+bd)^2 + (bc-ad)^2}{(c^2+d^2)^2}} \\ &= \sqrt{\frac{a^2c^2 + 2abcd + b^2d^2 + b^2c^2 - 2abcd + a^2d^2}{(c^2+d^2)^2}} \\ &= \sqrt{\frac{a^2c^2 + a^2d^2 + b^2d^2 + b^2c^2}{(c^2+d^2)^2}} \\ &= \sqrt{\frac{a^2(c^2+d^2) + b^2(c^2+d^2)}{(c^2+d^2)^2}} \\ &= \sqrt{\frac{(c^2+d^2)(a^2+b^2)}{(c^2+d^2)^2}} \\ &= \sqrt{\frac{a^2+b^2}{c^2+d^2}} \qquad (1)\end{aligned}$$

ម្យ៉ាងទៀត $\frac{|z_1|}{|z_2|} = \frac{\sqrt{a^2+b^2}}{\sqrt{c^2+d^2}} = \sqrt{\frac{a^2+b^2}{c^2+d^2}}$ (2)

តាមរយៈទំនាក់ទំនង (1) និង (2) បញ្ជាក់បានថា $\left|\frac{z_1}{z_2}\right| = \frac{|z_1|}{|z_2|}$

ដូចនេះ: $\left|\frac{z_1}{z_2}\right| = \frac{|z_1|}{|z_2|}$ ត្រូវបានស្រាយបញ្ជាក់ ។

ង. ស្រាយបញ្ជាក់ថា $|z_1+z_2|\le|z_1|+|z_2|$

➢របៀបទី១ តាមលក្ខណៈវិសមភាព

គេតាង $z_1=a+bi$ និង $z_2=c+di$ នោះ $|z_1|=\sqrt{a^2+b^2}$ និង $|z_2|=\sqrt{c^2+d^2}$

គេបាន $|z_1|+|z_2|=\sqrt{a^2+b^2}+\sqrt{c^2+d^2}$ ដែល $|z_1|+|z_2|>0$

ហើយ $z_1+z_2=(a+bi)+(c+di)=(a+c)+(b+d)i$

នាំឱ្យ $|z_1+z_2|=\sqrt{(a+c)^2+(b+d)^2}$ ដែល $|z_1+z_2|>0$

ឧបមាថា $|z_1+z_2|\le|z_1|+|z_2|$

គេបាន $\sqrt{(a+c)^2+(b+d)^2}\le\sqrt{a^2+b^2}+\sqrt{c^2+d^2}$ (លើកអង្គទាំងពីរជាការេ)

$$(a+c)^2+(b+d)^2\le(a^2+b^2)+2\sqrt{(a^2+b^2)(c^2+d^2)}+(c^2+d^2)$$

$$a^2+2ac+c^2+b^2+2bd+d^2\le a^2+b^2+2\sqrt{(a^2+b^2)(c^2+d^2)}+c^2+d^2$$

$$2(ac+bd)\le2\sqrt{(a^2+b^2)(c^2+d^2)}$$

$$(ac+bd)^2\le(a^2+b^2)(c^2+d^2)$$

$$a^2c^2+2abcd+b^2d^2\le a^2c^2+a^2d^2+b^2c^2+b^2d^2$$

$$2abcd\le a^2d^2+b^2c^2$$

$$0\le a^2d^2-2abcd+b^2c^2$$

$0\le(ad-bc)^2$ ពិតគ្រប់ $a\,,b\,,c\,,d$ ជាចំនួនពិត

ដូចនេះ $|z_1+z_2|\le|z_1|+|z_2|$ ត្រូវបានស្រាយបញ្ជាក់ ។

➢របៀបទី២ តាមវិសមភាពក្នុងត្រីកោណ

គេតាង $M_1$ , $M_2$ ជារូបភាពរៀងគ្នានៃចំនួនកុំផ្លិច $z_1$ , $z_2$

គេបាន $M$ ជារូបភាពនៃ $z_1+z_2$




តាមវិសមភាពក្នុងត្រីកោណ $OM_1M$

គេបាន $OM<OM_1+M_1M$ ឬ $|z_1+z_2|<|z_1|+|z_2|$ (1)

ព្រោះ $OM=|z_1+z_2|$ , $OM_1=|z_1|$ , $M_1M=|z_2|$

ម្យ៉ាងទៀត បើ $z_1=z_2=0$ នោះ $|z_1|+|z_2|=|z_1+z_2|$ (2)

តាមរយៈ (1) និង (2) គេបាន $|z_1+z_2|\le|z_1|+|z_2|$

ដូចនេះ $|z_1+z_2|\le|z_1|+|z_2|$ ត្រូវបានស្រាយបញ្ជាក់ ។

6. ក. ស្រាយបញ្ជាក់ថា $z_1z_2=r_1r_2\left[\cos(\alpha_1+\alpha_2)+i\sin(\alpha_1+\alpha_2)\right]$

គេមាន $z_1=r_1(\cos\alpha_1+i\sin\alpha_1)$ និង $z_2=r_2(\cos\alpha_2+i\sin\alpha_2)$

រំលឹករូបមន្ត $\cos(a+b)=\cos a\cos b-\sin a\sin b$

$\sin(a+b)=\sin a\cos b+\sin b\cos a$

គេបាន $z_1 \times z_2 = r_1(\cos\alpha_1 + i\sin\alpha_1) \times r_2(\cos\alpha_2 + i\sin\alpha_2)$

$= r_1 r_2(\cos\alpha_1 + i\sin\alpha_1)(\cos\alpha_2 + i\sin\alpha_2)$

$= r_1 r_2(\cos\alpha_1\cos\alpha_2 + i\cos\alpha_1\sin\alpha_2 + i\cos\alpha_2\sin\alpha_1 + i^2\sin\alpha_1\sin\alpha_2)$

$= r_1 r_2[(\cos\alpha_1\cos\alpha_2 - \sin\alpha_1\sin\alpha_2) + i(\cos\alpha_1\sin\alpha_2 + \cos\alpha_2\sin\alpha_1)]$

$= r_1 r_2[\cos(\alpha_1 + \alpha_2) + i\sin(\alpha_1 + \alpha_2)]$

ដូចនេះ $z_1 z_2 = r_1 r_2[\cos(\alpha_1 + \alpha_2) + i\sin(\alpha_1 + \alpha_2)]$ ត្រូវបានស្រាយបញ្ជាក់ ។

**ខ. ស្រាយបញ្ជាក់ថា** $\frac{z_1}{z_2} = \frac{r_1}{r_2} \times [\cos(\alpha_1 - \alpha_2) + i\sin(\alpha_1 - \alpha_2)]$

គេមាន $z_1 = r_1(\cos\alpha_1 + i\sin\alpha_1)$ និង $z_2 = r_2(\cos\alpha_2 + i\sin\alpha_2)$

រំលឹករូបមន្ត $\cos(a-b) = \cos a\cos b + \sin a\sin b$

$\sin(a-b) = \sin a\cos b - \sin b\cos a$

$\sin^2 a + \cos^2 a = 1$

គេបាន $\frac{z_1}{z_2} = \frac{r_1(\cos\alpha_1 + i\sin\alpha_1)}{r_2(\cos\alpha_2 + i\sin\alpha_2)}$

$= \frac{r_1}{r_2} \times \frac{(\cos\alpha_1 + i\sin\alpha_1)(\cos\alpha_2 - i\sin\alpha_2)}{(\cos\alpha_2 + i\sin\alpha_2)(\cos\alpha_2 - i\sin\alpha_2)}$

$= \frac{r_1}{r_2} \times \frac{\cos\alpha_1\cos\alpha_2 - i\cos\alpha_1\sin\alpha_2 + i\cos\alpha_2\sin\alpha_1 + \sin\alpha_1\sin\alpha_2}{\cos^2\alpha_2 - i^2\sin^2\alpha_2}$

$= \frac{r_1}{r_2}\left[\frac{(\cos\alpha_1\cos\alpha_2 + \sin\alpha_1\sin\alpha_2) + i(\cos\alpha_2\sin\alpha_1 - \cos\alpha_1\sin\alpha_2)}{\cos^2\alpha_2 + \sin^2\alpha_2}\right]$

$= \frac{r_1}{r_2}[\cos(\alpha_1 - \alpha_2) + i\sin(\alpha_1 - \alpha_2)]$

ដូចនេះ $\frac{z_1}{z_2} = \frac{r_1}{r_2} \times [\cos(\alpha_1 - \alpha_2) + i\sin(\alpha_1 - \alpha_2)]$ ត្រូវបានស្រាយបញ្ជាក់ ។

7. **ក. ស្រាយបញ្ជាក់ថា បើគេមាន** $z = r(\cos\theta + i\sin\theta)$ **នោះគេបាន** $z^n = r^n(\cos n\theta + i\sin n\theta)$

គេមាន $z = r(\cos\theta + i\sin\theta)$

ប្រើរូបមន្ត $z_1 z_2 = r_1 r_2[\cos(\alpha_1 + \alpha_2) + i\sin(\alpha_1 + \alpha_2)]$

គេបាន $z^2 = z \times z = rr[\cos(\alpha + \alpha) + i\sin(\alpha + \alpha)] \qquad = r^2(\cos 2\alpha + i\sin 2\alpha)$

$z^3 = z^2 \times z = r^2 r[\cos(2\alpha + \alpha) + i\sin(2\alpha + \alpha)] \qquad = r^3(\cos 3\alpha + i\sin 3\alpha)$

$z^4 = z^3 \times z = r^3 r[\cos(3\alpha + \alpha) + i\sin(3\alpha + \alpha)] \qquad = r^4(\cos 4\alpha + i\sin 4\alpha)$

..................................................................................................

..................................................................................................

តាមលំនាំ គេអាចសរសេរបាន $z^n = r^n(\cos n\alpha + i\sin n\alpha)$ , $n \in \mathbb{N}$

ដូចនេះ $z^n = r^n(\cos n\alpha + i\sin n\alpha)$ , $n \in \mathbb{N}$ ត្រូវបានស្រាយបញ្ជាក់ ។

ខ. ស្រាយបញ្ជាក់ថា រូបមន្តដឺម័រ $(\cos\theta+i\sin\theta)^n=\cos n\theta+i\sin n\theta$

**➢របៀបទី១** តាមលក្ខណៈផលគុណ

គេតាង $z_1=\cos\theta_1+i\sin\theta_1$ , $z_2=\cos\theta_2+i\sin\theta_2$ , $z_3=\cos\theta_3+i\sin\theta_3$ , ... , $z_n=\cos\theta_n+i\sin\theta_n$

តាមរូបមន្ត $z_1z_2=r_1r_2\left[\cos(\alpha_1+\alpha_2)+i\sin(\alpha_1+\alpha_2)\right]$

គេបាន $z_1z_2z_3\times\ldots\times z_n=\cos(\theta_1+\theta_2+\theta_3+\ldots+\theta_n)+i\sin(\theta_1+\theta_2+\theta_3+\ldots+\theta_n)$

បើគេយក $z_1=z_2=z_3=\ldots=z_n=z$ , $\theta_1=\theta_2=\theta_3=\ldots=\theta_n=\theta$

គេបាន $z\cdot z\cdot z\times\ldots\times z=\cos(\theta+\theta+\theta+\ldots+\theta)+i\sin(\theta+\theta+\theta+\ldots+\theta)$

ឬ $z^n=\cos(n\theta)+i\sin(n\theta)$

ដូនេះ: | រូបមន្តដឺម័រ $(\cos\theta+i\sin\theta)^n=\cos n\theta+i\sin n\theta$ ត្រូវបានស្រាយបញ្ជាក់ | ។

**➢របៀបទី២** តាមវិចារកំណើន

ចំពោះ: $n=1$ នោះ: $(\cos\theta+i\sin\theta)^1=\cos\theta+i\sin\theta$ ពិត

ចំពោះ: $n=2$ នោះ:

$$(\cos\theta+i\sin\theta)^2=\cos2\theta+i\sin2\theta$$
$$(\cos\theta+i\sin\theta)^2=\cos2\theta+i\sin2\theta$$
$$\cos^2\theta+2i\cos\theta\sin\theta-\sin^2\theta=\cos2\theta+i\sin2\theta$$
$$\left(1-2\sin^2\theta\right)+2i\cos\theta\sin\theta=\cos2\theta+i\sin2\theta$$
$$\cos2\theta+i\sin2\theta=\cos2\theta+i\sin2\theta \text{ ពិត}$$

ឧបមាថាវាពិតរហូតដល់ $n=k$ នោះ: $(\cos\theta+i\sin\theta)^k=\cos k\theta+i\sin k\theta$

គេនឹងស្រាយថាវានៅតែពិតរហូតដល់ $n=k+1$ នោះ: $(\cos\theta+i\sin\theta)^{k+1}=\cos(k+1)\theta+i\sin(k+1)\theta$

គេមាន
$$\begin{aligned}(\cos\theta+i\sin\theta)^{k+1}&=(\cos\theta+i\sin\theta)^k\cdot(\cos\theta+i\sin\theta)\\&=(\cos k\theta+i\sin k\theta)(\cos\theta+i\sin\theta)\\&=\cos(k\theta+\theta)+i\sin(k\theta+\theta)\\&=\cos(k+1)\theta+i\sin(k+1)\theta\end{aligned}$$

ដូចនេះ: | រូបមន្តដឺម័រ $(\cos\theta+i\sin\theta)^n=\cos n\theta+i\sin n\theta$ ត្រូវបានស្រាយបញ្ជាក់ | ។

៦. **ស្រាយបញ្ជាក់ថា** $\left(\dfrac{1+\sin\varphi+i\cos\varphi}{1+\sin\varphi-i\cos\varphi}\right)^n=\cos\left[n\left(\dfrac{\pi}{2}-\varphi\right)\right]+i\sin\left[n\left(\dfrac{\pi}{2}-\varphi\right)\right]$ ។

រំលឹករូបមន្ត ការេនៃត្រីធា $(a+b+c)^2=a^2+b^2+c^2+2ab+2ac+2bc$

មុំបំពេញ $\sin\theta=\cos\left(\dfrac{\pi}{2}-\theta\right)$

$\cos\theta=\sin\left(\dfrac{\pi}{2}-\theta\right)$

ដឺម័រ $(\cos\theta+i\sin\theta)^n=\cos n\theta+i\sin n\theta$

តាមរូបមន្តខាងលើ គេអាចស្រាយបញ្ជាក់សមភាពនេះបានដូចតទៅ ៖

គេមាន $\dfrac{1+\sin\varphi+i\cos\varphi}{1+\sin\varphi-i\cos\varphi}=\dfrac{(1+\sin\varphi+i\cos\varphi)^2}{(1+\sin\varphi-i\cos\varphi)(1+\sin\varphi+i\cos\varphi)}$ (គុណនឹងកុំផ្លិចឆ្លាស់នៃភាគបែង)

$$=\frac{1^2+\sin^2\varphi+(i\cos\varphi)^2+2\sin\varphi+2i\cos\varphi+2\sin\varphi\cdot i\cos\varphi}{(1+\sin\varphi)^2-(i\cos\varphi)^2}$$

$$=\frac{1^2+\sin^2\varphi-\cos^2\varphi+2\sin\varphi+2i\cos\varphi+2\sin\varphi\cdot i\cos\varphi}{1^2+2\sin\varphi+\sin^2\varphi+\cos^2\varphi}$$

$$=\frac{2\sin^2\varphi+2\sin\varphi+2i\cos\varphi+2\sin\varphi\cdot i\cos\varphi}{2+2\sin\varphi}$$

$$=\frac{\sin\varphi(2\sin\varphi+2)+i\cos\varphi(2+2\sin)}{2+2\sin\varphi}$$

$$=\frac{(2\sin\varphi+2)(\sin\varphi+i\cos\varphi)}{2+2\sin\varphi}$$

$$=\sin\varphi+i\cos\varphi$$

$$=\cos\left(\frac{\pi}{2}-\varphi\right)+i\sin\left(\frac{\pi}{2}-\varphi\right)$$

តាមដឺម័រ $\left(\dfrac{1+\sin\varphi+i\cos\varphi}{1+\sin\varphi-i\cos\varphi}\right)^n=\left[\cos\left(\dfrac{\pi}{2}-\varphi\right)+i\sin\left(\dfrac{\pi}{2}-\varphi\right)\right]^n$

$=\cos\left[n\left(\dfrac{\pi}{2}-\varphi\right)\right]+i\sin\left[n\left(\dfrac{\pi}{2}-\varphi\right)\right]$ (ដូចបំណងដែលចង់ស្រាយបញ្ជាក់)

ដូចនេះ: ស្រាយបញ្ជាក់បានថា $\left(\dfrac{1+\sin\varphi+i\cos\varphi}{1+\sin\varphi-i\cos\varphi}\right)^n=\cos\left[n\left(\dfrac{\pi}{2}-\varphi\right)\right]+i\sin\left[n\left(\dfrac{\pi}{2}-\varphi\right)\right]$ ។

9. **ស្រាយបញ្ជាក់ រូបមន្តខាងក្រោម ៖**

**ក. ស្រាយបញ្ជាក់ រូបមន្ត** $\begin{cases}\cos 2\alpha=\cos^2\alpha-\sin^2\alpha\\ \sin 2\alpha=2\sin\alpha\cos\alpha\end{cases}$

គេយក $z=r(\cos\alpha+i\sin\alpha)$ តាមដឺម័រនោះ: $z^n=r^n(\cos n\alpha+i\sin n\alpha)$

បើ $n=2$ នោះ: $z^2=r^2(\cos 2\alpha+i\sin 2\alpha)$ (1)

ម្យ៉ាងទៀត $z^2=z\cdot z=r(\cos\alpha+i\sin\alpha)\times r(\cos\alpha+i\sin\alpha)$

$$=r^2(\cos\alpha+i\sin\alpha)^2$$

$$=r^2\left[\cos^2\alpha+2i\sin\alpha\cos\alpha+i^2\sin^2\alpha\right]$$

$$=r^2\left(\cos^2\alpha-\sin^2\alpha+i2\sin\alpha\cos\alpha\right)\qquad(2)$$

តាមរយ: ទំនាក់ទំនង (1) និង (2) : $r^2(\cos 2\alpha+i\sin 2\alpha)=r^2\left(\cos^2\alpha-\sin^2\alpha+i2\sin\alpha\cos\alpha\right)$

ឬ $\cos^2\alpha-\sin^2\alpha+i2\sin\alpha\cos\alpha=\cos 2\alpha+i\sin 2\alpha$

តាមនិយមន័យចំនួនកុំផ្លិចស្មើគ្នា គេផ្ទឹមបាន $\begin{cases}\cos 2\alpha=\cos^2\alpha-\sin^2\alpha\\ \sin 2\alpha=2\sin\alpha\cos\alpha\end{cases}$

ដូចនេះ: រូបមន្ត $\begin{cases}\cos 2\alpha=\cos^2\alpha-\sin^2\alpha\\ \sin 2\alpha=2\sin\alpha\cos\alpha\end{cases}$ ត្រូវបានស្រាយបញ្ជាក់ ។

ខ. ស្រាយបញ្ជាក់ រូបមន្ត $\begin{cases}\cos 3a = \cos^3 a - 3\cos a\sin^2 a = 4\cos^3 a - 3\cos a \\ \sin 3a = 3\cos^2 a\sin a - \sin^3 a = -4\sin^3 a + 3\sin a\end{cases}$

គេយក $z = r(\cos\alpha + i\sin\alpha)$ តាមដឺម័រនោះ $z^n = r^n(\cos n\alpha + i\sin n\alpha)$

បើ $n=3$ នោះ $z^3 = r^3(\cos 3\alpha + i\sin 3\alpha)$ (1)

ម្យ៉ាងទៀត $z^3 = \left[r(\cos a + i\sin a)\right]^3$

$$= r^3(\cos a + i\sin a)^3$$

$$= r^3\left[\cos^3 a + 3\cos^2 a\cdot i\sin a + 3\cos a(i\sin a)^2 + (i\sin a)^3\right]$$

$$= r^3\left[\left(\cos^3 a - 3\cos a\sin^2 a\right) + i\left(3\cos^2 a\sin a - \sin^3 a\right)\right] \quad (2)$$

$$= r^3\left[\left(\cos^3 a - 3\cos a\left(1-\cos^2 a\right)\right) + i\left(3\left(1-\sin^2 a\right)\sin a - \sin^3 a\right)\right]$$

$$= r^3\left[\left(\cos^3 a - 3\cos a + 3\cos^3 a\right) + i\left(3\sin a - 3\sin^3 a - \sin^3 a\right)\right]$$

$$= r^3\left[\left(4\cos^3 a - 3\cos a\right) + i\left(-4\sin^3 a + 3\sin a\right)\right] \quad (3)$$

តាមរយៈ ទំនាក់ទំនង (1), (2) និង (3) ដោយសម្រួល $r^3$ គេបាន ៖

$$\cos 3\alpha + i\sin 3\alpha = \left(\cos^3 a - 3\cos a\sin^2 a\right) + i\left(3\cos^2 a\sin a - \sin^3 a\right) = \left(4\cos^3 a - 3\cos a\right) + i\left(-4\sin^3 a + 3\sin a\right)$$

តាមនិយមន័យចំនួនកុំផ្លិចស្មើគ្នា គេផ្ទឹមបាន $\begin{cases}\cos 3a = \cos^3 a - 3\cos a\sin^2 a = 4\cos^3 a - 3\cos a \\ \sin 3a = 3\cos^2 a\sin a - \sin^3 a = -4\sin^3 a + 3\sin a\end{cases}$

ដូចនេះ រូបមន្ត $\begin{cases}\cos 3a = \cos^3 a - 3\cos a\sin^2 a = 4\cos^3 a - 3\cos a \\ \sin 3a = 3\cos^2 a\sin a - \sin^3 a = -4\sin^3 a + 3\sin a\end{cases}$ ត្រូវបានស្រាយបញ្ជាក់ ។

គ. ស្រាយបញ្ជាក់ រូបមន្ត $\begin{cases}\cos 4a = \cos^4 a + \sin^4 a - 6\cos^2 a\sin^2 a \\ \sin 4a = 4\cos^3 a\sin a - 4\cos a\sin^3 a\end{cases}$

គេយក $z = r(\cos\alpha + i\sin\alpha)$ តាមដឺម័រនោះ $z^n = r^n(\cos n\alpha + i\sin n\alpha)$

បើ $n=4$ នោះ $z^4 = r^4(\cos 4\alpha + i\sin 4\alpha)$ (1)

ម្យ៉ាងទៀត $z^4 = \left[r(\cos a + i\sin a)\right]^4$

$$= r^4(\cos a + i\sin a)^4$$

$$= r^4\left[\cos^4 a + 4\cos^3 a(i\sin a) + 6\cos^2 a(i\sin a)^2 + 4\cos a(i\sin a)^3 + (i\sin a)^4\right]$$

$$= r^4\left[\left(\cos^4 a - 6\cos^2 a\sin^2 a + \sin^4 a\right) + i\left(4\cos^3 a\sin a - 4\cos a\sin^3 a\right)\right] \quad (2)$$

តាម (1) និង (2) : $r^4(\cos 4a + i\sin 4a) = r^4\left[\left(\cos^4 a + \sin^4 a - 6\cos^2 a\sin^2 a\right) + i\left(4\cos^3 a\sin a - 4\cos a\sin^3 a\right)\right]$

សម្រួលនឹង $r^4$ $\cos 4a + i\sin 4a = \left(\cos^4 a + \sin^4 a - 6\cos^2 a\sin^2 a\right) + i\left(4\cos^3 a\sin a - 4\cos a\sin^3 a\right)$

តាមនិយមន័យចំនួនកុំផ្លិចស្មើគ្នា គេផ្ទឹមបាន $\begin{cases}\cos 4a = \cos^4 a + \sin^4 a - 6\cos^2 a\sin^2 a \\ \sin 4a = 4\cos^3 a\sin a - 4\cos a\sin^3 a\end{cases}$

ដូចនេះ រូបមន្ត $\begin{cases}\cos 4a = \cos^4 a + \sin^4 a - 6\cos^2 a\sin^2 a \\ \sin 4a = 4\cos^3 a\sin a - 4\cos a\sin^3 a\end{cases}$ ត្រូវបានស្រាយបញ្ជាក់ ។

10. **ស្រាយបញ្ជាក់ថា បើ $P$ នៅលើ $[AB]$ ហើយចែក $[AB]$ តាមផលធៀប $m:n$ នោះគេបាន ៖** $z=\dfrac{z_1+\lambda z_2}{1+\lambda}$

**ដែល** $\lambda=\dfrac{m}{n}$ , $P(z)$ , $A(z_1)$ **និង** $B(z_2)$




ភ្ជាប់ចំណុច $O$ និង $A$

គូសអង្កត់ $OC//AB$ និង $AO//BC$ ដែល $OC$ ប្រសព្វ $BC$ ត្រង់ $C$

គូសអង្កត់ $PQ//AO$ ដែល $Q$ ស្ថិតនៅលើអង្កត់ $OC$

តាង $A'(-z)$ ជារូបភាពនៃ $-z_1$

គេបាន $C(z_2-z_1)$ ជារូបភាពនៃ $z_2+(-z_1)$ ឬ $z_2-z_1$

$Q(z-z_1)$ ជារូបភាពនៃ $z+(-z_1)$ ឬ $z-z_1$

ពិនិត្យ $\dfrac{m}{m+n}=\dfrac{z-z_1}{z_2-z_1}$ នោះ $z-z_1=\dfrac{m}{m+n}(z_2-z_1)$

នាំឱ្យ $z=\dfrac{m}{m+n}(z_2-z_1)+z_1=\dfrac{mz_2-mz_1}{m+n}+\dfrac{mz_1+nz_1}{m+n}=\dfrac{mz_2+nz_1}{m+n}$ (ចែកភាគយក និងភាគបែង ដោយ $n$)

គេបាន $z=\dfrac{\frac{m}{n}z_2+z_1}{\frac{m}{n}+1}=\dfrac{z_1+\frac{m}{n}z_2}{1+\frac{m}{n}}=\dfrac{z_1+\lambda z_2}{1+\lambda}$ ព្រោះ $\lambda=\dfrac{m}{n}$

ដូចនេះ $z=\dfrac{z_1+\lambda z_2}{1+\lambda}$ ត្រូវបានស្រាយបញ្ជាក់ ។

ចំណាំ
- បើ $\lambda=1$ នោះចំណុច $P$ ស្ថិតនៅកណ្ដាល $AB$
- បើ $\lambda>1$ នោះចំណុច $P$ ស្ថិតនៅចន្លោះ $AB$
- បើ $\lambda<1$ នោះចំណុច $P$ ស្ថិតនៅក្រៅ $AB$ ឬ បន្លាយនៃ $AB$ ។

11. **ស្រាយបញ្ជាក់ថា** $\dfrac{AC}{AB}=\left|\dfrac{z_2-z}{z_1-z}\right|$ **ហើយ** $\angle BAC=\arg\left(\dfrac{z_2-z}{z_1-z}\right)$




គេមាន $A(z)$, $B(z_1)$ និង $C(z_2)$ បង្កើតបានជាត្រីកោណ $ABC$

គេសង់វ៉ិចទ័រ $\overrightarrow{OB'}=\overrightarrow{AB}$ និង $\overrightarrow{OC'}=\overrightarrow{AC}$ នោះ $\angle BAC=\angle B'AC'$

គេបាន $\Delta BAC\cong\Delta B'AC'$ (ជ.ម.ជ)

ហើយ $\overrightarrow{AB}$ ជារូបភាពនៃ $z_1-z$ និង $\overrightarrow{AC}$ ជារូបភាពនៃ $z_2-z$

គេបាន $\dfrac{AC}{AB}=\dfrac{|\overrightarrow{AC}|}{|\overrightarrow{AB}|}=\dfrac{|z_2-z|}{|z_1-z|}=\left|\dfrac{z_2-z}{z_1-z}\right|$

ដោយ $(\overrightarrow{Ox},\overrightarrow{OB'})=\arg(z_1-z)$ និង $(\overrightarrow{Ox},\overrightarrow{OC'})=\arg(z_2-z)$

ហើយ $\angle BAC=\angle B'AC'=\arg(z_2-z)-\arg(z_1-z)=\arg\left(\dfrac{z_2-z}{z_1-z}\right)$

ដូចនេះ ស្រាយបញ្ជាក់បានថា $\dfrac{AC}{AB}=\left|\dfrac{z_2-z}{z_1-z}\right|$ ហើយ $\angle BAC=\arg\left(\dfrac{z_2-z}{z_1-z}\right)$ ។

# ការស្រាយបញ្ជាក់លើមេរៀន លីមីត

1. ស្រាយបញ្ជាក់ទ្រឹស្តីបទ L'Hospital ៖ ចំពោះ $\lim_{x\to c}\frac{f(x)}{g(x)}$ មានរាងមិនកំណត់ $\frac{0}{0}$ ឬ $\frac{\infty}{\infty}$ គេបាន $\lim_{x\to c}\frac{f(x)}{g(x)}=\lim_{x\to c}\frac{f'(x)}{g'(x)}$ ។

2. ស្រាយបញ្ជាក់រូបមន្តលីមីតត្រីកោណមាត្រខាងក្រោម ៖

ក. $\lim_{x\to 0}\frac{\sin x}{x}=\lim_{x\to 0}\frac{x}{\sin x}=1$ ខ. $\lim_{x\to 0}\frac{1-\cos x}{x}=0$ គ. $\lim_{x\to 0}\frac{\tan x}{x}=\lim_{x\to 0}\frac{x}{\tan x}=1$ ។

3. ស្រាយបញ្ជាក់រូបមន្តលីមីតអនុគមន៍អិចស្ប៉ូណង់ស្យែលខាងក្រោម ៖

ក. $\lim_{x\to+\infty} e^x=+\infty$ ខ. $\lim_{x\to-\infty} e^x = 0$ គ. $\lim_{x\to+\infty}\frac{e^x}{x}=+\infty$

ឃ. $\lim_{x\to+\infty}\frac{e^x}{x^n}=+\infty\ ,\ n>0$ ង. $\lim_{x\to+\infty}\frac{x^n}{e^x}=0\ ,\ n>0$ ច. $\lim_{x\to 0}\frac{e^x-1}{x}=1$

ឆ. $\lim_{u\to 0}\frac{e^u-1}{u}=1$ ជ. $\lim_{x\to 0}\frac{(1+x)^n-1}{x}=n$ ឈ. $\lim_{x\to 0}\frac{a^x-1}{x}=\ln a\ ,\ 0<a\neq 1$

ញ. $\lim_{x\to+\infty}\left(1+\frac{1}{x}\right)^x=e$ ដ. $\lim_{x\to 0}(1+x)^{\frac{1}{x}}=e$

4. ស្រាយបញ្ជាក់រូបមន្តលីមីតអនុគមន៍លោការីតនេពែខាងក្រោម ៖

ក. $\lim_{x\to+\infty}\ln x=+\infty$ ខ. $\lim_{x\to 0^+}\ln x=-\infty$ គ. $\lim_{x\to+\infty}\frac{\ln x}{x}=0$

ឃ. $\lim_{x\to 0^+}x\ln x=0$ ង. $\lim_{x\to+\infty}\frac{\ln x}{x^n}=0$ ច. $\lim_{x\to 0^+}x^n\ln x=0$

ឆ. $\lim_{x\to+\infty}x^n\ln x=+\infty$ ជ. $\lim_{x\to 0^+}\frac{\ln x}{x^n}=-\infty$ ឈ. $\lim_{x\to 0}\frac{\ln(1+x)}{x}=1\ ,x>-1$

5. ស្រាយបញ្ជាក់ថា បើអនុគមន៍ $f$ ជាប់ ហើយកើនដាច់ខាត ឬចុះដាច់ខាតលើចន្លោះបិទ $[a\,,b]$ នោះចំពោះគ្រប់ចំនួន $k$ នៅចន្លោះ $f(a)$ និង $f(b)$ សមីការ $f(x)=k$ មានចម្លើយតែមួយគត់ក្នុងចន្លោះ $[a\,,b]$ ។

6. ចំពោះស៊េរីអនន្ត $\sum_{n=1}^{\infty}a_n$ ស្រាយបញ្ជាក់ថា ៖

ក. បើស៊េរី $\sum_{n=1}^{\infty}a_n$ ជាស៊េរីរួមនោះ $\lim_{n\to+\infty}a_n=0$ ។

ខ. បើស្វ៊ីត $(a_n)$ មិនរួមរក 0 នោះ $\sum_{n=1}^{\infty}a_n$ ជាស៊េរីរីក ។

7. ស្រាយបញ្ជាក់ថា បើអនុគមន៍ $f$ ជាប់លើចន្លោះបិទ $[a\,,b]$ និង $k$ ជាចំនួនមួយនៅចន្លោះ $f(a)$ និង $f(b)$ នោះមានចំនួន $c$ មួយយ៉ាងតិចក្នុងចន្លោះបិទ $[a\,,b]$ ដែល $f(c)=k$ ។

# ការស្រាយបញ្ជាក់លើមេរៀន លីមីត

1. ស្រាយបញ្ជាក់ទ្រឹស្តីបទ L'Hospital ៖ ចំពោះ $\lim_{x\to c}\frac{f(x)}{g(x)}$ មានរាងមិនកំណត់ $\frac{0}{0}$ ឬ $\frac{\infty}{\infty}$ គេបាន $\lim_{x\to c}\frac{f(x)}{g(x)}=\lim_{x\to c}\frac{f'(x)}{g'(x)}$

គេមាន $\lim_{x\to c} f(x)=\lim_{x\to c} g(x)=0$ ឬ $\lim_{x\to c} f(x)=\lim_{x\to c} g(x)=\pm\infty$

តាមលក្ខណៈសមាមាត្រ $\frac{f(x)}{g(x)}=\frac{f(c)}{g(c)}=\frac{f(x)-f(c)}{g(x)-g(c)}$

គេបាន $\lim_{x\to c}\frac{f(x)}{g(x)}=\lim_{x\to c}\frac{f(x)-f(c)}{g(x)-g(c)}$ (ចែកភាគយក និងភាគបែងដោយ $x-c$)

$$=\lim_{x\to c}\frac{\frac{f(x)-f(c)}{x-c}}{\frac{g(x)-g(c)}{x-c}}$$

$$=\frac{\lim_{x\to c}\frac{f(x)-f(c)}{x-c}}{\lim_{x\to c}\frac{g(x)-g(c)}{x-c}}$$

$$=\frac{f'(c)}{g'(c)}=\lim_{x\to c}\frac{f'(x)}{g'(x)}$$

ព្រោះតាមនិយមន័យដេរីវេ $f'(c)=\lim_{x\to c}\frac{f(x)-f(c)}{x-c}$ , $g'(c)=\lim_{x\to c}\frac{g(x)-g(c)}{x-c}$

ដូចនេះ: ទ្រឹស្តីបទ L'Hospital បើ $\lim_{x\to c}\frac{f(x)}{g(x)}$ រាង $\frac{0}{0}$ ឬ $\frac{\infty}{\infty}$ នោះ $\lim_{x\to c}\frac{f(x)}{g(x)}=\lim_{x\to c}\frac{f'(x)}{g'(x)}$ ត្រូវបានស្រាយបញ្ជាក់ ។

**សម្គាល់ : ត្រឹមកម្រិតថ្នាក់ទី១២ មិនមានប្រើ L'Hospital នោះទេ ប៉ុន្តែអ្នករៀបរៀងចង់ឱ្យមានការស្រាយបញ្ជាក់ច្រើនរបៀប ហេតុនេះ ទើបមានការស្រាយបញ្ជាក់ទ្រឹស្តីបទ L'Hospital ជាមុន ដើម្បីយកទ្រឹស្តីនេះ បកស្រាយរូបមន្តផ្សេងៗទៀត ។**

2. **ស្រាយបញ្ជាក់រូបមន្តលីមីតត្រីកោណមាត្រខាងក្រោម ៖**

**ក. ស្រាយបញ្ជាក់ថា** $\lim_{x\to 0}\frac{\sin x}{x}=\lim_{x\to 0}\frac{x}{\sin x}=1$

**➤របៀបទី១** តាមទ្រឹស្តីបទ L'Hospital

គេមាន $\lim_{x\to 0}\frac{\sin x}{x}$ មានរាងមិនកំណត់ $\frac{0}{0}$ តាមទ្រឹស្តីបទ L'Hospital គេបាន $\lim_{x\to 0}\frac{\sin x}{x}=\lim_{x\to 0}\frac{(\sin x)'}{x'}=\lim_{x\to 0}\cos x=1$

ហើយ $\lim_{x\to 0}\frac{x}{\sin x}$ មានរាងមិនកំណត់ $\frac{0}{0}$ តាមទ្រឹស្តីបទ L'Hospital គេបាន $\lim_{x\to 0}\frac{x}{\sin x}=\lim_{x\to 0}\frac{x'}{(\sin x)'}=\lim_{x\to 0}\frac{1}{\cos x}=1$

ដូចនេះ: រូបមន្ត $\lim_{x\to 0}\frac{\sin x}{x}=\lim_{x\to 0}\frac{x}{\sin x}=1$ ត្រូវបានស្រាយបញ្ជាក់ ។

**>របៀបទី២** តាមផ្ទៃក្រឡាចម្រៀកថាស

គេមាន $x$ ជារង្វាស់មុំគិតជារ៉ាដ្យង់ ដែល $-\frac{\pi}{2}<x<0$ ឬ $0<x<\frac{\pi}{2}$ គេបាន ៖




ផ្ទៃក្រឡា $\Delta OAT \geq$ ផ្ទៃក្រឡាចម្រៀកថាស $OAP \geq$ ក្រឡាផ្ទៃ $\Delta OAP$

$$\frac{1}{2}\times OA\times AT \geq \pi r^2\times\frac{x}{2\pi}\geq\frac{1}{2}\times OA\times HP$$

តែ $r=OA=1$ , $AT=\tan x$ , $HP=\sin x$

គេបាន $\frac{1}{2}\times 1\times\tan x\geq\pi\times 1^2\times\frac{x}{2\pi}\geq\frac{1}{2}\times 1\times\sin x$

$$\tan x\geq x\geq\sin x$$

$$\frac{\sin x}{\cos x}\geq x\geq\sin x \quad (1)$$

គេគុណវិសមភាព $(1)$ នឹង $\frac{1}{\sin x}$ គេបានទិសដៅវិសមភាពប្រែប្រួល ឬមិនប្រែប្រួលដូចខាងក្រោម ៖

• បើ $-\frac{\pi}{2}<x<0$ នោះ $\frac{1}{\sin x}<0$ គេបាន $(1)$ : $\frac{1}{\cos x}\leq\frac{x}{\sin x}\leq 1$

នាំឱ្យ $\lim\limits_{x\to0}\frac{1}{\cos x}\leq\lim\limits_{x\to0}\frac{x}{\sin x}\leq\lim\limits_{x\to0}1$ ឬ $1\leq\lim\limits_{x\to0}\frac{x}{\sin x}\leq 1$ នោះ $\lim\limits_{x\to0}\frac{x}{\sin x}=1$

• បើ $0<x<\frac{\pi}{2}$ នោះ $\frac{1}{\sin x}>0$ គេបាន $(1)$ : $\frac{1}{\cos x}\geq\frac{x}{\sin x}\geq 1$

នាំឱ្យ $\lim\limits_{x\to0}\frac{1}{\cos x}\geq\lim\limits_{x\to0}\frac{x}{\sin x}\geq\lim\limits_{x\to0}1$ ឬ $1\geq\lim\limits_{x\to0}\frac{x}{\sin x}\geq 1$ នោះ $\lim\limits_{x\to0}\frac{x}{\sin x}=1$

ម្យ៉ាងទៀត $\lim\limits_{x\to0}\frac{\sin x}{x}=\lim\limits_{x\to0}\frac{1}{\frac{x}{\sin x}}=\frac{1}{1}=1$

ដូចនេះ | រូបមន្ត $\lim\limits_{x\to0}\frac{x}{\sin x}=1$ និង $\lim\limits_{x\to0}\frac{\sin x}{x}=1$ ត្រូវបានស្រាយបញ្ជាក់ | ។

**ខ. ស្រាយបញ្ជាក់ថា** $\lim\limits_{x\to0}\frac{1-\cos x}{x}=0$

**>របៀបទី១** ប្រើរូបមន្ត $1-\cos 2x=2\sin^2 x$ ឬអាចសរសេរ $1-\cos x=2\sin^2\frac{x}{2}$

គេបាន $\lim\limits_{x\to0}\frac{1-\cos x}{x}=\lim\limits_{x\to0}\frac{2\sin^2\frac{x}{2}}{x}=\lim\limits_{x\to0}\frac{2\sin^2\frac{x}{2}}{2\times\frac{x}{2}}=\lim\limits_{x\to0}\left(\frac{\sin\frac{x}{2}}{\frac{x}{2}}\times\sin\frac{x}{2}\right)=1\times0=0$

**>របៀបទី២** ប្រើទ្រឹស្តីបទ L'Hospital

គេបាន $\lim\limits_{x\to0}\frac{1-\cos x}{x}=\lim\limits_{x\to0}\frac{(1-\cos x)'}{x'}=\lim\limits_{x\to0}\sin x=0$

ដូចនេះ | រូបមន្ត $\lim\limits_{x\to0}\frac{1-\cos x}{x}=0$ ត្រូវបានស្រាយបញ្ជាក់ | ។

គ. ស្រាយបញ្ជាក់ថា $\lim_{x\to 0}\frac{\tan x}{x}=\lim_{x\to 0}\frac{x}{\tan x}=1$

➢របៀបទី១ ប្រើរូបមន្ត $\tan x=\frac{\sin x}{\cos x}$

គេបាន $\lim_{x\to 0}\frac{\tan x}{x}=\lim_{x\to 0}\frac{\frac{\sin x}{\cos x}}{x}=\lim_{x\to 0}\frac{\sin x}{x\cos x}=\lim_{x\to 0}\left(\frac{\sin x}{x}\times\frac{1}{\cos x}\right)=1\times 1=1$

ហើយ $\lim_{x\to 0}\frac{x}{\tan x}=\lim_{x\to 0}\frac{x}{\frac{\sin x}{\cos x}}=\lim_{x\to 0}\left(\frac{x}{\sin x}\times\cos x\right)=1\times 1=1$

➢របៀបទី២ ប្រើទ្រឹស្តីបទ L'Hospital

គេបាន $\lim_{x\to 0}\frac{\tan x}{x}=\lim_{x\to 0}\frac{(\tan x)'}{x'}=\lim_{x\to 0}\frac{1}{\cos^2 x}=\frac{1}{1^2}=1$

ហើយ $\lim_{x\to 0}\frac{x}{\tan x}=\lim_{x\to 0}\frac{x'}{(\tan x)'}=\lim_{x\to 0}\frac{1}{\frac{1}{\cos^2 x}}=\frac{1}{\frac{1}{1^2}}=\frac{1}{1}=1$

ដូចនេះ: រូបមន្ត $\lim_{x\to 0}\frac{\tan x}{x}=1$ និង $\lim_{x\to 0}\frac{x}{\tan x}=1$ ត្រូវបានស្រាយបញ្ជាក់ ។

3. ស្រាយបញ្ជាក់រូបមន្តលីមីតអនុគមន៍អិចស្ប៉ូណង់ស្យែលខាងក្រោម ៖

ក. ស្រាយបញ្ជាក់រូបមន្តលីមីត $\lim_{x\to+\infty}e^x=+\infty$

គេប្រើតារាងតម្លៃលេខដើម្បីបង្ហាញតម្លៃនៃ $e^x$ ពេល $x\to+\infty$ ដូចខាងក្រោម ៖

| $x$ | 1 | 5 | 10 | 50 | 100 | 600 | ... | $+\infty$ |
|---|---|---|---|---|---|---|---|---|
| $e^x$ | 2.7 | 148.4 | $2.2\times10^4$ | $5.2\times10^{21}$ | $2.7\times10^{43}$ | $3.8\times10^{260}$ | ... | $+\infty$ |

តាមតារាងនេះគេសង្កេតឃើញថា បើ $x$ យកតម្លៃវិជ្ជមានកាន់តែធំទៅៗគ្មានទីបញ្ចប់ នោះ $e^x$ ក៏មានតម្លៃវិជ្ជមានកាន់តែធំទៅៗគ្មានទីបញ្ចប់ដែរ ។ តាមហេតុផលនេះគេបាន $\lim_{x\to+\infty}e^x=+\infty$ ។

ដូចនេះ: ស្រាយបញ្ជាក់បានថា $\lim_{x\to+\infty}e^x=+\infty$ ។

ខ. ស្រាយបញ្ជាក់រូបមន្តលីមីត $\lim_{x\to-\infty}e^x=0$

➢របៀបទី១ ប្រើតារាងតម្លៃលេខ

គេប្រើតារាងតម្លៃលេខដើម្បីបង្ហាញតម្លៃនៃ $e^x$ ពេល $x\to-\infty$ ដូចខាងក្រោម ៖

| $x$ | $-1$ | $-5$ | $-10$ | $-60$ | $-200$ | $-700$ | ... | $-\infty$ |
|---|---|---|---|---|---|---|---|---|
| $e^x$ | 0.4 | 0.006 | $4.5\times10^{-4}$ | $8.8\times10^{-27}$ | $1.8\times10^{-87}$ | $9.9\times10^{-305}$ | ... | 0 |

តាមតារាងនេះគេសង្កេតឃើញថា បើ $x$ យកតម្លៃអវិជ្ជមានកាន់តែតូចទៅៗគ្មានទីបញ្ចប់ នោះ $e^x$ មានតម្លៃវិជ្ជមានកាន់តែតូចទៅៗស្ទើរតែសូន្យ ។ តាមហេតុផលនេះគេបាន $\lim_{x\to-\infty}e^x=0$ ។

ដូចនេះ: ស្រាយបញ្ជាក់បានថា $\lim_{x\to+\infty}e^x=+\infty$ ។

➢**របៀបទី២** ប្រើទំនាក់ទំនង $\lim_{x\to+\infty} e^x = +\infty$

គេចង់គណនា $A = \lim_{x\to-\infty} e^x$

គេតាង $t = -x \Rightarrow x = -t$

បើ $x \to -\infty \Rightarrow t \to +\infty$

គេបាន $A = \lim_{x\to-\infty} e^x = \lim_{t\to+\infty} e^{-t} = \lim_{t\to+\infty} \frac{1}{e^t} = \frac{1}{\lim_{t\to+\infty} e^t} = 0$ ព្រោះបើ ភាគបែងធំមិនកំណត់ នោះ $\frac{1}{\lim_{t\to+\infty} e^t}$ ស្មើរតែសូន្យ ។

ដូចនេះ: **ស្រាយបញ្ជាក់បានថា $\lim_{x\to+\infty} e^x = +\infty$** ។

**គ. ស្រាយបញ្ជាក់រូបមន្តលីមីត** $\lim_{x\to+\infty} \frac{e^x}{x} = +\infty$

➢**របៀបទី១** ប្រើតារាងតម្លៃលេខ

គេប្រើតារាងតម្លៃលេខដើម្បីបង្ហាញតម្លៃនៃ $\frac{e^x}{x}$ ពេល $x \to +\infty$ ដូចខាងក្រោម ៖

| $x$ | 1 | 5 | 10 | 60 | 300 | 700 | ... | $+\infty$ |
|---|---|---|---|---|---|---|---|---|
| $\frac{e^x}{x}$ | 2.7 | 29.7 | $2.2\times10^{3}$ | $1.9\times10^{24}$ | $6.5\times10^{127}$ | $1.4\times10^{301}$ | ... | $+\infty$ |

តាមតារាងនេះគេសង្កេតឃើញថា បើ $x$ យកតម្លៃវិជ្ជមានកាន់តែធំទៅៗគ្មានទីបញ្ចប់ នោះ $\frac{e^x}{x}$ មានតម្លៃវិជ្ជមានកាន់តែធំទៅៗ គ្មានទីបញ្ចប់ដែរ ។ តាមហេតុផលនេះគេបាន $\lim_{x\to+\infty} \frac{e^x}{x} = +\infty$ ។

ដូចនេះ: **ស្រាយបញ្ជាក់បានថា $\lim_{x\to+\infty} \frac{e^x}{x} = +\infty$** ។

➢**របៀបទី២** ប្រើទ្រឹស្តីបទ L'Hospital

គេមាន $\lim_{x\to+\infty} \frac{e^x}{x} = \lim_{x\to+\infty} \frac{(e^x)'}{x'} = \lim_{x\to+\infty} e^x = +\infty$ (ព្រោះ: $\lim_{x\to+\infty} e^x = +\infty$)

ដូចនេះ: **ស្រាយបញ្ជាក់បានថា $\lim_{x\to+\infty} \frac{e^x}{x} = +\infty$** ។

**ឃ. ស្រាយបញ្ជាក់រូបមន្តលីមីត** $\lim_{x\to+\infty} \frac{e^x}{x^n} = +\infty$ , $n > 0$ ($n$ ជាចំនួនកំណត់មួយ)

➢**របៀបទី១** ប្រើតារាងតម្លៃលេខ

គេប្រើតារាងតម្លៃលេខដើម្បីបង្ហាញតម្លៃនៃ $\frac{e^x}{x^n}$ ពេល $x \to +\infty$ ដោយសន្មត់យក $n = 10$ ដូចខាងក្រោម ៖

| $x$ | 1 | 5 | 10 | 60 | 300 | 700 | ... | $+\infty$ |
|---|---|---|---|---|---|---|---|---|
| $\frac{e^x}{x^{10}}$ | 2.7 | $1.5\times10^{-5}$ | $2.2\times10^{-6}$ | $1.9\times10^{8}$ | $3.3\times10^{105}$ | $3.6\times10^{275}$ | ... | $+\infty$ |

តាមតារាងនេះគេសង្កេតឃើញថា បើ $x$ យកតម្លៃវិជ្ជមានកាន់តែធំទៅៗគ្មានទីបញ្ចប់ នោះ $\frac{e^x}{x^{10}}$ មានតម្លៃវិជ្ជមានកាន់តែធំទៅៗ គ្មានទីបញ្ចប់ដែរ ។ តាមហេតុផលនេះគេបាន $\lim_{x\to+\infty} \frac{e^x}{x^n} = +\infty$ ។

ដូចនេះ: **ស្រាយបញ្ជាក់បានថា $\lim_{x\to+\infty} \frac{e^x}{x^n} = +\infty$** ។

➤របៀបទី២ ប្រើទ្រឹស្តីបទ L'Hospital

គេធ្វើដេរីវេបន្តបន្ទាប់នៃ $\lim\limits_{x\to+\infty}\frac{e^x}{x^n}$ រហូតអស់រាងមិនកំណត់ $\frac{\infty}{\infty}$

$$\lim_{x\to+\infty}\frac{e^x}{x^n}=\lim_{x\to+\infty}\frac{\left(e^x\right)'}{\left(x^n\right)'}=\lim_{x\to+\infty}\frac{\left(e^x\right)'}{\left(nx^{n-1}\right)'}=\lim_{x\to+\infty}\frac{\left(e^x\right)'}{\left(n(n-1)x^{n-2}\right)'}=\lim_{x\to+\infty}\frac{\left(e^x\right)'}{\left(n(n-1)(n-2)x^{n-3}\right)'}=\ldots=\lim_{x\to+\infty}\frac{e^x}{n!}=+\infty$$

(ព្រោះ $\lim\limits_{x\to+\infty}\frac{e^x}{n!}=+\infty$ )

ដូចនេះ ស្រាយបញ្ជាក់បានថា $\lim\limits_{x\to+\infty}\frac{e^x}{x^n}=+\infty$ ។

**ង. ស្រាយបញ្ជាក់រូបមន្តលីមីត** $\lim\limits_{x\to+\infty}\frac{x^n}{e^x}=0\ ,\ n>0$

➤របៀបទី១ គេមាន $\lim\limits_{x\to+\infty}\frac{e^x}{x^n}=+\infty$

នាំឱ្យ $\lim\limits_{x\to+\infty}\frac{x^n}{e^x}=\lim\limits_{x\to+\infty}\frac{1}{\frac{e^x}{x^n}}=0$ ព្រោះ បើភាគបែងកាន់តែធំទៅៗមិនកំណត់ វានឹងធ្វើឱ្យតម្លៃកន្សោមស្មើរស្មើសូន្យ ។

ដូចនេះ ស្រាយបញ្ជាក់បានថា $\lim\limits_{x\to+\infty}\frac{x^n}{e^x}=0\ ,\ n>0$ ។

➤របៀបទី២ ប្រើទ្រឹស្តីបទ L'Hospital

គេធ្វើដេរីវេបន្តបន្ទាប់នៃ $\lim\limits_{x\to+\infty}\frac{x^n}{e^x}$ រហូតអស់រាងមិនកំណត់ $\frac{\infty}{\infty}$

$$\lim_{x\to+\infty}\frac{x^n}{e^x}=\lim_{x\to+\infty}\frac{\left(x^n\right)'}{\left(e^x\right)'}=\lim_{x\to+\infty}\frac{\left(nx^{n-1}\right)'}{\left(e^x\right)'}=\lim_{x\to+\infty}\frac{\left(n(n-1)x^{n-2}\right)'}{\left(e^x\right)'}=\lim_{x\to+\infty}\frac{\left(n(n-1)(n-2)x^{n-3}\right)'}{\left(e^x\right)'}=\ldots=\lim_{x\to+\infty}\frac{n!}{e^x}=0$$

(ព្រោះ $\lim\limits_{x\to+\infty}\frac{n!}{e^x}=0$ )

ដូចនេះ ស្រាយបញ្ជាក់បានថា $\lim\limits_{x\to+\infty}\frac{x^n}{e^x}=0\ ,\ n>0$ ។

**ច. ស្រាយបញ្ជាក់រូបមន្តលីមីត** $\lim\limits_{x\to0}\frac{e^x-1}{x}=1$

➤របៀបទី១ ប្រើតារាងតម្លៃលេខ

គេប្រើតារាងតម្លៃលេខដើម្បីបង្ហាញតម្លៃនៃ $\frac{e^x-1}{x}$ ពេល $x\to0$ ដូចខាងក្រោម ៖

| $x$ | 1 | 0.1 | 0.001 | 0.00001 | 0.000001 | 0.0000001 | ... | 0 |
|---|---|---|---|---|---|---|---|---|
| $\frac{e^x-1}{x}$ | 1.7 | 1.05 | 1.0005 | 1.000005 | 1.0000005 | 1.00000005 | ... | 1 |

តាមតាងរាងនេះគេសង្កេតឃើញថា បើ $x$ យកតម្លៃវិជ្ជមានកាន់តែតូចទៅៗស្មើរសូន្យ នោះ $\frac{e^x-1}{x}$ មានតម្លៃវិជ្ជមានស្មើរស្មើមួយ ។

ដូចនេះ ស្រាយបញ្ជាក់បានថា $\lim\limits_{x\to0}\frac{e^x-1}{x}=1$ ។

➢របៀបទី២ ប្រើទ្រឹស្តីបទ L'Hospital

គេមាន $\lim_{x\to 0}\frac{e^x-1}{x}=\lim_{x\to 0}\frac{(e^x-1)'}{x'}=\lim_{x\to 0}e^x=e^0=1$

ដូចនេះ ស្រាយបញ្ជាក់បានថា $\lim_{x\to 0}\frac{e^x-1}{x}=1$ ។

**ឆ.ស្រាយបញ្ជាក់រូបមន្តលីមីត** $\lim_{u\to 0}\frac{e^u-1}{u}=1$

ដូចសម្រាយ ច. ខាងលើគ្រាន់តែប្តូរអថេរ $x$ ទៅជា $u$ ដូចនេះ គេបាន $\lim_{u\to 0}\frac{e^u-1}{u}=1$ ។

**ជ. ស្រាយបញ្ជាក់រូបមន្តលីមីត** $\lim_{x\to 0}\frac{(1+x)^n-1}{x}=n$

➢របៀបទី១ ប្រើស្វ័យគុណនៃទ្វេធា

គេមាន $\lim_{x\to 0}\frac{(1+x)^n-1}{x}=\lim_{x\to 0}\frac{\left[(1+x)-1\right]\left[(1+x)^{n-1}+(1+x)^{n-2}+(1+x)^{n-3}+\ldots+(1+x)+1\right]}{x}$

$=\lim_{x\to 0}\left[(1+x)^{n-1}+(1+x)^{n-2}+(1+x)^{n-3}+\ldots+(1+x)+1\right]$

$=\underbrace{1+1+1+\ldots+1}_{n\text{ តួ}}=n$

ដូចនេះ ស្រាយបញ្ជាក់បានថា $\lim_{x\to 0}\frac{(1+x)^n-1}{x}=n$ ។

➢របៀបទី២ ប្រើទ្រឹស្តីបទ L'Hospital

គេមាន $\lim_{x\to 0}\frac{(1+x)^n-1}{x}=\lim_{x\to 0}\frac{\left[(1+x)^n-1\right]'}{x'}$

$=\lim_{x\to 0}\left[n(1+x)'(1+x)^n\right]$

$=\lim_{x\to 0}\left[n(1+x)^n\right]$

$=n\times 1^n=n$

ដូចនេះ ស្រាយបញ្ជាក់បានថា $\lim_{x\to 0}\frac{(1+x)^n-1}{x}=n$ ។

**ឈ. ស្រាយបញ្ជាក់រូបមន្តលីមីត** $\lim_{x\to 0}\frac{a^x-1}{x}=\ln a$ **ដែល** $0<a\neq 1$

គេប្រើទ្រឹស្តីបទ L'Hospital

គេមាន $\lim_{x\to 0}\frac{a^x-1}{x}=\lim_{x\to 0}\frac{(a^x-1)'}{x'}$

$=\lim_{x\to 0}a^x\ln a=a^0\times\ln a=\ln a$ ព្រោះ $(a^x)'=a^x\ln a$

ដូចនេះ ស្រាយបញ្ជាក់បានថា $\lim_{x\to 0}\frac{a^x-1}{x}=\ln a$ ។

**ញ. ស្រាយបញ្ជាក់រូបមន្តលីមីត** $\lim_{x\to+\infty}\left(1+\frac{1}{x}\right)^x = e$

គេប្រើតារាងតម្លៃលេខដើម្បីបង្ហាញតម្លៃនៃ $\left(1+\frac{1}{x}\right)^x$ ពេល $x\to+\infty$ ដូចខាងក្រោម ៖

| $x$ | $\frac{1}{x}$ | $1+\frac{1}{x}$ | $\left(1+\frac{1}{x}\right)^x$ |
|---|---|---|---|
| 1 | 1 | 2 | 2.000 000 00 |
| 10 | $0.1=10^{-1}$ | $1.1=1+10^{-1}$ | 2.593 742 46 |
| $10^2$ | $0.01=10^{-2}$ | $1.01=1+10^{-2}$ | 2.704 813 83 |
| $10^3$ | $10^{-3}$ | $1.001=1+10^{-3}$ | 2.716 923 93 |
| $10^4$ | $10^{-4}$ | $1.0001=1+10^{-4}$ | 2.718 145 93 |
| $10^5$ | $10^{-5}$ | $1.00001=1+10^{-5}$ | 2.718 268 24 |
| $10^6$ | $10^{-6}$ | $1.000001=1+10^{-6}$ | 2.718 280 47 |
| $10^7$ | $10^{-7}$ | $1.0000001=1+10^{-7}$ | 2.718 281 69 |
| $10^8$ | $10^{-8}$ | $1.00000001=1+10^{-8}$ | 2.718 281 81 |
| $10^9$ | $10^{-9}$ | $1+10^{-9}$ | 2.718 281 83 $\approx e$ |
| ⋮ | ⋮ | ⋮ | ⋮ |

តាមតារាងនេះគេសង្កេតឃើញថា បើ $x$ យកតម្លៃវិជ្ជមានកាន់តែធំទៅៗគ្មានទីបញ្ចប់ នោះ $\left(1+\frac{1}{x}\right)^x$ មានតម្លៃវិជ្ជមានកាន់តែខិតទៅរកតម្លៃលីមីតមួយស្មើ $e=2.718281$ ។ តាមហេតុផលនេះគេបាន $\lim_{x\to+\infty}\left(1+\frac{1}{x}\right)^x = e$ ។

ដូចនេះ: ស្រាយបញ្ជាក់បានថា $\lim_{x\to+\infty}\left(1+\frac{1}{x}\right)^x = e$ ។

**ដ. ស្រាយបញ្ជាក់រូបមន្តលីមីត** $\lim_{x\to0}(1+x)^{\frac{1}{x}} = e$

គេមាន $\lim_{x\to0}(1+x)^{\frac{1}{x}} = e$

គេតាង $t=\frac{1}{x} \Rightarrow x=\frac{1}{t}$

បើ $x\to0^+ \Rightarrow t\to+\infty$

គេបាន $\lim_{x\to0}(1+x)^{\frac{1}{x}} = \lim_{t\to+\infty}\left(1+\frac{1}{t}\right)^t = e$ ព្រោះតាមសម្រាយ ញ. $\lim_{x\to+\infty}\left(1+\frac{1}{x}\right)^x = e$

ដូចនេះ: ស្រាយបញ្ជាក់បានថា $\lim_{x\to0}(1+x)^{\frac{1}{x}} = e$ ។

4. ស្រាយបញ្ជាក់រូបមន្តលីមីតអនុគមន៍លោការីតនេពខាងក្រោម ៖

ក. ស្រាយបញ្ជាក់រូបមន្ត $\lim_{x\to+\infty}\ln x=+\infty$

គេប្រើតារាងតម្លៃលេខដើម្បីបង្ហាញតម្លៃនៃ $\ln x$ ពេល $x\to+\infty$ ដូចខាងក្រោម ៖

| $x$ | 20 | 50 | 200 | 1000 | 10000 | 1000000 | ... | $+\infty$ |
|---|---|---|---|---|---|---|---|---|
| $\ln x$ | 2.996 | 3.912 | 5.298 | 6.908 | 9.210 | 13.816 | ... | $+\infty$ |

តាមតារាងនេះគេសង្កេតឃើញថា បើ $x$ យកតម្លៃវិជ្ជមានកាន់តែធំទៅៗគ្មានទីបញ្ចប់ នោះ $\ln x$ ក៏មានតម្លៃវិជ្ជមានកាន់តែធំទៅៗគ្មានទីបញ្ចប់ដែរ ។ តាមហេតុផលនេះគេបាន $\lim_{x\to+\infty}\ln x=+\infty$ ។

ដូចនេះ: ស្រាយបញ្ជាក់បានថា $\lim_{x\to+\infty}\ln x=+\infty$ ។

ខ.ស្រាយបញ្ជាក់រូបមន្ត $\lim_{x\to0^+}\ln x=-\infty$

គេមាន $\lim_{x\to0^+}\ln x$

គេតាង $x=\frac{1}{t} \Rightarrow t=\frac{1}{x}$

បើ $x\to0^+ \Rightarrow t\to+\infty$

គេបាន $\lim_{x\to0^+}\ln x=\lim_{t\to+\infty}\ln\frac{1}{t}=\lim_{t\to+\infty}\ln t^{-1}=\lim_{t\to+\infty}(-\ln t)=-\lim_{t\to+\infty}(\ln t)=-(+\infty)=-\infty$

ដូចនេះ: ស្រាយបញ្ជាក់បានថា $\lim_{x\to0^+}\ln x=-\infty$ ។

គ. ស្រាយបញ្ជាក់រូបមន្ត $\lim_{x\to+\infty}\frac{\ln x}{x}=0$

➢របៀបទី១ តាមតារាងតម្លៃលេខ

គេប្រើតារាងតម្លៃលេខដើម្បីបង្ហាញតម្លៃនៃ $\frac{\ln x}{x}$ ពេល $x\to+\infty$ ដូចខាងក្រោម ៖

| $x$ | 20 | 50 | 200 | 1000 | 10000 | 1000000 | ... | $+\infty$ |
|---|---|---|---|---|---|---|---|---|
| $\frac{\ln x}{x}$ | 0.1498 | 0.0782 | 0.0265 | 0.00691 | 0.00092 | 0.00001 | ... | 0 |

តាមតារាងនេះគេសង្កេតឃើញថា បើ $x$ យកតម្លៃវិជ្ជមានកាន់តែធំទៅៗគ្មានទីបញ្ចប់ នោះ $\frac{\ln x}{x}$ មានតម្លៃវិជ្ជមានកាន់តែតូចទៅៗស្ទើរតែសូន្យ ។ តាមហេតុផលនេះគេបាន $\lim_{x\to+\infty}\frac{\ln x}{x}=0$ ។

ដូចនេះ: ស្រាយបញ្ជាក់បានថា $\lim_{x\to+\infty}\frac{\ln x}{x}=0$ ។

➢របៀបទី២ គេប្រើទ្រឹស្តីបទ L'Hospital

គេមាន $\lim_{x\to+\infty}\frac{\ln x}{x}=\lim_{x\to+\infty}\frac{(\ln x)'}{x'}=\lim_{x\to+\infty}\frac{1}{x}=0$ ព្រោះ បើ $x\to+\infty$ នោះ $\frac{1}{x}\to0$

ដូចនេះ: ស្រាយបញ្ជាក់បានថា $\lim_{x\to+\infty}\frac{\ln x}{x}=0$ ។

**ឃ. ស្រាយបញ្ជាក់រូបមន្ត** $\lim\limits_{x\to 0^+} x\ln x = 0$

គេមាន $\lim\limits_{x\to 0^+} x\ln x$

គេតាង $x=\dfrac{1}{t} \Rightarrow t=\dfrac{1}{x}$

បើ $x\to 0^+ \Rightarrow t\to +\infty$

គេបាន $\lim\limits_{x\to 0^+} x\ln x = \lim\limits_{t\to+\infty}\dfrac{1}{t}\ln\dfrac{1}{t} = \lim\limits_{t\to+\infty}\dfrac{1}{t}\ln t^{-1} = \lim\limits_{t\to+\infty}\left(-\dfrac{\ln t}{t}\right) = -\lim\limits_{t\to+\infty}\dfrac{\ln t}{t} = -0 = 0$ ព្រោះ $\lim\limits_{x\to+\infty}\dfrac{\ln x}{x}=0$

ដូចនេះ: ស្រាយបញ្ជាក់បានថា $\lim\limits_{x\to 0^+} x\ln x = 0$ ។

**ង. ស្រាយបញ្ជាក់រូបមន្ត** $\lim\limits_{x\to+\infty}\dfrac{\ln x}{x^n}=0$

**➢របៀបទី១** តាមតារាងតម្លៃលេខ

គេប្រើតារាងតម្លៃលេខដើម្បីបង្ហាញតម្លៃនៃ $\dfrac{\ln x}{x^n}$ ពេល $x\to+\infty$ ដោយសន្មត់ថា $n=4$ ដូចខាងក្រោម ៖

| $x$ | 2 | 3 | 5 | 8 | 15 | 20 | ... | $+\infty$ |
|---|---|---|---|---|---|---|---|---|
| $\dfrac{\ln x}{x^4}$ | 0.04332 | 0.01356 | 0.00258 | 0.00051 | 0.00005 | 0.00002 | ... | 0 |

តាមតាងរាងនេះគេសង្កេតឃើញថា បើ $x$ យកតម្លៃវិជ្ជមានកាន់តែធំទៅៗគ្មានទីបញ្ចប់ នោះ $\dfrac{\ln x}{x^n}$ មានតម្លៃវិជ្ជមានកាន់តែតូចទៅៗ ស្ទើរតែសូន្យ ។ តាមហេតុផលនេះគេបាន $\lim\limits_{x\to+\infty}\dfrac{\ln x}{x^n}=0$ ។

ដូចនេះ: ស្រាយបញ្ជាក់បានថា $\lim\limits_{x\to+\infty}\dfrac{\ln x}{x^n}=0$ ។

**➢របៀបទី២** គេប្រើទ្រឹស្តីបទ L'Hospital

គេមាន $\lim\limits_{x\to+\infty}\dfrac{\ln x}{x^n} = \lim\limits_{x\to+\infty}\dfrac{(\ln x)'}{(x^n)'} = \lim\limits_{x\to+\infty}\dfrac{\frac{1}{x}}{nx^{n-1}} = \lim\limits_{x\to+\infty}\dfrac{1}{nx^n}=0$ ព្រោះ បើ $x\to+\infty$ នោះ $\dfrac{1}{nx^n}\to 0$

ដូចនេះ: ស្រាយបញ្ជាក់បានថា $\lim\limits_{x\to+\infty}\dfrac{\ln x}{x^n}=0$ ។

**ច. ស្រាយបញ្ជាក់រូបមន្ត** $\lim\limits_{x\to 0^+} x^n\ln x = 0$

គេមាន $\lim\limits_{x\to 0^+} x^n\ln x$

គេតាង $x=\dfrac{1}{t} \Rightarrow t=\dfrac{1}{x}$

បើ $x\to 0^+ \Rightarrow t\to +\infty$

គេបាន $\lim\limits_{x\to 0^+} x^n\ln x = \lim\limits_{t\to+\infty}\left(\dfrac{1}{t}\right)^n\ln\dfrac{1}{t} = \lim\limits_{t\to+\infty}\dfrac{\ln t^{-1}}{t^n} = -\lim\limits_{t\to+\infty}\dfrac{\ln t}{t^n} = -0 = 0$ ព្រោះ $\lim\limits_{x\to+\infty}\dfrac{\ln x}{x^n}=0$

ដូចនេះ: ស្រាយបញ្ជាក់បានថា $\lim\limits_{x\to 0^+} x^n\ln x = 0$ ។

ឆ. ស្រាយបញ្ជាក់រូបមន្ត $\lim\limits_{x\to+\infty} x^n \ln x = +\infty$

គេមាន $\lim\limits_{x\to+\infty} x^n \ln x = \lim\limits_{x\to+\infty} x^n \times \lim\limits_{x\to+\infty} \ln x = (+\infty)(+\infty) = +\infty$

ព្រោះ កាលណា $x \to +\infty$ នោះ $x^n \to +\infty$ និង $\ln x \to +\infty$

ដូចនេះ ស្រាយបញ្ជាក់បានថា $\lim\limits_{x\to+\infty} x^n \ln x = +\infty$ ។

ជ. ស្រាយបញ្ជាក់រូបមន្ត $\lim\limits_{x\to0^+} \frac{\ln x}{x^n} = -\infty$

គេមាន $\lim\limits_{x\to0^+} \frac{\ln x}{x^n}$

គេតាង $x = \frac{1}{t} \quad \Rightarrow \quad t = \frac{1}{x}$

បើ $x \to 0^+ \quad \Rightarrow \quad t \to +\infty$

គេបាន $\lim\limits_{x\to0^+} \frac{\ln x}{x^n} = \lim\limits_{t\to+\infty} \frac{\ln \frac{1}{t}}{\left(\frac{1}{t}\right)^n} = \lim\limits_{t\to+\infty} t^n \ln t^{-1} = -\lim\limits_{t\to+\infty} t^n \ln t = -(+\infty) = -\infty$ ព្រោះ $\lim\limits_{x\to+\infty} x^n \ln x = +\infty$

ដូចនេះ ស្រាយបញ្ជាក់បានថា $\lim\limits_{x\to0^+} \frac{\ln x}{x^n} = -\infty$ ។

ឈ. ស្រាយបញ្ជាក់រូបមន្ត $\lim\limits_{x\to0} \frac{\ln(1+x)}{x} = 1 \ , \ x > -1$

➤របៀបទី១ គេប្រើទំនាក់ទំនងរូបមន្តមានស្រាប់

គេមាន
$$\lim_{x\to0} \frac{\ln(1+x)}{x} = \lim_{x\to0}\left[\frac{1}{x}\ln(1+x)\right]$$
$$= \lim_{x\to0} \ln(1+x)^{\frac{1}{x}}$$
$$= \ln\left[\lim_{x\to0}(1+x)^{\frac{1}{x}}\right]$$
$$= \ln e$$
$$= 1$$

ព្រោះ $\lim\limits_{x\to0}(1+x)^{\frac{1}{x}} = e$ បានស្រាយរួចហើយ

ដូចនេះ ស្រាយបញ្ជាក់បានថា $\lim\limits_{x\to0} \frac{\ln(1+x)}{x} = 1 \ , \ x > -1$ ។

➤របៀបទី២ គេប្រើទ្រឹស្តីបទ L'Hospital

គេមាន $\lim\limits_{x\to0} \frac{\ln(1+x)}{x} = \lim\limits_{x\to0} \frac{[\ln(1+x)]'}{x'} = \lim\limits_{x\to0} \frac{(1+x)'}{1+x} = \lim\limits_{x\to0} \frac{1}{1+x} = \frac{1}{1+0} = 1$

ដូចនេះ ស្រាយបញ្ជាក់បានថា $\lim\limits_{x\to0} \frac{\ln(1+x)}{x} = 1 \ , \ x > -1$ ។

5. **ស្រាយបញ្ជាក់ថា បើអនុគមន៍ $f$ ជាប់ ហើយកើនដាច់ខាត ឬចុះដាច់ខាតលើចន្លោះបិទ $[a\,,b]$ នោះចំពោះគ្រប់ចំនួន $k$ នៅចន្លោះ $f(a)$ និង $f(b)$ សមីការ $f(x)=k$ មានចម្លើយតែមួយគត់ក្នុងចន្លោះ $[a\,,b]$**




អនុគមន៍ $f$ ជាប់និងកើនដាច់ខាតលើចន្លោះបិទ $[a\,,b]$ ។
$f$ កើនដាច់ខាត មានន័យថា បើ $x$ និង $x'$ នៅក្នុងចន្លោះ $[a\,,b]$ ដែល $x<x'$ នោះគេបាន $f(x)<f(x')$ ។

ឱ្យចំនួន $k$ នៅចន្លោះ $f(a)$ និង $f(b)$ , $\left(f(a)<k<f(b)\right)$ និង $f$ ជាអនុគមន៍ជាប់ តាមទ្រឹស្តីបទបញ្ជាក់ថា មានចំនួន $c$ មួយនៅចន្លោះ $a$ និង $b$ ដែល $f(c)=k$ ។

ឧបមាថា មានចំនួនមួយទៀត $c'$ ខុសពី $c$ ផ្ទៀងផ្ទាត់គ្នា $f(c')=k$ នោះ $f(c)=f(c')$ ជាករណីផ្ទុយពីសម្មតិកម្មដែលថា $f$ ជាអនុគមន៍កើនដាច់ខាត ។

ដូចនេះ មានចំនួន $c$ មួយគត់ដែលផ្ទៀងផ្ទាត់ $f(c)=k$ គឺសមីការ $f(x)=k$ មានចម្លើយតែមួយគត់ ។

6. **ចំពោះស៊េរីអនន្ត $\sum_{n=1}^{\infty} a_n$**

**ក. ស្រាយបញ្ជាក់ថាបើស៊េរី $\sum_{n=1}^{\infty} a_n$ ជាស៊េរីរួមនោះ $\lim_{n\to+\infty} a_n=0$**

ឧបមាថា ស៊េរីអនន្ត $\sum_{n=1}^{\infty} a_n$ រួម

គេតាង $S=\sum_{n=1}^{\infty} a_n$ និង $S_n$ ជាផលបូក $n$ តួនៃស៊េរីនេះ

គេបាន $S=\sum_{n=1}^{\infty} a_n = a_1+a_2+a_3+\ldots+a_{n-1}+a_n=S_{n-1}+a_n$

នាំឱ្យ $a_n=S_n-S_{n-1}$

$\lim_{n\to+\infty} a_n=\lim_{n\to+\infty}\left(S_n-S_{n-1}\right)=S-S=0$

ដូចនេះ | ស្រាយបញ្ជាក់បានថា បើស៊េរីអនន្ត $\sum_{n=1}^{\infty} a_n$ ជាស៊េរីរួមនោះ $\lim_{n\to+\infty} a_n=0$ | ។

**ខ. ស្រាយបញ្ជាក់ថាបើស៊្វីត $(a_n)$ មិនរួមរក 0 នោះ $\sum_{n=1}^{\infty} a_n$ ជាស៊េរីរីក**

តាមសំណើផ្ទុយពីសម្មតិកម្មក្នុងសម្រាយ ក. គឺ បើ $\lim_{n\to+\infty} a_n\neq 0$ នោះស៊េរីអនន្ត $\sum_{n=1}^{\infty} a_n$ ជាស៊េរីរីក
ដោយសំណើក្នុងសម្រាយ ក. ពិត នាំឱ្យសំណើផ្ទុយពីសម្មតិកម្មរបស់វាក៏ពិតដែរ ។

ដូចនេះ | គេអាចសន្និដ្ឋានបានថា បើ $a_n$ មិនរួមទៅរក 0 នោះស៊េរី $\sum_{n=1}^{\infty} a_n$ រីក | ។

# ការស្រាយបញ្ជាក់លើមេរៀន ដេរីវេ

1. ដោយប្រើនិយមន័យដេរីវេ រកដេរីវេនៃអនុគមន៍ខាងក្រោម៖

ក. $f(x)=c$ , $c$ ថេរ នោះ $f'(x)=0$

ខ. $f(x)=cx$ , $c$ ថេរ នោះ $f'(x)=c$

គ. $f(x)=ax+b$, $a$ , $b$ ថេរ នោះ $f'(x)=a$

ឃ. $f(x)=x^2+2x$ នោះ $f'(x)=2x+2$

ង. $f(x)=x^3$ នោះ $f'(x)=3x^2$

ច. $f(x)=\sqrt{x}$ នោះ $f'(x)=\dfrac{1}{2\sqrt{x}}$

ឆ. $f(x)=\sqrt[3]{x}$ នោះ $f'(x)=\dfrac{1}{3\sqrt[3]{x^2}}$

ជ. $f(x)=\dfrac{1}{x}$ នោះ $f'(x)=-\dfrac{1}{x^2}$

ឈ. $f(x)=\dfrac{1}{\sqrt{x}}$ នោះ $f'(x)=-\dfrac{1}{2x\sqrt{x}}$

ញ. $f(x)=x^n$ នោះ $f'(x)=nx^{n-1}$

ដ. $y=\log_a x=\dfrac{\ln x}{\ln a}$ នោះ $y'=\dfrac{1}{x\ln a}$

ឋ. $y=a^x$ , $0<a\neq 1$ នោះ $y'=a^x\ln a$

2. បើ $u$ និង $v$ ជាអនុគមន៍នៃ $x$ ស្រាយបញ្ជាក់ថា ៖

ក. $y=au$ , $a$ ថេរ នោះ $y'=u'$

ខ. $y=u^n$ នោះ $y'=nu'u^{n-1}$

គ. $y=u+v-w$ នោះ $y'=u'+v'-w'$

ឃ. $y=uv$ នោះ $y'=u'v+v'u$

ង. $y=\dfrac{u}{v}$ នោះ $y'=\dfrac{u'v-v'u}{v^2}$

ច. $y=\sqrt{u}$ នោះ $y'=\dfrac{u'}{2\sqrt{u}}$

ឆ. $y=\dfrac{1}{u}$ នោះ $y'=-\dfrac{u'}{u^2}$

3. ស្រាយបញ្ជាក់ថា បើ $y=f(u)$ និង $u=g(x)$ នោះគេបាន $\dfrac{dy}{dx}=\dfrac{dy}{du}\times\dfrac{du}{dx}$ ឬ $\dfrac{d}{dx}f\left[u(x)\right]=f'(u)\times u'(x)$ ។

4. ស្រាយបញ្ជាក់ថា បើ $y=u^n$ និង $u$ ជាអនុគមន៍នៃ $x$ នោះ $\dfrac{dy}{dx}=nu^{n-1}\times\dfrac{du}{dx}=nu^{n-1}\times u'$ ។

5. ស្រាយបញ្ជាក់រូបមន្តដេរីវេនៃអនុគមន៍ត្រីកោណមាត្រខាងក្រោម ៖

ក. $y=\sin x$ នោះ $y'=\cos x$

ខ. $y=\cos x$ នោះ $y'=-\sin x$

គ. $y=\tan x$ នោះ $y'=\dfrac{1}{\cos^2 x}=1+\tan^2 x$

ឃ. $y=\cot x$ នោះ $y'=-\dfrac{1}{\sin^2 x}=-(1+\cot^2 x)$

ង. $y=\sin u$ នោះ $y'=u'\cos u$

ច. $y=\cos u$ នោះ $y'=-u'\sin u$

ឆ. $y=\tan u$ នោះ $y'=\dfrac{u'}{\cos^2 u}=u'(1+\tan^2 u)$

ជ. $y=\cot u$ នោះ $y'=-\dfrac{u'}{\sin^2 u}=-u'(1+\cot^2 u)$

6. ស្រាយបញ្ជាក់រូបមន្តដេរីវេនៃអនុគមន៍អិចស្ប៉ូណង់ស្យែលខាងក្រោម ៖

ក. $y=e^x$ នោះ $y'=e^x$

ខ. $y=e^u$ នោះ $y'=u'e^u$

គ. $y=a^x$ នោះ $y'=a^x\ln a$ ដែល $0<a\neq 1$

ឃ. $y=a^u$ នោះ $y'=u'a^u\ln a$

7. ស្រាយបញ្ជាក់រូបមន្តដេរីវេនៃអនុគមន៍លោការីតខាងក្រោម ៖

ក. $y=\ln x$ , $x>0$ នោះ $y'=\dfrac{1}{x}$

ខ. $y=\ln u$ នោះ $y'=\dfrac{u'}{u}$

គ. $y=\log_a x=\dfrac{\ln x}{\ln a}$ នោះ $y'=\dfrac{1}{x\ln a}$

ឃ. $y=\log_a u$ នោះ $y'=\dfrac{u'}{u\ln a}$

8. វិសមភាពកំណើនមានកំណត់ : គេឱ្យ $f$ ជាអនុគមន៍កំណត់និងជាប់ហើយមានដេរីវេលើចន្លោះ $I$ ។ បើមានពីរចំនួនពិត $m$ និង $M$ ដែលចំពោះគ្រប់ $x\in I$ , $m\leq f'(x)\leq M$ នោះគ្រប់ចំនួនពិត $a\,,b\in I$ ដែល $a<b$ គេបាន
$m(b-a)\leq f(b)-f(a)\leq M(b-a)$ ។

9. គេឱ្យអនុគមន៍ $f$ មានដេរីវេលើចន្លោះ $[a\,,b]$ ។ បើមានចំនួនពិត $M$ ដែល $|f'(x)|\leq M$ ចំពោះ $x\in[a\,,b]$ នោះ គេបានវិសមភាព $|f(b)-f(a)|\leq M|b-a|$ ។

10. ទ្រឹស្តីបទរ៉ូល : បើ $f$ ជាអនុគមន៍ជាប់លើចន្លោះ $[a\,,b]$ មានដេរីវេលើចន្លោះ $(a\,,b)$ និង $f(a)=f(b)$ នោះមានចំនួន $c\in(a\,,b)$ យ៉ាងតិចមួយដែល $f'(c)=0$ ។

11. ទ្រឹស្តីបទតម្លៃមធ្យម : បើ $f$ ជាអនុគមន៍ជាប់លើចន្លោះ $[a\,,b]$ មានដេរីវេលើចន្លោះ $(a\,,b)$ នោះមាន $c\in(a\,,b)$ មួយយ៉ាងតិចដែល $f'(c)=\dfrac{f(b)-f(a)}{b-a}$ ។

# ការស្រាយបញ្ជាក់លើមេរៀន ដេរីវេ

1. **ដោយប្រើនិយមន័យដេរីវេ ស្រាយបញ្ជាក់រូបមន្តដេរីវេនៃអនុគមន៍ខាងក្រោម៖**

**ក. ស្រាយបញ្ជាក់ថា** $f(x)=c$ , $c$ **ថេរ នោះ** $f'(x)=0$

តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$$
$$=\lim_{h\to 0}\frac{c-c}{h}$$
$$=\lim_{h\to 0}\frac{0}{h}$$
$$=\lim_{h\to 0}0=0$$

ដូចនេះ: | រូបមន្ត បើ $f(x)=c$ , $c$ ថេរ នោះ: $f'(x)=0$ ត្រូវបានស្រាយបញ្ជាក់ | ។

**ខ. ស្រាយបញ្ជាក់ថា** $f(x)=cx$ , $c$ **ថេរ នោះ** $f'(x)=c$

តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$$
$$=\lim_{h\to 0}\frac{c(x+h)-cx}{h}$$
$$=\lim_{h\to 0}\frac{cx+ch-cx}{h}$$
$$=\lim_{h\to 0}\frac{ch}{h}=\lim_{h\to 0}c=c$$

ដូចនេះ: | រូបមន្ត បើ $f(x)=cx$ , $c$ ថេរ នោះ: $f'(x)=c$ ត្រូវបានស្រាយបញ្ជាក់ | ។

**គ. ស្រាយបញ្ជាក់ថា** $f(x)=ax+b$, $a$ , $b$ ថេរ នោះ: $f'(x)=a$

តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$$
$$=\lim_{h\to 0}\frac{a(x+h)+b-(ax+b)}{h}$$
$$=\lim_{h\to 0}\frac{ax+ah+b-ax-b}{h}$$
$$=\lim_{h\to 0}\frac{ah}{h}=\lim_{h\to 0}a=a$$

ដូចនេះ: | រូបមន្ត បើ $f(x)=ax+b$, $a$ , $b$ ថេរ នោះ: $f'(x)=a$ ត្រូវបានស្រាយបញ្ជាក់ | ។

**ឃ. ស្រាយបញ្ជាក់ថា** $f(x)=x^2+2x$ **នោះ** $f'(x)=2x+2$

តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$$
$$=\lim_{h\to 0}\frac{(x+h)^2+2(x+h)-(x^2+2x)}{h}$$
$$=\lim_{h\to 0}\frac{x^2+2xh+h^2+2x+2h-x^2-2x}{h}$$
$$=\lim_{h\to 0}\frac{2xh+h^2+2h}{h}$$
$$=\lim_{h\to 0}(2x+h+2)=2x+2$$

ដូចនេះ: | រូបមន្ត បើ $f(x)=x^2+2x$ នោះ $f'(x)=2x+2$ ត្រូវបានស្រាយបញ្ជាក់ | ។

**ង. ស្រាយបញ្ជាក់ថា** $f(x)=x^3$ **នោះ** $f'(x)=3x^2$

តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$$
$$=\lim_{h\to 0}\frac{(x+h)^3-x^3}{h}$$
$$=\lim_{h\to 0}\frac{x^3+3x^2h+3xh^2+h^3-x^3}{h}$$
$$=\lim_{h\to 0}\frac{h(3x^2+3xh+h^2)}{h}=3x^2$$

ដូចនេះ: | រូបមន្ត បើ $f(x)=x^3$ នោះ $f'(x)=3x^2$ ត្រូវបានស្រាយបញ្ជាក់ | ។

**ច. ស្រាយបញ្ជាក់ថា** $f(x)=\sqrt{x}$ **នោះ** $f'(x)=\frac{1}{2\sqrt{x}}$

តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}=\lim_{h\to 0}\frac{\sqrt{x+h}-\sqrt{x}}{h}$$
$$=\lim_{h\to 0}\frac{(\sqrt{x+h}-\sqrt{x})(\sqrt{x+h}+\sqrt{x})}{h(\sqrt{x+h}+\sqrt{x})}$$
$$=\lim_{h\to 0}\frac{x+h-x}{h(\sqrt{x+h}+\sqrt{x})}$$
$$=\lim_{h\to 0}\frac{1}{\sqrt{x+h}+\sqrt{x}}=\frac{1}{2\sqrt{x}}$$

ដូចនេះ: | រូបមន្ត បើ $f(x)=\sqrt{x}$ នោះ $f'(x)=\frac{1}{2\sqrt{x}}$ ត្រូវបានស្រាយបញ្ជាក់ | ។

ឆ. ស្រាយបញ្ជាក់ថា $f(x)=\sqrt[3]{x}$ នោះ $f'(x)=\dfrac{1}{3\sqrt[3]{x^2}}$

តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$$
$$=\lim_{h\to 0}\frac{\sqrt[3]{x+h}-\sqrt[3]{x}}{h}$$
$$=\lim_{h\to 0}\frac{\left(\sqrt[3]{x+h}-\sqrt[3]{x}\right)\left(\sqrt[3]{(x+h)^2}+\sqrt[3]{(x+h)\cdot x}+\sqrt[3]{x^2}\right)}{h\left(\sqrt[3]{(x+h)^2}+\sqrt[3]{(x+h)\cdot x}+\sqrt[3]{x^2}\right)}$$
$$=\lim_{h\to 0}\frac{x+h-x}{h\left(\sqrt[3]{(x+h)^2}+\sqrt[3]{(x+h)\cdot x}+\sqrt[3]{x^2}\right)}$$
$$=\lim_{h\to 0}\frac{1}{\sqrt[3]{(x+h)^2}+\sqrt[3]{(x+h)\cdot x}+\sqrt[3]{x^2}}$$
$$=\frac{1}{\sqrt[3]{x^2}+\sqrt[3]{x\cdot x}+\sqrt[3]{x^2}}=\frac{1}{3\sqrt[3]{x^2}}$$

ដូចនេះ: | រូបមន្ត បើ $f(x)=\sqrt[3]{x}$ នោះ $f'(x)=\dfrac{1}{3\sqrt[3]{x^2}}$ ត្រូវបានស្រាយបញ្ជាក់ | ។

ជ. ស្រាយបញ្ជាក់ថា $f(x)=\dfrac{1}{x}$ នោះ $f'(x)=-\dfrac{1}{x^2}$

តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$$
$$=\lim_{h\to 0}\frac{\frac{1}{x+h}-\frac{1}{x}}{h}$$
$$=\lim_{h\to 0}\frac{\frac{x-x-h}{x(x+h)}}{h}$$
$$=\lim_{h\to 0}\frac{\frac{-h}{x(x+h)}}{h}$$
$$=\lim_{h\to 0}\frac{-1}{x(x+h)}$$
$$=-\frac{1}{x^2}$$

ដូចនេះ: | រូបមន្ត បើ $f(x)=\dfrac{1}{x}$ នោះ $f'(x)=-\dfrac{1}{x^2}$ ត្រូវបានស្រាយបញ្ជាក់ | ។

ឈ. ស្រាយបញ្ជាក់ថា $f(x)=\frac{1}{\sqrt{x}}$ នោះ $f'(x)=-\frac{1}{2x\sqrt{x}}$

តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$$
$$=\lim_{h\to 0}\frac{\frac{1}{\sqrt{x+h}}-\frac{1}{\sqrt{x}}}{h}$$
$$=\lim_{h\to 0}\frac{\sqrt{x}-\sqrt{x+h}}{h\sqrt{x(x+h)}}$$
$$=\lim_{h\to 0}\frac{\left(\sqrt{x}-\sqrt{x+h}\right)\left(\sqrt{x}+\sqrt{x+h}\right)}{h\sqrt{x(x+h)}\cdot\left(\sqrt{x}+\sqrt{x+h}\right)}$$
$$=\lim_{h\to 0}\frac{x-(x+h)}{h\sqrt{x(x+h)}\cdot\left(\sqrt{x}+\sqrt{x+h}\right)}$$
$$=\lim_{h\to 0}\frac{-1}{\sqrt{x(x+h)}\cdot\left(\sqrt{x}+\sqrt{x+h}\right)}=-\frac{1}{\sqrt{x^2}\left(\sqrt{x}+\sqrt{x}\right)}=-\frac{1}{2x\sqrt{x}}$$

ដូចនេះ: រូបមន្ត បើ $f(x)=\frac{1}{\sqrt{x}}$ នោះ $f'(x)=-\frac{1}{2x\sqrt{x}}$ ត្រូវបានស្រាយបញ្ជាក់ ។

ញ. ស្រាយបញ្ជាក់ថា $f(x)=x^n$ នោះ $f'(x)=nx^{n-1}$

តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$$
$$=\lim_{h\to 0}\frac{(x+h)^n-x^n}{h}$$
$$=\lim_{h\to 0}\frac{\left[(x+h)-x\right]\left[(x+h)^{n-1}+(x+h)^{n-2}\cdot x+(x+h)^{n-3}\cdot x^2+\ldots+(x+h)\cdot x^{n-2}+x^{n-1}\right]}{h}$$
$$=\lim_{h\to 0}\frac{h\left[(x+h)^{n-1}+(x+h)^{n-2}\cdot x+(x+h)^{n-3}\cdot x^2+\ldots+(x+h)\cdot x^{n-2}+x^{n-1}\right]}{h}$$
$$=\lim_{h\to 0}\left[(x+h)^{n-1}+(x+h)^{n-2}\cdot x+(x+h)^{n-3}\cdot x^2+\ldots+(x+h)\cdot x^{n-2}+x^{n-1}\right]$$
$$=x^{n-1}+x^{n-2}\cdot x+x^{n-3}\cdot x^2+\ldots+x\cdot x^{n-2}+x^{n-1}$$
$$=\underbrace{x^{n-1}+x^{n-1}+x^{n-1}+\ldots+x^{n-1}+x^{n-1}}_{n\text{ តួ}}$$
$$=nx^{n-1}$$

ដូចនេះ: រូបមន្ត បើ $f(x)=x^n$ នោះ $f'(x)=nx^{n-1}$ ត្រូវបានស្រាយបញ្ជាក់ ។

**ឌ. ស្រាយបញ្ជាក់ថា** $y=\log_a x=\dfrac{\ln x}{\ln a}$ **នោះ** $y'=\dfrac{1}{x\ln a}$

លក្ខខណ្ឌ $0<a\neq 1$ , $x>0$

តាមនិយមន័យដេរីវេ គេបាន ៖

$$
\begin{aligned}
f'(x) &= \lim_{h\to 0}\frac{f(x+h)-f(x)}{h}\\
&= \lim_{h\to 0}\frac{\dfrac{\ln(x+h)}{\ln a}-\dfrac{\ln x}{\ln a}}{h}\\
&= \lim_{h\to 0}\frac{\ln(x+h)-\ln x}{h\ln a}\\
&= \lim_{h\to 0}\frac{\ln\left(1+\dfrac{h}{x}\right)}{h\ln a}\\
&= \lim_{h\to 0}\frac{\ln\left(1+\dfrac{h}{x}\right)}{\dfrac{h}{x}\cdot x\ln a}\\
&= \lim_{h\to 0}\left[\frac{\ln\left(1+\dfrac{h}{x}\right)}{\dfrac{h}{x}}\cdot\frac{1}{x\ln a}\right]\\
&= 1\times\frac{1}{x\ln a}=\frac{1}{x\ln a}
\end{aligned}
$$

ដូចនេះ: | រូបមន្ត បើ $y=\log_a x=\dfrac{\ln x}{\ln a}$ នោះ: $y'=\dfrac{1}{x\ln a}$ ត្រូវបានស្រាយបញ្ជាក់ | ។

**ឋ. ស្រាយបញ្ជាក់ថា** $y=a^x$ , $0<a\neq 1$ **នោះ** $y'=a^x\ln a$

តាមនិយមន័យដេរីវេ គេបាន ៖

$$
\begin{aligned}
f'(x) &= \lim_{h\to 0}\frac{f(x+h)-f(x)}{h}\\
&= \lim_{h\to 0}\frac{a^{x+h}-a^x}{h}\\
&= \lim_{h\to 0}\frac{a^x\left(a^h-1\right)}{h}\\
&= \lim_{h\to 0}\left[a^x\cdot\frac{a^h-1}{h}\right]=a^x\ln a
\end{aligned}
$$

ព្រោះ: $\lim\limits_{h\to 0}\dfrac{a^h-1}{h}=\ln a$

ដូចនេះ: | រូបមន្ត បើ $y=a^x$ , $0<a\neq 1$ នោះ: $y'=a^x\ln a$ ត្រូវបានស្រាយបញ្ជាក់ | ។

2. បើ $u$ និង $v$ ជាអនុគមន៍នៃ $x$ ៖

ក. ស្រាយបញ្ជាក់ថា $y=au$ នោះ $y'=au'$ ដែល $a$ ជាចំនួនថេរ

គេយក $u=u(x)$ តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{au(x+h)-au(x)}{h}$$
$$=\lim_{h\to 0}\left[a\times\frac{u(x+h)-u(x)}{h}\right]$$
$$=au'(x)=au'$$

ដូចនេះ: រូបមន្ត បើ $y=au$ នោះ $y'=au'$ ដែល $a$ ជាចំនួនថេរ ត្រូវបានស្រាយបញ្ជាក់ ។

ខ. ស្រាយបញ្ជាក់ថា $y=u^n$ នោះ $y'=nu'u^{n-1}$

គេយក $u=u(x)$ តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$$
$$=\lim_{h\to 0}\frac{\left[u(x+h)\right]^n-\left[u(x)\right]^n}{h}$$
$$=\lim_{h\to 0}\frac{\left[u(x+h)-u(x)\right]\left[u^{n-1}(x+h)+u^{n-2}(x+h)\cdot u(x)+\ldots+u(x+h)\cdot u^{n-2}(x)+u^{n-1}(x)\right]}{h}$$
$$=\lim_{h\to 0}\frac{\left[u(x+h)-u(x)\right]}{h}\times\lim_{h\to 0}\left[u^{n-1}(x+h)+u^{n-2}(x+h)\cdot u(x)+\ldots+u(x+h)\cdot u^{n-2}(x)+u^{n-1}(x)\right]$$
$$=u'(x)\times\left[u^{n-1}(x)+u^{n-2}(x)\cdot u(x)+\ldots+u(x)\cdot u^{n-2}(x)+u^{n-1}(x)\right]$$
$$=u'(x)\times\underbrace{\left[u^{n-1}(x)+u^{n-1}(x)+\ldots+u^{n-1}(x)+u^{n-1}(x)\right]}_{n\text{ តួ}}$$
$$=u'(x)\times nu^{n-1}(x)=nu'u^{n-1}$$

ដូចនេះ: រូបមន្ត បើ $y=u^n$ នោះ $y'=nu'u^{n-1}$ ត្រូវបានស្រាយបញ្ជាក់ ។

គ. ស្រាយបញ្ជាក់ថា $y=u+v-w$ នោះ $y'=u'+v'-w'$

គេយក $u=u(x)$ , $v=v(x)$ និង $w=w(x)$ តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$$
$$=\lim_{h\to 0}\frac{\left[u(x+h)+v(x+h)-w(x+h)\right]-\left[u(x)+v(x)-w(x)\right]}{h}$$
$$=\lim_{h\to 0}\frac{u(x+h)-u(x)+v(x+h)-v(x)-w(x+h)+w(x)}{h}$$
$$=\lim_{h\to 0}\frac{u(x+h)-u(x)}{h}+\lim_{h\to 0}\frac{v(x+h)-v(x)}{h}-\lim_{h\to 0}\frac{w(x+h)-w(x)}{h}$$
$$=u'(x)+v'(x)-w'(x)=u'+v'-w'$$

ដូចនេះ: រូបមន្ត បើ $y=u+v-w$ នោះ $y'=u'+v'-w'$ ត្រូវបានស្រាយបញ្ជាក់ ។

ឃ. ស្រាយបញ្ជាក់ថា $y=uv$ នោះ $y'=u'v+v'u$

គេយក $u=u(x)$ និង $v=v(x)$ តាមនិយមន័យដេរីវេ គេបាន ៖

$$\begin{aligned}
f'(x) &= \lim_{h\to 0}\frac{f(x+h)-f(x)}{h}\\
&= \lim_{h\to 0}\frac{u(x+h)v(x+h)-u(x)v(x)}{h}\\
&= \lim_{h\to 0}\frac{u(x+h)v(x+h)-u(x)v(x+h)+u(x)v(x+h)-u(x)v(x)}{h}\\
&= \lim_{h\to 0}\frac{u(x+h)v(x+h)-u(x)v(x+h)}{h}+\lim_{h\to 0}\frac{u(x)v(x+h)-u(x)v(x)}{h}\\
&= \lim_{h\to 0}\left[\frac{u(x+h)-u(x)}{h}\times v(x+h)\right]+\lim_{h\to 0}\left[\frac{v(x+h)-v(x)}{h}\times u(x)\right]\\
&= u'(x)v(x)+v'(x)u(x)=u'v+v'u
\end{aligned}$$

ដូចនេះ

| រូបមន្ត បើ $y=uv$ នោះ $y'=u'v+v'u$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

ង. ស្រាយបញ្ជាក់ថា $y=\frac{u}{v}$ នោះ $y'=\frac{u'v-v'u}{v^2}$

គេយក $u=u(x)$ និង $v=v(x)$ តាមនិយមន័យដេរីវេ គេបាន ៖

$$\begin{aligned}
f'(x) &= \lim_{h\to 0}\frac{f(x+h)-f(x)}{h}\\
&= \lim_{h\to 0}\frac{\frac{u(x+h)}{v(x+h)}-\frac{u(x)}{v(x)}}{h}\\
&= \lim_{h\to 0}\frac{\frac{u(x+h)v(x)-u(x)v(x+h)}{v(x+h)v(x)}}{h}\\
&= \lim_{h\to 0}\frac{u(x+h)v(x)-u(x)v(x)+u(x)v(x)-u(x)v(x+h)}{hv(x+h)v(x)}\\
&= \lim_{h\to 0}\frac{u(x+h)v(x)-u(x)v(x)}{hv(x+h)v(x)}+\lim_{h\to 0}\frac{u(x)v(x)-u(x)v(x+h)}{hv(x+h)v(x)}\\
&= \lim_{h\to 0}\left[\frac{u(x+h)-u(x)}{h}\times\frac{v(x)}{v(x+h)v(x)}\right]-\lim_{h\to 0}\left[\frac{v(x+h)-v(x)}{h}\times\frac{u(x)}{v(x+h)v(x)}\right]\\
&= \left[u'(x)\times\frac{v(x)}{v^2(x)}\right]-\left[v'(x)\times\frac{u(x)}{v^2(x)}\right]\\
&= \frac{u'(x)v(x)}{v^2(x)}-\frac{v'(x)u(x)}{v^2(x)}\\
&= \frac{u'(x)v(x)-v'(x)u(x)}{v^2(x)}=\frac{u'v-v'u}{v^2}
\end{aligned}$$

ដូចនេះ

| រូបមន្ត បើ $y=\frac{u}{v}$ នោះ $y'=\frac{u'v-v'u}{v^2}$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

ច. ស្រាយបញ្ជាក់ថា $y=\sqrt{u}$ នោះ $y'=\dfrac{u'}{2\sqrt{u}}$

គេយក $u=u(x)$ តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$$

$$=\lim_{h\to 0}\frac{\sqrt{u(x+h)}-\sqrt{u(x)}}{h}$$

$$=\lim_{h\to 0}\frac{\left[\sqrt{u(x+h)}-\sqrt{u(x)}\right]\left[\sqrt{u(x+h)}+\sqrt{u(x)}\right]}{h\left[\sqrt{u(x+h)}+\sqrt{u(x)}\right]}$$

$$=\lim_{h\to 0}\frac{u(x+h)-u(x)}{h\left[\sqrt{u(x+h)}+\sqrt{u(x)}\right]}$$

$$=\lim_{h\to 0}\left[\frac{u(x+h)-u(x)}{h}\times\frac{1}{\sqrt{u(x+h)}+\sqrt{u(x)}}\right]$$

$$=u'(x)\times\frac{1}{\sqrt{u(x)}+\sqrt{u(x)}}=\frac{u'(x)}{2\sqrt{u(x)}}=\frac{u'}{2\sqrt{u}}$$

ដូចនេះ

| |
|---|
| រូបមន្ត បើ $y=\sqrt{u}$ នោះ $y'=\dfrac{u'}{2\sqrt{u}}$ ត្រូវបានស្រាយបញ្ជាក់ |

។

ឆ. ស្រាយបញ្ជាក់ថា $y=\dfrac{1}{u}$ នោះ $y'=-\dfrac{u'}{u^2}$

គេយក $u=u(x)$ តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$$

$$=\lim_{h\to 0}\frac{\dfrac{1}{u(x+h)}-\dfrac{1}{u(x)}}{h}$$

$$=\lim_{h\to 0}\frac{\dfrac{u(x)-u(x+h)}{u(x)u(x+h)}}{h}$$

$$=\lim_{h\to 0}\frac{u(x)-u(x+h)}{hu(x)u(x+h)}$$

$$=-\lim_{h\to 0}\left[\frac{u(x+h)-u(x)}{h}\times\frac{1}{u(x)u(x+h)}\right]$$

$$=-u'(x)\times\frac{1}{u(x)u(x)}=-\frac{u'(x)}{u^2(x)}$$

ដូចនេះ

| |
|---|
| រូបមន្ត បើ $y=\dfrac{1}{u}$ នោះ $y'=-\dfrac{u'}{u^2}$ ត្រូវបានស្រាយបញ្ជាក់ |

។

3. ស្រាយបញ្ជាក់ថា $\frac{dy}{dx}=\frac{dy}{du}\times\frac{du}{dx}$ ឬ $\frac{d}{dx}f\left[u(x)\right]=f'(u)\times u'(x)$

គេមាន $y=f(u)$ និង $u=g(x)$

គេតាង $F(x)=y=f(u)$ នោះ $F(x)=f\left[g(x)\right]$

ដើម្បីស្រាយថា $\frac{dy}{dx}=\frac{dy}{du}\times\frac{du}{dx}$ គេត្រូវស្រាយឱ្យបានថា $F'(x)=f'\left[g(x)\right]\times g'(x)$

ព្រោះថា $F'(x)=\frac{dy}{dx}$ , $f'\left[g(x)\right]=\frac{dy}{du}$ , $g'(x)=\frac{du}{dx}$

ដោយប្រើនិយមន័យភាពមានដេរីវេត្រង់ $x=x_0$ គេបាន ៖

$$F'(x_0)=\lim_{x\to x_0}\frac{F(x)-F(x_0)}{x-x_0}$$
$$=\lim_{x\to x_0}\frac{f\left[g(x)\right]-f\left[g(x_0)\right]}{x-x_0}$$
$$=\lim_{x\to x_0}\left[\frac{f\left[g(x)\right]-f\left[g(x_0)\right]}{g(x)-g(x_0)}\times\frac{g(x)-g(x_0)}{x-x_0}\right]$$
$$=f'\left[g(x_0)\right]\times g'(x_0)$$

នាំឱ្យ $F'(x)=f'\left[g(x)\right]\times g'(x)$ មានន័យថាគេបាន $\frac{dy}{dx}=\frac{dy}{du}\times\frac{du}{dx}$

ដោយ $F'(x)=\frac{d}{dx}f\left[u(x)\right]$ , $f'\left[g(x)\right]=f'(u)$ , $g'(x)=u'(x)$

នោះគេក៏អាចសរសេរ $F'(x)=f'\left[g(x)\right]\times g'(x)$ ទៅជា $\frac{d}{dx}f\left[u(x)\right]=f'(u)\times u'(x)$

ដូចនេះ: | រូបមន្ត $\frac{dy}{dx}=\frac{dy}{du}\times\frac{du}{dx}$ ឬ $\frac{d}{dx}f\left[u(x)\right]=f'(u)\times u'(x)$ ត្រូវបានស្រាយបញ្ជាក់ | ។

4. ស្រាយបញ្ជាក់ថា $\frac{dy}{dx}=nu^{n-1}\times\frac{du}{dx}=nu^{n-1}\times u'$

គេមាន $y=u^n$ និង $u$ ជាអនុគមន៍នៃ $x$

យើងមានទំនាក់ទំនង $\frac{dy}{dx}=\frac{dy}{du}\times\frac{du}{dx}$ (បានស្រាយរួចខាងលើ)

$$=\frac{d}{du}\left(u^n\right)\times\frac{du}{dx}$$
$$=nu^{n-1}\times\frac{du}{dx}$$
$$=nu^{n-1}\times u'$$

ដូចនេះ: | រូបមន្ត $\frac{dy}{dx}=nu^{n-1}\times\frac{du}{dx}=nu^{n-1}\times u'$ ត្រូវបានស្រាយបញ្ជាក់ | ។

5. ស្រាយបញ្ជាក់រូបមន្តដេរីវេនៃអនុគមន៍ត្រីកោណមាត្រខាងក្រោម ៖

**ក. ស្រាយបញ្ជាក់ថា** $y=\sin x$ **នោះ** $y'=\cos x$

**➤របៀបទី១** : តាមនិយមន័យដេរីវេ គេបាន ៖

$$\begin{aligned}
f'(x) &= \lim_{h\to 0}\frac{f(x+h)-f(x)}{h}\\
&= \lim_{h\to 0}\frac{\sin(x+h)-\sin x}{h}\\
&= \lim_{h\to 0}\frac{\sin x\cos h+\sin h\cos x-\sin x}{h}\\
&= \lim_{h\to 0}\frac{\sin x(\cos h-1)+\sin h\cos x}{h}\\
&= \lim_{h\to 0}\left[\frac{\sin x(\cos h-1)}{h}+\frac{\sin h\cos x}{h}\right]\\
&= \lim_{h\to 0}\left[\sin x\cdot\frac{\cos h-1}{h}+\frac{\sin h}{h}\cdot\cos x\right]\\
&= \sin x\cdot 0+1\cdot\cos x\\
&= \cos x
\end{aligned}$$

**➤របៀបទី២** : តាមនិយមន័យដេរីវេ គេបាន ៖

$$\begin{aligned}
f'(x) &= \lim_{h\to 0}\frac{f(x+h)-f(x)}{h}\\
&= \lim_{h\to 0}\frac{\sin(x+h)-\sin x}{h}\\
&= \lim_{h\to 0}\frac{2\sin\left(\frac{x+h-x}{2}\right)\cos\left(\frac{x+h+x}{2}\right)}{h}\\
&= \lim_{h\to 0}\frac{2\sin\frac{h}{2}\cos\left(x+\frac{h}{2}\right)}{h}\\
&= \lim_{h\to 0}\left[\frac{\sin\frac{h}{2}}{\frac{h}{2}}\cdot\cos\left(x+\frac{h}{2}\right)\right]\\
&= 1\cdot\cos x=\cos x
\end{aligned}$$

ដូចនេះ: | រូបមន្ត បើ $y=\sin x$ នោះ $y'=\cos x$ ត្រូវបានស្រាយបញ្ជាក់ | ។

**ខ. ស្រាយបញ្ជាក់ថា** $y=\cos x$ **នោះ** $y'=-\sin x$

**➤របៀបទី១** : តាមនិយមន័យដេរីវេ គេបាន ៖

$$\begin{aligned}
f'(x) &= \lim_{h\to 0}\frac{f(x+h)-f(x)}{h}\\
&= \lim_{h\to 0}\frac{\cos(x+h)-\cos x}{h}\\
&= \lim_{h\to 0}\frac{\cos x\cos h-\sin x\sin h-\cos x}{h}\\
&= \lim_{h\to 0}\frac{\cos x(\cos h-1)-\sin x\sin h}{h}\\
&= \lim_{h\to 0}\left[\frac{\cos x(\cos h-1)}{h}-\frac{\sin x\sin h}{h}\right]\\
&= \lim_{h\to 0}\left[\cos x\cdot\frac{\cos h-1}{h}-\sin x\cdot\frac{\sin h}{h}\right]\\
&= \cos x\cdot 0-\sin x\cdot 1\\
&= -\sin x
\end{aligned}$$

**➤របៀបទី២** : តាមនិយមន័យដេរីវេ គេបាន ៖

$$\begin{aligned}
f'(x) &= \lim_{h\to 0}\frac{f(x+h)-f(x)}{h}\\
&= \lim_{h\to 0}\frac{\cos(x+h)-\cos x}{h}\\
&= \lim_{h\to 0}\frac{-2\sin\left(\frac{x+h+x}{2}\right)\sin\left(\frac{x+h-x}{2}\right)}{h}\\
&= -\lim_{h\to 0}\frac{\sin\left(x+\frac{h}{2}\right)\sin\frac{h}{2}}{\frac{h}{2}}\\
&= -\lim_{h\to 0}\left[\sin\left(x+\frac{h}{2}\right)\times\frac{\sin\frac{h}{2}}{\frac{h}{2}}\right]\\
&= -\sin x\times 1=-\sin x
\end{aligned}$$

ដូចនេះ: | រូបមន្ត បើ $y=\cos x$ នោះ $y'=-\sin x$ ត្រូវបានស្រាយបញ្ជាក់ | ។

គ. ស្រាយបញ្ជាក់ថា $y=\tan x$ នោះ $y'=\frac{1}{\cos^2 x}=1+\tan^2 x$

យើងមាន $y=\tan x=\frac{\sin x}{\cos x}$ តាមរូបមន្ត $\left(\frac{u}{v}\right)'=\frac{u'v-v'u}{v^2}$ គេបាន ៖

$$y'=(\tan x)'=\left(\frac{\sin x}{\cos x}\right)'$$
$$=\frac{(\sin x)'\cos x-(\cos x)'\sin x}{(\cos x)^2}$$
$$=\frac{\cos^2 x+\sin^2 x}{\cos^2 x}=\frac{1}{\cos^2 x}$$
$$=1+\tan^2 x$$

ដូចនេះ: រូបមន្ត បើ $y=\tan x$ នោះ $y'=\frac{1}{\cos^2 x}=1+\tan^2 x$ ត្រូវបានស្រាយបញ្ជាក់ ។

ឃ. ស្រាយបញ្ជាក់ថា $y=\cot x$ នោះ $y'=-\frac{1}{\sin^2 x}=-(1+\cot^2 x)$

យើងមាន $y=\cot x=\frac{\cos x}{\sin x}$ តាមរូបមន្ត $\left(\frac{u}{v}\right)'=\frac{u'v-v'u}{v^2}$ គេបាន ៖

$$y'=(\tan x)'=\left(\frac{\cos x}{\sin x}\right)'$$
$$=\frac{(\cos x)'\sin x-(\sin x)'\cos x}{(\sin x)^2}$$
$$=\frac{-\sin^2 x-\cos^2 x}{\sin^2 x}=-\frac{1}{\sin^2 x}$$
$$=-(1+\cot^2 x)$$

ដូចនេះ: រូបមន្ត បើ $y=\cot x$ នោះ $y'=-\frac{1}{\sin^2 x}=-(1+\cot^2 x)$ ត្រូវបានស្រាយបញ្ជាក់ ។

ង. ស្រាយបញ្ជាក់ថា $y=\sin u$ នោះ $y'=u'\cos u$

គេយក $u=u(x)$ តាមរូបមន្តដេរីវេនៃអនុគមន៍បណ្តាក់ $\frac{dy}{dx}=\frac{dy}{du}\times\frac{du}{dx}$

គេបាន $\frac{dy}{du}=\frac{d}{du}\left[\sin u(x)\right]\times\frac{du}{dx}$

$$=\cos u(x)\times u'(x)$$
$$=u'(x)\cos u(x)$$
$$=u'\cos u$$

ដូចនេះ: រូបមន្ត បើ $y=\sin u$ នោះ $y'=u'\cos u$ ត្រូវបានស្រាយបញ្ជាក់ ។

**ច. ស្រាយបញ្ជាក់ថា** $y=\cos u$ **នោះ** $y'=-u'\sin u$

គេយក $u=u(x)$ តាមរូបមន្តដេរីវេនៃអនុគមន៍បណ្ដាក់ $\dfrac{dy}{dx}=\dfrac{dy}{du}\times\dfrac{du}{dx}$

គេបាន $\dfrac{dy}{du}=\dfrac{d}{du}\left[\cos u(x)\right]\times\dfrac{du}{dx}$

$=-\sin u(x)\times u'(x)$

$=-u'(x)\sin u(x)$

$=-u'\sin u$

ដូចនេះ: | រូបមន្ត បើ $y=\cos u$ នោះ $y'=-u'\sin u$ ត្រូវបានស្រាយបញ្ជាក់ | ។

**ឆ. ស្រាយបញ្ជាក់ថា** $y=\tan u$ **នោះ** $y'=\dfrac{u'}{\cos^2 u}=u'\left(1+\tan^2 u\right)$

គេយក $u=u(x)$ តាមរូបមន្តដេរីវេនៃអនុគមន៍បណ្ដាក់ $\dfrac{dy}{dx}=\dfrac{dy}{du}\times\dfrac{du}{dx}$

គេបាន $\dfrac{dy}{du}=\dfrac{d}{du}\left[\tan u(x)\right]\times\dfrac{du}{dx}$

$=\dfrac{1}{\cos^2 u(x)}\times u'(x)$

$=\dfrac{u'(x)}{\cos^2 u(x)}$

$=\dfrac{u'}{\cos^2 u}$

ម្យ៉ាងទៀត $\dfrac{dy}{du}=\dfrac{d}{du}\left[\tan u(x)\right]\times\dfrac{du}{dx}$

$=\left[1+\tan^2 u(x)\right]\times u'(x)$

$=u'(x)\left[1+\tan^2 u(x)\right]$

$=u'\left(1+\tan^2 u\right)$

ដូចនេះ: | រូបមន្ត បើ $y=\tan u$ នោះ $y'=\dfrac{u'}{\cos^2 u}=u'\left(1+\tan^2 u\right)$ ត្រូវបានស្រាយបញ្ជាក់ | ។

**ជ. ស្រាយបញ្ជាក់ថា** $y=\cot u$ **នោះ** $y'=-\dfrac{u'}{\sin^2 u}=-u'\left(1+\cot^2 u\right)$

គេយក $u=u(x)$ តាមរូបមន្តដេរីវេនៃអនុគមន៍បណ្ដាក់ $\dfrac{dy}{dx}=\dfrac{dy}{du}\times\dfrac{du}{dx}$

គេបាន $\dfrac{dy}{du}=\dfrac{d}{du}\left[\cot u(x)\right]\times\dfrac{du}{dx}$

$=-\dfrac{1}{\sin^2 u(x)}\times u'(x)$

$=-\dfrac{u'(x)}{\sin^2 u(x)}$

$=-\dfrac{u'}{\sin^2 u}$

ម្យ៉ាងទៀត $\dfrac{dy}{du}=\dfrac{d}{du}\left[\cot u(x)\right]\times\dfrac{du}{dx}$

$=-\left[1+\cot^2 u(x)\right]\times u'(x)$

$=-u'(x)\left[1+\cot^2 u(x)\right]$

$=-u'\left(1+\cot^2 u\right)$

ដូចនេះ: | រូបមន្ត បើ $y=\cot u$ នោះ $y'=-\dfrac{u'}{\sin^2 u}=-u'\left(1+\cot^2 u\right)$ ត្រូវបានស្រាយបញ្ជាក់ | ។

6. ស្រាយបញ្ជាក់រូបមន្តដេរីវេនៃអនុគមន៍អិចស្ប៉ូណង់ស្យែលខាងក្រោម ៖

**ក. ស្រាយបញ្ជាក់ថា** $y=e^x$ **នោះ** $y'=e^x$

តាមនិយមន័យដេរីវេ គេបាន ៖

$$\begin{aligned} f'(x) &= \lim_{h\to 0}\frac{e^{x+h}-e^x}{h} \\ &= \lim_{h\to 0}\frac{e^x\left(e^h-1\right)}{h} \\ &= \lim_{h\to 0}\left(e^x\cdot\frac{e^h-1}{h}\right) \\ &= e^x\cdot 1 = e^x \end{aligned}$$

ដូចនេះ: | រូបមន្ត បើ $y=e^x$ នោះ $y'=e^x$ ។ |

**ខ. ស្រាយបញ្ជាក់ថា** $y=e^u$ **នោះ** $y'=u'e^u$

គេយក $u=u(x)$ តាមរូបមន្តដេរីវេនៃអនុគមន៍បណ្ដាក់ $\frac{dy}{dx}=\frac{dy}{du}\times\frac{du}{dx}$

គេបាន

$$\begin{aligned} \frac{dy}{dx} &= \frac{d}{du}\left[e^{u(x)}\right]\times\frac{du}{dx} \\ &= e^{u(x)}\times u'(x) \\ &= u'(x)e^{u(x)} \\ &= u'e^u \end{aligned}$$

ដូចនេះ: | រូបមន្ត បើ $y=e^u$ នោះ $y'=u'e^u$ ត្រូវបានស្រាយបញ្ជាក់ | ។

**គ. ស្រាយបញ្ជាក់ថា** $y=a^x$ **នោះ** $y'=a^x\ln a$ **ដែល** $0<a\neq 1$

តាមនិយមន័យដេរីវេ គេបាន ៖

$$\begin{aligned} f'(x) &= \lim_{h\to 0}\frac{f(x+h)-f(x)}{h} \\ &= \lim_{h\to 0}\frac{a^{x+h}-a^x}{h} \\ &= \lim_{h\to 0}\frac{a^x\left(a^h-1\right)}{h} \\ &= \lim_{h\to 0}\left[a^x\cdot\frac{a^h-1}{h}\right] = a^x\ln a \end{aligned}$$

(ព្រោះ $\lim_{h\to 0}\frac{a^h-1}{h}=\ln a$ មើលការស្រាយបញ្ជាក់ក្នុងមេរៀនលីមីត)

ដូចនេះ: | រូបមន្ត $y=a^x$ , $0<a\neq 1$ នោះ $y'=a^x\ln a$ ត្រូវបានស្រាយ | ។ (លំហាត់នេះបានស្រាយរួចម្ដងហើយ)

ឃ. ស្រាយបញ្ជាក់ថា $y=a^u$ នោះ $y'=u'a^u\ln a$

គេយក $u=u(x)$ តាមរូបមន្តដេរីវេនៃអនុគមន៍បណ្ដាក់ $\frac{dy}{dx}=\frac{dy}{du}\times\frac{du}{dx}$

គេបាន $\frac{dy}{dx}=\frac{d}{du}\left[a^{u(x)}\right]\times\frac{du}{dx}$

$=a^{u(x)}\ln a\times u'(x)$

$=u'(x)a^{u(x)}\ln a$

$=u'a^u\ln a$

ដូចនេះ | រូបមន្ត បើ $y=a^u$ នោះ $y'=u'a^u\ln a$ ត្រូវបានស្រាយបញ្ជាក់ | ។

7. ស្រាយបញ្ជាក់រូបមន្តដេរីវេនៃអនុគមន៍លោការីតខាងក្រោម ៖

ក. ស្រាយបញ្ជាក់ថា $y=\ln x$ , $x>0$ នោះ $y'=\frac{1}{x}$

តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{\ln(x+h)-\ln x}{h}$$

$$=\lim_{h\to 0}\frac{\ln\left(\frac{x+h}{x}\right)}{h}$$

$$=\lim_{h\to 0}\frac{\ln\left(1+\frac{h}{x}\right)}{\frac{h}{x}\cdot x}$$

$$=\lim_{h\to 0}\left[\frac{\ln\left(1+\frac{h}{x}\right)}{\frac{h}{x}}\times\frac{1}{x}\right]=1\times\frac{1}{x}=\times\frac{1}{x}$$

ដូចនេះ | រូបមន្ត បើ $y=\ln x$ , $x>0$ នោះ $y'=\frac{1}{x}$ ត្រូវបានស្រាយបញ្ជាក់ | ។

ខ. ស្រាយបញ្ជាក់ថា $y=\ln u$ នោះ $y'=\frac{u'}{u}$

គេយក $u=u(x)$ តាមរូបមន្តដេរីវេនៃអនុគមន៍បណ្ដាក់ $\frac{dy}{dx}=\frac{dy}{du}\times\frac{du}{dx}$

គេបាន $\frac{dy}{dx}=\frac{d}{du}\left[\ln u(x)\right]\times\frac{du}{dx}$

$=\frac{1}{u(x)}\times u'(x)$

$=\frac{u'(x)}{u(x)}=\frac{u'}{u}$

ដូចនេះ | រូបមន្ត បើ $y=\ln u$ នោះ $y'=\frac{u'}{u}$ ត្រូវបានស្រាយបញ្ជាក់ | ។

**គ. ស្រាយបញ្ជាក់ថា** $y=\log_a x=\dfrac{\ln x}{\ln a}$ **នោះ** $y'=\dfrac{1}{x\ln a}$

លក្ខខណ្ឌ $0<a\neq 1$ , $x>0$

តាមនិយមន័យដេរីវេ គេបាន ៖

$$f'(x)=\lim_{h\to 0}\frac{f(x+h)-f(x)}{h}$$
$$=\lim_{h\to 0}\frac{\dfrac{\ln(x+h)}{\ln a}-\dfrac{\ln x}{\ln a}}{h}$$
$$=\lim_{h\to 0}\frac{\ln(x+h)-\ln x}{h\ln a}$$
$$=\lim_{h\to 0}\frac{\ln\left(1+\dfrac{h}{x}\right)}{h\ln a}$$
$$=\lim_{h\to 0}\frac{\ln\left(1+\dfrac{h}{x}\right)}{\dfrac{h}{x}\cdot x\ln a}$$
$$=\lim_{h\to 0}\left[\frac{\ln\left(1+\dfrac{h}{x}\right)}{\dfrac{h}{x}}\cdot\frac{1}{x\ln a}\right]$$
$$=1\times\frac{1}{x\ln a}=\frac{1}{x\ln a}$$

ដូចនេះ: | រូបមន្ត បើ $y=\log_a x=\dfrac{\ln x}{\ln a}$ នោះ: $y'=\dfrac{1}{x\ln a}$ ត្រូវបានស្រាយបញ្ជាក់ | ។ (ស្រាយរួចម្តងហើយ)

**ឃ. ស្រាយបញ្ជាក់ថា** $y=\log_a u$ **នោះ** $y'=\dfrac{u'}{u\ln a}$

គេមាន $y=\log_a u=\dfrac{\ln u}{\ln a}$ ដែល $0<a\neq 0$ , $u>0$

គេយក $u=u(x)$ តាមរូបមន្តដេរីវេនៃអនុគមន៍បណ្តាក់ $\dfrac{dy}{dx}=\dfrac{dy}{du}\times\dfrac{du}{dx}$

គេបាន $\dfrac{dy}{dx}=\dfrac{d}{du}\left[\dfrac{\ln u(x)}{\ln a}\right]\times\dfrac{du}{dx}$ (មាន $\ln a$ ជាចំនួនថេរ)

$$=\frac{1}{\ln a}\times\frac{d}{du}\left[\ln u(x)\right]\times\frac{du}{dx}$$
$$=\frac{1}{\ln a}\times\frac{1}{u(x)}\times u'(x)$$
$$=\frac{u'(x)}{u(x)\ln a}=\frac{u'}{u\ln a}$$

ដូចនេះ: | រូបមន្ត បើ $y=\log_a u$ នោះ: $y'=\dfrac{u'}{u\ln a}$ ត្រូវបានស្រាយបញ្ជាក់ | ។

8. **ស្រាយបញ្ជាក់វិសមភាពកំណើនមានកំណត់** $m(b-a)\le f(b)-f(a)\le M(b-a)$

គេមាន $x\in I$ , $m\le f'(x)\le M$ និង $a\,,b\in I$ ដែល $a<b$

គេបាន $f'(x)-m\ge 0$ និង $f'(x)-M\le 0$

តាងអនុគមន៍ $g(x)=f(x)-mx$ និង $h(x)=f(x)-Mx$ ដែល $g$ និង $f$ មានដេរីវេលើចន្លោះ $I$

$g'(x)=f'(x)-m$ និង $h'(x)=f'(x)-M$

នាំឱ្យ $g'(x)\ge 0$ គ្រប់ $x\in I$ មានន័យថា $g(x)$ ជាអនុគមន៍កើនលើ $I$ និងលើ $[a\,,b]$ គេបាន ៖

$$g(b)-g(a)\ge 0$$
$$\left[f(b)-mb\right]-\left[f(a)-ma\right]\ge 0$$
$$f(b)-mb-f(a)+ma\ge 0$$
$$f(b)-f(a)\ge mb-ma$$
$$f(b)-f(a)\ge m(b-a)\quad (1)$$

ម្យ៉ាងទៀត $h'(x)\ge 0$ គ្រប់ $x\in I$ មានន័យថា $h(x)$ ជាអនុគមន៍ចុះលើ $I$ និងលើ $[a\,,b]$ គេបាន ៖

$$h(b)-h(a)\le 0$$
$$\left[f(b)-Mb\right]-\left[f(a)-Ma\right]\le 0$$
$$f(b)-Mb-f(a)+Ma\le 0$$
$$f(b)-f(a)\le Mb-Ma$$
$$f(b)-f(a)\le M(b-a)\quad (2)$$

តាមទំនាក់ទំនង (1) និង (2) គេបាន $m(b-a)\le f(b)-f(a)\le M(b-a)$

ដូចនេះ វិសមភាពកំណើនមានកំណត់ $m(b-a)\le f(b)-f(a)\le M(b-a)$ ត្រូវបានស្រាយបញ្ជាក់ ។

9. **ស្រាយបញ្ជាក់ថា បើ** $|f'(x)|\le M$ **ចំពោះ** $x\in[a\,,b]$ **នោះ គេបាន វិសមភាព** $|f(b)-f(a)|\le M|b-a|$

គេមាន $f$ មានដេរីវេលើចន្លោះ $[a\,,b]$ និង $|f'(x)|\le M$ ចំពោះគ្រប់ $x\in I$

នាំឱ្យ $-M\le f'(x)\le M$ ហើយ $M\ge 0$ ព្រោះ $|f'(x)|\ge 0$

តាមវិសមភាពកំណើនមានកំណត់ ៖

-ចំពោះ $a<b$ គេបាន

$$-M(b-a)\le f(b)-f(a)\le M(b-a)$$
$$|f(b)-f(a)|\le |M(b-a)|$$
$$|f(b)-f(a)|\le M|b-a|\quad (1)$$

-ចំពោះ $a>b$ គេបាន

$$-M(a-b)\le f(a)-f(b)\le M(a-b)$$
$$M(a-b)\ge f(b)-f(a)\ge -M(a-b)$$
$$-M(a-b)\le f(b)-f(a)\le M(a-b)$$
$$|f(b)-f(a)|\le |M(a-b)|$$
$$|f(b)-f(a)|\le M|a-b|\quad (2)$$

តាមទំនាក់ទំនង (1) និង (2) នាំឱ្យគេបាន $|f(b)-f(a)|\le M|b-a|$ ព្រោះថា $|b-a|=|a-b|$

ដូចនេះ បើ $|f'(x)|\le M$ ចំពោះ $x\in[a\,,b]$ នោះ គេបាន វិសមភាព $|f(b)-f(a)|\le M|b-a|$ ។

10. **ស្រាយបញ្ជាក់ទ្រឹស្តីបទរ៉ូល : បើ $f(a)=f(b)$ នោះមានចំនួន $c\in(a\,,b)$ យ៉ាងតិចមួយដែល $f'(c)=0$**

គេមាន $f$ ជាអនុគមន៍ជាប់លើចន្លោះ $[a\,,b]$ មានដេរីវេលើចន្លោះ $(a\,,b)$ និង $f(a)=f(b)$

គេតាង $f(a)=f(b)=d$

គេមានបីករណីក្នុងការសិក្សាទីតាំងរវាង $f(x)$ និងបន្ទាត់ $d$ ដើម្បីរកឱ្យឃើញថា មាន $c\in(a\,,b)$ មួយយ៉ាងតិចដែល $f'(c)=0$

• ករណីទី ១: បើ $f(x)=d$ នោះគ្រប់ $x\in[a\,,b]$ គេបាន ៖

$f$ ជាអនុគមន៍ថេរលើចន្លោះ $[a\,,b]$

នាំឱ្យ $f'(x)=0$ មាន $x=c\in[a\,,b]$ ដែល $f'(c)=0$




• ករណីទី ២: បើ $f(x)>d$ នោះគ្រប់ $x\in[a\,,b]$ គេបាន ៖

$f$ ជាអនុគមន៍មានតម្លៃអតិបរមាមួយយ៉ាងតិចត្រង់ $x=c$

ដោយ $f$ មានដេរីវេត្រង់ $x=c$ គេបាន $f'(c)=0$




• ករណីទី ៣: បើ $f(x)<d$ នោះគ្រប់ $x\in[a\,,b]$ គេបាន ៖

$f$ ជាអនុគមន៍មានតម្លៃអប្បបរមាមួយយ៉ាងតិចត្រង់ $x=c$

ដោយ $f$ មានដេរីវេត្រង់ $x=c$ គេបាន $f'(c)=0$

ឃើញថា គ្រប់ករណីខាងលើគេរកបាន $f'(c)=0$

ដូចនេះ | ទ្រឹស្តីបទរ៉ូល : បើ $f(a)=f(b)$ នោះមានចំនួន $c\in(a\,,b)$ យ៉ាងតិចមួយដែល $f'(c)=0$ ត្រូវបានស្រាយ | ។

11. **ស្រាយបញ្ជាក់ ទ្រឹស្តីបទតម្លៃមធ្យម : $f'(c)=\dfrac{f(b)-f(a)}{b-a}$**

គេមាន $f$ ជាអនុគមន៍ជាប់លើចន្លោះ $[a\,,b]$ មានដេរីវេលើចន្លោះ $(a\,,b)$

បន្ទាត់កាត់តាមពីរចំណុច $(a\,,\,f(a))$ និង $(b\,,\,f(b))$ មានសមីការ $\dfrac{y-f(a)}{x-a}=\dfrac{f(b)-f(a)}{b-a}$

នាំឱ្យ $y=\dfrac{f(b)-f(a)}{b-a}(x-a)+f(a)$

គេតាង $g(x)=f(x)-y$

គេបាន $g(x)=f(x)-\dfrac{f(b)-f(a)}{b-a}(x-a)-f(a)$

$$g'(x)=f'(x)-\dfrac{f(b)-f(a)}{b-a}$$

ចំពោះ $x=a$ នោះ $g(a)=f(a)-\dfrac{f(b)-f(a)}{b-a}(a-a)-f(a)=0$

ចំពោះ $x=b$ នោះ $g(b)=f(b)-\dfrac{f(b)-f(a)}{b-a}(b-a)-f(a)=0$

ដោយ $g$ ជាអនុគមន៍ពហុធាជាប់លើ $[a\,,b]$ និង $g(a)=g(b)=0$ តាមទ្រឹស្តីបទរ៉ូល មានចំនួន $c\in(a\,,b)$ មួយយ៉ាងតិច

ដែល $g'(c)=0$ នោះ $g'(c)=f'(c)-\dfrac{f(b)-f(a)}{b-a}=0$ ទាញបាន $f'(c)=\dfrac{f(b)-f(a)}{b-a}$ ។

ដូចនេះ | ទ្រឹស្តីបទតម្លៃមធ្យម $f'(c)=\dfrac{f(b)-f(a)}{b-a}$ ត្រូវបានស្រាយបញ្ជាក់ | ។

# ការស្រាយបញ្ជាក់លើមេរៀន សិក្សាអនុគមន៍

1. ស្រាយបញ្ជាក់ទ្រឹស្តីបទ : បើ $f$ ជាអនុគមន៍ជាប់លើចន្លោះ $[a\,,b]$ និងមានដេរីវេលើចន្លោះ $(a\,,b)$ ៖
   ក. បើ $f'(x)>0$ ចំពោះគ្រប់ $x\in(a\,,b)$ នោះ $f$ ជាអនុគមន៍កើនលើចន្លោះ $[a\,,b]$ ។
   ខ. បើ $f'(x)<0$ ចំពោះគ្រប់ $x\in(a\,,b)$ នោះ $f$ ជាអនុគមន៍ចុះលើចន្លោះ $[a\,,b]$ ។
   គ. បើ $f'(x)=0$ ចំពោះគ្រប់ $x\in(a\,,b)$ នោះ $f$ ជាអនុគមន៍ថេរលើចន្លោះ $[a\,,b]$ ។
2. ស្រាយបញ្ជាក់តម្លៃបរមាធៀប : គេមានអនុគមន៍ $f$ ជាប់លើចន្លោះ $[a\,,b]$ និងមាន $c\in(a\,,b)$ ដែល $f'(c)=0$ ។
   បើ $f$ មានដេរីវេលើចន្លោះ $(a\,,b)$ លើកលែងតែត្រង់ $c$ នោះ $f(c)$ ត្រូវបានគេកំណត់ដូចខាងក្រោម ៖
   ក. បើ $f'(x)$ ប្តូរសញ្ញាពី $-$ ទៅ $+$ ត្រង់ $c$ នោះ $f(c)$ គឺជាតម្លៃអប្បបរមានៃ $f$ ។
   ខ. បើ $f'(x)$ ប្តូរសញ្ញាពី $+$ ទៅ $-$ ត្រង់ $c$ នោះ $f(c)$ គឺជាតម្លៃអតិបរមានៃ $f$ ។
3. ស្រាយបញ្ជាក់ពីបរមា ដោយប្រើដេរីវេទី២ : បើ $f$ ជាអនុគមន៍ដែល $f'(c)=0$ និងមានដេរីវេលើចន្លោះ $I$ ដែលមាន $c$ នោះគេថា៖
   ក. បើ $f''(c)>0$ នោះ $f(c)$ គឺជាតម្លៃអប្បរមា ។
   ខ. បើ $f''(c)<0$ នោះ $f(c)$ គឺជាតម្លៃអតិរមា ។
   គ. បើ $f''(c)=0$ និងសញ្ញានៅសងខាង $f''(c)$ ប្រែប្រួល នោះគេថាអនុគមន៍មានចំណុចរបត់ត្រង់ $c$ ។
4. បង្ហាញថា បើ អនុគមន៍ $f$ មានដេរីវេលើចន្លោះ $I=(a\,,b)$ នោះ $f$ ជាប់លើចន្លោះ $I$ ។
5. ស្រាយបញ្ជាក់ថា : បើ $I(a\,,b)$ ជាផ្ចិតឆ្លុះនៃខ្សែកោង $C$ តាងអនុគមន៍ $f$ លុះត្រាតែវាផ្ទៀងផ្ទាត់ $f(2a-x)+f(x)=2b$ ។
6. បង្ហាញថា ក្រាបនៃអនុគមន៍ដឺក្រេទី៣ មានចំណុចរបត់មួយ ដែលជាផ្ចិតឆ្លុះរបស់វា ។
7. ស្រាយបញ្ជាក់ថា បើ $\lim\limits_{x\to\pm\infty}\dfrac{f(x)}{x}=a$ និង $\lim\limits_{x\to\pm\infty}\left[f(x)-ax\right]=b$ នោះបន្ទាត់ដែលមានសមីការ $y=ax+b$ គឺជាអាស៊ីមតូតទ្រេតនៃក្រាបតាង $f$ ។
8. ស្រាយបញ្ជាក់ថា បន្ទាត់ប៉ះក្រាបតាងអនុគមន៍ $f$ ត្រង់ $x_0$ មានសមីការ $y=f'(x_0)(x-x_0)+f(x_0)$ ។

# ការស្រាយបញ្ជាក់លើមេរៀន សិក្សាអនុគមន៍

1. **រំលឹក :** ចំពោះ $x_1$ និង $x_2$ ដែល $x_2 > x_1$ ហើយ $f$ គ្មានបរមានៅចន្លោះ $(x_1 , x_2)$ គេកំណត់ ៖

-បើ $f(x_2) > f(x_1)$ នោះ $f$ ជាអនុគមន៍ **កើន** ។

-បើ $f(x_2) > f(x_1)$ នោះ $f$ ជាអនុគមន៍ **ចុះ** ។

-បើ $f(x_2) = f(x_1)$ នោះ $f$ ជាអនុគមន៍ **ថេរ** ។

**ក. ស្រាយបញ្ជាក់ទ្រឹស្តីបទ : បើ $f'(x) > 0$ ចំពោះគ្រប់ $x \in (a , b)$ នោះ $f$ ជាអនុគមន៍កើនលើចន្លោះ $[a , b]$**

គេមាន $f'(x) > 0$ ចំពោះគ្រប់ $x \in (a , b)$

គេតាង $x_1 < x_2$ ដែល $x_1 , x_2 \in (a , b)$

តាមទ្រឹស្តីបទតម្លៃមធ្យម : មាន $c$ ដែល $x_1 < c < x_2$

គេបាន $f'(c) = \dfrac{f(x_2) - f(x_1)}{x_2 - x_1}$

ដោយ $f'(x) > 0$ ចំពោះគ្រប់ $x \in (a , b)$ នោះ $f'(c) > 0$

នាំឱ្យ $\dfrac{f(x_2) - f(x_1)}{x_2 - x_1} > 0$ (គុណអង្គទាំងពីរនឹង $x_2 - x_1 > 0$ មិនប្តូរទិសដៅ)

$f(x_2) - f(x_1) > 0$

$f(x_2) > f(x_1)$ នេះបញ្ជាក់ថា $f$ ជាអនុគមន៍កើន

ដូចនេះ | បើ $f'(x) > 0$ នោះ $f$ ជាអនុគមន៍កើន | ។

**ខ. ស្រាយបញ្ជាក់ទ្រឹស្តីបទ : បើ $f'(x) < 0$ ចំពោះគ្រប់ $x \in (a , b)$ នោះ $f$ ជាអនុគមន៍ចុះលើចន្លោះ $[a , b]$**

គេមាន $f'(x) < 0$ ចំពោះគ្រប់ $x \in (a , b)$

គេតាង $x_1 < x_2$ ដែល $x_1 , x_2 \in (a , b)$

តាមទ្រឹស្តីបទតម្លៃមធ្យម : មាន $c$ ដែល $x_1 < c < x_2$

គេបាន $f'(c) = \dfrac{f(x_2) - f(x_1)}{x_2 - x_1}$

ដោយ $f'(x) < 0$ ចំពោះគ្រប់ $x \in (a , b)$ នោះ $f'(c) < 0$

នាំឱ្យ $\dfrac{f(x_2) - f(x_1)}{x_2 - x_1} < 0$ (គុណអង្គទាំងពីរនឹង $x_2 - x_1 > 0$ មិនប្តូរទិសដៅ)

$f(x_2) - f(x_1) < 0$

$f(x_2) < f(x_1)$ នេះបញ្ជាក់ថា $f$ ជាអនុគមន៍ចុះ

ដូចនេះ | បើ $f'(x) < 0$ នោះ $f$ ជាអនុគមន៍ចុះ | ។

គ. ស្រាយបញ្ជាក់ទ្រឹស្តីបទ : បើ $f'(x)=0$ ចំពោះគ្រប់ $x\in(a\ ,\ b)$ នោះ $f$ ជាអនុគមន៍ថេរលើចន្លោះ $[a\ ,\ b]$

គេមាន $f'(x)=0$ ចំពោះគ្រប់ $x\in(a\ ,\ b)$

គេតាង $x_1<x_2$ ដែល $x_1\ ,\ x_2\in(a\ ,\ b)$

តាមទ្រឹស្តីបទតម្លៃមធ្យម : មាន $c$ ដែល $x_1<c<x_2$

គេបាន $f'(c)=\dfrac{f(x_2)-f(x_1)}{x_2-x_1}$

ដោយ $f'(x)=0$ ចំពោះគ្រប់ $x\in(a\ ,\ b)$ នោះ $f'(c)=0$

នាំឱ្យ $\dfrac{f(x_2)-f(x_1)}{x_2-x_1}=0$ (គុណអង្គទាំងពីរនឹង $x_2-x_1>0$ មិនប្តូរទិសដៅ)

$f(x_2)-f(x_1)=0$

$f(x_2)=f(x_1)$ នេះបញ្ជាក់ថា $f$ ជាអនុគមន៍ថេរ

ដូចនេះ **បើ $f'(x)=0$ នោះ $f$ ជាអនុគមន៍ថេរ** ។

2. **ស្រាយបញ្ជាក់តម្លៃបរមាធៀប :**

**ក. ស្រាយបញ្ជាក់ថា បើ $f'(x)$ ប្តូរសញ្ញាពី $-$ ទៅ $+$ ត្រង់ $c$ នោះ $f(c)$ គឺជាតម្លៃអប្បបរមានៃ $f$**

ដោយ ក្នុងចន្លោះ $(a\ ,\ b)$ មានដេរីវេទី១ $f'(x)$ ប្តូរសញ្ញាពី $-$ ទៅ $+$ ត្រង់ $c$ នោះ ៖

គេបាន $f'(x)<0$ ចំពោះ $x\in(a\ ,\ c)$ នាំឱ្យ $f$ ជាអនុគមន៍ចុះលើចន្លោះ $(a\ ,\ c)$

$f'(x)>0$ ចំពោះ $x\in(c\ ,\ b)$ នាំឱ្យ $f$ ជាអនុគមន៍កើនលើចន្លោះ $(c\ ,\ b)$

នាំឱ្យ ក្រាបនៃ $f$ ចុះដល់ $f(c)$ រួចហើយកើនវិញ នោះ $f$ មានអប្បបរមាត្រង់ $x=c$

ដូចនេះ **បើ $f'(x)$ ប្តូរសញ្ញាពី $-$ ទៅ $+$ ត្រង់ $c$ នោះ $f(c)$ គឺជាតម្លៃអប្បបរមានៃ $f$** ។

**ខ. ស្រាយបញ្ជាក់ថា បើ $f'(x)$ ប្តូរសញ្ញាពី $+$ ទៅ $-$ ត្រង់ $c$ នោះ $f(c)$ គឺជាតម្លៃអតិបរមានៃ $f$**

ដោយ ក្នុងចន្លោះ $(a\ ,\ b)$ មានដេរីវេទី១ $f'(x)$ ប្តូរសញ្ញាពី $+$ ទៅ $-$ ត្រង់ $c$ នោះ ៖

គេបាន $f'(x)>0$ ចំពោះ $x\in(a\ ,\ c)$ នាំឱ្យ $f$ ជាអនុគមន៍កើនលើចន្លោះ $(a\ ,\ c)$

$f'(x)<0$ ចំពោះ $x\in(c\ ,\ b)$ នាំឱ្យ $f$ ជាអនុគមន៍ចុះលើចន្លោះ $(c\ ,\ b)$

នាំឱ្យ ក្រាបនៃ $f$ កើនដល់ $f(c)$ រួចហើយចុះវិញ នោះ $f$ មានអតិបរមាត្រង់ $x=c$

ដូចនេះ **បើ $f'(x)$ ប្តូរសញ្ញាពី $+$ ទៅ $-$ ត្រង់ $c$ នោះ $f(c)$ គឺជាតម្លៃអតិបរមានៃ $f$** ។

**ចំណាំ** **ចំពោះអនុគមន៍ $f$ នៅត្រង់ $x=x_0$**

**បើ $f'(x_0)=0$ និងប្តូរសញ្ញា មានន័យថា អនុគមន៍មានបរមា ត្រង់ចំណុច $(x_0\ ,\ f(x_0))$**

**បើ $f''(x_0)=0$ និងប្តូរសញ្ញា មានន័យថា អនុគមន៍មានចំណុចរបត់ ត្រង់ចំណុច $(x_0\ ,\ f(x_0))$**

3. ស្រាយបញ្ជាក់ពីបរមា ដោយប្រើដេរីវេទី២ :

**ក. ស្រាយបញ្ជាក់ថា បើ $f'(c)=0$ និង $f''(c)>0$ នោះ $f(c)$ គឺជាតម្លៃអប្បបរមា លើចន្លោះ $I$**

តាមនិយមន័យដេរីវេ គេបាន $f''(c)=\lim\limits_{x\to c}\dfrac{f'(x)-f'(c)}{x-c}$

ឬ $f''(c)=\lim\limits_{x\to c}\dfrac{f'(x)}{x-c}$ ព្រោះ $f'(c)=0$

ដោយ $f''(c)>0$ នោះ $\lim\limits_{x\to c}\dfrac{f'(x)}{x-c}>0$

-បើ $x<c$ នោះ $x-c<0$ នាំឱ្យ $f'(x)<0$ មានន័យថា $f'(x)$ ជាអនុគមន៍ចុះ

-បើ $x>c$ នោះ $x-c>0$ នាំឱ្យ $f'(x)>0$ មានន័យថា $f'(x)$ ជាអនុគមន៍កើន

ឃើញថា ក្នុងចន្លោះ $I$ ក្រាបនៃ $f$ ចុះដល់ $f(c)$ រួចកើនវិញ មានន័យថា $f$ មានតម្លៃអប្បបរមាត្រង់ $x=c$

ដូចនេះ | បើ $f'(c)=0$ និង $f''(c)>0$ នោះ $f(c)$ គឺជាតម្លៃអប្បបរមាលើចន្លោះ $I$ | ។

**ខ. ស្រាយបញ្ជាក់ថា បើ $f'(c)=0$ និង $f''(c)<0$ នោះ $f(c)$ គឺជាតម្លៃអតិបរមា លើចន្លោះ $I$**

តាមនិយមន័យដេរីវេ គេបាន $f''(c)=\lim\limits_{x\to c}\dfrac{f'(x)-f'(c)}{x-c}$

ឬ $f''(c)=\lim\limits_{x\to c}\dfrac{f'(x)}{x-c}$ ព្រោះ $f'(c)=0$

ដោយ $f''(c)<0$ នោះ $\lim\limits_{x\to c}\dfrac{f'(x)}{x-c}<0$

-បើ $x<c$ នោះ $x-c<0$ នាំឱ្យ $f'(x)>0$ មានន័យថា $f'(x)$ ជាអនុគមន៍កើន

-បើ $x>c$ នោះ $x-c>0$ នាំឱ្យ $f'(x)<0$ មានន័យថា $f'(x)$ ជាអនុគមន៍ចុះ

ឃើញថា ក្នុងចន្លោះ $I$ ក្រាបនៃ $f$ កើនដល់ $f(c)$ រួចចុះវិញ មានន័យថា $f$ មានតម្លៃអតិបរមាត្រង់ $x=c$

ដូចនេះ | បើ $f'(c)=0$ និង $f''(c)<0$ នោះ $f(c)$ គឺជាតម្លៃអតិបរមាលើចន្លោះ $I$ | ។

**គ. ស្រាយបញ្ជាក់ថា បើ $f''(c)=0$ និងសញ្ញានៅសងខាង $f''(c)$ ប្រែប្រួល នោះគេថាអនុគមន៍មានចំណុចរបត់ត្រង់ $c$**

រំលឹក : អនុគមន៍មួយមានចំណុចរបត់ត្រង់ចំណុច $I(a,b)$ កាលណានៅត្រង់ចំណុច $I$ នេះ អនុគមន៍ផ្លាស់ប្តូរភាពប៉ោង ឬផត ។

គេមាន $f$ ជាអនុគមន៍ដែល $f'(c)=0$ , $f''(c)=0$ និងសញ្ញានៅសងខាង $f''(c)$ ប្រែប្រួល

ដោយ $f''(c)=0$ នេះបញ្ជាក់ថាអនុគមន៍គ្មានបរមាទេ ត្រង់ $c$

ហើយ សញ្ញានៅសងខាង $f''(c)$ ប្រែប្រួល មានន័យថា អនុគមន៍ផ្លាស់ប្តូរភាពប៉ោង ឬផត មានពីរករណីគឺ ៖

-បើត្រង់ $c$ , $f''(c)=0$ ហើយប្តូរសញ្ញាពី $+$ ទៅ $-$ នោះក្រាបនៃអនុគមន៍ប្តូរពីផត ទៅប៉ោង

-បើត្រង់ $c$ , $f''(c)=0$ ហើយប្តូរសញ្ញាពី $-$ ទៅ $+$ នោះក្រាបនៃអនុគមន៍ប្តូរពីប៉ោង ទៅផត

ឃើញថា $f$ ផ្លាស់ប្តូរភាពប៉ោង ឬផត ត្រង់ $c$ នាំឱ្យ $f$ មានចំណុចរបត់នៅត្រង់ $c$

ដូចនេះ | អនុគមន៍ $f$ មានចំណុចរបត់នៅត្រង់ $c$ | ។

4. **ស្រាយបញ្ជាក់ថា បើ អនុគមន៍ $f$ មានដេរីវេលើចន្លោះ $I=(a\ ,\ b)$ នោះ $f$ ជាប់លើចន្លោះ $I$**

បើ $f$ មានដេរីវេលើចន្លោះ $I=(a\ ,\ b)$ នោះ ចំពោះគ្រប់ $x_o \in I$

គេបាន $f'(x_0)=\lim\limits_{x\to x_0}\dfrac{f(x)-f(x_0)}{x-x_0}$

ដោយ $\lim\limits_{x\to x_0}\left[f(x)-f(x_0)\right]=\lim\limits_{x\to x_0}\left[\dfrac{f(x)-f(x_0)}{x-x_0}\cdot(x-x_0)\right]=f'(x_0)\cdot 0=0$

នាំឱ្យ $\lim\limits_{x\to x_0}\left[f(x)-f(x_0)\right]=0$

$\lim\limits_{x\to x_0} f(x)-\lim\limits_{x\to x_0} f(x_0)=0$

$\lim\limits_{x\to x_0} f(x)-f(x_0)=0$

$\lim\limits_{x\to x_0} f(x)=f(x_0)$

ដោយ $\lim\limits_{x\to x_0} f(x)=f(x_0)$ ពិតចំពោះគ្រប់ $x_o\in I$ នោះបញ្ជាក់ថា $f$ ជាអនុគមន៍ជាប់លើចន្លោះ $I$

ដូចនេះ | បើ អនុគមន៍ $f$ មានដេរីវេលើចន្លោះ $I=(a\ ,\ b)$ នោះ $f$ ជាប់លើចន្លោះ $I$ | ។

5. **ស្រាយបញ្ជាក់ថា : បើ $I(a\ ,\ b)$ ជាផ្ចិតឆ្លុះនៃខ្សែកោង $C$ តាងអនុគមន៍ $f$ លុះត្រាតែវាផ្ទៀងផ្ទាត់ $f(2a-x)+f(x)=2b$**

ក្នុងប្លង់ $(P)$ ប្រកបដោយតម្រុយ អរតូណរម៉ាល់ $(O\ ,\ \vec{i}\ ,\ \vec{j})$

គេយក $I$ មានកូអរដោនេ $(a\ ,\ b)$

តាមបំលែងឆ្លុះផ្ចិត $I(a\ ,\ b)$ ចំណុច $M(x\ ,\ y)$ មានរូបភាព $M'(x'\ ,\ y')$

យ $I$ ជាចំណុចកណ្ដាលនៃ $[MM']$




គេបាន $\begin{cases} a=\dfrac{x+x'}{2} \\ b=\dfrac{y+y'}{2}\end{cases}$ នោះ $\begin{cases} x'=2a-x \\ y'=2b-y\end{cases}$

ខ្សែកោង $(C)$ នៃអនុគមន៍ $y=f(x)$ មាន $I$ ជាផ្ចិតឆ្លុះលុះត្រាតែ ៖

$M\in(C)$ សមមូល $x\in(D_f)$ និង $y=f(x)$

$M'\in(C)$ សមមូល $x'\in(D_f)$ ឬ $2a-x\in(D_f)$ និង $y'=2b-y$

គេបាន $f(x')=2b-f(x)$ អាចសរសេរ $f(x')+f(x)=2b$

ឬ $f(2a-x)+f(x)=2b$

ដូចនេះ | បើ $I(a\ ,\ b)$ ជាផ្ចិតឆ្លុះនៃខ្សែកោង $C$ តាងអនុគមន៍ $f$ លុះត្រាតែ $f(2a-x)+f(x)=2b$ | ។

6. **បង្ហាញថា ក្រាបនៃអនុគមន៍ដឺក្រេទី៣ មានចំណុចរបត់មួយ ដែលជាផ្ចិតឆ្លុះរបស់វា**

គេតាង $y=f(x)=ax^3+bx^2+cx+d$ , $a\neq 0$ ជាអនុគមន៍ដឺក្រេទី៣

នាំឱ្យ $f'(x)=3ax^2+2bx+c$

$f''(x)=6ax+2b$

គេឱ្យ $f''(x)=0 \Leftrightarrow 6ax+2b=0$ នាំឱ្យ $x=-\dfrac{b}{3a}$

$$f\left(-\frac{b}{3a}\right)=a\left(-\frac{b}{3a}\right)^3+b\left(-\frac{b}{3a}\right)^2+c\left(-\frac{b}{3a}\right)+d$$

$$=-\frac{b^3}{27a^2}+\frac{b^3}{9a^2}-\frac{bc}{3a}+d$$

$$=\frac{2b^3}{27a^2}-\frac{bc}{3a}+d$$

តារាងសញ្ញា $f''(x)$

| $x$ | $-\infty$ | $-\dfrac{b}{3a}$ | $+\infty$ |
|---|---|---|---|
| $f''(x)$ | សញ្ញាផ្ទុយ $a$ | 0 | សញ្ញាដូច $a$ |

ត្រង់ $x=-\dfrac{b}{3a}$ , $f''(x)=0$ និងប្តូរសញ្ញា មានន័យថា ក្រាបនៃ $f$ មានចំណុចរបត់ $I\left(-\dfrac{b}{3a}\,,\,\dfrac{2b^3}{27a^2}-\dfrac{bc}{3a}+d\right)$ (1)

ម្យ៉ាងទៀត បើ $I(a,b)=I\left(-\dfrac{b}{3a}\,,\,\dfrac{2b^3}{27a^2}-\dfrac{bc}{3a}+d\right)$ ជាផ្ចិតឆ្លុះនៃ $f$ លុះត្រាតែវាផ្ទៀងផ្ទាត់ $f(2a-x)+f(x)=2b$

គេបាន $f(2a-x)=f\left(-\dfrac{2b}{3a}-x\right)$

$$=a\left(-\frac{2b}{3a}-x\right)^3+b\left(-\frac{2b}{3a}-x\right)^2+c\left(-\frac{2b}{3a}-x\right)+d$$

$$=a\left(-\frac{8b^3}{27a^3}-\frac{12b^2x}{9a^2}-\frac{6bx^2}{3a}-x^3\right)+b\left(\frac{4b^2}{9a^2}+\frac{4bx}{3a}+x^2\right)-\frac{2bc}{3a}-cx+d$$

$$=-\frac{8b^3}{27a^2}-\frac{4b^2x}{3a}-2bx^2-ax^3+\frac{4b^3}{9a^2}+\frac{4b^2x}{3a}+bx^2-\frac{2bc}{3a}-cx+d$$

$$=\frac{4b^3}{27a^2}-\frac{2bc}{3a}+2d-ax^3-bx^2-cx-d$$

$$=\frac{4b^3}{27a^2}-\frac{2bc}{3a}+2d-\left(ax^3+bx^2+cx+d\right)$$

$$=2\left(\frac{2b^3}{27a^2}-\frac{bc}{3a}+d\right)-f(x)$$

$$=2b-f(x)$$

នាំឱ្យ $f(2a-x)+f(x)=2b$ នេះបញ្ជាក់ថា $I\left(-\dfrac{b}{3a}\,,\,\dfrac{2b^3}{27a^2}-\dfrac{bc}{3a}+d\right)$ ជាផ្ចិតឆ្លុះនៃក្រាបតាងអនុគមន៍ $f$ (2)

តាម (1) និង (2) ក្រាបនៃអនុគមន៍ដឺក្រេទី៣ មានចំណុចរបត់មួយ ដែលជាផ្ចិតឆ្លុះរបស់វា

ដូចនេះ **បង្ហាញបានថា ក្រាបនៃអនុគមន៍ដឺក្រេទី៣ មានចំណុចរបត់មួយ ដែលជាផ្ចិតឆ្លុះរបស់វា** ។

7. **ស្រាយបញ្ជាក់ថា បើ $\lim\limits_{x\to\pm\infty}\frac{f(x)}{x}=a$ និង $\lim\limits_{x\to\pm\infty}\left[f(x)-ax\right]=b$ នោះបន្ទាត់ $y=ax+b$ គឺជាអាស៊ីមតូត ទ្រេត**

តាមនិយមន័យ បន្ទាត់ $y=ax+b$ ជាអាស៊ីមតូតទ្រេតនៃក្រាបតាងអនុគមន៍ $f$ កាលណា $\lim\limits_{x\to-\infty}\left[f(x)-(ax+b)\right]=0$ ឬ $\lim\limits_{x\to+\infty}\left[f(x)-(ax+b)\right]=0$ ។

ពីនិយមន័យខាងលើ គេអាចសរសេរបាន $f(x)-(ax+b)=\varepsilon(x)$ ដែល $\lim\limits_{x\to-\infty}\varepsilon(x)=0$ ឬ $\lim\limits_{x\to+\infty}\varepsilon(x)=0$

គេបាន $$\frac{f(x)}{x}-\frac{(ax+b)}{x}=\frac{\varepsilon(x)}{x}$$

$$\frac{f(x)}{x}-a-\frac{b}{x}=\frac{\varepsilon(x)}{x}$$

$$\frac{f(x)}{x}=a+\frac{b}{x}+\frac{\varepsilon(x)}{x}$$

នាំឱ្យ $$\lim_{x\to\pm\infty}\frac{f(x)}{x}=\lim_{x\to\pm\infty}\left[a+\frac{b}{x}+\frac{\varepsilon(x)}{x}\right]=a+0+0=a$$

ម្យ៉ាងទៀត $f(x)-ax=b+\varepsilon(x)$

នាំឱ្យ $$\lim_{x\to\pm\infty}\left[f(x)-ax\right]=\lim_{x\to\pm\infty}\left[b+\varepsilon(x)\right]=b+0=b$$

ដូចនេះ

| បើ $\lim\limits_{x\to\pm\infty}\frac{f(x)}{x}=a$ និង $\lim\limits_{x\to\pm\infty}\left[f(x)-ax\right]=b$ នោះបន្ទាត់ $y=ax+b$ គឺជាអាស៊ីមតូតទ្រេតនៃក្រាបតាង $f$ |
|---|

។

8. **ស្រាយបញ្ជាក់ថា បន្ទាត់ប៉ះក្រាបតាងអនុគមន៍ $f$ ត្រង់ $x_0$ មានសមីការ $y=f'(x_0)(x-x_0)+f(x_0)$**

គេមានចំណុច $M(x_0\,,\,f(x_0))$ និង $N(x\,,\,f(x))$ លើក្រាបតាងអនុគមន៍ $f$

ខ្នាត់ $MN$ មានមេគុណប្រាប់ទិស $\dfrac{f(x)-f(x_0)}{x-x_0}$




បើ $N$ ផ្លាស់ទីលើក្រាបខិតទៅរក $M$ នោះខ្នាត់ $MN$ ងាករកទីតាំងលីមីត $MT$ ដែលហៅថា បន្ទាត់ប៉ះក្រាបនៃអនុគមន៍ $f$ ត្រង់ $M(x_0, f(x_0))$ ។

ក្នុងករណី $x\to x_0$ នោះមេគុណប្រាប់ទិសនៃខ្នាត់ $MN$ ក្លាយជាមេគុណប្រាប់ទិសនៃបន្ទាត់ប៉ះ $MT$ គឺ $m=\lim\limits_{x\to x_0}\dfrac{f(x)-f(x_0)}{x-x_0}$ ឬ $m=f'(x_0)$

ដោយ បន្ទាត់ប៉ះ $MT$ មានមេគុណប្រាប់ទិស $f'(x_0)$ នោះគេបាន ៖

$$\frac{y-y_0}{x-x_0}=f'(x_0)$$

$$y-y_0=f'(x_0)(x-x_0)$$

$$y=f'(x_0)(x-x_0)+y_0$$

$$y=f'(x_0)(x-x_0)+f(x_0) \quad \text{ព្រោះ } y_0=f(x_0)$$

ដូចនេះ

| បន្ទាត់ប៉ះក្រាបតាងអនុគមន៍ $f$ ត្រង់ $x_0$ មានសមីការ $y=f'(x_0)(x-x_0)+f(x_0)$ |
|---|

។

# ការស្រាយបញ្ជាក់លើមេរៀន អាំងតេក្រាល

1. ស្រាយបញ្ជាក់ថា បើ $F(x)$ ជាព្រីមីទីវមួយនៃ $f(x)$ នោះព្រីមីទីវទាំងអស់នៃ $f$ មានទម្រង់ទូទៅ $F(x)+c$ ដែល $c$ ជាចំនួនថេរ ។

2. ស្រាយបញ្ជាក់រូបមន្តគ្រឹះនៃអាំងតេក្រាលខាងក្រោម ដែលមាន $k$ , $c$ ជាចំនួនថេរ ៖

ក. $\int kdx = kx + c$ ដែល $k \neq 0$

ខ. $\int kf(x)dx = k\int f(x)dx$ ដែល $k \neq 0$

គ. $\int x^n dx = \frac{x^{n+1}}{n+1} + c$ ដែល $n \neq -1$

ឃ. $\int \frac{1}{x^2}dx = -\frac{1}{x} + c$

ង. $\int \frac{1}{\sqrt{x}}dx = 2\sqrt{x} + c$

ច. $\int [f(x) \pm g(x)]dx = \int f(x)dx \pm \int g(x)dx$

ឆ. $\int \frac{1}{ax+b}dx = \frac{1}{a}\ln|ax+b| + c$

ជ. $\int \frac{x}{ax+b}dx = \frac{x}{a} - \frac{b}{a^2}\ln|ax+b| + c$

ឈ. $\int \frac{1}{(ax+b)^2}dx = -\frac{1}{a(ax+b)} + c$

ញ. $\int \frac{1}{x(ax+b)}dx = \frac{1}{b}\ln\left|\frac{x}{ax+b}\right| + c$

ដ. $\int (ax+b)^n dx = \frac{(ax+b)^{n+1}}{a(n+1)} + c$

ឋ. $\int u^n du = \frac{u^{n+1}}{n+1} + c$ , $n \neq -1$

ឌ. $\int \frac{1}{x}du = \ln|x| + c$ ដែល $x \neq 0$

ឍ. $\int \frac{1}{\sqrt{ax+b}}dx = \frac{2}{a}\left(\sqrt{ax+b}\right) + c$

ណ. $\int \frac{1}{a^2-x^2}dx = \frac{1}{2a}\ln\left|\frac{x-a}{x+a}\right| + c$ , $a \neq 0$

ត. $\int \frac{1}{\sqrt{x^2+a^2}}dx = \ln\left|x + \sqrt{x^2+a^2}\right| + c$

ថ. $\int kf'(x)dx = kf(x) + c$

ទ. $\int [f(x)]^n f'(x)dx = \frac{[f(x)]^{n+1}}{n+1} + c, n \neq -1$

ធ. $\int \frac{f'(x)}{f(x)}dx = \ln|f(x)| + c$

ន. $\int \frac{f'(x)}{[f(x)]^2}dx = \frac{-1}{f(x)} + c$

ប. $\int \frac{f'(x)}{[f(x)]^n}dx = \frac{-1}{(n-1)[f(x)]^{n-1}} + c$

ផ. $\int \frac{f'(x)}{\sqrt{f(x)}}dx = 2\sqrt{f(x)} + c$

3. ស្រាយបញ្ជាក់រូបមន្តអាំងតេក្រាលនៃអនុគមន៍ត្រីកោណមាត្រ ៖

ក. $\int \sin xdx = -\cos x + c$

ខ. $\int \cos xdx = \sin x + c$

គ. $\int \tan xdx = \int \frac{\sin x}{\cos x}dx = -\ln|\cos x| + c$

ឃ. $\int \cot xdx = \int \frac{\cos x}{\sin x}dx = \ln|\sin x| + c$

ង. $\int \frac{1}{\cos^2 x}dx = \int (1 + \tan^2 x)dx = \tan x + c$

ច. $\int \frac{1}{\sin^2 x}dx = \int (1 + \cot^2 x)dx = -\cot x + c$

ឆ. $\int \sin axdx = -\frac{1}{a}\cos ax + c$

ជ. $\int \cos axdx = \frac{1}{a}\sin ax + c$

ឈ. $\int \sin ax \cdot \cos axdx = \frac{1}{2a}\sin^2 ax + c$

ឈ. $\int \sin^n ax \cos axdx = \frac{1}{(n+1)a}\sin^{n+1} ax + c$

ដ. $\int \cos^n ax \sin axdx = \frac{-1}{(n+1)a}\cos^{n+1} ax + c$

ឋ. $\int \sin[f(x)]f'(x)dx = -\cos[f(x)] + c$

ឌ. $\int \cos\left[f(x)\right] f'(x)\,dx = \sin\left[f(x)\right] + c$

ឍ. $\int \dfrac{f'(x)}{\cos^2\left[f(x)\right]}dx = \int\left[1+\tan^2\left[f(x)\right]\right]f'(x)\,dx = \tan\left[f(x)\right]+c$

ណ. $\int \dfrac{f'(x)}{\sin^2\left[f(x)\right]}dx = \int\left[1+\cot^2\left[f(x)\right]\right]f'(x)\,dx = -\cot\left[f(x)\right]+c$

4. ស្រាយបញ្ជាក់រូបមន្តអាំងតេក្រាលនៃអនុគមន៍អិចស្ប៉ូណង់ស្យែល ៖

ក. $\int e^x dx = e^x + c$ ខ. $\int e^{ax}dx = \dfrac{e^{ax}}{a} + c$ គ. $\int e^{ax+b}dx = \dfrac{1}{a}e^{ax+b} + c$

ឃ. $\int a^x dx = \dfrac{a^x}{\ln a} + c$ ង. $\int e^u du = e^u + c$ ច. $\int f'(x)e^{f(x)}dx = e^{f(x)} + c$

5. ស្រាយបញ្ជាក់រូបមន្តអាំងតេក្រាលនៃអនុគមន៍លោការីត ៖

ក. $\int \ln x\,dx = x\ln x - x + c$ ខ. $\int \dfrac{\ln x}{x}dx = \dfrac{1}{2}\ln^2 x$ គ. $\int \dfrac{\ln^n x}{x}dx = \dfrac{\ln^{n+1} x}{n+1} + c$

ឃ. $\int \dfrac{1}{x\ln x}dx = \ln(\ln x) + c$

6. ស្រាយបញ្ជាក់រូបមន្តអាំងតេក្រាលដោយផ្នែក ៖ $\int f(x)g'(x)\,dx = f(x)g(x) - \int g(x)f'(x)\,dx$ ។

7. ស្រាយបញ្ជាក់នូវលក្ខណៈនៃអាំងតេក្រាលកំណត់ខាងក្រោម ៖

ក. $\int_a^b f(x)dx = -\int_b^a f(x)dx$

ខ. $\int_a^a f(x)dx = 0$

គ. បើ $f$ ជាប់និងកំណត់លើចន្លោះ $[a\,,\,b]$ និង $a<b<c$ គេបាន $\int_a^b f(x)dx + \int_b^c f(x)dx = \int_a^c f(x)dx$ ។

ឃ. $\int_a^b kf(x)dx = k\int_a^b f(x)\,dx \quad ,k\in\mathbb{R}$

ង. បើមាន $\int_a^b f(x)dx$ និង $\int_a^b g(x)dx$ នោះគេបាន ៖

i) $\int_a^b\left[f(x)\pm g(x)\right]dx = \int_a^b f(x)\,dx \pm \int_a^b g(x)dx$

ii) $\int_a^b\left[\alpha f(x)\pm\beta g(x)\right]dx = \alpha\int_a^b f(x)\,dx \pm \beta\int_a^b g(x)dx$

ដែលមាន $\alpha$ និង $\beta$ ជាចំនួនពិតថេរ ។

8. ស្រាយបញ្ជាក់ រូបមន្តអាំងតេក្រាលកំណត់ដោយផ្នែក ៖ $f$ និង $g$ ជាអនុគមន៍ជាប់លើចន្លោះ $[a\,,\,b]$ និងមានដេរីវេលើចន្លោះ $(a\,,\,b)$ នោះគេបាន $\int_a^b f(x)g'(x)dx = \left[f(x)g(x)\right]_a^b - \int_a^b g(x)f'(x)dx$ ។

9. ស្រាយបញ្ជាក់ រូបមន្តអាំងតេក្រាលកំណត់ដោយប្តូរអថេរ ៖ បើ $u=g(x)$ ជាប់និងមានដេរីវេលើចន្លោះ $[a\,,\,b]$ នោះអាំងតេក្រាល $\int_a^b f\left[g(x)\right]g'(x)\,dx = \int_{g(a)}^{g(b)} f(u)\,du$ ។

10. ស្រាយបញ្ជាក់ថា បើ $f$ ជាអនុគមន៍ជាប់លើចន្លោះ $[a,b]$ នោះអនុគមន៍ $F$ កំណត់លើចន្លោះ $[a,b]$ ដោយ $F(x) = \int_a^x f(t)\,dt$ ជាប់នៅលើចន្លោះ $[a,b]$ និងមានដេរីវេត្រង់គ្រប់ចំណុចនៃចន្លោះ $[a,b]$ ហើយ $\dfrac{d}{dx}\left[F(x)\right] = \dfrac{d}{dx}\left[\int_a^x f(t)dt\right] = f(x)$ ។

11. ស្រាយបញ្ជាក់ថា : ប្រវែងធ្នូនៃក្រាបតាងអនុគមន៍ $f$ ដែលនៅចន្លោះបន្ទាត់ឈរ $x=a$ និង $x=b$ កំណត់ដោយ

$L=\int_a^b \sqrt{1+\left[f'(x)\right]^2}\,dx$ ។

12. ស្រាយបញ្ជាក់ថា បើអនុគមន៍ $f$ មានអាំងតេក្រាលលើចន្លោះ $[a\,,\,b]$ នោះគេបាន $\int_a^b \left|f(x)\right|dx \ge \left|\int_a^b f(x)\,dx\right|$ ។

13. បង្ហាញថា អនុគមន៍ $y=f(x)$ ជាអនុគមន៍ជាប់មិនអវិជ្ជមានលើចន្លោះ $[a\,,\,b]$ ។ មាឌនៃសូលីតបរិវត្តដែលបង្កើតឡើងដោយរង្វិលជុំវិញអ័ក្សអាប់ស៊ីសនៃផ្ទៃដែលខណ្ឌដោយខ្សែកោងតាងអនុគមន៍ $y=f(x)$ និងអ័ក្សអាប់ស៊ីស បន្ទាត់ឈរ $x=a$ និង $x=b$ កំណត់ដោយ $V=\lim_{n\to+\infty}\sum_{k=1}^{n}\pi\left[f(x_k)\right]^2\Delta x=\pi\int_a^b\left[f(x)\right]^2 dx$ ។

# ការស្រាយបញ្ជាក់លើមេរៀន អាំងតេក្រាល

1. **ស្រាយបញ្ជាក់ថា បើ $F(x)$ ជាព្រីមីទីវមួយនៃ $f(x)$ នោះព្រីមីទីវទាំងអស់នៃ $f$ មានទម្រង់ទូទៅ $F(x)+c$ ដែល $c$ ជាចំនួនថេរ**

គេមាន $F(x)$ ជាព្រីមីទីវនៃ $f(x)$

តាមនិយមន័យ គេបាន $F'(x)=f(x)$

ដោយ $\left[F(x)+c\right]'=F'(x)=f(x)$

ដូចនេះ ព្រីមីទីវទាំងអស់នៃ $f(x)$ មានទម្រង់ទូទៅ $F(x)+c$ ។

2. **ស្រាយបញ្ជាក់រូបមន្តគ្រឹះនៃអាំងតេក្រាលខាងក្រោម ដែលមាន $k$ , $c$ ជាចំនួនថេរ ៖**

**ក. ស្រាយបញ្ជាក់រូបមន្ត $\int kdx=kx+c$ ដែល $k\neq 0$**

ដោយ $(kx+c)'=k$

តាមនិយមន័យ គេបាន $\int kdx=kx+c$

ដូចនេះ រូបមន្ត $\int kdx=kx+c$ ត្រូវបានស្រាយបញ្ជាក់ ។

**សម្គាល់ :** បើ $k=1$ គេបាន $\int dx=x+c$ ដែល $c$ ជាចំនួនថេរ ។

**ខ. ស្រាយបញ្ជាក់រូបមន្ត $\int kf(x)dx=k\int f(x)dx$ ដែល $k\neq 0$**

តាមនិយមន័យ $\int f(x)dx=F(x)+c$ សមមូល $\left[F(x)+c\right]'=f(x)$

ដោយ $\left[k\int f(x)dx\right]'=k\left[\int f(x)dx\right]'=k\left[F(x)+c\right]'=kf(x)$

នាំឱ្យ $\int kf(x)dx=k\int f(x)dx$

(ដើម្បីងាយយល់អ្នកត្រូវគិតថា $A'=B$ នាំឱ្យគេបាន $\int B=A$)

ដូចនេះ រូបមន្ត $\int kf(x)dx=k\int f(x)dx$ ត្រូវបានស្រាយបញ្ជាក់ ។

**គ. ស្រាយបញ្ជាក់រូបមន្ត $\int x^n dx=\dfrac{x^{n+1}}{n+1}+c$ ដែល $n\neq -1$**

តាមនិយមន័យ $\int f(x)dx=F(x)+c$ សមមូល $\left[F(x)+c\right]'=f(x)$

ដោយ $\left[\dfrac{x^{n+1}}{n+1}+c\right]'=(n+1)\cdot\dfrac{x^n}{n+1}=x^n$

នាំឱ្យ $\int x^n dx=\dfrac{x^{n+1}}{n+1}+c$ ដែល $n\neq -1$

ដូចនេះ រូបមន្ត $\int x^n dx=\dfrac{x^{n+1}}{n+1}+c$ ដែល $n\neq -1$ ត្រូវបានស្រាយបញ្ជាក់ ។

ឃ. ស្រាយបញ្ជាក់រូបមន្ត $\int \frac{1}{x^2}dx = -\frac{1}{x}+c$

តាមនិយមន័យ $\int f(x)dx = F(x)+c$ សមមូល $\left[F(x)+c\right]' = f(x)$

ដោយ $\left[-\frac{1}{x}+c\right]' = \left[-x^{-1}+c\right]' = -\left(x^{-1}\right)' = -(-1)x^{-1-1} = x^{-2} = \frac{1}{x^2}$

នាំឱ្យ $\int \frac{1}{x^2}dx = -\frac{1}{x}+c$

ដូចនេះ: រូបមន្ត $\int \frac{1}{x^2}dx = -\frac{1}{x}+c$ ត្រូវបានស្រាយបញ្ជាក់ ។

ង. ស្រាយបញ្ជាក់រូបមន្ត $\int \frac{1}{\sqrt{x}}dx = 2\sqrt{x}+c$

តាមនិយមន័យ $\int f(x)dx = F(x)+c$ សមមូល $\left[F(x)+c\right]' = f(x)$

ដោយ $\left(2\sqrt{x}+c\right)' = 2\cdot\frac{1}{2\sqrt{x}} = \frac{1}{\sqrt{x}}$

នាំឱ្យ $\int \frac{1}{\sqrt{x}}dx = 2\sqrt{x}+c$

ដូចនេះ: រូបមន្ត $\int \frac{1}{\sqrt{x}}dx = 2\sqrt{x}+c$ ត្រូវបានស្រាយបញ្ជាក់ ។

ច. ស្រាយបញ្ជាក់រូបមន្ត $\int [f(x)\pm g(x)]dx = \int f(x)dx \pm \int g(x)dx$

តាមនិយមន័យ $\int f(x)dx = F(x)+c_1$ សមមូល $\left[F(x)+c_1\right]' = f(x)$

ឬ $\int g(x)dx = G(x)+c_2$ សមមូល $\left[G(x)+c_2\right]' = g(x)$

គេបាន $\left[F(x)\pm G(x)+c\right]' = F'(x)\pm G'(x) = f(x)\pm g(x)$ , $c = c_1 \pm c_2$

នាំឱ្យ $\int\left[f(x)\pm g(x)\right]dx = F(x)\pm G(x)+c$ (1)

ម្យ៉ាងទៀត $\int f(x)dx \pm \int g(x)dx = \left[F(x)+c_1\right]\pm\left[G(x)+c_1\right] = F(x)\pm G(x)+c$ , $c = c_1 \pm c_2$ (2)

តាម (1) និង (2) គេបាន $\int [f(x)\pm g(x)]dx = \int f(x)dx \pm \int g(x)dx$

ដូចនេះ: រូបមន្ត $\int [f(x)\pm g(x)]dx = \int f(x)dx \pm \int g(x)dx$ ត្រូវបានស្រាយបញ្ជាក់ ។

ឆ. ស្រាយបញ្ជាក់រូបមន្ត $\int \frac{1}{ax+b}dx = \frac{1}{a}\ln|ax+b|+c$

➢របៀបទី១ តាមនិយមន័យ $\int f(x)dx = F(x)+c_1$ សមមូល $\left[F(x)+c_1\right]' = f(x)$

ដោយ $\left[\frac{1}{a}\ln|ax+b|+c\right]' = \frac{1}{a}\left[\ln|ax+b|\right]' = \frac{1}{a}\times\frac{(ax+b)'}{ax+b} = \frac{1}{a}\times\frac{a}{ax+b} = \frac{1}{ax+b}$ ព្រោះ $(\ln u)' = \frac{u'}{u}$

នាំឱ្យ $\int \frac{1}{ax+b}dx = \frac{1}{a}\ln|ax+b|+c$

ដូចនេះ: រូបមន្ត $\int \frac{1}{ax+b}dx = \frac{1}{a}\ln|ax+b|+c$ ត្រូវបានស្រាយបញ្ជាក់ ។

>របៀបទី២ គេមាន $\int \frac{1}{ax+b}dx$ តាង $u=ax+b \Rightarrow du=adx$

គេបាន $\int \frac{1}{ax+b}dx=\frac{1}{a}\int \frac{1}{ax+b}\cdot adx=\frac{1}{a}\int \frac{1}{u}du$

$=\frac{1}{a}\int \frac{1}{u}du=\frac{1}{a}\ln|u|+c=\frac{1}{a}\ln|ax+b|+c$ ព្រោះ $(\ln x)'=\frac{1}{x}$

ដូចនេះ

| រូបមន្ត $\int \frac{1}{ax+b}dx=\frac{1}{a}\ln|ax+b|+c$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

**ជ. ស្រាយបញ្ជាក់រូបមន្ត** $\int \frac{x}{ax+b}dx=\frac{x}{a}-\frac{b}{a^2}\ln|ax+b|+c$

>របៀបទី១ គេមាន $\int \frac{x}{ax+b}dx=\int \frac{\frac{1}{a}(ax+b)-\frac{b}{a}}{ax+b}dx$

$$=\int \frac{\frac{1}{a}(ax+b)}{ax+b}dx-\int \frac{\frac{b}{a}}{ax+b}dx$$

$$=\int \frac{1}{a}dx-\frac{b}{a}\int \frac{1}{ax+b}dx$$

$$=\frac{x}{a}+c_1-\frac{b}{a}\times\frac{1}{a}\ln|ax+b|+c_2$$

$$=\frac{x}{a}-\frac{b}{a^2}\ln|ax+b|+c \quad , \quad c=c_1+c_2$$

ដូចនេះ

| រូបមន្ត $\int \frac{x}{ax+b}dx=\frac{x}{a}-\frac{b}{a^2}\ln|ax+b|+c$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

>របៀបទី២ តាមនិយមន័យ $\int f(x)dx=F(x)+c$ សមមូល $[F(x)+c]'=f(x)$

ដោយ $\left[\frac{x}{a}-\frac{b}{a^2}\ln|ax+b|+c\right]'=\frac{1}{a}-\frac{b}{a^2}\cdot\frac{(ax+b)'}{ax+b}$

$$=\frac{1}{a}-\frac{b}{a^2}\cdot\frac{a}{ax+b}$$

$$=\frac{1}{a}-\frac{b}{a(ax+b)}$$

$$=\frac{(ax+b)-b}{a(ax+b)}$$

$$=\frac{ax}{a(ax+b)}$$

$$=\frac{x}{ax+b}$$

នាំឱ្យគេបាន $\int \frac{x}{ax+b}dx=\frac{x}{a}-\frac{b}{a^2}\ln|ax+b|+c$

ដូចនេះ

| រូបមន្ត $\int \frac{x}{ax+b}dx=\frac{x}{a}-\frac{b}{a^2}\ln|ax+b|+c$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

ឈ. ស្រាយបញ្ជាក់រូបមន្ត $\int \frac{1}{(ax+b)^2}dx = -\frac{1}{a(ax+b)}+c$

គេមាន $\int \frac{1}{(ax+b)^2}dx$ តាង $u = ax+b \Rightarrow du = adx$

គេបាន
$$\int \frac{1}{(ax+b)^2}dx = \frac{1}{a}\int \frac{1}{(ax+b)^2}\cdot adx$$
$$= \frac{1}{a}\int \frac{1}{u^2}du = \frac{1}{a}\times\left(-\frac{1}{u}\right)+c$$
$$= \frac{1}{a}\times\left(-\frac{1}{ax+b}\right)+c$$
$$= -\frac{1}{a(ax+b)}+c$$

ដូចនេះ: រូបមន្ត $\int \frac{1}{(ax+b)^2}dx = -\frac{1}{a(ax+b)}+c$ ត្រូវបានស្រាយបញ្ជាក់ ។

ញ. ស្រាយបញ្ជាក់រូបមន្ត $\int \frac{1}{x(ax+b)}dx = \frac{1}{b}\ln\left|\frac{x}{ax+b}\right|+c$

គេមាន $\frac{1}{x(ax+b)} = \frac{A}{x}+\frac{B}{ax+B}$ ដែល $A$ និង $B$ ជាចំនួនដែលត្រូវកំណត់

$$\frac{1}{x(ax+b)} = \frac{A(ax+b)+Bx}{x(ax+b)}$$
$$\frac{1}{x(ax+b)} = \frac{(Aa+B)x+Ab}{x(ax+b)}$$

គេផ្ទឹមបាន $\begin{cases} Aa+B=0 \\ Ab=1 \end{cases} \Rightarrow \begin{cases} B=-\frac{a}{b} \\ A=\frac{1}{b} \end{cases}$ នោះ: $\frac{1}{x(ax+b)} = \frac{\frac{1}{b}}{x}+\frac{-\frac{a}{b}}{ax+B} = \frac{1}{b}\left(\frac{1}{x}-\frac{a}{ax+B}\right)$

នាំឱ្យ
$$\int \frac{1}{x(ax+b)}dx = \int \frac{1}{b}\left(\frac{1}{x}-\frac{a}{ax+B}\right)dx$$
$$= \frac{1}{b}\left[\int \frac{1}{x}dx - a\int \frac{1}{ax+b}dx\right]$$
$$= \frac{1}{b}\left(\ln|x| - a\cdot\frac{1}{a}\ln|ax+b|+c_1\right)$$
$$= \frac{1}{b}\left(\ln|x|-\ln|ax+b|\right)+\frac{c_1}{b}$$
$$= \frac{1}{b}\ln\left|\frac{x}{ax+b}\right|+c \quad , \quad c=\frac{c_1}{b}$$

ដូចនេះ: រូបមន្ត $\int \frac{1}{x(ax+b)}dx = \frac{1}{b}\ln\left|\frac{x}{ax+b}\right|+c$ ត្រូវបានស្រាយបញ្ជាក់ ។

ដ. ស្រាយបញ្ជាក់រូបមន្ត $\int (ax+b)^n dx = \dfrac{(ax+b)^{n+1}}{a(n+1)} + c$

គេមាន $\int (ax+b)^n dx$ តាង $u = ax+b \Rightarrow du = adx \Rightarrow dx = \dfrac{1}{a}\cdot du$

គេបាន $\int (ax+b)^n dx = \int u^n \cdot \dfrac{1}{a} du = \dfrac{1}{a}\int u^n du = \dfrac{1}{a}\cdot\dfrac{u^{n+1}}{n+1} + c = \dfrac{(ax+b)^{n+1}}{a(n+1)} + c$

ដូចនេះ

| រូបមន្ត $\int (ax+b)^n dx = \dfrac{(ax+b)^{n+1}}{a(n+1)} + c$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

ឋ. ស្រាយបញ្ជាក់រូបមន្ត $\int u^n du = \dfrac{u^{n+1}}{n+1} + c \text{ , } n \neq -1$

ដោយ $\int u^n du$ មានទម្រង់ដូច $\int x^n dx = \dfrac{x^{n+1}}{n+1} + c$ នាំឱ្យ $\int u^n du = \dfrac{u^{n+1}}{n+1} + c \text{ , } n \neq -1$

ដូចនេះ

| រូបមន្ត $\int u^n du = \dfrac{u^{n+1}}{n+1} + c$ ដែល $n \neq -1$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

ឌ. ស្រាយបញ្ជាក់រូបមន្ត $\int \dfrac{1}{x} dx = \ln|x| + c$ ដែល $x \neq 0$

គេមាន បើ $x > 0$ នោះគេបាន $(\ln x + c)' = \dfrac{1}{x}$ នាំឱ្យ $\int \dfrac{1}{x} dx = \ln x + c$

បើ $x < 0$ នោះគេបាន $\left[\ln(-x) + c\right]' = \dfrac{(-x)'}{-x} = \dfrac{-1}{-x} = \dfrac{1}{x}$ នាំឱ្យ $\int \dfrac{1}{x} dx = \ln(-x) + c$

តាមពីរករណីខាងលើ គេបាន $\int \dfrac{1}{x} dx = \ln|x| + c$ ដែល $x \neq 0$

ដូចនេះ

| រូបមន្ត $\int \dfrac{1}{x} dx = \ln|x| + c$ ដែល $x \neq 0$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

ឍ. ស្រាយបញ្ជាក់រូបមន្ត $\int \dfrac{1}{\sqrt{ax+b}} dx = \dfrac{2}{a}\left(\sqrt{ax+b}\right) + c$

គេមាន $\int \dfrac{1}{\sqrt{ax+b}} dx$ តាង $u = ax+b \Rightarrow du = adx \Rightarrow dx = \dfrac{1}{a}\cdot du$

គេបាន $\int \dfrac{1}{\sqrt{ax+b}} dx = \int \dfrac{1}{\sqrt{u}}\cdot\dfrac{1}{a} du = \dfrac{1}{a}\int \dfrac{1}{\sqrt{u}} du = \dfrac{1}{a}\left(2\sqrt{u} + c_1\right) = \dfrac{2}{a}\sqrt{ax+b} + c \text{ , } c = \dfrac{c_1}{a}$

ដូចនេះ

| រូបមន្ត $\int \dfrac{1}{\sqrt{ax+b}} dx = \dfrac{2}{a}\left(\sqrt{ax+b}\right) + c$ ដែល $x \neq 0$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

ណ. ស្រាយបញ្ជាក់រូបមន្ត $\int \frac{1}{a^2-x^2}dx=\frac{1}{2a}\ln\left|\frac{x+a}{x-a}\right|+c\ ,a\neq 0$

គេមាន $\frac{1}{a^2-x^2}=-\frac{1}{(x-a)(x+a)}=-\left(\frac{A}{x-a}+\frac{B}{x+a}\right)$ ដែល $A$ និង $B$ ជាចំនួនដែលត្រូវកំណត់

គេបាន $\frac{1}{(x-a)(x-a)}=\frac{A}{x-a}+\frac{B}{x-a}=\frac{A(x+a)+B(x-a)}{(x-a)(x+a)}=\frac{(A+B)x+Aa-Ba}{(x-a)(x+a)}$

គេផ្ទឹមបាន $\begin{cases}A+B=0\\ Aa-Ba=1\end{cases}\Rightarrow\begin{cases}A+B=0\\ A-B=\frac{1}{a}\end{cases}\Rightarrow\begin{cases}B=-A\\ 2A=\frac{1}{a}\end{cases}\Rightarrow\begin{cases}B=-\frac{1}{2a}\\ A=\frac{1}{2a}\end{cases}$

នាំឱ្យ $\frac{1}{a^2-x^2}=-\left(\frac{\frac{1}{2a}}{x-a}+\frac{-\frac{1}{2a}}{x+a}\right)=\frac{1}{2a}\left(\frac{1}{x+a}-\frac{1}{x-a}\right)$

គេបាន $\int\frac{1}{a^2-x^2}dx=\int\frac{1}{2a}\left(\frac{1}{x+a}-\frac{1}{x-a}\right)dx=\frac{1}{2a}\int\left(\frac{1}{x+a}-\frac{1}{x-a}\right)dx$

$=\frac{1}{2a}\left[\int\frac{1}{x+a}dx-\int\frac{1}{x-a}dx\right]$

$=\frac{1}{2a}\left[\ln|x+a|+c_1-\ln|x-a|-c_2\right]$

$=\frac{1}{2a}\left[\ln\left|\frac{x+a}{x-a}\right|+c_3\right]\quad ,\quad c_3=c_1-c_2$

$=\frac{1}{2a}\ln\left|\frac{x+a}{x-a}\right|+c\quad ,\quad c=\frac{c_3}{2a}$

ដូចនេះ: រូបមន្ត $\int\frac{1}{a^2-x^2}dx=\frac{1}{2a}\ln\left|\frac{x+a}{x-a}\right|+c\ ,\ a\neq 0$ ត្រូវបានស្រាយបញ្ជាក់ ។

ត.ស្រាយបញ្ជាក់រូបមន្ត $\int\frac{1}{\sqrt{x^2+a^2}}dx=\ln\left|x+\sqrt{x^2+a^2}\right|+c$

គេមាន $\int\frac{1}{\sqrt{x^2+a^2}}dx$ តាង $x=a\tan u\ \Rightarrow\ dx=\frac{a}{\cos^2 u}du$

គេបាន $\int\frac{1}{\sqrt{x^2+a^2}}dx=\int\frac{1}{\sqrt{(a\tan u)^2+a^2}}\times\frac{a}{\cos^2 u}du$

$=\int\frac{1}{a\sqrt{\tan^2 u+1}}\times\frac{a}{\cos^2 u}du=\int\frac{1}{a\sqrt{\frac{1}{\cos^2 u}}}\times\frac{a}{\cos^2 u}du$

$=\int\frac{1}{\cos u}du=\int\frac{\cos u}{\cos^2 u}du=\int\frac{1}{1-\sin^2 u}\cdot\cos u du$

តាង $t=\sin u\ \Rightarrow\ dt=\cos u du$

$=\int\frac{1}{1-t^2}dt=\frac{1}{2}\ln\left|\frac{t+1}{t-1}\right|+c_1=\frac{1}{2}\ln\left|\frac{\sin u+1}{\sin u-1}\right|+c_1$ ព្រោះ $\int\frac{1}{a^2-x^2}dx=\frac{1}{2a}\ln\left|\frac{x+a}{x-a}\right|+c$

ម្យ៉ាងទៀត $x = a\tan u \Rightarrow \dfrac{x}{a} = \dfrac{\sin u}{\cos u}$ នាំឱ្យ $\cos u = \dfrac{a\sin u}{x}$

តែ $\sin^2 u + \cos^2 u = 1$ នាំឱ្យ $\sin^2 u + \left(\dfrac{a\sin u}{x}\right)^2 = 1$ ឬ $\sin^2 u\left(1 + \dfrac{a^2}{x^2}\right) = 1$ ឬ $\sin^2 u\left(\dfrac{x^2+a^2}{x^2}\right) = 1$

នាំឱ្យ $\sin^2 u = \dfrac{x^2}{x^2+a^2}$ ទាញបាន $\sin u = \sqrt{\dfrac{x^2}{x^2+a^2}} \Leftrightarrow \sin u = \dfrac{x}{\sqrt{x^2+a^2}}$

គេបាន $\displaystyle\int \frac{1}{\sqrt{x^2+a^2}}dx = \frac{1}{2}\ln\left|\frac{\sin u+1}{\sin u-1}\right| + c_1 = \frac{1}{2}\ln\left|\frac{\frac{x}{\sqrt{x^2+a^2}}+1}{\frac{x}{\sqrt{x^2+a^2}}-1}\right| + c_1 = \frac{1}{2}\ln\left|\frac{x+\sqrt{x^2+a^2}}{x-\sqrt{x^2+a^2}}\right| + c_1$

$$= \frac{1}{2}\ln\left|\frac{\left(x+\sqrt{x^2+a^2}\right)^2}{\left(x-\sqrt{x^2+a^2}\right)\left(x+\sqrt{x^2+a^2}\right)}\right| + c = \frac{1}{2}\ln\left|\frac{\left(x+\sqrt{x^2+a^2}\right)^2}{x^2-\left(x^2+a^2\right)}\right| + c$$

$$= \frac{1}{2}\ln\left|\frac{\left(x+\sqrt{x^2+a^2}\right)^2}{-a^2}\right| + c = \frac{1}{2}\ln\left|\frac{\left(x+\sqrt{x^2+a^2}\right)^2}{a^2}\right| + c$$ ព្រោះ $|-x| = |x|$

$$= \frac{1}{2}\ln\left|\left(\frac{x+\sqrt{x^2+a^2}}{a}\right)^2\right| + c_1 = \ln\left|\frac{x+\sqrt{x^2+a^2}}{a}\right| + c_1$$

$$= \ln\left|x+\sqrt{x^2+a^2}\right| - \ln|a| + c_1 = \ln\left|x+\sqrt{x^2+a^2}\right| + c \quad , \quad c = -\ln|a| + c_1$$

ដូចនេះ: រូបមន្ត $\displaystyle\int \frac{1}{\sqrt{x^2+a^2}}dx = \ln\left|x+\sqrt{x^2+a^2}\right| + c$ ត្រូវបានស្រាយបញ្ជាក់ ។

ថ. ស្រាយបញ្ជាក់រូបមន្ត $\int kf'(x)dx = kf(x) + c$

តាមនិយមន័យ $\int f(x)dx = F(x) + c$ សមមូល $\left[F(x)+c\right]' = f(x)$

ដោយ $\left[kf(x)+c\right]' = kf'(x)$ នាំឱ្យ $\int kf'(x)dx = kf(x) + c$

ដូចនេះ: រូបមន្ត $\int kf'(x)dx = kf(x) + c$ ត្រូវបានស្រាយបញ្ជាក់ ។

ទ. ស្រាយបញ្ជាក់រូបមន្ត $\displaystyle\int [f(x)]^n f'(x)dx = \frac{[f(x)]^{n+1}}{n+1} + c, n \neq -1$

តាមនិយមន័យ $\int f(x)dx = F(x) + c$ សមមូល $\left[F(x)+c\right]' = f(x)$

ដោយ $\displaystyle\left(\frac{\left[f(x)\right]^{n+1}}{n+1} + c\right)' = \frac{1}{n+1}\cdot(n+1)\left[f(x)\right]'\left[f(x)\right]^{n+1-1} = f'(x)\left[f(x)\right]^n = \left[f(x)\right]^n f'(x)$

នាំឱ្យ $\displaystyle\int \left[f(x)\right]^n f'(x)dx = \frac{\left[f(x)\right]^{n+1}}{n+1}$

ដូចនេះ: រូបមន្ត $\displaystyle\int \left[f(x)\right]^n f'(x)dx = \frac{\left[f(x)\right]^{n+1}}{n+1}$ ត្រូវបានស្រាយបញ្ជាក់ ។

ធ. ស្រាយបញ្ជាក់រូបមន្ត $\int \frac{f'(x)}{f(x)}dx = \ln|f(x)| + c$

តាមនិយមន័យ $\int f(x)dx = F(x)+c$ សមមូល $[F(x)+c]' = f(x)$

-បើ $f(x)>0$ គេបាន $[\ln f(x)+c]' = \frac{f'(x)}{f(x)}$ នាំឱ្យ $\int \frac{f'(x)}{f(x)}dx = \ln f(x)+c$

-បើ $f(x)<0$ គេបាន $(\ln[-f(x)]+c)' = \frac{[-f(x)]'}{-f(x)} = \frac{-f'(x)}{-f(x)} = \frac{f'(x)}{f(x)}$ នាំឱ្យ $\int \frac{f'(x)}{f(x)}dx = \ln[-f(x)]+c$

តាមករណីទាំងពីរខាងលើ $\int \frac{f'(x)}{f(x)}dx = \ln|f(x)|+c$

ដូចនេះ រូបមន្ត $\int \frac{f'(x)}{f(x)}dx = \ln|f(x)| + c$ ត្រូវបានស្រាយបញ្ជាក់ ។

ន. ស្រាយបញ្ជាក់រូបមន្ត $\int \frac{f'(x)}{[f(x)]^2}dx = \frac{-1}{f(x)} + c$

តាមនិយមន័យ $\int f(x)dx = F(x)+c$ សមមូល $[F(x)+c]' = f(x)$

ដោយ $\left[-\frac{1}{f(x)}+c\right]' = -\left[-\frac{f'(x)}{[f(x)]^2}\right] = \frac{f'(x)}{[f(x)]^2}$

នាំឱ្យ $\int \frac{f'(x)}{[f(x)]^2}dx = -\frac{1}{f(x)}+c$

ដូចនេះ រូបមន្ត $\int \frac{f'(x)}{[f(x)]^2}dx = -\frac{1}{f(x)}+c$ ត្រូវបានស្រាយបញ្ជាក់ ។

ប. ស្រាយបញ្ជាក់រូបមន្ត $\int \frac{f'(x)}{[f(x)]^n}dx = \frac{-1}{(n-1)[f(x)]^{n-1}} + c$

តាមនិយមន័យ $\int f(x)dx = F(x)+c$ សមមូល $[F(x)+c]' = f(x)$

ដោយ $\left[-\frac{1}{(n-1)[f(x)]^{n-1}}+c\right]' = -\frac{1}{n-1}\left([f(x)]^{-n+1}\right)' = -\frac{1}{n-1}\cdot(-n+1)f'(x)[f(x)]^{-n+1-1} = \frac{f'(x)}{[f(x)]^n}$

នាំឱ្យ $\int \frac{f'(x)}{[f(x)]^n}dx = \frac{-1}{(n-1)[f(x)]^{n-1}}+c$

ដូចនេះ រូបមន្ត $\int \frac{f'(x)}{[f(x)]^n}dx = \frac{-1}{(n-1)[f(x)]^{n-1}}+c$ ត្រូវបានស្រាយបញ្ជាក់ ។

ផ. ស្រាយបញ្ជាក់រូបមន្ត $\int \frac{f'(x)}{\sqrt{f(x)}}dx = 2\sqrt{f(x)} + c$

តាមនិយមន័យ $\int f(x)dx = F(x) + c$ សមមូល $\left[F(x)+c\right]' = f(x)$

ដោយ $\left[2\sqrt{f(x)}+c\right]' = 2\cdot\frac{f'(x)}{2\sqrt{f(x)}} = \frac{f'(x)}{\sqrt{f(x)}}$

នាំឱ្យ $\int \frac{f'(x)}{\sqrt{f(x)}}dx = 2\sqrt{f(x)} + c$

ដូចនេះ: រូបមន្ត $\int \frac{f'(x)}{\sqrt{f(x)}}dx = 2\sqrt{f(x)} + c$ ត្រូវបានស្រាយបញ្ជាក់ ។

3. ស្រាយបញ្ជាក់រូបមន្តអាំងតេក្រាលនៃអនុគមន៍ត្រីកោណមាត្រ ៖

ក. ស្រាយបញ្ជាក់រូបមន្ត $\int \sin xdx = -\cos x + c$

តាមនិយមន័យ $\int f(x)dx = F(x) + c$ សមមូល $\left[F(x)+c\right]' = f(x)$

ដោយ $(-\cos x + c)' = -(\cos x)' = -(-\sin x) = \sin x$

នាំឱ្យ $\int \sin xdx = -\cos x + c$

ដូចនេះ: រូបមន្ត $\int \sin xdx = -\cos x + c$ ត្រូវបានស្រាយបញ្ជាក់ ។

ខ. ស្រាយបញ្ជាក់រូបមន្ត $\int \cos xdx = \sin x + c$

តាមនិយមន័យ $\int f(x)dx = F(x) + c$ សមមូល $\left[F(x)+c\right]' = f(x)$

ដោយ $(\sin x + c)' = (\sin x)' = \cos x$

នាំឱ្យ $\int \cos xdx = \sin x + c$

ដូចនេះ: រូបមន្ត $\int \cos xdx = \sin x + c$ ត្រូវបានស្រាយបញ្ជាក់ ។

គ. ស្រាយបញ្ជាក់រូបមន្ត $\int \tan xdx = \int \frac{\sin x}{\cos x}dx = -\ln|\cos x| + c$

តាមនិយមន័យ $\int f(x)dx = F(x) + c$ សមមូល $\left[F(x)+c\right]' = f(x)$

- បើ $\cos x > 0$ គេបាន $\left[-\ln\cos x + c\right]' = -\frac{(\cos x)'}{\cos x} = -\frac{-\sin x}{\cos x} = \tan x$ នាំឱ្យ $\int \tan xdx = -\ln\cos x + c$

- បើ $\cos x < 0$ គេបាន $\left[-\ln(-\cos x) + c\right]' = -\frac{(-\cos x)'}{-\cos x} = \frac{\sin x}{\cos x} = \tan x$ នាំឱ្យ $\int \tan xdx = -\ln(-\cos x) + c$

តាមពីរករណីខាងលើ គេសរសេរបាន $\int \tan xdx = \int \frac{\sin x}{\cos x}dx = -\ln|\cos x| + c$

ដូចនេះ: រូបមន្ត $\int \tan xdx = \int \frac{\sin x}{\cos x}dx = -\ln|\cos x| + c$ ត្រូវបានស្រាយបញ្ជាក់ ។

**ឃ. ស្រាយបញ្ជាក់រូបមន្ត** $\int \cot x dx = \int \frac{\cos x}{\sin x} dx = \ln|\sin x| + c$

តាមនិយមន័យ $\int f(x)dx = F(x) + c$ សមមូល $\left[F(x)+c\right]' = f(x)$

- បើ $\sin x > 0$ គេបាន $\left[\ln \sin x + c\right]' = \frac{(\sin x)'}{\sin x} = \frac{\cos x}{\sin x} = \cot x$ នាំឱ្យ $\int \cot x dx = \ln \sin x + c$

- បើ $\sin x < 0$ គេបាន $\left[\ln(-\sin x) + c\right]' = \frac{(-\sin x)'}{-\sin x} = \frac{\cos x}{\sin x} = \cot x$ នាំឱ្យ $\int \cot x dx = \ln(-\sin x) + c$

តាមពីរករណីខាងលើ គេសរសេរបាន $\int \cot x dx = \int \frac{\cos x}{\sin x} dx = \ln|\sin x| + c$

ដូចនេះ: | រូបមន្ត $\int \cot x dx = \int \frac{\cos x}{\sin x} dx = \ln|\sin x| + c$ ត្រូវបានស្រាយបញ្ជាក់ | ។

**ង. ស្រាយបញ្ជាក់រូបមន្ត** $\int \frac{1}{\cos^2 x} dx = \int (1 + \tan^2 x) dx = \tan x + c$

តាមនិយមន័យ $\int f(x)dx = F(x) + c$ សមមូល $\left[F(x)+c\right]' = f(x)$

ដោយ $(\tan x + c)' = 1 + \tan^2 x = \frac{1}{\cos^2 x}$

នាំឱ្យ $\int (1 + \tan^2 x) dx = \int \frac{1}{\cos^2 x} dx = \tan x + c$

ដូចនេះ: | រូបមន្ត $\int (1 + \tan^2 x) dx = \int \frac{1}{\cos^2 x} dx = \tan x + c$ ត្រូវបានស្រាយបញ្ជាក់ | ។

**ច. ស្រាយបញ្ជាក់រូបមន្ត** $\int \frac{1}{\sin^2 x} dx = \int (1 + \cot^2 x) dx = -\cot x + c$

តាមនិយមន័យ $\int f(x)dx = F(x) + c$ សមមូល $\left[F(x)+c\right]' = f(x)$

ដោយ $(-\cot x + c)' = -\left[-(1 + \cot^2 x)\right] = 1 + \cot^2 x = \frac{1}{\sin^2 x}$

នាំឱ្យ $\int \frac{1}{\sin^2 x} dx = \int (1 + \cot^2 x) dx = -\cot x + c$

ដូចនេះ: | រូបមន្ត $\int \frac{1}{\sin^2 x} dx = \int (1 + \cot^2 x) dx = -\cot x + c$ ត្រូវបានស្រាយបញ្ជាក់ | ។

**ឆ. ស្រាយបញ្ជាក់រូបមន្ត** $\int \sin ax dx = -\frac{1}{a} \cos ax + c$

**➢របៀបទី១** ប្រើអថេរជំនួយ

គេមាន $\int \sin ax dx$ តាង $t = ax \Rightarrow dt = adx$

គេបាន $\int \sin ax dx = \frac{1}{a} \int \sin ax \cdot adx = \frac{1}{a} \int \sin t dt = \frac{1}{a}(-\cos t) + c = -\frac{1}{a} \cos ax + c$

ដូចនេះ: | រូបមន្ត $\int \sin ax dx = -\frac{1}{a} \cos ax + c$ ត្រូវបានស្រាយបញ្ជាក់ | ។

**➤របៀបទី២** តាមនិយមន័យ $\int f(x)dx = F(x)+c$ សមមូល $\left[F(x)+c\right]' = f(x)$

ដោយ $\left(-\frac{1}{a}\cos ax + c\right)' = -\frac{1}{a}(\cos ax)' = -\frac{1}{a}\cdot(ax)'(-\sin ax) = \sin ax$

នាំឱ្យ $\int \sin axdx = -\frac{1}{a}\cos ax + c$

ដូចនេះ | រូបមន្ត $\int \sin axdx = -\frac{1}{a}\cos ax + c$ ត្រូវបានស្រាយបញ្ជាក់ | ។

**ជ. ស្រាយបញ្ជាក់រូបមន្ត** $\int \cos axdx = \frac{1}{a}\sin ax + c$

**➤របៀបទី១** ប្រើអថេរជំនួយ

គេមាន $\int \cos axdx$ តាង $t = ax \Rightarrow dt = adx$

គេបាន $\int \cos axdx = \frac{1}{a}\int \cos ax\cdot adx = \frac{1}{a}\int \cos tdt = \frac{1}{a}(\sin t) + c = \frac{1}{a}\sin ax + c$

ដូចនេះ | រូបមន្ត $\int \cos axdx = \frac{1}{a}\sin ax + c$ ត្រូវបានស្រាយបញ្ជាក់ | ។

**➤របៀបទី២** តាមនិយមន័យ $\int f(x)dx = F(x)+c$ សមមូល $\left[F(x)+c\right]' = f(x)$

ដោយ $\left(\frac{1}{a}\sin ax + c\right)' = \frac{1}{a}(\sin ax)' = \frac{1}{a}\cdot(ax)'(\cos ax) = \cos ax$

នាំឱ្យ $\int \cos axdx = \frac{1}{a}\sin ax + c$

ដូចនេះ | រូបមន្ត $\int \cos axdx = \frac{1}{a}\sin ax + c$ ត្រូវបានស្រាយបញ្ជាក់ | ។

**ឈ. ស្រាយបញ្ជាក់រូបមន្ត** $\int \sin ax\cdot\cos axdx = \frac{1}{2a}\sin^2 ax + c$

គេមាន $\int \sin ax\cdot\cos axdx$ តាង $t = \sin ax \Rightarrow dt = a\cos axdx$

គេបាន $\int \sin ax\cdot\cos axdx = \frac{1}{a}\int \sin ax\cdot a\cos axdx$

$$= \frac{1}{a}\int tdt = \frac{1}{a}\times\frac{t^2}{2} + c$$

$$= \frac{1}{2a}t^2 + c$$

$$= \frac{1}{2a}\sin^2 ax + c$$

ដូចនេះ | រូបមន្ត $\int \cos axdx = \frac{1}{a}\sin ax + c$ ត្រូវបានស្រាយបញ្ជាក់ | ។

ញ. ស្រាយបញ្ជាក់រូបមន្ត $\int \sin^n ax\cos ax dx = \frac{1}{(n+1)a}\sin^{n+1} ax + c$

គេមាន $\int \sin^n ax\cos ax dx$ តាង $t = \sin ax \Rightarrow dt = a\cos ax dx$

គេបាន $\int \sin^n ax\cos ax dx = \frac{1}{a}\int \sin^n ax \cdot a\cos ax dx$

$$= \frac{1}{a}\int t^n dt = \frac{1}{a}\times\frac{t^{n+1}}{n+1} + c$$

$$= \frac{1}{a(n+1)}t^{n+1} + c$$

$$= \frac{1}{a(n+1)}\sin^{n+1} ax + c$$

ដូចនេះ: រូបមន្ត $\int \sin^n ax\cos ax dx = \frac{1}{(n+1)a}\sin^{n+1} ax + c$ ត្រូវបានស្រាយបញ្ជាក់ ។

ដ. ស្រាយបញ្ជាក់រូបមន្ត $\int \cos^n ax\sin ax dx = \frac{-1}{(n+1)a}\cos^{n+1} ax + c$

គេមាន $\int \cos^n ax\sin ax dx$ តាង $t = \cos ax \Rightarrow dt = -a\sin ax dx$

គេបាន $\int \cos^n ax\sin ax dx = -\frac{1}{a}\int \cos^n ax(-a\sin ax)dx$

$$= -\frac{1}{a}\int t^n dt = -\frac{1}{a}\times\frac{t^{n+1}}{n+1} + c$$

$$= -\frac{1}{a(n+1)}\times t^{n+1} + c$$

$$= -\frac{1}{a(n+1)}\cos^{n+1} ax + c$$

ដូចនេះ: រូបមន្ត $\int \cos^n ax\sin ax dx = \frac{-1}{(n+1)a}\cos^{n+1} ax + c$ ត្រូវបានស្រាយបញ្ជាក់ ។

ឋ. ស្រាយបញ្ជាក់រូបមន្ត $\int \sin[f(x)]f'(x)dx = -\cos[f(x)] + c$

គេមាន $\int \sin[f(x)]f'(x)dx$ តាង $t = f(x) \Rightarrow dt = f'(x)dx$

គេបាន $\int \sin[f(x)]f'(x)dx = \int \sin t dt = -\cos t + c = -\cos[f(x)] + c$

ដូចនេះ: រូបមន្ត $\int \sin[f(x)]f'(x)dx = -\cos[f(x)] + c$ ត្រូវបានស្រាយបញ្ជាក់ ។

ឌ. ស្រាយបញ្ជាក់រូបមន្ត $\int \cos[f(x)]f'(x)dx = \sin[f(x)] + c$

គេមាន $\int \cos[f(x)]f'(x)dx$ តាង $t = f(x) \Rightarrow dt = f'(x)dx$

គេបាន $\int \cos[f(x)]f'(x)dx = \int \cos t dt = \sin t + c = \sin[f(x)] + c$

ដូចនេះ: រូបមន្ត $\int \cos[f(x)]f'(x)dx = \sin[f(x)] + c$ ត្រូវបានស្រាយបញ្ជាក់ ។

ឈ. ស្រាយបញ្ជាក់រូបមន្ត $\int \frac{f'(x)}{\cos^2[f(x)]}dx = \int[1+\tan^2[f(x)]]f'(x)dx = \tan[f(x)]+c$

គេមាន $\int \frac{f'(x)}{\cos^2[f(x)]}dx$ និង $\int[1+\tan^2[f(x)]]f'(x)dx$

តាង $u = f(x) \Rightarrow du = f'(x)dx$

គេបាន $\int \frac{f'(x)}{\cos^2[f(x)]}dx = \int \frac{1}{\cos^2 u}du = \tan u + c = \tan[f(x)]+c$

ម្យ៉ាងទៀត $\int[1+\tan^2[f(x)]]f'(x)dx = \int[1+\tan^2 u]du = \tan u + c = \tan[f(x)]+c$

ដូចនេះ | រូបមន្ត $\int \frac{f'(x)}{\cos^2[f(x)]}dx = \int[1+\tan^2[f(x)]]f'(x)dx = \tan[f(x)]+c$ ត្រូវបានស្រាយបញ្ជាក់ | ។

ញ. ស្រាយបញ្ជាក់រូបមន្ត $\int \frac{f'(x)}{\sin^2[f(x)]}dx = \int[1+\cot^2[f(x)]]f'(x)dx = -\cot[f(x)]+c$

គេមាន $\int \frac{f'(x)}{\sin^2[f(x)]}dx$ និង $\int[1+\cot^2[f(x)]]f'(x)dx$

តាង $u = f(x) \Rightarrow du = f'(x)dx$

គេបាន $\int \frac{f'(x)}{\sin^2[f(x)]}dx = \int \frac{1}{\sin^2 u}du = -\cot u + c = -\cot[f(x)]+c$

ម្យ៉ាងទៀត $\int[1+\cot^2[f(x)]]f'(x)dx = \int[1+\cot^2 u]du = -\cot u + c = -\cot[f(x)]+c$

ដូចនេះ | រូបមន្ត $\int \frac{f'(x)}{\cos^2[f(x)]}dx = \int[1+\tan^2[f(x)]]f'(x)dx = \tan[f(x)]+c$ ត្រូវបានស្រាយបញ្ជាក់ | ។

4. ស្រាយបញ្ជាក់រូបមន្តអាំងតេក្រាលនៃអនុគមន៍អិចស្ប៉ូណង់ស្យែល ៖

ក. ស្រាយបញ្ជាក់រូបមន្ត $\int e^x dx = e^x + c$

តាមនិយមន័យ $\int f(x)dx = F(x)+c$ សមមូល $[F(x)+c]' = f(x)$

ដោយ $[e^x + c]' = e^x$

នាំឱ្យ $\int e^x dx = e^x + c$

ដូចនេះ | រូបមន្ត $\int e^x dx = e^x + c$ ត្រូវបានស្រាយបញ្ជាក់ | ។

ខ. ស្រាយបញ្ជាក់រូបមន្ត $\int e^{ax}dx = \frac{e^{ax}}{a}+c$

តាមនិយមន័យ $\int f(x)dx = F(x)+c$ សមមូល $[F(x)+c]' = f(x)$

ដោយ $\left[\frac{e^{ax}}{a}+c\right]' = \frac{1}{a}(e^{ax})' = \frac{1}{a}\cdot(ax)'\cdot e^{ax} = e^{ax}$ នាំឱ្យ $\int e^{ax}dx = \frac{e^{ax}}{a}+c$

ដូចនេះ | រូបមន្ត $\int e^x dx = e^x + c$ ត្រូវបានស្រាយបញ្ជាក់ | ។

គ. ស្រាយបញ្ជាក់រូបមន្ត $\int e^{ax+b}dx = \frac{1}{a}e^{ax+b} + c$

តាមនិយមន័យ $\int f(x)dx = F(x)+c$ សមមូល $[F(x)+c]' = f(x)$

ដោយ $\left[\frac{1}{a}e^{ax+b}+c\right]' = \frac{1}{a}\cdot\left(e^{ax+b}\right)' = \frac{1}{a}\cdot(ax+b)'\cdot e^{ax+b} = e^{ax+b}$

នាំឱ្យ $\int e^{ax+b}dx = \frac{1}{a}e^{ax+b} + c$

ដូចនេះ: រូបមន្ត $\int e^{ax+b}dx = \frac{1}{a}e^{ax+b} + c$ ត្រូវបានស្រាយបញ្ជាក់ ។

ឃ. ស្រាយបញ្ជាក់រូបមន្ត $\int a^x dx = \frac{a^x}{\ln a} + c$

តាមនិយមន័យ $\int f(x)dx = F(x)+c$ សមមូល $[F(x)+c]' = f(x)$

ដោយ $\left[\frac{a^x}{\ln a}+c\right]' = \frac{1}{\ln a}\cdot\left(a^x\right)' = \frac{1}{\ln a}\cdot a^x \ln a = a^x$

នាំឱ្យ $\int a^x dx = \frac{a^x}{\ln a} + c$

ដូចនេះ: រូបមន្ត $\int a^x dx = \frac{a^x}{\ln a} + c$ ត្រូវបានស្រាយបញ្ជាក់ ។

ង. ស្រាយបញ្ជាក់រូបមន្ត $\int e^u du = e^u + c$

តាមសម្រាយបញ្ជាក់ក្នុងលំហាត់ ក.

គេបាន $\int e^x dx = e^x + c$

នាំឱ្យបាន $\int e^u du = e^u + c$

ដូចនេះ: រូបមន្ត $\int e^u du = e^u + c$ ត្រូវបានស្រាយបញ្ជាក់ ។

ច.ស្រាយបញ្ជាក់រូបមន្ត $\int f'(x)e^{f(x)}dx = e^{f(x)} + c$

តាមនិយមន័យ $\int f(x)dx = F(x)+c$ សមមូល $[F(x)+c]' = f(x)$

ដោយ $\left[e^{f(x)}+c\right]' = f'(x)e^{f(x)}$

នាំឱ្យ $\int f'(x)e^{f(x)}dx = e^{f(x)} + c$

ដូចនេះ: រូបមន្ត $\int f'(x)e^{f(x)}dx = e^{f(x)} + c$ ត្រូវបានស្រាយបញ្ជាក់ ។

5. **ស្រាយបញ្ជាក់រូបមន្តអាំងតេក្រាលដោយផ្នែក ៖** $\int f(x)g'(x)dx = f(x)g(x)-\int g(x)f'(x)dx$

តាមរូបមន្ត $\left[f(x)g(x)\right]' = f'(x)g(x)+g'(x)f(x)$

$f(x)g'(x)=\left[f(x)g(x)\right]'-f'(x)g(x)$ បំពាក់អាំងតេក្រាលលើអង្គទាំងពីរ

គេបាន $\int f(x)g'(x)dx=\int\left(\left[f(x)g(x)\right]'-f'(x)g(x)\right)dx$

$=\int\left[f(x)g(x)\right]'dx-\int f'(x)g(x)dx$

$=f(x)g(x)-\int g(x)f'(x)dx$

ដូចនេះ: | រូបមន្តអាំងតេក្រាលដោយផ្នែក $\int f(x)g'(x)dx = f(x)g(x)-\int g(x)f'(x)dx$ ត្រូវបានស្រាយបញ្ជាក់ | ។

✓**យល់ដឹង** ពេលខ្លះគេសរសេរ $\int fg' = fg-\int gf'$ ដែល $f=f(x)$ និង $g=g(x)$

ឬក៏គេអាចសរសេរ $\int udv = uv-\int vdu$ ដែល $u=u(x)$ និង $v=v(x)$

6. **ស្រាយបញ្ជាក់រូបមន្តអាំងតេក្រាលនៃអនុគមន៍លោការីត ៖**

**ក. ស្រាយបញ្ជាក់រូបមន្ត** $\int \ln x dx = x\ln x - x + c$ **ដែល** $x>0$

➤**របៀបទី១** តាមអាំងតេក្រាលដោយផ្នែក

គេមាន $\int \ln x dx$

គេតាង $u=\ln x \Rightarrow du=\frac{1}{x}dx$

$dv=dx \Rightarrow v=x$

តាមរូបមន្ត អាំងតេក្រាលដោយផ្នែក $\int udv=uv-\int vdu$

គេបាន $\int \ln x dx = x\ln x-\int x\cdot\frac{1}{x}dx$

$=x\ln x-\int dx$

$=x\ln x-x+c$

ដូចនេះ: | រូបមន្ត $\int \ln x dx = x\ln x - x + c$ ត្រូវបានស្រាយបញ្ជាក់ | ។

➤**របៀបទី២** តាមនិយមន័យ

តាមនិយមន័យ $\int f(x)dx=F(x)+c$ សមមូល $\left[F(x)+c\right]'=f(x)$

ដោយ $\left[x\ln x-x+c\right]'=(x)'\ln x+(\ln x)'x-1=\ln x+\frac{1}{x}\cdot x-1=\ln x+1-1=\ln x$

នាំឱ្យ $\int \ln x dx = x\ln x - x + c$

ដូចនេះ: | រូបមន្ត $\int \ln x dx = x\ln x - x + c$ ត្រូវបានស្រាយបញ្ជាក់ | ។

ខ. ស្រាយបញ្ជាក់រូបមន្ត $\int \frac{\ln x}{x}dx = \frac{1}{2}\ln^2 x$

➢របៀបទី១ តាមអាំងតេក្រាលដោយផ្នែក

គេមាន $\int \frac{\ln x}{x}dx$

គេតាង $u = \ln x \quad \Rightarrow \quad du = \frac{1}{x}dx$

$dv = \frac{1}{x}dx \quad \Rightarrow \quad v = \ln x$

តាមរូបមន្ត អាំងតេក្រាលដោយផ្នែក $\int udv = uv - \int vdu$

គេបាន $\int \frac{\ln x}{x}dx = \ln x \cdot \ln x - \int \frac{\ln x}{x}dx$

ឬ $2\int \frac{\ln x}{x}dx = \ln^2 x$

នាំឱ្យ $\int \frac{\ln x}{x}dx = \frac{1}{2}\ln^2 x$

ដូចនេះ រូបមន្ត $\int \frac{\ln x}{x}dx = \frac{1}{2}\ln^2 x$ ត្រូវបានស្រាយបញ្ជាក់ ។

➢របៀបទី២ តាមវិធីដោយប្រើអថេរជំនួយ

គេមាន $\int \frac{\ln x}{x}dx = \int \ln x \cdot \frac{1}{x}dx$

គេតាង $u = \ln x \Rightarrow \quad du = \frac{1}{x}dx$

គេបាន $\int \frac{\ln x}{x}dx = \int \ln x \cdot \frac{1}{x}dx = \int udu = \frac{u^2}{2} + c = \frac{\ln^2 x}{2}$ (យក $c = 0$)

ដូចនេះ រូបមន្ត $\int \frac{\ln x}{x}dx = \frac{1}{2}\ln^2 x$ ត្រូវបានស្រាយបញ្ជាក់ ។

➢របៀបទី២ តាមនិយមន័យ

តាមនិយមន័យ $\int f(x)dx = F(x) + c$ សមមូល $\left[F(x) + c\right]' = f(x)$

ដោយ $\left[\frac{1}{2}\ln^2 x\right]' = \frac{1}{2}\cdot 2(\ln x)' \cdot \ln x$

$= \frac{1}{x}\cdot \ln x = \frac{\ln x}{x}$

នាំឱ្យ $\int \frac{\ln x}{x}dx = \frac{1}{2}\ln^2 x$

ដូចនេះ រូបមន្ត $\int \frac{\ln x}{x}dx = \frac{1}{2}\ln^2 x$ ត្រូវបានស្រាយបញ្ជាក់ ។

គ. ស្រាយបញ្ជាក់រូបមន្ត $\int \frac{\ln^n x}{x}dx = \frac{\ln^{n+1} x}{n+1} + c$

➢របៀបទី១ តាមវិធីដោយប្រើអថេរជំនួយ

គេមាន $\int \ln^n x \cdot \frac{1}{x}dx$

តាង $u = \ln x \quad \Rightarrow \quad du = \frac{1}{x}dx$

គេបាន $\int \ln^n x \cdot \frac{1}{x}dx = \int u^n du = \frac{u^{n+1}}{n+1} + c = \frac{\ln^{n+1} x}{n+1} + c$

ដូចនេះ: | រូបមន្ត $\int \frac{\ln^n x}{x}dx = \frac{\ln^{n+1} x}{n+1} + c$ ត្រូវបានស្រាយបញ្ជាក់ | ។

➢របៀបទី២ តាមនិយមន័យ

តាមនិយមន័យ $\int f(x)dx = F(x) + c$ សមមូល $\left[F(x) + c\right]' = f(x)$

ដោយ $\left[\frac{\ln^{n+1} x}{n+1} + c\right]' = \frac{1}{n+1}\left(\ln^{n+1} x\right)' = \frac{1}{n+1}(n+1)(\ln x)' \ln^n x = \frac{1}{x} \cdot \ln^n x = \frac{\ln^n x}{x}$

នាំឱ្យ $\int \frac{\ln^n x}{x}dx = \frac{\ln^{n+1} x}{n+1} + c$

ដូចនេះ: | រូបមន្ត $\int \frac{\ln^n x}{x}dx = \frac{\ln^{n+1} x}{n+1} + c$ ត្រូវបានស្រាយបញ្ជាក់ | ។

➢របៀបទី៣ តាមអាំងតេក្រាលដោយផ្នែក

គេមាន $\int \frac{\ln^n x}{x}dx$

តាង $u = \ln^n x \quad \Rightarrow \quad du = n \cdot (\ln x)' \cdot \ln^{n-1} x dx = \frac{n\ln^{n-1} x}{x}dx$

$dv = \frac{1}{x}dx \quad \Rightarrow \quad v = \ln x$

តាមរូបមន្ត អាំងតេក្រាលដោយផ្នែក $\int u dv = uv - \int v du$

គេបាន $\int \frac{\ln^n x}{x}dx = \ln^n x \cdot \ln x - \int \ln x \cdot \frac{n\ln^{n-1} x}{x}dx$

$\int \frac{\ln^n x}{x}dx = \ln^n x \cdot \ln x - n\int \frac{\ln^n x}{x}dx$

$n\int \frac{\ln^n x}{x}dx + \int \frac{\ln^n x}{x}dx = \ln^{n+1} x$

$(n+1)\int \frac{\ln^n x}{x}dx = \ln^{n+1} x \quad \Rightarrow \quad \int \frac{\ln^n x}{x}dx = \frac{\ln^{n+1} x}{n+1}$

ដូចនេះ: | រូបមន្ត $\int \frac{\ln^n x}{x}dx = \frac{\ln^{n+1} x}{n+1} + c$ ត្រូវបានស្រាយបញ្ជាក់ | ។

**ឃ. ស្រាយបញ្ជាក់រូបមន្ត** $\int \frac{1}{x\ln x}dx = \ln(\ln x)+c$ **ដែល** $x>1$

**➤របៀបទី១** តាមវិធីដោយប្រើអថេរជំនួយ

គេមាន $\int \frac{1}{x\ln x}dx = \int \frac{1}{\ln x}\cdot\frac{1}{x}dx$

គេតាង $u=\ln x \Rightarrow du=\frac{1}{x}dx$

គេបាន $\int \frac{1}{x\ln x}dx = \int \frac{1}{\ln x}\cdot\frac{1}{x}dx = \int \frac{1}{u}du = \ln u + c = \ln(\ln x)+c$

ដូចនេះ

| រូបមន្ត $\int \frac{1}{x\ln x}dx = \ln(\ln x)+c$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

**➤របៀបទី២** តាមនិយមន័យ

តាមនិយមន័យ $\int f(x)dx = F(x)+c$ សមមូល $[F(x)+c]' = f(x)$

ដោយ $[\ln(\ln x)+c]' = \frac{(\ln x)'}{\ln x} = (\ln x)'\times\frac{1}{\ln x} = \frac{1}{x}\times\frac{1}{\ln x} = \frac{1}{x\ln x}$

នាំឱ្យ $\int \frac{1}{x\ln x}dx = \ln(\ln x)+c$

ដូចនេះ

| រូបមន្ត $\int \frac{1}{x\ln x}dx = \ln(\ln x)+c$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

7. **ស្រាយបញ្ជាក់នូវលក្ខណៈនៃអាំងតេក្រាលកំណត់ខាងក្រោម ៖**

**ក. ស្រាយបញ្ជាក់នូវលក្ខណៈ** $\int_a^b f(x)dx = -\int_b^a f(x)dx$

តាមនិយមន័យ $\int_a^b f(x)dx = F(b)-F(a)$ ដែល $F(x)$ ជាព្រីមីទីវនៃ $f(x)$

គេមាន $\int_a^b f(x)dx = F(b)-F(a) = -[F(a)-F(b)] = -\int_b^a f(x)dx$

ដូចនេះ

| លក្ខណៈ $\int_a^b f(x)dx = -\int_b^a f(x)dx$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

**ខ. ស្រាយបញ្ជាក់នូវលក្ខណៈ** $\int_a^a f(x)dx = 0$

តាមនិយមន័យ $\int_a^b f(x)dx = F(b)-F(a)$ ដែល $F(x)$ ជាព្រីមីទីវនៃ $f(x)$

គេមាន $\int_a^a f(x)dx = F(a)-F(a) = 0$

ដូចនេះ

| លក្ខណៈ $\int_a^a f(x)dx = 0$ ត្រូវបានស្រាយបញ្ជាក់ |
|---|

។

**តើអ្នកដឹងទេថា** «ក្នុងការបកស្រាយរូបមន្ត គេតែងតែប្រើនិយមន័យ ដើម្បីជាយោងក្នុងការបកស្រាយ» ?

**គិតទាំងអស់គ្នា** «ស្វ័យសត្យជាអ្វី? និយមន័យជាអ្វី? ជាទូទៅជាអ្វី? លក្ខណៈជាអ្វី? ទ្រឹស្តីបទជាអ្វី? រូបមន្តជាអ្វី? វិបាកជាអ្វី? ...»

គ. ស្រាយបញ្ជាក់នូវលក្ខណៈ $\int_a^b f(x)dx+\int_b^c f(x)dx=\int_a^c f(x)dx$

គេមាន $f$ ជាប់និងកំណត់លើចន្លោះ $[a\,,b]$ និង $a<b<c$

គេបាន
$$\int_a^b f(x)dx+\int_b^c f(x)dx=[F(b)-F(a)]-[F(c)-F(b)]$$
$$=F(b)-F(a)+F(c)-F(b)$$
$$=F(c)-F(a)$$
$$=\int_a^c f(x)dx$$

ដូចនេះ: | លក្ខណៈ: $\int_a^b f(x)dx+\int_b^c f(x)dx=\int_a^c f(x)dx$ ត្រូវបានស្រាយបញ្ជាក់ | ។

ឃ. ស្រាយបញ្ជាក់នូវលក្ខណៈ: $\int_a^b kf(x)dx=k\int_a^b f(x)dx\quad ,k\in\mathbb{R}$

គេមាន $\int_a^b kf(x)dx=kF(b)-kF(a)=k[F(b)-F(a)]=k\int_a^b f(x)$

ដូចនេះ: | លក្ខណៈ: $\int_a^b f(x)dx+\int_b^c f(x)dx=\int_a^c f(x)dx$ ត្រូវបានស្រាយបញ្ជាក់ | ។

ង. -ស្រាយបញ្ជាក់នូវលក្ខណៈ: $i)\ \int_a^b[f(x)\pm g(x)]dx=\int_a^b f(x)dx\pm\int_a^b g(x)dx$

គេមាន
$$\int_a^b[f(x)+g(x)]dx=[F(b)+G(b)]-[F(a)+G(a)]$$
$$=F(b)+G(b)-F(a)-G(a)$$
$$=[F(b)-F(a)]+[G(b)-G(a)]$$
$$=\int_a^b f(x)dx+\int_a^b g(x)dx$$

ម្យ៉ាងទៀត
$$\int_a^b[f(x)-g(x)]dx=[F(b)-G(b)]-[F(a)-G(a)]$$
$$=F(b)-G(b)-F(a)+G(a)$$
$$=[F(b)-F(a)]-[G(b)-G(a)]$$
$$=\int_a^b f(x)dx-\int_a^b g(x)dx$$

ដូចនេះ: | លក្ខណៈ: $\int_a^b[f(x)\pm g(x)]dx=\int_a^b f(x)dx\pm\int_a^b g(x)dx$ ត្រូវបានស្រាយបញ្ជាក់ | ។

-ស្រាយបញ្ជាក់នូវលក្ខណៈ: $ii)\ \int_a^b[\alpha f(x)\pm\beta g(x)]dx=\alpha\int_a^b f(x)dx\pm\beta\int_a^b g(x)dx$

គេមាន
$$\int_a^b[\alpha f(x)+\beta g(x)]dx=[\alpha F(b)+\beta G(b)]-[\alpha F(a)+\beta G(a)]$$
$$=\alpha F(b)-\alpha F(a)+\beta G(b)-\beta G(a)$$
$$=\alpha[F(b)-F(a)]+\beta[G(b)-G(a)]$$
$$=\alpha\int_a^b f(x)dx+\beta\int_a^b g(x)dx$$

ម្យ៉ាងទៀត $\int_a^b[\alpha f(x)-\beta g(x)]dx=[\alpha F(b)-\beta G(b)]-[\alpha F(a)-\beta G(a)]$

$$=\alpha F(b)-\beta G(b)-\alpha F(a)+\beta G(a)$$
$$=\alpha F(b)-\alpha F(a)-\beta G(b)+\beta G(a)$$
$$=\alpha[F(b)-F(a)]-\beta[G(b)-G(a)]$$
$$=\alpha\int_a^b f(x)dx-\beta\int_a^b g(x)dx$$

ដូចនេះ: | លក្ខណ: $\int_a^b[\alpha f(x)\pm\beta g(x)]dx=\alpha\int_a^b f(x)dx\pm\beta\int_a^b g(x)dx$ ត្រូវបានស្រាយបញ្ជាក់ | ។

8. ស្រាយបញ្ជាក់ រូបមន្តអាំងតេក្រាលកំណត់ដោយផ្នែក ៖ $\int_a^b f(x)g'(x)dx=[f(x)g(x)]_a^b-\int_a^b g(x)f'(x)dx$

គេមាន $[f(x)g(x)]'=f'(x)g(x)+g'(x)f(x)$ (រូបមន្តដេរីវេ)

នាំឱ្យ $g'(x)f(x)=[f(x)g(x)]'-f'(x)g(x)$ (បំពាក់អាំងតេក្រាលកំណត់ពី $a$ ទៅ $b$ លើអង្គទាំងពីរ)

គេបាន $\int_a^b g'(x)f(x)dx=\int_a^b[f(x)g(x)]'dx-\int_a^b f'(x)g(x)dx$

ឬ $\int_a^b f(x)g'(x)dx=[f(x)g(x)]_a^b-\int_a^b g(x)f'(x)dx$

ដូចនេះ: | លក្ខណ: $\int_a^b f(x)g'(x)dx=[f(x)g(x)]_a^b-\int_a^b g(x)f'(x)dx$ ត្រូវបានស្រាយបញ្ជាក់ | ។

9. ស្រាយបញ្ជាក់ រូបមន្តអាំងតេក្រាលកំណត់ដោយប្តូរអថេរ ៖ $\int_a^b f[g(x)]g'(x)dx=\int_{g(a)}^{g(b)} f(u)du$

គេមាន $u=g(x)$ នោះ $du=g'(x)dx$

គេតាង $F(u)$ ជាព្រីមីទីវនៃ $f(u)$ នោះ $F'(u)=f(u)$

គេបាន $\int_a^b f[g(x)]g'(x)dx=\int_a^b f(u)du$

$$=[F(u)]_a^b=[F(g(x))]_a^b$$
$$=F[g(b)]-F[g(a)]$$
$$=\int_{g(a)}^{g(b)} f(u)du$$

ដូចនេះ: | រូបមន្ត $\int_a^b f[g(x)]g'(x)dx=\int_{g(a)}^{g(b)} f(u)du$ ត្រូវបានស្រាយបញ្ជាក់ | ។

10. ស្រាយបញ្ជាក់ថា $\frac{d}{dx}[F(x)]=\frac{d}{dx}\left[\int_a^x f(t)dt\right]=f(x)$

គេមាន $F(x)=\int_a^x f(t)dt$

គេតាង $F(t)$ ជាព្រីមីទីវនៃ $f(t)$ នោះ $F'(t)=f(t)$

គេបាន $\frac{d}{dx}[F(x)]=\frac{d}{dx}\left[\int_a^x f(t)dt\right]=\frac{d}{dx}[F(t)]_a^x=\frac{d}{dx}[F(x)-F(a)]=\frac{d}{dx}[F(x)]-0=F'(x)=f(x)$

ដូចនេះ: | $\frac{d}{dx}[F(x)]=\frac{d}{dx}\left[\int_a^x f(t)dt\right]=f(x)$ ត្រូវបានស្រាយបញ្ជាក់ | ។

11. **ស្រាយបញ្ជាក់ថា ប្រវែងធ្នូនៃក្រាបតាងអនុគមន៍** $f$ **នៅចន្លោះបន្ទាត់ឈរ** $x=a$ **និង** $x=b$ **គឺ** $L=\int_a^b\sqrt{1+\left[f'(x)\right]^2}\,dx$

គេមាន $f$ ជាអនុគមន៍ជាប់ និងកំណត់ដោយ $y=f(x)$ និងមានក្រាប $C$

គេចែក $[a\,,b]$ ជា $n$ ចំណែក

គេយក ចំណុច $P_0\left(x\,,\,f(x)\right)$ និង $P_1\left(x+\Delta x\,,\,f(x+\Delta x)\right)$

ដែល $a\le x<x+\Delta x\le b$




គេតាង $\Delta y=f(x+\Delta x)-f(x)$ និងតាង $\Delta L=P_0P_1$

ចំពោះ: $\Delta L=P_0P_1$ គេបាន ៖ $x$

$$\Delta L=\sqrt{(x+\Delta x-x)^2+\left[f(x+\Delta x)-f(x)\right]^2}$$

$$=\sqrt{(\Delta x)^2+(\Delta y)^2}$$

$$=\sqrt{(\Delta x)^2\left[1+\left(\frac{\Delta y}{\Delta x}\right)^2\right]}$$

$$=\sqrt{1+\left(\frac{\Delta y}{\Delta x}\right)^2}\cdot\Delta x$$

គេបាន $dL=\sqrt{1+\left(\frac{dy}{dx}\right)^2}\cdot dx$

នាំឱ្យ ប្រវែងធ្នូ $L$ នៃក្រាបតាង $y=f(x)$ នៅចន្លោះបន្ទាត់ឈរ $x=a$ និង $x=b$ គឺ

$$L=\int_a^b\sqrt{1+\left(\frac{dy}{dx}\right)^2}\cdot dx \quad ឬ \quad L=\int_a^b\sqrt{1+\left[f'(x)\right]^2}\cdot dx$$

ដូចនេះ: | ប្រវែងធ្នូនៃក្រាបតាងអនុគមន៍ $f$ នៅចន្លោះបន្ទាត់ឈរ $x=a$ និង $x=b$ គឺ $L=\int_a^b\sqrt{1+\left[f'(x)\right]^2}\,dx$ | ។

12. **ស្រាយបញ្ជាក់ថា** $\int_a^b\left|f(x)\right|dx\ge\left|\int_a^b f(x)\,dx\right|$

គេមាន $f$ មានអាំងតេក្រាលលើចន្លោះ $[a\,,b]$

ដោយ $-\left|f(x)\right|\le f(x)\le\left|f(x)\right|$ (ធ្វើអាំងតេក្រាលកំណត់ពី $a$ ទៅ $b$ លើវិសមភាព)

គេបាន $\int_a^b-\left|f(x)\right|dx\le\int_a^b f(x)\,dx\le\int_a^b\left|f(x)\right|dx$

$-\int_a^b\left|f(x)\right|dx\le\int_a^b f(x)\,dx\le\int_a^b\left|f(x)\right|dx$ (តាមលក្ខណៈ: $-M\le x\le M \iff |x|\le M$ )

នាំឱ្យ $\left|\int_a^b f(x)\,dx\right|\le\int_a^b\left|f(x)\right|dx$

ដូចនេះ: | ទំនាក់ទំនង $\int_a^b\left|f(x)\right|dx\ge\left|\int_a^b f(x)\,dx\right|$ ត្រូវបានស្រាយបញ្ជាក់ | ។

# ការស្រាយបញ្ជាក់លើមេរៀន សមីការឌីផេរ៉ង់ស្យែល

1. ស្រាយបញ្ជាក់ថា សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី១ មេគុនថេរអង្គទី២ស្មើសូន្យ $y'+ay=0$ មានចម្លើយទូទៅ $y=Ae^{-ax}$ ដែល $A$ ជាចំនួនថេរ ។
2. បង្ហាញថា សមីការ $y'+ay=p(x)$ , $p(x)\neq 0$ មានចម្លើយទូទៅ $y=y_c+y_p$ ដែល $y_c=ce^{-ax}$ និង $y_p=e^{-ax}\int e^{ax}p(x)dx$ ។
3. ស្រាយបញ្ជាក់ សមីការ $(E): y''+by'+cy=0$ ដែលសមីការសម្គាល់ $\lambda^2+by+c=0$ មានចម្លើយទូទៅគឺ ៖

   ក. $y=Ae^{\alpha x}+Be^{\beta x}$ , $A$ និង $B$ ជាចំនួនថេរណាមួយក៏បាន ក្នុងករណី $\Delta>0$ សមីការសម្គាល់មានឫស $\lambda_1=\alpha$ , $\lambda_2=\beta$ ។

   ខ. $y=Axe^{\alpha x}+Be^{\alpha x}$ , $A$ និង $B$ ជាចំនួនថេរណាមួយក៏បាន ក្នុងករណី $\Delta=0$ សមីការសម្គាល់មានឫស $\lambda_1=\lambda_2=\alpha$ ។

   គ. $y=(C\cos\beta x+D\sin\beta x)e^{\alpha x}$ , $C$ និង $D$ ជាចំនួនថេរណាមួយក៏បាន ក្នុងករណី $\Delta<0$ សមីការសម្គាល់មានឫសជាចំនួនកុំផ្លិចឆ្លាស់គ្នា $\lambda_1=\alpha-i\beta$ និង $\lambda_2=\alpha+i\beta$ ។

# ការស្រាយបញ្ជាក់លើមេរៀន សមីការឌីផេរ៉ង់ស្យែល

1. **បង្ហាញថា សមីការឌីផេរ៉ង់ស្យែល $y'+ay=0$ មានចម្លើយទូទៅ $y=Ae^{-ax}$ ដែល $A$ ជាចំនួនថេរ**

គេមាន $y'+ay=0$

$$\frac{dy}{dx}=-ay \quad \text{ឬ} \quad dy=-aydx$$

$$\frac{dy}{y}=-adx \quad \text{(បំពាក់អាំងតេក្រាលលើអង្គទាំងពីរ)}$$

$$\int\frac{dy}{y}=\int -adx$$

$$\ln|y|=-ax+c$$

$$|y|=e^{-ax+c}$$

$$y=\pm e^{c}\cdot e^{-ax}$$

$$y=Ae^{-ax} \quad , \; A=\pm e^{c}$$

ដូចនេះ | ចម្លើយទូទៅនៃសមីការ $y'+ay=0$ គឺ $y=Ae^{-ax}$ ដែល $A$ ជាចំនួនថេរ ត្រូវបានស្រាយបញ្ជាក់ ។

2. **បង្ហាញថា សមីការ $y'+ay=p(x)$ , $p(x)\neq 0$ មានចម្លើយទូទៅ $y=y_c+y_p$**

គេមានសមីការ $y'+ay=0$ មានចម្លើយទូទៅ $y=Ae^{-ax}$

គេធ្វើបម្រែបម្រួលចំនួនថេរ $A$ ទៅជា $A(x)$

គេបាន $y=A(x)e^{-ax}$

$$y'=A'(x)e^{-ax}+\left(e^{-ax}\right)'A(x)$$

$$=A'(x)e^{-ax}-aA(x)e^{-ax}$$

យកតម្លៃ $y=A(x)e^{-ax}$ និង $y'=A'(x)e^{-ax}-aA(x)e^{-ax}$ ជំនួសក្នុងសមីការ $y'+ay=p(x)$

គេបាន $A'(x)e^{-ax}-aA(x)e^{-ax}+aA(x)e^{-ax}=p(x)$

$$A'(x)e^{-ax}=p(x)$$

$$A'(x)=e^{ax}p(x)$$

$$\int A'(x)dx=\int e^{ax}p(x)dx+c$$

$$A(x)=\int e^{ax}p(x)dx+c$$

នាំឱ្យ $y=A(x)e^{-ax}$

$$=\left(\int e^{ax}p(x)dx+c\right)e^{-ax}$$

$$=e^{-ax}\int e^{ax}p(x)dx+ce^{-ax}$$

$=y_p+y_c$ ព្រោះគេឱ្យ $y_c=ce^{-ax}$ និង $y_p=e^{-ax}\int e^{ax}p(x)dx$

ដូចនេះ | សមីការ $y'+ay=p(x)$ , $p(x)\neq 0$ មានចម្លើយទូទៅ $y=y_c+y_p$ ត្រូវបានស្រាយបញ្ជាក់ ។

3. ក. ស្រាយបញ្ជាក់ថា សមីការ $(E): y''+by'+cy=0$ មានចម្លើយទូទៅគឺ $y=Ae^{\alpha x}+Be^{\beta x}$ ក្នុងករណី $\Delta>0$

គេមាន $(E): y''+by'+cy=0$ មានសមីការសម្គាល់ $\lambda^2+by+c=0$ ដែលមានឫស $\lambda_1=\alpha$ , $\lambda_2=\beta$

តាមវ្យែត ផលបូកឫស $\alpha+\beta=-b$ និងផលគុណឫស $\alpha\beta=c$

គេបាន $(E):\ y''-(\alpha+\beta)y'+(\alpha\beta)y=0$

$$y''-\alpha y'-\beta y'+\alpha\beta y=0$$

$$(y'-\alpha y)'-\beta(y'-\alpha y)=0$$

គេតាង $y'-\alpha y=Z$ នោះ $(y'-\alpha y)'=Z'$

គេបាន $Z'-\beta Z=0$ (ជាសមីការឌីផេរ៉ង់ស្យែលលំដាប់១ អូម៉ូសែន)

$$\frac{dZ}{dx}=\beta Z \quad \text{ឬ} \quad \frac{dZ}{Z}=\beta dx$$ (បំពាក់អាំងតេក្រាលលើអង្គទាំងពីរ)

$$\int\frac{dZ}{Z}=\int\beta dx$$

$$\ln|Z|=\beta x+c$$

$$|Z|=e^{\beta x+c}$$

$$Z=\pm e^c\cdot e^{\beta x}=c_1e^{\beta x} \quad , \quad c_1=\pm e^c$$

នាំឱ្យ $y'-\alpha y=Z$ ទៅជា $y'-\alpha y=c_1e^{\beta x}$ (1) (ជាសមីការឌីផេរ៉ង់ស្យែលលំដាប់១ មិនអូម៉ូសែន)

គេនឹងដោះស្រាយសមីការ $y'-\alpha y=0$ រួចហើយធ្វើបម្រែបម្រួលចំនួនថេរ

គេបាន $\frac{dy}{dx}=ay$ ឬ $dy=aydx$ ឬ $\frac{dy}{y}=adx$ (បំពាក់អាំងតេក្រាលលើអង្គទាំងពីរ)

$$\int\frac{dy}{y}=\int\alpha dx$$

$$\ln|y|=\alpha x+c$$

$$|y|=e^{\alpha x+c}$$

$$y=\pm e^c\cdot e^{\alpha x}=c_2e^{\alpha x} \quad , \quad c_2=\pm e^c$$

គេធ្វើបម្រែបម្រួលចំនួនថេរ $c_2$ ទៅជា $c_2(x)$

គេមាន $y=c_2(x)e^{\alpha x}$ (2) នោះ $y'=c_2'(x)e^{\alpha x}+(e^{\alpha x})'c_2(x)$

$$=c_2'(x)e^{\alpha x}+\alpha c_2(x)e^{\alpha x}$$

គេបាន $(1):\ c_2'(x)e^{\alpha x}+\alpha c_2(x)e^{\alpha x}-\alpha c_2(x)e^{\alpha x}=c_1e^{\beta x}$

$$c_2'(x)e^{\alpha x}=c_1e^{\beta x}$$

$$c_2'(x)=c_1e^{\beta x-\alpha x}$$ (បំពាក់អាំងតេក្រាលលើអង្គទាំងពីរ)

នាំឱ្យ $\int c_2'(x)dx=\int c_1e^{(\beta-\alpha)x}dx$ ឬ $c_2(x)=\frac{c_1}{\beta-\alpha}e^{(\beta-\alpha)x}+A$ ឬ $c_2(x)=Be^{(\beta-\alpha)x}+A$ , $B=\frac{c_1}{\beta-\alpha}$

គេបាន $(2):\ y=\left[Be^{(\beta-\alpha)x}+A\right]e^{\alpha x}=Ae^{\alpha x}+Be^{\beta x}$ ដែល $A$ និង $B$ ជាចំនួនថេរណាមួយក៏បាន

ដូចនេះ **សមីការ $y''+by'+cy=0$ មានចម្លើយទូទៅគឺ $y=Ae^{\alpha x}+Be^{\beta x}$ ត្រូវបានស្រាយបញ្ជាក់** ។

ខ. ស្រាយបញ្ជាក់ថា សមីការ $(E): y''+by'+cy=0$ មានចម្លើយទូទៅគឺ $y=Axe^{\alpha x}+Be^{\alpha x}$ ក្នុងករណី $\Delta=0$

គេមាន $(E): y''+by'+cy=0$ មានសមីការសម្គាល់ $\lambda^2+by+c=0$ ដែលមានឫសឌុប $\lambda_1=\lambda_2=\alpha$

តាមវ្យែត ផលបូកឫស $\alpha+\alpha=-b$ និងផលគុណឫស $\alpha\alpha=c$

គេបាន $(E): \; y''-(\alpha+\alpha)y'+(\alpha\alpha)y=0$

$$y''-\alpha y'-\alpha y'+\alpha\alpha y=0$$

$$(y'-\alpha y)'-\alpha(y'-\alpha y)=0$$

គេតាង $y'-\alpha y=Z$ នោះ $(y'-\alpha y)'=Z'$

គេបាន $Z'-\alpha Z=0$ (ជាសមីការឌីផេរ៉ង់ស្យែលលំដាប់១ អូម៉ូសែន)

$\frac{dZ}{dx}=\alpha Z$ ឬ $\frac{dZ}{Z}=\alpha dx$ (បំពាក់អាំងតេក្រាលលើអង្គទាំងពីរ)

$$\int\frac{dZ}{Z}=\int\alpha dx$$

$$\ln|Z|=\alpha x+c$$

$$|Z|=e^{\alpha x+c}$$

$$Z=\pm e^{c}\cdot e^{\alpha x}=Ae^{\alpha x} \quad , \quad A=\pm e^{c}$$

នាំឱ្យ $y'-\alpha y=Z$ ទៅជា $y'-\alpha y=Ae^{\alpha x}$ $(1)$ (ជាសមីការឌីផេរ៉ង់ស្យែលលំដាប់១ មិនអូម៉ូសែន)

គេនឹងដោះស្រាយសមីការ $y'-\alpha y=0$ រួចហើយធ្វើបម្រែបម្រួលចំនួនថេរ

គេបាន $\frac{dy}{dx}=ay$ ឬ $dy=aydx$ ឬ $\frac{dy}{y}=adx$ (បំពាក់អាំងតេក្រាលលើអង្គទាំងពីរ)

$$\int\frac{dy}{y}=\int\alpha dx$$

$$\ln|y|=\alpha x+c$$

$$|y|=e^{\alpha x+c}$$

$$y=\pm e^{c}\cdot e^{\alpha x}=c_1e^{\alpha x} \quad , \quad c_1=\pm e^{c}$$

គេធ្វើបម្រែបម្រួលចំនួនថេរ $c_1$ ទៅជា $c_1(x)$

គេមាន $y=c_1(x)e^{\alpha x}$ $(2)$ នោះ $y'=c_1'(x)e^{\alpha x}+(e^{\alpha x})'c_1(x)$

$$=c_1'(x)e^{\alpha x}+\alpha c_1(x)e^{\alpha x}$$

គេបាន $(1): \; c_1'(x)e^{\alpha x}+\alpha c_1(x)e^{\alpha x}-\alpha c_1(x)e^{\alpha x}=Ae^{\alpha x}$

$$c_1'(x)e^{\alpha x}=Ae^{\alpha x}$$

$c_1'(x)=A$ (បំពាក់អាំងតេក្រាលលើអង្គទាំងពីរ)

នាំឱ្យ $\int c_1'(x)dx=\int Adx$ ឬ $c_1(x)=Ax+B$ ដែល $B$ ជាចំនួនថេរ

គេបាន $(2): \; y=(Ax+B)e^{\alpha x}=Axe^{\alpha x}+Be^{\alpha x}$ ដែល $A$ និង $B$ ជាចំនួនថេរណាមួយក៏បាន

ដូចនេះ: **សមីការ $y''+by'+cy=0$ មានចម្លើយទូទៅគឺ $y=Axe^{\alpha x}+Be^{\alpha x}$ ត្រូវបានស្រាយបញ្ជាក់** ។

**គ. ស្រាយបញ្ជាក់ថា សមីការ** $(E): y''+by'+cy=0$ **មានចម្លើយទូទៅគឺ** $y=(C\cos\beta x+D\sin\beta x)e^{\alpha x}$

គេមាន $(E): y''+by'+cy=0$ មានសមីការសម្គាល់ $\lambda^2+by+c=0$

តាមវិធីដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី២ សមីការសម្គាល់មានឫសពីរផ្សេងគ្នា $\lambda_1$ , $\lambda_2$ នោះគេបានចម្លើយទូទៅ

នៃសមីការ $(E)$ គឺ : $y=Ae^{\lambda_1 x}+Be^{\lambda_2 x}$ ដែល $A$ និង $B$ ជាចំនួនថេរណាមួយក៏បាន

គេជំនួស $\lambda_1=\alpha-i\beta$ និង $\lambda_2=\alpha+i\beta$

គេបាន $y=Ae^{(\alpha-i\beta)x}+Be^{(\alpha+i\beta)x}$

$=Ae^{\alpha x}\cdot e^{-i\beta x}+Be^{\alpha x}\cdot e^{i\beta x}$

$=\left(Ae^{-i\beta x}+Be^{i\beta x}\right)e^{\alpha x}$

តាមរូបមន្ត *Euler* : $e^{ix}=\cos x+i\sin x$ នោះ $e^{i\beta x}=\cos\beta x+i\sin\beta x$

$e^{-ix}=\cos x-i\sin x$ នោះ $e^{-i\beta x}=\cos\beta x-i\sin\beta x$

នាំឱ្យ $y=\left[A(\cos\beta x-i\sin\beta x)+B(\cos\beta x+i\sin\beta x)\right]e^{\alpha x}$

$=\left[A\cos\beta x-iA\sin\beta x+B\cos\beta x+iB\sin\beta x\right]e^{\alpha x}$

$=\left[A\cos\beta x+B\cos\beta x+iB\sin\beta x-iA\sin\beta x\right]e^{\alpha x}$

$=\left[(A+B)\cos\beta x+i(B-A)\sin\beta x\right]e^{\alpha x}$

$=(C\cos\beta x+D\sin\beta x)e^{\alpha x}$

ដែលគេតាង $C=A+B$ និង $D=i(B-A)$ ឬ $C$ និង $D$ ជាចំនួនថេរណាមួយក៏បាន

ដូចនេះ | សមីការ $y''+by'+cy=0$ មានចម្លើយទូទៅគឺ $y=(C\cos\beta x+D\sin\beta x)e^{\alpha x}$ ត្រូវបានស្រាយបញ្ជាក់ | ។

# ការស្រាយបញ្ជាក់លើមេរៀន ធរណីមាត្រក្នុងលំហ

1. ស្រាយបញ្ជាក់លក្ខណៈផលគុណនៃពីរវ៉ិចទ័រ ដូចខាងក្រោម ៖

បើ $\vec{u}$ , $\vec{v}$ និង $\vec{w}$ ជាវ៉ិចទ័រនៅក្នុងលំហ និង $c$ ជាចំនួនពិត នោះគេបាន ៖

ក. $\vec{u}\times\vec{v}=-(\vec{v}\times\vec{u})$

ខ. $\vec{u}\times(\vec{v}+\vec{w})=(\vec{u}\times\vec{v})+(\vec{u}\times\vec{w})$

គ. $c(\vec{u}\times\vec{v})=(c\vec{u})\times\vec{v}=\vec{u}\times(c\vec{v})$

ឃ. $\vec{u}\times\vec{O}=\vec{O}\times\vec{u}=\vec{O}$

ង. $\vec{u}\times\vec{u}=\vec{O}$

ច. $\vec{u}\cdot(\vec{v}\times\vec{w})=(\vec{u}\times\vec{v})\cdot\vec{w}$

2. បើ $\vec{u}$ និង $\vec{v}$ ជាវ៉ិចទ័រមិនសូន្យ នៅក្នុងលំហ និង $\theta$ ជាមុំផ្គុំរវាង $\vec{u}$ និង $\vec{v}$ នោះគេបាន ៖

ក. $\vec{u}\times\vec{v}$ អរតូកូណាល់ទៅនឹង $\vec{u}$ ផង និង អរតូកូណាល់ទៅនឹង $\vec{v}$ ផង ។

ខ. $|\vec{u}\times\vec{v}|=|\vec{u}|\cdot|\vec{v}|\cdot\sin\theta$

គ. បើ $\vec{u}\times\vec{v}=\vec{0}$ នោះ $\vec{u}$ និង $\vec{v}$ ជាវ៉ិចទ័រកូលីនេអ៊ែនឹងគ្នា ។

ឃ. $|\vec{u}\times\vec{v}|=$ ផ្ទៃក្រឡារបស់ប្រលេឡូក្រាម ដែលសង់លើវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ។

ង. $\frac{1}{2}|\vec{u}\times\vec{v}|=$ ផ្ទៃក្រឡារបស់ត្រីកោណ ដែលសង់លើវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ។

3. ស្រាយបញ្ជាក់ថា បើប្រលេឡូក្រាមសង់វ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ហើយមុំ $\theta$ ជាមុំផ្គុំរវាង $\vec{u}$ និង $\vec{v}$ នោះគេបាន ៖

ក. កម្ពស់នៃប្រលេឡូក្រាម ស្មើ $|\vec{v}|\cdot\sin\theta$ ។

ខ. ផ្ទៃក្រឡាប្រលេឡូក្រាម $S=|\vec{u}||\vec{v}|\sin\theta=|\vec{u}\times\vec{v}|$ ។

4. ស្រាយបញ្ជាក់ថា ចំពោះវ៉ិចទ័រឯកតា $\vec{i}$ , $\vec{j}$ និង $\vec{k}$ គេបាន ៖

ក. $\vec{k}=\vec{i}\times\vec{j}$ ខ. $\vec{i}=\vec{j}\times\vec{k}$ គ. $\vec{j}=\vec{k}\times\vec{i}$ ។

5. ស្រាយបញ្ជាក់ថា បើគេមានបីវ៉ិចទ័រ $\vec{u}=u_1\vec{i}+u_2\vec{j}+u_3\vec{k}$ , $\vec{v}=v_1\vec{i}+v_2\vec{j}+v_3\vec{k}$ និង $\vec{w}=w_1\vec{i}+w_2\vec{j}+w_3\vec{k}$ នោះគេបាន ៖

$$\vec{u}\cdot(\vec{v}\times\vec{w})=\begin{vmatrix}u_1 & u_2 & u_3\\ v_1 & v_2 & v_3\\ w_1 & w_2 & w_3\end{vmatrix}$$ ។

6. ស្រាយបញ្ជាក់ថា មាឌ $V$ របស់ប្រលេពីប៉ែតដែលសង់លើវ៉ិចទ័រ $\vec{u}$ , $\vec{v}$ និង $\vec{w}$ គឺ ៖ $V=|\vec{u}\cdot(\vec{v}\times\vec{w})|$ និង មាឌ $W$ របស់តេត្រាអ៊ែតគឺ $W=\frac{1}{6}|\vec{u}\cdot(\vec{v}\times\vec{w})|$ បានន័យថា យកមាឌរបស់ប្រលេពីប៉ែតចែកនឹង 6 ។

7. ស្រាយបញ្ជាក់ថា សមីការបន្ទាត់ក្នុងលំហ កាត់តាមចំណុច $P(x_0 , y_0 , z_0)$ និងមានវ៉ិចទ័រប្រាប់ទិស $\vec{u}=(a , b , c)$ មានសមីការប៉ារ៉ាម៉ែត្រ $\begin{cases}x=x_0+at\\ y=y_0+bt\\ z=z_0+ct\end{cases}$ , $t\in\mathbb{R}$ រួចទាញបញ្ជាក់ថា $\frac{x-x_0}{a}=\frac{y-y_0}{b}=\frac{z-z_0}{c}$ ដែលគេហៅថា សមីការឆ្លុះ ។

8. ស្រាយបញ្ជាក់ថា បើប្លង់មួយកាត់តាមចំណុច $P(x_0\ ,\ y_0\ ,\ z_0)$ និងមានវ៉ិចទ័រណរម៉ាល់ $\vec{n}=(a\ ,\ b\ ,\ c)$ នោះប្លង់នោះមានសមីការស្តង់ដា $a(x-x_0)+b(y-y_0)+c(z-z_0)=0$ ។

9. ស្រាយបញ្ជាក់ថា សមីការទូទៅនៃប្លង់គឺ $ax+by+cz+d=0$ បានពីពន្លាតសមីការស្តង់ដា $a(x-x_0)+b(y-y_0)+c(z-z_0)=0$ ដែល $d=-(ax_0+by_0+cz_0)$ ។

10. ស្រាយបញ្ជាក់ថា បើមុំ $\theta$ ជាមុំផ្គុំរវាងប្លង់ពីរ $\alpha_1$ និង $\alpha_2$ ដែលមាន $\vec{n}_1$ និង $\vec{n}_2$ ជាវ៉ិចទ័រណរម៉ាល់រៀងគ្នា នោះគេបាន $\cos\theta=\dfrac{|\vec{n}_1\cdot\vec{n}_2|}{|\vec{n}_1||\vec{n}_2|}$ ។

11. ស្រាយបញ្ជាក់ថា បើប្លង់ពីរមានវ៉ិចទ័រណរម៉ាល់រៀងគ្នា $\vec{n}_1$ និង $\vec{n}_2$ នោះគេបាន ៖

ក. ប្លង់ទាំងពីរកែងគ្នា បើ $\vec{n}_1\cdot\vec{n}_2=0$ ។

ខ. ប្លង់ទាំងពីរស្របគ្នា បើ $\vec{n}_1=k\vec{n}_2$ ដែល $k$ ជាចំនួនថេរខុសពីសូន្យ ។

12. ស្រាយបញ្ជាក់ថា បើគេមានពីរចំណុច $P(x_1\ ,\ y_1\ ,\ z_1)$ និង $Q(x_2\ ,\ y_2\ ,\ z_2)$ ក្នុងលំហ នោះគេបានចម្ងាយពីរចំណុចនេះកំណត់ដោយ $d=PQ=\sqrt{(x_2-x_1)^2+(y_2-y_1)^2+(z_2-z_1)^2}$ ។

13. ស្រាយបញ្ជាក់ថា សមីការស្វ៊ែដែលមានផ្ចិត $C(x_0\ ,\ y_0\ ,\ z_0)$ និងមានកាំ $r$ កំណត់ដោយ $(x-x_0)^2+(y-y_0)^2+(z-z_0)^2=r^2$ ។

14. ស្រាយបញ្ជាក់ថា សមីការទូទៅនៃស្វ៊ែ $x^2+y^2+z^2-2x_0x-2y_0y-2z_0z+k=0$ ដែល $k=x_0^2+y_0^2+z_0^2-r^2$ ជាសមីការទូទៅបានពីពន្លាតសមីការស្តង់ដា $(x-x_0)^2+(y-y_0)^2+(z-z_0)^2=r^2$ ។

15. ស្រាយបញ្ជាក់ថា ចម្ងាយពីចំណុច $Q$ ទៅប្លង់ $\alpha$ ដែលចំណុច $Q$ មិននៅក្នុងប្លង់ $\alpha$ កំណត់ដោយ $D=\dfrac{|\overrightarrow{PQ}\cdot\vec{n}|}{\vec{n}}$ ដែល $P$ ជាចំណុចនៅក្នុងប្លង់ និង $\vec{n}$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ ។

16. ស្រាយបញ្ជាក់ថា ចម្ងាយពីចំណុច $Q(x_0\ ,\ y_0\ ,\ z_0)$ ទៅប្លង់ $\alpha :\ ax+by+cz+d=0$ កំណត់ដោយ $D=\dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$ ។

17. ស្រាយបញ្ជាក់ថា ចម្ងាយពីចំណុច $Q$ ទៅបន្ទាត់ $L$ ក្នុងលំហ កំណត់ដោយ $D=\dfrac{|\overrightarrow{PQ}\times\vec{u}|}{|\vec{u}|}$ ដែល $\vec{u}$ ជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $L$ និង $P$ ជាចំណុចមួយនៅលើបន្ទាត់ $L$ ។

18. ស្រាយបញ្ជាក់ថា ចម្ងាយពីបន្ទាត់ $L_1$ ទៅបន្ទាត់ $L_2$ កំណត់ដោយ $d(L_1\ ,\ L_2)=\dfrac{|\overrightarrow{M_1M_2}\cdot(\vec{u}_1\times\vec{u}_2)|}{|\vec{u}_1\times\vec{u}_2|}$ ដែល $M_1\ ,\ M_2$ ជាចំណុចនៅលើបន្ទាត់ $L_1\ ,\ L_2$ រៀងគ្នា ហើយ $\vec{u}_1\ ,\ \vec{u}_2$ ជាវ៉ិចទ័រប្រាប់ទិសរៀងគ្នានៃបន្ទាត់ $L_1\ ,\ L_2$ ។

# ការស្រាយបញ្ជាក់លើមេរៀន ធរណីមាត្រក្នុងលំហ

1. ស្រាយបញ្ជាក់លក្ខណៈផលគុណនៃពីរវ៉ិចទ័រ ដូចខាងក្រោម ៖

បើ $\vec{u}$ , $\vec{v}$ និង $\vec{w}$ ជាវ៉ិចទ័រនៅក្នុងលំហ និង $c$ ជាចំនួនពិត នោះគេបាន ៖

ក. ស្រាយបញ្ជាក់លក្ខណៈ $\vec{u}\times\vec{v}=-(\vec{v}\times\vec{u})$

គេតាង $\vec{u}=(u_1\,,u_2\,,u_3)$ និង $\vec{v}=(v_1\,,v_2\,,v_3)$

គេបាន $$\vec{v}\times\vec{u}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ v_1 & v_2 & v_3\\ u_1 & u_2 & u_3\end{vmatrix}=(u_3v_2-u_2v_3)\vec{i}-(u_3v_1-u_1v_3)\vec{j}+(u_2v_1-u_1v_2)\vec{k}$$

ហើយ $$\vec{u}\times\vec{v}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ u_1 & u_2 & u_3\\ v_1 & v_2 & v_3\end{vmatrix}=(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}$$

$$=-(u_3v_2-u_2v_3)\vec{i}+(u_3v_1-u_1v_3)\vec{j}-(u_2v_1-u_1v_2)\vec{k}$$

$$=-\left[(u_3v_2-u_2v_3)\vec{i}-(u_3v_1-u_1v_3)\vec{j}+(u_2v_1-u_1v_2)\vec{k}\right]$$

$$=-(\vec{v}\times\vec{u})$$

ដូចនេះ **លក្ខណៈ $\vec{u}\times\vec{v}=-(\vec{v}\times\vec{u})$ ត្រូវបានស្រាយបញ្ជាក់** ។

ខ. ស្រាយបញ្ជាក់លក្ខណៈ $\vec{u}\times(\vec{v}+\vec{w})=(\vec{u}\times\vec{v})+(\vec{u}\times\vec{w})$

គេតាង $\vec{u}=(u_1\,,u_2\,,u_3)$ , $\vec{v}=(v_1\,,v_2\,,v_3)$ និង $\vec{w}=(w_1\,,w_2\,,w_3)$

នាំឱ្យ $\vec{v}+\vec{w}=(v_1+w_1\,,v_2+w_2\,,v_3+w_3)$

គេបាន $$\vec{u}\times\vec{v}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ u_1 & u_2 & u_3\\ v_1 & v_2 & v_3\end{vmatrix}=(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}$$

ហើយ $$\vec{u}\times\vec{w}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ u_1 & u_2 & u_3\\ w_1 & w_2 & w_3\end{vmatrix}=(u_2w_3-u_3w_2)\vec{i}-(u_1w_3-u_3w_1)\vec{j}+(u_1w_2-u_2w_1)\vec{k}$$

គេបាន

$\vec{u}\times(\vec{v}+\vec{w})$

$$=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ u_1 & u_2 & u_3\\ v_1+w_1 & v_2+w_2 & v_3+w_3\end{vmatrix}$$

$=\left[u_2(v_3+w_3)-u_3(v_2+w_2)\right]\vec{i}-\left[u_1(v_3+w_3)-u_3(v_1+w_1)\right]\vec{j}+\left[u_1(v_2+w_2)-u_2(v_1+w_1)\right]\vec{k}$

$=\left[u_2v_3+u_2w_3-u_3v_2-u_3w_2\right]\vec{i}-\left[u_1v_3+u_1w_3-u_3v_1-u_3w_1\right]\vec{j}+\left[u_1v_2+u_1w_2-u_2v_1-u_2w_1\right]\vec{k}$

$=\left[(u_2v_3-u_3v_2)+(u_2w_3-u_3w_2)\right]\vec{i}-\left[(u_1v_3-u_3v_1)+(u_1w_3-u_3w_1)\right]\vec{j}+\left[(u_1v_2-u_2v_1)+(u_1w_2-u_2w_1)\right]\vec{k}$

$=(u_2v_3-u_3v_2)\vec{i}+(u_2w_3-u_3w_2)\vec{i}-(u_1v_3-u_3v_1)\vec{j}-(u_1w_3-u_3w_1)\vec{j}+(u_1v_2-u_2v_1)\vec{k}+(u_1w_2-u_2w_1)\vec{k}$

$=\left[(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}\right]+\left[(u_2w_3-u_3w_2)\vec{i}-(u_1w_3-u_3w_1)\vec{j}+(u_1w_2-u_2w_1)\vec{k}\right]$

$=(\vec{u}\times\vec{v})+(\vec{u}\times\vec{w})$

ដូចនេះ  **លក្ខណៈ $\vec{u}\times(\vec{v}+\vec{w})=(\vec{u}\times\vec{v})+(\vec{u}\times\vec{w})$ ត្រូវបានស្រាយបញ្ជាក់** ។

**គ. ស្រាយបញ្ជាក់លក្ខណៈ: $c(\vec{u}\times\vec{v})=(c\vec{u})\times\vec{v}=\vec{u}\times(c\vec{v})$**

គេតាង $\vec{u}=(u_1,u_2,u_3)$ និង $\vec{v}=(v_1,v_2,v_3)$

នាំឱ្យ $c\vec{u}=(cu_1,cu_2,cu_3)$ និង $c\vec{v}=(cv_1,cv_2,cv_3)$

គេបាន $\vec{u}\times\vec{v}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ u_1 & u_2 & u_3\\ v_1 & v_2 & v_3\end{vmatrix}=(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}$

នោះ $c(\vec{u}\times\vec{v})=c\left[(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}\right]$

$=c(u_2v_3-u_3v_2)\vec{i}-c(u_1v_3-u_3v_1)\vec{j}+c(u_1v_2-u_2v_1)\vec{k}$

$=(cu_2v_3-cu_3v_2)\vec{i}-(cu_1v_3-cu_3v_1)\vec{j}+(cu_1v_2-cu_2v_1)\vec{k}\quad(1)$

ហើយ $(c\vec{u})\times\vec{v}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ cu_1 & cu_2 & cu_3\\ v_1 & v_2 & v_3\end{vmatrix}=(cu_2v_3-cu_3v_2)\vec{i}-(cu_1v_3-cu_3v_1)\vec{j}+(cu_1v_2-cu_2v_1)\vec{k}\quad(2)$

$\vec{u}\times(c\vec{v})=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ u_1 & u_2 & u_3\\ cv_1 & cv_2 & cv_3\end{vmatrix}=(cu_2v_3-cu_3v_2)\vec{i}-(cu_1v_3-cu_3v_1)\vec{j}+(cu_1v_2-cu_2v_1)\vec{k}\quad(3)$

តាមរយៈ ទំនាក់ទំនង $(1),(2)$ និង $(3)$ គេបាន $c(\vec{u}\times\vec{v})=(c\vec{u})\times\vec{v}=\vec{u}\times(c\vec{v})$

ដូចនេះ  **លក្ខណៈ $c(\vec{u}\times\vec{v})=(c\vec{u})\times\vec{v}=\vec{u}\times(c\vec{v})$ ត្រូវបានស្រាយបញ្ជាក់** ។

**ឃ. ស្រាយបញ្ជាក់លក្ខណៈ** $\vec{u}\times\vec{O}=\vec{O}\times\vec{u}=\vec{O}$

គេតាង $\vec{u}=(u_1,u_2,u_3)$ និង $\vec{O}=(0,0,0)$

គេបាន $$\vec{u}\times\vec{O}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\u_1&u_2&u_3\\0&0&0\end{vmatrix}=(u_2\cdot 0-u_3\cdot 0)\vec{i}-(u_1\cdot 0-u_3\cdot 0)\vec{j}+(u_1\cdot 0-u_2\cdot 0)\vec{k}=0\vec{i}+0\vec{j}+0\vec{k}=\vec{O}\quad(1)$$

$$\vec{O}\times\vec{u}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\0&0&0\\u_1&u_2&u_3\end{vmatrix}=(0\cdot u_3-u_2\cdot 0)\vec{i}-(0\cdot u_3-u_1\cdot 0)\vec{j}+(0\cdot u_2-u_1\cdot 0)\vec{k}=0\vec{i}+0\vec{j}+0\vec{k}=\vec{O}\quad(2)$$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ គេបាន $\vec{u}\times\vec{O}=\vec{O}\times\vec{u}=\vec{O}$

ដូចនេះ | លក្ខណៈ $\vec{u}\times\vec{O}=\vec{O}\times\vec{u}=\vec{O}$ ត្រូវបានស្រាយបញ្ជាក់ | ។

**ង. ស្រាយបញ្ជាក់លក្ខណៈ** $\vec{u}\times\vec{u}=\vec{O}$

គេតាង $\vec{u}=(u_1,u_2,u_3)$

គេបាន $$\vec{u}\times\vec{u}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\u_1&u_2&u_3\\u_1&u_2&u_3\end{vmatrix}=(u_2u_3-u_2u_3)\vec{i}-(u_1u_3-u_1u_3)\vec{j}+(u_1u_2-u_1u_2)\vec{k}=0\vec{i}+0\vec{j}+0\vec{k}=\vec{O}$$

ដូចនេះ | លក្ខណៈ $\vec{u}\times\vec{u}=\vec{O}$ ត្រូវបានស្រាយបញ្ជាក់ | ។

**ច. ស្រាយបញ្ជាក់លក្ខណៈ** $\vec{u}\cdot(\vec{v}\times\vec{w})=(\vec{u}\times\vec{v})\cdot\vec{w}$

គេតាង $\vec{u}=(u_1,u_2,u_3)$ , $\vec{v}=(v_1,v_2,v_3)$ និង $\vec{w}=(w_1,w_2,w_3)$

គេបាន $$\vec{v}\times\vec{w}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\v_1&v_2&v_3\\w_1&w_2&w_3\end{vmatrix}=(v_2w_3-v_3w_2)\vec{i}-(v_1w_3-v_3w_1)\vec{j}+(v_1w_2-v_2w_1)\vec{k}$$

នាំឱ្យ $$\begin{aligned}\vec{u}\cdot(\vec{v}\times\vec{w})&=u_1(v_2w_3-v_3w_2)-u_2(v_1w_3-v_3w_1)+u_3(v_1w_2-v_2w_1)\\&=u_1v_2w_3-u_1v_3w_2-u_2v_1w_3+u_2v_3w_1+u_3v_1w_2-u_3v_2w_1\\&=u_1v_2w_3+u_2v_3w_1+u_3v_1w_2-u_1v_3w_2-u_2v_1w_3-u_3v_2w_1\quad(1)\end{aligned}$$

ហើយ $$\vec{u}\times\vec{v}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\u_1&u_2&u_3\\v_1&v_2&v_3\end{vmatrix}=(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}$$

នាំឱ្យ $$\begin{aligned}(\vec{u}\times\vec{v})\cdot\vec{w}&=(u_2v_3-u_3v_2)w_1-(u_1v_3-u_3v_1)w_2+(u_1v_2-u_2v_1)w_3\\&=u_2v_3w_1-u_3v_2w_1-u_1v_3w_2+u_3v_1w_2+u_1v_2w_3-u_2v_1w_3\\&=u_1v_2w_3+u_2v_3w_1+u_3v_1w_2-u_1v_3w_2-u_2v_1w_3-u_3v_2w_1\quad(2)\end{aligned}$$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ គេបាន $\vec{u}\cdot(\vec{v}\times\vec{w})=(\vec{u}\times\vec{v})\cdot\vec{w}$

ដូចនេះ | លក្ខណៈ $\vec{u}\cdot(\vec{v}\times\vec{w})=(\vec{u}\times\vec{v})\cdot\vec{w}$ ត្រូវបានស្រាយបញ្ជាក់ | ។

2. បើ $\vec{u}$ និង $\vec{v}$ ជាវ៉ិចទ័រមិនសូន្យ នៅក្នុងលំហ និង $\theta$ ជាមុំផ្គុំរវាង $\vec{u}$ និង $\vec{v}$ នោះគេបាន ៖

ក. -ស្រាយបញ្ជាក់ថា $\vec{u}\times\vec{v}$ អរត្តូកូណាល់ទៅនឹង $\vec{u}$

គេតាង $\vec{u}=(u_1\ ,u_2\ ,u_3)$ និង $\vec{v}=(v_1\ ,v_2\ ,v_3)$

ដោយ $(\vec{u}\times\vec{v})\perp\vec{u} \Leftrightarrow (\vec{u}\times\vec{v})\cdot\vec{u}=0$




គេបាន $$\vec{u}\times\vec{v}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ u_1 & u_2 & u_3\\ v_1 & v_2 & v_3\end{vmatrix}=(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}$$

នាំឱ្យ $$\begin{aligned}(\vec{u}\times\vec{v})\cdot\vec{u}&=(u_2v_3-u_3v_2)u_1-(u_1v_3-u_3v_1)u_2+(u_1v_2-u_2v_1)u_3\\&=(u_2v_3-u_3v_2)u_1-(u_1v_3-u_3v_1)u_2+(u_1v_2-u_2v_1)u_3\\&=u_1u_2v_3-u_1u_3v_2-u_1u_2v_3+u_2u_3v_1+u_1u_3v_2-u_2u_3v_1\\&=0\end{aligned}$$

ដូចនេះ: $\vec{u}\times\vec{v}$ អរត្តូកូណាល់ទៅនឹង $\vec{u}$ ត្រូវបានស្រាយបញ្ជាក់ ។

-ស្រាយបញ្ជាក់ថា $\vec{u}\times\vec{v}$ អរត្តូកូណាល់ទៅនឹង $\vec{v}$

គេតាង $\vec{u}=(u_1\ ,u_2\ ,u_3)$ និង $\vec{v}=(v_1\ ,v_2\ ,v_3)$

ដោយ $(\vec{u}\times\vec{v})\perp\vec{v} \Leftrightarrow (\vec{u}\times\vec{v})\cdot\vec{v}=0$




គេបាន $$\vec{u}\times\vec{v}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ u_1 & u_2 & u_3\\ v_1 & v_2 & v_3\end{vmatrix}=(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}$$

នាំឱ្យ $$\begin{aligned}(\vec{u}\times\vec{v})\cdot\vec{v}&=(u_2v_3-u_3v_2)v_1-(u_1v_3-u_3v_1)v_2+(u_1v_2-u_2v_1)v_3\\&=(u_2v_3-u_3v_2)v_1-(u_1v_3-u_3v_1)v_2+(u_1v_2-u_2v_1)v_3\\&=u_2v_1v_3-u_3v_1v_2-u_1v_2v_3+u_3v_1v_2+u_1v_2v_3-u_2v_1v_3\\&=0\end{aligned}$$

ដូចនេះ: $\vec{u}\times\vec{v}$ អរត្តូកូណាល់ទៅនឹង $\vec{v}$ ត្រូវបានស្រាយបញ្ជាក់ ។

ខ. ស្រាយបញ្ជាក់ថា $|\vec{u}\times\vec{v}|=|\vec{u}|\cdot|\vec{v}|\cdot\sin\theta$

គេតាង $\vec{u}=(u_1\ ,u_2\ ,u_3)$ និង $\vec{v}=(v_1\ ,v_2\ ,v_3)$




គេបាន $$\vec{u}\times\vec{v}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ u_1 & u_2 & u_3\\ v_1 & v_2 & v_3\end{vmatrix}=(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}$$

នាំឱ្យ $$\begin{aligned}|\vec{u}\times\vec{v}|&=\sqrt{(u_2v_3-u_3v_2)^2+\left[-(u_1v_3-u_3v_1)\right]^2+(u_1v_2-u_2v_1)^2}\\&=\sqrt{(u_2v_3-u_3v_2)^2+(u_1v_3-u_3v_1)^2+(u_1v_2-u_2v_1)^2}\end{aligned}$$

ម្យ៉ាងទៀត $\sin^2\theta+\cos^2\theta=1$ នោះ $\sin\theta=\sqrt{1-\cos^2\theta}$ ព្រោះ $0<\theta<\pi$

នាំឱ្យ $\sin\theta=\sqrt{1-\left(\dfrac{\vec{u}\cdot\vec{v}}{|\vec{u}||\vec{v}|}\right)^2}$ (ព្រោះ $\cos\theta=\dfrac{\vec{u}\cdot\vec{v}}{|\vec{u}||\vec{v}|}$ ដោយសារនិយមន័យ $\vec{u}\cdot\vec{v}=|\vec{u}||\vec{v}|\cos\theta$)

$$=\sqrt{\frac{|\vec{u}|^2|\vec{v}|^2-(\vec{u}\cdot\vec{v})^2}{|\vec{u}|^2|\vec{v}|^2}}=\frac{1}{|\vec{u}||\vec{v}|}\sqrt{|\vec{u}|^2|\vec{v}|^2-(\vec{u}\cdot\vec{v})^2}$$

គេបាន $|\vec{u}|\cdot|\vec{v}|\cdot\sin\theta=|\vec{u}||\vec{v}|\cdot\dfrac{1}{|\vec{u}||\vec{v}|}\sqrt{|\vec{u}|^2|\vec{v}|^2-(\vec{u}\cdot\vec{v})^2}=\sqrt{|\vec{u}|^2|\vec{v}|^2-(\vec{u}\cdot\vec{v})^2}$

ដោយ $|\vec{u}|=\sqrt{u_1^2+u_2^2+u_3^2}$ នោះ $|\vec{u}|^2=u_1^2+u_2^2+u_3^2$

$|\vec{v}|=\sqrt{v_1^2+v_2^2+v_3^2}$ នោះ $|\vec{v}|^2=v_1^2+v_2^2+v_3^2$

$\vec{u}\cdot\vec{v}=u_1v_1+u_2v_2+u_3v_3$

នាំឱ្យ

$$|\vec{u}|\cdot|\vec{v}|\cdot\sin\theta$$
$$=\sqrt{\left(u_1^2+u_2^2+u_3^2\right)\left(v_1^2+v_2^2+v_3^2\right)-\left(u_1v_1+u_2v_2+u_3v_3\right)^2}$$
$$=\sqrt{u_1^2v_1^2+u_1^2v_2^2+u_1^2v_3^2+u_2^2v_1^2+u_2^2v_2^2+u_2^2v_3^2+u_3^2v_1^2+u_3^2v_2^2+u_3^2v_3^2-\left(u_1^2v_1^2+u_2^2v_2^2+u_3^2v_3^2+2u_1v_1u_2v_2+2u_1v_1u_3v_3+2u_2v_2u_3v_3\right)}$$
$$=\sqrt{u_1^2v_2^2+u_1^2v_3^2+u_2^2v_1^2+u_2^2v_3^2+u_3^2v_1^2+u_3^2v_2^2-2u_1v_1u_2v_2-2u_1v_1u_3v_3-2u_2v_2u_3v_3}$$
$$=\sqrt{\left(u_2^2v_3^2-2u_2v_2u_3v_3+u_3^2v_2^2\right)+\left(u_1^2v_3^2-2u_1v_1u_3v_3+u_3^2v_1^2\right)+\left(u_1^2v_2^2-2u_1v_1u_2v_2+u_2^2v_1^2\right)}$$
$$=\sqrt{\left(u_2v_3-u_3v_2\right)^2+\left(u_1v_3-u_3v_1\right)^2+\left(u_1v_2-u_2v_1\right)^2}$$
$$=|\vec{u}\times\vec{v}|$$

ដូចនេះ: $|\vec{u}\times\vec{v}|=|\vec{u}|\cdot|\vec{v}|\cdot\sin\theta$ ត្រូវបានស្រាយបញ្ជាក់ ។

**គ. ស្រាយបញ្ជាក់ថា បើ $\vec{u}\times\vec{v}=\vec{0}$ នោះ $\vec{u}$ និង $\vec{v}$ ជាវ៉ិចទ័រកូលីនេអ៊ែនឹងគ្នា**

គេតាង $\vec{u}=(u_1\ ,\ u_2\ ,\ u_3)$ និង $\vec{v}=(v_1\ ,\ v_2\ ,\ v_3)$ ដែល $\vec{u}\neq\vec{0}$ , $\vec{v}\neq\vec{0}$

គេបាន $\vec{u}\times\vec{v}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\u_1&u_2&u_3\\v_1&v_2&v_3\end{vmatrix}=(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}$

ដោយ $\vec{u}\times\vec{v}=\vec{0}$ នោះ $(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}=0\vec{i}-0\vec{j}+0\vec{k}$

ទាញបាន $\begin{cases}u_2v_3-u_3v_2=0\\u_1v_3-u_3v_1=0\\u_1v_2-u_2v_1=0\end{cases}\Leftrightarrow\begin{cases}u_2v_3=u_3v_2\\u_1v_3=u_3v_1\\u_1v_2=u_2v_1\end{cases}\Leftrightarrow\begin{cases}\dfrac{u_2}{v_2}=\dfrac{u_3}{v_3}\\\dfrac{u_1}{v_1}=\dfrac{u_3}{v_3}\\\dfrac{u_1}{v_1}=\dfrac{u_2}{v_2}\end{cases}\Rightarrow\dfrac{u_1}{v_1}=\dfrac{u_2}{v_2}=\dfrac{u_3}{v_3}$

តាមរយៈ ទំនាក់ទំនង $\dfrac{u_1}{v_1}=\dfrac{u_2}{v_2}=\dfrac{u_3}{v_3}$ បញ្ជាក់ថា $\vec{u}\parallel\vec{v}$

ដូចនេះ: បើ $\vec{u}\times\vec{v}=\vec{0}$ នោះ $\vec{u}$ និង $\vec{v}$ ជាវ៉ិចទ័រកូលីនេអ៊ែនឹងគ្នា ត្រូវបានស្រាយបញ្ជាក់ ។

**ឃ. ស្រាយបញ្ជាក់ថា $|\vec{u}\times\vec{v}|=$ ផ្ទៃក្រឡារបស់ប្រលេឡូក្រាម ដែលសង់លើវ៉ិចទ័រ $\vec{u}$ និង $\vec{v}$**




គេមាន ផ្ទៃក្រឡារបស់ប្រលេឡូក្រាម $=OA\times BH$

ដោយ $OA=|\vec{u}|$ និង $OB=|\vec{v}|$

ក្នុងត្រីកោណកែង $OHB$ មាន $BH=OB\cdot\sin\theta=|\vec{v}|\cdot\sin\theta$

នាំឱ្យ ផ្ទៃក្រឡារបស់ប្រលេឡូក្រាម $=|\vec{u}|\cdot|\vec{v}|\cdot\sin\theta=|\vec{u}\times\vec{v}|$

ព្រោះ $|\vec{u}|\cdot|\vec{v}|\cdot\sin\theta=|\vec{u}\times\vec{v}|$ (បានស្រាយរួចខាងលើ)

ដូចនេះ: $|\vec{u}\times\vec{v}|=$ ផ្ទៃក្រឡារបស់ប្រលេឡូក្រាម ត្រូវបានស្រាយបញ្ជាក់ ។

**ង. ស្រាយបញ្ជាក់ថា $\frac{1}{2}|\vec{u}\times\vec{v}|=$ ផ្ទៃក្រឡារបស់ត្រីកោណ ដែលសង់លើវ៉ិចទ័រ $\vec{u}$ និង $\vec{v}$**




គេមាន ផ្ទៃក្រឡារបស់ត្រីកោណ $=\frac{1}{2}\times OA\times BH$

ដោយ $OA\times BH=$ ផ្ទៃក្រឡារបស់ប្រលេឡូក្រាម $=|\vec{u}\times\vec{v}|$

នាំឱ្យ ផ្ទៃក្រឡារបស់ត្រីកោណ $=\frac{1}{2}|\vec{u}\times\vec{v}|$

ដូចនេះ: ផ្ទៃក្រឡារបស់ត្រីកោណ $=\frac{1}{2}|\vec{u}\times\vec{v}|$ ត្រូវបានស្រាយបញ្ជាក់ ។

3. **ស្រាយបញ្ជាក់ថា បើប្រលេឡូក្រាមសង់វ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ហើយមុំ $\theta$ ជាមុំផ្គុំរវាង $\vec{u}$ និង $\vec{v}$ នោះគេបាន ៖**

**ក. កម្ពស់នៃប្រលេឡូក្រាម ស្មើ $|\vec{v}|\cdot\sin\theta$**




ក្នុងប្រលេឡូក្រាម មាន $BH$ ជាកម្ពស់

ក្នុងត្រីកោណកែង $OHB$ មាន $\sin\theta=\frac{BH}{OB}$ នោះ $BH=OB\cdot\sin\theta$

ដោយ $OB=|\vec{v}|$

នាំឱ្យ កម្ពស់ប្រលេឡូក្រាម $BH=|\vec{v}|\cdot\sin\theta$

ដូចនេះ: កម្ពស់នៃប្រលេឡូក្រាម ស្មើ $|\vec{v}|\cdot\sin\theta$ ត្រូវបានស្រាយបញ្ជាក់ ។

**ខ. ផ្ទៃក្រឡាប្រលេឡូក្រាម $S=|\vec{u}||\vec{v}|\sin\theta=|\vec{u}\times\vec{v}|$**




គេមាន ផ្ទៃក្រឡារបស់ប្រលេឡូក្រាម $S=OA\times BH$

ដោយ $OA=|\vec{u}|$ និង $BH=|\vec{v}|\cdot\sin\theta$

នាំឱ្យ ផ្ទៃក្រឡារបស់ប្រលេឡូក្រាម $S=|\vec{u}||\vec{v}|\sin\theta$

តែ $|\vec{u}\times\vec{v}|=|\vec{u}||\vec{v}|\sin\theta$

នោះ ផ្ទៃក្រឡារបស់ប្រលេឡូក្រាម $S=|\vec{u}||\vec{v}|\sin\theta=|\vec{u}\times\vec{v}|$

ដូចនេះ: ផ្ទៃក្រឡារបស់ប្រលេឡូក្រាម $S=|\vec{u}||\vec{v}|\sin\theta=|\vec{u}\times\vec{v}|$ ត្រូវបានស្រាយបញ្ជាក់ ។

4. ចំពោះវ៉ិចទ័រឯកតា $\vec{i}$ , $\vec{j}$ និង $\vec{k}$ គេបាន ៖

ក. ស្រាយបញ្ជាក់ថា $\vec{k}=\vec{i}\times\vec{j}$

➢របៀបទី១

គេមាន $\vec{i}\times\vec{j}=|\vec{i}||\vec{j}|\sin\theta\cdot\vec{k}$

ដោយ $\vec{i}$ , $\vec{j}$ និង $\vec{k}$ ជាវ៉ិចទ័រឯកតា ហើយកែងរៀងគ្នាទាំងបី

នាំឱ្យ $|\vec{i}|=1$ , $|\vec{j}|=1$ និង $\theta=90°$

គេបាន $\vec{i}\times\vec{j}=1\cdot1\sin 90°\cdot\vec{k}=\vec{k}$

ដូចនេះ $\vec{k}=\vec{i}\times\vec{j}$ ត្រូវបានស្រាយបញ្ជាក់ ។

➢របៀបទី២

គេមាន វ៉ិចទ័រឯកតា $\vec{i}=(1,0,0)$ , $\vec{j}=(0,1,0)$ និង $\vec{k}=(0,0,1)$

គេបាន $\vec{i}\times\vec{j}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & 0 & 0\\ 0 & 1 & 0\end{vmatrix}=(0-0)\vec{i}-(0-0)\vec{j}+(1-0)\vec{k}=\vec{k}$

ដូចនេះ $\vec{k}=\vec{i}\times\vec{j}$ ត្រូវបានស្រាយបញ្ជាក់ ។

ខ. ស្រាយបញ្ជាក់ថា $\vec{i}=\vec{j}\times\vec{k}$

➢របៀបទី១

គេមាន $\vec{j}\times\vec{k}=|\vec{j}||\vec{k}|\sin\theta\cdot\vec{i}$

ដោយ $\vec{i}$ , $\vec{j}$ និង $\vec{k}$ ជាវ៉ិចទ័រឯកតា ហើយកែងរៀងគ្នាទាំងបី

នាំឱ្យ $|\vec{j}|=1$ , $|\vec{k}|=1$ និង $\theta=90°$

គេបាន $\vec{j}\times\vec{k}=1\cdot1\cdot\sin 90°\cdot\vec{i}=\vec{i}$

ដូចនេះ $\vec{i}=\vec{j}\times\vec{k}$ ត្រូវបានស្រាយបញ្ជាក់ ។

➢របៀបទី២

គេមាន វ៉ិចទ័រឯកតា $\vec{i}=(1,0,0)$ , $\vec{j}=(0,1,0)$ និង $\vec{k}=(0,0,1)$

គេបាន $\vec{j}\times\vec{k}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 0 & 1 & 0\\ 0 & 0 & 1\end{vmatrix}=(1-0)\vec{i}-(0-0)\vec{j}+(0-0)\vec{k}=\vec{i}$

ដូចនេះ $\vec{i}=\vec{j}\times\vec{k}$ ត្រូវបានស្រាយបញ្ជាក់ ។

គ. ស្រាយបញ្ជាក់ថា $\vec{j}=\vec{k}\times\vec{i}$

➤របៀបទី១

គេមាន $\vec{k}\times\vec{i}=|\vec{k}||\vec{i}|\sin\theta\cdot\vec{j}$

ដោយ $\vec{i}$ , $\vec{j}$ និង $\vec{k}$ ជាវ៉ិចទ័រឯកតា ហើយកែងរៀងគ្នាទាំងបី

នាំឱ្យ $|\vec{k}|=1$ , $|\vec{i}|=1$ និង $\theta=90°$

គេបាន $\vec{k}\times\vec{i}=1\cdot1\cdot\sin 90°\cdot\vec{j}=\vec{j}$

ដូចនេះ $\vec{j}=\vec{k}\times\vec{i}$ ត្រូវបានស្រាយបញ្ជាក់ ។

➤របៀបទី២

គេមាន វ៉ិចទ័រឯកតា $\vec{i}=(1,0,0)$ , $\vec{j}=(0,1,0)$ និង $\vec{k}=(0,0,1)$

គេបាន $\vec{k}\times\vec{i}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\0&0&1\\1&0&0\end{vmatrix}=(0-0)\vec{i}-(0-1)\vec{j}+(0-0)\vec{k}=\vec{j}$

ដូចនេះ $\vec{j}=\vec{k}\times\vec{i}$ ត្រូវបានស្រាយបញ្ជាក់ ។

5. **ស្រាយបញ្ជាក់ថា** $\vec{u}\cdot(\vec{v}\times\vec{w})=\begin{vmatrix}u_1&u_2&u_3\\v_1&v_2&v_3\\w_1&w_2&w_3\end{vmatrix}$

គេមាន $\vec{u}=u_1\vec{i}+u_2\vec{j}+u_3\vec{k}$ , $\vec{v}=v_1\vec{i}+v_2\vec{j}+v_3\vec{k}$ និង $\vec{w}=w_1\vec{i}+w_2\vec{j}+w_3\vec{k}$

គេបាន $\vec{v}\times\vec{w}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\v_1&v_2&v_3\\w_1&w_2&w_3\end{vmatrix}=(v_2w_3-v_3w_2)\vec{i}-(v_1w_3-v_3w_1)\vec{j}+(v_1w_2-v_2w_1)\vec{k}$

នាំឱ្យ $\vec{u}\cdot(\vec{v}\times\vec{w})=u_1(v_2w_3-v_3w_2)-u_2(v_1w_3-v_3w_1)+u_3(v_1w_2-v_2w_1)\quad(1)$

ម្យ៉ាងទៀត $\begin{vmatrix}u_1&u_2&u_3\\v_1&v_2&v_3\\w_1&w_2&w_3\end{vmatrix}=u_1(v_2w_3-v_3w_2)-u_2(v_1w_3-v_3w_1)+u_3(v_1w_2-v_2w_1)\quad(2)$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ គេបាន $\vec{u}\cdot(\vec{v}\times\vec{w})=\begin{vmatrix}u_1&u_2&u_3\\v_1&v_2&v_3\\w_1&w_2&w_3\end{vmatrix}$

ដូចនេះ $\vec{u}\cdot(\vec{v}\times\vec{w})=\begin{vmatrix}u_1&u_2&u_3\\v_1&v_2&v_3\\w_1&w_2&w_3\end{vmatrix}$ ត្រូវបានស្រាយបញ្ជាក់ ។ (គេហៅថា ផលគុណចម្រុះ)

6. ស្រាយបញ្ជាក់ថា មាឌប្រលេពីប៉ែត $V=\left|\vec{u}\cdot(\vec{v}\times\vec{w})\right|$




គេតាង $\theta$ ជាមុំផ្គុំរវាង $\vec{u}$ និង $h$ ($h$ ជាកម្ពស់ប្រលេពីប៉ែត)

គេមាន $V=$ ផ្ទៃបាត $\times$ កម្ពស់

$V=S\times h$

ដោយ ផ្ទៃប្រលេឡូក្រាម $S=\left|\vec{v}\times\vec{w}\right|$

កម្ពស់ $h=\left|\vec{u}\right|\cdot\cos\theta$ ដែល $0^\circ<\theta<90^\circ$

គេបាន $V=\left|\vec{v}\times\vec{w}\right|\cdot\left|\vec{u}\right|\cdot\cos\theta \quad (1)$

ម្យ៉ាងទៀត $\vec{u}\cdot(\vec{v}\times\vec{w})=\left|\vec{u}\right|\cdot\left|\vec{v}\times\vec{w}\right|\cdot\cos\theta \quad (2)$

តាមរយៈ ទំនាក់ទំនង $(1)$ និង $(2)$ គេបាន $V=\vec{u}\cdot(\vec{v}\times\vec{w})$

ក្នុងករណី $90^\circ<\theta<180^\circ$ នោះ $\cos\theta<0$ នាំឱ្យ $V=-\vec{u}\cdot(\vec{v}\times\vec{w})$

សរុបមក $V=\left|\vec{u}\cdot(\vec{v}\times\vec{w})\right|$

ដូចនេះ: | មាឌប្រលេពីប៉ែត $V=\left|\vec{u}\cdot(\vec{v}\times\vec{w})\right|$ ត្រូវបានស្រាយបញ្ជាក់ | ។

**ស្រាយបញ្ជាក់ថា មាឌតេត្រាអែត $W=\frac{1}{6}\left|\vec{u}\cdot(\vec{v}\times\vec{w})\right|$**




គេមាន មាឌតេត្រាអ៊ែត $=\frac{1}{3}\times$ ផ្ទៃបាត $\times$ កម្ពស់

$W=\frac{1}{3}\times S\times h$

ដោយ ផ្ទៃបាតជាត្រីកោណ $S=\frac{1}{2}\left|\vec{v}\times\vec{w}\right|$

កម្ពស់ $h=\left|\vec{u}\right|\cdot\cos\theta$ ដែល $0^\circ<\theta<90^\circ$

គេបាន $W=\frac{1}{3}\cdot\frac{1}{2}\left|\vec{v}\times\vec{w}\right|\cdot\left|\vec{u}\right|\cdot\cos\theta$

$=\frac{1}{6}\left|\vec{v}\times\vec{w}\right|\cdot\left|\vec{u}\right|\cdot\cos\theta$

$=\frac{1}{6}\left[\vec{u}\cdot(\vec{v}\times\vec{w})\right]$

ក្នុងករណី $90^\circ<\theta<180^\circ$ នោះ $\cos\theta<0$ នាំឱ្យ $W=\frac{1}{6}\left[-\vec{u}\cdot(\vec{v}\times\vec{w})\right]$

សរុបមក $W=\frac{1}{6}\left|\vec{u}\cdot(\vec{v}\times\vec{w})\right|$

ដូចនេះ: | មាឌប្រលេពីប៉ែត $W=\frac{1}{6}\left|\vec{u}\cdot(\vec{v}\times\vec{w})\right|$ ត្រូវបានស្រាយបញ្ជាក់ | ។

**ឃើញថា** មាឌប្រលេពីប៉ែត $V=\left|\vec{u}\cdot(\vec{v}\times\vec{w})\right|$ រីឯមាឌតេត្រាអ៊ែត $W=\frac{1}{6}\left|\vec{u}\cdot(\vec{v}\times\vec{w})\right|$

**សន្និដ្ឋាន** មាឌតេត្រាអ៊ែត ស្មើមាឌប្រលេពីប៉ែតចែកនឹង 6 ។

7. ស្រាយបញ្ជាក់ថា សមីការបន្ទាត់ក្នុងលំហ មានសមីការ ប៉ារ៉ាម៉ែត្រ $\begin{cases} x = x_0 + at \\ y = y_0 + bt \\ z = z_0 + ct \end{cases}, t \in \mathbb{R}$




គេមាន បន្ទាត់កាត់តាមចំណុច $P(x_0 , y_0 , z_0)$

បន្ទាត់មានវ៉ិចទ័រប្រាប់ទិស $\vec{u} = (a , b , c)$

គេយក $Q(x , y , z)$ ជាចំណុចនៅលើបន្ទាត់

គេបាន $\overrightarrow{PQ} \parallel \vec{u}$ នោះ $\overrightarrow{PQ} = t\vec{u}$ , $t$ ជាចំនួនពិត

នាំឱ្យ $(x - x_0 , y - y_0 , z - z_0) = t(a, b , c)$

$(x - x_0 , y - y_0 , z - z_0) = (ta, tb , tc)$

ទាញបាន $\begin{cases} x - x_0 = at \\ y - y_0 = bt \\ z - z_0 = ct \end{cases} \Rightarrow \begin{cases} x = x_0 + at \\ y = y_0 + bt \\ z = z_0 + ct \end{cases}$

ដូចនេះ: សមីការបន្ទាត់ក្នុងលំហ មានសមីការប៉ារ៉ាម៉ែត្រ $\begin{cases} x = x_0 + at \\ y = y_0 + bt \\ z = z_0 + ct \end{cases}, t \in \mathbb{R}$ ត្រូវបានស្រាយបញ្ជាក់ ។

**រួចទាញបញ្ជាក់ថា $\dfrac{x - x_0}{a} = \dfrac{y - y_0}{b} = \dfrac{z - z_0}{c}$ ដែលគេហៅថា សមីការឆ្លុះ**

គេមាន $\begin{cases} x - x_0 = at \\ y - y_0 = bt \\ z - z_0 = ct \end{cases} \Rightarrow \begin{cases} \dfrac{x - x_0}{a} = t \\ \dfrac{y - y_0}{b} = t \\ \dfrac{z - z_0}{c} = t \end{cases}$

ទាញបាន $\dfrac{x - x_0}{a} = \dfrac{y - y_0}{b} = \dfrac{z - z_0}{c} = t$

ដូចនេះ: $\dfrac{x - x_0}{a} = \dfrac{y - y_0}{b} = \dfrac{z - z_0}{c}$ ដែលគេហៅថា សមីការឆ្លុះ ត្រូវបានស្រាយបញ្ជាក់ ។

8. ស្រាយបញ្ជាក់ថា ប្លង់មានសមីការស្តង់ដា $a(x - x_0) + b(y - y_0) + c(z - z_0) = 0$




គេមាន ប្លង់កាត់តាមចំណុច $P(x_0 , y_0 , z_0)$

ប្លង់មានវ៉ិចទ័រណរម៉ាល់ $\vec{n} = (a , b , c)$

ចំពោះ: គ្រប់ចំណុច $Q(x , y , z)$ នៃប្លង់នោះ $\overrightarrow{PQ} \perp \vec{n}$

គេបាន $\vec{n} \cdot \overrightarrow{PQ} = 0$ ដែល $\overrightarrow{PQ} = (x - x_0 , y - y_0 , z - z_0)$

នាំឱ្យ $a(x - x_0) + b(y - y_0) + c(z - z_0) = 0$

ដូចនេះ: ប្លង់មានសមីការស្តង់ដា $a(x - x_0) + b(y - y_0) + c(z - z_0) = 0$ ត្រូវបានស្រាយបញ្ជាក់ ។

9. **ស្រាយបញ្ជាក់ថា សមីការទូទៅនៃប្លង់គឺ** $ax+by+cz+d=0$

គេមាន $a(x-x_0)+b(y-y_0)+c(z-z_0)=0$

$$ax-ax_0+by-by_0+cz-cz_0=0$$

$$ax+by+cz-(ax_0+by_0+cz_0)=0$$

ដោយ $d=-(ax_0+by_0+cz_0)$

នាំឱ្យ $ax+by+cz+d=0$

ដូចនេះ: ប្លង់ទូទៅនៃប្លង់មានរាង $ax+by+cz+d=0$ ត្រូវបានស្រាយបញ្ជាក់ ។

10. **ស្រាយបញ្ជាក់ថា បើមុំ $\theta$ ជាមុំផ្គុំរវាងប្លង់ពីរ នោះគេបាន** $\cos\theta=\dfrac{|\vec{n}_1\cdot\vec{n}_2|}{|\vec{n}_1||\vec{n}_2|}$




គេមាន ប្លង់ពីរ $\alpha_1$ និង $\alpha_2$ មានវ៉ិចទ័រណរម៉ាល់រៀងគ្នា $\vec{n}_1$ និង $\vec{n}_2$

ហើយ មុំផ្គុំរវាងប្លង់ $\alpha_1$ និង $\alpha_2$ ស្មើនឹងមុំផ្គុំរវាងវ៉ិចទ័រណរម៉ាល់ $\vec{n}_1$ និង $\vec{n}_2$ (ព្រោះមុំទាំងពីរមានជ្រុងត្រូវគ្នាកែងរៀងគ្នា)

តាមនិយមន័យផលគុណស្កាលែនៃ $\vec{n}_1$ និង $\vec{n}_2$

គេបាន $\vec{n}_1\cdot\vec{n}_2=|\vec{n}_1|\cdot|\vec{n}_2|\cdot\cos\theta$

ទាញបាន $\cos\theta=\dfrac{\vec{n}_1\cdot\vec{n}_2}{|\vec{n}_1|\cdot|\vec{n}_2|}$

ម្យ៉ាងទៀត មុំផ្គុំរវាងប្លង់ពីរ មានពីរខុសគ្នា មានមួយស្រួច មួយទៀតទាល ដែលមុំទាំងពីរជាមុំបន្ថែមគ្នា បើគេតាងមុំស្រួចដោយ $\theta$ នោះ មុំទាលគឺ $\pi-\theta$ មានន័យថា បើស្គាល់មុំ $\theta$ គេក៏ស្គាល់មុំ $\pi-\theta$ ដែរ ។ ក្នុងការសិក្សា គេគិតតែមុំស្រួចប៉ុណ្ណោះ

នាំឱ្យ $\cos\theta>0$ គេសរសេរ $\cos\theta=\left|\dfrac{\vec{n}_1\cdot\vec{n}_2}{|\vec{n}_1|\cdot|\vec{n}_2|}\right|=\dfrac{|\vec{n}_1\cdot\vec{n}_2|}{\left||\vec{n}_1|\cdot|\vec{n}_2|\right|}=\dfrac{|\vec{n}_1\cdot\vec{n}_2|}{\left||\vec{n}_1|\right|\left||\vec{n}_2|\right|}=\dfrac{|\vec{n}_1\cdot\vec{n}_2|}{|\vec{n}_1|\cdot|\vec{n}_2|}$

ដូចនេះ: មុំផ្គុំរវាងប្លង់ពីរគឺ $\cos\theta=\dfrac{|\vec{n}_1\cdot\vec{n}_2|}{|\vec{n}_1||\vec{n}_2|}$ ត្រូវបានស្រាយបញ្ជាក់ ។

11. **បើប្លង់ពីរមានវ៉ិចទ័រណរម៉ាល់រៀងគ្នា $\vec{n}_1$ និង $\vec{n}_2$ ៖**

**ក. ស្រាយបញ្ជាក់ថា ប្លង់ទាំងពីរកែងគ្នា បើ** $\vec{n}_1\cdot\vec{n}_2=0$

គេមាន $\vec{n}_1$ និង $\vec{n}_2$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ពីរ ដែលផ្គុំបានមុំ $\theta$

គេបាន $\cos\theta=\dfrac{|\vec{n}_1\cdot\vec{n}_2|}{|\vec{n}_1||\vec{n}_2|}$

បើប្លង់ទាំងពីរ កែងគ្នានោះ $\theta=90^\circ$

នាំឱ្យ $\cos 90^\circ=\dfrac{|\vec{n}_1\cdot\vec{n}_2|}{|\vec{n}_1||\vec{n}_2|} \Leftrightarrow \dfrac{|\vec{n}_1\cdot\vec{n}_2|}{|\vec{n}_1||\vec{n}_2|}=0 \Leftrightarrow |\vec{n}_1\cdot\vec{n}_2|=0 \Rightarrow \vec{n}_1\cdot\vec{n}_2=0$ (ព្រោះ $|\vec{n}_1|\neq 0$ , $|\vec{n}_2|\neq 0$ )

ដូចនេះ: បើប្លង់ពីរកែងគ្នា នោះ $\vec{n}_1\cdot\vec{n}_2=0$ ត្រូវបានស្រាយបញ្ជាក់ ។

ខ. ស្រាយបញ្ជាក់ថា ប្លង់ទាំងពីរស្របគ្នា បើ $\vec{n}_1 = k\vec{n}_2$

ដោយ $\vec{n}_1 = k\vec{n}_2$ នោះ $\vec{n}_1 \parallel \vec{n}_2$

នាំឱ្យ $\vec{n}_1$ កែងនឹងប្លង់ទី១ផង និង $\vec{n}_1$ កែងនឹងប្លង់ទី២ផង

មានន័យថា ប្លង់ពីរមានវ៉ិចទ័រណរម៉ាល់ដូចគ្នា នោះប្លង់ទាំងពីរជាប្លង់ស្របគ្នា

ដូចនេះ: | ប្លង់ពីរស្របគ្នា បើ $\vec{n}_1 = k\vec{n}_2$ ត្រូវបានស្រាយបញ្ជាក់ | ។

12. ស្រាយបញ្ជាក់ថា ចម្ងាយពីរចំណុច $P$ និង $Q$ កំណត់ដោយ $d = PQ = \sqrt{(x_2 - x_1)^2 + (y_2 - y_1)^2 + (z_2 - z_1)^2}$




គេមាន ពីរចំណុច $P(x_1 , y_1 , z_1)$ និង $Q(x_2 , y_2 , z_2)$

ក្នុងត្រីកោណកែង $PQR$ តាមពីតាគ័រ $PQ^2 = PR^2 + QR^2$

ដែល $PR^2 = AB^2 = (x_2 - x_1)^2 + (y_2 - y_1)^2$

ហើយ $QR^2 = (z_2 - z_1)^2$

គេបាន $PQ^2 = (x_2 - x_1)^2 + (y_2 - y_1)^2 + (z_2 - z_1)^2$

នាំឱ្យ $PQ = \sqrt{(x_2 - x_1)^2 + (y_2 - y_1)^2 + (z_2 - z_1)^2}$

គេតាង $d = PQ$ (ព្រោះ $d = \text{distance} =$ ចម្ងាយ)

គេសរសេរ $d = PQ = \sqrt{(x_2 - x_1)^2 + (y_2 - y_1)^2 + (z_2 - z_1)^2}$

ដូចនេះ: | ចម្ងាយ $d = PQ = \sqrt{(x_2 - x_1)^2 + (y_2 - y_1)^2 + (z_2 - z_1)^2}$ ត្រូវបានស្រាយបញ្ជាក់ | ។

13. ស្រាយបញ្ជាក់ថា សមីការស្វ៊ែកំណត់ដោយ $(x - x_0)^2 + (y - y_0)^2 + (z - z_0)^2 = r^2$ ។




គេមាន ស្វ៊ែដែលមានផ្ចិត $C(x_0 , y_0 , z_0)$ និងកាំ $r$

គេតាង $P(x , y , z)$ ជាចំណុចទូទៅនៅលើស្វ៊ែ

តាមនិយមន័យស្វ៊ែ គេបាន $CP^2 = r^2$

តាមរូបមន្ត ចម្ងាយ $CP^2 = (x - x_0)^2 + (y - y_0)^2 + (z - z_0)^2$

គេបាន $(x - x_0)^2 + (y - y_0)^2 + (z - z_0)^2 = r^2$

ដូចនេះ: | សមីការស្វ៊ែ $(x - x_0)^2 + (y - y_0)^2 + (z - z_0)^2 = r^2$ ត្រូវបានស្រាយបញ្ជាក់ | ។

14. ស្រាយបញ្ជាក់ថា សមីការទូទៅនៃស្វ៊ែ $x^2 + y^2 + z^2 - 2x_0x - 2y_0y - 2z_0z + k = 0$ ដែល $k = x_0^2 + y_0^2 + z_0^2 - r^2$

គេមាន $(x - x_0)^2 + (y - y_0)^2 + (z - z_0)^2 = r^2$

$x^2 - 2x_0x + x_0^2 + y^2 - 2y_0y + y_0^2 + z^2 - 2z_0z + z_0^2 = r^2$

$x^2 + y^2 + z^2 - 2x_0x - 2y_0y - 2z_0z + x_0^2 + y_0^2 + z_0^2 - r^2 = 0$

$x^2 + y^2 + z^2 - 2x_0x - 2y_0y - 2z_0z + k = 0$ (ព្រោះ $k = x_0^2 + y_0^2 + z_0^2 - r^2$ )

ដូចនេះ: | សមីការទូទៅនៃស្វ៊ែ $x^2 + y^2 + z^2 - 2x_0x - 2y_0y - 2z_0z + k = 0$ ត្រូវបានស្រាយបញ្ជាក់ | ។

15. ស្រាយបញ្ជាក់ថា ចម្ងាយពីចំណុចទៅប្លង់កំណត់ដោយ $D=\dfrac{\left|\overrightarrow{PQ}\cdot\vec{n}\right|}{|\vec{n}|}$




គេមាន ប្លង់ $\alpha$ មានចំណុច $P$ និងចំណុច $Q$ មិននៅក្នុងប្លង់ $\alpha$

ហើយ $\vec{n}$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់

គេតាង $H$ ជាចំណោលកែងនៃ $Q$ លើ $\vec{n}$

គេបាន $\overrightarrow{PQ}\cdot\vec{n}=|\vec{n}|\cdot\left|\overrightarrow{PQ}\right|\cdot\cos\theta$ (ជានិយមន័យផលគុណស្កាលែ)

ក្នុងត្រីកោណកែង $PHQ$ មាន $\left|\overrightarrow{PH}\right|=\left|\overrightarrow{PQ}\right|\cdot\cos\theta$

នាំឱ្យ $\overrightarrow{PQ}\cdot\vec{n}=|\vec{n}|\cdot\left|\overrightarrow{PH}\right|$ ឬ $\overrightarrow{PQ}\cdot\vec{n}=|\vec{n}|\cdot D$ (ព្រោះ $\left|\overrightarrow{PH}\right|=D$)

ទាញបាន $D=\dfrac{\overrightarrow{PQ}\cdot\vec{n}}{|\vec{n}|}$ តែ $D$ ជាចម្ងាយត្រូវតែមានតម្លៃវិជ្ជមាន នោះ $D=\dfrac{\left|\overrightarrow{PQ}\cdot\vec{n}\right|}{|\vec{n}|}$

ដូចនេះ

| |
|---|
| ចម្ងាយពីចំណុចទៅប្លង់គឺ $D=\dfrac{\left\|\overrightarrow{PQ}\cdot\vec{n}\right\|}{\|\vec{n}\|}$ ត្រូវបានស្រាយបញ្ជាក់ |

។

16. ស្រាយបញ្ជាក់ថា ចម្ងាយពីចំណុចទៅប្លង់កំណត់ដោយ $D=\dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$

គេមាន ចំណុច $Q(x_0\,,\,y_0\,,\,z_0)$ និងប្លង់ $\alpha:\ ax+by+cz+d=0$

តាមរយៈ ចម្ងាយពីចំណុចទៅប្លង់គឺ $D=\dfrac{\left|\overrightarrow{PQ}\cdot\vec{n}\right|}{|\vec{n}|}$ (បានស្រាយរួចខាងលើ)

ដែលមាន $\vec{n}=(a\,,\,b\,,\,c)$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ និង $P$ ជាចំណុចនៅក្នុងប្លង់

គេយក $P(x\,,\,y\,,\,z)$ ជាចំណុចនៅក្នុងប្លង់

ចំពោះ $\overrightarrow{PQ}\cdot\vec{n}=a(x-x_0)+b(y-y_0)+c(z-z_0)$

$=ax-ax_0+by-by_0+cz-cz_0$

$=ax+by+cz-ax_0-by_0-cz_0$

ដោយ $\alpha:\ ax+by+cz+d=0$ នាំឱ្យ $ax+by+cz=-d$

នាំឱ្យ $\overrightarrow{PQ}\cdot\vec{n}=-d-ax_0-by_0-cz_0$

ហើយ $\vec{n}=(a\,,\,b\,,\,c)$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $\alpha$ នោះ $|\vec{n}|=\sqrt{a^2+b^2+c^2}$

គេបាន $D=\dfrac{|-d-ax_0-by_0-cz_0|}{\sqrt{a^2+b^2+c^2}}$ ឬ $D=\dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$ (ព្រោះថា $|-x|=|x|$ , $\forall x$ ជាចំនួនពិត)

ដូចនេះ

| |
|---|
| ចម្ងាយពីចំណុចទៅប្លង់កំណត់ដោយ $D=\dfrac{\|ax_0+by_0+cz_0+d\|}{\sqrt{a^2+b^2+c^2}}$ ត្រូវបានស្រាយបញ្ជាក់ |

។

17. **ស្រាយបញ្ជាក់ថា ចម្ងាយពីចំណុចទៅបន្ទាត់ក្នុងលំហកំណត់ដោយ** $D=\dfrac{\left|\overrightarrow{PQ}\times\vec{u}\right|}{|\vec{u}|}$




គេមាន $\vec{u}$ ជាវ៉ិចទ័រប្រាប់ទិស និង $P$ ជាចំណុចមួយនៃបន្ទាត់ $L$

ក្នុងត្រីកោណកែង $PHQ$ មាន $D=\left|\overrightarrow{PQ}\right|\cdot\sin\theta$

ដោយ $\left|\overrightarrow{PQ}\times\vec{u}\right|=|\vec{u}|\cdot\left|\overrightarrow{PQ}\right|\cdot\sin\theta$ (បានស្រាយរួចក្នុងលំហាត់លេខ 2)

ឬ $\left|\overrightarrow{PQ}\times\vec{u}\right|=|\vec{u}|\cdot D$ នាំឱ្យ $D=\dfrac{\left|\overrightarrow{PQ}\times\vec{u}\right|}{|\vec{u}|}$

ដូចនេះ: | ចម្ងាយពីចំណុចទៅបន្ទាត់កំណត់ដោយ $D=\dfrac{\left|\overrightarrow{PQ}\times\vec{u}\right|}{|\vec{u}|}$ ត្រូវបានស្រាយបញ្ជាក់ | ។

18. **ស្រាយបញ្ជាក់ថា ចម្ងាយពីបន្ទាត់ទៅបន្ទាត់កំណត់ដោយ** $d\left(L_1\,,\,L_2\right)=\dfrac{\left|\overrightarrow{M_1M_2}\cdot\left(\vec{u}_1\times\vec{u}_2\right)\right|}{\left|\vec{u}_1\times\vec{u}_2\right|}$




គេមាន $M_1\,,\,M_2$ ជាចំណុចនៅលើបន្ទាត់ $L_1\,,\,L_2$ រៀងគ្នា

ហើយ $\vec{u}_1\,,\,\vec{u}_2$ ជាវ៉ិចទ័រប្រាប់ទិសរៀងគ្នានៃបន្ទាត់ $L_1\,,\,L_2$

គ្រប់បន្ទាត់ $L_1\,,\,L_2$ ក្នុងលំហគេអាចសង់បាន ប្រលេពីប៉ែតបានដូចរូប:

ដោយ មាឌប្រលេពីប៉ែត $V=\left|\vec{u}_1\times\vec{u}_2\right|\cdot d$ (1)

ម្យ៉ាងទៀត មាឌប្រលេពីប៉ែត $V=\left|\overrightarrow{M_1M_2}\cdot\left(\vec{u}_1\times\vec{u}_2\right)\right|$ (2)

តាមរយៈ (1) និង (2) គេបាន $\left|\vec{u}_1\times\vec{u}_2\right|\cdot d=\left|\overrightarrow{M_1M_2}\cdot\left(\vec{u}_1\times\vec{u}_2\right)\right|$

ទាញបាន $d=\dfrac{\left|\overrightarrow{M_1M_2}\cdot\left(\vec{u}_1\times\vec{u}_2\right)\right|}{\left|\vec{u}_1\times\vec{u}_2\right|}$

ដូចនេះ: | ចម្ងាយរវាងពីរបន្ទាត់ក្នុងលំហកំណត់ដោយ $d\left(L_1\,,\,L_2\right)=\dfrac{\left|\overrightarrow{M_1M_2}\cdot\left(\vec{u}_1\times\vec{u}_2\right)\right|}{\left|\vec{u}_1\times\vec{u}_2\right|}$ ត្រូវបានស្រាយបញ្ជាក់ | ។

# ការស្រាយបញ្ជាក់លើមេរៀន កោនិច

**ប៉ារ៉ាបូល**

1. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃប៉ារ៉ាបូលដែលមានកំពូលជាគល់តម្រុយ និងអ័ក្សឆ្លុះជាអ័ក្សអាប់ស៊ីស គឺ $y^2 = 4px$ ហើយមានបន្ទាត់ប្រាប់ទិស $x = -p$ ។
2. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃប៉ារ៉ាបូលដែលមានកំពូលជាគល់តម្រុយ និងអ័ក្សឆ្លុះជាអ័ក្សអរដោនេ គឺ $x^2 = 4py$ ហើយមានបន្ទាត់ប្រាប់ទិស $y = -p$ ។
3. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃប៉ារ៉ាបូលដែលមានកំពូល $V(h, k)$ និងអ័ក្សឆ្លុះស្របនឹងអ័ក្ស ៖

   ក. អរដោនេ គឺ $(x-h)^2 = 4p(y-k)$ ។

   ខ. អាប់ស៊ីស គឺ $(y-k)^2 = 4p(x-h)$ ។
4. ស្រាយបញ្ជាក់ថា សមីការទូទៅនៃប៉ារ៉ាបូលមានរាង ៖

   ក. $Ax^2 + Cx + Dy + E = 0$ , $(A \neq 0)$ បើមានអ័ក្សឆ្លុះជាអ័ក្សឈរ ។

   ខ. $By^2 + Cx + Dy + E = 0$ , $(B \neq 0)$ បើមានអ័ក្សឆ្លុះជាអ័ក្សដេក ។
5. ស្រាយបញ្ជាក់ថា លក្ខណៈអុបទិចនៃប៉ារ៉ាបូល ៖ បន្ទាត់ស្របនឹងអ័ក្សឆ្លុះនៃប៉ារ៉ាបូល ដែលកាត់ប៉ារ៉ាបូលត្រង់ $P$ និងបន្ទាត់ $PF$ ផ្គុំជាមួយបន្ទាត់ប៉ះប៉ារ៉ាបូលត្រង់ $P$ បានមុំស្មើគ្នា ។

**អេលីប**

6. ស្រាយបញ្ជាក់ថា $a^2 = b^2 + c^2$ នៃអេលីបដែលមាន $a$ ជាចម្ងាយពីផ្ចិតទៅកំពូល , $c$ ជាចម្ងាយពីផ្ចិតទៅកំណុំ , $b$ ជាកន្លះអ័ក្សតូច។
7. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃអេលីបដែលមានផ្ចិតជាគល់តម្រុយគឺ ៖

   ក. $\frac{x^2}{a^2} + \frac{y^2}{b^2} = 1$ បើមានអ័ក្សធំ ជាអ័ក្សអាប់ស៊ីស ។

   ខ. $\frac{x^2}{b^2} + \frac{y^2}{a^2} = 1$ បើមានអ័ក្សធំ ជាអ័ក្សអរដោនេ ។
8. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃអេលីបដែលមានផ្ចិត $(h, k)$ ៖

   ក. $\frac{(x-h)^2}{a^2} + \frac{(y-k)^2}{b^2} = 1$ បើមានអ័ក្សធំ ស្របនឹងអ័ក្សអាប់ស៊ីស ។

   ខ. $\frac{(x-h)^2}{b^2} + \frac{(y-k)^2}{a^2} = 1$ បើមានអ័ក្សធំ ស្របនឹងអ័ក្សអរដោនេ ។
9. ស្រាយបញ្ជាក់ថា អេលីបមានសមីការទូទៅ $Ax^2 + By^2 + Cx + Dy + E = 0$ ដែល $A \cdot B > 0$ និង $A \neq B$ បានពីសម្រួលរាងពីសមីការស្តង់ដា ។

**អ៊ីពែបូល**

10. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃអ៊ីពែបូលដែលមានផ្ចិតជាគល់តម្រុយគឺ (គេកំណត់យក $b^2 = c^2 - a^2$) ៖

    ក. $\frac{x^2}{a^2} - \frac{y^2}{b^2} = 1$ បើមានអ័ក្សទទឹង ជាអ័ក្សអាប់ស៊ីស និងមានសមីការអាស៊ីមតូតទ្រេត $y = \pm \frac{b}{a} x$ ។

    ខ. $\frac{y^2}{a^2} - \frac{x^2}{b^2} = 1$ បើមានអ័ក្សទទឹង ជាអ័ក្សអរដោនេ និងមានសមីការអាស៊ីមតូតទ្រេត $y = \pm \frac{a}{b} x$ ។

11. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃអ៊ីពែបូលដែលមានផ្ចិត $(h\,,\,k)$ ៖

ក. $\frac{(x-h)^2}{a^2}-\frac{(y-k)^2}{b^2}=1$ បើមានអ័ក្សទទឹង ស្របនឹងអ័ក្សអាប់ស៊ីស និងមានសមីការអាស៊ីមតូតទ្រេត $y=k\pm\frac{b}{a}(x-h)$ ។

ខ. $\frac{(y-h)^2}{a^2}-\frac{(x-h)^2}{b^2}=1$ បើមានអ័ក្សទទឹង ស្របនឹងអ័ក្សអាប់ស៊ីស និងមានសមីការអាស៊ីមតូតទ្រេត $y=k\pm\frac{a}{b}(x-h)$ ។

12. ស្រាយបញ្ជាក់ថា អ៊ីពែបូលមានសមីការទូទៅ $Ax^2+By^2+Cx+Dy+E=0$ ដែល $AB<0$ បានពីសម្រួលរាងសមីការស្តង់ដា ។

# ការស្រាយបញ្ជាក់លើមេរៀន កោនិច

## ប៉ារ៉ាបូល

1. **ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃប៉ារ៉ាបូលដែលមានកំពូលជាគល់តម្រុយ និងអ័ក្សឆ្លុះជាអ័ក្សអាប់ស៊ីស គឺ $y^2=4px$ ហើយមានបន្ទាត់ប្រាប់ទិស $x=-p$**




ឧបមាថា ប៉ារ៉ាបូលមានកំពូល $V$ ជាគល់អ័ក្សកូអរដោនេ និង កំណុំ $F$ ស្ថិតនៅលើអ័ក្សអាប់ស៊ីស

បើពីកំពូល $V$ ទៅកំណុំ $F$ មានចម្ងាយ $p$ ឯកតា នោះ $F(p,0)$

និងបន្ទាត់ប្រាប់ទិស $\Delta$ មានសមីការ $x=-p$

តាង $P(x,y)$ ជាចំណុចមួយស្ថិតនៅលើប៉ារ៉ាបូល និង $D$ ជាចំណុចមួយដែលមានកូអរដោនេ $(-p\,,y)$ តាមនិយមន័យប៉ារ៉ាបូលគេបាន ៖

$$PF=PD$$
$$\sqrt{(p-x)^2+(0-y)^2}=\sqrt{(x+p)^2+(y-y)^2}$$
$$(p-x)^2+(0-y)^2=(x+p)^2+(y-y)^2$$
$$p^2-2px+x^2+y^2=x^2+2px+p^2$$
$$y^2=4px$$

ដូចនេះ ប៉ារ៉ាបូលមានកំពូលជាគល់អ័ក្ស និងអ័ក្សឆ្លុះជាអ័ក្សអាប់ស៊ីស មានសមីការស្តង់ដា $y^2=4px$ ។

2. **ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃប៉ារ៉ាបូលដែលមានកំពូលជាគល់តម្រុយ និងអ័ក្សឆ្លុះជាអ័ក្សអរដោនេ គឺ $x^2=4py$ ហើយមានបន្ទាត់ប្រាប់ទិស $y=-p$**

ឧបមាថា ប៉ារ៉ាបូលមានកំពូល $V$ ជាគល់អ័ក្សកូអរដោនេ និងកំណុំ $F$ ស្ថិតនៅលើអ័ក្សអរដោនេ




បើពីកំពូល $V$ ទៅកំណុំ $F$ មានចម្ងាយ $p$ ឯកតា នោះ: $F(0,p)$ និងបន្ទាត់ប្រាប់ទិស $\Delta$ មានសមីការ $y=-p$

តាង $P(x,y)$ ជាចំណុចមួយស្ថិតនៅលើប៉ារ៉ាបូល និង $D$ ជាចំណុចមួយដែលមានកូអរដោនេ $(x\,,-p)$ តាមនិយមន័យប៉ារ៉ាបូលគេបាន ៖

$$PF=PD$$
$$\sqrt{(0-x)^2+(p-y)^2}=\sqrt{(x-x)^2+(-p-y)^2}$$
$$(0-x)^2+(p-y)^2=(x-x)^2+(-p-y)^2$$
$$x^2+p^2-2py+y^2=p^2+2py+y^2$$
$$x^2=4py$$

ដូចនេះ ប៉ារ៉ាបូលមានកំពូលជាគល់អ័ក្ស និងអ័ក្សឆ្លុះជាអ័ក្សអាប់ស៊ីស មានសមីការស្តង់ដា $x^2=4py$ ។

3. ក. ស្រាយបញ្ជាក់ថា សមីការស្តង់ដាប៉ារ៉ាបូលមានកំពូល $V(h,k)$ និងអ័ក្សឆ្លុះស្របនឹងអ័ក្សអរដោនេ គឺ $(x-h)^2=4p(y-k)$

គេមាន កំពូល $V(h,k)$ អ័ក្សឆ្លុះស្របអ័ក្ស $y'y$ និង $p$ ជាចម្ងាយពីកំពូលទៅកំណុំ ឬពីកំពូលទៅបន្ទាត់ប្រាប់ទិស នាំឱ្យ កំណុំមានកូអរដោនេ $F(h,k+p)$




យក $P(x,y)$ ជាចំណុចនៅលើប៉ារ៉ាបូល និង $D$ នៅលើបន្ទាត់ប្រាប់ទិស ដែលមានកូអរដោនេ $(x,k-p)$

តាមនិយមន័យប៉ារ៉ាបូលគេបាន៖ $PF=PD$ ឬ $PF^2=PD^2$

ដោយ

$$PF=\sqrt{(x-h)^2+[y-(k+p)]^2}$$

$$PF^2=(x-h)^2+y^2-2y(k+p)+(k+p)^2$$

$$=(x-h)^2+y^2-2yk-2yp+k^2+2kp+p^2$$

$$PD=\sqrt{(x-x)^2+[(k-p)-y]^2}$$

$$PD^2=(k-p)^2-2(k-p)y+y^2$$

$$=k^2-2kp+p^2-2yk+2yp+y^2$$

គេបាន $(x-h)^2+y^2-2yk-2yp+k^2+2kp+p^2=k^2-2kp+p^2-2yk+2yp+y^2$

$$(x-h)^2=-4kp+4yp$$

$$(x-h)^2=4p(y-k)$$

ដូចនេះ | សមីការស្តង់ដានៃប៉ារ៉ាបូល មានកំពូល $V(h,k)$ អ័ក្សឆ្លុះឈរ គឺ $(x-h)^2=4p(y-k)$ | ។

ខ. ស្រាយបញ្ជាក់ថា សមីការស្តង់ដាប៉ារ៉ាបូលមានកំពូល $V(h,k)$ និងអ័ក្សឆ្លុះស្របនឹងអ័ក្សអាប់ស៊ីសគឺ $(y-k)^2=4p(x-h)$

គេមាន កំពូល $V(h,k)$ អ័ក្សឆ្លុះស្របអ័ក្ស $x'x$ និង $p$ ជាចម្ងាយពីកំពូលទៅកំណុំ ឬពីកំពូលទៅបន្ទាត់ប្រាប់ទិស នាំឱ្យ កំណុំមានកូអរដោនេ $F(h+p,k)$




យក $P(x,y)$ ជាចំណុចនៅលើប៉ារ៉ាបូល និង $D$ នៅលើបន្ទាត់ប្រាប់ទិស ដែលមានកូអរដោនេ $(h-p,k)$

តាមនិយមន័យប៉ារ៉ាបូលគេបាន៖ $PF=PD$ ឬ $PF^2=PD^2$

ដោយ

$$FP=\sqrt{[x-(h+p)]^2+(y-k)^2}$$

$$FP^2=x^2-2x(h+p)+(h+p)^2+(y-k)^2$$

$$=x^2-2xh-2xp+h^2+2hp+p^2+(y-k)^2$$

$PD = \sqrt{\left[x-(h-p)\right]^2+(y-y)^2}$

$PD^2 = x^2-2x(h-p)+(h-p)^2$

$= x^2-2xh+2xp+h^2-2hp+p^2$

គេបាន $x^2-2xh-2xp+h^2+2hp+p^2+(y-k)^2 = x^2-2xh+2xp+h^2-2hp+p^2$

$$-2xp+2hp+(y-k)^2 = 2xp-2hp$$

$$(y-k)^2 = 4xp-4hp$$

$$(y-k)^2 = 4p(x-h)$$

ដូចនេះ | សមីការស្តង់ដានៃប៉ារ៉ាបូល មានកំពូល $V(h,k)$ អ័ក្សឆ្លុះដេក គឺ $(y-k)^2 = 4p(x-h)$ | ។

4. **ក. ស្រាយបញ្ជាក់ថា សមីការទូទៅនៃប៉ារ៉ាបូលមានរាង $Ax^2+Cx+Dy+E=0$ , $(A\neq 0)$ បើមានអ័ក្សឆ្លុះជាអ័ក្សឈរ**

គេមានសមីការស្តង់ដាដែលមានអ័ក្សឆ្លុះឈរគឺ $(x-h)^2 = 4p(y-k)$

គេពន្លាតបាន ៖

$$x^2-2xh+h^2 = 4py-4pk$$

$$x^2-2xh+h^2-4py+4pk=0$$

$$x^2-2hx-4py+h^2+4pk=0$$

ដើម្បីឱ្យវាទូទៅ គេតាង $B$ ជាមេគុណ $x^2$ , $C=-2h$ , $D=-4p$ និង $E=h^2+4pk$

នាំឱ្យគេបានសមីការទូទៅនៃប៉ារ៉ាបូលមានអ័ក្សឆ្លុះឈរគឺ $Ax^2+Cx+Dy+E=0$ , $(A\neq 0)$

ដូចនេះ | សមីការទូទៅនៃប៉ារ៉ាបូលមានអ័ក្សឆ្លុះជាអ័ក្សឈរមានរាង $Ax^2+Cx+Dy+E=0$ , $(A\neq 0)$ | ។

**ខ. ស្រាយបញ្ជាក់ថា សមីការទូទៅនៃប៉ារ៉ាបូលមានរាង $By^2+Cx+Dy+E=0$ , $(B\neq 0)$ បើមានអ័ក្សឆ្លុះជាអ័ក្សដេក**

គេមានសមីការស្តង់ដាដែលមានអ័ក្សឆ្លុះឈរគឺ $(y-k)^2 = 4p(x-h)$

គេបានពន្លាតបាន ៖

$$y^2-2ky+k^2 = 4px-4ph$$

$$y^2-2ky+k^2-4px+4ph =$$

$$y^2-4px-2ky+k^2+4ph=0$$

ដើម្បីឱ្យវាទូទៅ គេតាង $B$ ជាមេគុណ $y^2$ , $C=-4p$ , $D=-2k$ និង $E=k^2+4ph$

នាំឱ្យគេបានសមីការទូទៅនៃប៉ារ៉ាបូលមានអ័ក្សឆ្លុះឈរគឺ $Ax^2+Cx+Dy+E=0$ , $(A\neq 0)$

ដូចនេះ | សមីការទូទៅនៃប៉ារ៉ាបូលមានអ័ក្សឆ្លុះជាអ័ក្សឈរមានរាង $By^2+Cx+Dy+E=0$ , $(B\neq 0)$ | ។

**សម្គាល់ :** ជាធម្មតាគេច្រើនឱ្យយើងបំលែងពីសមីការទូទៅនៃប៉ារ៉ាបូល ឱ្យទៅជាសមីការស្តង់ដា ។
សមីការស្តង់ដា ជាសមីការដែលគេងាយមើលធាតុពិសេសនៃប៉ារ៉ាបូល ដូចជា កំពូល កំណុំ អ័ក្សឆ្លុះ បន្ទាត់ប្រាប់ទិស ។
កញ្ចក់រាងប៉ារ៉ាបូល ក៏មានលក្ខណៈចាំងផ្លាតដូចកញ្ចក់ប្លង់ដែរ (សូមមើលសម្រាយបញ្ជាក់ខាងក្រោម) ។

5. ស្រាយបញ្ជាក់ លក្ខណៈអុបទិចនៃប៉ារ៉ាបូល ៖ បន្ទាត់ស្របនឹងអ័ក្សឆ្លុះនៃប៉ារ៉ាបូល ដែលកាត់ប៉ារ៉ាបូលត្រង់ $P$ និងបន្ទាត់ $PF$ ផ្គុំជាមួយបន្ទាត់ប៉ះប៉ារ៉ាបូលត្រង់ $P$ បានមុំស្មើគ្នា

ឧបមាថា គេមានប៉ារ៉ាបូល $x^2=4py$

គូសបន្ទាត់ $(\ell)$ ប៉ះប៉ារ៉ាបូលត្រង់ $P(x_0\ ,\ y_0)$ ហើយ

កាត់អ័ក្សអរដោនេត្រង់ $Q(0,q)$




តាង $\alpha$ ជាមុំផ្គុំរវាង $FP$ និងបន្ទាត់ $(\ell)$

$\beta$ ជាមុំផ្គុំរវាង បន្ទាត់ $(\ell)$ និងបន្ទាត់ឈរស្របនឹងអ័ក្សឆ្លុះ

$\beta'$ ជាមុំផ្គុំរវាងអ័ក្សអរដោនេ និងបន្ទាត់ $(\ell)$

គេបាន $\beta=\beta'$ (ជាមុំត្រូវគ្នា)

គេនឹងស្រាយថា មុំចំណាំងប៉ះស្មើនឹងមុំចំណាំងផ្លាត គឺ $\beta=\alpha$ ???

គេមាន ប៉ារ៉ាបូល $x^2=4py$ នោះ $y=\dfrac{x^2}{4p}$ នាំឱ្យ $y'=\dfrac{2x}{4p}$ ឬ $y'=\dfrac{x}{2p}$ ហើយម្យ៉ាងទៀត $y_0=\dfrac{x_0^2}{4p}$

នាំឱ្យ មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះប៉ារ៉ាបូលត្រង់ $P(x_0\ ,\ y_0)$ គឺ $y'(x_0)=\dfrac{x_0}{2p}$

សមីការបន្ទាត់ប៉ះមានរាង $y=y'(x_0)(x-x_0)+y_0$

ដោយ បន្ទាត់ប៉ះកាត់តាម $Q(0\ ,\ q)$ គេបាន ៖ $q=\dfrac{x_0}{2p}(0-x_0)+y_0$ ឬ $q=-\dfrac{x_0^2}{2p}+y_0=-\dfrac{x_0^2}{2p}+\dfrac{x_0^2}{4p}=-\dfrac{x_0^2}{4p}$

$$QF=\sqrt{(0-0)^2+(p-q)^2}=\sqrt{(p-q)^2}=p-q=p-\left(-\frac{x_0^2}{4p}\right)=p+\frac{x_0^2}{4p}$$

$$FP=\sqrt{(x_0-0)^2+(y_0-p)^2}=\sqrt{x_0^2+\left(\frac{x_0^2}{4p}-p\right)^2}$$

$$=\sqrt{x_0^2+\left(\frac{x_0^2}{4p}\right)^2-2\frac{x_0^2}{4p}\cdot p+p^2}=\sqrt{x_0^2+\left(\frac{x_0^2}{4p}\right)^2-\frac{x_0^2}{2}+p^2}$$

$$=\sqrt{\left(\frac{x_0^2}{4p}\right)^2+\frac{x_0^2}{2}+p^2}=\sqrt{\left(\frac{x_0^2}{4p}\right)^2+2\cdot\frac{x_0^2}{4p}\cdot p+p^2}$$

$$=\sqrt{\left(\frac{x_0^2}{4p}+p\right)^2}=\frac{x_0^2}{4p}+p$$

ឃើញថា ក្នុងត្រីកោណ $FPQ$ មាន $QF=FP=\dfrac{x_0^2}{4p}+p$ នាំឱ្យវាជាត្រីកោណសមបាត វិបាក មុំបាត $\alpha=\beta'$ ឬ $\alpha=\beta$

ដូចនេះ | មុំចាំងប៉ះក្នុងប៉ារ៉ាបូល ស្មើនឹងមុំចាំងផ្លាត ត្រូវបានស្រាយបញ្ជាក់ | ។

សន្និដ្ឋាន : គ្រប់កាំពន្លឺស្របនឹងអ័ក្សឆ្លុះនៃប៉ារ៉ាបូល ដែលមកប៉ះនឹងប៉ារ៉ាបូល ចាំងផ្លាតទៅចំណុចតែមួយគឺកំណុំនៃប៉ារ៉ាបូល ។

**អេលីប**

6. **ស្រាយបញ្ជាក់ថា $a^2 = b^2 + c^2$ នៃអេលីបដែលមាន $a$ ជាចម្ងាយពីផ្ចិតទៅកំពូល , $c$ ជាចម្ងាយពីផ្ចិតទៅកំណុំ , $b$ កន្លះអ័ក្សតូច**

ឧបមាថា គេមានអេលីបដែលមាន ផ្ចិត $O(0,0)$ និង $P$ នៅលើអេលីប




ក្នុងត្រីកោណកែង $POF_1$ តាមទ្រឹស្តីបទពីតាគ័រ

គេបាន $(PF_2)^2 = (OP)^2 + (OF_2)^2$ ឬ $(PF_2)^2 = b^2 + c^2 \quad (1)$

ក្នុងត្រីកោណសមបាត $PF_1F_2$ មាន $PF_1 = PF_2$ (ព្រោះ $P$ ជាចំណុចស្ថិតលើមេដ្យាទ័រនៃ $[F_1F_2]$)

តាមនិយមន័យអេលីប $PF_1 + PF_2 = 2a$ ឬ $2PF_2 = 2a$ ឬ $PF_2 = a$

ជំនួស $PF_2 = a$ ក្នុង $(1)$ គេបាន $a^2 = b^2 + c^2$

ដូចនេះ | ក្នុងអេលីប $a^2 = b^2 + c^2$ ត្រូវបានស្រាយបញ្ជាក់ | ។

7. **ក. ស្រាយបញ្ជាក់ថា $\frac{x^2}{a^2} + \frac{y^2}{b^2} = 1$ ជាសមីការស្តង់ដានៃអេលីបដែលមានផ្ចិតជាគល់តម្រុយ និងអ័ក្សធំ ជាអ័ក្សអាប់ស៊ីស**

ឧបមាថា គេមានអេលីបផ្ចិត $O(0,0)$ ជាគល់តម្រុយ និងអ័ក្សធំ នៅលើអ័ក្សអាប់ស៊ីស ។ យក $P(x,y)$ ជាចំណុចនៅលើអេលីប




តាមនិយមន័យអេលីប គេបាន ៖ $F_2P + PF_1 = 2a$

ដោយ $F_2P = \sqrt{(x+c)^2 + (y-0)^2} = \sqrt{x^2 + 2xc + c^2 + y^2}$

$PF_1 = \sqrt{(c-x)^2 + (0-y)^2} = \sqrt{c^2 - 2xc + x^2 + y^2}$

គេបាន៖

$$\sqrt{x^2 + 2xc + c^2 + y^2} + \sqrt{c^2 - 2xc + x^2 + y^2} = 2a$$

$$\sqrt{x^2 + 2xc + c^2 + y^2} = 2a - \sqrt{c^2 - 2xc + x^2 + y^2}$$

$$x^2 + 2xc + c^2 + y^2 = 4a^2 - 4a\sqrt{c^2 - 2xc + x^2 + y^2} + c^2 - 2xc + x^2 + y^2$$

$$4xc = 4a^2 - 4a\sqrt{c^2 - 2xc + x^2 + y^2}$$

$$a\sqrt{c^2 - 2xc + x^2 + y^2} = a^2 - xc$$

$$a^2\left(c^2 - 2xc + x^2 + y^2\right) = a^4 - 2a^2xc + x^2c^2$$

$$a^2c^2 - 2a^2xc + a^2x^2 + a^2y^2 = a^4 - 2a^2xc + x^2c^2$$

$$a^2c^2 + a^2x^2 + a^2y^2 = a^4 + x^2c^2$$

$$a^2x^2 - x^2c^2 + a^2y^2 = a^4 - a^2c^2$$

$$x^2\left(a^2 - c^2\right) + a^2y^2 = a^2\left(a^2 - c^2\right) \quad , \quad b^2 = a^2 - c^2$$

$$b^2x^2 + a^2y^2 = a^2b^2 \qquad (1)$$

ចែកអង្គទាំងពីរនៃ $(1)$ នឹង $a^2b^2$ គេបាន $\frac{x^2}{a^2} + \frac{y^2}{b^2} = 1$

ដូចនេះ | សមីការអេលីបមានផ្ចិតជាគល់តម្រុយ និងអ័ក្សធំនៅលើអ័ក្សអាប់ស៊ីសគឺ $\frac{x^2}{a^2} + \frac{y^2}{b^2} = 1$ | ។

ខ. ស្រាយបញ្ជាក់ថា $\frac{x^2}{b^2}+\frac{y^2}{a^2}=1$ ជាសមីការស្តង់ដានៃអេលីបដែលមានផ្ចិតជាគល់តម្រុយ និងអ័ក្សធំ ជាអ័ក្សអរដោនេ




ឧបមាថា គេមានអេលីបផ្ចិត $O(0,0)$ ជាគល់តម្រុយ និងអ័ក្សធំ នៅលើអ័ក្សអរដោនេ ។ យក $P(x,y)$ ជាចំណុចនៅលើអេលីប

តាមនិយមន័យអេលីប គេបាន ៖ $F_1P+PF_2=2a$

ដោយ $F_1P=\sqrt{(x-0)^2+(y-c)^2}=\sqrt{x^2+y^2-2cy+c^2}$

$F_2P=\sqrt{(x-0)^2+(y+c)^2}=\sqrt{x^2+y^2+2cy+c^2}$

គេបាន៖

$$\sqrt{x^2+y^2+2cy+c^2}+\sqrt{x^2+y^2-2cy+c^2}=2a$$
$$\sqrt{x^2+y^2+2cy+c^2}=2a-\sqrt{x^2+y^2-2cy+c^2}$$
$$x^2+y^2+2cy+c^2=4a^2-4a\sqrt{x^2+y^2-2cy+c^2}+x^2+y^2-2cy+c^2$$
$$4a\sqrt{x^2+y^2-2cy+c^2}=4a^2-4cy$$
$$a\sqrt{x^2+y^2-2cy+c^2}=a^2-cy$$
$$a^2\left(x^2+y^2-2cy+c^2\right)=a^4-2a^2cy+c^2y^2$$
$$a^2x^2+a^2y^2+a^2c^2=a^4+c^2y^2$$
$$a^2x^2+a^2y^2-c^2y^2=a^4-a^2c^2$$
$$a^2x^2+\left(a^2-c^2\right)y^2=a^2\left(a^2-c^2\right)\quad,\quad b^2=a^2-c^2$$
$$a^2x^2+b^2y^2=a^2b^2\quad(1)$$

ចែកអង្គទាំងពីរនៃ $(1)$ នឹង $a^2b^2$ គេបាន $\frac{x^2}{b^2}+\frac{y^2}{a^2}=1$

ដូចនេះ: | សមីការអេលីបមានផ្ចិតជាគល់តម្រុយ និងអ័ក្សធំនៅលើអ័ក្សអរដោនេគឺ $\frac{x^2}{b^2}+\frac{y^2}{a^2}=1$ | ។

*8.* ➤ **របៀបទី ១** : តាមបំលែងកិល

**ក. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃអេលីប ផ្ចិត $(h,k)$ និងអ័ក្សធំស្របនឹងអ័ក្សអាប់ស៊ីសគឺ** $\frac{(x-h)^2}{a^2}+\frac{(y-k)^2}{b^2}=1$

គេធ្វើបំលែងកិលអេលីប $\frac{x^2}{a^2}+\frac{y^2}{b^2}=1$ ពីផ្ចិត $O(0,0)$ ទៅជាផ្ចិត $I(h,k)$ ដោយ ៖

-រំកិល $h$ ឯកតាស្របអ័ក្សអាប់ស៊ីស បើ $h>0$ រំកិលទៅខាងស្តាំ តែបើ $h<0$ រំកិលទៅខាងឆ្វេង ។

-រំកិល $k$ ឯកតាស្របអ័ក្សអរដោនេ បើ $k>0$ រំកិលទៅខាងលើ តែបើ $k<0$ រំកិលទៅខាងក្រោម ។

ដូចនេះ: | សមីការស្តង់ដានៃអេលីប ផ្ចិត $(h,k)$ និងអ័ក្សធំស្របនឹងអ័ក្សអាប់ស៊ីសគឺ $\frac{(x-h)^2}{a^2}+\frac{(y-k)^2}{b^2}=1$ | ។

**ខ. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃអេលីប ផ្ចិត $(h\,,\,k)$ និងអ័ក្សធំស្របនឹងអ័ក្សអរដោនេគឺ** $\frac{(x-h)^2}{b^2}+\frac{(y-k)^2}{a^2}=1$

គេធ្វើបំលែងកិលអេលីប $\frac{x^2}{b^2}+\frac{y^2}{a^2}=1$ ពីផ្ចិត $O(0\,,\,0)$ ទៅជាផ្ចិត $I(h\,,\,k)$ ដោយ ៖

-រំកិល $h$ ឯកតាស្របអ័ក្សអាប់ស៊ីស បើ $h>0$ រំកិលទៅខាងស្តាំ តែបើ $h<0$ រំកិលទៅខាងឆ្វេង ។

-រំកិល $k$ ឯកតាស្របអ័ក្សអរដោនេ បើ $k>0$ រំកិលទៅខាងលើ តែបើ $k<0$ រំកិលទៅខាងក្រោម ។

ដូចនេះ: សមីការស្តង់ដានៃអេលីប ផ្ចិត $(h\,,\,k)$ និងអ័ក្សធំស្របនឹងអ័ក្សអរដោនេគឺ $\frac{(x-h)^2}{b^2}+\frac{(y-k)^2}{a^2}=1$ ។

➢ **របៀបទី ២ :** តាមនិយមន័យអេលីប

**ក. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃអេលីប ផ្ចិត $(h\,,\,k)$ និងអ័ក្សធំស្របនឹងអ័ក្សអាប់ស៊ីសគឺ** $\frac{(x-h)^2}{a^2}+\frac{(y-k)^2}{b^2}=1$

គេមាន អេលីបផ្ចិត $(h\,,\,k)$ និងអ័ក្សធំស្របអ័ក្សអាប់ស៊ីស

នាំឱ្យ កំណុំ $F_1(h+c,k)$ និង $F_2(h-c,k)$

យក $P(x\,,\,y)$ ជាចំណុចនៅលើអេលីប

តាមនិយមន័យអេលីបគេបាន $F_1P+PF_2=2a$




$$F_1P=\sqrt{\left[x-(h+c)\right]^2+(y-k)^2}$$
$$=\sqrt{\left[(x-h)-c\right]^2+(y-k)^2}$$
$$=\sqrt{(x-h)^2-2(x-h)c+c^2+(y-k)^2}$$
$$=\sqrt{(x-h)^2-2xc+2hc+c^2+(y-k)^2}$$

$$F_2P=\sqrt{\left[x-(h-c)\right]^2+(y-k)^2}$$
$$=\sqrt{\left[(x-h)+c\right]^2+(y-k)^2}$$
$$=\sqrt{(x-h)^2+2(x-h)c+c^2+(y-k)^2}$$
$$=\sqrt{(x-h)^2+2xc-2hc+c^2+(y-k)^2}$$

គេបាន ៖

$$\sqrt{(x-h)^2-2xc+2hc+c^2+(y-k)^2}+\sqrt{(x-h)^2+2xc-2hc+c^2+(y-k)^2}=2a$$

$$\sqrt{(x-h)^2-2xc+2hc+c^2+(y-k)^2}=2a-\sqrt{(x-h)^2+2xc-2hc+c^2+(y-k)^2}$$

$$(x-h)^2-2xc+2hc+c^2+(y-k)^2=4a^2-4a\sqrt{(x-h)^2+2xc-2hc+c^2+(y-k)^2}+(x-h)^2+2xc-2hc+c^2+(y-k)^2$$

$$-4xc+4hc=4a^2-4a\sqrt{(x-h)^2+2xc-2hc+c^2+(y-k)^2}$$

$$-xc+hc=a^2-a\sqrt{(x-h)^2+2xc-2hc+c^2+(y-k)^2}$$

$$a\sqrt{(x-h)^2+2xc-2hc+c^2+(y-k)^2}=a^2+xc-hc$$

$$a^2\left[(x-h)^2+2xc-2hc+c^2+(y-k)^2\right]=a^4+x^2c^2+h^2c^2+2a^2xc-2a^2hc-2xhc^2$$

$$a^2(x-h)^2+2a^2xc-2a^2hc+a^2c^2+a^2(y-k)^2=a^4+x^2c^2+h^2c^2+2a^2xc-2a^2hc-2xhc^2$$

$$a^2(x-h)^2+a^2c^2+a^2(y-k)^2=a^4+x^2c^2+h^2c^2-2xhc^2$$

$$a^2(x-h)^2+a^2c^2+a^2(y-k)^2=a^4+c^2(x-h)^2$$

$$a^2(x-h)^2-c^2(x-h)^2+a^2(y-k)^2=a^4-a^2c^2$$

$$(a^2-c^2)(x-h)^2+a^2(y-k)^2=a^2(a^2-c^2)\qquad,\quad b^2=a^2-c^2$$

$$b^2(x-h)^2+a^2(y-k)^2=a^2b^2$$

$$\frac{(x-h)^2}{a^2}+\frac{(y-k)^2}{b^2}=1$$

ដូចនេះ: | សមីការស្តង់ដានៃអេលីប ផ្ចិត $(h\,,\,k)$ និងអ័ក្សធំស្របនឹងអ័ក្សអាប់ស៊ីសគឺ $\frac{(x-h)^2}{a^2}+\frac{(y-k)^2}{b^2}=1$ | ។

**ខ. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃអេលីប ផ្ចិត $(h\,,\,k)$ និងអ័ក្សធំស្របនឹងអ័ក្សអរដោនេគឺ $\frac{(x-h)^2}{b^2}+\frac{(y-k)^2}{a^2}=1$**

គេមាន អេលីបផ្ចិត $(h\,,\,k)$ និងអ័ក្សធំស្របអ័ក្សអរដោនេ នោះកំណុំ $F_1(h+c,k)$ និង $F_2(h-c,k)$ ។

យក $P(x\,,\,y)$ ជាចំណុចនៅលើអេលីប

តាមនិយមន័យអេលីបគេបាន $F_1P+PF_2=2a$




$$F_1P=\sqrt{(x-h)^2+\left[y-(k+c)\right]^2}$$
$$=\sqrt{(x-h)^2+\left[(y-k)-c\right]^2}$$
$$=\sqrt{(x-h)^2+(y-k)^2-2(y-k)c+c^2}$$
$$=\sqrt{(x-h)^2+(y-k)^2-2yc+2kc+c^2}$$

$$F_2P=\sqrt{(x-h)^2+\left[y-(k-c)\right]^2}$$
$$=\sqrt{(x-h)^2+\left[(y-k)+c\right]^2}$$
$$=\sqrt{(x-h)^2+(y-k)^2+2(y-k)c+c^2}$$
$$=\sqrt{(x-h)^2+(y-k)^2+2yc-2kc+c^2}$$

គេបាន ៖

$$\sqrt{(x-h)^2+(y-k)^2-2yc+2kc+c^2}+\sqrt{(x-h)^2+(y-k)^2+2yc-2kc+c^2}=2a$$

$$\sqrt{(x-h)^2+(y-k)^2-2yc+2kc+c^2}=2a-\sqrt{(x-h)^2+(y-k)^2+2yc-2kc+c^2}$$

$$(x-h)^2+(y-k)^2-2yc+2kc+c^2=4a^2-4a\sqrt{(x-h)^2+(y-k)^2+2yc-2kc+c^2}+(x-h)^2+(y-k)^2+2yc-2kc+c^2$$

$$-4yc+4kc=4a^2-4a\sqrt{(x-h)^2+(y-k)^2+2yc-2kc+c^2}$$

$$a\sqrt{(x-h)^2+(y-k)^2+2yc-2kc+c^2}=a^2+yc-kc$$

$$a^2\left[(x-h)^2+(y-k)^2+2yc-2kc+c^2\right]=a^4+y^2c^2+k^2c^2+2a^2yc-2a^2kc-2ykc^2$$

$$a^2(x-h)^2+a^2(y-k)^2+2a^2yc-2a^2kc+a^2c^2=a^4+y^2c^2+k^2c^2+2a^2yc-2a^2kc-2ykc^2$$

$$a^2(x-h)^2+a^2(y-k)^2+a^2c^2=a^4+y^2c^2+k^2c^2-2ykc^2$$

$$a^2(x-h)^2+a^2(y-k)^2+a^2c^2=a^4+c^2(y-k)^2$$

$$a^2(x-h)^2+a^2(y-k)^2-c^2(y-k)^2=a^4-a^2c^2$$

$$a^2(x-h)^2+(a^2-c^2)(y-k)^2=a^2(a^2-c^2)\quad,\quad b^2=a^2-c^2$$

$$a^2(x-h)^2+b^2(y-k)^2=a^2b^2$$

$$\frac{(x-h)^2}{b^2}+\frac{(y-k)^2}{a^2}=1$$

ដូចនេះ: | សមីការស្តង់ដានៃអេលីប ផ្ចិត $(h\,,\,k)$ និងអ័ក្សធំស្របនឹងអ័ក្សអរដោនេគឺ $\frac{(x-h)^2}{b^2}+\frac{(y-k)^2}{a^2}=1$ | ។

9. **ស្រាយបញ្ជាក់ថា អេលីបមានសមីការទូទៅ** $Ax^2+By^2+Cx+Dy+E=0$ **ដែល** $A\cdot B>0$ **និង** $A\neq B$

-គេពន្លាត សមីការស្តង់ដា $\frac{(x-h)^2}{a^2}+\frac{(y-k)^2}{b^2}=1$ គុណអង្គទាំងពីរនឹង $a^2b^2$ គេបាន

$$b^2(x-h)^2+a^2(y-k)^2=a^2b^2$$

$$b^2(x^2-2hx+h^2)+a^2(y^2-2ky+k^2)=a^2b^2$$

$$b^2x^2-2b^2hx+b^2h^2+a^2y^2-2a^2ky+a^2k^2=a^2b^2$$

$$b^2x^2+a^2y^2-2b^2hx-2a^2ky+b^2h^2+a^2k^2-a^2b^2=0$$

-គេពន្លាត សមីការស្តង់ដា $\frac{(x-h)^2}{b^2}+\frac{(y-k)^2}{a^2}=1$ គុណអង្គទាំងពីរនឹង $a^2b^2$ គេបាន

$$a^2(x-h)^2+b^2(y-k)^2=a^2b^2$$

$$a^2(x^2-2hx+h^2)+b^2(y^2-2ky+k^2)=a^2b^2$$

$$a^2x^2-2a^2hx+a^2h^2+b^2y^2-2b^2ky+b^2k^2=a^2b^2$$

$$a^2x^2+b^2y^2-2a^2hx-2b^2ky+a^2h^2+b^2k-a^2b^2=0$$

ក្រោយពីពន្លាតសមីការស្តង់ដាទាំងពីរមានរាង $Ax^2+By^2+Cx+Dy+E=0$ ដែល $AB=a^2b^2>0$

ដូចនេះ: | សមីការទូទៅនៃអេលីបគឺ $Ax^2+By^2+Cx+Dy+E=0$ ដែល $AB>0\ ,\ A\neq B$ | ។

**អ៊ីពែបូល**

10. ក. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃអ៊ីពែបូលដែលមានផ្ចិតជាគល់តម្រុយ និងអ័ក្សទទឹងជាអ័ក្សអាប់ស៊ីសគឺ $\frac{x^2}{a^2}-\frac{y^2}{b^2}=1$

គេមាន អ៊ីពែបូលមានផ្ចិតនៅគល់តម្រុយ និងអ័ក្សទទឹងជាអ័ក្សអាប់ស៊ីស

គេយក $P(x\,,\,y)$ នៅលើប៉ារ៉ាបូល និងយក $b^2=c^2-a^2$

គេបាន កំណុំ $F_1(0\,,\,c)$ និង $F_2(0\,,\,-c)$




តាមនិយមន័យ អ៊ីពែបូល គេបាន $|F_1P-F_2P|=2a$

ឬ $F_1P-F_2P=\pm 2a$ ឬ $F_1P=\pm 2a+F_2P$

ដោយ $F_1P=\sqrt{(x-c)^2+(y-0)^2}=\sqrt{x^2-2xc+c^2+y^2}$

$F_2P=\sqrt{(x+c)^2+(y-c)^2}=\sqrt{x^2+2xc+c^2+y^2}$

គេបាន

$$\sqrt{x^2-2xc+c^2+y^2}=\pm 2a-\sqrt{x^2+2xc+c^2+y^2}$$

$$x^2-2xc+c^2+y^2=4a^2\mp 4a\sqrt{x^2+2xc+c^2+y^2}+x^2+2xc+c^2+y^2$$

$$-4xc=4a^2\mp 4a\sqrt{x^2+2xc+c^2+y^2}$$

$$\pm a\sqrt{x^2+2xc+c^2+y^2}=a^2+xc$$

$$a^2\left(x^2+2xc+c^2+y^2\right)=a^4+2a^2xc+x^2c^2$$

$$a^2x^2+2a^2xc+a^2c^2+a^2y^2=a^4+2a^2xc+x^2c^2$$

$$a^2x^2+a^2c^2+a^2y^2=a^4+x^2c^2$$

$$a^2c^2-a^4=x^2c^2-a^2x^2-a^2y^2$$

$$a^2\left(c^2-a^2\right)=\left(c^2-a^2\right)x^2-a^2y^2 \quad , \quad b^2=c^2-a^2$$

$$a^2b^2=b^2x^2-a^2y^2$$

$$1=\frac{x^2}{a^2}-\frac{y^2}{b^2} \quad (1)$$

ទាញរក $y$ ពីសមីការ $(1)$ គេបាន $\frac{y^2}{b^2}=\frac{x^2}{a^2}-1 \Leftrightarrow y^2=b^2\left(\frac{x^2}{a^2}-1\right) \Rightarrow y=\pm\sqrt{b^2\left(\frac{x^2}{a^2}-1\right)}$ មានន័យលុះត្រាតែ

$\frac{x^2}{a^2}-1\geq 0 \Rightarrow x^2\geq a^2$ នាំឱ្យ $x\geq a$ ឬ $x\leq -a$ គេបាន $y=\pm\sqrt{b^2\cdot\frac{x^2}{a^2}\left(1-\frac{a^2}{x^2}\right)} \Leftrightarrow y=\pm\frac{b}{a}x\sqrt{1-\frac{a^2}{x^2}}$

បើ $x\to+\infty$ នោះកន្សោម $1-\frac{a^2}{x^2}\to 1$ ហើយ អរដោនេ $y$ នៃចំណុច $P(x\,,\,y)$ នៅលើអ៊ីពែបូលខិតជិត $\frac{b}{a}x$ ឬ $-\frac{b}{a}x$ ។

ដូចនេះចំណុច $P(x\,,\,y)$ ខិតជិតបន្ទាត់ $y=\frac{b}{a}x$ កាលណា $y>0$ និងខិតជិតបន្ទាត់ $y=-\frac{b}{a}x$ កាលណា $y<0$ ។

ស្ថានភាពដូចគ្នា បើ $x\leq -a$ នោះ $x\to-\infty$ ។ បន្ទាត់មានសមីការ $y=\pm\frac{b}{a}x$ ជាអាស៊ីមតូតនៃអ៊ីពែបូល $\frac{x^2}{a^2}-\frac{y^2}{b^2}=1$

ដូចនេះ: សមីការស្តង់ដានៃអ៊ីពែបូលដែលមានផ្ចិតជាគល់តម្រុយ និងអ័ក្សទទឹងជាអ័ក្សអាប់ស៊ីសគឺ $\frac{x^2}{a^2}-\frac{y^2}{b^2}=1$ ។

ខ. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃអ៊ីពែបូលដែលមានផ្ចិតជាគល់តម្រុយ និងអ័ក្សទទឹងជាអ័ក្សអរដោនេគឺ $\frac{y^2}{a^2}-\frac{x^2}{b^2}=1$

គេមាន អ៊ីពែបូលមានផ្ចិតនៅគល់តម្រុយ និងអ័ក្សទទឹងជាអ័ក្សអរដោនេ

គេយក $P(x\,,\,y)$ នៅលើប៉ារ៉ាបូល និងកំណត់យក $b^2=c^2-a^2$

គេបាន កំណុំ $F_1(0\,,\,c)$ និង $F_2(0\,,\,-c)$




តាមនិយមន័យ អ៊ីពែបូល គេបាន $|F_1P-F_2P|=2a$

ឬ $F_1P-F_2P=\pm 2a$ ឬ $F_1P=\pm 2a+F_2P$

ដោយ $F_1P=\sqrt{(x-0)^2+(y-c)^2}=\sqrt{x^2+y^2-2yc+c^2}$

$F_2P=\sqrt{(x-0)^2+(y+c)^2}=\sqrt{x^2+y^2+2yc+c^2}$

គេបាន

$$\sqrt{x^2+y^2-2yc+c^2}=\pm 2a-\sqrt{x^2+y^2+2yc+c^2}$$

$$x^2+y^2-2yc+c^2=4a^2\mp 4a\sqrt{x^2+y^2+2yc+c^2}+x^2+y^2+2$$

$$-4yc=4a^2\mp 4a\sqrt{x^2+y^2+2yc+c^2}$$

$$\pm a\sqrt{x^2+y^2+2yc+c^2}=a^2+yc$$

$$a^2\left(x^2+y^2+2yc+c^2\right)=a^4+2a^2yc+y^2c^2$$

$$a^2x^2+a^2y^2+2a^2yc+a^2c^2=a^4+2a^2yc+y^2c^2$$

$$a^2x^2+a^2y^2+a^2c^2=a^4+y^2c^2$$

$$a^2c^2-a^4=y^2c^2-a^2y^2-a^2x^2$$

$$a^2\left(c^2-a^2\right)=\left(c^2-a^2\right)y^2-a^2x^2 \quad , \quad b^2=c^2-a^2$$

$$a^2b^2=b^2y^2-a^2x^2$$

$$\frac{y^2}{a^2}-\frac{x^2}{b^2}=1$$

ដូចនេះ

| សមីការស្តង់ដានៃអ៊ីពែបូលដែលមានផ្ចិតជាគល់តម្រុយ និងអ័ក្សទទឹងជាអ័ក្សអរដោនេគឺ $\frac{y^2}{a^2}-\frac{x^2}{b^2}=1$ |
|---|

។

11. ➢**របៀបទី ១** : តាមបំលែងកិល

**ក. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃអ៊ីពែបូលមានផ្ចិត $(h\,,\,k)$ និងអ័ក្សទទឹងស្របនឹងអ័ក្សអាប់ស៊ីសគឺ** $\frac{(x-h)^2}{a^2}-\frac{(y-k)^2}{b^2}=1$

គេធ្វើបំលែងកិលអ៊ីពែបូល $\frac{x^2}{a^2}-\frac{y^2}{b^2}=1$ ពីផ្ចិត $O(0\,,\,0)$ ទៅជាផ្ចិត $I(h\,,\,k)$ ដោយ ៖

-រំកិល $h$ ឯកតាស្របអ័ក្សអាប់ស៊ីស បើ $h>0$ រំកិលទៅខាងស្តាំ តែបើ $h<0$ រំកិលទៅខាងឆ្វេង ។

-រំកិល $k$ ឯកតាស្របអ័ក្សអរដោនេ បើ $k>0$ រំកិលទៅខាងលើ តែបើ $k<0$ រំកិលទៅខាងក្រោម ។

ដូចនេះ

| សមីការស្តង់ដានៃអ៊ីពែបូលមានផ្ចិត $(h\,,\,k)$ និងអ័ក្សទទឹងស្របនឹងអ័ក្សអាប់ស៊ីសគឺ $\frac{(x-h)^2}{a^2}-\frac{(y-k)^2}{b^2}=1$ |
|---|

។

**ខ. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃអ៊ីពែបូលមានផ្ចិត $(h\,,\,k)$ និងអ័ក្សទទឹងស្របនឹងអ័ក្សអរដោនេគឺ** $\dfrac{(y-h)^2}{a^2}-\dfrac{(x-h)^2}{b^2}=1$

គេធ្វើបំលែងកិលអ៊ីពែបូល $\dfrac{y^2}{a^2}-\dfrac{x^2}{b^2}=1$ ពីផ្ចិត $O(0\,,\,0)$ ទៅជាផ្ចិត $I(h\,,\,k)$ ដោយ ៖

-រំកិល $h$ ឯកតាស្របអ័ក្សអាប់ស៊ីស បើ $h>0$ រំកិលទៅខាងស្តាំ តែបើ $h<0$ រំកិលទៅខាងឆ្វេង ។

-រំកិល $k$ ឯកតាស្របអ័ក្សអរដោនេ បើ $k>0$ រំកិលទៅខាងលើ តែបើ $k<0$ រំកិលទៅខាងក្រោម ។

ដូចនេះ សមីការស្តង់ដានៃអ៊ីពែបូលមានផ្ចិត $(h\,,\,k)$ និងអ័ក្សទទឹងស្របនឹងអ័ក្សអរដោនេគឺ $\dfrac{(y-h)^2}{a^2}-\dfrac{(x-h)^2}{b^2}=1$ ។

**➢របៀបទី ២** : តាមនិយមន័យអ៊ីពែបូល

**ក. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃអ៊ីពែបូលមានផ្ចិត $(h\,,\,k)$ និងអ័ក្សទទឹងស្របនឹងអ័ក្សអាប់ស៊ីសគឺ** $\dfrac{(x-h)^2}{a^2}-\dfrac{(y-k)^2}{b^2}=1$

គេមាន អ៊ីពែបូលដែលមានផ្ចិត $(h\,,\,k)$ និងអ័ក្សទទឹងស្របអ័ក្សអាប់ស៊ីស

គេបាន កំណុំ $F_1(h+c\,,\,k)$ និង $F_2(h-c\,,\,k)$

យក $P(x\,,\,y)$ ជាចំណុចនៅលើអ៊ីពែបូល និងយក $b^2=c^2-a^2$




តាមនិយមន័យ អ៊ីពែបូល គេបាន $|F_1P-F_2P|=2a$

ឬ $F_1P-F_2P=\pm 2a$ ឬ $F_1P=\pm 2a+F_2P$

ដោយ

$$F_1P=\sqrt{\left[x-(h+c)\right]^2+(y-k)^2}$$
$$=\sqrt{\left[(x-h)-c\right]^2+(y-k)^2}$$
$$=\sqrt{(x-h)^2-2(x-h)c+c^2+(y-k)^2}$$
$$=\sqrt{(x-h)^2-2xc+2hc+c^2+(y-k)^2}$$

$$F_2P=\sqrt{\left[x-(h-c)\right]^2+(y-k)^2}$$
$$=\sqrt{\left[(x-h)+c\right]^2+(y-k)^2}$$
$$=\sqrt{(x-h)^2+2(x-h)c+c^2+(y-k)^2}$$
$$=\sqrt{(x-h)^2+2xc-2hc+c^2+(y-k)^2}$$

គេបាន ៖

$$\sqrt{(x-h)^2-2xc+2hc+c^2+(y-k)^2}=\pm 2a-\sqrt{(x-h)^2+2xc-2hc+c^2+(y-k)^2}$$

$$(x-h)^2-2xc+2hc+c^2+(y-k)^2=4a^2\mp 4a\sqrt{(x-h)^2+2xc-2hc+c^2+(y-k)^2}+(x-h)^2+2xc-2hc+c^2+(y-k)^2$$

$$-4xc+4hc=4a^2\mp 4a\sqrt{(x-h)^2+2xc-2hc+c^2+(y-k)^2}$$

$$a\sqrt{(x-h)^2+2xc-2hc+c^2+(y-k)^2}=a^2+xc-hc$$

$$a^2\left[(x-h)^2+2xc-2hc+c^2+(y-k)^2\right]=a^4+x^2c^2+h^2c^2+2a^2xc-2a^2hc-2xhc^2$$

$$a^2(x-h)^2+2a^2xc-2a^2hc+a^2c^2+a^2(y-k)^2=a^4+x^2c^2+h^2c^2+2a^2xc-2a^2hc-2xhc^2$$

$$a^2(x-h)^2+a^2c^2+a^2(y-k)^2=a^4+x^2c^2+h^2c^2-2xhc^2$$

$$a^2(x-h)^2+a^2c^2+a^2(y-k)^2=a^4+c^2(x-h)^2$$

$$a^2c^2-a^4=c^2(x-h)^2-a^2(x-h)^2-a^2(y-k)^2$$

$$a^2(c^2-a^2)=(c^2-a^2)(x-h)^2-a^2(y-k)^2 \quad , \quad b^2=c^2-a^2$$

$$a^2b^2=b^2(x-h)^2-a^2(y-k)^2$$

$$1=\frac{(x-h)^2}{a^2}-\frac{(y-k)^2}{b^2}$$

ដូចនេះ | សមីការស្តង់ដានៃអ៊ីពែបូលមានផ្ចិត $(h\ ,\ k)$ និងអ័ក្សទទឹងស្របនឹងអ័ក្សអាប់ស៊ីសគឺ $\dfrac{(x-h)^2}{a^2}-\dfrac{(y-k)^2}{b^2}=1$ | ។

**ខ. ស្រាយបញ្ជាក់ថា សមីការស្តង់ដានៃអ៊ីពែបូលមានផ្ចិត $(h\ ,\ k)$ និងអ័ក្សទទឹងស្របនឹងអ័ក្សអរដោនេគឺ** $\dfrac{(y-h)^2}{a^2}-\dfrac{(x-h)^2}{b^2}=1$

គេមាន អ៊ីពែបូលដែលមានផ្ចិត $(h\ ,\ k)$ និងអ័ក្សទទឹងស្របអ័ក្សអរដោនេ

គេបាន កំណុំ $F_1(h\ ,\ k+c)$ និង $F_2(h\ ,\ k-c)$

យក $P(x\ ,\ y)$ ជាចំណុចនៅលើអ៊ីពែបូល និងយក $b^2=c^2-a^2$




តាមនិយមន័យ អ៊ីពែបូល គេបាន $|F_1P-F_2P|=2a$

ឬ $F_1P-F_2P=\pm 2a$ ឬ $F_1P=\pm 2a+F_2P$

ដោយ

$$F_1P=\sqrt{(x-h)^2+[y-(k+c)]^2}$$
$$=\sqrt{(x-h)^2+[(y-k)-c]^2}$$
$$=\sqrt{(x-h)^2+(y-k)^2-2(y-k)c+c^2}$$
$$=\sqrt{(x-h)^2+(y-k)^2-2yc+2ck+c^2}$$

$$F_2P=\sqrt{(x-h)^2+[y-(k-c)]^2}$$
$$=\sqrt{(x-h)^2+[(y-k)+c]^2}$$
$$=\sqrt{(x-h)^2+(y-k)^2+2(y-k)c+c^2}$$
$$=\sqrt{(x-h)^2+(y-k)^2+2yc-2ck+c^2}$$

គេបាន ៖

$$\sqrt{(x-h)^2+(y-k)^2-2yc+2ck+c^2}=\pm 2a-\sqrt{(x-h)^2+(y-k)^2+2yc-2ck+c^2}$$

$$(x-h)^2+(y-k)^2-2yc+2ck+c^2=4a^2\mp 4a\sqrt{(x-h)^2+(y-k)^2+2yc-2ck+c^2}+(x-h)^2+(y-k)^2+2yc-2ck+c^2$$

$$-4yc+4ck=4a^2\mp 4a\sqrt{(x-h)^2+(y-k)^2+2yc-2ck+c^2}$$

$$\pm a\sqrt{(x-h)^2+(y-k)^2+2yc-2ck+c^2}=a^2+yc-ck$$

$$a^2\left[(x-h)^2+(y-k)^2+2yc-2ck+c^2\right]=a^4+y^2c^2+c^2k^2+2a^2yc-2a^2ck-2ykc^2$$

$$a^2(x-h)^2+a^2(y-k)^2+2a^2yc-2a^2ck+a^2c^2=a^4+y^2c^2+c^2k^2+2a^2yc-2a^2ck-2ykc^2$$

$$a^2(x-h)^2+a^2(y-k)^2+a^2c^2=a^4+y^2c^2+c^2k^2-2ykc^2$$

$$a^2(x-h)^2+a^2(y-k)^2+a^2c^2=a^4+c^2(y-k)^2$$

$$a^2c^2-a^4=+c^2(y-k)^2-a^2(y-k)^2-a^2(x-h)^2$$

$$a^2(c^2-a^2)=(c^2-a^2)(y-k)^2-a^2(x-h)^2 \quad , \quad b^2=c^2-a^2$$

$$a^2b^2=b^2(y-k)^2-a^2(x-h)^2$$

$$1=\frac{(y-k)^2}{a^2}-\frac{(x-h)^2}{b^2}$$

ដូចនេះ: | សមីការស្តង់ដានៃអ៊ីពែបូលមានផ្ចិត $(h\,,\,k)$ និងអ័ក្សទទឹងស្របនឹងអ័ក្សអរដោនេគឺ $\frac{(y-h)^2}{a^2}-\frac{(x-h)^2}{b^2}=1$ | ។

12. ស្រាយបញ្ជាក់ថា អ៊ីពែបូលមានសមីការទូទៅ $Ax^2+By^2+Cx+Dy+E=0$ ដែល $AB<0$ បានពីសម្រួលរាងសមីការស្តង់ដា

គេពន្លាតសមីការស្តង់ដា $\frac{(x-h)^2}{a^2}-\frac{(y-k)^2}{b^2}=1$ គេបាន ៖

$$b^2(x-h)^2-a^2(y-k)^2=a^2b^2$$

$$b^2(x^2-2xh+h^2)-a^2(y^2-2yk+k^2)=a^2b^2$$

$$b^2x^2-2b^2xh+b^2h^2-a^2y^2+2a^2yk-a^2k^2=a^2b^2$$

$$b^2x^2-a^2y^2-2b^2xh+2a^2yk+b^2h^2-a^2k^2-a^2b^2=0$$

គេពន្លាតសមីការស្តង់ដា $\frac{(y-h)^2}{a^2}-\frac{(x-h)^2}{b^2}=1$ គេបាន ៖

$$b^2(y-k)^2-a^2(x-h)^2=a^2b^2$$

$$b^2(y^2-2yk+k^2)-a^2(x^2-2xh+h^2)=a^2b^2$$

$$b^2y^2-2b^2yh+b^2k^2-a^2x^2+2a^2xh-a^2h^2=a^2b^2$$

$$-a^2x^2+b^2y^2+2a^2xh-2b^2yh+b^2k^2-a^2h^2-a^2b^2=0$$

ក្រោយពីពន្លាតសមីការស្តង់ដានីមួយៗ គេបានសមីការមានរាងទូទៅ $Ax^2+By^2+Cx+Dy+E=0$ ដែលមាន

$A\cdot B=b^2(-a^2)=(-a^2)b^2<0$ ព្រោះ $a^2b^2>0$ និង $a\neq 0\,,\,b\neq 0$

ដូចនេះ: | អ៊ីពែបូលមានសមីការទូទៅ $Ax^2+By^2+Cx+Dy+E=0$ ដែល $AB<0$ បានពីសម្រួលរាងសមីការស្តង់ដា | ។

# រង្វង់

## 1. និយមន័យរង្វង់

រង្វង់ ជាសំណុំចំណុចជាច្រើននៅក្នុងប្លង់មួយ ដែលស្ថិតនៅស្មើចម្ងាយពីចំណុចនឹងមួយ ដែលចំណុចនឹងនោះ ហៅថា ផ្ចិតរង្វង់ ។



## 2. លក្ខណៈនៃរង្វង់

លក្ខណៈនៃរង្វង់រួមមានដូចខាងក្រោមៈ

- កាំរង្វង់ $OA = OB = OC$ (អង្កត់ភ្ជាប់ពីផ្ចិតទៅខ្សែរង្វង់)
- អង្កត់ធ្នូ $BC$ (អង្កត់ដែលភ្ជាប់ពីចំណុច $B$ ទៅចំណុច $C$)
- អង្កត់ផ្ចិត $AB$ (អង្កត់ធ្នូវែងជាងគេ ឬអង្កត់ដែលគូសកាត់ផ្ចិតរង្វង់)
- ផ្ចិត $O$ (ជាចំណុចផ្ចិតឆ្លុះនៃរង្វង់ ឬចំណុចកណ្តាលនៃរង្វង់)
- ធ្នូ $BC$ (ជាប្រវែងខ្សែកោង $BC$ ដែលខណ្ឌដោយអង្កត់ធ្នូ $BC$)
- មុំផ្ចិត $\alpha$ (មុំមានកំពូលនៅលើផ្ចិតរង្វង់)
- មុំក្នុងរង្វង់ ឬមុំជុំវិញផ្ចិតមានរង្វាស់ស្មើនឹង $360°$ ។
- រង្វង់គ្មានផ្ទៃទេ វាដូចជាកងដៃ តែថាសទើបមានផ្ទៃ ។
- រង្វង់មានផ្ចិតឆ្លុះមួយ គឺជាចំណុចផ្ចិតរបស់វា ។ គ្រប់អង្កត់ផ្ចិត ជាអ័ក្សឆ្លុះនៃរង្វង់ ។




## 3. ទំនាក់ទំនងក្នុងរង្វង់

- កាំតាងដោយ $R$ (ជាវិមាត្រនៃរង្វង់)
- អង្កត់ផ្ចិតតាងដោយ $D$ ដែល $D = 2R$
- បរិមាត្ររង្វង់តាងដោយ $P$ ដែល $P = 2\pi R$ ឬ $P = \pi D$
- ផ្ទៃថាសតាងដោយ $S$ ដែល $S = \pi R^2$ ឬ $S = \dfrac{\pi D^2}{4}$
- ប្រវែងធ្នូ $BC$ មានរូបមន្តៈ $\overset{\frown}{BC} = 2\pi R \times \dfrac{\alpha^o}{360^o}$ ឬ $\overset{\frown}{BC} = P \times \dfrac{\alpha^o}{360^o}$
- ផ្ទៃចម្រៀកថាសមានរូបមន្ត $s = \pi R^2 \times \dfrac{\alpha^o}{360^o}$




## 4. ទីតាំងនៃរង្វង់ពីរ

**១. រង្វង់កាត់គ្នាៈ** រង្វង់ពីរកាត់គ្នាគេបានចំណុចប្រសព្វពីរ។ ច្រាសមកវិញ កាលណារង្វង់ពីរមានចំណុចប្រសព្វពីរ មានន័យថារង្វង់ទាំងពីរកាត់គ្នា។




**២-រង្វង់ប៉ះគ្នាៈ** រង្វង់ពីរប៉ះគ្នា គេបានចំណុចរួមមួយ គឺចំណុចប៉ះ ។ រង្វង់ពីរប៉ះគ្នាមានពីរករណី គឺរង្វង់ប៉ះក្នុង និងរង្វង់ប៉ះក្រៅ។



**៣-រង្វង់គ្មានចំណុចប្រសព្វៈ** រង្វង់គ្មានចំណុចប្រសព្វ មានន័យថា រង្វង់គ្មានចំណុចរួមគ្នានៃខ្សែរង្វង់។




www.facebook.com/7khmer
fb : Entertainment And Knowledge

## 5. ទីតាំងនៃបន្ទាត់ និងរង្វង់

មានរង្វង់ផ្ចិត $O$ កាំ $R$ មួយ និងបន្ទាត់ $\ell$ មួយ ។ យើងមានបីករណីដូចខាងក្រោម ៖

| គ្មានចំណុចប្រសព្វ | មានចំណុចប្រសព្វ ១ | មានចំណុចប្រសព្វ ២ |
|---|---|---|
|  |  |  |
| ➢ $OH > R$<br>បន្ទាត់ $\ell$ និងរង្វង់គ្មានចំណុចរួម ។<br>គេថា បន្ទាត់ $\ell$ នៅខាង ***ក្រៅរង្វង់*** ។ | ➢ $OH = R$<br>បន្ទាត់ $\ell$ និងរង្វង់មានចំណុចរួមមួយ ។<br>គេថា បន្ទាត់ $\ell$ ***ប៉ះរង្វង់*** ហើយកែងនឹងកាំរង្វង់ $[OH]$ ត្រង់ $H$ ។ | ➢ $OH < R$<br>បន្ទាត់ $\ell$ និងរង្វង់មានចំណុចរួមពីរត្រង់ $A$ និង $B$ ។<br>គេថា បន្ទាត់ $\ell$ ***កាត់រង្វង់*** ។ |

## 6. លក្ខណៈនៃបន្ទាត់ប៉ះនឹងធ្នូ

> បើបន្ទាត់ប៉ះរង្វង់ស្របទៅនឹងអង្កត់ធ្នូមួយ
> នោះចំណុចប៉ះចែកធ្នូសន្ទឹងជាពីរផ្នែកប៉ុនគ្នា ។

☑ **សម្រាយបញ្ជាក់**




គេឱ្យបន្ទាត់ $EF$ ប៉ះរង្វង់ $O$ ត្រង់ចំណុច $C$ ។ អង្កត់ធ្នូ $AB$ ស្របនឹងបន្ទាត់ $EF$ ។ ស្រាយបញ្ជាក់ថា $\overset{\frown}{AC} = \overset{\frown}{BC}$ ។

**ស្រាយបញ្ជាក់** : ដោយ $EF$ ប៉ះរង្វង់ត្រង់ចំណុច $C$ នោះ

$OC \perp EF$ និង $AB \parallel EF$ នាំឱ្យ $OC \perp AB$

ដោយកាំរង្វង់ត្រូវកែងនឹងអង្កត់ធ្នូត្រង់ចំណុចកណ្ដាលជានិច្ច

នោះ $OC$ ជាមេដ្យាទ័រនៃអង្កត់ $AB$ គេបាន $AC = BC$ ឬ $\overset{\frown}{AC} = \overset{\frown}{BC}$ ។

## 7. បន្ទាត់ប៉ះពីរដែលគូសចេញពីចំណុចរួមមួយ នៅក្រៅរង្វង់

> បើបន្ទាត់ពីរគូសចេញពីចំណុចរួម $A$ មួយនៅក្រៅរង្វង់
> មានផ្ចិត $O$ ហើយប៉ះរង្វង់នេះត្រង់ $B$ និង $C$ គេបាន ៖
> $AB = AC$ , $\angle OAB = \angle OAC$ , $\angle BOA = \angle COA$




☑ **សម្រាយបញ្ជាក់**

ដោយ $AB$ , $AC$ ជាបន្ទាត់ប៉ះរង្វង់ត្រង់ $B$ , $C$ រៀងគ្នា នោះ $OB \perp AB$ និង $OC \perp AC$

គេបាន $OAB$ និង $OAC$ ជាត្រីកោណកែងដែលមាន ៖

-ជ្រុង $OA$ ជាអ៊ីប៉ូតេនុសរួមគ្នា

-ជ្រុង $OB = OC$ ជាកាំរង្វង់តែមួយ

នាំឱ្យ $OAB \cong OAC$ តាមលក្ខខណ្ឌទី២ អ.ជ

វិបាក $\cong \begin{array}{c|} OAB \\ OAC \end{array} \Rightarrow \boxed{AB = AC \ , \ \angle OAB = \angle OAC \ , \ \angle BOA = \angle COA}$



www.facebook.com/7khmer
fb : Entertainment And Knowledge

## 8. ចតុកោណចារឹកក្រៅរង្វង់



> ក្នុងចតុកោណចារឹកក្រៅរង្វង់មួយ
> មានផលបូករង្វាស់ជ្រុងឈមស្មើគ្នា
> $AB+CD=BC+AD$ ។

☑ **សម្រាយបញ្ជាក់**



តាង $x , y , z , t$ ជាចំណុចដែលចតុកោណប៉ះរង្វង់

តាមលក្ខណៈបន្ទាត់ប៉ះគេបាន ៖

$Ax = At \quad , \quad Bx = By$

$Cy = Cz \quad , \quad Dz = Dt$

គេបាន $\quad AB+CD = Ax+Bx+Cz+Dz$

$$= At+By+Cy+Dt$$

$$=(At+Dt)+(By+Cy)$$

$$= AD+BC$$

ដូចនេះ $\boxed{AB+CD=BC+AD}$ ។

## 9. មុំផ្ចិត



> មុំផ្ចិត ជាមុំដែលមានកំពូលនៅលើផ្ចិតរង្វង់ ។
> រង្វាស់មុំផ្ចិតស្មើនឹងរង្វាស់ធ្នូស្កាត់ ។ $\boxed{\angle O = \overset{\frown}{AB}}$

☑ **ស្រាយបញ្ជាក់** : មុំផ្ចិតមានរង្វាស់ស្មើនឹងធ្នូស្កាត់របស់វា

ដោយមុំផ្ចិតមានរង្វាស់ 360° និងធ្នូរង្វង់មានរង្វាស់ 360° ដែរ

ដូចនេះ មុំផ្ចិតត្រូវមានរង្វាស់ស្មើនឹងធ្នូស្កាត់នៃមុំផ្ចិតនោះដែរ ។

## 10. មុំចារឹក



> មុំចារឹក ជាមុំដែលមានកំពូលនៅលើរង្វង់ ហើយជ្រុង
> ពីរទៀតកាត់រង្វង់ ។ រង្វាស់មុំចារឹកស្មើកន្លះធ្នូស្កាត់។
> $\boxed{\angle C = \dfrac{\overset{\frown}{AB}}{2}}$

☑ **ស្រាយបញ្ជាក់ថា** $\angle C = \dfrac{\overset{\frown}{AB}}{2}$

គេមានបីករណីដូចខាងក្រោម ដើម្បីបង្ហាញថាមុំចារឹកមានរង្វាស់ស្មើនឹងពាក់កណ្ដាលធ្នូស្កាត់របស់វា ៖

* **ករណីជ្រុងមុំកាត់ផ្ចិត**



គូសភ្ជាប់ $OA$ គេបាន $AOC$ ជាត្រីកោណសមបាទ ដែល $\angle A = \angle C$

ហើយ $\angle C + \angle A = \angle AOB$ ឬ $2\angle C = \angle AOB$ ព្រោះ $\angle A = \angle C$

ដោយ $\angle AOB = \overset{\frown}{AB}$ នោះ $2\angle C = \overset{\frown}{AB}$ ទាញបាន $\angle C = \dfrac{\overset{\frown}{AB}}{2}$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

* **ករណីផ្ចិតរង្វង់នៅក្នុងមុំ**




គូសអង្កត់ផ្ចិត $CD$ គេបាន $\angle ACB = \angle ACD + \angle BCD$

តាមករណីទី១ ខាងលើ $\angle ACD = \frac{1}{2}\overset{\frown}{AD}$ និង $\angle BCD = \frac{\overset{\frown}{BD}}{2}$

នាំឱ្យ $\angle ACB = \frac{\overset{\frown}{AD}}{2} + \frac{\overset{\frown}{BD}}{2} = \frac{\overset{\frown}{AD} + \overset{\frown}{BD}}{2} = \frac{\overset{\frown}{AB}}{2}$ ឬ $\angle C = \frac{\overset{\frown}{AB}}{2}$ ។

* **ករណីផ្ចិតរង្វង់នៅក្រៅមុំ**




គូសអង្កត់ផ្ចិត $CD$ គេបាន $\angle ACB = \angle ACD - \angle BCD$

តាមករណីទី១ ខាងលើ $\angle ACD = \frac{\overset{\frown}{AD}}{2}$ និង $\angle BCD = \frac{\overset{\frown}{BD}}{2}$

នាំឱ្យ $\angle ACB = \frac{\overset{\frown}{AD}}{2} - \frac{\overset{\frown}{BD}}{2} = \frac{\overset{\frown}{AD} - \overset{\frown}{BD}}{2} = \frac{\overset{\frown}{AB}}{2}$ ឬ $\angle C = \frac{\overset{\frown}{AB}}{2}$ ។

## 11. មុំចារឹកកន្លះរង្វង់




> មុំចារឹកកន្លះរង្វង់ ជាមុំដែលមានកំពូលនៅលើរង្វង់ ហើយជ្រុងទាំងពីរកាត់រង្វង់ ដែលចំណុចកាត់ទាំងពីរភ្ជាប់បានជាអង្កត់ផ្ចិតនៃរង្វង់ ។ មុំចារឹកកន្លះរង្វង់មានរង្វាស់ស្មើនឹង $90^\circ$ ។

☑ **សម្រាយបញ្ជាក់**




ស្រាយបញ្ជាក់ថា មុំចារឹកកន្លះរង្វង់មានរង្វាស់ស្មើ $90^\circ$

ដោយ $BC$ ជាអង្កត់ផ្ចិត មុំផ្ចិត $\angle BOC = \overset{\frown}{BC} = 180^\circ$

មុំ $\angle A$ ជាមុំចារឹកមានធ្នូស្កាត់ $\overset{\frown}{BC}$ នាំឱ្យ $\angle A = \frac{\overset{\frown}{BC}}{2} = \frac{180^\circ}{2} = 90^\circ$ ។

## 12. មុំចារឹកពិសេស




> មុំចារឹកពិសេស គឺជាមុំដែលកើតដោយកន្លះបន្ទាត់ប៉ះ និងខ្នាត់គូសចេញពីចំណុចប៉ះ។ រង្វាស់មុំចារឹកពិសេសស្មើកន្លះធ្នូស្កាត់ ។
>
> $$\angle A = \frac{\overset{\frown}{AB}}{2}$$

☑ **សម្រាយបញ្ជាក់**




ស្រាយបញ្ជាក់ថា រង្វាស់មុំចារឹកពិសេសស្មើកន្លះធ្នូស្កាត់

គូសអង្កត់ធ្នូ $BC$ ឱ្យស្របនឹងបន្ទាត់ប៉ះ នោះគេបាន ៖

$\angle xAB = \angle ABC$ (មុំឆ្លាស់ក្នុង) និងធ្នូ $\overset{\frown}{AB} = \overset{\frown}{AC}$

ដោយ $\angle ABC = \frac{\overset{\frown}{AC}}{2} = \frac{\overset{\frown}{AB}}{2}$

នាំឱ្យ $\angle xAB = \frac{\overset{\frown}{AB}}{2}$ ឬ $\angle A = \frac{\overset{\frown}{AB}}{2}$ ។

## 13. មុំក្នុងរង្វង់

មុំក្នុងរង្វង់ គឺជាមុំដែលមានកំពូលនៅខាងក្នុងនៃរង្វង់ ហើយជ្រុង និងបន្លាយនៃជ្រុងកាត់រង្វង់ ។ មុំក្នុងរង្វង់មានរង្វាស់ស្មើកន្លះនៃផលបូកធ្នូស្កាត់មុំនោះ និងធ្នូដែលស្កាត់បន្លាយជ្រុងនៃមុំនោះ។

$$\angle I = \frac{\overset{\frown}{AB}+\overset{\frown}{CD}}{2}$$




☑ **សម្រាយបញ្ជាក់**

ស្រាយបញ្ជាក់ថា មុំក្នុងរង្វង់មានរង្វាស់ស្មើកន្លះនៃផលបូកធ្នូស្កាត់មុំនោះ និងធ្នូដែលស្កាត់បន្លាយជ្រុងនៃមុំនោះ




គូសភ្ជាប់អង្កត់ធ្នូ $AC$ នោះ $ACI$ ជាត្រីកោណដែលមាន

$\angle CID = \angle ACB + \angle CAD$ (មុំក្រៅនៃត្រីកោណ)

តែ $\angle ACB = \frac{\overset{\frown}{AB}}{2}$ , $\angle CAD = \frac{\overset{\frown}{CD}}{2}$

នាំឱ្យ $\angle CID = \frac{\overset{\frown}{AB}}{2} + \frac{\overset{\frown}{CD}}{2} = \frac{\overset{\frown}{AB}+\overset{\frown}{CD}}{2}$ ឬ $\angle I = \frac{\overset{\frown}{AB}+\overset{\frown}{CD}}{2}$ ។

## 14. មុំក្រៅរង្វង់

មុំក្រៅរង្វង់ ជាមុំដែលមានកំពូលនៅខាងក្រៅនៃរង្វង់ ហើយជ្រុងរបស់វាកាត់រង្វង់។ មុំក្រៅរង្វង់ មានរង្វាស់ស្មើកន្លះនៃផលដកធ្នូស្កាត់ទាំងពីរនៃមុំនោះ។

$$\angle P = \frac{\overset{\frown}{CD}-\overset{\frown}{AB}}{2}$$




☑ **សម្រាយបញ្ជាក់**

ស្រាយបញ្ជាក់ថា មុំក្រៅរង្វង់ មានរង្វាស់ស្មើកន្លះនៃផលដកធ្នូស្កាត់ ទាំងពីរនៃមុំនោះ




គូសភ្ជាប់អង្កត់ធ្នូ $BC$ នោះ $PBC$ ជាត្រីកោណមាន

$\angle CPB + \angle BCP = \angle CBD$ (មុំក្រៅត្រីកោណ)

នាំឱ្យ $\angle CPB = \angle CBD - \angle BCP$

តែ $\angle CBD = \frac{\overset{\frown}{CD}}{2}$ , $\angle BCP = \angle BCA = \frac{\overset{\frown}{AB}}{2}$

គេបាន $\angle CPB = \frac{\overset{\frown}{CD}}{2} - \frac{\overset{\frown}{AB}}{2} = \frac{\overset{\frown}{CD}-\overset{\frown}{AB}}{2}$ ឬ $\angle P = \frac{\overset{\frown}{CD}-\overset{\frown}{AB}}{2}$



www.facebook.com/7khmer
fb : Entertainment And Knowledge

## 15. អង្កត់ធ្នូ និងធ្នូ

- ➢ អង្កត់ធ្នូ ជាអង្កត់ដែលគូសភ្ជាប់ពីរចំណុចនៅលើរង្វង់ ។ អង្កត់ធ្នូកំណត់បានធ្នូសន្ទឹង ។
- ➢ អង្កត់ធ្នូដែលវែងជាងគេត្រូវកាត់តាមផ្ចិតនៃរង្វង់ គេហៅថាអង្កត់ផ្ចិត ។
- ➢ អង្កត់ផ្ចិត គឺត្រូវកែងនឹងអង្កត់ធ្នូ ត្រង់ចំណុចកណ្តាល ។
- ➢ អង្កត់ធ្នូកាន់តែវែង គឺកាន់តែនៅជិតផ្ចិត ។
- ➢ អង្កត់ធ្នូកាន់តែវែង កំណត់បានធ្នូសន្ទឹងកាន់តែធំ ។
- ➢ ធ្នូ ជាកំណោងនៃរង្វង់ដែលកំណត់ដោយអង្កត់ធ្នូ ។
- ➢ ធ្នូពីរនៅចន្លោះអង្កត់ធ្នូស្របគ្នា ជាធ្នូប៉ុនគ្នា ។

## 16. ទំនាក់ទំនងរវាងអង្កត់ធ្នូ និងធ្នូ

ក្នុងរង្វង់តែមួយ ឬរង្វង់ពីរប៉ុនគ្នា បើអង្កត់ធ្នូប៉ុនគ្នា នោះធ្នូដែលកំណត់ដោយអង្កត់ធ្នូទាំងពីរក៏ប៉ុនគ្នាដែរ ។
$AB = CD$ នោះ $\overset{\frown}{AB} = \overset{\frown}{CD}$




☑ **សម្រាយបញ្ជាក់**

គេភ្ជាប់ $OA$ , $OB$ , $OC$ និង $OD$ គេបាន ៖

$OAB$ និង $OCD$ ជាត្រីកោណដែលមាន ៖

-ជ្រុង $OA = OC$ (កាំរង្វង់តែមួយ)

-ជ្រុង $OB = OD$ (កាំរង្វង់តែមួយ)

-ជ្រុង $AB = CD$ (សម្មតិកម្ម)




នាំឱ្យ $\Delta OAB \cong \Delta OCD$ តាមលក្ខខណ្ឌទី៣ ជ.ជ.ជ

វិបាក $\cong \left.\begin{matrix}\Delta OAB \\ \Delta OCD\end{matrix}\right| \Rightarrow \angle AOB = \angle COD$ (ជាមុំផ្ចិតដូចគ្នា)

តែ $\angle AOB = \overset{\frown}{AB}$ , $\angle COD = \overset{\frown}{CD}$ (ធ្នូស្ទាត់ និងមុំផ្ចិតមានរង្វាស់ស្មើគ្នា)

នាំឱ្យ $\overset{\frown}{AB} = \overset{\frown}{CD}$ ។ ដូចនេះ បើធ្នូ $AB = CD$ នោះ $\boxed{\overset{\frown}{AB} = \overset{\frown}{CD}}$ ។

## 17. ការកំណត់រង្វង់

| មួយចំណុច $A$ | ពីរចំណុច $A$ និង $B$ | បីចំណុច $A$ , $B$ និង $C$ |
|---|---|---|
|   ➢តាមចំណុច $A$ មួយគេអាចគូសរង្វង់បានច្រើនរាប់មិនអស់ ។ |   ➢តាមពីរចំណុច $A$ និង $B$ គេអាចគូសរង្វង់បានច្រើនរាប់មិនអស់ ដែលមានផ្ចិតឋិតនៅលើបន្ទាត់តែមួយ ។ |   ➢តាមបីចំណុច $A$ , $B$ , $C$ គេអាចគូសរង្វង់បានតែ មួយគត់ ។ |



www.facebook.com/7khmer
fb : Entertainment  And Knowledge

## 18. សមីការស្តង់ដានៃរង្វង់

➢ សមីការស្តង់ដានៃរង្វង់ដែលមានផ្ចិត $O(0,0)$ និងកាំ $r$ គឺ :

$\boxed{x^2+y^2=r^2}$ ។

☑ **សម្រាយបញ្ជាក់**




តាង $P(x,y)$ ជាចំណុចនៅលើរង្វង់ គេបាន $OP=r$ ឬ $OP^2=r^2$

ចម្ងាយពី $O$ ទៅ $P$ កំណត់ដោយ $OP=\sqrt{(x-x_O)^2+(y-y_O)^2}$

នាំឱ្យ $OP^2=x^2+y^2$ គេបាន $x^2+y^2=r^2$

ដូចនេះ សមីការស្តង់ដារង្វង់មានផ្ចិត $O(0,0)$ កាំ $r$ គឺ $x^2+y^2=r^2$ ។

➢ សមីការស្តង់ដានៃរង្វង់ដែលមានផ្ចិត $I(a,b)$ និងកាំ $r$ គឺ :

$\boxed{(x-a)^2+(y-b)^2=r^2}$ ។

☑ **សម្រាយបញ្ជាក់**




តាង $P(x,y)$ ជាចំណុចនៅលើរង្វង់ គេបាន $IP=r$ ឬ $IP^2=r^2$

ចម្ងាយពី $I$ ទៅ $P$ កំណត់ដោយ $IP=\sqrt{(x-a)^2+(y-b)^2}$

នាំឱ្យ $IP^2=(x-a)^2+(y-b)^2$ គេបាន $(x-a)^2+(y-b)^2=r^2$

ដូចនេះ សមីការស្តង់ដារង្វង់មានផ្ចិត $I(a,b)$ កាំ $r$ គឺ $(x-a)^2+(y-b)^2=r^2$ ។

## 19. សមីការទូទៅនៃរង្វង់

➢ សមីការទូទៅនៃរង្វង់គឺ $\boxed{x^2+y^2+Ax+By+C=0}$ ។

☑ **សម្រាយបញ្ជាក់**

គេមានសមីការស្តង់ដានៃរង្វង់គឺ $(x-a)^2+(y-b)^2=r^2$

គេបាន $$x^2-2ax+a^2+y^2-2by+b^2=r^2$$

$$x^2+y^2-2ax-2by+a^2+b^2-r^2=0$$

បើតាង $A=-2a$ , $B=-2b$ , $C=a^2+b^2-r^2$

នាំឱ្យគេបាន $x^2+y^2+Ax+By+C=0$

ដូចនេះ សមីការទូទៅនៃរង្វង់មានទម្រង់ $\boxed{x^2+y^2+Ax+By+C=0}$ ។




www.facebook.com/7khmer
fb : Entertainment And Knowledge

## 20. ការស្រាយបញ្ជាក់រូបមន្តក្រឡាផ្ទៃថាស

☑ **សម្រាយបញ្ជាក់ ១** : ការប្រើវិធីអព្ភន្តរញាណ (ប្រើប្រាស់រូបបង្ហាញ)

គូសរង្វង់កាំ $R$ នៅលើក្រដាសកាតុង រួចកាត់ថាសឱ្យបានជាចម្រៀកស្មើៗគ្នា (កាន់តែច្រើនកាន់តែល្អ) ដូចបង្ហាញក្នុងរូបទី១



(រូបទី១)

យកចម្រៀកថាសដែលកាត់បាន រៀបជារាងចតុកោណកែង ដូចរូបទី២ ដែលមានបណ្តោយ $\pi R$ និងទទឹង $R$ ។

(កាត់កាន់តែច្រើនចម្រៀក កាន់តែមានរាងជាចតុកោណកែង)



(រូបទី២)

គេបាន ផ្ទៃថាស $S =$ ផ្ទៃចតុកោណកែង

$=$ បណ្តោយ $\times$ ទទឹង

$= \pi R \times R = \pi R^2$

ដូចនេះ ក្រឡាផ្ទៃថាសដែលមានកាំ $R$ កំណត់ដោយ $\boxed{S = \pi R^2}$ ។

☑ **សម្រាយបញ្ជាក់ ២** : ការប្រើវិធីអាំងតេក្រាល

គេមាន សមីការរង្វង់ដែលមានផ្ចិតជាគល់តម្រុយមានរាង $x^2 + y^2 = R^2$

គេបាន $y^2 = R^2 - x^2$ ឬ $y = \sqrt{R^2 - x^2}$ (គិតតែ $y > 0$)

គណនាក្រឡាផ្ទៃក្នុងកាដ្រង់ទី១ រួចគុណនឹង 4 គេនឹងបានផ្ទៃថាសទាំងមូល




$S = 4\int_0^R \sqrt{R^2 - x^2}\,dx$ (ជាក្រឡាផ្ទៃថាស)

តាង $x = R\sin t$ នាំឱ្យ $dx = R\cos t\,dt$

បើ $x = 0$ នោះ $t = 0$ , បើ $x = R$ នោះ $t = \frac{\pi}{2}$

$$S = 4\int_0^{\frac{\pi}{2}} \sqrt{R^2 - R^2\sin^2 t}\cdot R\cos t\,dt$$

$$= 4\int_0^{\frac{\pi}{2}} \sqrt{R^2\left(1 - \sin^2 t\right)}\cdot R\cos t\,dt$$

$$= 4\int_0^{\frac{\pi}{2}} \sqrt{R^2\cos^2 t}\cdot R\cos t\,dt$$

$$= 4\int_0^{\frac{\pi}{2}} R^2\cos^2 t\,dt$$

$$= 4R^2\int_0^{\frac{\pi}{2}} \frac{1 + \cos 2t}{2}\,dt$$

$$= 2R^2\int_0^{\frac{\pi}{2}} \left(1 + \cos 2t\right)dt$$

$$= 2R^2\left[t + \frac{1}{2}\sin 2t\right]_0^{\frac{\pi}{2}}$$

$$= 2R^2\left(\left[\frac{\pi}{2} + \frac{1}{2}\sin\pi\right] - \left[0 + \frac{1}{2}\sin 0\right]\right)$$

$$= \boxed{\pi R^2}$$



www.facebook.com/7khmer
fb : Entertainment  And Knowledge

☑ **សម្រាយបញ្ជាក់ ៣** : ការប្រើវិធីលីមីត

គេមានពហុកោណនិយ័តមាន $n$ ជ្រុងចារឹកក្នុងរង្វង់ ។ ផ្ទៃនៃពហុកោណនិយ័តនេះ
បានពី $n$ ដងនៃផ្ទៃត្រីកោណ ដែលបានចាក់ពណ៌ដូចរូបខាងស្តាំ ។

-ផ្ទៃត្រីកោណមួយនៃពហុកោណនិយ័ត

$$S_1=\frac{1}{2}Rh=\frac{1}{2}R\times R\sin\frac{2\pi}{n}=\frac{1}{2}R^2\sin\frac{2\pi}{n}$$

-ផ្ទៃនៃពហុកោណនិយ័តដែលមាន $n$ ជ្រុង គឺ $S_2=nS_1$ ឬ $S_2=\frac{1}{2}R^2n\sin\frac{2\pi}{n}$

-នៅពេល $n\to+\infty$ នោះផ្ទៃនៃពហុកោណនិយ័តក្លាយទៅជាផ្ទៃក្រឡានៃរង្វង់មានកាំ $R$

គេបាន ផ្ទៃក្រឡារង្វង់ $S=\lim\limits_{n\to+\infty}S_2=\lim\limits_{n\to+\infty}\left(\frac{1}{2}R^2n\sin\frac{2\pi}{n}\right)$

$$=\frac{1}{2}R^2\lim_{n\to+\infty}\left(n\sin\frac{2\pi}{n}\right)$$




តាង $t=\frac{1}{n}$ នោះ $n=\frac{1}{t}$

បើ $n\to+\infty$ នោះ $t\to0$

$$S=\frac{1}{2}R^2\cdot\lim_{t\to0}\left(\frac{1}{t}\sin2\pi t\right)$$

$$=\frac{1}{2}R^2\cdot\lim_{t\to0}\left(\frac{\sin2\pi t}{t}\right)$$

$$=\frac{1}{2}R^2\cdot\lim_{t\to0}\left(\frac{\sin2\pi t}{2\pi t}\times2\pi\right)$$

$$=\frac{1}{2}R^2(1\times2\pi)=\boxed{\pi R^2}$$

## 21. ចតុកោណចារឹកក្នុងរង្វង់




> ចតុកោណចារឹកក្នុងរង្វង់មួយ ផលបូករង្វាស់មុំឈមស្មើនឹង 180° ។
>
> $\angle A+\angle C=\angle B+\angle D=180^\circ$

☑ **សម្រាយបញ្ជាក់** :

ដោយ $\angle A=\frac{\overset{\frown}{BCD}}{2}$ , $\angle C=\frac{\overset{\frown}{BAD}}{2}$ និង $\overset{\frown}{BCD}+\overset{\frown}{BAD}=360^\circ$

នាំឱ្យ $\angle A+\angle C=\frac{\overset{\frown}{BCD}}{2}+\frac{\overset{\frown}{BAD}}{2}=\frac{\overset{\frown}{BCD}+\overset{\frown}{BAD}}{2}=\frac{360^\circ}{2}=180^\circ$

ដូចគ្នាដែរ $\angle B=\frac{\overset{\frown}{ADC}}{2}$ , $\angle D=\frac{\overset{\frown}{ABC}}{2}$ និង $\overset{\frown}{ADC}+\overset{\frown}{ABC}=360^\circ$

នាំឱ្យ $\angle B+\angle D=\frac{\overset{\frown}{ADC}}{2}+\frac{\overset{\frown}{ABC}}{2}=\frac{\overset{\frown}{ADC}+\overset{\frown}{ABC}}{2}=\frac{360^\circ}{2}=180^\circ$

ដូចនេះ $\boxed{\angle A+\angle C=\angle B+\angle D=180^\circ}$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

## 22. សមីការបន្ទាត់ប៉ះរង្វង់

> សមីការបន្ទាត់ប៉ះរង្វង់ $x^2+y^2=r^2$ ត្រង់ចំណុច $P(x_0\ ,\ y_0)$
> មានរាង ៖ $\boxed{x_0x+y_0y=r^2}$ ។

☑ **សម្រាយបញ្ជាក់** :

គេមាន សមីការរង្វង់ $x^2+y^2=r^2$ (ធ្វើដេរីវេធៀបនឹង $x$ លើអង្គទាំងពីរ)

$$2x+2y'y=0 \Rightarrow y'=-\frac{x}{y} \text{ ឬ } y'(x_0)=-\frac{x_0}{y_0}$$




សមីការបន្ទាត់ប៉ះមានរាង $y=y'(x_0)(x-x_0)+y_0$

$$=-\frac{x_0}{y_0}(x-x_0)+y_0=\frac{-x_0x+x_0^2}{y_0}+y_0$$

$$=\frac{-x_0x+x_0^2+y_0^2}{y_0}$$

$$y_0y=-x_0x+x_0^2+y_0^2$$

$$x_0x+y_0y=x_0^2+y_0^2$$

ដោយ $P(x_0\ ,\ y_0)$ ជាចំណុចនៅលើរង្វង់ នោះវាផ្ទៀងផ្ទាត់ $x_0^2+y_0^2=r^2$

ដូចនេះ សមីការបន្ទាត់ប៉ះរង្វង់អាចសរសេរ $\boxed{x_0x+y_0y=r^2}$ ។

## 23. សមីការបន្ទាត់ប៉ះរង្វង់

> សមីការបន្ទាត់ប៉ះរង្វង់ $(x-a)^2+(y-b)^2=r^2$ ត្រង់ចំណុច
> $P(x_0\ ,\ y_0)$ មានរាង ៖ $\boxed{(x_0-a)(x-a)+(y_0-b)(y-b)=r^2}$ ។

☑ **សម្រាយបញ្ជាក់** :

គេមាន $(x-a)^2+(y-b)^2=r^2$ (ធ្វើដេរីវេលើអង្គទាំងពីរធៀបនឹង $x$)

គេបាន $2(x-a)+2y'(y-b)=0$ ឬ $y'=-\dfrac{x-a}{y-b}$ ឬ $y'(x_0)=-\dfrac{x_0-a}{y_0-b}$




សមីការបន្ទាត់ប៉ះមានរាង $y=y'(x_0)(x-x_0)+y_0$

$$y=-\frac{x_0-a}{y_0-b}(x-x_0)+y_0$$

$$(y_0-b)(y-y_0)=-(x_0-a)(x-x_0)$$

$$(x_0-a)(x-a+a-x_0)+(y_0-b)(y-b+b-y_0)=0$$

$$(x_0-a)(x-a)-(x_0-a)^2+(y_0-b)(y-b)-(y_0-b)^2=0$$

$$(x_0-a)(x-a)+(y_0-b)(y-b)=(x_0-a)^2+(y_0-b)^2$$

ដោយ $P(x_0\ ,\ y_0)$ ជាចំណុចនៅលើរង្វង់ នោះវាផ្ទៀងផ្ទាត់សមីការ $(x_0-a)^2+(y_0-b)^2=r^2$

ដូចនេះ សមីការបន្ទាត់ប៉ះរង្វង់អាចសរសេរ $\boxed{(x_0-a)(x-a)+(y_0-b)(y-b)=r^2}$ ។

## 24. ប្រវែងធ្នូនៃរង្វង់

> រង្វង់មួយមានប្រវែងកាំ $r$ និងមានមុំផ្ចិត $\theta$ គិតជារ៉ាដ្យង់ ស្កាត់ដោយធ្នូមានប្រវែង $S$ នោះគេបាន $\boxed{S = r\theta}$ ។




☑ **សម្រាយបញ្ជាក់**

យើងមានរង្វង់កាំ $r$ និងមានមុំផ្ចិត $\theta$ និង $\theta_1$ ដែលវាស់ជារ៉ាដ្យង់

ហើយមុំផ្ចិតទាំងពីរស្កាត់ដោយធ្នូ $S$ និង $S_1$ រៀងគ្នា (ដូចរូប) ។

តាមលក្ខណៈធរណីមាត្រ យើងបាន $\dfrac{\theta}{\theta_1} = \dfrac{S}{S_1}$




ឧបមាថា $\theta_1 = 1$ រ៉ាដ្យង់ នោះ $S_1 = r$

នាំឱ្យ $\dfrac{\theta}{1} = \dfrac{S}{r}$ ទាញបាន $S = r\theta$

ដូចនេះ ចំពោះរង្វង់មួយមានប្រវែងកាំ $r$ និងមានមុំផ្ចិត $\theta$ គិតជារ៉ាដ្យង់

ស្កាត់ដោយធ្នូបានប្រវែង $S$ ដែល $\boxed{S = r\theta}$ ។

## 25. ផ្ទៃចម្រៀកថាស

> ផ្ទៃក្រឡាចម្រៀកថាស $A$ នៃរង្វង់ដែលមានកាំ $r$ និងមាន មុំផ្ចិត $\theta$ គិតជារ៉ាដ្យង់ កំណត់ដោយ $\boxed{A = \frac{1}{2}r^2\theta}$ ។




☑ **សម្រាយបញ្ជាក់**

យើងមានរង្វង់ផ្ចិត $O$ និងកាំ $r$ ហើយ $\theta$ ជាមុំផ្ចិតគិតជារ៉ាដ្យង់

យើងនឹងកំណត់ផ្ទៃចម្រៀកថាស $A$ ដែលអាស្រ័យនឹងមុំផ្ចិត $\theta$

ឧបមាថារង្វង់មានកាំប្រវែង $r$ ហើយ $\theta_1$ និង $\theta$ ជាមុំផ្ចិតពីរ

ដែលគិតជារ៉ាដ្យង់ និងកំណត់បានផ្ទៃចម្រៀកថាស $A_1$ និង $A$ រៀងគ្នា




តាមលក្ខណៈ ធរណីមាត្រៈ $\dfrac{\theta}{\theta_1} = \dfrac{A}{A_1}$

យក $\theta_1 = 2\pi$ នោះ $A_1 = \pi r^2$

គេបាន $\dfrac{\theta}{2\pi} = \dfrac{A}{\pi r^2}$ ទាញបាន $A = \dfrac{1}{2}r^2\theta$

ដូចនេះ ផ្ទៃចម្រៀកថាស $A$ នៃរង្វង់កាំ $r$ មានមុំផ្ចិត $\theta\,(rd)$

កំណត់ដោយ $\boxed{A = \frac{1}{2}r^2\theta}$ ។



www.facebook.com/7khmer
fb : Entertainment And Knowledge

**លំហាត់អនុវត្ត**

1. គេឱ្យបន្ទាត់ $EF$ ប៉ះរង្វង់ $O$ ត្រង់ចំណុច $C$ ។ អង្កត់ធ្នូ $AB$ ស្របនឹងបន្ទាត់ $EF$ ។ ស្រាយបញ្ជាក់ថា $\overset{\frown}{AC} = \overset{\frown}{BC}$ ។
2. គេឱ្យចំណុច $A$ នៅក្រៅរង្វង់ $O$ ។ បន្ទាត់ពីរ $AB$ និង $AC$ ប៉ះរង្វង់រៀងគ្នាត្រង់ $B$ និង $C$ ។ ស្រាយបញ្ជាក់ថា

   ក. $AB = AC$ ។

   ខ. $[AO)$ ជាកន្លះបន្ទាត់ពុះមុំ $\angle BAC$ និង $\angle BOC$ ។
3. ស្រាយបញ្ជាក់ថា ក្នុងចតុកោណចារឹកក្រៅរង្វង់មួយ មានផលបូករង្វាស់ជ្រុងឈមស្មើគ្នា ។
4. គេឱ្យ $\angle ABC$ ចារឹកក្នុងរង្វង់ផ្ចិត $O$ ដែល $O \in [BC]$ ។ បង្ហាញថា $\angle ABC = \frac{1}{2}\overset{\frown}{AC}$ ។
5. ស្រាយបញ្ជាក់ ចតុកោណចារឹកក្នុងរង្វង់មួយ ផលបូករង្វាស់មុំឈមស្មើនឹង $180°$ ។
6. ស្រាយបញ្ជាក់ថា មុំក្នុងរង្វង់មានរង្វាស់ស្មើនឹង កន្លះផលបូក រង្វាស់ធ្នូស្កាត់ដោយជ្រុងមុំ និងបន្លាយនៃជ្រុងនោះ ។
7. ស្រាយបញ្ជាក់ថា មុំក្រៅរង្វង់មានរង្វាស់ស្មើនឹង កន្លះផលដក រង្វាស់ធ្នូស្កាត់ស្កាត់ដោយជ្រុងនៃមុំនេះ ។
8. ក. បង្ហាញថា សមីការបន្ទាត់ប៉ះរង្វង់ $x^2 + y^2 = r^2$ ត្រង់ចំណុច $P(x_0\ ,\ y_0)$ មានរាង ៖ $x_0x + y_0y = r^2$ ។

   ខ. បង្ហាញថា សមីការបន្ទាត់ប៉ះរង្វង់ $(x-a)^2 + (y-b)^2 = r^2$ ត្រង់ចំណុច $P(x_0\ ,\ y_0)$ មានរាង ៖

   $(x_0 - a)(x-a) + (y_0 - b)(y-b) = r^2$ ។
9. បង្ហាញថា ថាសដែលមានកាំ $R$ មានក្រឡាផ្ទៃកំណត់ដោយ $S = \pi R^2$ ។